មគ្គបដិបត្តិ

អានាបានសតិ ២២០ ញាណ

បិដក អដ្ឋកថា

ថាលី-ខ្មែរ

ភាគ ១

រួបរួមដោយ

ភិក្ខុ ហានវរោ ស្វូស ប៊ុនថន

ផ្សាយចេញពី

ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា

សម្រាប់ធម្មទាន

ព.ស.២៥៦៩ គ.ស.២០២៥

មគ្គបដិបត្តិ

អានាបានសូត្រ ២២០ ញាណ

បិដក អដ្ឋកថា

ចាលី-ខ្មែរ

ភាគ ១

រួបរួមដោយ

ភិក្ខុ ហានវរោ ស្វូស ប៊ុនថន

ផ្សាយចេញពី

ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា

សម្រាប់ធម្មទាន

ព.ស.២៥៦៩ គ.ស.២០២៥

ឈ្មោះសៀវភៅ **មគ្គបដិបត្តិអានាបានសូត្រ ២២0 ញាណ តាគ ១**

ត្រួតពិនិត្យដោយ *ព្រះសាសនមុនី មហាកម្មដ្ឋានាចរិយ*

ហ៊ឹម ប៊ុនធឿន ធម្មត្ថេរោ

រៀបរៀងដោយ *ភិក្ខុ ឋានវរោ* **សួស ប៊ុនថន**

រចនាក្របដោយ *មហាឧបាសក* **ធឿន ពិសិដ្ឋ**

ឧបត្ថម្ភដោយ *អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍*

សុខ អ៊ឹម *ព្រមទាំងបុត្រ* **ភូ ឆៃគឿង** *និងភរិយា ព្រមទាំងចៅ*

បោះពុម្ពលើកទី១ *ចំនួន...*

បោះពុម្ពដោយ ...

ថ្ងៃបោះពុម្ព ...

ទីកន្លែងធ្វើ *ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា*

ភូមិភ្នំ ឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល

ការផ្សាយរបស់ *ពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា*

ទស្សនកថា

ខ្ញុំព្រះករុណា អាត្មាភាព បានពិនិត្យនូវរាល់ខ្លឹមសារព្រះធម៌សៀវភៅ **មគ្គបដិបត្តិ អានាបានស្សតិកម្មដ្ឋាន**នេះ ដោយយកចិត្តទុកដាក់បំផុត ទៅលើអត្ថន័យ និងពាក្យពេចន៍នៃព្រះធម៌ ដែលបានដកស្រង់ចេញពី **ព្រះ-ត្រៃបិដក អដ្ឋកថា** និង **កម្ពីរវិសុទ្ធិមគ្គ** បានឃើញថា សៀវភៅនេះពិតជាមានសារៈប្រយោជន៍ច្រើនណាស់ សម្រាប់ពុទ្ធសាសនិកជន អ្នកសិក្សាប្រតិបត្តិ និងស្រាវជ្រាវ ស្វែងយល់ព្រះធម៌ របស់ព្រះសម្មាសម្ពុទ្ធ ឱ្យកាន់តែស៊ីជម្រៅទៅលើអត្ថ និងព្យញ្ជនៈ និងរបៀបកិច្ចចម្រើនប្រតិបត្តិ ឱ្យកាន់តែយល់ជាក់ច្បាស់ត្រឹមត្រូវល្អ ងាយស្រួលយកទៅអនុវត្តប្រតិបត្តិ ធាប់បានសម្រេចគុណធម៌ពិតប្រាកដ ។

អានាបានស្សតិ ជាគោលបដិបត្តិដ៏ឧត្តម ល្អិតផ្លូវផង់មួយចំណែក ក្នុងសតិប្បដ្ឋាន ដែលជាផ្លូវមួលតែមួយនាំសត្វឱ្យស្អាតបរិសុទ្ធ រួចចាកសេចក្តីទុក្ខទាំងពួងបាន ។

ខ្ញុំព្រះករុណា អាត្មាភាព ពិតជាមានបីតិសោមនស្សរីករាយដ៏ក្រៃលែងចំពោះការខិតខំប្រឹងប្រែង ចងក្រង រៀបចំ សៀវភៅដ៏មានតម្លៃនេះឡើង គឺជាការបំពេញបន្ថែម នូវបញ្ញាញាណមួយកម្រិតទៀត ដើម្បីជំនួយដល់សតិបញ្ញាដល់ពុទ្ធបរិស័ទទូទៅគ្រប់រូប ឱ្យបានស្គាល់តម្លៃនៃសច្ចធម៌ដ៏បរិសុទ្ធ របស់ព្រះសម្មាសម្ពុទ្ធ ដែលបានត្រាស់ដឹង ពិតជាមានប្រយោជន៍សេចក្តីសុខ សេចក្តីចម្រើន ដល់ទេវតា និងមនុស្សទាំងឡាយពិតមែន ។

សូមឱ្យធម្មទាន ដែលមានរសព្រះធម៌ដ៏ត្រជាក់ក្សេមចាកទុក្ខ ដែលកើតឡើងពីការចម្រើន ព្រះអានាបានស្សតិកម្មដ្ឋាននេះ បានផ្សព្វផ្សាយជ្រាបក្នុងដួងចិត្តសព្វសត្វគ្រប់គ្នាទាំងអស់កុំបីអាក់ខានឡើយ ។

សូមឱ្យព្រះពុទ្ធសាសនា ផ្សាយទូទៅពេញសកលលោក ។ សូមឱ្យលោកទាំងមូល បានទទួលសុខសន្តិភាព និងការរីកចម្រើន អស់កាលជាយូរអង្វែងតរៀងទៅ ។

ថ្ងៃចន្ទ ២កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ពុទ្ធមណ្ឌល ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៥

ព្រះសាសនមុនី ហ៊ឹម ប៊ុនធឿន ធម្មត្ថេរោ

អារម្ភកថា

ឥមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វីរិយានមស្ការ ថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

មុនិន្ទវទនម្ភោជ កព្ភសម្ភវសុន្ទរី
សរណំ ចាណិនំ ភណី មយ្ហំ បីណយតំ មនំ ។

ព្រះសទ្ធម្មដ៏ល្អស្អាត កើតអំពីត្របកនៃផ្កាឈូក ពោលគឺព្រះឱសរបស់ព្រះមុនិន្ទ ជាទីពឹងនៃសព្វសត្វទាំងឡាយ សូមញុំាងចិត្តរបស់ខ្ញុំព្រះអង្គឲ្យសប្បាយរីករាយ ។

ខ្ញុំព្រះករុណាអាត្មាភាព សូមរំលឹកនឹកដល់ឧបការគុណនៃបុគ្គលទាំងឡាយមាន ព្រះអង្គគ្រូ លោកគ្រូគ្រប់ព្រះអង្គគ្រប់រូប និងគុណព្រះមហាថេរៈ ព្រះថេរៈ គុណមាតាបិតានិងគុណសព្រហ្មចារីទាំងឡាយក្នុងសេចក្តីល្អដែលលោកបានធ្វើហើយចំពោះខ្លួនខ្ញុំព្រះករុណាអាត្មាភាព ។ ដោយអានុភាពនៃកិរិយានមស្ការ និងការរំលឹកនឹកគុណនេះ **សព្វអន្តរាយាបិ វិនស្សន្តុ** *សេចក្តីអន្តរាយទាំងពួងចូរវិនាសបាត់ទៅ កុំបៀតបៀនរាំងរាំងក្នុងការរួបរួមធ្វើសៀវភៅនេះឡើយ* **សព្វសម្ប្បត្តិ មយ្ហំ សមិជ្ឈន្តុ** *សេចក្តីត្រិះរិះគ្រប់យ៉ាងរបស់ខ្ញុំចូរសម្រេចដោយល្អ ។*

សៀវភៅដែលព្រះគុណម្ចាស់ និងញាតិញោមកំពុងតែកាន់ក្នុងព្រះហស្ត និងក្នុងដៃនេះ ជាការរួបរួមឡើង ដោយអាស្រ័យបានសិក្សាជាមួយព្រះអាចារ្យ **បញ្ញាធរោ មហាណាម៉ិន** *និងគ្រូអាចារ្យ* **សុតី ថុមថង** *ក្នុងថ្ងៃទី ១ ពេច*

ខែចេត្រ ឆ្នាំកុរ ព.ស. ២៥៦២, ត្រូវនឹងថ្ងៃទី២០ ខែមេសា គ.ស. ២០១៩ មកដល់ថ្ងៃទី ១កោច ខែជេស្ឋ ឆ្នាំខាល ព.ស. ២៥៦៦, ត្រូវនឹងថ្ងៃទី ១៥ ខែមិថុនា គ.ស. ២០២២ ។ ហើយនៅថ្ងៃទី១១កោច ខែជេស្ឋ ឆ្នាំខាល ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា គ.ស. ២០២២ និងមកដល់ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០២៦ដែល រូបខ្ញុំព្រះករុណាអាត្មាភាព បានសេចក្តីអនុគ្រោះអំពីព្រះអង្គគ្រូសាសនមុនី មហាកម្មដ្ឋានាចរិយ **ហ៊ឹម ប៊ុនធឿន ធម្មត្តេរោ** បានមករស់នៅក្នុងពុទ្ធមណ្ឌលវិបស្សនាធុរៈ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបានសិក្សានូវកម្មដ្ឋានបន្តទៀតក្នុងសម្នាក់របស់ព្រះអង្គគ្រូ ។ ក្នុងឱកាសគង់នៅពុទ្ធមណ្ឌលវិបស្សនាធុរៈនេះឯង ដែលខ្ញុំបានសិក្សាបន្តទៀត និងបានធ្វើសៀវភៅនេះឡើង ព្រោះថាកាលគង់នៅក្នុងសម្នាក់របស់ព្រះអាចារ្យ **បញ្ញាធរោ មហាឈាប៊ុន** នាប្រទេសថៃនោះ ឯកសារទាំងអស់នោះនៅជាសំណៅសរសេរដៃនៅឡើយ ទើបមកដល់ពុទ្ធមណ្ឌលវិបស្សនាធុរៈទើបបានចម្លងចូលក្នុងកុំព្យូទ័រ ។ ហើយក្នុងការរួបរួមនេះ ខ្ញុំព្រះករុណាអាត្មាភាពប្រារព្ធក្នុងបុព្វហេតុបីយ៉ាងគឺ ៖

១. ខ្ញុំព្រះករុណាអាត្មាភាព មើលឃើញថា សៀវភៅដែលបរិយាយលម្អិតអំពីកិច្ចបដិបត្តិ ពុំសូវមានច្រើន ពិសេសសំដៅវិធីសាស្ត្រនៃការចម្រើនកម្មដ្ឋានឱ្យបានត្រឹមត្រូវទៅតាមពុទ្ធឱវាទរបស់ព្រះសម្មាសម្ពុទ្ធ ។

២. ខ្ញុំព្រះករុណាអាត្មាភាព មើលឃើញថា ការបដិបត្តិសមាធិ ចាប់ផ្តើមមានការចាប់អារម្មណ៍ច្រើនឡើងៗអំពីសម្នាក់ពុទ្ធបរិស័ទ និងត្រូវការរបៀបបដិបត្តិឱ្យត្រឹមត្រូវមួយតាមក្បួនច្បាប់គម្ពីរ និងចៀសវាងការបដិបត្តិខុស ។

៣. ខ្ញុំព្រះករុណាអាត្មាភាព មើលឃើញថា ឯកសារជាភាសាបរទេសមានភាសាថៃ ភូមា ជាដើម គេបានស្រាវជ្រាវ និងចងក្រងទុកមានច្រើន ដើម្បីសម្រួលដល់ការយល់ត្រូវក្នុងផ្លូវបដិបត្តិ តែជាភាសាខ្មែរមិនទាន់សម្បូរទេ ។

ដោយហេតុយ៉ាងនេះ អាត្មាភាពចាប់ផ្តើមចំណាយពេលវេលាដើម្បី

រួបរួមឯកសារនេះទុកទៅតាមគម្ពីរ ព្រះត្រៃបិដក និងអដ្ឋកថា ព្រមទាំងបកប្រែពីភាសាបរទេសមកបន្ថែមទៀត ដើម្បីសង្កាយសេចក្តីឱ្យកាន់តែច្បាស់លាស់ក្នុងកិច្ចបដិបត្តិសមាធិនេះ ។

*គោលបំណងក្នុងការរៀបរៀង សៀវភៅនេះ គឺដើម្បីរក្សា នូវ **សម្មាបដិបទា** ក្នុងការអប់រំចម្រើននូវសមាធិភាវនា ។ ម្យ៉ាងវិញទៀត ដើម្បីផ្តល់កម្លាំងចិត្តដល់ព្រះយោគាវចរគ្រប់រូប ជាអ្នកត្រេកអរក្នុងវិវេកធម៌ មានព្រៃស្ងាត់ទៀបគល់ឈើ និងផ្ទះស្ងាត់ជាដើម ។ ម្យ៉ាងវិញទៀតដើម្បីថែរក្សា នូវត្រៃសិក្ខា ពោលគឺ សីល សមាធិ និងបញ្ញា ដូចមានក្នុងគម្ពីរវិសុទ្ធិមគ្គបានសម្តែងទុកមកថា **លម្ពបទដើម** ព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសសម្តែងដោយ សីល, **លម្ពបទកណ្តាល** ទ្រង់ប្រកាសសម្តែងដោយ សមាធិ, និង**លម្ពបទចុង** ទ្រង់ប្រកាសសម្តែងដោយ បញ្ញា ។ ចំណុចសំខាន់នៃសៀវភៅអានាបានស្សតិកម្មដ្ឋាន នេះមានការបំភ្លឺជុំវិញ នៃការអប់រំអានាបានស្សតិ ដើម្បីជៀសវាងការបដិបត្តិ ចូលទៅកាន់ **មិច្ឆាសមាធិ** ដែលជាសត្រូវដល់ **សម្មាសមាធិ** ហើយក្នុងសៀវភៅនេះមានគោលអាងពីភាសាបាលី ចេញពីព្រះត្រៃបិដក និងអដ្ឋកថា ។*

*ខ្ញុំព្រះករុណាអាត្មាភាព សូមបូជាសៀវភៅភាគទី ១ នេះដល់ព្រះពុទ្ធ-សាសនា ហើយសូមប្តូរយកនូវព្រះនិព្វានតែម្យ៉ាង ហើយសង្ឃឹមថា សៀវភៅនេះនឹងបានជាប្រទីប ក្នុងការធ្វេីបញ្ចាំង **នូវសម្មាបដិបទា** ដល់ព្រះយោគាវចរគ្រប់ៗរូប ដែលជាអ្នកត្រេកអរក្នុងត្រៃសិក្ខា និងបានជាប្រយោជន៍ដល់មហាជនជាច្រើនគ្នាផងដែរ ។ ដោយអំណាចនៃសេចក្តីព្យាយាមរបស់អាត្មាភាព សូមឱ្យយើងខ្ញុំទាំងឡាយ និងសព្វសត្វទាំងអស់ បាននូវ សេចក្តីចម្រើន បានជាប្រយោជន៍ បាននូវសេចក្តីសុខ ជារៀងរហូត និងបានជាបច្ច័យក្នុងការរួចផុតចាកទុក្ខ ពោលគឺបានសម្បត្តិព្រះនិព្វានតែម្យ៉ាងគ្រប់ៗគ្នានៅឯខាងមុខនេះផង សូមសព្វសត្វអនុមោទនាបុណ្យ ។*

រតនត្តយតេជេន កម្ពោជរដ្ឋវាសិនោ

ចុឌ្ឍឹ ចិរូឡ្ហឹបប្បោន្តុ សន្តិភាវញ្ច នាញ្ញថា ។

ដោយតេជះនៃព្រះរតនៈត្រៃ សូមឱ្យប្រជាជនទាំងឡាយអ្នករស់នៅក្នុងកម្ពុជរដ្ឋដល់នូវការលូតលាស់រីកចម្រើន និងសន្តិភាព កុំបីឃ្ជៀងឃ្ជាតទៅជាបការៈដទៃឡើយ ។

ពុទ្ធមណ្ឌលវិបស្សនាធុរៈនៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១២រោច ខែដេស្ឋ ឆ្នាំម្សាញ់ ព.ស.២៥៦៩

ត្រូវនឹងថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០២៥ ។

ភិក្ខុ ឃានវរោ សួស ប៊ុនថន

ទាចារអ្នករួបរួម

*ការរៀបរៀងឡើងនូវសៀវភៅ "**អានាបានសូត្រ ២២០ ញាណ**" នេះ ខ្ញុំ ព្រះករុណា បានរៀបរៀងទៅតាមព្រះបាលី នៃព្រះត្រៃបិដក ហើយរួមជាមួយ និងអដ្ឋកថា ដែលមានសេចក្តីប្រែជា ខេមរភាសា និងរៀបរៀងទៅតាមលំដាប់ នៃមាតិកានីមួយៗ យ៉ាងផ្ចិតផ្ចង់បំផុត មិនឱ្យឃ្លៀងឃ្លាតពីច្បាប់ដើមឡើយ ដើម្បីបានជាប្រយោជន៍ដល់កុលបុត្រជាអ្នកជ្រះថ្លា ក្នុងព្រះរតនៈត្រ័យ និង ជាពិសេសដើម្បីជាប្រយោជន៍ ដល់ការសិក្សារបស់ព្រះយោគាវចរគ្រប់ៗរូប ងាយស្រួលក្នុងការសិក្សារៀនសូត្រ និងបដិបត្តិឱ្យបានត្រឹមត្រូវទៅតាមព្រះធម៌ ព្រះវិន័យរបស់ព្រះសម្មាសម្ពុទ្ធនៃយើង។ សៀវភៅនេះបានលម្អិតច្បាស់លាស់ អំពីកម្មដ្ឋាននិងពន្យល់អត្ថសេចក្តីយ៉ាងច្បាស់លាស់ទៅតាមព្រះពុទ្ធដីកា ដើម្បី ងាយយល់ក្នុងការអាន យោគីអ្នកបដិបត្តិគប្បីយល់អំពីលំដាប់នៃការរួបរួមនេះ ដោយផ្តើមអំពីពុទ្ធដីកាជាគោល។*

*សៀវភៅដែលឈ្មោះថា **មគ្គបដិបត្តិអានាចានសូត្រ២២០ញាញ** នេះ មកពីពាក្យថា **មគ្គ** ប្រែថា ផ្លូវ **បដិបត្តិ** ប្រែថា ប្រព្រឹត្តិតាម **អាន** ប្រែថា ខ្យល់ ដង្ហើមចូល **អចាន** ប្រែថា ខ្យល់ដង្ហើមចេញ **សតិ** ប្រែថា កំណត់ដឹង **២២០ ញាណ** ជាការអធិប្បាយបន្ថែមរបស់ព្រះសារីបុត្តថេរ ដែលមាននៅក្នុងបិដក លេខ ៧០ [៦៩] ព្រះថេរៈលោកបានចែកមាន ១១ លំដាប់ ស្មើនឹង២២០ញាណ ដែលមានផ្នែកសមថ និងវិបស្សនា ផ្នែកលោកិយ និងលោកុត្តរ ហើយមានការ អធិប្បាយទៅតាមលេខឃ្លាបរបស់បិដក និង**អដ្ឋកថាសទ្ធម្មបកាសិនី** ទៅតាម លំដាប់ ហើយមានលេខឃ្លាបរបស់ធដ្ឋសង្គាយនាលើកទី ៦ផង ដើម្បី ងាយស្រួលដល់អ្នកសិក្សាចង់ដឹងនូវអត្ថសេចក្តីនីមួយៗឱ្យបានជាក់ច្បាស់ និង ទៅតាមលំដាប់នីមួយៗ ទាំងនេះធ្វើឱ្យព្រះធម៌រឹងរឹតតែមានឱជារស ព្រោះអ្នក សិក្សាបានអានទៅតាមលំដាប់ មានឱកាសសង្កេតចាប់យកសេចក្តីនៃព្រះធម៌ បាន ការអធិប្បាយក្នុងភាគទី ១ នេះ ជាការអធិប្បាយផ្នែកខាងដើម ដែលធ្វើឱ្យ ព្រះយោគីអ្នកសិក្សាពេញចិត្តនូវអត្ថសេចក្តី រួចហើយបន្តទៅសិក្សាភាគទី ២*

ទៀត ជាការពិតណាស់អ្នកបដិបត្តិត្រូវតែសិក្សានូវព្រះបរិយត្តិផ្នែកបដិបត្តិនេះ ឱ្យបានត្រឹមត្រូវនូវសេចក្តីនីមួយៗឱ្យបានល្អជាមុនសិន ទើបការបដិបត្តិនោះបានត្រឹមត្រូវទៅតាមធម៌ព្រះសម្មាសម្ពុទ្ធនៃយើង កាលដែលបដិបត្តិត្រឹមត្រូវនេះ ហើយដែលជាហេតុធ្វើឱ្យដល់ព្រះនិព្វានបាន ដូច្នេះអ្នកបដិបត្តិត្រូវតែសិក្សានូវក្បួនច្បាប់របស់ព្រះពុទ្ធសាសនារបស់យើងនេះឱ្យបានគ្រប់ៗគ្នា ចៀសវាងទៅបដិបត្តខុស។ មូលហេតុដែលអាត្មាភាពរៀបឱ្យមានជាភាសាបាលី ប្រៃ បែបនេះ ព្រោះថា កាលបើរៀបឱ្យមានតែភាសាប្រៃតែម្យ៉ាងនោះ ប្រាកដណាស់ថានឹងមានអ្នកអាន អ្នកបដិបត្តិមានសេចក្តីសង្ស័យនឹងចង់បាននូវភាសាបាលីមកមើលផង ហើយម្យ៉ាងទៀតភាសាប្រៃសុទ្ធនោះ មានលោកអ្នកប្រាជ្ញបានប្រែរួចមកហើយ ដូច្នេះក្នុងការតម្រូវសម្រាប់អ្នកសិក្សាស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅផង ទើបតម្រូវឱ្យមានទាំងភាសាបាលី ប្រៃ សម្រាប់បំពេញចំណេះដឹងបន្ថែមទៀតជាពិសេសធ្វើឱ្យការបដិបត្តិរបស់យើងបានត្រឹមត្រូវផងដែរ។

ដោយសេចក្តីខិតខំព្យាយាមរបស់ខ្ញុំព្រះករុណាអាត្មាភាព ដែលមានហើយនេះ **អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ**

ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ ។

ធម៌គឺពរទាំងឡាយ ៤ ប្រការ គឺអាយុ ១ ពណ៌សម្បុរកាយ ១ សេចក្តីសុខ ១ កម្លាំង ១ រមែងចម្រើនអស់កាលជានិច្ច ដល់អ្នកដែលមានសេចក្តីឱនកាយថ្វាយបង្គំដល់ព្រះរតនត្រ័យជាប្រក្រតី និងអ្នកដែលមានសេចក្តីគោរពកោតក្រែង ដល់បុគ្គលដែលជាអ្នកមានសេចក្តីចម្រើនដោយគុណ មានសីលគុណជាដើម ឬដែលចម្រើនដោយវ័យ គឺចាស់ព្រឹទ្ធាចារ្យ កើតមានដល់សព្វសត្វទាំងឡាយតាំងពីបច្ចុប្បន្ននេះរហូតដល់ព្រះនិព្វាន សូមអនុមោទនា។

ភិក្ខុ ហានវរោ សួស ប៊ុនថន

បដិការគុណកថា

១. ព្រះសាសនមុនី មហាកម្មដ្ឋានាចរិយ **ហ៊ឹម ប៊ុនធឿន ធម្មត្តេរោ** *ព្រះអង្គគ្រូជាអ្នកបង្ហាត់បង្រៀននូវកម្មដ្ឋាន ជួយត្រួតពិនិត្យសៀវភៅ និងជាអ្នកចង្អុលបង្ហាញប្រាប់នូវអត្ថសេចក្តី*

២. ព្រះអាចារ្យ **បញ្ញាធរោ មហាណាប៊ុន** *ជាអ្នកបង្ហាត់បង្រៀននូវកម្មដ្ឋាន និងប្រាប់ពន្យល់នូវអត្ថសេចក្តី ។*

៣. គ្រូអាចារ្យ **សុគី ថុមថង** *ជាអ្នកបង្រៀននូវកម្មដ្ឋានប្រាប់ពន្យល់នូវអត្ថសេចក្តីដោយភាសាបាលីប្រៃ ។*

៤. ព្រះភិក្ខុ សាវានន្ទោ **ឡាំ សុផាត** *ជួយពិនិត្យកែអក្ខរាវិរុទ្ធ*

៥. សាមណេរ សុវណ្ណជោតោ **ហាម ស៊ុយ** *ជួយពិនិត្យកែអក្ខរាវិរុទ្ធ និងកែសម្រួលសៀវភៅ*

៦. ឧបាសក **ធឿន ពិសិដ្ឋ** *រចនាក្រប និងកែសម្រួលសៀវភៅ*

៧. មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក **វ៉ែត ការនីណាដ្យ** *ជួយពិនិត្យកែអក្ខរាវិរុទ្ធ ។*

ឧទ្ទិសកថា

ដោយអំណាចវីរិយភាព ដែលខ្ញុំព្រះករុណាអាត្មាភាព និងក្រុមការងារគណៈកម្មការពុទ្ធមណ្ឌលវិបស្សនាធុរៈទាំងអស់ ដែលបានប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការរៀបចំបោះពុម្ពសៀវភៅ **មគ្គបដិបត្តិអានាបានស្សតិ ២២០ ញ្ញាណ** *ដែលជា* ***ក្បួនច្បាប់របស់ព្រះពុទ្ធសាសនាថេរវាទ*** *។*

សៀវភៅនេះមានគុណតម្លៃយ៉ាងក្រៃលែងណាស់ មិនអាចកាត់ថ្លៃបានហើយបានរៀបចំបោះពុម្ពទុកដាក់សម្រាប់ជាធម្មទាន ។ ដោយសទ្ធាទឹកចិត្តជ្រះថ្លាប្រកបដោយ មហាកុសល ដ៏ថ្លៃថ្លាប្រសើរខ្ពង់ខ្ពស់ទាំងអស់នេះ! ខ្ញុំព្រះករុណា សូមថ្វាយប្រគេន នូវមហាកុសលនេះឧទ្ទិសជូនចំពោះ **សម្តេចព្រះមហាសង្ឃរាជ សម្តេចព្រះសង្ឃនាយក សម្តេចព្រះមន្ត្រីសង្ឃ** *គ្រប់ឋានានុក្រម ជាពិសេស* **សម្តេចមហាសង្ឃរាជ ដោតញ្ញាណោ ជួន ណាត** *និងក្រុមជំនុំបកប្រែគម្ពីរព្រះត្រៃបិដកគ្រប់អង្គ/នាក់ និងប្រគេនចំពោះព្រះគ្រូឧបជ្ឈាយាចារ្យ កម្មដ្ឋានគ្រប់ៗព្រះអង្គ មានព្រះអង្គគ្រូ* **ព្រះធម្មវិបស្សនា កេតុធម្មោ សំ ប៊ុនធឿន** *ជាដើម ។*

ជាពិសេសជូនចំពោះ ញោមប្រុស ឧបាសក **ឆៀង ផុន** *និង ញោមស្រី ឧបាសិកា* **រស់ ស្រឿន** *ព្រមទាំងពពួកញាតិ និងអ្នកមានគុណូបការៈទាំងអស់ក្នុងសង្សារវដ្ត ។*

សូមអនុមោទនា ផលានិសង្សនៃធម្មទាននេះ ហើយទទួលបានបរមសុខក្នុងសុគតិភព ជាកិយ្យោភាពតរៀងទៅ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអនុមោទនា សាធុ សាធុ សាធុ!

ថ្ងៃពុធ ១១រោច ខែស្រាពណ៌ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ពុទ្ធមណ្ឌល ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៥

តិក្ខ ឋានចរោ សួស ប៊ុនថន

មាតិកា

ទស្សនកថា III

អារម្ភកថា V

វាចាអ្នកជួបជួម IX

បដិការគុណកថា XI

ឧទ្ទិសកថា XII

ឧបត្ថម្ភកថា XIII

មាតិកា XIV

មគ្គបដិបត្តិអនាបានសូត្រ ២២0 ញាណ ๑

សមថកម្មដ្ឋាន ៤0 ..... ๒

ទី ๑. កសិណ ๑0 ..... ๒

ទី ๒. អសុភ ๑0 ..... ๒

ទី ๓. អនុស្សតិ ๑0 ..... ๓

ទី ๔. ព្រហ្មវិហារធម៌ ๔ ..... ๓

ទី ๕. អរូបជ្ឈាន ๔ ..... ๔

ទី ๖. សញ្ញា ๑ ..... ๕

ទី ๗. វវត្ថាន ๑ ..... ๕

វិសុទ្ធិទាំង ๗ យ៉ាង ๗

សោឡសញ្ញាណ ๑๖ ឬ វិបស្សនាញាណ ๑๖ ..... ๘

បរិញ្ញា ៣ ..... ๑๑

ពោធិបក្ខិយធម៌ ៣៧ ..... ๑๑

๑. សតិប្បដ្ឋាន ៤ ..... ๑๒

๒. សម្មប្បធាន ៤ ..... ๑๒

๓. ឥទ្ធិបាទ ៤ ..... ๑๓

๔. ឥន្ទ្រិយ ៥ ..... ๑๓

๕. ពល ៥ ..... ๑๔

๖. ពោជ្ឈង្គ ៧ ..... ๑๔

๗. អរិយមគ្គអង្គ ៨ ..... ๑๕

អដ្ឋមំ អានាបានស្សតិសុត្តំ ๑๗

អានាបានស្សតិសូត្រទី ៨ (ម. ๒๖) ๑๗

๑. កាយានុបស្សនា ๒๗

๒. វេទនានុបស្សនា ๒๘

๓. ចិត្តានុបស្សនា ๒๙

๔.ធម្មានុបស្សនា ๓๐

អានាបានស្សតិញ្ចាំង សតិប្បដ្ឋានទាំង ๔ ឲ្យពេញបរិបូរណ៌ ๓๒

๑. កាយានុបស្សនាសតិប្បដ្ឋាន ๓๒

๒. វេទនានុបស្សនាសតិប្បដ្ឋាន ๓๔

๓. ចិត្តានុបស្សនាសតិប្បដ្ឋាន ๓๖

๔. ធម្មានុបស្សនាសតិប្បដ្ឋាន ๓๘

សតិប្បដ្ឋានទាំង ៤ ញុំាងពោជ្ឈង្គ ៧ ឲ្យពេញបរិបូរណ៌បាន ๘๑

ពួកកាយក្នុងកាយ ๘๑

ពួក វេទនា ចិត្ត និង ធម្ម ๘๖

ពោជ្ឈង្គទាំង ៧ ដែលបុគ្គលបានចម្រើនហើយ តើដូចម្តេច ? ๕๒

ព្រះសុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ (បិដក ๗๐) [๖๙] ... ๕๕

๑.មហាវគ្គ ๕๕

๓. អានាបានស្សតិកថា ๕๕

កថាពោលអំពីអានាបានស្សតិ ๒๒๐ ញ្ញាណ

๑. គណនវារ ๕๕

លំដាប់រាប់ញ្ញាណទាំង ๑๑ ញ្ញាណ ស្មើ ๒๒๐ ញ្ញាណ ๕๕

๑.ញ្ញាណទី ๑ ធ្វើឲ្យអន្តរាយ ๘ ញ្ញាណ ๕๗

និងញ្ញាណទី๒ មានឧបការ ๘ ញ្ញាណ ๕๗

អដ្ឋកថា សទ្ធម្មបកាសិនី ๕๙

๓. អានាបានស្សតិកថា ๖๐

កថាពោលអំពីអានាបានស្សតិ ๖๐

๑. គណនាវារវណ្ណនា ๖๐

ការពណ៌នាគណនាវារៈ ๖๐

๒. សោឡសញ្ញាណនិទ្ទេសោ ๖๙

ការសម្តែងនូវឯកត្តទាំង ១៦ (បិដក ៧០) [៧១] ៦៩
ដំណើរទៅកាន់ព្រះនិព្វាន ៧១
២. សោឡសញាណនិទ្ទេសវណ្ណនា (អដ្ឋកថា) ៧៧
៣. ឧបក្កិលេសញ្ញាណនិទ្ទេសោ ៨២
ញាណទី ៣ ឧបក្កិលេសទាំង ១៨ ញាណ (បិដក ៧០) [៧៣] ... ៨២
បឋមច្ឆក្កៈ ១ មាន ៦ ញាណ ៨២
គាថា សរុបឧបក្កិលេសទាំង ៦ ញាណ ៨៤
៣. អដ្ឋកថេសុ ឧបក្កិលេសញាណនិទ្ទេសវណ្ណនា ៨៥
ពណ៌នាឧបក្កិលេសញាណនិទ្ទេសក្នុងអដ្ឋកថា បឋមច្ឆក ទី ១ ..... ៨៥
ទុតិយច្ឆក្កៈ ២ មាន ៦ ញាណ (បិដក ៧0) [៧៤] ៩០
គាថាសរុបឧបក្កិលេសនៅក្នុង ទុតិយច្ឆកទី២ មាន ៦ញាណ ៩១
ទុតិយច្ឆក ទី ២ (អដ្ឋកថា) ៩៣
តតិយច្ឆក្កៈ ៣ មាន ៦ ញាណ (បិដក ៧0) ៩៥
តតិយច្ឆក្កទី ៣ (អដ្ឋកថា) ៩៧
សរុបឧបក្កិលេសទាំង ១៨ ញាណ (បិដក៧០) [៧៦] ១០០
គាថាសរុបសេចក្តី ១០៤
សរុបឧបក្កិលេសទាំង ១៨ ញាណ (អដ្ឋកថា) ១០៥
៤. តេរស ញោទានេ ញាណនិទ្ទេសោ ១០៨
ញាណទី ៤ ញោទានញាណទាំង ១៣ ញាណ (បិដក៧០) [៧៧] ... ១០៨
៤. ញោទានញាណនិទ្ទេសវណ្ណនា ១១១

ពណ៌នាវោទានញាណ ជាញាណលំដាប់ទី ៤ (អដ្ឋកថា) ១១១
អធិប្បាយនៃឈាន ទាំង ៤ ..... ១១៤
ឯកត្ត ដោយហេតុ ៤ យ៉ាង (អដ្ឋកថា)..... ១១៥
បឋមជ្ឈាន (បិដក៣០) [៧៩] ១២១
បឋមជ្ឈាន (អដ្ឋកថា)..... ១២១
បឋមជ្ឈានមានបដិបទាវិសុទ្ធិ ជាខាងដើម (បិដក ៣០) [៨០]... ១២៣
បឋមជ្ឈានមានបដិបទាវិសុទ្ធិ ជាខាងដើម (អដ្ឋកថា)..... ១២៤
បឋមជ្ឈាន មានការសម្ងឹងពិនិត្យ ជាកណ្តាល(បិដក ៣០)[៨១] ... ១២៥
បឋមជ្ឈាន មានការរសម្ងឹងពិនិត្យ ជាកណ្តាល (អដ្ឋកថា)..... ១២៧
បឋមជ្ឈាន មានការរីករាយព្រម ជាខាងចុង (បិដក ៣០) [៨២]... ១៣០
បឋមជ្ឈាន មានការរីករាយព្រម ជាខាងចុង (អដ្ឋកថា)..... ១៣២
ទុតិយជ្ឈាន (បិដក ៣០) [៨៣] ១៣៤
ទុតិយជ្ឈាន (អដ្ឋកថា)..... ១៣៦
តតិយជ្ឈាន (បិដក៣០) [៨៤] ១៣៦
ចតុត្ថជ្ឈាន (បិដក ៣០) [៨៥]..... ១៣៨
អរូបសមាបត្តិ ៤ (បិដក ៣០) [៨៦]..... ១៣៩
អនិច្ចានុបស្សនា (បិដក ៣០) [៨៧] ១៤០
អនិច្ចានុបស្សនា (អដ្ឋកថាក្នុងបិដក ៣០) [៨៧]..... ១៤២
អរហត្តមគ្គ (បិដក ៣០) [៨៨]..... ១៤៤
អរហត្តមគ្គ មានការសម្ងឹងពិនិត្យ ជាកណ្តាល (បិដក ៣០) [៨៩] ... ១៤៦

អរហត្តមគ្គ មានការរីករាយព្រម ជាខាងចុង (បិដក ៧០)[៩០]...១៤៧
ធម៌ ៣ យ៉ាងត្រូវដឹង (បិដក៧០) [៩១] ១៥០
ធម៌ ៣ យ៉ាងត្រូវដឹង (អដ្ឋកថា) ១៥០
ឧបមា និង ឧបមេយ្យ (បិដក ៧០) [៩២]..... ១៥២
ការឧបមា ១៥៣
ការឧបមេយ្យ..... ១៥៣
ការឧបមា និង ឧបមេយ្យ (អដ្ឋកថា) ១៥៦
ការឧបមា (អដ្ឋកថា) ១៥៨
ការឧបមេយ្យ (អដ្ឋកថា)..... ១៥៩
ការព្យាយាម (បិដក ៧០) [៩៣]..... ១៦១
ការព្យាយាម (អដ្ឋកថា)..... ១៦២
គាថាសរុប (បិដក៧០) [៩៤]..... ១៦៥
អធិប្បាយគាថា..... ១៦៥
គាថាសរុប (អដ្ឋកថា)..... ១៧០
សេចក្តីសូប់ដ៏ល្អ (បិដក ៧០) [៩៤] (ត)..... ១៨២
ពាក្យថា តាម គឺ តាមសភាវៈមាន ១០ យ៉ាងគឺ៖..... ១៨៥
សេចក្តីសូប់ដ៏ល្អ (អដ្ឋកថា) [៩៤] (ត)..... ១៨៧
ពាក្យថា តាម គឺតាមសភាវ ១០ យ៉ាង (អដ្ឋកថា ត)..... ១៩៥
ពាក្យថា ពុទ្ធោ ១៥ យ៉ាង (បិដក ៧០[៩៤] (ត) ១៩៩
ពាក្យថា ពុទ្ធោ ១៥ យ៉ាង (អដ្ឋកថា) ២០៥

៥. សតោការិញ្ញាណនិទ្ទេសោ ២១៨

ញាណលំដាប់ទី ៥ សតោការិញ្ញាណនិទ្ទេស (បិដក៧០) [៩៥]... ២១៨

ចតុក្ក ទី ១ ពួកកាយ ២១៩

ចតុក្ក ទី ២ ពួកវេទនា ២២០

ចតុក្ក ទី ៣ ពួកចិត្ត ២២០

ចតុក្ក ទី ៤ ពួកធម៌ ២២១

៥. សតោការិញ្ញាណនិទ្ទេសវណ្ណនា ២២២

ការពណ៌នាក្នុងសតោការីនិទ្ទេស (អដ្ឋកថា)..... ២២២

អរញ្ញគតោ វា ។បេ។ សុញ្ញាគារគតោ វា តាមន័យទី ២ ..... ២២៥

អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា តាមន័យទី ៣... ២២៧

អធិប្បាយសព្ទ អស្សាស បស្សាស ២៣២

អធិប្បាយពាក្យ សព្ទកាយប្បដិសំវេទី ២៣៥

អធិប្បាយពាក្យ បស្សម្ភយំ កាយសង្ខារំ..... ២៣៩

តាមន័យ សមថ ២៤២

តាមន័យ វិបស្សនា ២៤៤

វិធី មនសិការយកកម្មដ្ឋាន មាន ៨ យ៉ាង..... ២៤៩

វិធី គណនា គឺការកំណត់រាប់ ២៥១

វិធី កំណត់រាប់យឺតៗ..... ២៥២

វីធី កំណត់រាប់លឿន..... ២៥៣

វិធីប្រើអនុពន្ធនា គឺសតិនៅជាមួយខ្យល់..... ២៥៧

ការឧបមាទី ១ ដូចបុរសខ្វិនជើង ២៥៩
ឧបមាទី ២ ដូចជាអ្នកយាមទ្វារ ២៦០
ឧបមាទី ៣ ដូចអ្នកអារឈើដោយរណារដៃ ២៦១
វិធីមនសិការអានាបានស្សតិ មានលក្ខណាផ្សេងពីកម្មដ្ឋានដទៃ ... ២៦៤
ឧបាយក្នុងការកំណត់ដឹងខ្យល់ឡើងវិញ ២៦៥
ឧបមា ដូចអ្នកដែលក្លរស្រែ ២៦៩
ឧគ្គហនិមិត្ត និងបដិភាគនិមិត្ត រមែងប្រាកដ ផ្សេងៗ គ្នា ២៧១
វិធីចម្រើនវិបស្សនា បន្តអំពីសមថៈ ២៧៦
ការកំណត់ នាម និង រូប ២៧៦
ក្នុងចតុក្ក ទី ២, ៣, ៤ ..... ២៧៩
ចតុក្កទី ២ វេទនានុបស្សនា ២៧៩
ចតុក្កទី ៣ ចិត្តានុបស្សនា ២៨២
ចតុក្កទី ៤ ធម្មានុបស្សនា ២៨៧
ពាក្យថា អនិច្ចានុបស្សី ២៨៧
ពាក្យថា វិរាគានុបស្សី ២៨៩
ពាក្យថា និរោធានុបស្សី ២៩០
ពាក្យថា បដិនិស្សគ្គានុបស្សី ២៩០
ពាក្យថា តថ សព្ទ (បិដក ៣០) [៩៦] ២៩៤
ពាក្យថា តថ សព្ទ (អដ្ឋកថា) ២៩៦
ប្រាប់វិធីនៃការរាប់ញាណសតោការី ៣២ ញាណ (បិដក ៣០) [៩៧] ... ៣១២

វិធីរាប់ញាណសតោការី ៣២ ញាណ (អដ្ឋកថា) *៣១៤*

បឋមចតុក្កនិទ្ទេសោ (បិដក ៧0) [៩៨] *៣១៧*

ការកំណត់ដឹងនូវខ្យល់ដង្ហើមវែង ៩ យ៉ាង *៣១៧*

បឋមចតុក្កនិទ្ទេសោ *៣២១*

កំណត់ដឹងខ្យល់ដង្ហើមវែង ៩ យ៉ាង (អដ្ឋកថា) *៣២១*

ភិក្ខុពិចារណាឃើញរឿយៗ ៧ យ៉ាង (បិដក ៧0) [៩៩] *៣២៦*

បានអានិសង្ស ៧ យ៉ាង *៣២៧*

អត្ថនៃពាក្យថា ការវនា មាន ៤ យ៉ាង *៣២៨*

ចិត្តដែលមានឧបចារ *៣២៨*

អធិប្បាយអំពី វេទនា *៣៣0*

ការតាំងឡើងរបស់វេទនា *៣៣១*

ការរលត់ទៅរបស់វេទនា *៣៣១*

អធិប្បាយអំពី សញ្ញា *៣៣៣*

ការតាំងឡើងរបស់សញ្ញា *៣៣៤*

ការរលត់ទៅរបស់សញ្ញា *៣៣៤*

អធិប្បាយអំពីវិតក្ក *៣៣៥*

ការតាំងឡើងនៃវិតក្ក *៣៣៧*

ការវិនាសទៅនៃវិតក្ក *៣៣៧*

ការកំណត់ដឹង ៧ យ៉ាង (អដ្ឋកថា) *៣៣៩*

ខ្យល់ដង្ហើមចូល - ចេញ រមែងប្រមូលមកនូវធម៌ទាំងឡាយ *៣៤៦*

ចតុក្ក្នីទី ១ លំដាប់ទី ១ (**មិដក ៧០**) [**១០៤**] ៣៤៦
១. ប្រមូលមកនូវពល:ទាំងឡាយដោយអត្ត ៥ យ៉ាង ៣៤៩
២. ប្រមូលមកនូវពោជ្ឈង្គទាំងឡាយដោយអត្ត ៧ យ៉ាង ៣៥០
៣. ប្រមូលមកនូវមគ្គដោយអត្ត ៨ យ៉ាង ៣៥១
៤. ប្រមូលមកនូវធម៌ទាំងឡាយទុកក្នុងអារម្មណ៍ដោយអត្ត ២៩ យ៉ាង ... ៣៥៣
ខ្យល់ដកដង្ហើមចូល ចេញខ្ងី ៣៦៥
ចតុក្ក្នីទី ១ លំដាប់ទី ២ (**មិដក ៧០**) [**១០៩**] ៣៦៥
១. ខ្យល់ដង្ហើមចូល ចេញខ្ងី ៣៦៦
២. ឆន្ទ: រមែងកើតឡើង ៣៦៦
៣. បាមោជ្ជ រមែងកើតឡើង ៣៦៧
៤. ឧបេក្ខា រមែងកើតឡើង ៣៦៨
ខ្យល់ដកដង្ហើមចូល ចេញខ្ងី ៣៧០
ចតុក្ក្នីទី ១ លំដាប់ទី ២ (អដ្ឋកថា) ៣៧០
សព្វកាយប្បដិសំវេទី ៣៧១
ចតុក្ក្នីទី ១ លំដាប់ទី ៣ (**មិដក ៧០**) [**១១១**] ៣៧១
ការដឹងប្រាកដមាន ១៥ យ៉ាង ៣៧៣
វិសុទ្ធិ និងសិក្ខាទាំង ៣ ..... ៣៧៧
ពាក្យថា សិក្សាមាន ១៥ យ៉ាង ៣៧៨
សព្វកាយប្បដិសំវេទី ៣៨០
ចតុក្ក្នីទី ១ លំដាប់ទី ៣ (អដ្ឋកថា) ៣៨០

បស្សម្ភយំ កាយសង្ខារំ ៣៨៦

ចតុក្កទី ១ លំដាប់ទី ៤ (មិកដ ៧០) [១១៤] ៣៨៦

ការដឹងខ្យល់ឡើងវិញ ៣៨៩

ការឧបមា ៣៩០

ការឧបមេយ្យ ៣៩១

ខ្យល់បានប្រាកដមកវិញ ៣៩៣

បស្សម្ភយំ កាយសង្ខារំ ៣៩៧

ចតុក្កទី១ លំដាប់ទី ៦ (អដ្ឋកថា) ៣៩៧

ទុតិយចតុក្កនិទ្ទេសោ ៦០៧

បីតិប្បដិសំវេទី ៦០៧

ចតុក្កទី ២ លំដាប់ទី ១ (មិដក ៧០) [១១៦] ៦០៧

ទុតិយចតុក្កនិទ្ទេសោ ៦១៣

បីតិប្បដិសំវេទី ៦១៣

ចតុក្កទី ២ លំដាប់ទី ១ (អដ្ឋកថា) ៦១៣

សុខប្បដិសំវេទី ៦១៦

ចតុក្កទី ២ លំដាប់ទី ២ (មិដក ៧០) [១១៧] ៦១៦

សុខប្បដិសំវេទី ៦២០

ចតុក្កទី ២ លំដាប់ទី ២ (អដ្ឋកថា) ៦២០

ចិត្តសង្ខារប្បដិសំវេទី ៦២៣

ចតុក្កទី ២ លំដាប់ទី ៣ (មិដក ៧០) [១១៨] ៦២៣

បស្សម្ភយំ ចិត្តសង្ខារំ ๔๒๗

จตุกฺกนิ ๒ ฉกฺกนิ ๔ (**ปิฏก ๗๐**) [**๑๑๔**] ๔๒๗

ตติยจตุกฺกนิทฺเทโส ๔๓๑

นิทฺเทสนฺเตจตุกฺก:ที ๓ ..... ๔๓๑

จตุกฺกนิ ๓ ฉกฺกนิ ๑ (**ปิฏก ๗๐**) [**๑๒๐**] ๔๓๑

ตติยจตุกฺกนิทฺเทสา ๔๓๕

จตุกฺกนิ ๓ ฉกฺกนิ ๑ (อฏฺฐกถา) ๔๓๕

จตุกฺกนิ ๓ ฉกฺกนิ ๒ (**ปิฏก ๗๐**) [**๑๒๑**] ๔๔๐

อภิปฺปโมทยิ จิตฺตำ ๔๔๔

จตุกฺกนิ ๓ ฉกฺกนิ ๒ (อฏฺฐกถา) ๔๔๔

สมาทหำ จิตฺตำ ๔๔๔

จตุกฺกนิ ๓ ฉกฺกนิ ๓ (**ปิฏก ๗๐**) [**๑๒๒**] ๔๔๔

สมาทหำ จิตฺตำ ๔๔๘

จตุกฺกนิ ๓ ฉกฺกนิ ๓ (อฏฺฐกถา) ๔๔๘

วิโมจยิ จิตฺตำ ๔๕๑

จตุกฺกนิ ๓ ฉกฺกนิ ๔ (**ปิฏก ๗๐**) [**๑๒๓**] ๔๕๑

วิโมจยิ จิตฺตำ ๔๕๔

จตุกฺกนิ ๓ ฉกฺกนิ ๔ (อฏฺฐกถา) ๔๕๔

จตุตฺถจตุกฺกนิทฺเทโส ๔๕๕

นิทฺเทสนฺเตจตุกฺกนิ ๔ ..... ๔๕๕

ចតុក្កនិ ៤ លំដាប់ទី ១ (**បិដក ៧0**) [**១២៤**] ๔๕๕
ចតុក្កនិ ៤ លំដាប់ទី ២ (**បិដក ៧0**) [**១២៥**] ๔๕๙
និពោជានុបស្សី ๔๖๒
ចតុក្កនិ ៤ លំដាប់ទី ៣ (**បិដក ៧0**) [**១២៦**] ๔๖๒
ចតុត្តចតុក្កនិទ្ទេសោ ๔๖๔
ចតុក្កទី ៤ លំដាប់ទី ១ (អដ្ឋកថា) ๔๖๔
បដិច្ចសមុប្បាទ (បិដក ៧0) [១២៧] ๔๖๘
បដិច្ចសមុប្បាទ (អដ្ឋកថា) ๔๗๗
បដិនិស្សគ្គានុបស្សី ๔๘๑
ចតុក្ក ទី ៤ លំដាប់ទី ៤ (**បិដក ៧0**) [**១២៩**] ๔๘๑
បដិនិស្សគ្គានុបស្សី (អដ្ឋកថា) ๔๘๗
๖. ញាណរាសិចក្កនិទ្ទេសោ ๔๙๐
ញាណរាសីនិទ្ទេសលំដាប់ទី ๖ ..... ๔๙๐
ចតុវីសតិ សមាធិវសេន ញាណានិ ๔๙๐
ញាណសមាធិមាន ๒๔ ញាណ លំដាប់ទី ๖ (បិដក ៧0) [๑๓0] ... ๔๙๐
វិធីរាប់ញាណសមាធិទាំង ๒๔ ..... ๔๙๑
๗.ទ្វេសត្តតិ វិបស្សនាចរសេន ញាណានិ ๔๙๒
វិបស្សនាញាណ ๗๒ ញាណ លំដាប់ទី ๗ ..... ๔๙๒
๘.អដ្ឋ និព្វិទាញាណានិ ๔๙๕
ញាណដែលនឿយណាយក្នុងសង្ខារធម៌មាន ๘ ញាណ ๔๙๕

វិធីរាប់និព្វិទាញាណ ៨ យ៉ាង..... ៤៩៦

៩.អដ្ឋ និព្វិទានុលោមេ ញាណានិ *៤៩៧*

ញាណពិចារណាឃើញសង្ខារស្របតាមនិព្វិទាញាណមាន ៨ ញាណ ... ៤៩៧

១០.អដ្ឋ និព្វិទាបដិប្បស្សទ្ធិញាណ *៤៩៩*

ញាណដឹងក្នុងការនឿយណាយមាន ៨ ញាណ លំដាប់ទី ១០... ៤៩៩

១១.ឯកវីសតិ វិមុត្តិសុខេ ញាណានិ *៥០១*

វិមុត្តិសុខញាណ ២១ យ៉ាង លំដាប់ទី ១១ ..... ៥០១

សោតាបត្តិមគ្គ លះបាន ៥ យ៉ាង..... ៥០១

សកទាគាមិមគ្គ លះបាន ៤ យ៉ាង..... ៥០២

អនាគាមិមគ្គ លះបាន ៤ យ៉ាង..... ៥០៣

អរហត្តមគ្គ លះបាន ៨ យ៉ាង..... ៥០៣

៦. ញាណរាសិធម្មនិទ្ទេសវណ្ណនា (អដ្ឋកថា) ៥០៦

ការពណ៌នារាសីធម្មនិទ្ទេស..... ៥០៦

ឯកសារយោង ៥១៥

មគ្គបដិបត្តិអានាបានស្សតិ ២២០ ញាណ

ការប្រព្រឹត្តតាមផ្លូវរបស់កម្មដ្ឋានអានាបានស្សតិ

សៀវភៅដែលឈ្មោះថា **មគ្គបដិបត្តិអានាបានស្សតិកម្មដ្ឋាន** *នេះ មកពីពាក្យ* **មគ្គ** *ប្រែថាផ្លូវ* **បដិបត្តិ** *ប្រែថា ប្រព្រឹត្តតាម* **អាន** *ប្រែថា ខ្យល់ដង្ហើមចូល* **អាបាន** *ប្រែថា ខ្យល់ដង្ហើមចេញ* **សតិ** *ប្រែថា រលឹកដឹង* **កម្មដ្ឋាន** *ប្រែថា ហេតុជាទីតម្កល់នៃបរិកម្ម ដូច្នេះ បានសេចក្តីថា ការប្រព្រឹត្តតាមផ្លូវរបស់កម្មដ្ឋានអានាបានស្សតិ ឬថា ប្រាប់ផ្លូវអំពីកម្មដ្ឋានមួយដែលមានខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញមកជាអារម្មណ៍ ។ សៀវភៅនេះកើតឡើងមកពីការរួបរួមគម្ពីរផ្សេងៗ ដើម្បីទុកឲ្យសេចក្តីរបស់អានាបានស្សតិជាប់តគ្នាងាយស្រួលក្នុងការសិក្សា និងយកទៅបដិបត្តិតាម ដែលមានដូចជាទី១ អានាបានស្សតិព្រះសូត្រទី ៨ ក្នុងបិដក ២៦ ជាព្រះសូត្រដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងដោយផ្ទាល់ព្រះអង្គឯងមាន ៤ ចតុក្ក ហើយមួយចតុក្កៗមាន៤ ចំណុច ដែលស្មើនឹង១៦ ចំណុច, ទី២ បន្ទាប់មកព្រះសារីបុត្តត្ថេរ ដែលមានបញ្ញាដ៏កំពូល បន្ទាប់អំពីព្រះអង្គ ព្រះថេរៈក៏បានអធិប្បាយសេចក្តីអានាបានស្សតិនោះ ទាំងសមថៈ និងវិបស្សនាផង បានបញ្ញាញាណស្មើ ២២០ញាណ ដែលមាននៅក្នុងបិដកខ្មែរលេខ ៧០ ត្រង់ [៦៩] ឈ្មោះថា គម្ពីរបដិសម្ភិទាមគ្គ, ទី ៣ ក្នុងចំណុចនេះផងដែរ ព្រះអដ្ឋកថាឈ្មោះថា សទ្ធម្មបកាសិនី បានពន្យល់នូវសេចក្តីនោះយ៉ាងពិស្តារ ។*

មគ្គបដិបត្តិអានាបានសតិ ២២០ ញាណ

សមថកម្មដ្ឋាន ៤០

ទី ១. កសិណ ១០

កសិណពណ៌ទាំង ៤ គឺ **ឧទាត** *ពណ៌ស១,* **បិតក** *ពណ៌លឿង១,* **លោហិត** *ពណ៌ ក្រហម១,* **នីល** *ពណ៌ខៀវ(ឬ ពណ៌ខ្មៅ)១ ។*

កសិណជាតុទាំង ៤ គឺ **បឋវី** *ពណ៌ដី១,* **អាចោ** *ពណ៌ទឹក១,* **តេជោ** *ពណ៌ ភ្លើង១,* **វាយោ** *ពណ៌ខ្យល់១ ។*

អាលោក *ពណ៌ពន្លឺ១,* **អាកាស** *ពណ៌លំហ១ ។*

ទី ២. អសុភ ១០

១. **ឧទ្ធុមាតក**	*ហើមពោរប៉ោងឡើង ។*
២. **វិនីលក**	*មានពណ៌ខៀវដំច្រើន ។*
៣. **វិបុព្វក**	*មានខ្ទុះហូរចេញ ទាំងខាងលើ និងខាងក្រោម ។*
៤. **វិច្ឆិទ្ទក**	*ដែលគេកាប់ដាច់ពាក់កណ្តាលខ្លួន ។*
៥. **វិក្ខាយិតក**	*ដែលសត្វកកេរស៊ី មានស្នាមរលុះរលួយផ្សេងៗ ។*
៦. **វិក្ខិត្តក**	*ដែលគេកាត់ដាច់ពីគ្នា ជាកំណាត់ៗរាត់រាយ ។*
៧. **ហតវិក្ខិត្តក**	*ដែលគេកាប់ចិញ្ច្រាំមានស្នាមរវើមរវាម ។*
៨. **លោហិតក**	*ដែលត្រូវគេប្រហារ មានឈាមហូរស្រោចស្រព ។*
៩. **បុឌ្ឍុវក**	*ដែលដង្កូវចោះហូរចេញតាមទ្វារទាំងប្រាំបួន ។*
១០. **អដ្ឋិក**	*ដែលមានតែឆ្អឹងរាត់រាយខ្ចាត់ខ្ចាយផ្សេងៗ ពីគ្នា ។*

ទី ៣. អនុស្សតិ ១០

១. ពុទ្ធានុស្សតិ *សេចក្តីរលឹករឿយៗ ដល់ពុទ្ធគុណ ។*

២. ធម្មានុស្សតិ *សេចក្តីរលឹករឿយៗ ដល់ធម្មគុណ ។*

៣. សង្ឃានុស្សតិ *សេចក្តីរលឹករឿយៗ ដល់សង្ឃគុណ ។*

៤. សីលានុស្សតិ *សេចក្តីរលឹករឿយៗ ដល់សីលគុណ ។*

៥. ចាគានុស្សតិ *សេចក្តីរលឹករឿយៗ ដល់ចាគគុណ ។*

៦. ទេវតានុស្សតិ *សេចក្តីរលឹករឿយៗ ដល់សទ្ធាទិគុណរបស់ទេវតា ។*

៧. មរណានុស្សតិ *សេចក្តីរលឹករឿយៗ ដល់សេចក្តីស្លាប់ ។*

៨. កាយគតាសតិ *សេចក្តីរលឹករឿយៗ ដែលតាំងចុះក្នុងកាយ ។*

៩. អានាបានស្សតិ *សេចក្តីរលឹករឿយៗ ដល់ខ្យល់ដង្ហើមចូលនិងខ្យល់ដង្ហើមចេញ ។*

១០. ឧបសមានុស្សតិ *សេចក្តីរលឹករឿយៗ ដល់គុណរបស់ព្រះនិព្វាន ។*

ទី ៤. ព្រហ្មវិហារធម៌ ៤

១. មេត្តា *ការផ្សាយសេចក្តីស្រលាញ់រាប់អាន ដល់សព្វសត្វដែលមានជីវិតរស់នៅថា* **អយំ សប្បុរិសោ អវេរោ ហោតុ** *សូមឲ្យសប្បុរសនេះ កុំឲ្យមានពៀរ,* **អយំ សប្បុរិសោ អព្យាបជ្ឈោ ហោតុ** *សូមឲ្យសប្បុរសនេះ កុំឲ្យមានព្យាបាទ,* **អយំ សប្បុរិសោ អនីឃោ ហោតុ** *សូមឲ្យសប្បុរសនេះ កុំឲ្យមាន សេចក្តីទុក្ខ,* **អយំ សប្បុរិសោ សុខី អត្តានំ បរិហរតុ** *សូមឲ្យសប្បុរស*

នេះ មានតែសេចក្តីសុខផងចុះ ។ (មេត្តានេះមាន **បិយមនាបសត្តប្បញ្ញត្តិ** *ជាអារម្មណ៍) ។*

២. ករុណា *ការផ្សាយសេចក្តីអាណិតអាសូរ ដល់សព្វសត្វទូរទៅដែលមានជីវិតរស់នៅថា សូមឲ្យរួចចាកទុក្ខទាំងពួង ។ (មាន* **ទុក្ខិតសត្តប្បញ្ញត្តិ** *ជាអារម្មណ៍) ។*

៣.មុទិតា *ការផ្សាយនូវសេចក្តីត្រេកអរីករាយពេញចិត្ត ដល់សព្វសត្វទូរទៅ ដែលមានជីវិតរស់នៅថា សូមឲ្យមានសេចក្តីសុខសប្បាយរីករាយផងចុះ ។ (មាន* **សុខិតសត្តប្បញ្ញត្តិ** *ជាអារម្មណ៍) ។*

៤. ឧបេក្ខា *ការផ្សាយនូវទឹកចិត្តជាកណ្តាលៗ ដល់សព្វសត្វទូរទៅដែលមានជីវិតរស់នៅថា សូមឲ្យរស់នៅទៅតាមអធ្យាស្រ័យផងចុះ ។ (មាន* **មជ្ឈត្តសត្តប្បញ្ញត្តិ** *ជាអារម្មណ៍) ។*

ទី ៥. អរូបជ្ឈាន ៤

១. អាកាសានញ្ចាយតន *យកអាកាសក្នុងបដិភាគនិមិត្ត ដែលកើតអំពីកសិណ ទាំង ៩ យ៉ាង លើកលែងតែ អាកាសកសិណមួយចេញ ដែលមិនមានទីបំផុតមកជាអារម្មណ៍, បានសេចក្តីថា យោគាវចរត្រូវចូលឈានក្នុងពួកកសិណណាមួយសិន ហើយចូលឈានទី១. ២. ៣. ៤ រួចហើយបង្អោនចិត្តបើកនូវកសិណនោះឲ្យទៅជាអាកាស បន្ទាប់មកបង្អោនចិត្តកាន់យកនូវពួកអរូបនោះ ធ្វើជាអារម្មណ៍, (***អនន្តោ អាកាសោ*** *អាកាសមិនមានទីបំផុត នេះជាអារម្មណ៍របស់អរូបឈានទី ១) ។*

២. វិញ្ញាណញ្ចាយតន *យកអរូបជ្ឈានទី ១ ដែលផ្សាយទៅមិនមានទីបំផុតនោះ មកជាអារម្មណ៍, (***អនន្តំ វិញ្ញាណំ** *វិញ្ញាណមិនមានទីបំផុត នេះជាអារម្មណ៍របស់អរូបជ្ឈានទី ២) ។*

៣. អាកិញ្ចញ្ញាយតន *កំណត់យកនូវអរូបឈានទី ២ ដែលផ្សាយទៅ ដោយមិនមានកង្វល់តិចតួចនោះ មកជាអារម្មណ៍, (**ន**ត្ថិ **កិ**ញ្ចិ *អ្វីតិចតួចមិនមាន នេះជាអារម្មណ៍របស់អរូបជ្ឈានទី ៣) ។*

៤. នេវសញ្ញានាសញ្ញាយតន *កំណត់យកភាពល្អិតរបស់អរូបជ្ឈានទី៣ ដែលមានសភាព មានស្ទើរតែមិនមាននោះ មកជាអារម្មណ៍,(**ឯ**តំ **ស**ន្តំ **ឯ**តំ **ប**ណីតំ នេះស្ងប់ណាស់ នេះល្អិតណាស់ នេះជាអារម្មណ៍របស់អរូបឈានទី ៤) ។*

ទី ៦. សញ្ញា ១

១. សញ្ញា *បានដល់អាហារបដិកូលសញ្ញា ដែលយោគាវចរត្រូវពិចារណាកំណត់អាហារ ឲ្យទៅជាបដិកូល ។*

ទី ៧. ឋឋត្តាន ១

១. វវដ្ឋាន *បានដល់ ចតុទ្ធាតុវវត្ថាន ដែលព្រះយោគាវចរត្រូវពិចារណាកំណត់នូវធាតុទាំង ៤ ក្នុងកវជ្ជកាយនេះ ។*

សមថកម្មដ្ឋានទាំង ៤០ *ប្រភេទនេះ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់បានសម្តែងទុកមកហើយនោះ កម្មដ្ឋានដែលបានត្រឹមតែ ឧបចារឈានមាន ១០ កម្មដ្ឋាន និងកម្មដ្ឋានអាចចូលឈានបានមាន ៣០ កម្មដ្ឋានគឺ កសិណ ១០, អសុភ ១០, កាយគតាសតិ ១, អានាបានស្សតិ ១, ព្រហ្មវិហារធម៌ ៤, អរូបជ្ឈាន ៤ ។ កម្មដ្ឋានទាំង ៣០ នេះ មាននិមិត្តដោយត្រង់នោះមានតែ ២២ កម្មដ្ឋាន គឺ កសិណ ១០, អសុភ ១០, កាយគតាសតិ ១ និង អានាបានស្សតិ ១ ។ ក្នុងបណ្តាកម្មដ្ឋាន ២២ ដែលមាននិមិត្តដោយត្រង់នេះ មានកម្មដ្ឋាន ២១ ដែលមាននិមិត្តចេញអំពីផ្លូវភ្នែកទៅកាន់ផ្លូវចិត្ត គឺចាប់ផ្តើមតាំងពីបរិកម្មនិមិត្ត ដែលមើលទៅក្នុងវត្តុផ្សេងៗ មានបឋវីកសិណជាដើម ជាការសម្ងឹងនូវអារម្មណ៍កម្មដ្ឋាន ហើយ*

ចាំបានដោយសញ្ញាចេញអំពីផ្លូវភ្នែកទៅកាន់ផ្លូវចិត្ត រហូតសញ្ញានោះតាំងនៅមាំបានល្អ ក្លាយទៅជា **ឧគ្គហនិមិត្ត** ហើយក៏ប្រាកដច្បាស់ឡើងៗ ទៅតាមផ្លូវចិត្ត សូម្បីតែបិទភ្នែកក៏នៅមើលឃើញបាន ដូចកាលបើកភ្នែកដែរ ថាមានការសម្ងឹងជាប់តៗ គ្មានហូតសមាធិកើតឡើងធ្វើឲ្យនិមិត្តនោះ ក្លាយទៅជាមានពន្លឺ ភ្លឺស្វាងឡើងៗ ទៅតាមពណ៌របស់កសិណនីមួយៗនោះ សភាពយ៉ាងនេះហៅថា **បដិភាគនិមិត្ត** គឺជានិមិត្តដែលប្រាកដច្បាស់តាំងមាំបានល្អនៅក្នុងផ្លូវចិត្ត រហូតបាន ១ ម៉ោង ២ ម៉ោង ៣ម៉ោង ឬច្រើនជាងនេះ ទើបអាចយកជាការបាន ។

ចំណែកនិមិត្តរបស់ អានាបានស្សតិវិញ មានសភាពផ្សេងអំពីកម្មដ្ឋានទាំង ២១ ប្រភេទនោះ គឺមាននិមិត្ត **ជានិមិត្តរបស់ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលមកប៉ះពាល់ត្រូវជាមួយសតិ នៅត្រង់ចន្លោះបុងច្រមុះ និងផ្នែបបូរមាត់ខាងលើ** ហើយមានសញ្ញាកំណត់ដឹងនូវការប៉ះពាល់ត្រូវនោះ ទៅព្រមជាមួយសតិនោះផងដែរ ដែលបានរលឹកដឹងរឿយៗ មិនឲ្យខាតចន្លោះប្រហោង គឺមិនឲ្យរាយមាយទៅគិតរឿងផ្សេង រហូតតាំងនៅមាំបានរយៈពេលខ្លីៗ ហើយខំព្យាយាមបន្តែមទៀតរឿយៗដើម្បីឲ្យតាំងនៅបានច្រើនម៉ោងក្នុងមួយភ្លែតៗនោះ ក្លាយទៅជា **ឧគ្គហនិមិត្ត** ហើយមិនមែនទៅជារូបភាព ផ្សេងៗ ឡើយ គឺមានពន្លឺភ្លឺស្វាង ហើយក៏អាចក្លាយទៅជា **បដិភាគនិមិត្ត** ទៅតាមលំដាប់ផងដែរ ប្រសិនបើមានរូបភាព ផ្សេងៗ បានកើតឡើងក្នុងរវាងការបដិបត្តិនេះ សូមឲ្យដឹងថា អ្នកបដិបត្តិកំពុងផ្ទាស់ប្តូរនូវអារម្មណ៍របស់កម្មដ្ឋានហើយ ដែលមានកសិណកម្មដ្ឋានជាដើម ឬក៏ អាចក្លាយទៅជា មិច្ឆាសមាធិ ព្រោះថា រូបភាពដែលកើតឡើងនោះ ចេញមកអំពីចិត្តជាអកុសលធម៌ ដែលមិនត្រឹមត្រូវតាមកុសលចិត្តដែលប្រកបដោយសតិសម្បជញ្ញៈទេ បែរជាតម្កល់ទៅក្នុងអារម្មណ៍ផ្សេងៗ ធ្វើឲ្យកើតនូវនិមិត្តប្លែកៗ ទៅតាមអារម្មណ៍ដែលខ្លួនចង់បាននោះ ។

វិសុទ្ធិទាំង ៧ យ៉ាង

វិសុទ្ធិ បានដល់ សេចក្តីបរិសុទ្ធិ ដែលមិនមានមន្ទិលរហូត បន្ទុះទៅដល់ព្រះនិព្វាន មាន ៧ យ៉ាងទៅតាមលំដាប់ គឺ៖

១. **សីលវិសុទ្ធិ** គឺសេចក្តីបរិសុទ្ធិរបស់សីល ព្រោះសីលបានធ្វើឲ្យកាយ វាចា មានរបៀបរៀបរយ និងជម្រះចិត្តឲ្យបានបរិសុទ្ធទៀតផង ឥន្ទ្រិយសំវរ ឬពោលដោយចតុបារិសុទ្ធិសីល ហៅថា **អធិសីល** យ៉ាងនេះក៏បាន ។

២. **ចិត្តវិសុទ្ធិ** គឺសេចក្តីបរិសុទ្ធនៃចិត្ត បានដល់ ចិត្តដែលប្រកបដោយសមាធិដែលកើតមកអំពីសតិបដ្ឋាន ហើយសមាធិនេះឯង ប្រើជាបាទនៃវិបស្សនា និងជាខណិកសមាធិ បានដល់ ឧបចារសមាធិ ឬ អប្បនាសមាធិ ប៉ុន្តែនៅក្នុងទីបំផុតនៃអរិយមគ្គ ត្រូវមាន អប្បនាសមាធិ ឬ រូបជ្ឈានទាំង ៤ ។

៣. **ទិដ្ឋិវិសុទ្ធិ** គឺសេចក្តីបរិសុទ្ធិ នៃទិដ្ឋិ បានដល់ ការយល់ចូលចិត្តបានឃើញច្បាស់ប្រាកដនូវ នាម និងរូប ទៅតាមសភាវៈពិត ឃើញរូបធាតុ និងនាមធាតុផ្សេងអំពីគ្នាយ៉ាងច្បាស់ពិតប្រាកដ ដែលជាហេតុធ្វើឲ្យមិនយល់ខុសថា រូបខន្ធនេះ មិនមែនជាខ្លួនយើងឡើយ ។

៤. **កង្ខាវិតរណវិសុទ្ធិ** គឺសេចក្តីបរិសុទ្ធនៃញាណ ជាគ្រឿងឆ្លងរួចផុតនូវសេចក្តីសង្ស័យ សេចក្តីបរិសុទ្ធនូវចំណុចដែលធ្វើឲ្យកើតសេចក្តីសង្ស័យ គឺបានកំណត់ដឹងនូវបច្ច័យនៃនាម និងរូប ទើបអស់សេចក្តីសង្ស័យ បានឃើញនូវបដិច្ចសមុប្បាទ ។

៥. **មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ** គឺសេចក្តីបរិសុទ្ធនៃញាណដែលជាគ្រឿងដឹងថា នេះជាផ្លូវ ឬ មិនមែនជាផ្លូវទេ ចិត្តបានទទួលដឹងនូវក្រសែតមកនៃត្រៃលក្ខណ៍ ។

៦. **បដិបទាញ្ញាណទស្សនវិសុទ្ធិ** គឺសេចក្តីបរិសុទ្ធនៃញាណ ដែលដឹង ដែលឃើញនូវផ្លូវដំណើរទៅ គឺ (វិបស្សនាញាណទាំង ៩ យ៉ាង) ដឹងនូវ

ទុក្ខអរិយសច្ច ទើបលះនូវសមុទយអរិយសច្ច ឃើញច្បាស់នូវនិរោធ និងសំបូរ ទៅដោយការចម្រើនអរិយមគ្គ និងពិចារណាទាំងអស់ព្រមគ្នា (សាមគ្គីធម៌) កាលបានដល់នូវសច្ចានុលោមិកញាណ ពិចារណាដូចជាអ្នកប្រឹក្សាគ្នារកនូវ ហេតុទាំងអស់ ។

៧. ញាណទស្សនវិសុទ្ធិ *គឺសេចក្តីបរិសុទ្ធនៃញាណទស្សន បានដល់ ការបដិបត្តិដែលបរិបូរណ៌រហូតបានធ្វើនូវភូមិចិត្តខាងដើម គឺគោត្រភូញាណ និងវិទានញាណ ? បានដឹងច្បាស់ក្នុងអរិយមគ្គ ឬ មគ្គញាណ បានបន្ទុះទៅជា អរិយបុគ្គល ឬ ផលញាណ ពិចារណាធម្មដែលបានបន្ទុះមកហើយ គឺបច្ចវេក្ខ ណញាណ រមែងកើតឡើងក្នុងរវាងចំណុចនៃវិសុទ្ធិនេះ ជាការបន្ទុះនូវផលដ៏ ខ្ពង់ខ្ពស់បំផុតនៃវិសុទ្ធិ ឬ នៃត្រៃសិក្ខា ឬការ បដិបត្តិធម៌នៅក្នុងព្រះពុទ្ធសាសនា នេះ ដែលចាប់ផ្តើមតាំងអំពីភូមិនៃការមិនយល់ខុសនោះមក ។*

សោឡសញ្ញាណ ១៦ ឬ ឥបស្សនាញ្ញាណ ១៦

១. ជាមរូបបរិច្ឆេទញ្ញាណ

គឺ ញាណ ដែលកំណត់ដឹងនូវ រូបធម៌និងនាមធម៌ ។

២. បច្ចយបរិគ្គហញ្ញាណ

គឺ ញាណ ដែលកំណត់ដឹងនូវបច្ច័យ(របស់រូបធម៌និងនាមធម៌) ។

៣. សម្មសនញ្ញាណ

គឺញាណ ដែលឃើញនូវសង្ខតលក្ខណ(អនិច្ចលក្ខណ) គឺការកើតឡើង ការតាំងនៅ និងការរលត់ទៅវិញរបស់ នាម និងរូប និងចាប់ផ្តើមឃើញ

ជាត្រៃលក្ខណ ជា **ឧទយព្វយញ្ញាណ** *យ៉ាងទន់ខ្លី ជា* ***វិបស្សនូបក្កិ-លេស*** *និងកើតឡើងក្នុងឱកាសនេះ ។*

៤. **ឧទយព្វយញ្ញាណ**

គឺ **ញាញ** *តាមឃើញនូវការកើតឡើង និងការរលត់ទៅវិញរបស់ នាម និងរូប ឃើញជា* **ពលវឧទយព្វយញ្ញាណ** *ជាញាណដ៏មានកម្លាំង កន្ទងផុតពី* ***វិបស្សនូ*** *។*

៥. **ភង្គញ្ញាណ**

គឺ **ញាណ** *តាមឃើញចំពោះការរលត់ទៅ និងការកើតឡើង តែម្យ៉ាង ។*

៦. **ភយញ្ញាណ**

គឺ **ញាណ** *ដែលមើលឃើញនូវសង្ខារធម៌ប្រាកដជារបស់គួរភ័យខ្លាច មិនទៀងទាត់ ដូចជាភ័យចំពោះ និងការស្លាប់ ។*

៧. **អាទីនវញ្ញាណ**

គឺ **ញាណ** *បានឃើញទុក្ខទោសគ្រប់រឿងរ៉ាវទាំងពួង ដែលមានការប្រែប្រួលទៅរហូតរកទីពឹងមិនបាន ។*

៨. **និព្វិទាញ្ញាណ**

គឺ **ញាណ** *បានឃើញដោយភាពនឿយណាយ ។*

៩. **មុញ្ចិតុកម្យតាញ្ញាណ**

គឺ **ញាណ** *បានដឹងនូវអ្វីដែលនឹងរួចផុតទៅបាន ។*

១០. **បដិសង្ខារញ្ញាណ**

គឺ **ញាណ** *ដែលពិចារណារំលឹកឡើងវិញ ដើម្បីនឹងរកផ្លូវចៀសចេញទៅ ។*

១១. សង្ខារុបេក្ខាញ្ញាណ

គឺ **ញាណ** *ដែលប្រព្រឹត្តិទៅដោយសភាពជាកណ្តាលៗ តម្កល់ជាធម្មតាៗ ចំពោះសង្ខារ ។*

១២. អនុលោមញ្ញាណ

គឺ **ញាណ** *ដែលប្រព្រឹត្តិទៅសមគួរដល់ការដឹងនូវអរិយសច្ចៈ ដែលអាចឃើញជាត្រៃលក្ខណធម៌ ភាវនាមយបញ្ញា បាន (ពិចារណាវិបស្សនាញាណទាំង ៨ ដែលបានឆ្លងមកហើយថា ជា* **ទុក្ខ** *កាលឃើញ* **ទុក្ខ** *ក៏ឃើញជា* **សមុទយ និរោធ មគ្គ** *ដោយញាណមួយៗ ជាហេតុកើតនូវមគ្គទាំង ៨ ទៅតាមលំដាប់ ហើយជា* **ចូឡសោតាបន្ន** *)។*

១៣. គោត្រភូញ្ញាណ

គឺ **ញាណ** *គ្របគ្រង់នូវគោត្រ បានដល់ ការដឹងដ៏មានកម្លាំងផុតខេត្តដែនរបស់បុថុជ្ជន និងកំពុងឡើងកាន់ខេត្តដែនរបស់ព្រះអរិយ ។*

១៤. មគ្គញ្ញាណ

គឺ **ញាណ** *ក្នុងអរិយមគ្គ ។*

១៥. ផលញ្ញាណ

គឺ **ញាណ** *អរិយផល ។*

១៦. បច្ចវេក្ខណាញ្ញាណ

គឺ **ញាណ** *ដែលពិចារណា ឡើងវិញនូវ (***មគ្គ ផល និព្វាន** *កិលេសដែលបានលះហើយ និងកិលេសដែលមិនទាន់បានលះ) ។*

ចប់ សោឡសញ្ញាណ

បរិញ្ញា ៣

១. **ញាតបរិញ្ញា** *ការកំណត់ដឹងនូវសភាវៈធម៌នោះៗ តាមលក្ខណៈដែលជាសភាវៈហ្នឹងឯង ។*

២. **តីរណបរិញ្ញា** *ការកំណត់ដឹងដោយការពិចារណាថា សភាវៈនោះៗមានលក្ខណៈ មិនទៀង ជាទុក្ខ ជាអនត្តា ។*

៣. **បហានបរិញ្ញា** *ការកំណត់ដឹងដល់ថ្នាក់លះបានគឺការកំណត់ដឹងថា សង្ខារ ជា អនិច្ចំ ទុក្ខំ អនត្តា ។*

ចប់ បរិញ្ញា

ពោធិបក្ខិយធម៌ ៣៧

ពោធិបក្ខិយធម៌ *ប្រែថា ធម៌កើតមានក្នុងចំណែក នៃអរិយមគ្គ ជាគ្រឿងត្រាស់ដឹងនូវចតុរារិយសច្ច មាន ៣៧ ប្រការគឺ ៖*

១. **សតិបដ្ឋាន ៤**	*សតិរលឹកដឹង*
២.**សម្មប្បធាន ៤**	*សេចក្តីព្យាយាម*
៣. **ឥទ្ធិបាទ ៤**	*គុណធម៌នាំឲ្យសម្រេច*
៤. **ឥន្ទ្រិយ ៥**	*ធម្មជាតជាធំ (ជាឥស្សរភាព)*
៥. **ពល ៥**	*កម្លាំងនៃកុសលធម៌*
៦.**ពោជ្ឈង្គ ៧**	*អង្គធម៌នៃការត្រាស់ដឹង*
៧. **អរិយមគ្គ ៨**	*ផ្លូវចេញចាកទុក្ខ*

១. សតិប្បដ្ឋាន ៤

សតិប្បដ្ឋាន ប្រែថា ជាទីតាំងនៅរបស់សតិ ឬថា ការតាំងនៅជាប្រធានរបស់សតិ ឬថា ជាទីឈរនៅរបស់សតិ ។

១.**កាយានុបស្សនា**	*ពាក្យថាកាយក្នុងទីនេះ គឺមានសតិរលឹកដឹងរឿយៗ នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ។*
២. **វេទនានុបស្សនា**	*មានសតិរលឹកដឹងរឿយៗ នូវវេទនា។*
៣. **ចិត្តានុស្សនា**	*មានសតិរលឹកដឹងរឿយៗ នូវចិត្ត ។*
៤. **ធម្មានុបស្សនា**	*មានសតិរលឹកដឹងរឿយៗ នូវធម្ម ។*

២. សម្មប្បធាន ៤

សម្មប្បធាន ប្រែថា ធម្មជាតជាគ្រឿងដំកល់ទុកដោយប្រពៃ បានខាងសេចក្តីព្យាយាមត្រូវ ឬល្អ មាន ៤ យ៉ាងគឺ ៖

(គឺមានលក្ខណជាធន្ធ:របស់ចិត្ត មិនមែនជាលក្ខណៈលោក:)

១. **បហានប្បធាន**	*មានសេចក្តីព្យាយាមលះនូវបាបអកុសលធម៌ដ៏លាមក ដែលបានកើតឡើងហើយ ។*
២. **សំវរប្បធាន**	*មានសេចក្តីព្យាយាមដើម្បីបិទបាំងរាំងបាបអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើង កុំឲ្យកើតឡើងបាន ។*
៣. **ភាវនាបធាន**	*មានសេចក្តីព្យាយាមដើម្បីបណ្តុះបណ្តាលនូវកុសលធម៌ ដែលមិនទាន់កើតឡើង ធ្វើឲ្យកើតឡើង ។*

៤. អនុរក្ខណាបធាន *មានសេចក្តីព្យាយាមចម្រើននិងរក្សានូវកុសលធម៌ ដែលមានមកហើយ ធ្វើឲ្យរឹងរឹតតែចម្រើនឡើងតទៅទៀត ។*

(ធម៌ទាំង ៤ យ៉ាងនេះ ជាតួវីរិយសម្ពោជ្ឈង្គ)

៣. ឥទ្ធិបាទ ៤

ឥទ្ធិបាទ *ប្រែថា ជាចំណែកគឺឫទ្ធិ ឬថា ជាទីតាំងនៃឫទ្ធិ ជាឧបាយ ជាគ្រឿងដល់នូវឫទ្ធិ មាន ៤ យ៉ាងគឺ ៖*

១. ឆន្ទិទ្ធិបាទ *សេចក្តីស្រលាញ់ពេញចិត្ត គាប់ចិត្តក្នុងកុសលធម៌ ដោយសមគួរ សមល្មម (ខុសអំពីលោភៈ) ។*

២. វីរិយិទ្ធិបាទ *មានសេចក្តីព្យាយាម ឱហាតសង្វាតមិនខ្ជិលច្រអូសក្នុងការចម្រើននូវកុសលធម៌ ។*

៣. ចិត្តិទ្ធិបាទ *សេចក្តីគិត សេចក្តីដឹងអារម្មណ៍ គំនិតរិះរៃបែរទៅរកផ្លូវល្អ ផ្លូវត្រាស់ដឹងនូវមគ្គ និងផល ។*

៤. វិមំសិទ្ធិបាទ *គឺតួបញ្ញា សេចក្តីដឹងច្បាស់ ។*

៤. ឥន្ទ្រិយ ៥

ឥន្ទ្រិយ *ប្រែថា ធម្មជាតជាធំ មាន ៥យ៉ាងគឺ ៖*

១. សទ្ធិន្ទ្រិយ *ការជឿស៊ប់ ជឿក្នុងការត្រាស់ដឹងរបស់ព្រះតថាគតជាដើម (គឺមានសទ្ធាក្នុងពោធិបក្ខិយធម៌)សង្គ្រោះចូលក្នុង* **សុតមយញ្ញាណ**។

២. វីរិយិន្ទ្រិយ *ការផ្គងឡើង ឱហាតសង្វាតប្រឹងប្រែង (គឺមានសេចក្តីព្យាយាមក្នុងសម្មប្បធាន) សង្គ្រោះចូលក្នុង*

សីលមយញ្ញាណ *ជា* **អធិសីលសិក្ខា** ។

៣. **សតិន្ទ្រិយ** *ការប្រុងប្រយ័ត្ន សេចក្តីរលឹក មានការរលឹកនូវពុទ្ធគុណ ជាដើម (ឬថា ការរឭកដឹងនៅក្នុងសតិប្បដ្ឋាន) សង្គ្រោះចូលក្នុង* **អធិចិត្តសិក្ខា** ។

៤. **សមាធិន្ទ្រិយ** *ការមិនរាយមាយ ការតម្កល់ចិត្តមាំ (គឺការតាំងមាំនៅក្នុងញាណ) សង្គ្រោះចូលក្នុង* **អធិចិត្តសិក្ខា** ។

៥. **បញ្ញិន្ទ្រិយ** *ការឃើញ ការយល់ជាលក្ខណៈ (គឺសេចក្តីចូលចិត្តនៅក្នុងអរិយសច្ច) សង្គ្រោះចូលក្នុង* **អធិបញ្ញាសិក្ខា** ។

៥. ពល ៥

ពល *ប្រែថា មិនកម្រើក ឬ កម្លាំង ឬថា រឹងប៉ឹង ដែលមិនញាប់ញ័រដោយធម៌ជាសត្រូវ មាន៥ យ៉ាងគឺ*

១. **សទ្ធាពល** *កម្លាំង គឺសទ្ធា ។*

២. **វីរិយពល** *កម្លាំង គឺវីរិយ ។*

៣. **សតិពល** *កម្លាំង គឺសតិ ។*

៤. **សមាធិពល** *កម្លាំង គឺសមាធិ ។*

៥. **បញ្ញាពល** *កម្លាំង គឺបញ្ញា ។*

៦. ពោជ្ឈង្គ ៧

ពោជ្ឈង្គ *ប្រែថា ធម៌ជាអង្គគឺជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច ឬថា ជាហេតុនៃការត្រាស់ដឹងនូវចតុរារិយសច្ច ពោជ្ឈង្គនេះមាន ៧ យ៉ាងគឺ៖*

១. សតិសម្ពោជ្ឈង្គ *សតិជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹង នូវចតុរារិយសច្ច ។*

២.ធម្មវិចយសម្ពោជ្ឈង្គ *បញ្ញាជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹង នូវចតុរារិយសច្ច។*

៣. វីរិយសម្ពោជ្ឈង្គ *វីរិយៈជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច ។*

៤.បីតិសម្ពោជ្ឈង្គ *បីតិសេចក្តីឆ្អែតកាយឆ្អែតចិត្តជាហេតុ នៃបុគ្គលជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច ។*

៥. បស្សទ្ធិសម្ពោជ្ឈង្គ *បស្សទ្ធិសេចក្តីរម្ងាប់កាយ រម្ងាប់ចិត្ត ជាហេតុនៃបុគ្គល ជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច ។*

៦.សមាធិសម្ពោជ្ឈង្គ *សមាធិជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច។*

៧.ឧបេក្ខាសម្ពោជ្ឈង្គ *ឧបេក្ខាជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវចតុរារិយសច្ច។*

៧. អរិយមគ្គអង្គ ៨

មគ្គ *ប្រែថា សភាវៈដែលបុគ្គលអ្នកត្រូវការដោយព្រះនិព្វានតែងស្វែងរក ឬថា សភាវៈស្វែងរកនូវព្រះនិព្វាន ឬថា សភាវៈសម្លាប់នូវកិលេសប្រព្រឹត្តិទៅ មគ្គនោះមានអង្គ ៨ គឺ ៖*

១. សម្មាទិដ្ឋិ *គឺបញ្ញាឃើញត្រឹមត្រូវ បានដល់ បញ្ញាឃើញនៅក្នុងកម្ម និងផលរបស់កម្ម រួមទាំងមានបញ្ញាឃើញស្របទៅតាមសភាពពិតក្នុងអរិយសច្ចទាំង ៤ ដែលមានទុក្ខអរិយសច្ច ជាដើម ។*

២. សម្មាសង្កប្ប	*គឺការពិចារណាដ៏ត្រឹមត្រូវ ដោយប្រពៃ បានដល់ នេក្ខម្មវិតក្ក ជាការពិចារណា និងចាកចេញអំពីកាម អព្យាបាទវិតក្ក ការពិចារណាលះបង់នូវព្យាបាទ អវិហិង្សាវិតក្ក ការពិចារណាលះបង់នូវការបៀតបៀន(ពិចារណាលះបង់នូវអកុសលធម៌)។*
៣. សម្មាវាចា	*គឺវាចាដ៏ប្រពៃ បានដល់ ការវៀរចាកនូវវចីទុច្ចរិត ៤ មានមុសាវាចា ជាដើម ។*
៤. សម្មាកម្មន្ត	*គឺការប្រព្រឹត្តិល្អតាមកាយ ការវៀរចាកនូវកាយទុច្ចរិត ៣ មានបាណាតិបាត ជាដើម ។*
៥. សម្មាអាជីវ	*គឺការចិញ្ចឹមជីវិតដោយប្រពៃ ដោយវៀរចាកនូវវចីទុច្ចរិត ៤ និងកាយទុច្ចរិត ៣ ដែលជាប់ទាក់ទងទៅនឹងការចិញ្ចឹមជីវិត ។*
៦. សម្មាវាយាម	*គឺការប្រកបនូវសេចក្តីព្យាយាមតាមផ្លូវចិត្ត ក្នុងការរក្សាកុសលធម៌ដែលកើតឡើងហើយ ដើម្បីឲ្យបរិបូរណ៌ថែមទៀត ។*
៧. សម្មាសតិ	*គឺសតិប្បដ្ឋានទាំង ៤ ជាការពិចារណាជាប់តៗគ្នាក្នុងកាយ ក្នុងវេទនា ក្នុងចិត្ត និងក្នុងធម៌ ។*
៨. សម្មាសមាធិ	*គឺសមាធិ ដែលកើតមកអំពីសម្មាសតិ ដែលជាឧបចារសមាធិ និងអប្បនាសមាធិ ទៅជាឈានចិត្ត ។*

អដ្ឋមំ អានាបានស្សតិសុត្តំ

អានាបានស្សតិសូត្រទី ៨ (មិ. ២៦)

[១៤៤] ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុបាសាទេ សម្ពហុលេហិ អភិញ្ញាតេហិ អភិញ្ញាតេហិ ថេរេហិ សាវកេហិ សទ្ធឹ អាយស្មតា ច សារិបុត្តេន អាយស្មតា ច មហាមោគ្គល្លានេន[1] អាយស្មតា ច មហាកស្សបេន អាយស្មតា ច មហាកច្চាយនេន អាយស្មតា ច មហាកោដ្ឋិកេន អាយស្មតា ច មហាកប្បិនេន អាយស្មតា ច មហាចុន្ទេន អាយស្មតា ច អនុរុទ្ធេន អាយស្មតា ច រេវតេន អាយស្មតា ច អានន្ទេន, អញ្ញេហិ ច អភិញ្ញាតេ ហិ អភិញ្ញាតេហិ ថេរេហិ សាវកេហិ សទ្ធឹ។

ខ្ញុំបានស្តាប់មក យ៉ាងនេះថា ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទមិគារមាតា ក្នុងបុព្វារាម ជិតក្រុងសាវត្ថី ព្រមដោយសាវ័កទាំងឡាយ ជាព្រះថេរៈច្រើនរូប ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញជាងគេ គឺព្រះសារីបុត្តមានអាយុ ១, ព្រះមហាមោគ្គល្លានមានអាយុ ១, ព្រះមហាកស្សបមានអាយុ ១, ព្រះមហាកច្চាយនៈមានអាយុ ១, ព្រះមហាកោដ្ឋិតៈមានអាយុ ១, ព្រះមហាកប្បិនៈមានអាយុ ១, ព្រះមហាចុន្ទៈមានអាយុ ១, ព្រះរេវតៈមានអាយុ ១, ព្រះអានន្ទមានអាយុ ១, ព្រមដោយសាវ័កទាំងឡាយជាព្រះថេរៈ ដទៃៗ ទៀត ដែលមានឈ្មោះល្បីល្បាញ ។

តេន ខោ បន សមយេន ថេរា ភិក្ខូ នវេ ភិក្ខូ ឱវទន្តិ អនុសាសន្តិ។

ក៏ក្នុងសម័យនោះឯង ភិក្ខុទាំងឡាយជាព្រះថេរៈ តែងទូន្មាន ប្រៀនប្រដៅពួកភិក្ខុថ្មីៗ ។

---

១ ក. មហាមោគ្គលានេន ។

អប្បេកចេ ថេរា កិក្ខូ ឧសបិ កិក្ខូ ឱវទន្តិ អនុសាសន្តិ, អប្បេកចេ ថេរា កិក្ខូ រីសម្បិ កិក្ខូ ឱវទន្តិ អនុសាសន្តិ, អប្បេកចេ ថេរា កិក្ខូ តីសម្បិ កិក្ខូ ឱវទន្តិ អនុសាសន្តិ, អប្បេកចេ ថេរា កិក្ខូ ចត្តារីសម្បិ កិក្ខូ ឱវទន្តិ អនុសាសន្តិ។

កិក្ខុជាព្រះថេរៈពួកខ្លះ បានទូន្មាន ប្រៀនប្រដៅដល់កិក្ខុ ១០ រូប ក៏មាន, កិក្ខុជាព្រះថេរៈពួកខ្លះ បានទូន្មាន ប្រៀនប្រដៅដល់កិក្ខុ ២០ រូប ក៏មាន, កិក្ខុជាព្រះថេរៈពួកខ្លះ បានទូន្មាន ប្រៀនប្រដៅដល់កិក្ខុ ៣០ រូប ក៏មាន, កិក្ខុជាព្រះថេរៈពួកខ្លះ បានទូន្មាន ប្រៀនប្រដៅដល់កិក្ខុ ៤០ រូប ក៏មាន ។

តេ ច ខលុ កិក្ខូ ថេរេហិ កិក្ខូហិ ឱវទិយមានា អនុសាសិយមានា ឧឡារំ បុព្ពេជាបរំ វិសេសំ ជានន្តិ[២] ។

ចំណែកកិក្ខុថ្មីៗ ទាំងអម្បាលនោះ កាលដែលកិក្ខុទាំងឡាយជាព្រះថេរៈ កំពុងទូន្មាន ប្រៀនប្រដៅ ក៏ដឹងគុណវិសេសជាឱឡារិកជាខ្លាំង លើសជាងខាងដើមទៅទៀត ។

[១៤៥] តេន ខោ បន សមយេន ភគវា តទហុចោសថេ បណ្ណរសេ បវារណាយ បុណ្ណាយ បុណ្ណមាយ រត្តិយា កិក្ខុសង្ឃបរិវុតោ អព្ភោកាសេ និសិន្នោ ហោតិ ។

សម័យនោះឯង ព្រះមានព្រះភាគ ដែលមានកិក្ខុសង្ឃចោមរោម ទ្រង់គង់ក្នុងទីវាលស្រឡះ នាថ្ងៃ ១៥កើត (ខែ អស្សុជ) ថ្ងៃនោះជាថ្ងៃឧបោសថ គឺជាថ្ងៃបវារណាដ៏បរិបូរណ៌ ក្នុងរាត្រីមានព្រះចន្ទ្រពេញវង់ ។

អថ ខោ ភគវា តុណ្ហីភូតំ តុណ្ហីភូតំ កិក្ខុសង្ឃំ អនុវិលោកេត្វា កិក្ខូ អាមន្តេសិ "អារទ្ធោស្មិ, កិក្ខវេ, ឥមាយ បដិបទាយ; អារទ្ធចិត្តោស្មិ, កិក្ខវេ, ឥមាយ បដិបទាយ ។ តស្មាតិហ, កិក្ខវេ, កិយ្យោសោមត្តាយ

---

២ *កំ. ស្យា. បជានន្តិ , ក. សញ្ញានន្តិ ។*

វីរិយំ អារភថ អប្បត្តស្ស បត្តិយា, អនធិកតស្ស អធិកមាយ, អសច្ឆិកតស្ស សច្ឆិកិរិយាយ។ ឥធេវាហំ សាវត្ថិយំ កោមុទឹ ចាតុមាសិនឹ អាកមេស្សាមី"តិ ។

លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ទតមើលភិក្ខុសង្ឆ ដែលអង្គុយនៅស្ងៀម ហើយទ្រង់មានព្រះតម្រាស់នឹងភិក្ខុសង្ឆថា "ម្នាលភិក្ខុសង្ឆទាំងឡាយ តថាគតត្រេកអរ ចំពោះបដិបទានេះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរប្រារព្ធនូវសេចក្តីព្យាយាម ឲ្យលើសជាងប្រមាណចុះ ដើម្បីឲ្យដល់ធម៌ ដែលខ្ជួនមិនទាន់ដល់, ដើម្បីសម្រេចធម៌ ដែលខ្ជួនមិនទាន់បានសម្រេច, ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលខ្ជួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ ។ តថាគតនឹងរង់ចាំអ្នកទាំងឡាយក្នុងក្រុងសាវត្ថីនេះឯង អស់ទីបំផុតនៃខែបួន ដែលជាកាលមានផ្កាកុមុទរីក (ផ្កាឈូករីក ក្នុងខែកត្តិក១៥កើត)" ។

អស្សោសុំ ខោ ជានបទា ភិក្ខូ "ភតវា កិរ តត្ថេវ សាវត្ថិយំ កោមុទឹ ចាតុមាសិនឹ អាកមេស្សតី"តិ ។

ព្រះភិក្ខុទាំងឡាយនៅក្នុងជនបទ បានឮដំណឹងថា ព្រះមានព្រះភាគនឹងរង់ចាំនៅក្នុងក្រុងសាវត្ថីនោះឯង អស់ទីបំផុតនៃខែបួន ដែលជាកាលមានផ្កាកុមុទរីក ។

តេ ជានបទា ភិក្ខូ សាវត្ថឹ[3] ឱសរន្តិ ភតវន្តំ ទស្សនាយ។

ទើបភិក្ខុអ្នកនៅក្នុងជនបទទាំងនោះ ប្រជុំគ្នាក្នុងក្រុងសាវត្ថី ដើម្បីបានចូលទៅគាល់ព្រះមានព្រះភាគ ។

តេ ច ខោ ថេរា ភិក្ខូ ភិយ្យោសោមត្តាយ នវេ ភិក្ខូ ឱវទន្តិ អនុសាសន្តិ។

ចំណែកភិក្ខុទាំងឡាយ ជាព្រះថេរៈនោះ ក៏ទូន្មាន ប្រៀនប្រដៅដល់ពួក

---

[3] ស្យា. កំ. បី. ក. សាវត្ថិយំ ។

ភិក្ខុថ្មីៗ ឲ្យលើសជាងប្រមាណ (គឺជាងមុន) ។

អប្បេកចេ ថេរា ភិក្ខូ ឧសបិ ភិក្ខូ ឱវឧន្តិ អនុសាសន្តិ, អប្បេកចេ ថេរា ភិក្ខូ រីសម្បិ ភិក្ខូ ឱវឧន្តិ អនុសាសន្តិ, អប្បេកចេ ថេរា ភិក្ខូ តឹសម្បិភិក្ខូ ឱវឧន្តិ អនុសាសន្តិ, អប្បេកចេ ថេរា ភិក្ខូ ចត្តារីសម្បិ ភិក្ខូ ឱវឧន្តិ អនុសាសន្តិ។

ភិក្ខុជាព្រះថេរ:ពួកខ្ងះ ទូន្មាន ប្រៀនប្រដៅភិក្ខុ ១០ រូបក៏មាន, ភិក្ខុជាព្រះថេរ:ពួកខ្ងះ ទូន្មាន ប្រៀនប្រដៅភិក្ខុ ២០ រូបក៏មាន, ភិក្ខុជាព្រះថេរ:ពួកខ្ងះ ទូន្មាន ប្រៀនប្រដៅភិក្ខុ ៣០ រូបក៏មាន, ភិក្ខុជាព្រះថេរ:ពួកខ្ងះ ទូន្មាន ប្រៀនប្រដៅភិក្ខុ ៤០ រូបក៏មាន ។

តេ ច នវា ភិក្ខូ ថេរេហិ ភិក្ខូហិ ឱវឧិយមានា អនុសាសិយមានា ឧឡារំ បុព្វេនាបរំ រិសេសំ ជានន្តិ ។

ចំណែកភិក្ខុថ្មីៗ ទាំងនោះ កាលដែលពួកភិក្ខុជាព្រះថេរ: កំពុងទូន្មាន ប្រៀនប្រដៅ ក៏ដឹងនូវគុណវិសេសជាឱឡារិកជាខ្ងាំង លើសជាងខាងដើម ទៅទៀត ។

[៧៤៦] **តេន ខោ បន សមយេន ភគវា តឧហុចោសថេ បណ្ណរសេ កោមុឧិយា ចាតុមាសិនិយា បុណ្ណាយ បុណ្ណមាយ រត្តិយា ភិក្ខុសង្ឆ-បរិវុតោ អញ្ភោកាសេ និសិន្នោ ហោតិ ។**

ក៏សម័យនោះឯង ព្រះមានព្រះភាគ ដែលមានភិក្ខុសង្ឆចោមរោម ទ្រង់គង់នៅក្នុងទីវាល ក្នុងរាត្រីមានព្រះចន្ទ្រពេញវង់ ជារាត្រីដែលមានរដូវភ្ជៀងគ្រប់គ្រាន់ហើយ ជាទីបំផុតនៃខែបួន ជាកាលមានផ្កាកុមុទរីក ថ្ងៃនោះជាថ្ងៃឧបោសថទី ១៥ កើត (ខែ កត្តិក) គឺថ្ងៃពេញបូណ៌មី ។

អថ ខោ ភគវា តុណ្ហីភូតំ តុណ្ហីភូតំ ភិក្ខុសង្ឆំ អនុវិលោកេត្វា

កិក្ខូ អាមន្តេសិ "អបលាចាយំ, កិក្ខវេ, បរិសា; និប្បលាចាយំ, កិក្ខវេ, បរិសា; សុទ្ធា សារេ[៤] បតិដ្ឋិតា ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ទតមើលកិក្ខុសង្ឃ ដែលអង្គុយនៅស្ងៀម ហើយបានត្រាស់នឹងកិក្ខុសង្ឃទាំងឡាយថា ម្នាលកិក្ខុទាំងឡាយ បរិស័ទនេះសូប់ស្ងាត់ហើយ ម្នាលកិក្ខុទាំងឡាយ បរិស័ទនេះសូប់ស្ងាត់ចាកការចរចា ហើយឋិតនៅក្នុងធម៌ដែលជាខ្លឹមសារដ៏បរិសុទ្ធ ។

តថារូចោ អយំ, កិក្ខវេ, កិក្ខុសង្ឃោ; តថារូចា អយំ, កិក្ខវេ, បរិសា យថារូចា បរិសា អាហុនេយ្យា ចាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករណីយា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។

បរិស័ទមានសភាពយ៉ាងណា ដែលគួរដល់ការបូជា គួរដល់អាគន្តុកទាន គួរដល់ទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ម្នាលកិក្ខុទាំងឡាយ កិក្ខុសង្ឃនេះ មានសភាពយ៉ាងនោះ ម្នាលកិក្ខុទាំងឡាយ បរិស័ទនេះ ក៏មានសភាពយ៉ាងនោះដែរ ។

តថារូចោ អយំ, កិក្ខវេ, កិក្ខុសង្ឃោ; តថារូចា អយំ, កិក្ខវេ, បរិសា យថារូចាយ បរិសាយ អប្បំ ទិន្នំ ពហុ ហោតិ, ពហុ ទិន្នំ ពហុតរំ ។

ទានតិចតួច ដែលបុគ្គលឲ្យហើយ ទៅជាទានមានផលច្រើន ឬទានច្រើន ដែលបុគ្គលឲ្យហើយ ក៏រឹងរឹតតែមានផលច្រើន ក្នុងបរិស័ទមានសភាពយ៉ាងណា ម្នាលកិក្ខុទាំងឡាយ កិក្ខុសង្ឃនេះ ក៏មានសភាពយ៉ាងនោះ ម្នាលកិក្ខុទាំងឡាយ បរិស័ទនេះ ក៏មានសភាពយ៉ាងនោះដែរ ។

តថារូចោ អយំ, កិក្ខវេ, កិក្ខុសង្ឃោ; តថារូចា អយំ, កិក្ខវេ, បរិសា យថារូចា បរិសា ទុល្លភា ទស្សនាយ លោកស្ស ។

បរិស័ទមានសភាពយ៉ាងណា ដែលសត្វលោកបានឃើញដោយក្រ

---

៤ ស្យា. កំ. បី. សុទ្ធសារេ បតិដ្ឋិតា ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះ ក៏មានសភាពយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ ក៏មានសភាពយ៉ាងនោះដែរ ។

តថារូចោ អយំ, ភិក្ខវេ, ភិក្ខុសង្ឃោ; តថារូចា អយំ, ភិក្ខវេ, បរិសា យថារូបំ បរិសំ អលំ យោជនកណានានិ ឧស្សនាយ តន្តុំ បុដោសេ-នាបិ"(៥) ។

បរិស័ទមានសភាពយ៉ាងណា ដែលបុគ្គលគួរស្ពាយស្បៀង ដើរតាមរកមើលអស់ទីរាប់ដោយយោជន៍ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះក៏មានសភាពយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ ក៏មានសភាពយ៉ាងនោះដែរ ។

[១៤៧] **"សន្តិ, ភិក្ខវេ, ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ អរហន្តោ ខីណាសវា វុសិតវន្តោ កតករណីយា ឱហិតភារា អនុប្បត្តសទត្តា បរិក្ខី-ណភវសំយោជនា សម្មទញ្ញាវិមុត្តា ឯវរូចាបិ, ភិក្ខវេ, សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ។**

ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ តែងមានពួកភិក្ខុជាអរហន្ត ខីណាស្រព មានព្រហ្មចរិយធម៌នៅរួចហើយ បានធ្វើកិច្ចដែលគួរធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ចំពោះខ្លួនសម្រេចហើយ មានសំយោជនៈក្នុងភពអស់ហើយ មានចិត្តផុតវិសេសហើយ ព្រោះដឹងដោយប្រពៃ, ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមាននៅក្នុងភិក្ខុសង្ឃនេះ ។

សន្តិ, ភិក្ខវេ, ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបចាតិកា តត្ត បរិនិព្ធាយិនោ អនាវត្តិធម្មា តស្មា លោកា ឯវរូចាបិ, ភិក្ខវេ, សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ។

ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាឱបបាតិកៈកំណើត

---

៥ សី. បី. ក. បុដោសេនាបិ, តថារូ-បោ អយំ ភិក្ខវេ ភិក្ខុសំឃោ, តថារូបា អយំ បរិសា ។

ហើយ បរិនិព្វានក្នុងលោកនោះ មិនវិលត្រឡប់ចាកលោកនោះមកវិញឡើយ (គឺសុទ្ធាវាសព្រហ្ម ជាទីកន្លែងកើតរបស់ព្រះអនាគាមី ដែលមានព្រហ្ម៥ពួក ១.អវិហា ២.អតប្បា ៣.សុទស្សា ៤.សុទស្សី ៥.អកនិដ្ឋា) ព្រោះអស់សំយោជន: ជាចំណែកខាងក្រោម ៥, ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមាននៅក្នុងភិក្ខុសង្ឃនេះ។

សន្តិ, ភិក្ខវេ, ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ តិណ្ណំ សំយោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិនោ សកិទេវ[6] ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សន្តិ ឯវម្បិ, ភិក្ខវេ, សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ។

ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានភិក្ខុជាសកទាគាមី នឹងមកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតនៃទុក្ខបាន ព្រោះអស់សំយោជន: ៣ ព្រោះមានរាគៈទោស: និងមោហៈស្រាលស្តើង, ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមាននៅក្នុងភិក្ខុសង្ឃនេះ។

សន្តិ, ភិក្ខវេ, ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ តិណ្ណំ សំយោជនានំ បរិក្ខយា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណា ឯវម្បិ, ភិក្ខវេ, សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ។

ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាសោតាបន្ន: មានសភាពមិនធ្លាក់ចុះទៅក្នុងអបាយភូមិ ជាបុគ្គលទៀង មានសម្ពោធិញ្ញាណប្រព្រឹត្តទៅខាងមុខ ព្រោះអស់សំយោជន: ៣, ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមាននៅក្នុងភិក្ខុសង្ឃនេះ។

``សន្តិ, ភិក្ខវេ, ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ចតុន្នំ សតិប្បដ្ឋានានំ ភាវនានុយោគមនុយុត្តា វិហរន្តិ ឯវម្បិ, ភិក្ខវេ, សន្តិ ភិក្ខូ ឥមស្មឹ

---

៦ ក. សកឹទេវ ។

កិក្ខុសង្ឃេ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកបរឿយៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវសតិប្បដ្ឋាន ៤ សម្រាន្តនៅដោយឥរិយាបថទាំង ៤, ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមាននៅក្នុងភិក្ខុសង្ឃនេះ ។

សន្តិ, ភិក្ខវេ, ភិក្ខូ ឥមស្មឹ កិក្ខុសង្ឃេ ចតុន្នំ សម្មប្បធានានំ ភាវនានុយោគមនុយុត្តា វិហរន្តិ។...បេ...។ ចតុន្នំ ឥទ្ធិបាទានំ... បញ្ចន្នំ ឥន្ទ្រិយានំ... បញ្ចន្នំ ពលានំ... សត្តន្នំ ពោជ្ឈង្គានំ... អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ភាវនានុយោគមនុយុត្តា វិហរន្តិ ឯវម្បិ, ភិក្ខវេ, សន្តិ ភិក្ខូ ឥមស្មឹ កិក្ខុសង្ឃេ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកបរឿយៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវសម្មប្បធាន ៤ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។...ល...។ ឥទ្ធិបាទទាំង ៤... ឥន្ទ្រិយទាំង ៥... ពលៈទាំង ៥... ពោជ្ឈង្គទាំង ៧... ជាអ្នកប្រកបរឿយៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវមគ្គ ប្រកបដោយអង្គ ៨ ដ៏ប្រសើរ សម្រាន្តនៅដោយឥរិយាបថទាំង ៤, ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមាននៅក្នុងភិក្ខុសង្ឃនេះ ។

សន្តិ, ភិក្ខវេ, ភិក្ខូ ឥមស្មឹ កិក្ខុសង្ឃេ មេត្តាភាវនានុយោគមនុយុត្តា វិហរន្តិ...ករុណាភាវនានុយោគមនុយុត្តា វិហរន្តិ... មុទិតាភាវនានុយោគមនុយុត្តា វិហរន្តិ... ឧបេក្ខាភាវនានុយោគមនុយុត្តា វិហរន្តិ... អសុភភាវនានុយោគមនុយុត្តា វិហរន្តិ... អនិច្ចសញ្ញាភាវនានុយោគមនុយុត្តា វិហរន្តិ ឯវម្បិ, ភិក្ខវេ, សន្តិ ភិក្ខូ ឥមស្មឹ កិក្ខុសង្ឃេ។

ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកបរឿយៗ

នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវមេត្តា សម្រាន្តនៅដោយឥរិយាបថទាំង ៤..., ជាអ្នកប្រកបរឿយៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវករុណា សម្រាន្តនៅដោយឥរិយាបថទាំង ៤..., ជាអ្នកប្រកបរឿយៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវមុទិតា សម្រាន្តនៅដោយឥរិយាបថទាំង ៤..., ជាអ្នកប្រកបរឿយៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវឧបេក្ខា សម្រាន្តនៅដោយឥរិយាបថទាំង ៤..., ជាអ្នកប្រកបរឿយៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវអសុភៈ សម្រាន្តនៅដោយឥរិយាបថទាំង ៤..., ជាអ្នកប្រកបរឿយៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវអនិច្ចសញ្ញា សម្រាន្តនៅដោយឥរិយាបថទាំង ៤, ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមាននៅក្នុងភិក្ខុសង្ឃនេះ។

សន្តិ, ភិក្ខវេ, ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ អានាបានស្សតិភាវនានុយោគមនុយុត្តា វិហរន្តិ។

ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកបរឿយៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវអានាបានស្សតិ សម្រាន្តនៅដោយឥរិយាបថទាំង ៤។

អានាបានស្សតិ, ភិក្ខវេ, ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា។

ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗហើយ រមែងមានផលច្រើន និងមានអានិសង្សច្រើន។

អានាបានស្សតិ, ភិក្ខវេ, ភាវិតា ពហុលីកតា ចត្តារោ សតិបដ្ឋានេ បរិបូរេតិ។

ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងសតិប្បដ្ឋានទាំង ៤ ឲ្យពេញបរិបូរណ៌បាន។

ចត្តារោ សតិបដ្ឋានា ភាវិតា ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ។

សតិប្បដ្ឋានទាំង ៤ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗហើយ រមែងញុំាងពោជ្ឈង្គទាំង ៧ ឲ្យពេញបរិបូរណ៌បាន ។

សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តឹ បរិបូរេន្តិ។

ពោជ្ឈង្គទាំង ៧ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ រមែងញុំាងវិជ្ជា(គឺមគ្គ) និងវិមុត្តិ(គឺផល)ឲ្យពេញបរិបូរណ៌បាន ។

[๑๔๘] **``កថំ ភាវិតា ច, ភិក្ខវេ, អានាបានស្សតិ កថំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា?**

ម្នាលភិក្ខុទាំងឡាយ ក៏អានាបានស្សតិ ដែលបុគ្គលបានចម្រើន និងបានធ្វើឲ្យរឿយៗ ហើយ តើដូចម្តេច? ទើបមានផលច្រើន និងមានអានិសង្សច្រើន ។

ឥធ, ភិក្ខវេ, ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា។

*ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ទៅកាន់ម្លប់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី រួចហើយអង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ **ហើយតម្កល់សតិ ឲ្យមានមុខឆ្ពោះទៅរកព្រះកម្មដ្ឋាន (គឺតម្កល់សតិ នៅត្រង់ចុងច្រមុះ ឬផ្នែបបូរមាត់ខាងលើ)** ។*

សោ សតោវ អស្សសតិ សតោ បស្សសតិ ។

ព្រះយោគាវចរភិក្ខុនោះ ជាអ្នកមានសតិតម្កល់(នៅត្រង់ចុងច្រមុះ ឬផ្នែបបូរមាត់ខាងលើ) ខណៈដកដង្ហើមចូល កំណត់ដឹងថាចូល, ជាអ្នកមានសតិតម្កល់(នៅត្រង់ចុងច្រមុះ ឬផ្នែបបូរមាត់ខាងលើ) ខណៈដកដង្ហើមចេញ កំណត់

ដឹងថាចេញ ។

១. កាយានុបស្សនា

១. ទីឃំ វា អស្សសន្តោ "ទីឃំ អស្សសាមី"តិ បជានាតិ។

ព្រះយោគាវចរភិក្ខុនោះ កាលដកដង្ហើមចូលវែង ក៏កំណត់ដឹងច្បាស់ថា "អាត្មាអញ ជាអ្នកដកដង្ហើមចូលវែង" ។

ទីឃំ វា បស្សសន្តោ "ទីឃំ បស្សសាមី"តិ បជានាតិ ។

កាលដកដង្ហើមចេញវែង ក៏កំណត់ដឹងច្បាស់ថា "អាត្មាអញ ជាអ្នកដកដង្ហើមចេញវែង" ។

២. រស្សំ វា អស្សសន្តោ "រស្សំ អស្សសាមី"តិ បជានាតិ ។

កាលដកដង្ហើមចូលខ្លី ក៏កំណត់ដឹងច្បាស់ថា "អាត្មាអញ ជាអ្នកដកដង្ហើមចូលខ្លី" ។

រស្សំ វា បស្សសន្តោ "រស្សំ បស្សសាមី"តិ បជានាតិ ។

កាលដកដង្ហើមចេញខ្លី ក៏កំណត់ដឹងច្បាស់ថា "អាត្មាអញ ជាអ្នកដកដង្ហើមចេញខ្លី" ។

៣. "សព្ពកាយប្បដិសំវេទី អស្សសិស្សាមី"តិ សិក្ខតិ ។

ភិក្ខុរមែងសិក្សាថា "អាត្មាអញ នឹងជាអ្នកកំណត់ដឹងឱ្យជាក់ច្បាស់ នូវកាយ គឺខ្យល់ដង្ហើមចូលទាំងអស់ ជាចំណែកៗ ដោយល្អ(គឺខាងដើម កណ្តាល និងខាងចុងរបស់ខ្យល់) ក្នុងខណៈដកដង្ហើមចូល" ។

"សព្ពកាយប្បដិសំវេទី បស្សសិស្សាមី"តិ សិក្ខតិ ។

កេចិ បន "និយ្យានន្តិ មគ្គោ"តិ វទន្តិ។

ចំណែក **កេចិ** *អាចារ្យបានពោលថា "ពាក្យថា* ***ធម៌ជាគ្រឿងនាំចេញចាកទុក្ខ*** *បានដល់ មគ្គ" ។*

ឥធ ឧបចារស្ស អធិប្បេតត្តា មគ្គក្ខណោ ច អាលោកសញ្ញាយ សព្ភកុសលធម្មានញ្ច អភាវា តំ ន យុជ្ជតិ។

ព្រោះក្នុងទីនេះ លោកប្រាថ្នាយក **ឧបចារ** *ព្រោះក្នុងខណៈនៃមគ្គមិនមាន* **អាលោកសញ្ញា** *និងកុសលធម៌ទាំងឡាយ* ***ពាក្យនោះ*** *ទើបមិនត្រឹមត្រូវ។*

"និវុតត្តា"តិ បដិច្ឆន្នត្តា។

ពាក្យថា ***"ព្រោះត្រូវអកុសលធម៌ទាំងនោះបិទបាំងទុក"*** *មានន័យថា ព្រោះត្រូវអកុសលធម៌ទាំងនោះបិទបាំងទុកហើយ ។*

"ឧប្បជ្ជាជាតី"តិ បុគ្គលវសេន វុត្តំ។

ពាក្យថា ***"រមែងមិនដឹងច្បាស់"*** *លោកពោលថា ជាប់តៗគ្នាដោយបុគ្គល ។*

"វិសុទ្ធចិត្តស្សា"តិ ឧបចារភូមិយំយេវ។

*ពាក្យថា **"អ្នកមានចិត្តបរិសុទ្ធ"** គឺនៅក្នុងឧបចារភូមិនោះឯង ។*

"ខណិកសមោធានា"តិ ចិត្តក្ខណោ ចិត្តក្ខណោ ឧប្បជ្ជនតោ ខណោ ឯតេសំ អត្ថីតិ ខណិកា, ឧបក្កិលេសា, ខណិកានំ សមោធានោ សមាគមោ បពន្ធោ ខណិកសមោធានោ។

*បទថា **"ខណិកសមោធានា"** មានន័យថា ខណៈមានឧបក្កិលេសទាំងនោះ ព្រោះកើតឡើងគ្រប់ៗ ខណៈចិត្ត ព្រោះហេតុនោះ ទើបឈ្មោះថា **ខណិក**, បានដល់ ឧបក្កិលេសទាំងឡាយដែលមានគ្រប់ៗខណៈចិត្ត, ការប្រជុំគឺការមករួបរួមគ្នា ដោយអាស្រ័យគ្នានៃឧបក្កិលេសដែលមានគ្រប់ៗខណៈ(ចិត្ត) ឈ្មោះថា **ខណិកសមោធានោ** (ប្រែថា ការប្រជុំនៃឧបក្កិលេសដែលមានគ្រប់ៗ ខណៈចិត្ត) ។*

តស្មា ខណិកសមោធានា, ឧប្បជ្ជមានា ឧបក្កិលេសា ខណិកប្បពន្ធវសេន ខណិកបរម្បរាវសេន ឧប្បជ្ជន្តិ, ន ឯកចិត្តក្ខណវសេនាតិ វុត្តំ ហោតិ។

*មានពាក្យអធិប្បាយថា ព្រោះការប្រជុំនៃឧបក្កិលេសដែលមានគ្រប់ៗខណៈ(ចិត្ត)នោះ, **ឧបក្កិលេស** កាលកើតឡើង រមែងកើតឡើងដោយអំណាចការជាប់តៗគ្នានៃឧបក្កិលេសដែលមានគ្រប់ៗខណៈចិត្ត ដោយអំណាចការអាស្រ័យគ្នានៃកិលេសដែលមានគ្រប់ៗខណៈមិនមែនដោយអំណាចនៃខណៈចិត្តតែមួយនោះទេ។*

សោឡសញ្ញាណនិទ្ទេសវណ្ណនា និដ្ឋិតា។

ការពណ៌នា នូវសោឡសញ្ញាណនិទ្ទេស ចប់ ។

๓. ឧបក្កិលេសញ្ញាណនិទ្ទេសោ

ញ្ញាណទី ๓ ឧបក្កិលេសទាំង ๑๘ ញ្ញាណ (បិដក ๗๐) [๗๓]

(ឧបក្កិលេសញ្ញាណមាន១៨ យ៉ាង ជាគ្រឿងសៅហ្មងរបស់សមាធិ ដែលធ្វើឲ្យសមាធិមិនអាចរីកចម្រើនទៅមុខបាន)

បឋមចតុក្កំ

បឋមចតុក្កទី ๑ មាន ๖ ញ្ញាណ

[๑๙๔] **កតមេ អដ្ឋារស ឧបក្កិលេសា ឧប្បជ្ជន្តិ?**

តើឧបក្កិលេសញ្ញាណទាំង ១៨ យ៉ាងនោះ កើតឡើង ដូចម្តេច?

๑. **អស្សាសាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆតោ**

កាលយោគីកិក្ខុ ផ្ចង់សតិស្មារតី ទៅតាមខ្យល់ដង្ហើមចូល ខាងដើម (គឺត្រង់ចុងច្រមុះ), កណ្តាល(គឺត្រង់បេះដូង), និងខាងចុង(គឺត្រង់ផ្ចិត), [๑๓]

អជ្ឈត្តវិក្ខេបកតំ ចិត្តំ សមាធិស្ស បរិបន្ថោ។

ចិត្តដែលរាយមាយ ទៅកាន់ខ្យល់ដង្ហើមខាងក្នុង(បែបនេះ) ជាការអន្តរាយដល់សមាធិ។

๒. **បស្សាសាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆតោ**

កាលយោគីកិក្ខុ ផ្ចង់សតិស្មារតី ទៅតាមខ្យល់ដង្ហើមចេញ ខាងដើម (គឺត្រង់ផ្ចិត), កណ្តាល(គឺត្រង់បេះដូង), និងខាងចុង(គឺត្រង់ចុងច្រមុះ),

ពហិទ្ធាវិក្ខេបកតំ ចិត្តំ សមាធិស្ស បរិបន្ថោ។

ចិត្តដែលរាយមាយ ទៅកាន់ខ្យល់ដង្ហើមខាងក្រៅ(បែបនេះ)ជាការ

---

๑๓ *(អដ្ឋកថា បដិសម្ភិទា និង ដីការិសុទ្ធិមគ្គ)។*

អន្តរាយដល់សមាធិ ។

៣. អស្សាសបដិកង្ខាជា និកន្តិ តណ្ហាចរិយា សមាធិស្ស បរិបន្ថោ។

សេចក្តីប្រាថ្នាចំពោះខ្យល់ដង្ហើមចូល (គឺការធ្វើឲ្យខ្យល់វែង ខ្លី ល្អិត ឲ្យស្ងប់ជាដើម ដែលខ្យល់នោះខុសពីធម្មជាតិរបស់វា) មានសេចក្តីត្រេកអរត្រេកត្រអាល (ជាប់ជំពាក់ក្នុងខ្យល់ដែលកំពុងមានសេចក្តីសុខ) មានការប្រព្រឹត្តិទៅនៃចំណង់ (ដែលខ្លួនឯងធ្វើបែបនេះ) ជាការអន្តរាយដល់សមាធិ ។

៤. បស្សាសបដិកង្ខាជា និកន្តិ តណ្ហាចរិយា សមាធិស្ស បរិបន្ថោ។

សេចក្តីប្រាថ្នាចំពោះខ្យល់ដង្ហើមចេញ (គឺការធ្វើឲ្យខ្យល់វែង ខ្លី ល្អិត ឲ្យស្ងប់ជាដើម ដែលខ្យល់នោះខុសពីធម្មជាតិរបស់វា) មានសេចក្តីត្រេកអរត្រេកត្រអាល (ជាប់ជំពាក់ក្នុងខ្យល់ដែលកំពុងមានសេចក្តីសុខ) មានការប្រព្រឹត្តិទៅនៃចំណង់ (ដែលខ្លួនឯងធ្វើបែបនេះ) ជាការអន្តរាយដល់សមាធិ ។

៥. អស្សាសេនាភិតុន្នស្ស បស្សាសបដិលាភេ មុច្ឆនា សមាធិស្ស បរិបន្ថោ។

ការជាប់ចិត្តក្នុងការបានចំពោះខ្យល់ដង្ហើមចេញ សម្រាប់បុគ្គលដែលទប់ខ្យល់ដង្ហើមចូល (គឺធ្វើបៀតខ្យល់ដង្ហើម) ជាការអន្តរាយដល់សមាធិ ។

៦. បស្សាសេនាភិតុន្នស្ស អស្សាសបដិលាភេ មុច្ឆនា សមាធិស្ស បរិបន្ថោ។

ការជាប់ចិត្តក្នុងការបានចំពោះខ្យល់ដង្ហើមចូល សម្រាប់បុគ្គលដែលទប់នូវខ្យល់ដង្ហើមចេញ (គឺធ្វើបៀតខ្យល់ដង្ហើម) ជាការអន្តរាយដល់សមាធិ ។

គាថា សរុបឧបក្កិលេសទាំង ๖ ញាណ

អនុកច្ឆនា ច អស្សាសំ, បស្សាសំ អនុកច្ឆនា;
សតិ អជ្ឈត្តវិក្ខេបា, កច្ឆនា ពហិទ្ធាវិក្ខេបបត្តនា[๑๔] ។
អស្សាសេនាភិតុន្នស្ស, បស្សាសបដិលាភេ មុច្ឆនា;
បស្សាសេនាភិតុន្នស្ស, អស្សាសបដិលាភេ មុច្ឆនា។
ឆ ឯតេ ឧបក្កិលេសា, អានាចានស្សតិសមាធិស្ស;
យេហិ វិក្ខិប្បមានស្ស[๑๕], ជោ ចេ ចិត្តំ វិមុច្ចតិ;
វិមោក្ខំ អប្បជានន្តា, តេ ហោន្តិ បរបត្តិយាតិ។

ប្រសិនបើចិត្តរបស់យោគីភិក្ខុនៅរាយមាយ ហើយមិនទាន់ផុតស្រឡះ (ចាកធម៌ដែលជាសឹកសត្រូវ) គឺឧបក្កិលេសទាំង៦ប្រាយណាទេ ឧបក្កិលេសរបស់អានាបានស្សតិសមាធិនោះមាន ๖ យ៉ាង គឺ សតិស្មារតីដែលទៅតាមខ្យល់ដង្ហើមចូល ๑, សតិស្មារតីដែលទៅតាមខ្យល់ដង្ហើមចេញ ๑, សេចក្តីប៉ុនប៉ងចង់បានខ្យល់ដង្ហើមចូលដែលមានភាពរាយមាយទៅខាងក្នុង ๑, សេចក្តីប្រាថ្នានូវខ្យល់ដង្ហើមចេញ ដែលមានភាពរាយមាយទៅខាងក្រៅ ๑, សេចក្តីត្រេកអរក្នុងការបានខ្យល់ដង្ហើមចេញរបស់អ្នកដែលត្រូវខ្យល់ដង្ហើមចូលទៅចាក់ដោតហើយ ๑, សេចក្តីត្រេកអរក្នុងការបានខ្យល់ដង្ហើមចូល របស់អ្នកដែលត្រូវខ្យល់ដង្ហើមចេញទៅ ចាក់ដោតហើយ ๑, យោគីភិក្ខុទាំងឡាយនោះ កាលដែលមិនទាន់ដឹងច្បាស់នូវសេចក្តីរួចផុត គឺវិមោក្ខ តែងនៅជឿអ្នកដទៃ (គឺ នៅមានអ្នកដទៃជាបច្ច័យ បានដល់ ត្រូវនៅជាមួយគ្រូបាអាចារ្យជាអ្នកបង្រៀន) ។

បឋមច្ឆក្ក ឋិតិ ។

បឋមច្ឆកទី ๑ ចប់ ។

---

๑๔ *ស្យា. វិក្ខេបបន្តនា ។*
๑๕ *ស្យា. វិកម្បមានស្ស ។*

៣. អដ្ឋកថេសុ ឧបក្កិលេសញ្ញាណនិទ្ទេសវណ្ណនា

បឋមច្ឆក្កំ

ពណ៌នាឧបក្កិលេសញ្ញាណនិទ្ទេសក្នុងអដ្ឋកថា បឋមច្ឆក ទី ១

[១៤៤] បឋមច្ឆក្កេ "**អស្សាសាទិមជ្ឈបរិយោសាន**"ន្តិ អព្ភន្តរបរិ-សនវាតស្ស ជាសិកគ្គំ វា មុខនិមិត្តំ វា អាទិ, ហាទយំ មជ្ឈំ, ជាកិ បរិយោសានំ។

*ពាក្យថា "**អស្សាសាទិមជ្ឈបរិយោសានំ** ប្រែថា **ខាងដើម កណ្តាល និងទីបំផុតនៃខ្យល់ដង្ហើមចូល**" នៅក្នុងបឋមច្ឆកបានអធិប្បាយថា ខ្យល់ដង្ហើមចូលខាងក្នុងដែលមានចុងច្រមុះ ឬលើផ្នែបបូរមាត់ខាងលើ នេះជាខាងដើមរបស់ខ្យល់, មានត្រង់បេះដូងជាកណ្តាលរបស់ខ្យល់, និងមានត្រង់ផ្ចិតជាទីបំផុតរបស់ខ្យល់ ។*

តំ តស្ស អាទិមជ្ឈបរិយោសានំ សតិយា អនុគច្ឆតោ យោគិស្ស ហាទយង្គមានុគមនេន ចិត្តំ អជ្ឈត្តំ វិក្ខេបំ គច្ឆតិ, តំ អជ្ឈត្តវិក្ខេបគតំ ចិត្តំ ឯកគ្គតេ អសណ្ឋាហនតោ សមាធិស្ស បរិបន្ថោ។

កាលព្រះយោគីកិក្ខុ ប្រើសតិតាមទៅខាងដើមខ្យល់ កណ្តាលខ្យល់ និងទីបំផុតខ្យល់របស់ខ្យល់ដង្ហើមចូល ខាងក្នុងនោះៗ ចិត្តរមែងដល់នូវភាពរាយមាយខាងក្នុង ដោយសារទៅតាមនៅទីកន្លែងផ្សេងៗគ្នា(ដែលលោកបានហាមរួចមកហើយ), ចិត្តដែលមានភាពរាយមាយខាងក្នុងនោះ ជាការអន្តរាយដល់សមាធិ ព្រោះមិនបានតម្កល់មាំនៅក្នុងទីកន្លែងមួយ (ដែលលោកបានអនុញ្ញាតឲ្យនៅត្រង់ចុងច្រមុះ ឬផ្នែបបូរមាត់ខាងលើ) ។

"**បស្សាសាទិមជ្ឈបរិយោសាន**"ន្តិ ពហិនិក្ខមនវាតស្ស ជាកិ អាទិ,

ហេដ្ឋយំ មជ្ឈំ, ជាសិកគ្គំ វា មុខនិមិត្តំ វា ពហិអាកាសោ វា បរិយោសានំ។

ពាក្យថា **"បស្សាសាទិមជ្ឈបរិយោសានំ** *ប្រែថា* ***ខាងដើមខ្យល់ កណ្តាលខ្យល់ និងទីបំផុតនៃខ្យល់ដង្ហើមចេញ"*** *បានសេចក្តីថា ខ្យល់ដង្ហើមចេញទៅខាងក្រៅ ដែលមានត្រង់ផ្ចិត ជាខាងដើមខ្យល់, មានបេះដូងជាកណ្តាលខ្យល់, និងមានចុងច្រមុះ ឬលើផ្នែបបូរមាត់ខាងលើ ឬថា ដែលមានអាកាសជាខាងក្រៅ ឈ្មោះថា ទីបំផុតរបស់ខ្យល់ ។*

យោគាវចរេន បនេត្ថ វុត្តនយេនេវ វេទិតព្វា។

ពាក្យដែលប្រកបក្នុងសេចក្តីនេះ គប្បីជ្រាបទៅតាមន័យដែលបានពោលមកហើយនោះឯង ។

"អស្សាសបដិកង្ខេន តណ្ហាចរិយា"តិ "ជាសិកាវាតាយត្តមិទំ កម្មដ្ឋាន"ន្តិ សល្លក្ខេត្វា ឱឝ្បរិកោឝ្បរិកស្ស អស្សាសស្ស បត្តនាសង្ខាតា និកាមនា ឯវ តណ្ហាបវត្តិ។

ពាក្យថា ***"អស្សាសបដិកង្ខេន តណ្ហាចរិយា"*** *ប្រែថា "ការប្រព្រឹត្តិទៅនៃតណ្ហា គឺការពេញចិត្តប្រាថ្នាឲ្យបាននូវខ្យល់ដង្ហើមចូល" មានសេចក្តីថា កាលព្រះយោគីកំណត់ថា "កម្មដ្ឋាននេះ អាស្រ័យដោយខ្យល់ដង្ហើមតាមច្រមុះ" ដូច្នេះហើយ មានការប្រាថ្នាប្រព្រឹត្តដោយតណ្ហា គឺការពេញចិត្តពោលគឺការប្រាថ្នានូវខ្យល់ដង្ហើមចូលដែលគ្រោតគ្រាតៗ (គឺការប្រឹងធ្វើខ្យល់ឲ្យចូល ចេញ) ។*

តណ្ហាបវត្តិយា សតិ ឯកត្តេ អសណ្ឋហនតោ សមាធិស្ស បរិបន្ថោ។

កាលប្រព្រឹត្តទៅនៃតណ្ហាបែបនេះ ជាការអន្តរាយដល់សមាធិ ព្រោះមិនតាំងនៅក្នុងសភាពឯកគ្គតាចិត្ត(គឺការមានអារម្មណ៍តែមួយ ក្នុងកន្លែងដែលត្រឹមត្រូវ) ។

"បស្សាសបដិកង្ខនា និកន្តី"តិ បុន អស្សាសបុព្ទកស្ស បស្សាសស្ស បត្ថនាសង្ខាតា និកន្តិ។

*ពាក្យថា "**សេចក្តីពេញចិត្ត គឺការប្រាថ្នានូវខ្យល់ដង្ហើមចេញ**" បានសេចក្តីថា សេចក្តីពេញចិត្តពោលគឺ សេចក្តីប្រាថ្នានូវខ្យល់ដង្ហើមចេញ ដែលមានខ្យល់ដង្ហើមចូលជាខាងដើមទៀត ។*

សេសំ វុត្តនយេនេវ យោជេតព្វំ។

ពាក្យដ៏សេសទៀត គប្បីប្រកបទៅតាមន័យដែលបានពោលទុកមកហើយនោះឯង ។

អស្សាសេនាភិតុន្នស្សាតិ អតិជីឃំ អតិរស្សំ វា អស្សាសំ ករោន្តស្ស អស្សាសមូលកស្ស កាយចិត្តកិលមថស្ស សញ្ជាវតោ តេន អស្សាសេន វិទ្ធស្ស បីឡិតស្ស។

*ពាក្យថា **ត្រូវខ្យល់ដង្ហើមចូលចាក់ដោតហើយ** បានន័យថា **ត្រូវបានខ្យល់ដង្ហើមចូលនោះ ចាក់ដោតហើយ** គឺការចាប់ច្របាច់ហើយ ព្រោះព្រះយោគីបានធ្វើខ្យល់ដង្ហើមចូលឲ្យវែងពេកទៅ ឬក៏ឲ្យខ្លីពេក ដែលមានការលំបាកដល់កាយនិងចិត្ត ដែលមានខ្យល់ដង្ហើមចូលជាមូល (នេះជាហេតុ) ។*

បស្សាសបដិលាភេ មុច្ចនាតិ អស្សាសេន បីឡិតត្តាយេវ បស្សាសេអស្សាឧសញ្ញិនោ បស្សាសំ បត្ថយតោ តស្មឹ បស្សាសបដិ-លាភេ រជ្ជនា។

*ពាក្យថា **ត្រេកអរក្នុងការបានចំពោះនូវខ្យល់ដង្ហើមចេញ** បានន័យថា កាលព្រះយោគី ជាអ្នកមានសេចក្តីសំខាន់ ដោយការត្រេកអរក្នុងខ្យល់ដង្ហើមចេញ ប្រាថ្នាខ្យល់ដង្ហើមចេញ ព្រោះត្រូវខ្យល់ដង្ហើមចូលបានចាប់ច្របាច់ហើយនោះឯង មានសេចក្តីថា ត្រេកអរក្នុងការបានចំពោះនូវខ្យល់ដង្ហើមចេញនោះ ។*

បស្សាសមូលកេបិ ឯសេវ នយោ។

សូម្បីក្នុងព្រះយោគី ជាអ្នកមានខ្យល់ដង្ហើមចេញជាមូល ក៏មាននិ័យបែបនេះដូចគ្នា ។

វុត្តស្សេវ អត្ថស្ស អនុវណ្ណនត្ថំ វុត្តេសុ គាថាពន្ធេសុ អនុតច្ឆជាតិ អនុតច្ឆមានា ។

*វិនិច្ឆ័យ ក្នុងពាក្យដែលលោកបានចងទុកជាគាថា ត្រង់សេចក្តីដែលលោកពោលទុកដើម្បីប្រាថ្នាឲ្យទៅតាមលំដាប់ នូវអត្ថសេចក្តីដូចដែលបានពោលមកហើយនោះឯង ត្រង់បទថា **អនុតច្ឆជា** ប្រែថា **តាមទៅ** ។*

"សតី"តិ អជ្ឈត្តពហិទ្ធាវិក្ខេបហេតុភូតា សតិ ។

*បទថា "**សតិ**" បានដល់ សតិដែលមានសភាពមិនរាយមាយ ទៅខាងក្នុងនិងទៅខាងក្រៅឡើយ ។*

"វិក្ខិប"តិ អនេន ចិត្តន្តិ វិក្ខេចោ។

*ឈ្មោះថា "**វិក្ខេប**" ដោយអត្ថថា ជាហេតុរាយមាយនៃចិត្ត ។*

កោ សោ? អស្សាសោ។

វិក្ខេប *នោះ គឺជាអ្វី? នោះគឺជាខ្យល់ដង្ហើមចូល ។*

(សោ) អជ្ឈត្តំ វិក្ខេចោ អជ្ឈត្តវិក្ខេចោ, តស្ស អាកឌ្ឍនា អជ្ឈត្តវិក្ខេចាកឌ្ឍនា, អសម្មាមនសិការវសេន អជ្ឈត្តវិក្ខេបកស្ស អស្សាសស្ស អាកឌ្ឍនាតិ វុត្តំ ហោតិ។

*ខ្យល់ដង្ហើមចូល ដែលមានភាពរាយមាយទៅខាងក្នុងនោះ ឈ្មោះថា អជ្ឈត្តវិក្ខេប, ជាសេចក្តីប្រាថ្នាចង់បាននូវខ្យល់ដង្ហើមចូល ដែលមានភាពរាយមាយទៅខាងក្នុងនោះ ឈ្មោះថា **អជ្ឈត្តវិក្ខេចាកឌ្ឍនា**, មានសេចក្តីតាំងចិត្ត (ភាពចង់បាន) នូវខ្យល់ដង្ហើមចូលមានការរាយមាយទៅខាងក្នុង*

ដោយអំណាចមនសិការដែលពេញចិត្ត ។

ឯតេនេវ នយេន ពហិទ្ធាវិក្ខេបបត្តា វេទិតព្វា។

គប្បីជ្រាបនូវសេចក្តីប្រាថ្នាខ្សល់ដង្ហើមចេញ ដែលមានការរាយមាយទៅខាងក្រៅតាមន័យដូចគ្នា ។

"យេហី"តិ យេហិ ឧបក្កិលេសេហិ។

*បទថា "**យេហិ**" ប្រែថា ដែលឧបក្កិលេសទាំងឡាយ ពួកណា ។*

"វិក្ខិប្បមានស្ស"តិ វិក្ខិបិយមានស្ស វិក្ខេបំ អាចាទិយមានស្ស។

*បទថា "**វិក្ខិប្បមានស្ស**" មានន័យថា ត្រូវបានឧបក្កិលេសពួកណាឲ្យរាយមាយ គឺឲ្យដល់នូវភាពរាយមាយ ។*

"នោ ច ចិត្តំ វិមុច្ចតី"តិ ចិត្តំ អស្សាសបស្សាសារម្មណោ ច ជាតិមុច្ចតិ, បច្ចនីកធម្មេហិ ច ន វិមុច្ចតិ។

*ពាក្យថា "**នោ ច ចិត្តំ វិមុច្ចតិ**" មានន័យថា ចិត្តមិនបង្អោនទៅក្នុងអារម្មណ៍ គឺខ្សល់ដង្ហើមចូល និងខ្សល់ដង្ហើមចេញ, នឹងមិនផុតអំពីធម៌ដែលជាសឹកសត្រូវ ។*

"ចិត្តំ នោ ច វិមុច្ចតិ បរបត្តិយា ច ហោន្តី"តិ សម្ពន្ធោ។

សេចក្តីថា "ចិត្តរមែងមិនរួចផុត បុគ្គលទាំងឡាយនោះ រមែងប្រព្រឹត្តទៅដើម្បីជឿបុគ្គលដទៃ" ។

"វិមោក្ខំ អប្បជានន្តា"តិ សោ វា អញ្ញោ វា អារម្មណាធិមុត្តិវិមោក្ខញ្ច បច្ចនីកវិមុត្តិវិមោក្ខញ្ច ឯវំ អប្បជានន្តា។

*ពាក្យថា "**មិនដឹងច្បាស់នូវវិមោក្ខ**" មានន័យថា បុគ្គលនោះក្តី បុគ្គលដទៃក្តី មិនដឹងច្បាស់នូវវិមោក្ខ គឺអារម្មណ៍វិមុត្តិ (ការបង្អោនទៅក្នុងអារម្មណ៍) និង*

វិមោក្ខ គឺបច្ចនីកវិមោក្ខ (ការរួចផុតអំពីធម៌ដែលជាសឹកសត្រូវ) យ៉ាងនេះ ។

"បរបត្តិយា"តិ បរបច្ចយំ បរសទ្ធហនំ អរហន្តិ, ន អត្តបច្ចក្ខំ ញាណន្តិ "បរបច្ចយិកា"តិ វត្តព្វេ "បរបត្តិយា"តិ វុត្តំ។

*ពាក្យថា "**ជឿបុគ្គលដទៃ**" មានសេចក្តីថា រមែងនៅមានបុគ្គលដទៃជាបច្ច័យ គឺត្រូវនៅអាស្រ័យជាមួយគ្រូអាចារ្យ, មិនមែនជាញាណដែលប្រចក្សច្បាស់ដល់ខ្លួនឯង ព្រោះហេតុនោះ កាលនឹងពោលថា "**បរប្បច្ចយិកា**" លោកពោលលះចោលថា "**បរបត្តិយា**"។*

អត្តោ បន សោយេវ ។

ចំណែកអត្ត មួយនោះ នុ៉ះឯង ។

បឋមច្ចក្ក និដ្ឋិតា ។

បឋមច្ចក្កទី ១ ចប់ ។

ទុតិយច្ចក្កំ

ទុតិយច្ចក្កទី ២ មាន ៦ ញាណ (បិដក ៧០) [៧៤]

[១៤៤]

១. **និមិត្តំ អាវជ្ជតោ អស្ឡាសេ ចិត្តំ វិកម្បតិ, សមាធិស្ឡ បរិបន្ថោ។**

កាលយោគីភិក្ខុកំពុងនឹកគិតនូវនិមិត្ត(គឺចុងច្រមុះ ឬផ្ទៃបបូរមាត់ខាងលើ) ចិត្តរមែងញាប់ញ័រនៅក្នុងខ្យល់ដង្ហើមចូល, ជាការអន្តរាយដល់សមាធិ ។

២. **អស្សាសំ អាវជ្ជតោ និមិត្តេ ចិត្តំ វិកម្បតិ, សមាធិស្ស បរិបន្ថោ។**

កាលយោគីកិក្ខុកំពុងនឹកគិតដល់ខ្យល់ដង្ហើមចូល ចិត្តរមែងញាប់ញ័រនៅក្នុងនិមិត្ត, ជាការអន្តរាយដល់សមាធិ។

៣. **និមិត្តំ អាវជ្ជតោ បស្សាសេ ចិត្តំ វិកម្បតិ, សមាធិស្ស បរិបន្ថោ។**

កាលយោគីកិក្ខុកំពុងនឹកគិតដល់និមិត្ត (គឺចុងច្រមុះ ឬផ្នែបបូរមាត់ខាងលើ) ចិត្តរមែងញាប់ញ័រនៅក្នុងខ្យល់ដង្ហើមចេញ, ជាការអន្តរាយដល់សមាធិ។

៤. **បស្សាសំ អាវជ្ជតោ និមិត្តេ ចិត្តំ វិកម្បតិ, សមាធិស្ស បរិបន្ថោ។**

កាលយោគីកិក្ខុកំពុងនឹកគិតដល់ខ្យល់ដង្ហើមចេញ ចិត្តរមែងញាប់ញ័រនៅក្នុងនិមិត្ត, ជាការអន្តរាយដល់សមាធិ។

៥. **អស្សាសំ អាវជ្ជតោ បស្សាសេ ចិត្តំ វិកម្បតិ, សមាធិស្ស បរិបន្ថោ។**

កាលយោគីកិក្ខុកំពុងនឹកគិតដល់ខ្យល់ដង្ហើមចូល ចិត្តរមែងញាប់ញ័រនៅក្នុងខ្យល់ដង្ហើមចេញ, ជាការអន្តរាយដល់សមាធិ។

៦. **បស្សាសំ អាវជ្ជតោ អស្សាសេ ចិត្តំ វិកម្បតិ, សមាធិស្ស បរិបន្ថោ។**

កាលយោគីកិក្ខុកំពុងនឹកគិតដល់ខ្យល់ដង្ហើមចេញ ចិត្តរមែងញាប់ញ័រនៅក្នុងខ្យល់ដង្ហើមចូល, ជាការអន្តរាយដល់សមាធិ។

គាថាសរុបឧបក្កិលេសនៅក្នុង ទុតិយចតុក្កទី២ មាន ៦ញាណ

១. **និមិត្តំ អាវជ្ជមានស្ស, អស្សាសេ វិក្ខិបតេ មនោ;**

កាលយោគីកិក្ខុកំពុងនឹកគិតដល់និមិត្ត ចិត្តរមែងញាប់ញ័រក្នុងខ្យល់ដង្ហើមចូល ១,

២. **អស្សាសំ អាវជ្ជមានស្ស, និមិត្តេ ចិត្តំ វិកម្បតិ។**

កាលយោគីកិក្ខុកំពុងនឹកគិតដល់ខ្យល់ដង្ហើមចូល ចិត្តរមែងញាប់ញ័រក្នុងនិមិត្ត ១ ។

៣. និមិត្តំ អារជ្ជមានស្ស, បស្សាសេ វិក្ខិបតេ មនោ។

កាលយោគីកិក្ខុកំពុងនឹកគិតដល់និមិត្ត ចិត្តរមែងញាប់ញ័រក្នុងខ្យល់ដង្ហើមចេញ១។

៤. បស្សាសំ អារជ្ជមានស្ស, និមិត្តេ ចិត្តំ វិកម្បតិ។

កាលយោគីកិក្ខុកំពុងនឹកគិតដល់ខ្យល់ដង្ហើមចេញ ចិត្តរមែងញាប់ញ័រក្នុងនិមិត្ត ១ ។

៥. អស្សាសំ អារជ្ជមានស្ស, បស្សាសេ វិក្ខិបតេ មនោ។

កាលយោគីកិក្ខុកំពុងនឹកគិតដល់ខ្យល់ដង្ហើមចូល ចិត្តរមែងញាប់ញ័រក្នុងខ្យល់ចេញ ១ ។

៦. បស្សាសំ អារជ្ជមានស្ស, អស្សាសេ ចិត្តំ វិកម្បតិ។

កាលយោគីកិក្ខុកំពុងនឹកគិតដល់ខ្យល់ដង្ហើមចេញ ចិត្តរមែងញាប់ញ័រក្នុងខ្យល់ចូល ១ ។

ឆ ឯតេ ឧបក្កិលេសា, អានាបានស្សតិសមាធិស្ស;

យេហិ វិក្ខិប្បមានស្ស, នោ ច ចិត្តំ វិមុច្ចតិ។

ប្រសិនបើ ចិត្តរបស់យោគីកិក្ខុ កាលនៅញាប់ញ័រ មិនទាន់ផុតស្រឡះចាកឧបក្កិលេសទាំងឡាយណាទេ ។ ឧបក្កិលេសទាំងឡាយនោះ របស់អានាបានស្សតិសមាធិមាន ៦ យ៉ាង គឺ៖

វិមោក្ខំ អប្បជានន្តា, តេ ហោន្តិ បរបត្តិយាតិ។

ជនទាំងឡាយនោះ កាលមិនទាន់ដឹងច្បាស់នូវវិមោក្ខ តែងនៅជឿ

អ្នកដទៃ ។

ទុតិយច្ឆក្កំ និដ្ឋិតំ ។

ទុតិយច្ឆក ទី ២ មាន ៦ញាណ ចប់ ។

ទុតិយច្ឆក្កំ

ទុតិយច្ឆក ទី ២ (អដ្ឋកថា)

[១៥៤] **ទុតិយច្ឆក្កេ "និមិត្ត"ន្តិ អស្សាសបស្សាសានំ ផុសនដ្ឋានំ។**

*នៅក្នុងទុតិយច្ឆក:នេះ ត្រង់ពាក្យថា "**និមិត្ត**" បានដល់ ទីកន្លែងដែលសតិពាល់ត្រូវនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ (បានសេចក្តីថា សតិ ដឹងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើចេញ នៅត្រង់ចុងច្រមុះ ឬផ្នែបបូរមាត់ខាងលើត្រង់នោះឯងហៅថា **និមិត្ត** ក្នុងសេចក្តីនេះ) ។*

អស្សាសបស្សាសា ហិ ឱឃជាសិកស្ស ជាសាមុដំ ឃដ្ដេត្វា បវត្តន្តិ, វស្សជាសិកស្ស ឧត្តរោដ្ឋំ។

មែនពិត ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ រមែងពាល់ត្រូវនៅត្រង់ប្រហោងចុងច្រមុះ នេះសំរាប់យោគីកិក្ខុអ្នកមានច្រមុះវែង, និងពាល់ត្រូវនៅត្រង់ផ្នែបបូរមាត់ខាងលើ នេះសំរាប់យោគីកិក្ខុអ្នកមានច្រមុះខ្លី ។

យទិ ហិ អយំ យោគី តំ និមិត្តមេវ អាវជ្ជតិ, តស្ស និមិត្តមេវ អាវជ្ជមានស្ស អស្សាសេ ចិត្តំ វិកម្បតិ, ន បតិដ្ឋាតីតិ អត្ថោ។

ប្រសិនបើ ព្រះយោគីកិក្ខុរូបនេះ គិតដល់និមិត្តនោះ, ចិត្តរបស់ព្រះយោគី

នោះ គឺបានគិតដល់និមិត្តតែម្យ៉ាង ហើយរមែងញាប់ញ័រទៅក្នុងខ្យល់ដង្ហើមចូល, មានន័យថា រមែងមិនតាំងមាំឡើយ ។

តស្ស តស្មឹ ចិត្តេ អប្បតិដ្ឋិតេ សមាធិស្ស អភាវតោ តំ វិកម្បនំ សមាធិស្ស បរិបន្ថោ។

ព្រោះសមាធិមិនមាននៅក្នុងចិត្ត ភាពតាំងមាំរបស់ព្រះយោគីក៏មិនមាន ភាពញាប់ញ័រនៃចិត្ត ក៏កើតមាន ធ្វើឲ្យអន្តរាយដល់សមាធិ ។

យទិ អស្សាសមេវ អាវជ្ជតិ, តស្ស ចិត្តំ អព្ភន្តរបវេសនវសេន វិក្ខេបំ អាវហតិ, និមិត្តេ ន បតិដ្ឋាតិ, តស្មា និមិត្តេ វិកម្បតិ។

ប្រសិនបើ ព្រះយោគីគិតដល់ខ្យល់ដង្ហើមចូលតែម្យ៉ាង, ចិត្តរបស់ព្រះយោគីនោះ ក៏មានភាពរាយមាយ ព្រោះការចូលទៅខាងក្នុង, ហើយមិនបានតាំងនៅត្រង់និមិត្ត, ព្រោះហេតុនោះ ចិត្តរមែងញាប់ញ័រក្នុងនិមិត្ត ។

ឥមិនា នយេន សេសេសុបិ យោជនា កាតព្វា។

សូម្បីនៅក្នុងពាក្យដ៏សេសទៀត ក៏មានន័យសេចក្តីដូចគ្នា ។

គាថាសុ វិក្ខិប្បតេតិ វិក្ខិបីយតិ វិក្ខេបំ អាចាទីយតិ។

ក្នុងគាថា បទថា **វិក្ខិប្បតេ** *ប្រែថា* ***រមែងរាយមាយ*** *គឺ មានភាពរាយមាយ។*

ទុតិយច្ឆក្កំ និដ្ឋិតំ ។

ទុតិយច្ឆក ទី ២ ចប់ ។

តតិយចតុក្កំ

តតិយចតុក្កទី ៣ មាន ៦ ញាណ (បិដក ៧០)

[១៥៦]

១. **អតីតានុជាវនំ ចិត្តំ វិក្ខេចានុបតិតំ , សមាធិស្ស បរិបន្ថោ។**

ចិត្តដែលស្ទុះទៅរកអារម្មណ៍ ជាអតីតហើយធ្លាក់ទៅក្នុងសេចក្តីពយមាយ, ជាការអន្តរាយដល់សមាធិ ។

២. **អនាគតបដិកង្ខំ ចិត្តំ វិកម្បិតំ , សមាធិស្ស បរិបន្ថោ។**

ចិត្តដែលប្រាថ្នារកអារម្មណ៍ទៅអនាគតធ្វើឲ្យញាប់ញ័រ, ជាការអន្តរាយដល់សមាធិ ។

៣. **លីនំ ចិត្តំ កោសជ្ជានុបតិតំ , សមាធិស្ស បរិបន្ថោ។**

ចិត្តរួញរា ដែលធ្លាក់ទៅក្នុងសេចក្តីខ្ជិលច្រអូស, ជាការអន្តរាយដល់សមាធិ ។

៤. **អតិបគ្គហិតំ ចិត្តំ ឧទ្ធច្ចានុបតិតំ , សមាធិស្ស បរិបន្ថោ។**

ចិត្តផ្គងហួសពេក (គឺការតាំងចិត្តព្យាយាមខ្លាំងពេក) ដែលធ្លាក់ទៅក្នុងឧទ្ធច្ច (ការរវើរវាយ), ជាការអន្តរាយដល់សមាធិ ។

៥. **អភិនតំ ចិត្តំ កាកានុបតិតំ , សមាធិស្ស បរិបន្ថោ។**

ចិត្តប្រាកដ (គឺចិត្តដែលបង្ខោនទៅរកអារម្មណ៍) ដែលធ្លាក់ទៅក្នុងរាគៈ, ជាការអន្តរាយដល់សមាធិ ។

៦. **អបនតំ ចិត្តំ ព្យាចាចានុបតិតំ , សមាធិស្ស បរិបន្ថោ។**

ចិត្តមិនប្រាកដ (គឺលះចោលនូវអារម្មណ៍កម្មដ្ឋាន) ដែលធ្លាក់ទៅក្នុង

ញ្ជាបាទ, ជាការអន្តរាយដល់សមាធិ ។

អតីតានុជាវនំ ចិត្តំ, អនាគតបដិកង្ខនំ លីនំ;

អតិបគ្គហិតំ អកិនតំ, អបនតំ ចិត្តំ ន សមាធិយតិ។

ចិត្តដែលស្ទុះទៅរកអារម្មណ៍ជាអតីត: ១, ចិត្តប្រាថ្នារកអារម្មណ៍ទៅអនាគត ១, ចិត្តរួញរា ១, ចិត្តផ្គងហួសពេក ១, ចិត្តប្រាកដ ១, ចិត្តដែលមិនប្រាកដ ១, រមែងមិនតម្កល់មាំឡើយ ។

ឆ ឯតេ ឧបក្កិលេសា, អានាបានស្សតិសមាធិស្ស;

យេហិ ឧបក្កិលិដ្ឋសង្កប្បោ, អធិចិត្តំ ន បជ្ជានាតីតិ។

អាការៈទាំង ៦ យ៉ាងនេះ ជាឧបក្កិលេសដល់អានាបានស្សតិសមាធិ ដែលជាហេតុឲ្យមានសេចក្តី សង្កប្បៈការសៅហ្មង មិនដឹងច្បាស់នូវអធិចិត្ត ។

ចប់ បិដក

(នៅក្នុងញាណឧបក្កិលេសទាំង ១៨ នេះលោកចែកជា ៣ ឆក្កៈ គឺ ៖

១. បឋមឆក្កៈ មាន ៦ ញាណ

២. ទុតិយឆក្កៈ មាន ៦ ញាណ

៣. តតិយឆក្កៈ មាន ៦ ញាណ

សរុប ឧបក្កិលេសញាណ មាន ១៨ ញាណ) ។

តតិយចតុក្កំ

តតិយចតុក្កទី ៣ (អដ្ឋកថា)

[១៥៦] តតិយចតុក្កេ អតីតានុជាវនំ ចិត្តន្តិ ផុសនដ្ឋានំ អតិក្កមិត្វា តតំ អស្សាសំ វា បស្សាសំ វា អនុគច្ឆមានំ ចិត្តំ។

ក្នុងតតិយចតុក្ក ត្រង់ពាក្យថា ***ចិត្តស្ទុះតាមទៅជាអតីតារម្មណ៍*** *មានន័យថា ចិត្តដែលស្ទុះតាមខ្យល់ដង្ហើមចូល ឬខ្យល់ដង្ហើមចេញ ដែលហួសទីកន្លែងដែលពាល់ត្រូវ។*

"វិក្ខេចានុបតិត"ន្តិ វិក្ខេបេន អនុតតំ, វិក្ខេបំ វា សយំ អនុបតិតំ អនុតតំ។

ពាក្យថា "***ធ្លាក់តាមទៅសេចក្តីរាយមាយ***", *ឬធ្លាក់តាមទៅ គឺតាមទៅកាន់សេចក្តីរាយមាយ។*

"អនាគតបដិកង្ខំ ចិត្ត"ន្តិ ផុសនដ្ឋានំ អប្បត្តំ អស្សាសំ វា បស្សាសំ វា បដិកង្ខមានំ បត្ថាសីសមានំ ចិត្តំ។

ពាក្យថា "***ចិត្តដែលប្រាថ្នានូវអនាគត***" *បានដល់ចិត្តដែលប្រាថ្នា គឺប្រាថ្នាតែចំពោះខ្យល់ដង្ហើមចូល ឬខ្យល់ដង្ហើមចេញ ដែលមិនទាន់មកដល់ទីកន្លែងដែលពាល់ត្រូវ។*

"វិកម្បិត"ន្តិ តស្មឹ អប្បតិដ្ឋានេនេវ វិក្ខេបេន វិកម្បិតំ។

ពាក្យថា "***ញាប់ញ័រ***" *បានសេចក្តីថា ញាប់ញ័រដោយសារភាពរាយមាយដែលមិនតាំងនៅក្នុងអារម្មណ៍(របស់កម្មដ្ឋាន)នោះ។*

"លីន"ន្តិ អតិសិថិលវីរិយតាទីហិ សង្កុចិតំ។

ពាក្យថា ***រួញរា (រថយ)*** *គឺមានសេចក្តីថា ព្យាយាមថយចុះហើយ។*

"កោសជ្ជានុបតិត"ន្តិ កុសីតភាវានុកតំ។

*ពាក្យថា "**ដែលធ្លាក់ទៅក្នុងសេចក្តីខ្ជិលច្រអូស**" គឺធ្វើតាមសេចក្តីខ្ជិលច្រអូស។*

"**អតិបគ្គហិត"ន្តិ អច្চារទ្ធវីរិយតាទីហិ អតិឧស្សាហិតំ**។

*ពាក្យថា "**ផ្គងហួសពេក**" គឺការឧស្សាហ៍ហួសពេក ដែលមានសេចក្តីប្រារព្ធព្យាយាមហួសពេក (ក្នុងការចង់ដឹងនូវខ្យល់ដង្ហើមចូល ចេញ) ជាដើម។*

"**ឧទ្ធច្চានុបតិត"ន្តិ វិក្ខេចានុកតំ**។

*ពាក្យថា "**ធ្លាក់ទៅក្នុងឧទ្ធច្ច (ការរវើរវាយ)**" គឺការធ្វើតាមសេចក្តីរាយមាយ។*

"**អកិនត"ន្តិ អស្សាឧវត្ថុសុ កុសំ នតំ អល្លីនំ**។

*ពាក្យថា "**ប្រាកដ (ចិត្តដែលបង្ហោនទៅរកអារម្មណ៍)**" គឺបង្ហោនទៅគិតយ៉ាងខ្លាំងក្នុងរឿងដែលពេញចិត្ត (មានរាគៈ ជាដើម)។*

អបនតន្តិ និរស្សាឧវត្ថុសុ បតិហតំ, តតោ អបកតំ វា, អបកតនតំ វា, ន តតោ អបកតន្តិ អត្ថោ។

*ពាក្យថា **មិនប្រាកដ (ការវិនាសទៅ)** គឺបានពាល់ត្រូវក្នុងរឿងដែលមិនពេញចិត្ត, ឬដោយការប្រាសចាករឿងដែលមិនស្រស់ស្រាយនូវចិត្ត, ឬថាបង្ហោនទៅដោយការប្រាសចាកហើយ, អធិប្បាយថា ដែលទៅប្រាសចាកហើយអំពីរឿងអ្វីណាមួយនោះ។*

ភគានុបតិតន្តិ ឯត្ត អស្សាសបស្សាសនិមិត្តំ មនសិកភោគោ ឧប្បន្នបីតិសុខេ វា បុព្វេ ហសិតលបិតកីឡិតវត្ថុសុ វា ភគោ អនុបតតិ។

ពាក្យថា ***ដែលធ្លាក់ទៅផ្នែកខាងរាគ*** *មានន័យថា កាលយោគីកិក្ខុកំពុងមនសិការនូវនិមិត្តគឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ រាគក៏កើតមានឡើង ហើយធ្លាក់ទៅជាមួយ បីតិ និង សុខ ដែលកើតមានខ្លះៗ ក្នុងរឿងថា ពេញចិត្ត ក្នុងការធ្លាប់ សើចញញឹមដាក់គ្នាលេងក្នុងកាលពីមុនៗមក ។*

ព្យាចាជាឧបតិតន្តិ ឯត្ត មនសិការេ និរស្សាទកតចិត្តស្ស ឧប្បន្នោមនស្សវសេន វា បុព្វេ សមុទាចិណ្ណេសុ អាឃាតវត្ថូសុ វា ព្យាចាទោ អឧបតតិ ។

ក្នុងពាក្យថា ***ដែលធ្លាក់ទៅផ្នែកខាងព្យាបាទ*** *នេះ មានសេចក្តីថា កាលយោគីកិក្ខុមានចិត្តនឹកដល់ភាពមិនស្រស់ស្រាយសប្បាយក្នុងចិត្ត ព្យាបាទ ក៏កើតមានឡើងហើយធ្លាក់ទៅតាម ដោយអំណាចនៃទោមនស្សចិត្តដែលកើតមានខ្លះៗ ក្នុងរឿងនៃអាឃាតដែលបានសន្សំទុកមកក្នុងកាលពីមុនៗមក ។*

តាថាសុ ន សមាធិយតីតិ ន សមាហិតំ ហោតិ។

ពាក្យថា ***រមែងមិនតាំងមាំ*** *ក្នុងគាថាទាំងឡាយ ឈ្មោះថា មិនមែនជាសមាធិឡើយ។*

"អធិចិត្ត"ន្តិ ចិត្តសីសេន ជិដ្ឋោ អធិកោ សមាធិ។

ពាក្យថា ***"អធិចិត្ត"*** *បានដល់ សមាធិដែលឧត្រិដ្ឋ ដែលបានសម្តែងអធិប្បាយទុកដោយចិត្ត សព្វ ដែលជាប្រធាន ។*

តតិយច្ឆក្កំ និដ្ឋិតំ ។

តតិយច្ឆក្ក ទី ៣ ចប់ ។

សរុបឧបក្កិលេសឆាំង ១៨ ញាណ (បិដក៧០) [៧៦]

[១៥៧]

១. អស្បាសាធិមជ្ឈបរិយោសានំ សតិយា អនុកច្ឆតោ អជ្ឈត្តំ រិក្ខេប-
កតេន ចិត្តេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច
ផន្ទិតា ច។

*កាលព្រះយោគាវចរភិក្ខុ ញ្ចាំងសតិតាមខ្យល់ដង្ហើមចូល ខាងដើម (ចុង
ច្រមុះ) កណ្តាល(បេះដូង) និងខាងចុង(គឺត្រង់ផ្ចិត) សូម្បីកាយ និងចិត្ត
រមែងជា សភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសារចិត្តដែល
បង្អោនទៅធ្វើឲ្យរាយមាយក្នុងខ្យល់ដង្ហើមខាងក្នុង ។*

២. បស្បាសាធិមជ្ឈបរិយោសានំ សតិយា អនុកច្ឆតោ ពហិទ្ធារិក្ខេប-
កតេន ចិត្តេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច
ផន្ទិតា ច។

*កាលព្រះយោគាវចរភិក្ខុ ញ្ចាំងសតិតាមខ្យល់ដង្ហើមចេញ ខាងដើម(ត្រង់
ផ្ចិត) កណ្តាល(ត្រង់បេះដូង) និងខាងចុង(ត្រង់ចុងច្រមុះ) សូម្បីកាយ និង
ចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ដោយសារចិត្ត
ដែលបង្អោនទៅធ្វើឲ្យរាយមាយក្នុងខ្យល់ដង្ហើមខាងក្រៅ ។*

៣. អស្បាសបដិកាជ្ឌនាយ និកាន្តិយា តណ្ហាចរិយាយ កាយោបិ
ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

*សូម្បីកាយ និងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង
ដោយសារសេចក្តីប្រាថ្នារកនូវខ្យល់ដង្ហើមចូល ដោយសេចក្តីត្រេកអរ
ដោយសេចក្តីប្រព្រឹត្តិទៅរបស់ចំណង់ ។*

៤. បស្បាសបដិកាជ្ឌនាយ និកាន្តិយា តណ្ហាចរិយាយ កាយោបិ

ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

សូម្បីកាយ និងចិត្ត រមែងជាសភាវៈរញ្ជួយផង រំកើបផង ញាប់ញ័រផង ដោយសាសេចក្តីប្រាថ្នារកនូវខ្យល់ដង្ហើមចេញ ដោយសេចក្តីត្រេកអរ ដោយសេចក្តីប្រព្រឹត្តិទៅរបស់ចំណង់ ។

៥. អស្សាសេ ជាតិតុន្នស្ស បស្សាសបដិលាភេ មុច្ឆិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

សូម្បីកាយ និងចិត្ត រមែងជាសភាវៈរញ្ជួយផង រំកើបផង ញាប់ញ័រផង ព្រោះជ្រប់ចិត្ត(ទៅក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ) ក្នុងការបាននូវខ្យល់ដង្ហើមចេញ សម្រាប់អ្នកទប់ខ្យល់ដង្ហើមចូល ។

៦. បស្សាសេ ជាតិតុន្នស្ស អស្សាសបដិលាភេ មុច្ឆិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

សូម្បីកាយ និងចិត្ត រមែងជាសភាវៈរញ្ជួយផង រំកើបផង ញាប់ញ័រផង ព្រោះជ្រប់ចិត្ត(ទៅក្នុងខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល) ក្នុងការបាននូវខ្យល់ដង្ហើមចូល សម្រាប់អ្នកទប់ខ្យល់ដង្ហើមចេញ ។

៧. និមិត្តំ អារជ្ជតោ អស្សាសេ ចិត្តំ វិកម្បិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

កាលព្រះយោគីកិក្ខុ នឹងរកនូវនិមិត្ត កាយនិងចិត្តរមែងជាសភាវៈរញ្ជួយផង រំកើបផង ញាប់ញ័រផង ព្រោះចិត្តបានញាប់ញ័រក្នុងខ្យល់ដង្ហើមចូល ។

៨. អស្សាសំ អារជ្ជតោ និមិត្តេ ចិត្តំ វិកម្បិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

កាលព្រះយោគីកិក្ខុ នឹងរកនូវខ្យល់ដង្ហើមចូល កាយនិងចិត្តរមែងជា

សភាវៈរញ្ជួយផង រំកើបផង ញាប់ញ័រផង ព្រោះចិត្តបានញាប់ញ័រក្នុងនិមិត្ត ។

៩. និមិត្តំ អាវជ្ជតោ បស្សាសេ ចិត្តំ វិកម្បិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

កាលព្រះយោគីកិក្ខុ នឹងរកនូវនិមិត្ត កាយនិងចិត្តរមែងជាសភាវៈរញ្ជួយផង រំកើបផង ញាប់ញ័រផង ព្រោះចិត្តបានញាប់ញ័រក្នុងខ្យល់ដង្ហើមចេញ ។

១០. បស្សាសំ អាវជ្ជតោ និមិត្តេ ចិត្តំ វិកម្បិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

កាលព្រះយោគីកិក្ខុ នឹងរកនូវខ្យល់ដង្ហើមចេញ កាយនិងចិត្តរមែងជាសភាវៈ រញ្ជួយផង រំកើបផង ញាប់ញ័រផង ព្រោះចិត្តបានញាប់ញ័រក្នុងនិមិត្ត ។

១១. អស្សាសំ អាវជ្ជតោ បស្សាសេ ចិត្តំ វិកម្បិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

កាលព្រះយោគីកិក្ខុ នឹងរកនូវខ្យល់ដង្ហើមចូល កាយនិងចិត្តរមែងជាសភាវៈរញ្ជួយផង រំកើបផង ញាប់ញ័រផង ព្រោះចិត្តបានញាប់ញ័រក្នុងខ្យល់ដង្ហើមចេញ ។

១២. បស្សាសំ អាវជ្ជតោ អស្សាសេ ចិត្តំ វិកម្បិតត្តា កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

កាលព្រះយោគីកិក្ខុ នឹងរកនូវខ្យល់ដង្ហើមចេញ កាយនិងចិត្តរមែងជាសភាវៈរញ្ជួយផង រំកើបផង ញាប់ញ័រផង ព្រោះចិត្តបានញាប់ញ័រក្នុងខ្យល់ដង្ហើមចូល ។

១៣. អតីតានុជាវនេន ចិត្តេន វិក្ខេចានុបតិតេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តស្ទុះទៅរកអារម្មណ៍ជាអតីតៈ ដែលធ្លាក់ទៅក្នុងសេចក្តីរយមាយ ។

១៤. អនាគតបដិកង្ខនេន ចិត្តេន វិកម្បិតេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តប្រាថ្នារកអារម្មណ៍ជាអនាគត ដែលញាប់ញ័រ ។

១៥. លីនេន ចិត្តេន កោសជ្ជានុបតិតេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តរួញរាដែលធ្លាក់ទៅក្នុងសេចក្តីខ្ជិលច្រអូស ។

១៦. អតិបគ្គហិតេន ចិត្តេន ឧទ្ធច្ចានុបតិតេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តផ្គងហួសពេក ដែលធ្លាក់ទៅក្នុង ឧទ្ធច្ចៈ ។

១៧. អភិនតេន ចិត្តេន រាគានុបតិតេន កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំភើបផង ញាប់ញ័រផង ព្រោះចិត្តដែលប្រាកដ(គឺការប្រកាន់ជាប់ទៅក្នុងអារម្មណ៍ដែលមិនគួរ) ដែលធ្លាក់ទៅក្នុងរាគៈ។

១៨. អបនតេន ចិត្តេន ព្យាបាទានុបតិតេន កាយោបិ ចិត្តម្បិ សារទ្ធា

ច ហោន្តិ ឥញ្ជិតា ច ផន្ទិតា ច។

កាយនិងចិត្ត រមែងជាសភាវៈរញ្ជួយផង រំកើបផង ញាប់ញ័រផង ព្រោះចិត្តមិនប្រាកដ (គឺការប្រាសចេញពីអារម្មណ៍របស់កម្មដ្ឋាន) ដែលជាប់ទៅក្នុង ព្យាបាទ។

គាថាសរុបសេចក្តី

អានាចានស្សតិ យស្ស, បរិបុណ្ណា អភាវិតា;
កាយោបិ ឥញ្ជិតោ ហោតិ, ចិត្តម្បិ ហោតិ ឥញ្ជិតំ;
កាយោបិ ផន្ទិតោ ហោតិ, ចិត្តម្បិ ហោតិ ផន្ទិតំ។

បុគ្គលណា មិនបានបំពេញ មិនបានចម្រើននូវអានាបានស្សតិ បុគ្គលនោះរមែងមានកាយរំកើបផង មានចិត្តរំកើបផង មានកាយញាប់ញ័រផង និងមានចិត្តញាប់ញ័រផង។

អានាចានស្សតិ យស្ស, បរិបុណ្ណា សុភាវិតា;
កាយោបិ អនិញ្ជិតោ ហោតិ, ចិត្តម្បិ ហោតិ អនិញ្ជិតំ;
កាយោបិ អផន្ទិតោ ហោតិ, ចិត្តម្បិ ហោតិ អផន្ទិតន្តិ។

បុគ្គលណា បានបំពេញ បានចម្រើនដោយល្អហើយនូវអានាបានស្សតិ បុគ្គលនោះរមែងមានកាយមិនរំកើបផង មានចិត្តមិនរំកើបផង មានកាយមិនញាប់ញ័រផង និងមានចិត្តមិនញាប់ញ័រផង។

ឥមេហិ ច បន នីវរណេហិ វិសុទ្ធចិត្តស្ស សោឩសវត្ថុកំ អានាចានស្សតិសមាធឹ ភាវយតោ ១ណិកសមោធានា

កាលព្រះយោគីកិក្ខុមានចិត្តសស្អាតចាកនីវរណៈធម៌ទាំងនោះ ហើយចម្រើននូវអានាបានស្សតិសមាធិ ដែលមានចំណុចសេចក្តី ចំនួន ១៦ ចំណុច

ខណិកសមោធាន (រមែងកើតមាន ដល់ព្រះយោគីភិក្ខុនោះ) ។

ឥមេ អដ្ឋារស ឧបក្កិលេសា ឧប្បជ្ជន្តិ។

នេះឯង ជាឧបក្កិលេសទាំង ១៨ យ៉ាង រមែងកើតឡើង ។

ឧបក្កិលេសញាណនិទ្ទេសោ តតិយោ។

ឧបក្កិលេសញាណនិទ្ទេស ទី ៣ ចប់ ។

សរុបឧបក្កិលេសទាំង ១៨ ញាណ (អដ្ឋកថា)

[១៥៧] ឯត្តាវតា តីហិ ឆក្កេហិ អដ្ឋារស ឧបក្កិលេសេ និទ្ទិសិត្វា ឥទានិ តេសំ ឧបក្កិលេសានំ សមាធិស្ស បរិបន្ថភាវសាធនេន អាទីនវំ ទស្សេន្តោ បុន "**អស្សាសាទិមជ្ឈបរិយោសាន**"ន្តិអាទិមាហ។

*កាលសម្តែង អធិប្បាយនៃឧបក្កិលេសទាំង ១៨ ប្រការ ដោយឆក្កៈទាំង ៣ យ៉ាង ទៅតាមលំដាប់នៃធម្មប៉ុណ្ណោះ ហើយឥឡូវនេះកាលនឹងសម្តែងនូវការញុំាងឧបក្កិលេសទាំងនោះឲ្យសម្រេចភាវៈដែលជាការអន្តរាយដល់សមាធិ លោកទើបពោលពាក្យថា **ខាងដើមខ្សល់ កណ្តាលខ្សល់ និងទីបំផុតខ្សល់ នៃខ្សល់ដង្ហើមចូល** ជាដើម ។*

តត្ថ "**កាយោបិ ចិត្តម្បិ សារទ្ធា ច ហោន្តី**"តិ វិក្ខេបសមុដ្ឋានរូបំ-វសេន រូបកាយោបិ, វិក្ខេបសន្តតិវសេន ចិត្តម្បិ មហតា ខោភេន ខុភិតា សទរថា ច ហោន្តិ។

*ក្នុងពាក្យទាំងនោះ ត្រង់ពាក្យថា **ទាំងកាយ ទាំងចិត្ត រមែងជាធម្មជាតិរញ្ជួយផង** មានន័យថា ទាំងរូបកាយ និងទាំងចិត្ត រមែងជាធម្មជាតិកម្រើក*

ដោយភាពកម្រើកខ្លាំង និងមានភាពរញ្ជួយ (សម្រាប់)រូបកាយដោយអំណាចនៃរូបដែលមានភាពរាយមាយជាសមុដ្ឋាន(សម្រាប់)ចិត្តដោយអំណាចភាពជាប់តនៃការរាយមាយ ។

តតោ មន្ទតរេ ឥញ្ជិតា កម្បិតា, តតោ មន្ទតរេ ផន្ទិតា ច លិតា ហោន្តិ។

តអំពីនោះ រមែងជាធម្មជាតិរំភើប គឺការកញ្ជ្រោលដោយអាការៈទន់ជាង, តអំពីនោះ រមែងជាធម្មជាតិញាប់ញ័រ គឺការញ័រដោយអាការៈទន់ជាង(ការញ័របន្តិចបន្តួច ឬខ្សោយជាង) ។

ពលវាបិ មជ្ឈិមោបិ មន្ទោបិ ខោភោ ហោតិ យេវ, ន សក្កា ខោភេន ន ភវិតុន្តិ វុត្តំ ហោតិ។

អធិប្បាយថា រមែងមានការកម្រើកទាំងមានកំលាំង(ខ្លាំង) ទាំងកណ្តាល(មធ្យម) ទាំងខ្សោយ(ធម្មតា) តែមួយ, ពិតមែនហើយអ្នកណាៗ ក៏មិនអាច មិនឲ្យមានភាពការកម្រើកបានឡើយ ។

"ចិត្តំ វិកម្បិតត្តា"តិ ចិត្តស្ស វិកម្បិតត្តា។

*បទទាំងពីរថា "**ចិត្តំ វិកម្បិតត្តា** ប្រែថា **ព្រោះចិត្តរញ្ជួយហើយ**" ។*

តាថាសុ បរិបុណ្ណា អភាវិតាតិ យថា បរិបុណ្ណា ហោតិ, តថា អភាវិតា។

*ក្នុងគាថាទាំងឡាយមានវិនិច្ឆ័យថា ពាក្យថា **ដែលធ្វើឲ្យបរិបូរប៉ុន្តែមិនបានច្រើន** មានន័យថា ដែលមិនបានចម្រើនដូចជាញាណដែលសម្បូរ ។*

"ឥញ្ជិតោ"តិ កម្បិតោ។

*បទថា "**ឥញ្ជិតោ** ប្រែថា **រំភើបហើយ**" ។*

"ផន្ទិតោ"តិ មន្ទកម្បិតោ។

បទថា "**ឆដ្ឋិតោ** *ប្រែថា ញាប់ញ័រ*បន្តិចបន្តួច" ។

ហេដ្ឋា នីវរណានំ អនន្តរត្តា "ឥមេហិ ច បន នីវរណេហីតិ[16] **អច្ចន្តសមីបនិទ្ទេសវចនំ កតំ។**

ព្រោះក្នុងខាងដើម នីវរណទាំងឡាយមានការជាប់តគ្នា លោកទើបដាក់សព្ទសម្តែងនូវអត្ថថា នៅជិតថា "**ឥមេហិ ច បន នីវរណេហិ**" ។

ឥធ បន និគមនេ នីវរណានំ សន្តរត្តា តេហិ ច បន នីវរណេហីតិ បរម្មុខនិទ្ទេសវចនំ កតំ។

ចំណែកក្នុងទីនេះ ព្រោះក្នុងពាក្យចុងក្រោយ នីវរណទាំងឡាយនៅមានចំណុច ដទៃជាច្រើន លោកទើបដាក់សព្ទសម្តែងនូវអត្ថត្រឡប់ក្រោយថា **តេហិ ច បន នីវរណេហិ**។

ឧបក្កិលេសញាណនិទ្ទេសវណ្ណនា និដ្ឋិតា។

ការពណ៌នានៃឧបក្កិលេសញាណនិទ្ទេស ចប់ ។

ចប់ ញាណលំដាប់ ទី ៣

---

១៦ បដិ. ម. បិ.៧០. ទំ.៨៨.[៧២] ។

៤. តេរស ចោទ្ទាឧ ញ្ញាណនិទ្ទេសោ

ញ្ញាណទី ៤ ចោទ្ទាឧញ្ញាណាំង ១៣ ញ្ញាណ (ម៉ិជ្ឈក៧0) [៧៧]

(ជាញាណដែលធ្វើឲ្យសមាធិស្អាតផូរផង់បានល្អ)

[១៤៨] **កតមានិ តេរស ចោទ្ទាឧ ញ្ញាណានិ?**

តើ ចោទានញ្ញាណទាំង ១៣ ដូចម្តេច?

១. **អតីតានុជាវនំ ចិត្តំ វិក្ខេចានុបតិតំ;**

ចិត្តស្ទុះទៅរកអារម្មណ៍ជាអតីតដែលជ្រាក់ទៅក្នុងសេចក្តីពយមាយ។

(ចិត្តស្ទុះទៅរកអារម្មណ៍ជាអតីត គឺរកខ្យល់ដង្ហើមចូល ចេញ ហើយចិត្តនឹកដល់ការអន់ចិត្តអន់ថ្នើម ក្នុងពេលនោះត្រូវលះចិត្តនោះ ហើយមកតម្កល់សតិចិត្តសាជាថ្មី ដោយនៅធម្មតា។ វិញជាមួយខ្យល់ដង្ហើមចូលនិងចេញ)។

តំ វិវជ្ជយិត្វា ឯកជ្ឈាឧ សមាឧហតិ។

ព្រះយោគី វៀរនូវចិត្តនោះ ហើយរមែងតម្កល់ចិត្តទុកក្នុងឋានមួយ (គឺសតិមកតាំងនៅត្រង់ចុងច្រមុះ ឬផ្នែបបូរមាត់ខាងលើ ជាកន្លែងដែលខ្យល់ពាល់ត្រូវនោះឯង)។

២. **ឯវម្បិ ចិត្តំ ឧ វិក្ខេបំ កច្ឆតិ។**

ចិត្តមិនដល់សេចក្តីពយមាយ យ៉ាងនេះខ្លះ។

៣. **អនាគតប្បដិកង្ខំ ចិត្តំ វិកម្បិតំ។**

ចិត្តប្រាថ្នារកអារម្មណ៍ ជាអនាគតដែលញាប់ញ័រ។

តំ វិវជ្ជយិត្វា តត្ថេវ អធិមោចេតិ។

ព្រះយោគីកិក្ខុ វៀរនូវចិត្តនោះហើយ រមែងរួចស្រឡះចាកចិត្តនោះឯង, (គឺ ទាញចិត្តឲ្យចុះមកវិញដោយអាការឬមៗ មកត្រង់កន្លែងដែលខ្សល់ពាល់ត្រូវដោយការបង្គាប់នូវចិត្តនោះ) ។

๔. ឯវម្បិ ចិត្តំ ន វិក្ខេបំ គច្ឆតិ។

ចិត្តមិនដល់សេចក្តីរាយមាយ យ៉ាងនេះខ្លះ ។

๕. លីនំ ចិត្តំ កោសជ្ជានុបតិតំ ។

ចិត្តដែលរួញរា (គឺត្រូវប្រើពុទ្ធគុណមកជាអារម្មណ៍ រឺ ប្រើបីតិ ឬក៏ ធម្មវិចយ មកជំរុញដល់ចិត្ត) ដែលធ្លាក់ទៅក្នុងសេចក្តីខ្ជិលច្រអូសនោះ ។

តំ បគ្គណ្ហាតិ្វា កោសជ្ជំ បជហាតិ ។

ព្រះយោគីផ្គងនូវចិត្តនោះ ហើយជាអ្នកលះបង់នូវសេចក្តីខ្ជិលច្រអូស (គឺ ផ្គងដោយការថ្នាក់ថ្នម ការដាស់តឿន ការជំរុញ ការបង្ខំនូវចិត្តនោះ ហើយមកតាំងសតិស្មារតីសាជាថ្មីវិញ) ។

๖. ឯវម្បិ ចិត្តំ ន វិក្ខេបំ គច្ឆតិ។

ចិត្តមិនដល់សេចក្តីរាយមាយ យ៉ាងនេះខ្លះ ។

๗. អតិបគ្គហិតំ ចិត្តំ ឧទ្ធច្ចានុបតិតំ។

ចិត្តផ្គងហួសពេក ដែលធ្លាក់ទៅក្នុង ឧទ្ធច្ចៈ (គឺការព្យាយាមរបស់សតិទៅកំណត់ដឹងនូវខ្សល់ដង្ហើមដោយការប្រឹងប្រែងចង់ដឹងខ្សល់ដង្ហើមខ្លាំងពេក ធ្វើឲ្យចិត្តរាយមាយ)។

តំ វិនិគ្គណ្ហាតិ្វា ឧទ្ធច្ចំ បជហាតិ ។

ព្រះយោគីកិក្ខុ សង្កត់សង្កិននូវចិត្តនោះ ហើយជាអ្នកលះបង់នូវឧទ្ធច្ចៈ (ត្រូវប្រើ ១ ចិត្តប្បស្សទ្ធិ, ២ សមាធិ, និង ៣ ឧបេក្ខា យកមកជាអារម្មណ៍

របស់កម្មដ្ឋានវិញ ដើម្បីកុំឲ្យចិត្តរាយមាយទៀត រួចហើយបង្អោនទៅកាន់អានាបានស្សតិវិញ) ។

៨. ឯវម្បិ ចិត្តំ ន វិក្ខេបំ កច្ឆតិ។

ចិត្តរមែងមិនដល់សេចក្តីរាយមាយ យ៉ាងនេះខ្លះ ។

៩. អភិនតំ ចិត្តំ ភគាឧបតិតំ។

ចិត្តរមែងប្រាកដ ដែលធ្លាក់ទៅក្នុងរាគ។

តំ សម្បជានោ ហុត្វា ភគំ បជហតិ ។

ព្រះយោគីជាអ្នកស្គាល់នូវចិត្តនោះច្បាស់ ហើយជាអ្នកលះបង់នូវរាគ (ដោយប្រើ អសុភកម្មដ្ឋានសិន បើសូប់ហើយបង្អោនទៅអានាបានស្សតិវិញ)។

១០. ឯវម្បិ ចិត្តំ ន វិក្ខេបំ កច្ឆតិ។

ចិត្តរមែងមិនដល់សេចក្តីរាយមាយ យ៉ាងនេះខ្លះ ។

១១. អបនតំ ចិត្តំ ព្យាចាឧបតិតំ ។

ចិត្តមិនប្រាកដ ដែលធ្លាក់ទៅក្នុងព្យាបាទ ។

តំ សម្បជានោ ហុត្វា ព្យាចាទំ បជហតិ ។

ព្រះយោគីជាអ្នកស្គាល់ចិត្តនោះច្បាស់ ហើយជាអ្នកលះបង់ព្យាបាទ (ប្រើមេត្តា) ។

១២. ឯវម្បិ ចិត្តំ ន វិក្ខេបំ កច្ឆតិ។

ចិត្តរមែងមិនដល់សេចក្តីរាយមាយ យ៉ាងនេះខ្លះ ។

១៣. ឥមេហិ ឆហិ ហានេហិ បរិសុទ្ធំ ចិត្តំ បរិយោទាតំ ឯកគ្គតគំ ហោតិ។

ចិត្តរមែងផូរផង់ដល់នូវឯកគ្គៈ ដោយហានទាំង ៦ ឃ្លាយ ៦ យ៉ាងនេះឯង ។

(ឋាន ៦នោះ គឺស្មើនឹងញាណ ១២ ហើយបូក និងញាណចុងក្រោយត្រង់ ពាក្យថា **ឥមេហិ ឆហិ ឋានេហិ បរិសុទ្ធំ ចិត្តំ បរិយោទាតំ ឯកត្តគតំ ហោតិ**, *នោះស្មើនិង ១៣ ញាណ ឬ ភោទានញាណ ១៣ ដូច្នេះឯង)* ។

៤. ភោទានញ្ញាណនិទ្ទេសវណ្ណនា

ពណ៌នាភោទានញ្ញាណ ជាញ្ញាណលំដាប់ទី ៤ (**អដ្ឋកថា**)

[១៥៨] "ភោទានេ ញាណានី"តិ វិសុទ្ធញ្ញាណានិ។

ពាក្យថា "**ញាណក្នុងភោទាន**" *បានដល់ញាណដែលបរិសុទ្ធ* ។

"**តំ វិវជ្ជយិត្វា**"តិ យំ បុព្វេ វុត្តំ អតីតានុភាវនំ ចិត្តំ វិក្ខេចានុបតិតំ, តំ វិវជ្ជយិត្វាតិ សម្ពន្ធិតព្ពំ។

បទថា "**តំ វិវជ្ជយិត្វា**" *គប្បីភ្ជាប់សេចក្តីថា ចិត្តដែលស្ទុះទៅតាមអតីតារម្មណ៍ដែលបានពោលទុកមកហើយក្នុងខាងដើម ជាចិត្តដែលធ្លាក់ទៅតាមការរាយមាយណា,គឺត្រូវវៀរនូវចិត្តដួងនោះចេញ* ។

"**ឯកដ្ឋានេ សមាធិតី**"តិ អស្សាសបស្សាសានំ ផុសនដ្ឋានេ សមំ អាធិតិ បតិដ្ឋាបេតិ។

ពាក្យថា "**រមែងតម្កល់ចិត្តទុកក្នុងឋានមួយ**" *បានន័យថា រមែងមកតាំងទុកដោយស្មើៗ គឺបិតនៅស៊ប់ទុកកន្លែង* **ផុសនដ្ឋាន** *ជាកន្លែងដែលពាល់ត្រូវរបស់ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ* ។

"**តត្ថេវ អនិមោចេតី**"តិ ឯកដ្ឋានេតិ វុត្តេ អស្សាសបស្សាសានំ ផុសនដ្ឋានេយេវ សន្និដ្ឋបេតិ សន្និដ្ឋានំ ករោតិ។

*ពាក្យថា "**រមែងបង្អោនទៅឋានមួយនោះឯង**" មានន័យថា រមែងតាំងចុះទុកយ៉ាងល្អ គឺធ្វើការតាំងចុះទុកយ៉ាងល្អ នៅកន្លែងដែលពាល់ត្រូវរបស់ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលលោកពោលថា ជាឋានមួយប៉ុណ្ណោះឯង។*

"បត្តណ្ហិត្វា"តិ ឩម្មិចយបីតិសម្ពោជ្ឈង្គភាវនាយ បត្តហោត្វា។

*ពាក្យថា "**ផ្គងហើយ**" គឺបម្រុងទុកហើយ ដោយការចម្រើនឩម្មិចយ-សម្ពោជ្ឈង្គ និងបីតិសម្ពោជ្ឈង្គ។*

"វិនិត្តណ្ហិត្វា"តិ បស្សទ្ធិសមាធិឧបេក្ខាសម្ពោជ្ឈង្គភាវនាយ វិនិត្តណ្ហិត្វា។

*ពាក្យថា "**សង្កត់សង្កិន**" គឺការឃុំគ្រងទុកដោយការចម្រើនបស្សទ្ធិ-សម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ និងឧបេក្ខាសម្ពោជ្ឈង្គ។*

"សតិន្ទ្រិយវីរិយិន្ទ្រិយេហិ បត្តហោត្វា, សតិន្ទ្រិយសមាធិន្ទ្រិយេហិ វិនិត្តហោត្វា" តិបិ វទន្តិ។

*លោកអាចារ្យទាំងឡាយពោលថា "**ការផ្គងចិត្តដោយសតិន្ទ្រិយ, សង្កត់សង្កិនដោយសតិន្ទ្រិយ និងសមាធិន្ទ្រិយ**" ដូច្នេះក៏មាន។*

"សម្បជានោ ហុត្វា"តិ អសុភភាវនាឌីហិ។

*ពាក្យថា "**ជាអ្នកស្គាល់នូវចិត្ត**" ដោយអសុភភាវនា ជាដើម។*

បុន **"សម្បជានោ ហុត្វា"**តិ មេត្តាភាវនាឌីហិ។

*ពាក្យថា "**ជាអ្នកស្គាល់នូវចិត្ត**" ដោយមេត្តាភាវនា ជាដើម។*

យេន ភាគេន អនុបតិតំ, យេន ព្យាចាខេន អនុបតិតំ, តំ បឌហាតីតិ សម្ពន្ធោ។

ភ្ជាប់សេចក្តីថា ចិត្តធ្វាក់ទៅតាមរាគណា, ធ្វាក់ទៅតាមដោយព្យាបាទណា, រមែងលះនូវរាគ និងព្យាបាទនោះ ។

តំ ចិត្តំ ឲ្យ៉ជិសន្តិ សម្ឆជានន្តោ តប្ឆដិបក្ខេន រាកំ បជហតិ, ព្យាចាជំ បជហតីតិ រា អត្តោ។

នីយម្យ៉ាងទៀត មានសេចក្តីថា ជាអ្នកដឹងថាចិត្តនោះជាយ៉ាងនេះ រមែងលះនូវរាគដោយធម្មដែលជាបដិបក្ខចំពោះរាគនោះ, រមែងលះបង់ព្យាបាទដោយធម្មដែលជាបដិបក្ខចំពោះព្យាបាទនោះ ដូច្នេះ ។

បរិសុទ្ធន្តិ និរុបក្ពិលេសំ។

*ពាក្យថា **ចិត្តបរិសុទ្ធ** គឺមិនមានឧបក្ពិលេស ។*

បរិយោជាតន្តិ បភស្ឆរំ។

*ពាក្យថា **ផូរផង់** គឺថ្វាស្អាត ។*

ឯកត្តកតំ ហោតីតិ តំ តំ រិសេសំ បត្តស្ឆ តំ តំ ឯកត្តំ កតំ ហោតិ។

*ពាក្យថា **ដល់នូវឯកត្ត (ដល់នូវភាវ:តែមួយ)** គឺកាលព្រះយោគីដល់នូវគុណវិសេសនោះៗហើយ ចិត្តរមែងជាធម្មជាតិដល់នូវភាពតែមួយនោះ។*

ឯកត្តដោយហេតុ ៤ យ៉ាង (ចិជក ៧០) [៧៨]

កតមេ តេ ឯកត្តា? ។

តើ ឯកត្ត ទាំងនោះដូចម្តេច? ។

១. ជានរោសក្ពុបជ្ជានេកត្តំ,

ទានវោសគ្គបដ្ឋាន(ការបរិច្ចាគទាន,ការឲ្យអភ័យទាន) ឈ្មោះថា ឯកត្ត។

๒. **សមថនិមិត្តុបដ្ឋានេកត្តំ,**

សមថនិមិត្តុបដ្ឋាន (ការប្រាកដច្បាស់របស់អារម្មណ៍សមថៈ គឺខ្យល់ចូលចេញ ត្រង់ចុងច្រមុះ និងលើផ្ទៃបបូរមាត់ខាងលើ មកជានិមិត្ត) ឈ្មោះថា ឯកត្ត,

๓. **វយលក្ខណុបដ្ឋានេកត្តំ,**

វយលក្ខណុបដ្ឋាន (លក្ខណាអស់ទៅសូន្យទៅមិនតាំងនៅបាន) ឈ្មោះថា ឯកត្ត,

๔. **និពេ្ពុបដ្ឋានេកត្តំ។**

និពេ្ពុបដ្ឋាន (គឺ ព្រះនិព្វាន) ឈ្មោះថា ឯកត្តៈ។

អធិប្បាយនៃឋាន ទាំង ៤

๑. **ទានវោសគ្គុបដ្ឋានេកត្តំ ចាគាធិមុត្តានំ,**

ទានវោសគ្គបដ្ឋានរបស់បុគ្គលអ្នកចុះចិត្តស៊ប់ក្នុងការលះបង់ ឈ្មោះថា ឯកត្តៈ,

๒. **សមថនិមិត្តុបដ្ឋានេកត្តញ្ច អធិចិត្តមនុយុត្តានំ,**

សមថនិមិត្តុបដ្ឋាន របស់ពួកបុគ្គលអ្នកប្រកបរឿយៗ នៅក្នុងអធិចិត្ត ឈ្មោះថា ឯកត្ត,

๓. **វយលក្ខណុបដ្ឋានេកត្តញ្ច វិបស្សកានំ,**

វយលក្ខណុបដ្ឋានរបស់បុគ្គលអ្នកពិចារណា (វិបស្សនា)ឈ្មោះថា ឯកត្តៈ,

๔. **និពេ្ពុបដ្ឋានេកត្តញ្ច អរិយបុគ្គលានំ ,**

និពេធុបដ្ឋានរបស់ពួកអរិយបុគ្គល ឈ្មោះថា ឯកត្តៈ,

ឥមេហិ ចតូហិ ហានេហិ ឯកត្តគតំ ចិត្តំ បដិបទាវិសុទ្ធិបក្ខន្ទញ្ចេវ ហោតិ, ឧបេក្ខានុព្រូហិតញ្ច, ញាណេន ច សម្បហំសិតំ។

ចិត្តដែលដល់នូវ ឯកត្ត ដោយហានទាំង៤ឋាយ ៤ នេះ ឈ្មោះថា ជាធម្មជាតិជ្រះថ្លា ដោយបដិបទាវិសុទ្ធិផង ឈ្មោះថា ជាការចម្រើនរឿយៗ នៃការសម្ងឹងពិនិត្យផង ឈ្មោះថា រីករាយដោយញាណផង ។

ឯកត្ត ដោយហេតុ ៤ យ៉ាង (អដ្ឋកថា)

កតមេ តេ ឯកត្តាតិ ឥធ យុជ្ជមានាយុជ្ជមានេបិ ឯកត្តេ ឯកតោ កត្វា បុច្ឆតិ។

លោកសួរជាសេចក្តីមួយ សូម្បីដែលប្រកបទុកក្នុងទីនេះ បានធ្វើរួមគ្នាថា ***ការៈ(នៃចិត្ត) តែមួយប៉ុណ្ណោះ តើដូចម្តេច ? ។***

ជានូបសក្កុបដ្ឋានេកត្តន្តិ ជានវត្ថុសង្ខាតស្ស ជានស្ស ឧបសក្កោ ភោសជ្ជំ ជានូបសក្កោ, ជានវត្ថុបរិច្ចាគចេតនា។

បទថា ***ជានូបសក្កុបដ្ឋានេកត្តំ*** *ប្រែថា* ***ការៈ(នៃចិត្ត) តែមួយ ក្នុងការប្រាកដនៃការបរិច្ចាគទាន*** *មានន័យថា ការបរិច្ចាគ គឺការលះនូវវត្ថុឲ្យទៅជាទាន ពោលគឺទានវត្ថុ ឈ្មោះថា ទានូបសគ្គោ,បានដល់ ចេតនាបរិច្ចាគទានវត្ថុ។*

តស្ស ឧបដ្ឋានំ អារម្មណាការណារសេន ឧបតដ្ឋា ហានំ ជានូបសក្កុបដ្ឋានំ, តទេវ ឯកត្តំ, តេន ច ឯកត្តំ ឯកត្តភាវោ ជានូបសក្កុ-បដ្ឋានេកត្តំ។

ការជ្រាកដ បានដល់ ភាវៈចូលទៅតាំងនៅដោយអំណាចធ្វើឲ្យជាអារម្មណ៍ នៃការបរិច្ចាគទាននោះ ឈ្មោះថា ទានូបសគ្គបដ្ឋានំ, ភាវៈតែមួយ គឺ ការជ្រាកដនៃការបរិច្ចាគទាននោះ, ឬ ភាវៈ(នៃចិត្ត)តែមួយ គឺ ការមានអារម្មណ៍តែមួយ ដោយការបរិច្ចាគទាននោះ ឈ្មោះថា ទានូបសគ្គបដ្ឋានេកត្តំ ប្រែថា ភាវៈ(នៃចិត្ត) តែមួយក្នុងការជ្រាកដនៃការ បរិច្ចាគទាន ។

ចានភោសក្កុបដ្ឋានេកត្តន្តិ ចាហោ សុន្ទរតរោ, សោ ឯវត្ថោ។

បាឋៈព្រះបាឡីពោលថា **ចានភោសក្កុបដ្ឋានេកត្តំ** *បែបនេះគឺ ក៏ល្អ, បាឋៈនោះមានសេចក្តីន័យដូចគ្នា ។*

ឯតេន បទុទ្ធារវសេន ចាតានុស្សតិសមាធិ វុត្តោ។

ដោយពាក្យនេះ លោកបានពោលដល់ សមាធិដែលមានចាគានុស្សតិមកជាអារម្មណ៍ ដោយអំណាចការអធិប្បាយនៃបទ ។

បទុទ្ធារវសេន វុត្តោបិ ចេស ឥតរេសំ តិណ្ណម្បិ ឯកត្តានំ ឧបនិស្សយបច្ចយោ ហោតិ, តស្មា ឥធ និទ្ទិដ្ឋន្តិ វេទិតព្ពំ។

ក៏សមាធិ ដែលមានចាគានុស្សតិមកជាអារម្មណ៍នេះ សូម្បីដែលលោកពោលដោយអំណាចការអធិប្បាយនៃបទ ក៏រមែងជាឧបនិស្សយបច្ច័យមួយក្នុងចំណោមទាំង ៣ ក្រៅពីនេះផងដែរ, ព្រោះហេតុនោះ លោកអាចារ្យទាំងឡាយទើបពោលថា បានសម្តែងខៃសេចក្តីមកហើយក្នុងទីនេះ ។

វិសាខាបិ ហិ មហាឧចាសិកា អាហ "ឥធ, ភន្តេ, ឯិសាសុ វស្សំវុដ្ឋោ ភិក្ខូ សាវត្ថឹ អាគច្ឆិស្សន្តិ ភគវន្តំ ឧស្សជាយ, តេ ភគវន្តំ ឧបសង្កមិត្វា បុច្ឆិស្សន្តិ 'ឥត្ថន្នាមោ, ភន្តេ, ភិក្ខុ កាលង្កតោ, តស្ស កា គតិ, កោ អភិសម្បរាយោ"តិ? ។

ពិតមែនហើយ សូម្បីលោកយាយវិសាខាមហាឧបាសិកា ក៏បាន

ក្រាបទូល(ដល់ព្រះដ៏មានព្រះភាគ) ថា "បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុអ្នកចាំវស្សា ក្នុងទិសទាំងឡាយនៅក្នុងលោកនេះ និងមកកាន់ក្រុងសាវត្ថី ដើម្បីមកគាល់ ព្រះដ៏មានព្រះភាគជាម្ចាស់, ភិក្ខុទាំងនោះចូលមកគាល់ព្រះដ៏មានព្រះភាគ ហើយនិងទូលសួរថា ' បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុឈ្មោះនេះបានធ្វើមរណៈ កាលទៅហើយ, តើភិក្ខុនោះមានគតិ ដូចម្តេច?, មានសម្បរាយភពដោយចំពោះ តើដូចម្តេចខ្លះ? ' ។

តំ ភគវា ព្យាករិស្សតិ សោតាបត្តិផលេ វា សកទាគាមិផលេ វា អនាគាមិផលេ វា អរហត្តេ វា។

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានព្យាករណ៍ដល់ភិក្ខុទាំងនោះថា ជា សោតាបត្តិផលខ្លះ ជាសកទាគាមិផលខ្លះ ជាអនាគាមិផលខ្លះ ជាអរហត្តខ្លះ ។

តាហំ ឧបសង្កមិត្វា បុច្ឆិស្សាមិ 'អាគតបុព្វា នុ ខោ, ភន្តេ, តេន អយ្យេន សាវត្ថី'តិ?សចេ មេ វក្ខន្តិ 'អាគតបុព្វា តេន ភិក្ខុនា សាវត្ថី'តិ។

ខ្ញុំម្ចាស់នឹងចូលទៅរកភិក្ខុទាំងនោះ ហើយនឹងបានទូលសួរថា លោកម្ចាស់ដ៏ចម្រើនតើលោកម្ចាស់រូបនោះបានធ្លាប់មកកាន់ក្រុងសាវត្ថីឬទេ? ប្រសិនបើ លោកម្ចាស់ទាំងនោះ នឹងឆ្លើយតបដល់ខ្ញុំម្ចាស់វិញថា ' ភិក្ខុរូបនោះ បានធ្លាប់មកកាន់ក្រុងសាវត្ថីដែរ ' ។

និដ្ឋមេត្ត កច្ឆិស្សាមិ និសីទនំ បរិភុត្តំ តេន អយ្យេន វស្សិកសាដិកា វា អាគន្តុកភត្តំ វា គមិកភត្តំ វា គិលានភត្តំ វា គិលានុបដ្ឋាកភត្តំ វា គិលានភេសជ្ជំ វា ឧប្បន្នា វាតិ។

ខ្ញុំម្ចាស់នឹងបានសប្បាយក្នុងចិត្ត ក្នុងការនិមន្តមករបស់គុណម្ចាស់រូប នោះថា ព្រះគុណម្ចាស់រូបនោះគង់នឹងធ្លាប់បានប្រើសំពត់វស្សិកសាដក គង់តែ បានឆាន់នូវអាគន្តុកភត្ត គមិកភត្ត គិលានភត្ត គិលានុដ្ឋាកភត្ត គិលានភេសជ្ជ ឬ

យាគូ(ដែលបានថ្វាយ)ជាប្រចាំ យ៉ាងពិតប្រាកដ ។

តស្សា មេ តជនុស្សរន្តិយា ចាមោជ្ជំ ជាយិស្សតិ, បមុជិតាយ បីតិ ជាយិស្សតិ, បីតិមនាយ កាយោ បស្សម្ភិស្សតិ, បស្សទ្ធកាយា សុខំ វេជយិស្សាមិ, សុខិនិយា ចិត្តំ សមាធិយិស្សតិ, សា មេ ភវិស្សតិ ឥន្ទ្រិយ-ភាវនា ពលភាវនា ពោជ្ឈង្គភាវនា"តិ[១៧] ។

កាលខ្ញុំម្ចាស់រលឹកដល់កុសលនោះ សេចក្តីបាមោជ្ជ និងកើតឡើង, កាលខ្ញុំម្ចាស់កើតនូវបាមោជ្ជ បីតិក៏នឹងកើតឡើង, កាលខ្ញុំម្ចាស់មានចិត្តប្រកបដោយ បីតិហើយ កាយក៏នឹងសូប់, ខ្ញុំម្ចាស់មានកាយសូប់ហើយ នឹងបានសោយនូវ សេចក្តីសុខ, កាលខ្ញុំម្ចាស់មានសេចក្តីសុខហើយ ចិត្តនឹងតាំងមាំ, រីការអប់រំ ឥន្ទ្រិយ ការអប់រំពល: ការអប់រំពោជ្ឈង្គ:នោះ នឹងមានដល់ខ្ញុំម្ចាស់" ដូច្នេះ ។

អថ វា ឯកត្តេសុ បឋមំ ឧបចារសមាធិវសេន រុត្តំ, ជុតិយំ អប្បនា-សមាធិវសេន, តតិយំ វិបស្សនាវសេន, ចតុត្តំ មក្គផលវសេនាតិ វេជិតព្វំ។

ម្យ៉ាងវិញទៀត គប្បីជ្រាបថា ក្នុងបណ្តាភាវ:(នៃចិត្ត)តែមួយ ភាវ:តែមួយ ក្នុងសេចក្តីខាងដើម លោកពោលទុកដោយអំណាចជា ឧបចារសមាធិ, ភាវ:តែមួយ(នៃឯកគ្គតា)ក្នុងសេចក្តីទី ២ លោកពោលទុកដោយអំណាចជា អប្បនាសមាធិ, ភាវ:តែមួយ(នៃឯកគ្គតា) នៅក្នុងសេចក្តីទី ៣ លោកពោលទុក ដោយអំណាចជា វិបស្សនា, ភាវ:តែមួយនៅក្នុងសេចក្តីទី ៤ លោកពោលទុក ដោយអំណាចនៃ មគ្គ និងផល ។

សមថស្ស និមិត្តំ សមថនិមិត្តំ។

និមិត្តនៃសមថ: ឈ្មោះថា **សមថនិមិត្ត** *។*

វយោ ភដ្តោ ឯវ លក្ខណំ វយលក្ខណំ។

---

១៧ (មហាវ. ៣៥១) ។

លក្ខណៈ គឺការអស់ទៅសូន្យទៅបានដល់ ការរលត់ ឈ្មោះថា ***វយលក្ខណ*** *។*

និរោធោ និញ្ចានំ។

ពាក្យថា ***និរោធ*** *បានដល់ ព្រះនិញ្ចាន ។*

សេសមេតេសុ តីសុ វុត្តនយេនេវ យោជេតព្ចំ។

ពាក្យដ៏សេស គប្បីប្រកបទៅតាមន័យដែលបានពោលទុកមកហើយ ក្នុងសេចក្តីថា ភាវៈតែមួយទាំង ៣ នោះ នុ៉ះឯង ។

ចាកាធិមុត្តានន្តិ ជានេ អធិមុត្តានំ។

ពាក្យថា ***របស់បុគ្គលអ្នកបង្អោនចិត្តទៅក្នុងចាគៈទាំងឡាយ*** *គឺរបស់បុគ្គលទាំងឡាយអ្នកបង្អោនចិត្តទៅក្នុងទាន ។*

"**អធិចិត្ត**"ន្តិ វិបស្សនាចាជកសមាធិ។

ពាក្យថា "**អធិចិត្ត**" *បានដល់ សមាធិដែលជាបាតនៃវិបស្សនា ។*

វិបស្សកានន្តិ ភជ្ជានុបស្សនតោ បដ្ឋាយ តីហិ អនុបស្សនាហិ សជ្ជ្ជាវេវិបស្សន្តានំ ។

ពាក្យថា ***របស់បុគ្គលអ្នកចម្រើនវិបស្សនាទាំងឡាយ*** *គឺរបស់បុគ្គលអ្នកឃើញច្បាស់នូវសង្ខារ ដោយអនុបស្សនាទាំង ៣ តាំងតែ ភង្គានុបស្សនាទៅ ។*

អរិយបុត្តលានន្តិ អដ្ឋន្នំ។

ពាក្យថា ***របស់ព្រះអរិយៈបុគ្គលទាំងឡាយ*** *បានដល់របស់ព្រះអរិយៈបុគ្គល៨ជំពូក។*

ជុតិយាជីនិ តីណិ ឯកត្តានិ អានាចានស្សតិវសេន សេសកម្ម-ដ្ឋានវសេន ច យុជ្ជន្តិ។

ភាវៈតែមួយទាំង ៣ មាន ភាវៈតែមួយក្នុងសេចក្តីទី ២ ជាដើម រមែងគួរ ដោយអំណាចអានាបានស្សតិ និងដោយអំណាចកម្មដ្ឋានដ៏សេសទៀត ។

ចតូហិ ហានេហីតិ ចតូហិ ការណេហិ។

*ពាក្យថា **ដោយហាន ៤** គឺដោយហេតុ ៤ ។*

សមាធិវិបស្សនាមគ្គផលានំ វសេន "ឯកត្តគតំ ចិត្តំ បដិបទាវិសុទ្ធិបក្ខន្ទនេ ហោតិ ឧបេក្ខានុព្រូហិតញ្ច ញាណេន ច សម្បហំសិត"ន្តិ ឧទ្ទេសបទានិ។

ក្នុងបទឧទ្ទេសបានសម្តែងថា "ចិត្តដែលដល់នូវ ឯកត្ត(ភាវៈតែមួយ) រមែងជាចិត្តស្ទុះទៅកាន់បដិបទាវិសុទ្ធិ ដែលឧបេក្ខាបានជំរុញឲ្យទៅតាមលំដាប់ និងជាញាណឲ្យដោយពេញចិត្ត ពេញកម្លាំង" ដូច្នេះ ដោយអំណាចនៃសមាធិ វិបស្សនា និងមគ្គផល ។

"បឋមស្ស ឈានស្ស កោ អាទី"តិអាទីនិ តេសំ ឧទ្ទេសបទានំ វិត្ថារេតុកម្យតាបុច្ឆាបុព្វង្គមានិ និទ្ទេសបទានិ។

ពាក្យថា "អ្វីជាខាងដើមនៃបឋមឈាន" ដូច្នេះ ជាដើម ជាបទនិទ្ទេស ដែលមានពាក្យសួរថា តើនរណានឹងញុំាងឧទ្ទេសទាំងនោះឲ្យពិស្តារជាខាងដើម។

តត្ថ បដិបទាវិសុទ្ធិបក្ខន្ទន្តិ បដិបទា ឋានីវរណាមលវិសោធនតោ វិសុទ្ធិ, តំ បដិបទាវិសុទ្ធឹ បក្ខន្ទំ បវិដ្ឋំ។

*ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា **ស្ទុះទៅកាន់បដិបទាវិសុទ្ធិ** មានសេចក្តីថា បដិបទានោះឯង ឈ្មោះថា ជាវិសុទ្ធិ ព្រោះញុំាងមន្ទិលគឺនីវរណឲ្យក្ងីថ្ងា, ស្ទុះទៅ គឺ ចូលទៅកាន់បដិបទាវិសុទ្ធិនោះ ។*

"ឧបេក្ខានុព្រូហិត"ន្តិ តត្រមជ្ឈត្តុបេក្ខាយ ព្រូហិតំ វឌ្ឍិតំ។

*ពាក្យថា "**ដែលឧបេក្ខាបានជំរុញឲ្យទៅតាមលំដាប់ ឬ ប្រែថា (ការចម្រើនរឿយៗ នៃការសម្ងឹងពិនិត្យ)**" គឺតម្រង់ឧបេក្ខាឲ្យបន្ថែម គឺឲ្យច្រើនហើយ។*

"**ញាណេន ច សម្បហំសិត**"ន្តិ បរិយោគាបកេន ញាណេន សម្បហំសិតំ បរិយោគាបិតំ វិសោធិតំ។

*ពាក្យថា "**ដែលញាណរីកពាយផង**" គឺញាណដែលជាតួធ្វើឲ្យក្ដៅថ្នា ធ្វើឲ្យរីកពាយ គឺឲ្យក្ដៅថ្នា ឲ្យក្ដៅស្វាងផង។*

បឋមជ្ឈាន (បិដក៧០) [៧៩]

បឋមស្ស ឈានស្ស កោ អាទិ, កិំ មជ្ឈេ, កិំ បរិយោសានំ?

តើបឋមជ្ឈាន មានអ្វីជាខាងដើម, មានអ្វីជាកណ្ដាល, និងមានអ្វីជាខាងចុង?។

បឋមស្ស ឈានស្ស បដិបទាវិសុទ្ធិ អាទិ, ឧបេក្ខានុព្រូហនា មជ្ឈេ, សម្បហំសនា បរិយោសានំ។

បឋមជ្ឈាន មានបដិបទាវិសុទ្ធិ ជាខាងដើម, មានការចម្រើនរឿយៗ នៃការសម្ងឹងពិនិត្យជាកណ្ដាល, មានការរីកពាយ(ដោយបញ្ញា)ព្រមជាខាងចុង។

បឋមជ្ឈាន (អដ្ឋកថា)

បដិបទាវិសុទ្ធិ នាម សសម្ភារិកោ ឧបចារោ, **ឧបេក្ខានុព្រូហនា** នាម អប្បនា, **សម្បហំសនា** នាម បច្ចវេក្ខណានតិ ឯវមេកេ វណ្ណយន្តិ។

លោកអាចារ្យ មួយពួកបាននពណ៌នាទុកយ៉ាងនេះថា ឧបចារសមាធិ ព្រមទាំងសម្ភារៈឈ្មោះថា ***បដិបទាវិសុទ្ធិ***, *អប្បនាសមាធិឈ្មោះថា* ***ការបន្ថែម(ការជំរុញ)នៃឧបេក្ខា ឬប្រែថា ការចម្រើនរឿយៗនៃការសម្ងឹងពិនិត្យ,*** *បច្ចវេក្ខណ ឈ្មោះថា* ***ការរីករាយ*** ។

យស្មា បន "ឯកត្តគតំ ចិត្តំ បដិបទាវិសុទ្ធិបក្ខន្ទញ្ចេវ ហោតី"តិ អាទិ វុត្តំ, តស្មា អត្ថោអប្បនាយមេវ អាគមនវសេន បដិបទាវិសុទ្ធិ, តត្រមជ្ឈត្តុបេក្ខាយ កិច្ចវសេន ឧបេក្ខានុព្រូហនា, ឆម្នាំ អនតិវត្តនា-ទិការសាធនេន បរិយោទាបកស្ស ញាណស្ស កិច្ចនិប្ផត្តិវសេន សម្បហំសនា វេទិតព្វា។

លោកពោលពាក្យថា "ចិត្តដែលដល់ការៈតែមួយ(គឺ ឯកត្តៈ) រមែងជាចិត្តស្ទុះទៅកាន់បដិបទាវិសុទ្ធិ" ដូច្នេះ ជាដើម, ព្រោះហេតុនោះ គប្បីជ្រាបនូវបដិបទាវិសុទ្ធិដោយអំណាចការមកខាងក្នុងអប្បនានោះឯង, គប្បីជ្រាបការបន្ថែម(ការចម្រើនរឿយៗ)នៃឧបេក្ខា ដោយអំណាចកិច្ចនៃតត្រមជ្ឈត្តុបេក្ខា, គប្បីជ្រាបការរីករាយដោយអំណាចការសម្រេចកិច្ចនៃញាណដែលញុំាងចិត្តឲ្យក្លីថ្លាដោយការសម្រេចការៈ មានការមិនប្រព្រឹត្តទៅកន្ទងគ្នានិងគ្នានៃធម៌ទាំងឡាយ ជាដើម ។

កថំ? យស្មិញ្ហិ ភាវេ អប្បនា ឧប្បជ្ជតិ, តស្មឹ យោ នីវរណសង្ខាតោ កិលេសគណោ តស្ស ឈានស្ស បរិបន្ថោ, តតោ ចិត្តំ វិសុជ្ឈតិ, វិសុទ្ធត្តា អារម្មណាវិរហិតំ ហុត្វា មជ្ឈិមំ សមថនិមិត្តំ បដិបជ្ជតិ។

គប្បីជ្រាបដូច្នេះ? ក៏អប្បនាកើតឡើងក្នុងភាវៈណា, ក្នុងភាវៈនោះពួកក្រុមកិលេស ពោលគឺនីវរណៈដែលអន្តរាយដល់ឈាននោះ, ចិត្តរមែងបរិសុទ្ធិចាកពួកក្រុមកិលេសនោះ, ព្រោះជាចិត្តបរិសុទ្ធិហើយ ទើបជាធម្មជាតិដែលវៀរចាកការរាាំង រមែងតំណើរទៅកាន់សមថៈនិមិត្ត ដែលជាកណ្តាល ។

បឋមជ្ឈានមានបដិបទាវិសុទ្ធិ ជាខាងដើម (ចិដក ៧0) [៨0]

បឋមស្ស ឈានស្ស បដិបទាវិសុទ្ធិ អាទិ

បឋមជ្ឈានមានបដិបទាវិសុទ្ធិ ជាខាងដើម

អាទិស្ស កតិ លក្ខណានិ?

តើ បដិបទាវិសុទ្ធិ ជាខាងដើមមានលក្ខណៈប៉ុន្មានយ៉ាង?

អាទិស្ស តីណិ លក្ខណានិ

បដិបទាវិសុទ្ធិជាខាងដើមមានលក្ខណៈ ៣ យ៉ាង គឺ ៖

១. **យោ តស្ស បរិបន្ថោ, តតោ ចិត្តំ វិសុជ្ឈតិ,**

ធម៌ណា ជាការអន្តរាយដល់បឋមជ្ឈាននោះ, ចិត្តរមែងបរិសុទ្ធិចាកធម៌នោះ,

២. **វិសុទ្ធត្តា ចិត្តំ មជ្ឈិមំ សមថនិមិត្តំ បដិបជ្ជតិ,**

ចិត្តរមែងដើរឆ្ពោះទៅកាន់សមថនិមិត្ត ជាកណ្តាលព្រោះសេចក្តីល្អស្អាត,

៣. **បដិបន្នត្តា តត្ត ចិត្តំ បក្ខន្ទតិ។**

ចិត្តរមែងស្ទុះទៅក្នុងសមថនិមិត្តនោះ ព្រោះការដើរឆ្ពោះទៅ។

យញ្ច បរិបន្ថតោ ចិត្តំ វិសុជ្ឈតិ,

គឺត្រង់ដែលចិត្តបរិសុទ្ធិ ចាកធម៌ជាការអន្តរាយ ១,

យញ្ច វិសុទ្ធត្តា ចិត្តំ មជ្ឈិមំ សមថនិមិត្តំ បដិបជ្ជតិ,

ត្រង់ដែលចិត្តដើរឆ្ពោះទៅកាន់សមថនិមិត្តជាកណ្តាល ព្រោះសេចក្តីល្អស្អាត ១,

យញ្ច បដិបន្នត្តា តត្ត ចិត្តំ បក្ខន្ទតិ។

ត្រង់ដែលចិត្តស្ទុះទៅក្នុងសមថនិមិត្តនោះ ព្រោះការដើរឆ្ពោះទៅ ១ ។

បឋមស្ស ឈានស្ស បដិបទាវិសុទ្ធិ អាទិ។

(ទាំង ៣ យ៉ាងនេះ) ឈ្មោះថា បដិបទាវិសុទ្ធិ ជាខាងដើមរបស់បឋមជ្ឈាន។

អាទិស្ស ឥមានិ តីណិ លក្ខណានិ។

នេះឯងជាលក្ខណៈ ៣ យ៉ាងរបស់ការចម្រើនរឿយៗ នៃការសម្ងឹងពិនិត្យជាកិច្ចកណ្តាល ។

តេន វុច្ចតិ ''បឋមំ ឈានំ អាទិកល្យាណញ្ចេវ ហោតិ លក្ខណាសម្បន្នញ្ច''។

ព្រោះហេតុនោះ លោកពោលថា "បឋមជ្ឈានមានលំអក្នុងកណ្តាលផង និងបរិបូរណ៌ដោយលក្ខណៈផង" ។

បឋមជ្ឈានមានបដិបទាវិសុទ្ធិ ជាខាងដើម (អដ្ឋកថា)

មជ្ឈិមំ សមថនិមិត្តំ ជាម សមប្បវត្តោ អប្បនាសមាធិយេវ។

*អប្បនាសមាធិ ដែលប្រព្រឹត្តទៅស្មើៗ នោះឯង ឈ្មោះថា **សមថនិមិត្ត ដែលជាកណ្តាល** ។*

តទនន្តរំ បន បុរិមចិត្តំ ឯកសន្តតិបរិណាមនយេន តថត្តំ ឧបគច្ឆមានំ មជ្ឈិមំ សមថនិមិត្តំ បដិបជ្ជតិ ជាម។

*ក៏ក្នុងលំដាប់នោះ ចិត្តដួងខាងដើមចូលដល់ភាវៈយ៉ាងនោះ ដោយន័យនៃការប្រព្រឹត្តិទៅរបស់សន្តតិតែមួយ ឈ្មោះថា **រមែងតំណើរទៅ** កាន់សមថៈ*

និមិត្តដែលជាកណ្តាល ។

ឯវំ បដិបន្នត្តា តថត្តុបគមនេន **តត្ត បក្ខន្ទតិ** ជាម។

ចិត្តឈ្មោះថា ***ស្ទុះទៅក្នុងសមថនិមិត្តនោះ*** *ដោយការចូលដល់ភាវៈយ៉ាងនោះ* ***ព្រោះជាចិត្តដំណើរទៅហើយ*** *យ៉ាងនេះ ។*

ឯវំ តាវ បុរិមចិត្តេ វិជ្ជមានាការនិច្ឆានិកា បឋមស្ស ឈានស្ស ឧប្បាទក្ខណោយេវ អាគមនវសេន បដិបទាវិសុទ្ធិ វេទិតព្វា។

គប្បីជ្រាបបដិបទាវិសុទ្ធិ ដោយអំណាចការមកក្នុងខណៈកើតនៃបឋមជ្ឈាននោះឯង ដែលឲ្យសម្រេចអាការៈដែលមាននៅក្នុងចិត្តដួងខាងដើមយ៉ាងនេះមុន ។

បឋមជ្ឈាន មានការសម្លឹងពិនិត្យ ជាកណ្តាល (បិដក ៧0)[៨១]

បឋមស្ស ឈានស្ស ឧបេក្ខានុព្រូហនា មជ្ឈេ។

បឋមជ្ឈាន មានការចម្រើនរឿយៗ នៃការសម្លឹងពិនិត្យ ជាកណ្តាល ។

មជ្ឈស្ស កតិ លក្ខណានិ?

តើការសម្លឹងពិនិត្យ ជាកិច្ចកណ្តាលមានលក្ខណៈប៉ុន្មានយ៉ាង?

មជ្ឈស្ស តីណិ លក្ខណានិ។

ការសម្លឹងពិនិត្យ ទុកជាកិច្ចកណ្តាលមានលក្ខណៈ ៣ យ៉ាងគឺ៖

๑. **វិសុទ្ធំ ចិត្តំ អជ្ឈុបេក្ខតិ,**

ចិត្តដែលបរិសុទ្ធិ រមែងសម្លឹងផ្ទៀងផ្ទាត់(គឺ មើលសង្កេត),

๒. **សមថបដិបន្នំ អជ្ឈុបេក្ខតិ,**

ចិត្តដែលដើរឆ្ពោះទៅរកសមថៈ(គឺ មើលជិតៗ),

៣. **ឯកគ្គតុបដ្ឋានំ អជ្ឈុបេក្ខតិ។**

រមែងសម្លឹងផ្ទៀងផ្ទាត់នូវចិត្តដែលតាំងឡើងក្នុង ឯកគ្គៈ។

យញ្ច វិសុទ្ធំ ចិត្តំ អជ្ឈុបេក្ខតិ,

រមែងសំឡឹងផ្ទៀងផ្ទាត់ គឺត្រង់ដែលចិត្តបរិសុទ្ធិ សម្លឹងផ្ទៀងផ្ទាត់ ១,

យញ្ច សមថបដិបន្នំ អជ្ឈុបេក្ខតិ,

ត្រង់ដែលចិត្ត ដើរឆ្ពោះទៅរកសមថៈ សម្លឹងផ្ទៀងផ្ទាត់ ១,

យញ្ច ឯកគ្គតុបដ្ឋានំ អជ្ឈុបេក្ខតិ ,

ត្រង់ដែលចិត្តតាំងឡើងនៅក្នុងឯកគ្គៈ សម្លឹងផ្ទៀងផ្ទាត់ ១,

បឋមស្ស ឈានស្ស ឧបេក្ខានុព្រូហនា មជ្ឈេ។

(ទាំង ៣ យ៉ាងនេះ) ឈ្មោះថា ការចម្រើនរឿយៗ នៃការសម្លឹងពិនិត្យ ទុកជាកណ្តាលនៃបឋមជ្ឈាន ។

មជ្ឈស្ស ឥមានិ តីណិ លក្ខណានិ។

នេះឯង ជាលក្ខណៈ ៣ យ៉ាងរបស់ការចម្រើនរឿយៗ នៃការសម្លឹង ពិនិត្យជាកិច្ចកណ្តាល ។

តេន វុច្ចតិ "បឋមំ ឈានំ មជ្ឈេកល្យាណញ្ចេវ ហោតិ លក្ខណាសម្បន្នញ្ច"។

ព្រោះហេតុនោះ លោកពោលថា "បឋមជ្ឈានមានលំអក្នុងកណ្តាលផង និងបរិបូរដោយលក្ខណៈផង" ។

បឋមជ្ឈាន មានការរសម្លឹងពិនិត្យ ជាកណ្តាល (អដ្ឋកថា)

ឯវំ វិសុទ្ធស្ស បន តស្ស បុន វិសោធេតព្វាការតោ វិសោធនេ ព្យាបារំ អកភោត្តោ **វិសុទ្ធំ ចិត្តំ អជ្ឈុបេក្ខតិ** នាម។

*ក៏ព្រោះចិត្តនោះដែលបរិសុទ្ធិយ៉ាងនេះ ទើបមិនមានវត្ថុដែលនឹងត្រូវធ្វើឲ្យម៉ត់ចត់តទៅទៀត ព្រះយោគាវចរកាលមិនធ្វើនូវសេចក្តីខ្វល់ខ្វាយក្នុងការធ្វើចិត្តឲ្យម៉ត់ចត់ទើបឈ្មោះថា **ចិត្តដែលបរិសុទ្ធិ រមែងសម្លឹងផ្ទៀងផ្ទាត់(គឺ តម្កល់ធម្មតា។ ជាឧបេក្ខានូវចិត្តដែលបរិសុទ្ធិហើយ)** ។*

សមថការូបគមនេន សមថបដិបន្នស្ស បុន សមាធានេ ព្យាបារំ អកភោត្តោ **សមថបដិបន្នំ អជ្ឈុបេក្ខតិ** នាម។

*ព្រះយោគីអ្នកបដិបត្តិ កាលមិនធ្វើនូវសេចក្តីខ្វល់ខ្វាយក្នុងភាពតម្កល់មាំតទៅនៃចិត្ត ដែលតំណើរទៅកាន់សមថៈ ដោយការចូលដល់ភាវៈនៃសមថៈ ឈ្មោះថា **ចិត្តដែលដើរផ្ងោះទៅរកសមថៈ(គឺ រមែងតម្កល់ធម្មតា។ នូវចិត្តដែលដំណើរផ្ងោះទៅកាន់សមថៈ)** ។*

សមថបដិបន្នការតោ ឯវ ចស្ស កិលេសសំសគ្គំ បហាយ ឯកត្តេន ឧបដ្ឋិតស្ស បុន ឯកត្តុបដ្ឋានេ ព្យាបារំ អកភោត្តោ **ឯកត្តុបដ្ឋានំ អជ្ឈុបេក្ខតិ** នាម។

*ព្រោះចិត្តនោះ លះចោលដោយកិលេសប្រាកដភាវៈតែមួយ(ឯកត្តៈ) ជាធម្មជាតិផ្ងោះទៅកាន់សមថៈតែម្យ៉ាង លោកទើបមិនត្រូវធ្វើនូវសេចក្តីខ្វល់ខ្វាយក្នុងការចូលទៅប្រាកដដោយភាវៈដូចគ្នាម្តងទៀត ឈ្មោះថា **រមែងសម្លឹងផ្ទៀងផ្ទាត់ នូវចិត្តដែលដំឡើងក្នុងឯកត្តៈ(គឺ រមែងតម្កល់ធម្មតា។ នូវភាពប្រាកដដោយភាវៈដូចគ្នា)** ។*

ឯវំ តត្រមជ្ឈត្តុបេក្ខាយ កិច្ចវសេន ឧបេក្ខាឧព្ភូហនា វេទិតព្វា។

គប្បីជ្រាបនូវសេចក្តីការចម្រើនរឿយៗ នៃឧបេក្ខា(ការសម្លឹងពិនិត្យ) ដោយអំណាចកិច្ចនៃតត្រមជ្ឈត្តុបេក្ខា ដោយប្រការដូច្នេះ ។

យេ បនេតេ ឯវំ ឧបេក្ខានុព្រូហិតេ តត្ត ជាតា សមាធិបញ្ញា-សង្ខាតា យុតនទ្ធធម្មា អញ្ញមញ្ញំ អនតិវត្តមានា ហុត្វា បវត្តា, យានិ ច សទ្ធាទីនិ ឥន្ទ្រិយានិ ជាជាកិលេសេហិ វិមុត្តត្តា វិមុត្តិរសេន ឯករសានិ ហុត្វា បវត្តានិ, យំ ចេស តទុបគំ តេសំ អនតិវត្តនឯករសភាវំ អនុច្ឆវិកំ វីរិយំ ឧបាយតិ, យា ច តស្ស តស្មឹ ខណេ បវត្តា អាសេវនា, សព្ពេបិ តេ អាការា យស្មា ញាណេន សំកិលេសភេជនេសុ តំ តំ អាទីនវញ្ច អានិសំសញ្ច ទិស្វា តថា តថា សម្បហំសិតត្តា វិសោធិតត្តា បរិយោទាបិតត្តា និប្ផន្នា, តស្មា ឆន្នំ អនតិវត្តនាទិការសាធនេន បរិយោទាបកស្ស ញាណស្ស កិច្ចនិប្ផត្តិរសេន សម្បហំសនា វេទិតព្វាតិ វុត្តំ។

លោកពោលទុកថា ធម៌ដែលជាគូនិងគ្នា គឺសមាធិជាគូនិងបញ្ញា ដែលកើតឡើងក្នុងចិត្តនោះ ដែលការចម្រើនឧបេក្ខាទៅតាមលំដាប់យ៉ាងនោះណា ជាសភាវៈប្រព្រឹត្តទៅមិនកន្ទងគ្នានិងគ្នាបាន, និងជាឥន្ទ្រិយទាំងឡាយមានសទ្ធាជាដើមនោះ ជាធម្មជាតិដែលមានរសដូចគ្នា ដោយវិមុត្តិរស ព្រោះហេតុផុតចាកកិលេសផ្សេងៗ, ម្យ៉ាងទៀត ព្រះយោគាវចរនេះ រមែងញុំាងនូវសេចក្តីព្យាយាមដែលសមគួរដល់សមាធិ និងបញ្ញានោះ គឺសមគួរដល់ភាវៈដែលប្រព្រឹត្តទៅមិនកន្ទងគ្នា និងភាវៈដែលមានរសតែមួយជាមួយគ្នាឲ្យប្រព្រឹត្តទៅ, ម្យ៉ាងទៀត ការសេពរហូតទៅជាទំលាប់ទៅក្នុងខណៈនោះ របស់ព្រះយោគីណា, អាការៈទាំងនោះព្រមទាំងសម្រេចហើយ ព្រោះឃើញនូវទោស និងអានិសង្សនោះៗ ក្នុងការសៅហ្មង និងភាពក្ខីជ្ជាដោយញាណ ហើយធ្វើឲ្យរីករាយ, ធ្វើឲ្យបរិសុទ្ធិ ធ្វើឲ្យក្លៀវក្លា ដោយប្រការៈនោះៗ, ព្រោះហេតុនោះ គប្បីជ្រាបនូវសេចក្តីរីករាយដោយអំណាចការសម្រេចកិច្ចនៃញាណ ដែលជាតួធ្វើឲ្យក្លៀវក្លា ដោយការ

ធ្វើឲ្យសម្រេចភាវៈមានការប្រព្រឹត្តទៅមិនកន្ទក់គ្នា ជាដើម នៃធម្មទាំងឡាយ នោះ ។

តត្ត យស្មា ឧបេក្ខាវសេន ញាណំ ចាកដំ ហោតិ, យថាហ

ក្នុងសេចក្តីនេះ ព្រោះញាណប្រាកដដោយអំណាចឧបេក្ខា, ដូចជាពាក្យដែលលោកពោលទុកមកថា ៖

"តថាបគ្គហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខតិ, ឧបេក្ខាវសេន បញ្ញាវសេន បញ្ញិន្ទ្រិយំ អធិមត្តំ ហោតិ។

"ចិត្តដែលបម្រុងហើយយ៉ាងនោះ រមែងតម្កល់ធម្មតា(ជាឧបេក្ខា)បានយ៉ាងល្អ,បញ្ញិន្ទ្រិយជាធម្មជាតិមានប្រមាណក្រៃលែង ដោយអំណាចឧបេក្ខា និងបញ្ញា ។

ឧបេក្ខាវសេន ជានត្តកិលេសេហិ ចិត្តំ វិមុច្ចតិ, វិមោក្ខវសេន បញ្ញាវសេន បញ្ញិន្ទ្រិយំ អធិមត្តំ ហោតិ។

ចិត្តរមែងរួចផុតចាកពីកិលេសផ្សេងៗ ដោយអំណាចឧបេក្ខា, បញ្ញិន្ទ្រិយជាធម្មជាតិដែលមានប្រមាណក្រៃលែង ដោយអំណាចវិមោក្ខ ដោយអំណាចបញ្ញា ។

វិមុត្តត្តា តេ ធម្មា ឯករសា ហោន្តិ, ឯករសដ្ឋេន ភាវនា"តិ [១៨] ។

ព្រោះចិត្តរួចផុតហើយ ធម៌ទាំងនោះទើបជាសភាវៈដែលមានរសដូចគ្នាតែម្យ៉ាង, ឈ្មោះថា ភាវនាមានអត្ថថា មានរសដូចគ្នាតែម្យ៉ាង" ដូច្នេះ ។

---

១៨ (បដិ. ម.) ។

បឋមជ្ឈាន មានការរីករាយព្រម ជាខាងចុង
(ចិដក ៧០) [៨២]

បឋមស្ស ឈានស្ស សម្បហំសនា បរិយោសានំ។

បឋមជ្ឈាន មានការរីករាយព្រម ជាខាងចុង ។

បរិយោសានស្ស កតិ លក្ខណានិ? បរិយោសានស្ស ចត្តារិលក្ខណានិ។

តើការរីករាយព្រម ជាខាងចុង មានលក្ខណៈប៉ុន្មានយ៉ាង ? ការរីករាយព្រម ជាខាងចុងមានលក្ខណៈ ៤ យ៉ាង គឺ ៖

១. **តត្ត ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន សម្បហំសនា,**

ការរីករាយព្រមដោយអត្ថថា មិនប្រព្រឹត្តកន្លងនូវពួកធម៌ដែលកើតក្នុងបឋមជ្ឈាននោះ ១,

២. **ឥន្ទ្រិយានំ ឯការសដ្ឋេន សម្បហំសនា,**

ការរីករាយព្រមដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ ១,

៣. **តទុបតវីរិយវាហនដ្ឋេន សម្បហំសនា ។**

ការរីករាយព្រមដោយអត្ថថា នាំទៅនូវការព្យាយាមគួររដល់ឥន្ទ្រិយនោះ ១ ។

៤. **អាសេវនដ្ឋេន សម្បហំសនា។**

ការរីករាយព្រមដោយអត្ថថា សេព ១ ,

បឋមស្ស ឈានស្ស សម្បហំសនា បរិយោសានំ,

(ទាំង ៤ យ៉ាងនេះ) ឈ្មោះថា ការរីករាយព្រមជាខាងចុងរបស់បឋមជ្ឈាន ។

បរិយោសានស្ស ឥមានិ ចត្តារិ លក្ខណានិ។

នេះឯងការរីករាយព្រម ជាខាងចុងមានលក្ខណៈ ៤ យ៉ាង ។

តេន វុច្ចតិ "បឋមំ ឈានំ បរិយោសានកល្យាណញ្ចេវ ហោតិ លក្ខណាសម្បន្នញ្ច"។

ព្រោះហេតុនោះ លោកពោលថា "បឋមជ្ឈានមានលំអខាងចុងផង បរិបូរដោយលក្ខណៈផង" ។

ឯវំ តិវត្តកតំ ចិត្តំ តិវិធកល្យាណកំ ឧសលក្ខណាសម្បន្នំ

ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការយ៉ាងនេះ មានលំអ ៣ ប្រការដូចបានពោលមកហើយ យ៉ាងនេះឯង រមែងជាចិត្តបរិបូរដោយលក្ខណៈ ១០ យ៉ាងគឺ៖

១. **វិតក្កសម្បន្នញ្ចេវ ហោតិ**

បរិបូរណ៌ដោយវិតក ១

២. **វិចារសម្បន្នញ្ច**

បរិបូរណ៌ដោយវិចារ ១

៣. **បីតិសម្បន្នញ្ច**

បរិបូរណ៌ដោយបីតិ ១

៤. **សុខសម្បន្នញ្ច**

បរិបូរណ៌ដោយសុខ ១

៥. **ចិត្តស្ស អធិដ្ឋានសម្បន្នញ្ច**

បរិបូរណ៌ដោយការអធិដ្ឋានចិត្ត ១

៦. **សទ្ធាសម្បន្នញ្ច**

បរិបូរណ៍ដោយសទ្ធា ១

៧. **វីរិយសម្បន្នញ**

បរិបូរណ៍ដោយវីរិយ: ១

៨. **សតិសម្បន្នញ**

បរិបូរណ៍ដោយសតិ ១

៩. **សមាធិសម្បន្នញ**

បរិបូរណ៍ដោយសមាធិ ១

១០. **បញ្ញាសម្បន្នញ។**

បរិបូរណ៍ដោយបញ្ញា ១ ។

បឋមជ្ឈាន មានការរីករាយព្រម ជាខាងចុង (អដ្ឋកថា)

តស្មា ញាណកិច្ចភូតា សម្បហំសនា បរិយោសានន្តិ វុត្តា។

*ព្រោះហេតុនោះ **សេចក្តីរីករាយ** ដែលជាកិច្ចនៃញាណទើបលោកពោលថា **ជាទីបំផុត** ។*

"ឯវំ តិវត្តកត"ន្តិអាទីនិ តស្សេវ ចិត្តស្ស ថោមនវចនានិ។

*ពាក្យថា "**ដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការនេះ**" ជាដើម ជាពាក្យសរសើរនូវចិត្តនោះ នុ៉ះឯង ។*

តត្ត "ឯវំ តិវត្តកត"ន្តិ ឯវំ យថាវុត្តេន វិធិនា បដិបជ្ជារិសុទ្ធិបក្ខន្ទន-ឧបេក្ខានុព្រូហនាញាណសម្បហំសនាវសេន តិវិធភាវំ កតំ។

ក្នុងពាក្យនោះ ត្រង់ពាក្យថា ***ដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការនេះ*** *គឺដល់សភាវៈ ៣ ប្រការ ដោយអំណាចការស្ទុះទៅកាន់បដិបទាវិសុទ្ធិ ការចម្រើននៃឧបេក្ខា និងការរីករាយនៃញាណតាមវិធីដែលបានពោលមកហើយ យ៉ាងនេះ។*

"វិតក្កសម្បន្ន"ន្តិ កិលេសក្ខោភវិរហិតត្តា វិតក្កេន សុន្ទរភាវំ បត្តំ កតំ។

*ពាក្យថា "**បរិបូរណ៌ដោយវិតក្ក**" មានន័យថា ការដល់ហើយ គឺការបន្ទុះហើយនូវភាវៈដែលយ៉ាងល្អដោយវិតក្ក ព្រោះវៀរចាកការកម្រើកនៃកិលេស។*

"ចិត្តស្ស អធិដ្ឋានសម្បន្ន"ន្តិ តស្មឹយេវ អារម្មណេ ចិត្តស្ស និរន្តរប្បវត្តិសង្ខាតេន អធិដ្ឋានេន សម្បន្នំ អនូនំ។

*ពាក្យថា "**បរិបូរណ៌ដោយការអធិដ្ឋានចិត្ត**" មានន័យថា សម្បូរហើយ គឺការមិនខ្វះខាតដោយការអធិដ្ឋាន ពោលគឺការប្រព្រឹត្តិទៅមិនដាច់ចន្លោះនៃនិមិត្តក្នុងអារម្មណ៍នោះ នុ៎ះឯង។*

យថា អធិដ្ឋានវសិយំ អធិដ្ឋានន្តិ ឈានប្បវត្តិ, តថា ឥធាបិ ចិត្តស្ស អធិដ្ឋានន្តិ ចិត្តេកគ្គតាបិ យុជ្ជតិ។

សូម្បី ឯកគ្គតានៃចិត្តរមែងគួរពោលថា ជាការអធិដ្ឋាននៃចិត្ត សូម្បីក្នុងពាក្យថា បរិបូរណ៌ដោយការអធិដ្ឋាននៃចិត្តនេះ ដូចសេចក្តីប្រព្រឹត្តទៅនៃញាណថា រមែងគួរពោលថា ជាការអធិដ្ឋានក្នុងការអធិដ្ឋានវសី ដូច្នោះ។

តេន ហិ ឯកស្មឹយេវ អារម្មណេ ចិត្តំ អធិដ្ឋាតិ, ន ឯត្ត វិក្ខិបតីតិ។

ព្រោះហេតុនោះឯង ចិត្តរមែងអធិដ្ឋាននៅក្នុងអារម្មណ៍តែមួយប៉ុណ្ណោះ, មិនរាយមាយទៅទីដទៃទេ។

"សមាធិសម្បន្ន"ន្តិ វិសុំ វុត្តត្តា បន វុត្តនយេនេវ កហេតព្វំ។

ព្រោះលោកពោលទុក ក្នុងចំណែកមួយថា "បរិបូរណ៌ដោយសមាធិ"

ដូច្នេះទើបគួរកាន់យកតាមន័យដែលបានពោលមកហើយនោះ នុ៎ះឯង ។

អថ វា សមាធិស្សេវ ឈានសង្គហិតត្តា ចិត្តស្ស អធិដ្ឋានសម្ប-ន្នត្តិ ឈានង្គបញ្ចកវសេន វុត្តំ។ សមាធិសម្បន្នត្តិ ឥន្ទ្រិយសង្គហិតត្តា ឥន្ទ្រិយបញ្ចកវសេន ។

*ន័យម្យ៉ាងទៀត ព្រោះហេតុដែលសមាធិនោះឯង សង្គ្រោះដោយអង្គ ឈាន ទើបលោកពោលដោយអំណាចក្រុម ៥ នៃអង្គឈានថា **បរិបូរណ៌ដោយ ការអធិដ្ឋាននៃចិត្ត**, ។ ពាក្យថា **បរិបូរដោយសមាធិ** លោកពោលដល់អំណាច ក្រុម ៥ នៃឥន្ទ្រិយ ព្រោះសង្គ្រោះដោយ ឥន្ទ្រិយ ។*

ទុតិយជ្ឈាន (ចិដក ៧០) [៨៣]

ទុតិយស្ស ឈានស្ស កោ អាទិ, កឹ មជ្ឈេ, កឹ បរិយោសានំ?

តើទុតិយជ្ឈាន មានអ្វីជាខាងដើម, មានអ្វីជាកណ្តាល, មានអ្វីជា ខាងចុង?

ទុតិយស្ស ឈានស្ស បដិបទាវិសុទ្ធិ អាទិ,

ទុតិយជ្ឈាន មានបដិបទាវិសុទ្ធិ ជាខាងដើម,

ឧបេក្ខានុព្រូហនា មជ្ឈេ,

មានការចម្រើនរឿយៗ នៃការសម្លឹងពិនិត្យ ជាកណ្តាល,

សម្បហំសនា បរិយោសានំ។...បេ....។[១៩]

មានការរីករាយព្រម ជាខាងចុង ។ ល ។

---

១៩ បិ. ៧០. [៨០.៨១.៨២] ។

ឯវំ តិវត្តកតំ ចិត្តំ

ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ

តិវិធកល្យាណកំ ឧសលក្ខណសម្បន្នំ

មានលំអ ៣ ប្រការដូចបានពោលមកហើយ យ៉ាងនេះឯង រមែងជាចិត្ត បរិបូរណ៌ដោយលក្ខណៈ ១០ យ៉ាង គឺ ៖

១. **វិចារសម្បន្នញ្ចេវ**[(២០)]

បរិបូរណ៌ដោយវិចារ ១

២. **បីតិសម្បន្នញ្ចេវ ហោតិ**

បរិបូរណ៌ដោយបីតិ ១

៣. **សុខសម្បន្នញ្ច**

បរិបូរណ៌ដោយ សុខ ១

៤. **ចិត្តស្ស អធិដ្ឋានសម្បន្នញ្ច**

បរិបូរណ៌ដោយ ការអធិដ្ឋានចិត្ត ១

៥. **សទ្ធាសម្បន្នញ្ច**

បរិបូរណ៌ដោយសទ្ធា ១

៦. **វីរិយសម្បន្នញ្ច**

បរិបូរណ៌ដោយ វីរិយ ១

៧. **សតិសម្បន្នញ្ច**

បរិបូរណ៌ដោយសតិ ១

---

២០ ក្នុង ធត្តសង្គាយនាលើកទី ៦មិនមាន តែបិដកខ្មែរ៣០. ទំ. ៩៩. [៨៣]មាន ។

៨. សមាធិសម្បន្នញ

បរិបូរណ៍ដោយ សមាធិ ១

៩. បញ្ញាសម្បន្នញ។

បរិបូរណ៍ដោយ បញ្ញា ១ ។

ចប់ទុតិយជ្ឈាន

ទុតិយជ្ឈាន (អដ្ឋកថា)

ទុតិយជ្ឈានាទីសុ បន អលព្ភមានានិ បទានិ បហាយ លព្ភមានកាវសេន "**បីតិសម្បន្ន**"ន្តិអាទិ វុត្តំ។

*ប៉ុន្តែ លោកលះបទដែលមិនបាននៅក្នុងទុតិយជ្ឈានជាដើម ដោយពោលពាក្យថា "**បរិបូរណ៍ដោយបីតិ**" ដោយអំណាចធម៌ដែលមាននៅ ។*

តតិយជ្ឈាន (បិដក៧០) [៨៤]

តតិយស្ស ឈានស្ស កោ អាទិ, កឺ មជ្ឈេ, កឺ បរិយោសានំ។...បេ...។

តើតតិយជ្ឈាន មានអ្វីជាខាងដើម, មានអ្វីជាកណ្តាល, មានអ្វីជាខាងចុង ។...ល...។

ឯវំ តិវត្តតតំ ចិត្តំ តិវិធកល្យាណកំ

ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ មានលំអ ៣ ប្រការ ដូចបានពោលមកហើយ យ៉ាងនេះឯង

ឧសលក្ខណសម្បន្នំ

រមែងជាចិត្តបរិបូរដោយលក្ខណ ១០ យ៉ាងគឺ ៖

១. **បីតិសម្បន្នញ្ចេវ**[២១]

បរិបូរណ៌ដោយបីតិ ១

២. **សុខសម្បន្នញ្ចេវ ហោតិ**

បរិបូរណ៌ដោយសុខ ១

៣. **ចិត្តស្ស អធិដ្ឋានសម្បន្នញ្ច**

បរិបូរណ៌ដោយការអធិដ្ឋានចិត្ត ១

៤. **សទ្ធាសម្បន្នញ្ច**

បរិបូរណ៌ដោយសទ្ធា ១

៥. **វីរិយសម្បន្នញ្ច**

បរិបូរណ៌ដោយវីរិយ ១

៦. **សតិសម្បន្នញ្ច**

បរិបូរណ៌ដោយសតិ ១

៧. **សមាធិសម្បន្នញ្ច**

បរិបូរណ៌ដោយសមាធិ ១

៨. **បញ្ញាសម្បន្នញ្ច។**

---

២១ ក្នុង ធម្មសង្គាយនាលើកទី ៦មិនមាន តែបិដកខ្មែរ៧០.ទំ៩៩. [៨៦]មាន ។

បរិបូរណ៌ដោយបញ្ញា ១ ។

ចតុត្ថជ្ឈាន (ចិដក ៧០) [៨៥]

ចតុត្ថស្ស ឈានស្ស កោ អាទិ, កឹ មជ្ឈេ, កឹ បរិយោសានំ។ បេ ។

តើចតុត្ថជ្ឈាន មានអ្វីជាខាងដើម ?, មានអ្វីជាកណ្តាល ?, និងមានអ្វីជាខាងចុង ? ។ ល ។

ឯវំ តិវត្តកតំ ចិត្តំ តិវិធកល្យាណកំ ឧសលក្ខណសម្បន្នញ្ច

ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ មានលំអ ៣ ប្រការ ដូចបានពោលមកហើយយ៉ាងនេះឯង រមែងជាចិត្ត បរិបូរដោយលក្ខណ ១០ យ៉ាងគឺ៖

១. ឧបេក្ខាសម្បន្នញ្ចេវ ហោតិ

បរិបូរណ៌ដោយឧបេក្ខា ១

២. ចិត្តស្ស អធិដ្ឋានសម្បន្នញ្ច

បរិបូរណ៌ដោយការអធិដ្ឋាននៃចិត្ត ១

៣. សទ្ធាសម្បន្នញ្ច

បរិបូរណ៌ដោយសទ្ធា ១

៤. វីរិយសម្បន្នញ្ច

បរិបូរណ៌ដោយវីរិយ ១

៥. សតិសម្បន្នញ្ច

បរិបូរណ៌ដោយសតិ ១

៦. សមាធិសម្បន្នញ្ច

បរិបូរណ៌ដោយសមាធិ ១

៧. បញ្ញាសម្បន្នញ្ច ។

បរិបូរណ៌ដោយបញ្ញា ១ ។

អរូបសមាបត្តិ ៤ (ចិដក ៧០) [៨៦]

១. អាកាសានញ្ចាយតនសមាបត្តិយា។...បេ...។

អាកាសានញ្ចាយតនសមាបត្តិ ១

២. វិញ្ញាណញ្ចាយតនសមាបត្តិយា...

វិញ្ញាណញ្ចាយតនសមាបត្តិ ១

៣. អាកិញ្ចញ្ញាយតនសមាបត្តិយា...

អាកិញ្ចញ្ញាយតនសមាបត្តិ ១

៤. នេវសញ្ញានាសញ្ញាយតនសមាបត្តិយា

នេវសញ្ញានាសញ្ញាយតនសមាបត្តិ ១

កោ អាទិ, កឹ មជ្ឈេ, កឹ បរិយោសានំ។...បេ...។

តើមានអ្វីជាខាងដើម ?, មានអ្វីជាកណ្តាល ?, និងមានអ្វីជាខាងចុង ? ។...ល...។

ឯវំ តិវត្តតនំ ចិត្តំ តិវិធកល្យាណកំ ឧសលក្ខណាសម្បន្នំ

ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ មានលំអ ៣ ប្រការ ដូចបានពោលមកហើយ យ៉ាងនេះ រមែងជាចិត្តបរិបូរណ៌ដោយលក្ខណ ១០ យ៉ាងគឺ ៖

១. ឧបេក្ខាសម្បន្នញ្ចេវ ហោតិ

បរិបូរណ៌ដោយឧបេក្ខា ១

២. ចិត្តស្ស អធិដ្ឋានសម្បន្នំ ច។...បេ...។

បរិបូរណ៌ដោយការអធិដ្ឋានចិត្ត ១ ។...ល...។

៧. បញ្ញាសម្បន្នញ្ច។

និងបរិបូរណ៌ដោយបញ្ញា ១ ។

អនិច្ចានុបស្សនា (ចិដក ៧0) [៨៧]

អនិច្ចានុបស្សនាយ កោ អាទិ, កឹ មជ្ឈេ, កឹ បរិយោសានំ ។...បេ...។

តើអនិច្ចានុបស្សនា មានអ្វីជាខាងដើម ?, មានអ្វីជាកណ្តាល ?, និងមានអ្វីជាខាងចុង ? ។....ល...។

ឯវំ តិវត្តកតំ ចិត្តំ តិវិធកល្យាណកំ ទសលក្ខណសម្បន្នំ

ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ៣ ប្រការ មានលំអ ៣ ប្រការដូចបានពោលមកហើយ យ៉ាងនេះឯង រមែងជាចិត្តបរិបូរណ៌ដោយលក្ខណ ១០ យ៉ាងគឺ ៖

១. វិតក្កសម្បន្នញ្ចេវ ហោតិ

បរិបូរណ៌ដោយវិតក្កៈ ១

២. វិចារសម្បន្នញ្ច

បរិបូរណ៌ដោយវិចារៈ ១

៣. បីតិសម្បន្នញ្ច

បរិបូរណ៌ដោយបីតិ ១

៤. សុខសម្បន្នញ្ច

បរិបូរណ៌ដោយសុខៈ ១

៥. ចិត្តស្ស អធិដ្ឋានសម្បន្នញ្ច

បរិបូរណ៌ដោយការអធិដ្ឋានចិត្ត ១

៦. សទ្ធាសម្បន្នញ្ច

បរិបូរណ៌ដោយសទ្ធា ១

៧. វីរិយសម្បន្នញ្ច

បរិបូរដោយវីរិយៈ ១

៨. សតិសម្បន្នញ្ច

បរិបូរដោយសតិ ១

៩. សមាធិសម្បន្នញ្ច

បរិបូរដោយសមាធិ ១

១០. បញ្ញាសម្បន្នញ្ច ។

បរិបូរដោយបញ្ញា ១ ។

ខុត្តានុបស្សនាយ។...បេ...។ អនត្តានុបស្សនាយ... និព្វិទានុបស្ស-នាយ... វិរាគានុបស្សនាយ... និរោធានុបស្សនាយ... បដិនិស្សគ្គា-

ឧបស្សជាយ... ខយានុបស្សជាយ... វយានុបស្សជាយ... វិបរិណាមានុបស្សជាយ... អនិមិត្តានុបស្សជាយ... អប្បណិហិតានុបស្សជាយ... សុញ្ញតានុបស្សជាយ... អធិប្បញ្ញាធម្មវិបស្សជាយ... យថាភូតញាណទស្សជាយ... អាទីនវានុបស្សជាយ... បដិសង្ខានុបស្សជាយ... វិវដ្ដនានុបស្សជាយ... បញ្ញាសម្ភន្ទញ្ច។ សោតាបត្តិមគ្គស្ស។...បេ...។ សកទាគាមិមគ្គស្ស... អនាគាមិមគ្គស្ស...។

តើមានអ្វីជាខាងដើម?, មានអ្វីជាកណ្តាល?, និងមានអ្វីជាខាងចុង? នៃទុក្ខានុបស្សនា ។....ល...។ អនត្តានុបស្សនា... និព្វិទានុបស្សនា... វិរាគានុបស្សនា... និរោធានុបស្សនា... បដិនិស្សគ្គានុបស្សនា... ខយានុបស្សនា... វយានុបស្សនា... វិបរិណាមានុបស្សនា... អនិមិត្តានុបស្សនា... អប្បណិហិតានុបស្សនា... សុញ្ញតានុបស្សនា... អធិប្បញ្ញាធម្មវិបស្សនា... យថាភូតញាណទស្សនា... អាទីនវានុបស្សនា... បដិសង្ខានុបស្សនា... វិវដ្ដនានុបស្សនា... បញ្ញាសម្ភន្ទញ្ច ។សោតាបត្តិមគ្គស្ស។...ល... ។ សកទាគាមិមគ្គស្ស... អនាគាមិមគ្គស្ស...។

អនិច្ចានុបស្សនា (អដ្ឋកថាក្ខុទ្ទកនិកាយ ៧០) [៨៧]

អនិច្ចានុបស្សនាឥសុ អដ្ឋារសសុ មហាវិបស្សនាសុ វិតក្កាទយោ បរិបុណ្ណាយេវ តាសំ ភាមាវចរត្តា។

*ធម៌ទាំងឡាយ មានវិតក្កជាដើម បរិបូរក្នុងពេលតែមួយ ក្នុងមហាវិបស្សនា ១៨ **ដែលមានអនិច្ចានុបស្សនា** ជាដើម ព្រោះមហាវិបស្សនា ១៨ ទាំងនោះជាភាមាវចរ។*

ឯតាសុ ច អប្បនាយ អភាវតោ បដិបទាវិសុទ្ធិអាទយោ ខណិកសមាធិវសេន យោជេតព្វា។

ក៏ព្រោះអប្បនាដែលមាននៅក្នុងមហាវិបស្សនាទាំងនេះ បដិបទាវិសុទ្ធិជាដើម ទើបគួរប្រកបដោយអំណាចខណិកសមាធិ។

ចតូសុ មគ្គេសុ បឋមជ្ឈានិកវសេន វិតក្កាទីនំ លព្ភនតោ លព្ភមានកវសេនេវ វិតក្កាទយោ បរិបុណ្ណា វុត្តា។

ព្រោះក្នុងមគ្គទាំង ៤ ធម៌ទាំងឡាយមានវិតក្ក: ជាដើម ដោយអំណាចជាធម៌ដែលប្រកបដោយបឋមជ្ឈាន ទើបលោកពោលធម៌មានវិតក្ក: ជាដើមទុកដោយបរិបូរ ដោយអំណាចជាធម៌ដែលបាននៅក្នុងពេលតែមួយ។

ទុតិយជ្ឈានិកាទីសុ ហិ មគ្គេសុ វិតក្កាទយោ ឈានេសុ វិយ បរិហាយន្តីតិ។

ធម៌ទាំងឡាយមានវិតក្ក:ជាដើម ក្នុងមគ្គទាំងឡាយ មានមគ្គដែលប្រកបដោយទុតិយជ្ឈានជាដើម រមែង(ធ្លាក់ចុះបរិហាយន្តិ) ដូចជាក្នុងឈានទាំងឡាយ នុ៎ះឯង។

ឯត្តាវតា តេរស ភោគានញ្ញាណានិ វិត្ថារតោ និទ្ទិដ្ឋានិ ហោន្តិ។

ដោយពាក្យត្រឹមតែប៉ុណ្ណោះ ជាការសម្តែងខែអធិប្បាយនូវញាណក្នុងភោគទាំង ១៣ ដោយពិស្តារហើយ។

កថំ ? ឯកជ្ឈានេ សមាទហានេន តត្ថេវ អធិមុច្ចនេន តោសជ្ជប្ប-ជហានេន ឧទ្ធច្ចប្បជហានេន ភគប្បជហានេន ព្យាចាទប្បជហានេន សម្បយុត្តានិ ឆ ញាណានិ, ចតូហិ ឯកគ្គេហិ សម្បយុត្តានិ ចត្តារិ ញាណានិ, បដិបទាវិសុទ្ធិឧបេក្ខានុព្រូហនាសម្បហំសនាហិ សម្បយុត្តានិ តីណិ ញាណានីតិ ឯវំ តេរស ញាណានិ និទ្ទិដ្ឋានិ។

សម្តែងខៃអធិប្បាយទុកយ៉ាងដូចម្តេច ? បានសម្តែងខៃអធិប្បាយនូវ ញាណទាំង ១៣ ចំណុចយ៉ាងនេះ គឺ ៖ ញាណ ៦ ចំណុចដែលសម្បយុត្ត ដោយភាពតាំងមាំក្នុងទីតែមួយ ជាមួយគ្នានោះឯង ដោយការលះភាពក្តៅ ក្រហាយ ដោយការលះនូវឧទ្ធច្ច: ដោយការលះនូវរាគ: ដោយការលះនូវ ព្យាបាទ:, ញាណ ៤ ចំណុចទៀតដែលសម្បយុត្តរួមជាមួយទាំង ៤, ញាណ ៣ ចំណុចទៀតសម្បយុត្តជាបដិបទាវិសុទ្ធិ ដោយការចម្រើននូវឧបេក្ខា និងភាព រីករាយ ។

អរហត្តមគ្ត (បិដក ៧០) [៨៨]

អរហត្តមក្តស្ស កោ អាទិ, កឺ មជ្ឈេ, កឺ បរិយោសានំ ? ។

តើព្រះអរហត្តមគ្ត មានអ្វីជាខាងដើម ?, មានអ្វីជាកណ្តាល ?, និងមានអ្វី ជាខាងចុង ? ។

អរហត្តមក្តស្ស បដិបទាវិសុទ្ធិ អាទិ, ឧបេក្ខានុព្រូហនា មជ្ឈេ, សម្បហំសនា បរិយោសានំ។ អរហត្តមក្តស្ស បដិបទាវិសុទ្ធិ អាទិ ។

ព្រះអរហត្តមគ្ត មានបដិបទាវិសុទ្ធិជាខាងដើម, មានការចម្រើនរឿយៗនៃ ការសម្ធឹងពិនិត្យ ជាកណ្តាល, និងមានការរីករាយព្រម ជាខាងចុង ។

អាទិស្ស កតិ លក្ខណានិ ? អាទិស្ស តីណិ លក្ខណានិ។

តើបដិបទាវិសុទ្ធិជាខាងដើម មានប៉ុន្មានយ៉ាង ? បដិបទាវិសុទ្ធិជា ខាងដើមមានលក្ខណ: ៣ យ៉ាងគឺ ៖

១. យោ តស្ស បរិបន្ថោ តតោ ចិត្តំ វិសុជ្ឈតិ,

ធម៌ណាជាសត្រូវ(អន្តរាយ) ដល់អរហត្តមគ្គនោះ ចិត្តរមែងបរិសុទ្ធិចាកធម៌នោះ,

២. **វិសុទ្ធត្តា ចិត្តំ មជ្ឈិមំ សមថនិមិត្តំ បដិបជ្ជតិ,**

ព្រោះសេចក្តីស្អាត ចិត្តរមែងដើរឆ្ពោះទៅកាន់សមថៈនិមិត្ត ជាកណ្តាល,

៣. **បដិបន្នត្តា តត្ត ចិត្តំ បក្ខន្ទតិ។**

ព្រោះការដើរឆ្ពោះ ចិត្តរមែងស្ទុះទៅក្នុងសមថៈនិមិត្តនោះ ។

យញ្ច បរិបន្ថតោ ចិត្តំ វិសុជ្ឈតិ,

ចិត្តរមែងបរិសុទ្ធិ ចាកពីធម៌អន្តរាយ ១,

យញ្ច វិសុទ្ធត្តា ចិត្តំ មជ្ឈិមំ សមថនិមិត្តំ បដិបជ្ជតិ,

ចិត្តរមែងដើរឆ្ពោះទៅកាន់សមថៈនិមិត្ត ដែលជាកណ្តាល ព្រោះសេចក្តីស្អាត ១,

យញ្ច បដិបន្នត្តា តត្ត ចិត្តំ បក្ខន្ទតិ ,

ចិត្តរមែងស្ទុះទៅក្នុងសមថៈនិមិត្តនោះ ព្រោះការដើរឆ្ពោះ ១ ,

អរហត្តមគ្គស្ស បដិបទាវិសុទ្ធិ អាទិ។

(ធម៌ទាំង ៣ យ៉ាងនេះ) ឈ្មោះថា បដិបទាវិសុទ្ធិ ជាខាងដើមរបស់ព្រះអរហត្តមគ្គ។

អាទិស្ស ឥមានិ តីណិ លក្ខណានិ។

នេះឯងលក្ខណៈ ៣ យ៉ាងរបស់បដិបទាវិសុទ្ធិ ជាខាងដើម ។

តេន វុច្ចតិ "អរហត្តមគ្គោ អាទិកល្យាណោ ចេវ ហោតិ លក្ខណសម្បន្នោ ច"។

ព្រោះហេតុនោះ លោកពោលថា ព្រះអរហត្តមគ្គមានលំអខាងដើមផង

និងបរិបូរដោយលក្ខណៈ (៣) ផង ។

អរហត្តមគ្គ មានការសម្លឹងពិនិត្យ ជាកណ្តាល (ចិដក ៧0) [៨៩]

អរហត្តមគ្គស្ស ឧបេក្ខានុព្រូហនា មជ្ឈេ។

អរហត្តមគ្គ មានការចម្រើនរឿយៗ នៃការសម្លឹងពិនិត្យ ជាកណ្តាល ។

មជ្ឈស្ស កតិ លក្ខណានិ ? , មជ្ឈស្ស តីណិ លក្ខណានិ។

តើការសម្លឹងពិនិត្យជាកិច្ចកណ្តាលមានលក្ខណៈ ប៉ុន្មានយ៉ាង ?, ការសម្លឹងពិនិត្យជាកិច្ចកណ្តាល មានលក្ខណ ៣ យ៉ាងគឺ ៖

១. **វិសុទ្ធំ ចិត្តំ អជ្ឈុបេក្ខតិ,**

ចិត្តដែលល្អស្អាត រមែងសម្លឹងផ្ទៀងផ្ទាត់ (យោគីកិក្ខុ រមែងតម្កល់ឧបេក្ខានូវចិត្តដែលបរិសុទ្ធិហើយ),

២. **សមថបដិបន្នំ អជ្ឈុបេក្ខតិ,**

រមែងតម្កល់ធម្មតានូវចិត្តដែលដើរឆ្ពោះទៅរកសមថ,

៣. **ឯកត្តុបដ្ឋានំ អជ្ឈុបេក្ខតិ។**

រមែងតម្កល់ធម្មតា(ជាឧបេក្ខា) នូវចិត្តតាំងឡើងក្នុងឯកត្តៈ (ជាការៈតែមួយ) ។

យញ្ច វិសុទ្ធំ ចិត្តំ អជ្ឈុបេក្ខតិ,

សេចក្តីនេះ យោគីកិក្ខុរមែងសម្លឹងផ្ទៀងផ្ទាត់ គឺត្រង់ដែលចិត្តស្អាត ហើយសម្លឹងផ្ទៀងផ្ទាត់ ១,

យញ្ច សមថបដិបន្នំ អជ្ឈុបេក្ខតិ,

ត្រង់ដែលចិត្តដើរឆ្ពោះទៅរកសមថ:សម្ងឹងផ្ទៀងផ្ទាត់ ១,

យញ្ច ឯកត្តុបដ្ឋានំ អជ្ឈុបេក្ខតិ។

ត្រង់ដែលចិត្តតាំងឡើងក្នុងឯកត្ត:សម្ងឹងផ្ទៀងផ្ទាត់ ១,

តេន វុចូតិ "អរហត្តមក្តោ មជ្ឈេកល្យាណោ ចេវ ហោតិ លក្ខណសម្បន្នោ ច" ។

ព្រោះហេតុនោះ លោកពោលថា អរហត្តមគ្គមានលំអ (ល្អស្អាត) ត្រង់កណ្តាលផង និងបរិបូរណ៍ដោយលក្ខណ:ផង ។

អរហត្តមគ្ត មានការរីករាយព្រម ជាខាងចុង (បិដក ៧០)[៩0]

អរហត្តមក្តស្ស សម្បហំសនា បរិយោសានំ។

អរហត្តមគ្ត មានការរីករាយព្រម ជាខាងចុង ។

បរិយោសានស្ស កតិ លក្ខណានិ ? ,បរិយោសានស្ស ចត្តារិ លក្ខណានិ។

តើការរីករាយព្រមជាខាងចុងមានលក្ខណ ប៉ុន្មានយ៉ាង ? ,ការរីករាយព្រម ជាខាងចុងមានលក្ខណ ៤ យ៉ាងគឺ ៖

១. តត្ត ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន សម្បហំសនា,

ការរីករាយព្រមដោយអត្ថថា មិនប្រព្រឹត្តកន្ងងនូវពួកធម៌ដែលកើតហើយក្នុងអរហត្តមគ្គនោះ ១,

๒. ឥន្ទ្រិយានំ ឯករសដ្ឋេន សម្បហំសនា,

ការរីករាយព្រមដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ ១,

๓. តទុបគវីរិយវាហនដ្ឋេន សម្បហំសនា,

ការរីករាយព្រមដោយអត្ថថា នាំទៅនូវសេចក្តីព្យាយាមគួរដល់ឥន្ទ្រិយនោះ ១,

๔. អាសេវនដ្ឋេន សម្បហំសនា។

ការរីករាយព្រមដោយអត្ថថា សេព ១ ។

អរហត្តមគ្គស្ស សម្បហំសនា បរិយោសានំ។

(ធម៌ទាំង ๔ យ៉ាងនេះ) ឈ្មោះថា ការរីករាយព្រមជាខាងចុងរបស់អរហត្តមគ្គ។

បរិយោសានស្ស ឥមានិ ចត្តារិ លក្ខណានិ។

នេះឯង ការរីករាយព្រម ជាខាងចុងដែលមានលក្ខណ ๔ យ៉ាង ។

តេន វុច្ចតិ – "អរហត្តមគ្គោ បរិយោសានកល្យាណោ ចេវ ហោតិ លក្ខណសម្បន្នោ ច"។

ព្រោះហេតុនោះ លោកពោលថា អរហត្តមគ្គមានលំអខាងចុងផង និងបរិបូរដោយលក្ខណផង ។

ឯវំ តិវត្តកតំ ចិត្តំ តិវិធកល្យាណកំ ឧសលក្ខណសម្បន្នំ

ចិត្តដែលប្រព្រឹត្តទៅក្នុងវត្ត ๓ ប្រការ មានលំអ ๓ ប្រការ ដូចបានពោលមកហើយយ៉ាងនេះ រមែងជាចិត្តបរិបូរដោយលក្ខណៈ ๑๐ យ៉ាងគឺ ៖

๑. វិតក្កសម្បន្នញ្ចេវ ហោតិ,

បរិបូរណ៌ដោយវិតក្កៈ ๑,

២. **វិចារសម្បន្នញ្ច**,

បរិបូរណ៌ដោយវិចារៈ ១,

៣. **បីតិសម្បន្នញ្ច**,

បរិបូរណ៌ដោយបីតិ ១,

៤. **សុខសម្បន្នញ្ច**,

បរិបូរណ៌ដោយសុខ ១,

៥. **ចិត្តស្ស អធិដ្ឋានសម្បន្នញ្ច**,

បរិបូរណ៌ដោយការអធិដ្ឋានចិត្ត ១ ,

៦. **សទ្ធាសម្បន្នញ្ច**,

បរិបូរណ៌ដោយសទ្ធា ១ ,

៧. **វីរិយសម្បន្នញ្ច**,

បរិបូរណ៌ដោយវីរិយ ១ ,

៨. **សតិសម្បន្នញ្ច**,

បរិបូរណ៌ដោយសតិ ១ ,

៩. **សមាធិសម្បន្នញ្ច**,

បរិបូរណ៌ដោយសមាធិ ១,

១០. **បញ្ញាសម្បន្នញ្ច ។**

បរិបូរណ៌ដោយបញ្ញា ១ ។

ធម៌ ៣ យ៉ាងត្រូវដឹង (បិដក៧០) [៩១]

គាថា

[១៥៩]

និមិត្តំ អស្សាសបស្សាសា, អជាវម្មណាមេកចិត្តស្ស;
អជានតោ ច តយោ ធម្មេ, ភាវនា នុបលព្ភតិ។

កាលយោគីភិក្ខុមិនស្គាល់នូវធម៌ ៣ ប្រការគឺ និមិត្ត(ត្រង់ចុងច្រមុះ) ១, ខ្យល់ដង្ហើមចូល ១, និងខ្យល់ដង្ហើមចេញ ១, ដែលមិនមែនជាអារម្មណ៍របស់ចិត្តមួយដួងទេ ការភាវនា រមែងមិនចម្រើនឡើយ ។

និមិត្តំ អស្សាសបស្សាសា, អជាវម្មណាមេកចិត្តស្ស;
ជានតោ ច តយោ ធម្មេ, ភាវនា ឧបលព្ភតីតិ។

កាលយោគីភិក្ខុបានស្គាល់នូវធម៌ ៣ ប្រការគឺ និមិត្ត(ត្រង់ចុងច្រមុះ) ១, ខ្យល់ដង្ហើមចូល ១, និងខ្យល់ដង្ហើមចេញ ១, ដែលមិនមែនជាអារម្មណ៍របស់ចិត្តមួយដួងទេ ការភាវនា រមែងចម្រើន ។

ធម៌ ៣ យ៉ាងត្រូវដឹង (អដ្ឋកថា)

[១៥៩]

ឯវំ សន្តេបិ អាជាចានស្សតិសមាធិភាវនាវសេន តេសំ និប្ផត្តិ ឧស្សេតុកាមោ តានិ ញាណានិ អនិតមេត្វា វ និមិត្តំ អស្សាសបស្សាសា-តិអាទិនា នយេន ចោទនាបុព្វង្គមំ អាជាចានស្សតិសមាធិភាវនាវិធិ

ឧស្សត្វា អន្តេ តានិ ញាណានិ និកមេត្វា ឧស្សសិ។

សូម្បីកាលជាយ៉ាងនេះ លោកប្រាថ្នានឹងសម្តែងនូវសេចក្តីសម្រេចនៃញាណទាំងនោះ ដោយអំណាចការចម្រើននូវអានាបានស្សតិសមាធិ មិនបានបញ្ជាក់ម្តងទៀតនូវញាណទាំងនោះ(នៅក្នុងចំណុចតែមួយ) សម្តែងវិធីការចម្រើនអានាបានស្សតិសមាធិ ដែលមានការរំលឹកឡើងវិញនៅខាងដើមដែលមានន័យជាអាទិសព្ទថា ***និមិត្ត ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ*** *ដូច្នេះហើយ ក្នុងទីបំផុតក៏បានសម្តែងបញ្ជាក់នូវញាណទាំងនោះ។*

តត្ត និមិត្តំ វុត្តមេវ។

ក្នុងបណ្តាបទទាំងនោះ ពាក្យថា **និមិត្ត** *បានពោលទុកនៅខាងដើមរួចហើយ)។*

អជារម្មណាមេកចិត្តស្សាតិ **អជារម្មណា ឯកចិត្តស្ស។**

បទថា ***អជារម្មណាមេកចិត្តស្ស*** *ដែលប្រែថា* ***មិនមែនជាអារម្មណ៍របស់ចិត្តមួយដួងទេ*** *។*

ម-ការោ បនេត្ថ បទសន្ធិករោ។

ក៏ **ម** *- អក្សរក្នុងទីនេះ ធ្វើជាបទសន្ធិ ។*

អជារម្មណាមេកចិត្តស្សាតិបិ ចាហោ, ឯកស្ស ចិត្តស្ស អារម្មណំ ន ភវន្តីតិ អត្ថោ។

ព្រះបាលីសម្តែងថា **អជារម្មណាមេកចិត្តស្ស** *ដូច្នេះ ក៏មាន, ប្រែថា មិនមែនជាអារម្មណ៍នៃចិត្តមួយដួងទេ ។*

"តយោ ធម្មេ"តិ និមិត្តាឧយោ តយោ ធម្មេ។

*ពាក្យថា "****ធម៌ ៣ យ៉ាង****" បានដល់ធម៌ទាំង ៣ ដែលមាននិមិត្ត ជាដើម ។*

ភាវនាតិ *អានាបានស្សតិសមាធិភាវនា។*

បទថា **ភាវនា** *បានដល់ ការចម្រើននូវអានាបានស្សតិសមាធិ ។*

ឧបមា និច ឧបមេយ្យ (បិដក ៧0) [៩២]

កថំ ឥមេ តយោ ធម្មា ឯកចិត្តស្ស អារម្មណា ន ហោន្តិ ?,

ធម៌ទាំង៣យ ៣ ប្រការ មិនមែនជាអារម្មណ៍របស់ចិត្តតែមួយដួង តើដូចម្តេច ?,

ន ចិមេ តយោ ធម្មា អវិដិតា ហោន្តិ,

ធម៌ទាំង៣យ ៣ ប្រការនេះ មិនមែនជាមិនប្រាកដផង,

១. **ន ច ចិត្តំ វិក្ខេបំ កច្ឆតិ,**

ចិត្តមិនដល់នូវសេចក្តីរាយមាយ ១ ,

២. **បធានញ្ច បញ្ញាយតិ,**

ការព្យាយាម រមែងប្រាកដ ១ ,

៣. **បយោគញ្ច សាធេតិ,**

យោគីកិក្ខុញុំាងប្រយោគ(គឺ ឈាន) ឲ្យសម្រេច ១ ,

វិសេសមធិគច្ឆតិ ?

និងបន្ទុះនូវគុណវិសេស តើដូចម្តេច ?

ការឧបមា

សេយ្យថាបិ រុក្ខោ សមេ ភូមិភាគេ ឋិក្ខិត្តោ។

ប្រៀបដូចដើមឈើមួយដើម ដែលគេតាំងទុកលើផ្ទៃដ៏រាបស្មើ ។

តមេនំ បុរិសោ កកចេន ឆិន្ទេយ្យ។

បុរសម្នាក់កាលអារដើមឈើនោះ ដោយរណារដៃ ។

រុក្ខេ ផុដ្ឋកកចទន្តានំវសេន បុរិសស្ស សតិ ឧបដ្ឋិតា ហោតិ;

សតិស្មារតីរបស់បុរសនោះ រមែងតម្កល់ទុក ដោយអំណាចនៃធ្មេញរណារដៃដែលពាល់ត្រូវជាមួយដើមឈើ,

ន អាគតេ វា គតេ វា កកចទន្តេ មនសិករោតិ។

(បុរសនោះ) មិនបានធ្វើទុកក្នុងចិត្តត្រង់ធ្មេញរណារដៃ ដែលទាញមកនិងរុញទៅទេ ។

ន អាគតា វា គតា វា កកចទន្តា អវិទិតា ហោន្តិ,

ធ្មេញរណារទាំងឡាយដែលទាញមកនិងរុញទៅ មិនមែនមិនជ្រាកដទេ,

បជានញ្ច បញ្ញាយតិ,

ទាំងការព្យាយាម(គឺ ការព្យាយាមអារដើមឈើ) រមែងមានជ្រាកដ,

បយោគញ្ច សាធេតិ ។

បុរសនោះ ក៏ញុាំងប្រយោគ(គឺកិរិយាអារដើមឈើ) ឲ្យសម្រេច

ការឧបមេយ្យ

យថា រុក្ខោ សមេ ភូមិភាគេ ឋិក្ខិត្តោ។

ដើមឈើដែលគេតាំងទុកនៅលើផ្ទៃដ៏រាបស្មើរួចហើយ យ៉ាងណា ។

ឯវំ ឧបនិពន្ធនា និមិត្តំ។

(ចំណែកឯ) និមិត្ត(គឺនៅត្រង់ចុងច្រមុះ ឬលើផ្ទៃបបូរមាត់ខាងលើ) ដែលជាគ្រឿងចូលទៅចងទុក(របស់សតិ) ក៏យ៉ាងនោះដូចគ្នា ។

យថា កកចឧន្ត,

ធ្មេញរណារទាំងឡាយ យ៉ាងណា,

ឯវំ អស្សាសបស្សាសា។

ឯខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ក៏យ៉ាងនោះដូចគ្នា ។

យថា រុក្ខេ ផុដ្ធកកចឧន្ត្ថានំវសេន បុរិសស្ស សតិ ឧបដ្ឋិតា ហោតិ,

សតិស្មារតីរបស់បុរសនោះ តម្កល់ទុកដោយអំណាចនៃធ្មេញរណារដែលបានពាល់ត្រូវជាមួយដើមឈើ យ៉ាងណា,

ន អាកតេ វា កតេ វា កកចឧន្ត្ថេ មនសិកហោតិ,

បុរសមិនបានធ្វើទុកក្នុងចិត្ត នៅត្រង់ធ្មេញរណារដែលទាញមក និងរុញទៅទេ ក៏យ៉ាងនោះដូចគ្នា,

ន អាកតា វា កតា វា កកចឧន្ត្ថា អវិជិតា ហោន្តិ,

ធ្មេញរណារទាំងឡាយដែលទាញមកក្តី និងរុញទៅក្តី មិនមែនមិនប្រាកដទេ,

បជានញ្ច បញ្ញាយតិ,

ការព្យាយាម រមែងប្រាកដផង,

បយោកញ្ច សាធេតិ វិសេសមធិកច្ឆតិ ។

យោគីភិក្ខុនោះ រមែងញ្ចាំងនូវប្រយោគឲ្យសម្រេចបាននូវគុណវិសេស

ផង ។

ឯវមេវំ ភិក្ខុ ជាសិកត្តេ វា មុខនិមិត្តេ វា សតឹ ឧបដ្ឋបេត្វា និសិន្នោ ហោតិ,

យោគីភិក្ខុនោះ អង្គុយរួចហើយតម្កល់សតិនៅត្រង់ចុងច្រមុះ ឬលើផ្នែបបូរមាត់ខាងលើ ក៏យ៉ាងនោះដូចគ្នា ,

ន អាគតេ វា គតេ វា អស្សាសបស្សាសេ មនសិករោតិ,

រមែងមិនធ្វើទុកក្នុងចិត្តនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលមកហើយក្តី និងទៅវិញក្តី,

ន អាគតា វា គតា វា អស្សាសបស្សាសា អវិទិតា ហោន្តិ,

ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញដែលមកហើយក្តី និងទៅវិញក្តី មិនមែនមិនប្រាកដទេ (គឺមានយ៉ាងពិតប្រាកដណាស់),

បជានញ្ច បញ្ញាយតិ,

ការព្យាយាមរមែងប្រាកដផង,

បយោគញ្ច សាធេតិ វិសេសមធិគច្ឆតិ[២២] ។

យោគីភិក្ខុនោះ រមែងញុំាងនូវប្រយោគឲ្យសម្រេចបាននូវគុណវិសេសផង ។

---

២២ *ម. វិសេសមធិគច្ឆតិ បជានាញ្ច ។*

ការឧបមា និង ឧបមេយ្យ (អដ្ឋកថា)

កថន្តិ បឋមំ វុត្តាយ ចោឧនាគាថាយ អនន្តរំ វុត្តាយ បរិហារគាថាយ អត្តំ កថេតុកម្យតាបុច្ឆា។

បទថា **កថំ** *ជាពាក្យបុច្ឆាដែលត្រូវការនឹងពោលនូវអត្តនៃគាថាឆ្វើយដែលបានពោលទុកក្នុងលំដាប់នៃគាថាដែលបានសួរទុក គឺបានពោលទុកមកហើយនៅខាងដើម ។*

ន ចិមេតិ ន ច ឥមេ។

បទថា **ន ចិ មេ** *កាត់បទទៅជា ន ច ឥមេ ។*

ន ចមេតិបិ ចាហោ, សោយេវ បឧច្ឆេឧោ។

បាឋ: សម្តែងថា ន ច មេ ដូច្នេះក៏មាន, ការកាត់បទបែបនេះ គឺមានសេចក្តីដូចគ្នា។

កថំ ន ច អវិឧិតា ហោន្តិ, កថំ ន ច ចិត្តំ វិក្ខេបំ កច្ឆតីតិ ឯវំ កថំ សឧ្ទោ សេសេហិ បញ្ចហិ យោជេតព្ទោ។

គប្បីប្រកបនូវ **កថំ** *សព្ទ ដោយប្រយោគ សូម្បីដ៏សេសទៀតទាំង ៥ យ៉ាងនេះថា ធម៌ទាំងឡាយ ជាធម៌មិនមែនមិនប្រាកដតើដូចម្តេច? ចិត្តមិនដល់នូវសេចក្តីរាយមាយ តើដូចម្តេច?*

បឧានញ្ច បញ្ញាយតីតិ អានាចានស្សតិសមាធិភាវនារម្ភកំ វីរិយំ សន្ធិស្សតិ។

បទថា **បឧានញ្ច បញ្ញាយតិ** *ប្រែថា* ***សេចក្តីព្យាយាមរមែងប្រាកដ*** *គឺមានន័យថា សេចក្តីព្យាយាមដែលប្រារព្ធចម្រើននូវអានាបានស្សតិសមាធិ រមែងប្រាកដ ។*

វីរិយញ្ហិ បធហន្តិ តេនាតិ បធានន្តិ វុច្ចតិ។

ពិតហើយ សេចក្តីព្យាយាម ហៅថា **បធាន** *ដោយអត្ថថា ជាហេតុចាប់ផ្តើម។*

"បយោគញ្ច សាធេតី"តិ នីវរណវិក្ខម្ភកំ ឈានញ្ច យោគី និច្ឆាធេតិ។

បទថា **"បយោគញ្ច សាធេតិ** *ប្រែថា* ***រមែងញុំាងប្រយោគឲ្យសម្រេច"*** *មានន័យថា យោគីកិក្ខុ រមែងញុំាងឈានដែលឃុំគ្រងនូវនីវរណធម៌ទុកឲ្យសម្រេច។*

ឈានញ្ហិ នីវរណវិក្ខម្ភនាយ បយុញ្ជិយតីតិ បយោគោតិ វុត្តំ។

ពិតហើយ **ឈាន** *ហៅថា* **បយោគ** *ដោយអត្ថថា ប្រកបដើម្បីឃុំគ្រងទុកនូវនីវរណៈធម៌។*

"វិសេសមធិគច្ឆតី"តិ សំយោជនប្បហានការំ មគ្គញ្ច បដិលភតិ។

បទថា **"វិសេសមធិគច្ឆតិ"** *ប្រែថា* ***ព្រះយោគីរមែងបន្ទុះនូវគុណវិសេស*** *បានសេចក្តីថា រមែងបានចំពោះនូវមគ្គដែលធ្វើការលះនូវសំយោជនៈ។*

មគ្គោ ហិ សមថវិបស្សនានំ អានិសំសត្តា វិសេសោតិ វុត្តោ។

ពិតហើយ **មគ្គ** *លោកពោលថាជាគុណវិសេស ព្រោះជាអានិសង្សនៃសមថៈ និងវិបស្សនា។*

វិសេសស្ស ច បមុខភូតត្តា ច-ការេន សមុច្ចយោ ន កតោ។

លោកមិនបានធ្វើសមុច្ចយៈ(គឺ ការរួបរួមទុក) ដោយ **ច** *អក្សរ ព្រោះជាប្រមុខរបស់គុណវិសេស។*

ការឧបមា (អដ្ឋកថា)

ឥទានិ តំ បុច្ឆិតមត្ថំ ឧបមាយ សាធេន្តោ សេយ្យថាបិ រុក្ខោតិអាទិមាហ។

ឥឡូវនេះ លោកកាលនឹងញុំាងអត្ថដែលលោកបានសួរទុកនោះ ឲ្យសម្រេចដោយការឧបមា ទើបលោកពោលពាក្យថា ***ប្រៀបដូចជាដើមឈើ*** *ជាដើម។*

តស្សត្ថោ – យថា ជាម កកចេន ជាលនត្ថំ វាសិយា តច្ឆិត្វា រុក្ខោ ជាលនកាលេ និច្ចលភាវត្ថំ *សមេ* ភូមិបទេសេ បយោគក្ខមំ កត្វា បឋិតោ។

*សេចក្តីនៃពាក្យនោះថា ដើមឈើដែលគេយកកាំបិតចាំងពន្លាត់ ដើម្បីនឹងកាត់ដោយរណារដៃ ក្នុងវេលានឹងអារកាត់ គេតម្កល់ទុកធ្វើឲ្យសមគួរដល់ប្រយោគក្នុងទីកន្លែង****ដែលរាបស្មើ*** *ដើម្បីមិនឲ្យញ័ររង្គើ។*

"កកចេនា"តិ ហត្ថកកចេន។

*ពាក្យថា "****ដោយរណារ****" គឺដោយរណារដៃ។*

"អាកតេ"តិ រុក្ខំ ផុសិត្វា អត្តនោ សមីបភាគំ អាកតេ។

ពាក្យថា ***ដែលមកហើយ*** *គឺដែលពាល់ត្រូវដើមឈើ ហើយមកកាន់ចំណែកដែលជិតនៃខ្លួន។*

"កតេ"តិ រុក្ខំ ផុសិត្វា បរភាគំ កតេ។

*ពាក្យថា "****ដែលទៅហើយ****" គឺដែលត្រូវពាល់ត្រូវដើមឈើ ហើយទៅចំណែកដទៃ។*

វា-សទ្ទោ សមុច្ចយត្ថោ។

វា សព្ទ ជាសមុច្ចយត្ថ គឺមានអត្ថថា រួបរួម ។

"**ន អវិជិតា ហោន្តី**"តិ រុក្ខេ កកចជន្តេហិ ផុដ្ឋំ បុរិសេន បេក្ខមានំ ហានំ អប្បត្វា តេសំ អាតមនតមនាភាវតោ សព្វេបិ កកចជន្តា វិជិតាវ ហោន្តិ។

*ពាក្យថា "**ធ្មេញរណារ មិនមែនមិនប្រាកដ**" បានសេចក្តីថា ព្រោះធ្មេញរណារទាំងនោះមិនទាន់មកដល់ទីកន្ទែងដែលបុរសត្រូវសម្ទឹងមើលដែលត្រូវធ្មេញរណារពាល់ត្រូវជាមួយដើមឈើ ក៏មិនទាន់មានអាការៈមក និងទៅធ្មេញរណារទាំងអស់ទើបមានប្រាកដ តែម្យ៉ាង ។*

"**បជាន**"ន្តិ រុក្ខច្ឆេជនវីរិយំ។

*ពាក្យថា "**បជាន**" បានដល់សេចក្តីព្យាយាមដែលនឹងកាត់ដើមឈើ ។*

"**បយោត**"ន្តិ រុក្ខច្ឆេជនកិរិយំ។

*ពាក្យថា **បយោត** បានដល់ កិរិយាដែលកាត់ដើមឈើ ។*

"**វិសេសមធិកច្ឆតី**"តិ វចនំ ឧបមាយ នត្ថិ។

*ពាក្យថា "**បន្ទុះនូវគុណវិសេស**" គឺសេចក្តីពិសេសមិនមានដោយការឧបមា ។*

ការឧបមេយ្យ (អដ្ឋកថា)

"**ឧបនិពន្ធនា និមិត្ត**"ន្តិ ឧបនិពន្ធនាយ សតិយា និមិត្តភូតំ ការណភូតំ នាសិកក្តំ វា មុខនិមិត្តំ វា។

*ពាក្យថា "**និមិត្តនៃការចូលទៅចងទុក**" បានដល់ ចុងច្រមុះ, ផ្ទៃបបូរមាត់ខាងលើ ដែលជានិមិត្ត គឺជាហេតុនៃសតិដែលជាគ្រឿងចូលទៅចងទុក ។*

ឧបនិពន្ធតិ ឯតាយ អារម្មណេ ចិត្តន្តិ ឧបនិពន្ធនា នាម សតិ។

សតិ ឈ្មោះថា **ឧបនិពន្ធនា** *ប្រែថា ជាគ្រឿងចូលទៅចងទុក ដោយអត្ថថា ជាហេតុចូលទៅចងចិត្តទុកនៅក្នុងអារម្មណ៍ ។*

"ជាសិកន្តេ វា"តិ ឥឃជាសិកោ ជាសិកន្តេ។

ពាក្យថា ***"ត្រង់ចុងច្រមុះ"*** *គឺមនុស្សដែលមានច្រមុះវែង (ទើបនៅ) ត្រង់ចុងច្រមុះ ។*

"មុខនិមិត្តេ វា"តិ រស្សជាសិកោ ឧត្តរោដ្ឋេ។

ពាក្យថា ***"លើផ្នែបបូរមាត់ខាងលើ"*** *គឺសំរាប់មនុស្សដែលមានច្រមុះខ្លី (ទើបនៅ) ត្រង់ផ្នែបបូរមាត់ខាងលើ ។*

ឧត្តរោដ្ឋោ ហិ មុខេ សតិយា និមិត្តន្តិ មុខនិមិត្តន្តិ វុត្តោ។

ក៏ផ្នែបបូរមាត់ខាងលើ លោកហៅថា **មុខនិមិត្ត** *ដោយអត្ថថា ជានិមិត្តនៃសតិត្រង់មាត់ (គឺកន្ទែងមាត់) ។*

"អាគតេ"តិ ជុដ្ឋដ្ឋានតោ អព្ភន្តរំ អាគតេ។

ពាក្យថា ***"ដែលកំពុងមក"*** *គឺដែលមកកាន់ខាងក្នុង ចាកឋានដែលត្រូវខ្យល់ពាល់ត្រូវ(ពាល់ត្រូវ) ។*

"គតេ"តិ ជុដ្ឋដ្ឋានតោ ពហិទ្ធា គតេ។

ពាក្យថា ***"ដែលកំពុងទៅ"*** *គឺដែលទៅខាងក្រៅ ចេញពីកន្ទែងដែលខ្យល់ពាល់ត្រូវ ។*

"ន អវិទិតា ហោន្តី"តិ ជុសន្ធានំ អប្បត្វា អស្សាសបស្សាសានំ អាគមនគមនាការតោ សព្ពេបិ តេ វិទិតា ឯវ ហោន្តិ។

ពាក្យថា ***"មិនមែនមិនជ្រាកដទេ"*** *គឺព្រោះខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនៅមិនទាន់មកដល់ឋានដែលត្រូវពាល់ត្រូវ ទើបមិនមានការមក*

និងការទៅ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងអស់នោះ រមែងមានប្រាកដនៅត្រង់កន្លែងមួយ ។

ការព្យាយាម (ចិដក ៧០) [៩៣]

កតមំ បជានំ ?

ការព្យាយាម តើដូចម្តេច ?

អារទ្ធវីរិយស្ស កាយោបិ ចិត្តម្បិ កម្មនិយំ ហោតិ , ឥទំ បជានំ។

ភិក្ខុមានការព្យាយាមប្រារព្ធហើយ តែងមានកាយ និងចិត្តគួរដល់ការងារ, នេះឈ្មោះថា ការព្យាយាម ។

កតមោ បយោគោ ?

តើប្រយោគដូចម្តេច ?

អារទ្ធវីរិយស្ស ឧបក្កិលេសា បហីយន្តិ, វិតក្កា វូបសមន្តិ, អយំ បយោគោ។

ព្រះយោគីភិក្ខុមានសេចក្តីព្យាយាមប្រារព្ធ រមែងលះបង់នូវពួកឧបក្កិលេស មានវិតក្កៈរមែងស្ងប់រម្ងាប់, នេះឈ្មោះថា ប្រយោគ(ការប្រកបសេចក្តីព្យាយាម) ។

កតមោ វិសេសោ ?

តើគុណវិសេសដូចម្តេច ?

អារទ្ធវីរិយស្ស សញ្ញោជនា បហីយន្តិ, អនុសយា ព្យន្តីហោន្តិ[៦៤]

[អនុសយា ព្យាសន្តិ (ស្យា)]។ អយំ វិសេសោ។

ព្រះយោគីកិក្ខុមានសេចក្តីព្យាយាមប្រារព្ធហើយ រមែងលះបង់ស្រឡះនូវពួកសញ្ញោជន:,មានពួកអនុស័យធម៌ រមែងវិនាសទៅ ។ នេះឈ្មោះថាគុណវិសេស ។

ឯវំ ឥមេ តយោ ធម្មា ឯកចិត្តស្ស អារម្មណា ន ហោន្តិ,

នេះធម៌ ៣ យ៉ាង ដែលមិនមែនជាអារម្មណ៍នៃឯក:ចិត្ត យ៉ាងនេះឯង ,

ន ចិមេ តយោ ធម្មា អវិទិតា ហោន្តិ,

នេះធម៌ ៣ យ៉ាងដែលភិក្ខុមិនមែនជាមិនដឹងទេ,

ន ច ចិត្តំ វិក្ខេបំ កច្ឆតិ,

គឺចិត្តមិនដល់នូវសេចក្តីរាយមាយ ១,

បធានញ្ច បញ្ញាយតិ,

ការព្យាយាម ក៏ប្រាកដ ១,

បយោគញ្ច សាធេតិ,វិសេសមធិគច្ឆតិ។

ភិក្ខុញុំាងសេចក្តីព្យាយាមឲ្យបានសម្រេចនូវគុណវិសេស ១ ។

ការព្យាយាម (អដ្ឋកថា)

"កម្មនិយំ ហោតី"តិ យេន វីរិយេន ការោបិ ចិត្តម្បិ កម្មនិយំ ភាវនាកម្មក្ខមំ ភាវនាកម្មយោគ្គំ ហោតិ។

*ពាក្យថា "**រមែងគួរដល់ការងារ**" បានសេចក្តីថា សូម្បីកាយនិងចិត្ត រមែង*

គួរដល់កាងារ គឺសមគួរដល់ការចម្រើនភាវនា គួរដល់កម្ម គឺភាវនាដោយសេចក្តីព្យាយាមណា ។

ឥទំ វីរិយំ បធានំ ជាមាតិ ផលេន ការណំ វុត្តំ ហោតិ។

*សេចក្តីព្យាយាម**នេះ** ឈ្មោះថា **ជាប្រធាន** ព្រោះដូច្នោះ ជាការពោលដល់ហេតុ (តែសំដៅ) ដល់ផល ។*

"**ឧបក្កិលេសា បហីយន្តី**"តិ វិក្ខម្ភនវសេន នីវរណានិ បហីយន្តិ។

*ពាក្យថា "**រមែងលះនូវឧបក្កិលេសបាន**" គឺរមែងលះនូវនីវរណធម៌ទាំងឡាយដោយអំណាចការឃុំគ្រងបាន ។*

"**វិតក្កា វូបសម្មន្តី**"តិ ជាជារម្មណាចារិនោ អនវដ្ឋិតា វិតក្កា ឧបសមំ គច្ឆន្តិ។

*ពាក្យថា "**វិតក្កវមែងសូប់**" មានន័យថា វិតក្ក:ដែលត្រាច់ទៅកាន់អារម្មណ៍ផ្សេងៗ ដែលរកទីតម្កល់មាំមិនបាន រមែងដល់នូវភាពសូប់ ។*

យេន ឈានេន ឧបក្កិលេសា បហីយន្តិ, វិតក្កា វូបសម្មន្តិ។

ឧបក្កិលេស រមែងលះបានដោយឈានណា, វិតក្ក: រមែងសូប់បានដោយឈាននោះ ។

"**អយំ បយោគោ**"តិ បយោគមបេក្ខិត្វា បុលិង្គនិទ្ទេសោ កតោ។

*លោកសំដៅដល់ប្រយោគធ្វើនិទ្ទេសដោយបុំលិង្គថា **អយំ បយោគោ** ។*

"**សញ្ញោជនា បហីយន្តី**"តិ តំតំមគ្គវជ្ឈា សញ្ញោជនា សមុច្ឆេទប្បហានេន បហីយន្តិ។

*ពាក្យថា "**រមែងលះបង់នូវសំយោជន**" គឺរមែងលះនូវសំយោជនដោយមគ្គនោះៗ និងកាត់ផ្តាច់ដោយសមុច្ឆេទបហាន ។*

"**អនុសយា ព្យន្តីហោន្តី**"តិ បហីនាំ បុន អនុប្បត្តិធម្មកត្តា វិគតោ ឧប្បាទន្តោ វា វយន្តោ វា ឯតេសន្តិ ព្យន្តា, បុព្វេ អព្យន្តា ព្យន្តា ហោន្តីតិ ព្យន្តីហោន្តិ, វិនស្សន្តីតិ អត្ថោ។

*ពាក្យថា "**អនុស័យរមែងវិនាសទៅ**" មានន័យថា ទីបំផុត គឺសេចក្តីកើតឡើង ឬទីបំផុតគឺសេចក្តីអស់ទៅរបស់អនុស័យទាំងនេះបានប្រាសទៅហើយ ព្រោះអនុស័យដែលលះបានហើយ មិនមានការកើតឡើងតទៅទៀតជាធម្មតា ហេតុនោះអនុស័យទាំងនេះ ឈ្មោះថា គ្រាមុន រមែងមានទីបំផុតទៅប្រាសហើយ ហេតុនោះ ទើបឈ្មោះថា* **ព្យន្តីហោន្តិ** *ប្រែថា រមែងអស់ទៅ, បានសេចក្តីថា វិនាសទៅ ។*

សញ្ញោជនប្បហានំ អនុសយប្បហានេន ហោតិ, ន អញ្ញថាតិ ឧស្សន្នត្តំ អនុសយប្បហានមាហ។

កាលសម្តែងសេចក្តីថាការលះសំយោជន: រមែងមានដោយការលះអនុស័យ, មិនមែនដោយប្រការដទៃទេ លោកទើបពោលការលះនូវអនុស័យ ។

យេន មគ្គេន សញ្ញោជនា បហីយន្តិ អនុសយា ព្យន្តីហោន្តិ, "អយំ វិសេសោ"តិ អត្ថោ។

*បានសេចក្តីថា សំយោជន:រមែងលះបាន អនុស័យរមែងអស់ទៅបានដោយមគ្គណា, "**មគ្គនេះជាគុណវិសេស**" ។*

ចតុត្ថចតុក្កេ អរិយមគ្គស្សាបិ និទ្ទិដ្ឋត្តា ឥធ អរិយមគ្គោ វុត្តោ។

ព្រោះសូម្បីអរិយមគ្គ លោកសម្តែងអធិប្បាយទុកនៅក្នុងចតុក្ក:ទី ៤ នៅក្នុងទីនេះលោកទើបបានពោលអរិយមគ្គ ។

ឯកចិត្តស្ស អារម្មណទ្វយការស្ស អវុត្តេបិ សិទ្ធត្តា តំ អវិស្សជ្ជេត្វា "ឯវំ ឥមេ តយោ ធម្មា ឯកចិត្តស្ស អារម្មណា ន ហោន្តី"តិ

ឯកមន្តំ កតំ។

*ព្រោះចិត្តមួយដួងមិនមានអារម្មណ៍ ២ ទេ សម្រេចហើយសូម្បីកាលមិនបានពោលទុកនោះ លោកទើបមិនបានវិសជ្ជនាធម៌នោះធ្វើពាក្យនិគមថា "**ធម៌ទាំង ៣ យ៉ាងនេះ មិនមែនជាអារម្មណ៍នៃចិត្តមួយដួង យ៉ាងនេះ**" ដូច្នេះ។*

គាថាសរុប (បិដក៧០) [៩៤]

[១៦០]

អានាបានស្សតិ យស្ស, បរិបុណ្ណា សុភាវិតា;
អនុបុព្ពំ បរិចិតា, យថា ពុទ្ធេន ទេសិតា;
សោ ឥមំ លោកំ បភាសេតិ, អព្ភា មុត្តោវ ចន្ទិមាតិ។

ព្រះយោគីភិក្ខុណា ចម្រើនអានាបានស្សតិបានល្អប្រពៃហើយ អប់រំសន្សំហើយ ទៅតាមលំដាប់ ឲ្យបរិបូរណ៌តាមដែលព្រះពុទ្ធអង្គទ្រង់បានសម្តែងទុកមកហើយ បុគ្គលនោះរមែងញុំាងលោកនេះឲ្យភ្លឺច្បាស់ ដូចជាព្រះចន្ទរះដែលផុតស្រឡះចាកពីពពក។

អធិប្បាយគាថា

"**អាន**"ន្តិ អស្សាសោ, ោ បស្សាសោ។

*ពាក្យថា "**អាន**" ប្រែថា "**ខ្យល់ដកដង្ហើមចូល**", មិនមែន ប្រែថាខ្យល់ដកដង្ហើមចេញនោះទេ។*

"អចាន"ន្តិ[๒๓] បស្សាសោ, ឆោ អស្សាសោ។

ពាក្យថា ***"អចាន"*** *ប្រែថា* ***"ខ្យល់ដកដង្ហើមចេញ"*****,** *មិនមែន ប្រែថា ខ្យល់ដកដង្ហើមចូលនោះទេ ។*

អស្សាសវសេន ឧបដ្ឋានំ សតិ, បស្សាសវសេន ឧបដ្ឋានំ សតិ។

ការចូលទៅតាំងមាំដោយអំណាចនៃខ្យល់ដកដង្ហើមចូល ឈ្មោះថា **សតិ**, *ការចូលទៅតាំងមាំដោយអំណាចនៃខ្យល់ដកដង្ហើមចេញ ឈ្មោះថា* **សតិ** *។*

យោ អស្សសតិ តស្សុបដ្ឋាតិ, យោ បស្សសតិ តស្សុបដ្ឋាតិ។

បុគ្គលណា រមែងដកដង្ហើមចូល សតិក៏រមែងតាំងជ្រាកដដល់បុគ្គលនោះ, បុគ្គលណារមែងដកដង្ហើមចេញ សតិក៏រមែងតាំងជ្រាកដដល់បុគ្គលនោះ ។

"បរិបុណ្ណា"តិ បរិត្តហេដ្ឋេន បរិបុណ្ណា, បរិវារដ្ឋេន បរិបុណ្ណា, បរិបូរដ្ឋេន បរិបុណ្ណា ។

បទថា ***"បរិបុណ្ណា"*** *ប្រែថា បរិបូរណ៌ ដោយអត្ថថា កំណត់កាន់យក, បរិបូរណ៌ហើយ ដោយអត្ថថា ជាបរិវារ, បរិបូរណ៌ហើយ ដោយអត្ថថា ពេញបរិបូរណ៌ ។*

"សុភាវិតា"តិ ចតស្សោ ភាវនា,

ពាក្យថា ភាវនា ក្នុងពាក្យថា ***"សុភាវិតា"*** *បានដល់ភាវនា ๔ យ៉ាងគឺ៖*

๑. **តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា,**

ពាក្យថា ភាវនា ដោយអត្ថថា ធម៌ទាំងឡាយដែលកើតក្នុងអានាបាន-ស្សតិនោះ មិនប្រព្រឹត្តកន្លងនូវគ្នានិងគ្នា ๑,

๒. **ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា,**

---

๒๓ ក. *អបានន្តិ ។*

ពាក្យថា ភាវនា ដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ ១,

៣. តទុបតរីយភាវនដ្ឋេន ភាវនា,

ពាក្យថា **ភាវនា** *ដោយអត្ថថា នាំទៅនូវការព្យាយាមសមគួរដល់ឥន្ទ្រិយទាំងឡាយនោះ ១,*

៤. អាសេវនដ្ឋេន ភាវនា។

ពាក្យថា ភាវនា ដោយអត្ថថា សេព ១ ។

តស្សិមេ ចត្តារោ ភាវនដ្ឋា យានីកតា ហោន្តិ វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា។

នេះឯង អត្ថរបស់ភាវនា ៤ យ៉ាង ដែលគេធ្វើឲ្យដូចជាយាន ធ្វើឲ្យដូចជាវត្ថុ ជាទីតាំង (គឺមគ្គ) ឲ្យតាំងឡើងរឿយៗ (ការបង្អោនទៅរឿយៗ) អប់រំសន្សំហើយ ប្រារព្ធនូវសេចក្តីសូប់ប្រពៃហើយ ។

"យានីកតា"តិ យត្ត យត្ត អាកង្ខតិ, តត្ត តត្ត វសិប្បត្តោ ហោតិ ពលប្បត្តោ វេសារជ្ជប្បត្តោ។

ពាក្យថា **"ធ្វើឲ្យដូចជាយាន"** *មានសេចក្តីថា យោគីភិក្ខុប្រាថ្នាប៉ុនប៉ងនូវធម៌ណាៗ, រមែងជាអ្នកដល់នូវការស្ទាត់ជំនាញ ដល់នូវកម្លាំង ដល់នូវសេចក្តីក្លៀវក្លា ក្នុងធម៌នោះៗ ។*

តស្ស មេ តេ ធម្មា អាវជ្ជនបដិពទ្ធា[៦៤]ហោន្តិ អាកង្ខបដិពទ្ធា មនសិការបដិពទ្ធា ចិត្តុប្បាទបដិពទ្ធា។

ធម៌ទាំងឡាយនោះៗ របស់ភិក្ខុនោះ រមែងជាប់ចំពោះដោយការនឹករំពឹង ជាប់ចំពោះដោយការប្រាថ្នាប៉ុនប៉ង ជាប់ចំពោះដោយការកើតឡើងនៃចិត្ត ។

តេន វុច្ចតិ – "យានីកតា"តិ។

---

៦៤ ក អាវជ្ជនបដិពទ្ធា (ក.) ឯវមីទិសេសុ បទេសុ ។

ព្រោះហេតុនោះ លោកទើបពោលថា "ធ្វើឲ្យដូចជាយាន" ។

"វត្ថុកតា"តិ យស្មឹ យស្មឹ វត្ថុស្មឹ ចិត្តំ សុាធិដ្ឋិតំ ហោតិ, តស្មឹ តស្មឹ វត្ថុស្មឹ សតិ សុបដ្ឋិតា ហោតិ។

*ពាក្យថា "**ធ្វើឲ្យដូចជាវត្ថុជាទីតាំង**" មានសេចក្តីថា ចិត្តដែលភិក្ខុអធិដ្ឋានបានល្អចំពោះវត្ថុណា, សតិស្មារតី ក៏រមែងតម្កល់មាំស៊ប់បានល្អចំពោះវត្ថុនោះ ។*

យស្មឹ យស្មឹ វា បន វត្ថុស្មឹ សតិ សុបដ្ឋិតា[៦៥]ហោតិ, តស្មឹ តស្មឹ វត្ថុស្មឹ ចិត្តំ សុាធិដ្ឋិតំ ហោតិ។

ឬក៏ សតិស្មារតីតម្កល់មាំបានស៊ប់ចំពោះវត្ថុណាៗ, ចិត្តរបស់ភិក្ខុនោះ ក៏អធិដ្ឋានតាំងមាំបានល្អក្នុងវត្ថុនោះៗ ។

តេន វុច្ចតិ – "វត្ថុកតា"តិ។

ព្រោះហេតុនោះ លោកទើបពោលថា "ធ្វើឲ្យដូចជាទីតាំង" ។

"អនុដ្ឋិតា"តិ វត្ថុស្មឹ យេន យេន ចិត្តំ អភិនីហរតិ, តេន តេន សតិ អនុបរិវត្តតិ។

*ពាក្យថា "**ឲ្យតាំងឡើង**" មានសេចក្តីថា ចិត្តបង្ហោនទៅក្នុងការនាវិសេសណាៗ (គឺការបង្ហោនទៅរឿយៗ), សតិស្មារតី ក៏ប្រព្រឹត្តទៅតាមក្នុងធម៌នោះៗ ។*

យេន យេន វា បន សតិ អនុបរិវត្តតិ, តេន តេន ចិត្តំ អភិនីហរតិ។

ឬក៏ សតិស្មារតីប្រព្រឹត្តទៅក្នុងធម៌ណាៗ, ចិត្តរបស់ភិក្ខុនោះក៏ឱនទៅក្នុងធម៌នោះៗ ។

តេន វុច្ចតិ – "អនុដ្ឋិតា"តិ។

ព្រោះហេតុនោះ លោកទើបពោលថា "ឲ្យតាំងឡើងរឿយៗ" ។

"បរិចិតា"តិ បរិតុហដ្ឋេន បរិចិតា, បរិវារដ្ឋេន បរិចិតា, បរិយុរដ្ឋេន

---

៦៥ ក សុបដ្ឋិតា ។

បរិចិតា។

*ពាក្យថា "**អប់រំសន្សំហើយ**" មានសេចក្តីថា ប្រាកដហើយ ដោយអត្ថថា កំណត់កាន់យក, អប់រំសន្សំហើយ ដោយអត្ថថា ជាបរិវារ, អប់រំសន្សំហើយ ដោយអត្ថថា ពេញបរិបូរ ។*

សតិយា បរិក្តណ្ហាន្តោ ជិនាតិ ចាបកេ អកុសលេ ធម្មេ។

ព្រះយោគីភិក្ខុកាលកំណត់កាន់យក(ធម៌)ដោយសតិស្មារតី រមែងឈ្នះ ពួកអកុសលធម៌ដ៏លាមកបាន ។

តេន វុចូតិ – "បរិចិតា"តិ។

ព្រោះហេតុនោះ លោកទើបពោលថា "អប់រំហើយ" ។

"**សុសមារទ្ធា**"តិ ចត្តារោ សុសមារទ្ធា –

*បទថា "**សុសមារទ្ធា** ប្រែថា **ប្រារព្ធសេចក្តីសូប់ល្អប្រពៃហើយ**" មានសេចក្តីថា ការប្រារព្ធសេចក្តីសូប់ប្រពៃមានធម៌ ៤ យ៉ាងគឺ៖*

១. **តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន សុសមារទ្ធា,**

ការប្រារព្ធនូវសេចក្តីសូប់ល្អប្រពៃ ដោយអត្ថថា ធម៌ទាំងឡាយដែលកើតក្នុងអានាបានស្សតិនោះ មិនប្រព្រឹត្តកន្ធងនូវគ្នានឹងគ្នា ១,

២. **ឥន្ទ្រិយានំ ឯករសដ្ឋេន សុសមារទ្ធា,**

ការប្រារព្ធនូវសេចក្តីសូប់ល្អប្រពៃ ដោយអត្ថថា ពួកឥន្ទ្រិយទាំងឡាយមានរសតែមួយ ១,

៣. **តទុបតវីរិយវាហនដ្ឋេន សុសមារទ្ធា,**

ការប្រារព្ធនូវសេចក្តីសូប់ប្រពៃ ដោយអត្ថថា នាំទៅនូវសេចក្តីព្យាយាមសមគួរដល់ឥន្ទ្រិយទាំងឡាយនោះ ១,

៤. តប្បច្ចនីកានំ កិលេសានំ សុសមូហតត្តា[៦៦]សុសមារទ្ធា។

ការប្រារព្ធនូវសេចក្តីស្ងប់ល្អប្រពៃ ដោយអត្ថថា ព្រោះគាស់រំលើងនូវពួកកិលេសដែលជាសឹកសត្រូវដល់ធម៌នោះៗ ១។

គាថាសរុប (អដ្ឋកថា)

[១៦០] ឥជានិ តំ ភាវនាសិទ្ធិសាធកំ យោគាវចរំ ថុនន្តោ "**អានាចានស្សតិ យស្ស**"តិ គាថំ វត្វា តស្ស និទ្ទេសមាហ។

ឥទ្បូវនេះ លោកកាលនឹងសរសើរដល់ព្រះយោគាវចរជាអ្នកបាន(ជាអ្នកតួយ៉ាង)សម្រេចនៃការភាវនានោះ ទើបពោលនូវគាថា ថា **អានាចានស្សតិ យស្ស** *ដូច្នេះជាដើម ហើយបានពោលនូវនិទ្ទេសនៃគាថានោះ។*

តត្ថ អានាចានស្សតិយោ **យថា ពុទ្ធេន ទេសិតា**, តថា **បរិបុណ្ណា សុភាវិតា អនុបុព្ពំ បរិចិតា** យស្ស អត្ថិ សំវិជ្ជន្តិ។

ក្នុងគាថានោះ មានសេចក្តីអធិប្បាយថា ព្រះយោគាវចរណា ***ចម្រើនអានាបានស្សតិបានល្អហើយ អប់រំសន្សំហើយទៅតាមលំដាប់ ឲ្យបរិបូរតាមដែលព្រះពុទ្ធអង្គទ្រង់សម្តែងទុក*** *គឺនៅមានយ៉ាងគ្រប់គ្រាន់។*

សោ ឥមំ លោកំ បភាសេតិ។

ព្រះយោគាវចរនោះ រមែងញុំាងលោកនេះឲ្យភ្លឺស្វាង។

កឹ វិយ? អព្ភា មុត្តោ ចន្ទិមា យថា អព្ភាឌីហិ មុត្តោ ចន្ទិមា ឥមំ ឱភាសលោកំ បភាសេតិ, តថា សោ យោគាវចរោ ឥមំ ខន្ធាទិលោកំ

---

២៦ ក. សុសមុហតត្តា។

បភាសេតីតិ **កាថាយ** **សម្ពន្ធោ**។

តើដូចនឹងអ្វី ? ***ដូចព្រះចន្ទរះផុតចាកពីពពក ដូច្នោះ*** *ភ្ជាប់សេចក្តីគាថាថា ព្រះចន្ទរះផុតចាកពពកជាដើម រមែងញុំាងឱកាសលោកនេះឲ្យភ្លឺស្វាង យ៉ាងណា, ព្រះយោគាវចរនោះ ក៏រមែងញុំាងលោកមានខន្ធលោកជាដើមនេះ ឲ្យភ្លឺស្វាងដូចគ្នា ក៏យ៉ាងនោះ ។*

"អញ្ញា មុត្តោវ ចន្ទិមា"តិ ច បទស្ស និទ្ទេសេ មហិកាឌីនម្បិ វុត្តត្តា ឯត្ត អាទិ-សទ្ទលោចោ កតោតិ វេទិតព្ពោ។

ក៏ព្រោះ សូម្បីពពកជាដើមលោកក៏ពោលទុកក្នុងនិទ្ទេសនៃបទថា ***"អញ្ញា មុត្តោវ ចន្ទិមា"*** *ទើបគប្បីជ្រាបថា លោកធ្វើការលុប* ***អាទិ*** *សព្ទទុកក្នុងបទថា* ***អញ្ញា*** *នេះ ។*

កាថានិទ្ទេសេ "នោ បស្សាសោ, នោ អស្សាសោ"តិ សោ សោយេវ អត្ថោ បដិសេធេន វិសេសេត្វា វុត្តោ។

ក្នុងនិទ្ទេសនៃគាថា លោកពោលសេចក្តីនោះ នុ៎ះឯងថា ***នោ បស្សាសោ មិនមែនខ្យល់ដកដង្ហើមចេញទេ, នោ អស្សាសោ មិនមែនខ្យល់ដកដង្ហើមចូលទេ*** *នេះហើយផ្សេងគ្នាដោយពាក្យបដិសេធ ។*

"ឧបដ្ឋានំ សតី"តិ អសម្មុស្សនតាយ តមេវ អស្សាសំ ឧបគន្ត្វា ឋានំ សតិ នាមាតិ អត្ថោ។

ទាំងពីរបទថា ***ឧបដ្ឋានំ សតិ*** *ប្រែថា* ***ការចូលទៅតម្កល់ ឈ្មោះថា សតិ*** *គឺការចូលទៅកាន់ខ្យល់ដង្ហើមចូលនោះ នុ៎ះឯង តម្កល់នៅដោយភាពមិនភ្លាំងភ្លាត់សតិ ឈ្មោះថា សតិ។*

តថា បស្សាសំ។

ដូចគ្នា ***ការចូលទៅកាន់ខ្យល់ដង្ហើមចេញនោះ*** *នុ៎ះឯង តម្កល់នៅដោយ*

ភាពមិនភ្លាំងភ្លាត់សតិ ឈ្មោះថា សតិ ។

ឯត្តាវតា អាជាចានេសុ សតិ អាជាចានស្សតីតិ អត្តោ វុត្តោ ហោតិ។

ដោយពាក្យត្រឹមតែប៉ុណ្ណេះ ជាការពោលដល់សេចក្តីថា សតិ ក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ឈ្មោះថា អានាបានស្សតិ ។

ឥទានិ សតិវសេនេវ "យស្សា"តិ វុត្តំ បុគ្គលំ និទ្ទិសិតុកាមោ យោ *អស្សសតិ, តស្សុបដ្ឋាតិ*។

*ឥទ្ធូវនេះ លោកប្រាថ្នានឹងសម្តែងខៃពន្យល់នូវបុគ្គលដែលលោកបានពោលទុកថា "**យស្សា**" ដោយអំណាចសតិនោះឯង ទើបពោលពាក្យថា **បុគ្គលណាដកដង្ហើមចូល, រមែងប្រាកដដល់បុគ្គលនោះ** ។*

"យោ *បស្សសតិ, តស្សុបដ្ឋាតី*"តិ វុត្តំ។

***បុគ្គលណាដកដង្ហើមចេញ, រមែងប្រាកដដល់បុគ្គលនោះ** ។*

យោ អស្សសតិ, តស្ស សតិ អស្សាសំ ឧបកឌ្ឍា តិដ្ឋតិ។

មានន័យថា បុគ្គលណាដកដង្ហើមចូល, សតិរមែងចូលទៅកាន់ខ្យល់ដង្ហើមចូល តាំងនៅដល់បុគ្គលនោះ ។

យោ បស្សសតិ, តស្ស សតិ បស្សាសំ ឧបកឌ្ឍា តិដ្ឋតីតិ អត្តោ។

បុគ្គលណាដកដង្ហើមចេញ, សតិរមែងចូលទៅកាន់ខ្យល់ដង្ហើមចេញ ហើយតាំងនៅដល់បុគ្គលនោះ ។

"*បរិបុណ្ណា*"តិ ឈានវិបស្សនាមគ្គបរម្បរាយ អរហត្តមគ្គប្បត្តិយា បរិបុណ្ណា។

*ពាក្យថា "**បរិបូរ**" មានន័យថា បរិបូរដោយការដល់នូវអរហត្តមគ្គ ដោយ*

ការភ្ជាប់តនៃឈានវិបស្សនា និងមគ្គ ។

តេយេវ ហិ ឈានវិបស្សនាមត្តជម្មេ សន្ធាយ បរិត្តហេដ្ឋេនាតិ-អាជិមាហ។

*ពិតហើយ លោកពោលពាក្យថា "**ដោយអត្ថថា កំណត់កាន់យក**" ជាដើម សំដៅដល់ធម៌ គឺឈានវិបស្សនា និងមគ្គទាំងនោះ នុ៉ះឯង ។*

តេ ហិ ជម្មា ឥមិនា យោតិនា បរិត្តយ្ហមានត្តា បរិត្តហា, តេន បរិត្តហេដ្ឋេន បរិបុណ្ណា។

*ព្រោះថា ធម៌ទាំងនោះ ឈ្មោះថា កំណត់កាន់យក ព្រោះព្រះយោគីនេះ កំណត់កាន់យក, ឈ្មោះថា "**បរិបូរ ដោយអត្ថថា កំណត់កាន់យក**" នោះ ។*

តត្ថ សព្វេសំ ចិត្តចេតសិកានំ អញ្ញមញ្ញបរិវារត្តា បរិវារដ្ឋេន បរិបុណ្ណា។

*ក្នុងពាក្យនោះ ឈ្មោះថា **បរិបូរ ដោយអត្ថថា ជាបរិវារ** ព្រោះចិត្តនិងចេតសិកទាំងអស់ជាបរិវារ គឺឡោមព័ទ្ធនូវគ្នានឹងគ្នា ។*

ភាវនាចារិបូរិវសេន បរិបូរដ្ឋេន បរិបុណ្ណា។

*ឈ្មោះថា **បរិបូរ ដោយអត្ថថា ពេញបរិបូរ** ដោយអំណាចពេញលេញនៃភាវនា ។*

ចតស្សោ ភាវនាតិអាជីនិ សុភាវិតាតិ វុត្តបជស្ស អត្ថវសេន វុត្តានិ។

*ពាក្យថា **ភាវនាទាំង ៤** ជាដើម លោកពោលទុកដោយអំណាចជាអត្ថនៃបទដែលបានពោលទុកថា សុភាវិតោ ដែលប្រែថា ចម្រើនហើយដោយល្អប្រពៃ។*

ចតស្សោ ភាវនា ហេដ្ឋា វុត្តាយេវ។

ភាវនាទាំង ៤ ខ្ញុំម្ចាស់បានពោលទុកមកហើយនៅខាងក្រោយ(គឺនៅខាងដើម) នុ៎ះឯង។

"យានីកតា"តិ យុត្តយានសទិសា កតា។

*ពាក្យថា "**ធ្វើឲ្យដូចជាយាន**" គឺធ្វើឲ្យដូចជាយានដែលគេទឹមហើយ ។*

"វត្ថុកតា"តិ បតិដ្ឋដ្ឋេន វត្ថុសទិសា កតា។

*ពាក្យថា "**ធ្វើឲ្យដូចជាទីតាំង**" គឺធ្វើឲ្យដូចជាទីតាំង ដោយអត្ថថា ជាទីប្រតិស្ឋាន។*

"អនុដ្ឋិតា"តិ បច្ចុបដ្ឋិតា។

*ពាក្យថា "**ដែលបានប្រាកដហើយ**" គឺតាំងទុកនៅចំពោះមុខហើយ ។*

"បរិចិតា"តិ សមន្តតោ ចិតា ឧបចិតា។

*ពាក្យថា "**អប់រំសន្សំហើយ**" គឺអប់រំ ចូលទៅអប់រំហើយដោយជុំវិញ ។*

"សុសមារទ្ធា"តិ សុដ្ឋុ សមារទ្ធា សុកតា។

*ពាក្យថា "**ប្រារព្ធសេចក្តីសូប់ប្រពៃហើយ**" មានសេចក្តីថា ប្រារព្ធដោយល្អហើយ ធ្វើដោយល្អហើយ ។*

"យត្ត យត្ត អាកង្ខតី"តិ យេសុ យេសុ ឈានេសុ យាសុ យាសុ វិបស្សនាសុ សចេ ឥច្ឆតិ។

*ពាក្យថា "**កិកុប្រាថ្នាប៉ុនប៉ងនូវធម៌ណាៗ**" មានសេចក្តីថា ប្រសិនបើកិក្ខុប្រាថ្នាក្នុងឈានណាៗ ក្នុងវិបស្សនាណាៗ ។*

តត្ត តត្ថាតិ តេសុ តេសុ ឈានេសុ តាសុ តាសុ វិបស្សនាសុ។

*ពាក្យថា "**ក្នុងធម៌នោះៗ**" គឺក្នុងឈាននោះៗ ក្នុងវិបស្សនានោះៗ ។*

"វសិប្បត្តោ"តិ វសីភាវំ ពហុភាវំ បត្តោ។

*ពាក្យថា "**ជាអ្នកដល់នូវការស្ទាត់ជំនាញ**" គឺភាពជាអ្នកជំនាញ ភាពជាអ្នកច្រើន។*

"ពលប្បត្តោ"តិ សមថវិបស្សនាពលប្បត្តោ។

*ពាក្យថា "**ដល់នូវកំលាំង**" គឺដល់នូវកំលាំងរបស់សមថៈនិងវិបស្សនា ។*

"វេសារជ្ជប្បត្តោ"តិ វិសារទភាវំ បជុភាវំ បត្តោ។

*ពាក្យថា "**ដល់នូវសេចក្តីក្លៀវក្លា**" គឺដល់នូវភាពជាអ្នកក្លៀវក្លា ភាវៈជាអ្នកប្រាកដ ។*

"តេ ធម្មា"តិ សមថវិបស្សនា ធម្មា។

*ពាក្យថា "**ធម៌ទាំងឡាយនោះ**" បានដល់ធម៌ គឺសមថៈនិងវិបស្សនា ។*

"អាវជ្ជនបដិពទ្ធា"តិ អាវជ្ជនាយត្តា, **អាវជ្ជិតមត្តេយេវ** តស្ស សព្ពានេន, ញាណេន វា សម្បយោគំ គច្ឆន្តីតិ អត្ថោ។

*ពាក្យថា "**ជាប់ចំពោះដោយការនឹករំពឹង**" គឺជាប់ដោយការនឹក, មានសេចក្តីថា ពេលនឹកប៉ុណ្ណោះ ក៏ដល់ការជួបដោយជាប់តគ្នានៃអាវជ្ជនៈនោះ, ឬដោយញាណ ។*

"អាកង្ខបដិពទ្ធា"តិ រុចិអាយត្តា, **ភោចិតមត្តេយេវ** វុត្តនយេន សម្បយោគំ គច្ឆន្តីតិ អត្ថោ។

*ពាក្យថា "**ជាប់ចំពោះដោយការប្រាថ្នាប៉ុនប៉ង**" គឺជាប់ដោយភាពពេញចិត្ត,មានសេចក្តីថា ការពេញចិត្តប៉ុណ្ណោះ ក៏ដល់ភាពជួបចូលតាមន័យដែលបានពោលមកហើយ។*

មនសិការោ បនេត្ថ អាវជ្ជនាយ **ចិត្តុប្បាទោ**។

*ចំណែក **មនសិការ** ប្រែថា ការធ្វើទុកក្នុងចិត្ត ក្នុងទីនេះបានដល់*

ចិត្តុប្បាទ គឺចិត្តកើតឡើងក្នុងការនឹក ។

អាកង្ខ្ជាយ វេចនវសេន អត្តវិវរណត្ថំ វុត្តោ។

លោកពោលទុក ដើម្បីជាការអធិប្បាយនូវអត្ថ ដោយអំណាចជា វេចន: នៃការប្រាថ្នាប៉ុនប៉ង ។

"តេន វុច្ចតិ យានីកតា"តិ ឯវំ កតត្តាយេវ តេ យុត្តយានសទិសា កតា ហោន្តីតិ វុត្តំ ហោតិ។

*ពាក្យថា "**ព្រោះហេតុនោះ លោកទើបពោលថា ធម៌ធ្វើឲ្យដូចជាយាន**" មានពាក្យអធិប្បាយថា ព្រោះបានធ្វើហើយយ៉ាងនេះ នុ៎ះឯង ធម៌ទាំងឡាយនោះ ទើបជាការធ្វើឲ្យដូចជាយានដែលបានទឹមហើយ (យានដែលបានទឹមគោ ឬសេះបានត្រៀមទុករួចហើយ) ។*

"យស្មិ យស្មិ វត្ថុស្មិ"ន្តិ សោឧ្បសសុ វត្ថូសុ ឯកេកស្មិ។

*ពាក្យថា "**ចំពោះវត្ថុណាៗ**" បានដល់ក្នុងវត្ថុតែម្យ៉ាង ក្នុងបណ្តាវត្ថុទាំង ១៦ នោះ ។*

"សុាធិដ្ឋិត"ន្តិ សុប្បតិដ្ឋិតំ។

*ពាក្យថា "**អធិដ្ឋានបានល្អ (តាំងមាំបានល្អ)**" គឺការតាំងទុកដោយល្អហើយ។*

"សុបដ្ឋិតា"តិ សុដ្ឋុ ឧបដ្ឋិតា។

*ពាក្យថា "**តម្កល់មាំស៊ប់បានល្អ**" គឺចូលទៅតាំងទុកបានដោយល្អ ។*

សម្បយុត្តចិត្តសតីនំ សហេវ សកសកកិច្ចករណតោ អនុលោមបដិលោមវសេន យោជេត្វា តេ ទ្វេ ធម្មា ឧស្សិតា។

ធម៌ទាំងពីរនោះ លោកសម្តែងប្រកបដោយអំណាចអនុលោម និង

បដិលោម ព្រោះធ្វើកិច្ចរបស់ខ្លួនៗ រួមគ្នាតែមួយនៃចិត្តនិងសតិដែលប្រកបរួមគ្នា។

"តេន វុច្ចតិ វត្ថុកតា"តិ ឯវំ ភូតត្តាយេវ កតបតិដ្ឋា ហោន្តីតិ វុត្តំ ហោតិ។

*ពាក្យថា "**ដោយហេតុនោះ លោកទើបពោលថា ធ្វើឲ្យដូចជាទីតាំង**" មានអធិប្បាយថា ព្រោះហេតុជាតំណែង យ៉ាងនេះ នុ៎ះឯង ទើបលោកពោលទុកថាបានធ្វើជាទីតាំងទុកហើយ ។*

"យេន យេន ចិត្តំ អភិនីហរតី"តិ បុព្វប្បវត្តិតោ អបនេត្វា យត្ត យត្ត ភាវនាវិសេសេ ចិត្តំ ឧបនេតិ។

*ពាក្យថា "**យេន យេន ចិត្តំ អភិនីហរតិ**" ប្រែថា "**ចិត្តបង្ហោនទៅក្នុងភាវនាវិសេសណាៗ**" មានន័យថា ព្រះយោគាវចរ បង្ហោនចិត្តចូលទៅក្នុងភាវៈផ្សេងៗនៃភាវនាណាៗ ប្រាសចេញចាកពីការប្រព្រឹត្តក្នុងកាលមុន ។*

"តេន តេន សតិ អនុបរិវត្តតី"តិ តស្មឹ តស្មឹយេវ ភាវនាវិសេសេ សតិ អនុកូលា ហុត្វា បុព្វប្បវត្តិតោ និវត្តិត្វា បវត្តតិ។

*ពាក្យថា "**តេន តេន សតិ អនុបរិវត្តតិ**" ប្រែថា "**សតិរមែងប្រព្រឹត្តទៅតាម ក្នុងធម៌នោះៗ**" មានសេចក្តីថា សតិជាធម្មជាតិជួយឧបត្ថម្ភឲ្យត្រលប់ចាកពីការប្រព្រឹត្តិទៅក្នុងកាលមុន ហើយរមែងប្រព្រឹត្តទៅក្នុងការផ្សេងនៃភាវនានោះៗ នុ៎ះឯង ។*

"យេន, តេនា"តិ ចេត្ថ "យេន ភគវា តេនុបសង្កមី"តិអាទីសុ[៦៧] វិយ ភុម្មត្ថោ វេទិតព្ពោ។

*ក៏ទាំងពីរបទថា "**យេន, និង តេន**" នេះ គប្បីជ្រាបថាចុះក្នុងអត្ថជាសត្តមីវិភត្តិ ដូចក្នុងពាក្យថា "**យេន ភគវា តេនុបសង្កមិ**" ដែលប្រែថា ព្រះដ៏*

---

៦៧ ក្នុងមង្គលសុត្ត បិ. ៥២/ ទំ. ៤ ។

មានព្រះភាគជាម្ចាស់ ទ្រង់គង់នៅក្នុងទីណា ចូលទៅគាល់ក្នុងទីនោះ ។

"តេន វុច្ចតិ អនុដ្ឋិតា"តិ ឯវំ ការណាតោយេវ តំ តំ ភាវនំ អនុគន្ត្វា បិតា ហោន្តីតិ វុត្តំ ហោតិ។

*ពាក្យថា "**តេន វុច្ចតិ អនុដ្ឋិតា**" មានពាក្យអធិប្បាយថា ព្រោះការធ្វើយ៉ាងនេះ នុ៎ះឯង ទើបលោកពោលថា ទៅតាមភាវនានោះៗ តាំងនៅហើយ ។*

អានាចានស្សតិយា សតិបជានត្តា វត្តុកតានុដ្ឋិតបទេសុ សតិយា សហាយោជនា កតាតិ វេទិតព្វា។

*គប្បីជ្រាបថា លោកធ្វើពាក្យប្រកបការព្រមដោយសតិក្នុងបទថា **វត្តុកត និង អនុដ្ឋិត** ព្រោះអានាបានស្សតិ មានសតិជាប្រធាន ។*

យស្មា បន បរិបុណ្ណាយេវ បរិចិតា ហោន្តិ វឌ្ឍិតា លទ្ធាសេវនា, តស្មា "បរិបុណ្ណា"តិបទេ វុត្តា តយោ អត្តា "បរិចិតា"តិបទេបិ វុត្តា, ចតុន្នោ វិសេសត្តោបិ វុត្តោ។

*ក៏ព្រោះ សតិ ដែលបរិបូរណ៌ហើយ នោះប៉ុណ្ណោះរមែងជាការបានអប់រំហើយ, ហេតុដូច្នោះ អត្តទាំង ៣ យ៉ាង ដែលពោលទុកក្នុងបទថា "**បរិបុណ្ណា**" លោកទើបពោល សូម្បីក្នុងបទថា "**បរិចិតា**", លោកពោលសូម្បីក្នុងអត្តពិសេសត្រង់ចំណុចទី ៤ ផងដែរ ។*

តត្ថ "សតិយា បរិក្ខណ្ហាន្តោ"តិ សម្បយុត្តាយ, បុព្វភាគាយ វា សតិយា បរិក្ខយេ បរិក្ខណ្ហាន្តោ យោគី។

*ក្នុងបណ្តាពាក្យទាំងឡាយនោះ ពាក្យថា "**កំណត់កាន់យកដោយសតិ**" មានសេចក្តីថា យោគីកិក្ខុកំណត់កាន់យកនូវធម៌ ដែលគួរកំណត់កាន់យកដោយសតិដែលប្រកបគ្នា, ឬដែលជាបុព្វភាគ ។*

"ជិនាតិ ចាបកេ អកុសលេ ឧម្មេ"តិ សមុច្ឆេទវសេន លាមកេ

កិលេសេ ជិនាតិ អភិភវតិ។

*ពាក្យថា **"រមែងឈ្នះពួកអកុសលធម៌ដ៏លាមកបាន"** មានសេចក្តីថា រមែងឈ្នះ គឺរមែងឃុំគ្រងនូវកិលេសដ៏លាមក ដោយអំណាចសមុច្ឆេទបាន ។*

អយញ្ច បុគ្គលាធិដ្ឋានា ធម្មទេសនា។

ក៏ពាក្យនេះ ជាព្រះធម្មទេសនាបុគ្គលាធិដ្ឋាន ។

ធម្មេសុ ហិ ជិនន្តេសុ តំធម្មសមង្គីបុគ្គលោបិ ជិនាតិ ឆាម។

ពិតហើយ កាលព្រះធម៌ទាំងឡាយឈ្នះ សូម្បីបុគ្គលព្រមព្រៀងដោយធម៌នោះ ក៏ឈ្មោះថា រមែងឈ្នះ ។

តេ ច ធម្មា សតឹអវិហាយ អត្តនោ បវត្តិក្ខណោ ជិនិតុមារទ្ធោ ជិតាតិ វុច្ចន្តិ យថា "កុញ្ជិតុមារទ្ធោ កុត្តោ"តិ វុច្ចតិ។

ក៏ព្រះធម៌ទាំងឡាយនោះមិនលះនូវសតិ ចាប់ផ្តើមឈ្នះក្នុងពេលបវត្តិក្ខណរបស់ខ្លួន លោកពោលថា ឈ្នះហើយដូចជាការដែលពោលមកហើយ "បុគ្គលអ្នកចាប់ផ្តើមបរិភោគ ជាអ្នកបរិភោគហើយ" ដូច្នោះ ។

លក្ខណំ បនេត្ថ សទ្ធសត្តតោ វេទិតព្ពំ។

ចំណែកសូត្រ(គឺវិធីធ្វើតួរូប) ក្នុងទីនេះ គប្បីជ្រាបចាកគម្ពីរសទ្ធសត្ត ។

ឯវំ សន្តេបិ "បរិជិតា"តិ វត្តព្ពេ ជ-ការស្ស ច-ការំ កត្វា "បរិចិតា"តិ វុត្តំ, យថាសម្ភា កតោ អស្សាតិ សុកតោតិ អត្ថវិកប្បេ ជ-ការស្ស ត-ការេ ឯវមិធាបិ វេទិតព្ពោ។

*សូម្បីកាលជាយ៉ាងនេះ កាលគួរនឹងពោលថា "**បរិជិតា**" លោកផ្លាស់ **ជ**-អក្សរទៅជា **ច**-អក្សរ ពោលថា "**បរិចិតា**", សូម្បីក្នុងពាក្យថា "**បរិចិតា**" នេះ ក៏គប្បីជ្រាបនូវសេចក្តីដូចគ្នានៅក្នុងអត្ថវិកប្បថា **សម្ភា កតោ អស្សាតិ សុកតោ** ដែលប្រែថា ឈ្មោះថា **សុកត** ដោយអត្ថថា មានព្រះវាចាល្អប្រពៃ*

ដែលលោកបានផ្ទាស់ ឧ-អក្សរទៅជា ត-អក្សរ ដោយលក្ខណៈនៃនិរុត្តិសាស្ត្រ ។

ឥមស្មឹ អត្តវិកប្បេ បរិចិតាតិ បឧំ កត្តុសាធនំ, បុរិមានិ តីណិ កម្មសាធនានិ។

ក្នុងអត្តវិកប្បៈនេះ បទថា **បរិចិតា** *ជាកត្តុសាធនៈ, ៣ បទខាងដើម ជាកម្មសាធនៈសមាស ។*

"ចត្តារោ សុសមារទ្ធា"តិ ចត្តារោ សុសមារទ្ធត្តាតិ វុត្តំ ហោតិ, អត្តសទ្ធស្ស លោចោ ឧជ្ជញ្ញោ។

*ទាំង ២ បទ "***ចត្តារោ សុសមារទ្ធា** *ប្រែថា* ***ការប្រារព្ធនូវសេចក្តីសូប់ប្រពៃមានធម៌ ៤ យ៉ាង"*** *មានអធិប្បាយថា ធម៌ ៤ យ៉ាង មានអត្តដែលលោកប្រារព្ធល្អប្រពៃហើយ, គប្បីឃើញការលុបនូវអត្តសព្ទ ។*

សុសមារទ្ធាតិ បឧស្ស អត្តាបិ ហិ ឥធ សុសមារទ្ធាតិ វុត្តាតិ វេឧិតព្ធា, សុសមារទ្ធធម្មា វា។

ពិតហើយ សូម្បីអត្តនៃបទថា **សុសមារទ្ធា** *ក៏គប្បីជ្រាបថា លោកពោលថា ជាការដែលលោកប្រារព្ធល្អប្រពៃហើយក្នុងទីនេះ, នំយម្យ៉ាងទៀត មានសេចក្តីថា មានធម៌ដែលលោកប្រារព្ធស្មើដោយល្អហើយ ។*

ចតុរត្តភេឧតោ ចត្តារោតិ វុត្តាតិ វេឧិតព្ធា, ន ធម្មភេឧតោ។

គប្បីជ្រាបថា លោកពោលថា ៤ យ៉ាង ដោយប្រភេទនៃអត្ត ៤ យ៉ាង, មិនមែនដោយប្រភេទនៃព្រះធម៌ទេ ។

យស្មា បន សុភាវិតាយេវ សុសមារទ្ធា ហោន្តិ, ន អញ្ញេ, តស្មា តយោ ភាវនត្តា ឥធាបិ វុត្តា។

ក៏ព្រោះព្រះធម៌ ដែលលោកបានអប់រំល្អហើយ រមែងដែលលោកប្រារព្ធល្អប្រពៃហើយ, មិនមែនធម៌ដទៃទេ, ព្រោះដូច្នោះ អត្តថា ចម្រើនទាំង ៣ លោក

ពោលហើយ សូម្បីក្នុងទីនេះ។

អាសេវនត្តោបិ តីសុ វុត្តេសុ វុត្តោយេវ ហោតិ, តស្មា តំ អវត្វា តប្បច្ចនីកានំ សុសមូហតត្តោ វុត្តោ។

សូម្បីក្នុងអត្ថថា **អាសេវន** *ក៏ជាការដែលលោកពោលហើយដូចគ្នា ក្នុងកាលដែលពោលនូវអត្ថទាំង ៣ ហើយ, ព្រោះដូច្នោះលោកទើបមិនពោលនូវអត្ថថា* **អាសេវន** *នោះ ពោលអត្ថថា ដកចេញហើយនូវធម៌ដែលជាសឹកសត្រូវដល់ធម៌ទាំងឡាយនោះ។*

បច្ចនីកសមុក្ឃាតេន ហិ អារទ្ធបរិយោសានំ បញ្ញាយតិ, តេន សុសមារទ្ធស្ស សិខាប្បត្តោ អត្តោ វុត្តោ ហោតិ។

ន័យម្យ៉ាងទៀត ទីបំផុតនៃការប្រារព្ធរមែងប្រាកដដោយការដកចេញនូវធម៌ដែលជាសឹកសត្រូវ,ដោយពាក្យនោះជាការពោលនូវអត្តដែលដល់ចំណុចកំពូលនៃធម៌ដែលប្រារព្ធល្អប្រពៃហើយ។

តត្ថ "តប្បច្ចនីកានៈ"ន្តិ តេសំ ឈានវិបស្សនាមគ្គានំ បដិបក្ខ-ភូតានំ។

*ក្នុងបណ្តាបទទាំងនោះ បទថា "***តប្បច្ចនីកានំ** *ប្រែថា* ***ជាការបដិបត្តិដល់ឈានវិបស្សនា****" និងមគ្គទាំងឡាយនោះ។*

"កិលេសានៈ"ន្តិ កាមច្ឆន្ទាទីនំ និច្ចសញ្ញាទិសម្បយុត្តានំ សក្កាយទិដ្ឋាទីនញ្ច។

*ពាក្យថា "***កិលេសទាំងឡាយ***" បានដល់កាមឆន្ទៈជាដើម និងសក្កាយទិដ្ឋិជាដើម ដែលសម្បយុត្តដោយនិច្ចសញ្ញា ជាដើម។*

"សុសមូហតត្តា"តិ វិក្ខម្ភនតទង្គសមុច្ឆេទវសេន សុដ្ឋុ សមូហតត្តា ជាសិតត្តា។

*ពាក្យថា "**ព្រោះគាស់រំលើងបានល្អប្រពៃហើយ**" មានន័យថា ព្រោះគាស់រំលើងហើយ ធ្វើឲ្យវិនាសបានល្អហើយ ដោយអំណាចនៃការឃុំគ្រងទុកដែលលះដោយអង្គឈាននោះៗ និងការកាត់បានដោយសមុច្ឆេទ ។*

ចោត្តកេសុ បន "សុសមុគ្ឃាតត្តា"តិ លិខិត្តិ, តំ ន សុន្ទរំ។

*ចំណែកនៅក្នុងគម្ពីរស្ទឹករឹតទាំងឡាយលោកចារឹកទុកថា "**សុសមុគ្ឃាតត្តា**", ពាក្យនោះមិនល្អ ។*

សេចក្តីស្ងប់ដ៏ល្អ (**បិដក ៧០**) [**៩៤**] (**ត**)

[១៦១] "**សុសម**"ន្តិ **អត្ថិ សមំ, អត្ថិ សុសមំ។**

*បទថា "**សុសមំ** ប្រែថា **សេចក្តីស្ងប់ដ៏ល្អ**" មានសេចក្តីថា ការស្ងប់ក៏មាន ការស្ងប់ប្រពៃក៏មាន ។*

កតមំ សមំ? យេ តត្ត ជាតា អនវជ្ជា កុសលា ពោធិបក្ខិយា – ឥទំ សមំ។

ការស្ងប់ តើដូចម្តេច? ពួកពោធិបក្ខិយធម៌ណា ដែលកើតក្នុងភាវនានោះ ជាធម៌មិនមានទោស ជាកុសល នេះឈ្មោះថា ការស្ងប់ ។

កតមំ សុសមំ? យំ តេសំ តេសំ ធម្មានំ អារម្មណា និរោធោ និព្ពានំ – ឥទំ សុសមំ។

ការស្ងប់ល្អប្រពៃ តើដូចម្តេច? ការរំលត់នូវអារម្មណ៍នៃធម៌ទាំងឡាយនោះៗណា គឺនិព្វាន, នេះឈ្មោះថា ការស្ងប់ល្អប្រពៃ ។

ឥតិ ឥទញ្ច សមំ ឥទញ្ច សុសមំ ញាតំ ហោតិ ទិដ្ឋំ វិទិតំ សច្ឆិកតំ

ផស្សិតំ បញ្ញាយ។

តាមប្រការដូចពោលមកនេះ ការសូប់និងការសូប់ល្អប្រពៃនេះ គឺយោគីភិក្ខុនោះ ដឹងហើយ ឃើញហើយ ជ្រាបច្បាស់ហើយ ធ្វើឲ្យជាក់ច្បាស់ហើយ ពាល់ត្រូវហើយដោយបញ្ញា ។

អារទ្ធំ ហោតិ វីរិយំ អសល្លីនំ, ឧបដ្ឋិតា សតិ អសម្មុដ្ឋា(៦៨) **, បស្សទ្ធោ កាយោ អសារទ្ធោ, សមាហិតំ ចិត្តំ ឯកគ្គំ។**

សេចក្តីព្យាយាមដែលយោគីភិក្ខុនោះប្រារព្ធហើយ មិនថមថយ, សតិស្មារតី ដែលលោកតម្កល់មាំហើយ រមែងមិនវង្វេង, កាយដែលស្ងប់ហើយ មិនរសាប់រសាយ, ចិត្តដែលជាសមាធិតម្កល់មាំ មានអារម្មណ៍តែមួយ ។

តេន វុច្ចតិ – "សុសមារទ្ធា"តិ។

ព្រោះហេតុនោះ លោកទើបពោលថា "ប្រារព្ធសេចក្តីស្ងប់ប្រពៃហើយ" ដោយប្រការដូច្នេះឯង ។

"អនុបុព្ពំ បរិចិតា"តិ ។

*ពាក្យថា "**អនុបុព្ពំ បរិចិតា** ប្រែថា **អប់រំហើយ តាមលំដាប់**" ។*

ឥមំ អស្សាសវសេន បុរិមា បុរិមា បរិចិតា, បច្ឆិមា បច្ឆិមា អនុបរិចិតា។

មានសេចក្តីថា យោគីភិក្ខុនោះមានសតិអប់រំនូវអានាបានស្សតិដែលកើតវគ្គមុនៗ(គឺកាលពីលើកមុនៗ) ដោយអំណាចនៃខ្យល់ដកដង្ហើមចូលវែង, អប់រំនូវអានាបានស្សតិដែលកើតវគ្គខាងក្រោយៗមក ដោយអំណាចនៃខ្យល់ដកដង្ហើមចូលវែង នេះឈ្មោះថា តាមលំដាប់ ។

ឥមំ បស្សាសវសេន បុរិមា បុរិមា បរិចិតា, បច្ឆិមា បច្ឆិមា

---

៦៨ ស្យា. អបមុដ្ឋា ។

អនុបរិចិតា។

យោគីភិក្ខុនោះមានសតិអប់រំនូវអានាបានស្សតិដែលកើតវគ្គមុនៗ(គឺកាលលើកមុនៗ) ដោយអំណាចនៃខ្យល់ដកដង្ហើមចេញវែង, មានសតិអប់រំនូវអានាបានស្សតិ ដែលកើតវគ្គខាងក្រោយៗមក ដោយអំណាចនៃខ្យល់ដកដង្ហើមចេញវែង នេះឈ្មោះថា តាមលំដាប់ ។

រស្សំ អស្សាសវសេន បុរិមា បុរិមា បរិចិតា, បច្ឆិមា បច្ឆិមា អនុបរិចិតា។

មានសតិអប់រំនូវអានាបានស្សតិដែលកើតវគ្គមុនៗ ដោយអំណាចខ្យល់ដកដង្ហើមចូលខ្លី, មានសតិអប់រំនូវអានាបានស្សតិ ដែលកើតវគ្គខាងក្រោយៗមក ដោយអំណាចខ្យល់ដកដង្ហើមចូលខ្លី នេះឈ្មោះថា តាមលំដាប់ ។

រស្សំ បស្សាសវសេន បុរិមា បុរិមា បរិចិតា, បច្ឆិមា បច្ឆិមា អនុបរិចិតា។បេ។

មានសតិអប់រំនូវអានាបានស្សតិដែលកើតវគ្គមុនៗ(គឺកាលពីលើកមុនៗ) ដោយអំណាចខ្យល់ដកដង្ហើមចេញខ្លី, មានសតិអប់រំនូវអានាបានស្សតិ ដែលកើតវគ្គខាងក្រោយៗមក ដោយអំណាចខ្យល់ដកដង្ហើមចេញខ្លី នេះឈ្មោះថា តាមលំដាប់ ។ល។ (គឺ សេចក្តីមានទៅតាមលំដាប់របស់អានាបានស្សតិទាំង ១៦ ចំណុច ឬទាំង ៤ ចតុក្ក) ។

បដិនិស្សគ្គានុបស្សី អស្សាសវសេន បុរិមា បុរិមា បរិចិតា, បច្ឆិមា បច្ឆិមា អនុបរិចិតា។

មានសតិអប់រំនូវអានាបានស្សតិដែលកើតវគ្គមុនៗ ដោយអំណាចជាអ្នកពិចារណាឃើញថា សង្ខារគួរលះបង់ស្រឡះដកដង្ហើមចូល, មានសតិអប់រំនូវអានាបានស្សតិ ដែលកើតកាលវគ្គខាងក្រោយៗមក ដោយអំណាចជាអ្នកពិចារណាឃើញសង្ខារគួរលះបង់ស្រឡះដកដង្ហើមចូល នេះឈ្មោះថា

តាមលំដាប់ ។

បដិនិស្សគ្គានុបស្សី បស្សាសវសេន បុរិមា បុរិមា បរិចិតា, បច្ឆិមា បច្ឆិមា អនុបរិចិតា។

មានសតិអប់រំនូវអានាបានស្សតិដែលកើតពីកាលវគ្គមុនៗ ដោយអំណាចជាអ្នកពិចារណាឃើញថា សង្ខារគួរលះបង់ស្រឡះដកដង្ហើមចេញ, មានសតិអប់រំនូវអានាបានស្សតិ ដែលកើតវគ្គខាងក្រោយៗមក ដោយអំណាចជាអ្នកពិចារណាឃើញសង្ខារគួរលះបង់ស្រឡះដកដង្ហើមចេញ នេះឈ្មោះថា តាមលំដាប់ ។

សព្ពាបិ សោឞ្បសវត្តុកា អានាបានស្សតិយោ អញ្ញមញ្ញំ បរិចិតា ចេវ ហោន្តិ អនុបរិចិតា ច។

អានាបានស្សតិ រួមទាំងអស់មាន ១៦ វត្ថុ យោគីកិក្ខុ បានអប់រំហើយផង អប់រំទៅតាមលំដាប់ហើយផង ទៅវិញទៅមកផង ។

តេន វុច្ចតិ – "អនុបុព្ពបរិចិតា"តិ។

ព្រោះហេតុនោះ លោកទើបពោលថា "អប់រំហើយ ទៅតាមលំដាប់" ដូច្នេះ ។

ពាក្យថា តាម គឺ តាមសភាវៈមាន ១០ យ៉ាងគឺ៖

"យថា"តិ ឧស យថត្ថា –

*ពាក្យថា "**តាម**" (គឺតាមព្រះពុទ្ធអង្គ) មានសេចក្តីថា អត្ថថា តាមសមគួរដល់សភាវៈមាន ១០ យ៉ាងគឺ៖*

១, អត្តឧមថត្តោ យថត្តោ,

អត្ថថា ទូន្មាននូវខ្លួន ឈ្មោះថា តាមសភាវៈ ឬតាមព្រះពុទ្ធអង្គ,

២, អត្តសមថត្តោ យថត្តោ,

អត្តថា សូប់រម្ងាប់នូវខ្លួន ឈ្មោះថា តាមសភាវៈ ឬតាមព្រះពុទ្ធអង្គ,

៣, អត្តបរិនិព្វាបនត្តោ យថត្តោ,

អត្តថា រំលត់នូវកិលេសទាំងអស់ក្នុងខ្លួន គឺបរិនិព្វាន ឈ្មោះថា តាមសភាវៈ ឬតាមព្រះពុទ្ធអង្គ,

៤, អភិញ្ញត្តោ យថត្តោ,

អត្តថា ដឹងច្បាស់នូវធម៌ ឈ្មោះថា តាមសភាវៈ ឬតាមព្រះពុទ្ធអង្គ,

៥, បរិញ្ញត្តោ យថត្តោ,

អត្តថា កំណត់ដឹងនូវវត្ថុដែលគួរដឹង ឈ្មោះថា តាមសភាវៈ ឬតាមព្រះពុទ្ធអង្គ,

៦, បហានត្តោ យថត្តោ,

អត្តថា លះបង់នូវវត្ថុដែលគួរលះបង់ ឈ្មោះថា តាមសភាវៈ ឬតាមព្រះពុទ្ធអង្គ,

៧, ភាវនត្តោ យថត្តោ,

អត្តថា ចម្រើននូវវត្ថុដែលគួរចម្រើនពោលគឺ ពោធិបក្ខិយធម៌ ឈ្មោះថា តាមសភាវៈ ឬតាមព្រះពុទ្ធអង្គ,

៨, សច្ឆិកិរិយត្តោ យថត្តោ,

អត្តថា ធ្វើឲ្យជាក់ច្បាស់ គឺ វិជ្ជា វិមុត្តិ និងនិព្វាន ឈ្មោះថា តាមសភាវៈ ឬតាមព្រះពុទ្ធអង្គ,

៩, សច្ចាភិសមយត្តោ យថត្តោ,

អត្តថា ត្រាស់ដឹងនូវអរិយសច្ចៈទាំង ៤ ឈ្មោះថា តាមសភាវៈ ឬតាម

ព្រះពុទ្ធអង្គ,

១០, និរោធេ បតិដ្ឋាបកត្តោ យថត្តោ។

អត្តថា តម្កល់ខ្លួនឲ្យស៊ប់នៅក្នុងនិរោធ មានព្រះនិព្វានមកជាអារម្មណ៍ ឈ្មោះថា តាមសភាវៈ ឬតាមព្រះពុទ្ធអង្គ,

"ពុទ្ធោ"តិ យោ សោ ភគវា សយម្ភូ អនាចរិយកោ បុព្វេ អននុស្សុ តេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឈិ,

*ពាក្យថា "**ព្រះពុទ្ធ**" បានដល់ ព្រះដ៏មានព្រះភាគដែលបានត្រាស់ដឹង ដោយព្រះអង្គឯង ទ្រង់ពុំមានអាចារ្យ ទ្រង់ត្រាស់ដឹងនូវសច្ចៈក្នុងធម៌ ទាំងឡាយដោយព្រះអង្គឯង ដែលទ្រង់មិនធ្លាប់បានឮមកក្នុងពេលមុន,*

តត្ត ច សព្ពញ្ញុតំ ចាបុណិ, ពលេសុ ច វសីភាវំ។

ទ្រង់ដល់នូវសព្វញ្ញុតញ្ញាណក្នុងធម៌ទាំងឡាយនោះ, ទ្រង់ដល់នូវសេចក្តីស្ទាត់ជំនាញក្នុងពលៈទាំងឡាយផង ។

សេចក្តីសង្ខេបដ៏ល្អ (អដ្ឋកថា) [៩៤] (ត)

[១៦១] បុន តស្សេវ បទស្ស អញ្ញម្បិ អត្ថវិកប្បំ ទស្សេន្តោ **"សុសម"**ន្តិអាទិមាហ។

*កាលលោកនឹងសម្តែងនូវអត្ថវិកប្បៈ(ជាពាក្យសម្តែងនូវសេចក្តីឲ្យជ្រើសរើសយកតែមួយប៉ុណ្ណោះ) សូម្បីបទដទៃនៃបទនោះ នុ៎ះឯង តទៅទើបពោលពាក្យថា "**សុសមំ**" ដូច្នេះជាដើម ។*

"តត្ត តត្ត ជាតា"តិ តស្មឹ សិខាប្បត្តភាវជាវិសេស ជាតា ។

*ក្នុងពាក្យនោះ ពាក្យថា "**កើតក្នុងធម៌នោះៗ**" គឺកើតក្នុងសេចក្តីផ្សេងនៃភាវនា ដែលសភាពបានដល់កំពូលនោះ ។*

"អនវជ្ជា"តិ កិលេសានំ អារម្មណភាវូបគមនេន កិលេសទោសវិរហិតា។

*ពាក្យថា "**មិនមានទោស**" បានដល់ វៀរចាកទោស គឺកិលេសដោយការមិនចូលទៅជាអារម្មណ៍នៃកិលេសទាំងឡាយ ។*

"កុសលា"តិ ជាតិវសេន កុសលា។

*បទថា "**កុសលា**" បានដល់ កុសលធម៌ដោយអំណាចនៃជាតិ ។*

"ពោធិបក្ខិយា"តិ ពុជ្ឈនដ្ឋេន ពោធីតិ លទ្ធនាមស្ស អរិយស្ស បក្ខេភវត្តា ពោធិបក្ខិយា។

*ពាក្យថា "**ពោធិបក្ខិយ**" បានដល់ ឈ្មោះថា **ពោធិបក្ខិយ** ព្រោះមាននៅក្នុងចំណែកនៃអរិយៈ ដែលបានឈ្មោះថា **ពោធិ** ដោយអត្ថថា ត្រាស់ដឹង ។*

"បក្ខេ ភវត្តា"តិ ហិ ឧបការភាវេ បិតត្តា។

*ពាក្យថា "**ព្រោះមាននៅក្នុងចំណែក**" មានសេចក្តីថា ព្រោះតាំងនៅជា ឧបការៈ។*

តេ ច "ចត្តារោ សតិបដ្ឋានា, ចត្តារោ សម្មប្បធានា, ចត្តារោ ឥទ្ធិបាទា, បញ្ចិន្ទ្រិយានិ, បញ្ច ពលានិ, សត្ត ពោជ្ឈង្គា, អរិយោ អដ្ឋង្គិកោ មគ្គោ"តិ[២៩] សត្តតឹស ធម្មា។

ក៏ពោធិបក្ខិយធម៌ទាំងឡាយនោះ បានដល់ ធម៌៣៧ ប្រការគឺ សតិប្បដ្ឋាន ៤, សម្មប្បធាន ៤, ឥទ្ធិបាទ ៤, ឥន្ទ្រិយ ៥, ពលៈ ៥, ពោជ្ឈង្គ ៧,

---

២៩ (ម. និ ; ចូឡនិ. មេត្តគូមាណវបុច្ឆានិទ្ទេស ២២; មិ. ប.) ។

អរិយមគ្គមានអង្គ ៨ ។

"ឥទំ សម"ន្តិ ឥទំ មគ្គក្ខណោ ធម្មជាតំ សមុច្ឆេទវសេន កិលេសេ សមេតិ វិនាសេតីតិ សមំ នាម។

*ពាក្យថា "**នេះ**" ឈ្មោះថា "**សូប៌**" មានសេចក្តីថា ធម្មជាតិក្នុងខណៈនៃមគ្គនេះ ឈ្មោះថា សូប៌ ព្រោះញុំាងកិលេសទាំងឡាយឲ្យសូប៌ គឺឲ្យវិនាសទៅដោយអំណាចជាសមុច្ឆេទ ។*

"និរោធោ និព្ពាន"ន្តិ ខុក្ខនិរោធត្តា និរោធោ, វានសង្ខាតាយ តណ្ហាយ អភាវានិព្ពានំ។

*ពាក្យថា "**និរោធនិព្ពាន**" មានសេចក្តីថា ឈ្មោះថា និរោធ ព្រោះរលត់ទុក្ខ, ឈ្មោះថា និព្វាន ព្រោះមិនមានតណ្ហា ពោលគឺវានៈ ។*

"ឥទំ សុសម"ន្តិ ឥទំ និព្វានំ សព្វសង្ខតវិសមាបកតត្តា សុដ្ឋុ សមន្តិ សុសមំនាម ។

*ពាក្យថា "**នេះ**" ឈ្មោះថា "**សូប៌ប្រពៃ**" មានសេចក្តីថា និព្វាននេះ ឈ្មោះថា សូប៌ប្រពៃ ដោយអត្ថថា សូប៌ល្អប្រពៃ ព្រោះប្រាសចាកនូវភាពដែលមិនសូប៌ គឺសង្ខតធម៌ទាំងពួង ។*

"ញាត"ន្តិ ពោធិបក្ខិយសង្ខាតំ សមំ អសម្មោហតោ ញាណេន ញាតំ, និព្វាន សង្ខាតំ សុសមំ អារម្មណតោ ញាណេន ញាតំ។

*ពាក្យថា ភិក្ខុនោះ "**ដឹងហើយ**" មានសេចក្តីថា សេចក្តីសូប៌ពោលគឺពោធិបក្ខិយ ដែលភិក្ខុនោះដឹងហើយដោយញាណ ដោយអសម្មោហ, សេចក្តីសូប៌ប្រពៃ ពោលគឺនិព្វាន ដែលភិក្ខុនោះដឹងហើយដោយញាណ ដោយអារម្មណ៍ ។*

តេនេវ ទ្វយំ តេនេវ ចក្ខុនា វិយ និដ្ឋំ។

ទាំងពីរយ៉ាងនេះឯង ដែលកិក្ខុនោះ ***ឃើញហើយ*** *ដូចជាឃើញដោយចក្ខុ (គឺ ភ្នែក) ។*

"វិទិត"ន្តិ តេនេវ ទ្វយំ សន្ធាយេ ឧប្បាទនេន អារម្មណាករណេន ច បដិលទ្ធំ។

ពាក្យថា "ដែលកិក្ខុនោះ ***ជ្រាបច្បាស់ហើយ"*** *មានសេចក្តីថា ទាំងពីរយ៉ាងនោះ ដែលកិក្ខុនោះបានចំពោះហើយដោយការធ្វើឲ្យកើតឡើងក្នុងសន្តានចិត្ត និងដោយការធ្វើឲ្យជាអារម្មណ៍ ។*

ញាតំ វិយ បញ្ញាយ *សច្ឆិកតំ ផស្សិតញ្ច*។

ដែលកិក្ខុនោះ ***ធ្វើឲ្យជាក់ច្បាស់ហើយ និងពាល់ត្រូវហើយ*** *ដោយបញ្ញាដូចជាការដែលដឹងហើយ ។*

"អសល្លីនំ អសម្មុដ្ឋា អសារទ្ធោ ឯកត្ត"ន្តិ បុរិមស្ស បុរិមស្ស បទស្ស អត្តប្បកាសនំ ។

ពាក្យថា "មិនថមថយ មិនវង្វេងមិនរសាប់រសាយ, ភាពតម្កល់មាំ " ជាពាក្យប្រកាសនូវសេចក្តីនៃបទខាងដើមៗ ។

តត្ថ "*អារទ្ធ*"ន្តិ បដ្ឋបិតំ។

ក្នុងបណ្តាពាក្យទាំងឡាយនោះ ពាក្យថា ***ប្រារព្ធហើយ*** *គឺចាប់ផ្តើមហើយ។*

"*អសល្លីន*"ន្តិ អសង្កុចិតំ។

*ពាក្យថា "****មិនថមថយ****" គឺមិនរាថយ ។*

"*ឧបដ្ឋិតា*"តិ ឧបគន្ត្វា បិតា។

*ពាក្យថា "****តម្កល់មាំហើយ****" គឺចូលទៅតាំងទុកហើយ ។*

"អសម្មុដ្ឋា"តិ អវិនដ្ឋា។

ពាក្យថា មិនវង្វេង គឺមិនវិនាសខូច ។

"បស្សទ្ធោ"តិ និព្ពុតោ។

*ពាក្យថា "**សូប់ហើយ**" គឺរលត់ហើយ ។*

"អសារទ្ធោ"តិ និទ្ទរថោ។

*ពាក្យថា "**មិនរសាប់រសាយ**" គឺមិនមានភាពក្រវ៉ល់ក្រវ៉ាយ ។*

"សមាហិត"ន្តិ សមំ បបិតំ។

*ពាក្យថា "**តម្កល់មាំ(សមាធិ)**" គឺតម្កល់ទុកស្មើៗ ។*

"ឯកគ្គ"ន្តិ អវិក្ខិត្តំ។

*ពាក្យថា "**មានអារម្មណ៍តែមួយ**" គឺមិនរាយមាយ ។*

"ចត្តារោ សុសមារទ្ធា"តិអាទិ សកលស្ស សុសមារទ្ធវចនស្ស មូលត្តោ។

ពាក្យថា "ធម៌ទាំង ៤ ដែលភិក្ខុប្រារព្ធល្អប្រពៃហើយ" ជាដើម ជាអត្ថ ជាមូលនៃពាក្យថា ប្រារព្ធល្អប្រពៃហើយទាំងអស់ ។

"អត្តិ សម"ន្តិអាទិ បន សុសមារទ្ធវចនស្ស, "ញាត"ន្តិអាទិ អារទ្ធវចនស្ស វិភាវនត្តា។

ចំណែកពាក្យថា "មានសេចក្តីសូប់" ជាដើម ជាអត្ថ ដែលជាវិភប្ប:នៃពាក្យថា សូប់ល្អប្រពៃ, ពាក្យថា "ដែលភិក្ខុដឹងហើយ" ជាដើម ជាអត្ថ ដែលជាវិភប្ប:នៃពាក្យថា ប្រារព្ធល្អប្រពៃហើយ ។

តត្ថាយំ បទត្ថសំសន្ទនា –

ក្នុងសេចក្តីនេះ មានការប្រៀបធៀបអត្ថនៃបទដូចតទៅនេះថា ៖

"**សមា ច សុសមា ច សមសុសមា**"តិ វត្តព្ពេ ឯកទេសសរូបេក-សេសំ កត្វា "**សុសមា**" ឥច្ចេវ វុត្តា យថា **ជាមញ្ច រូបញ្ច ជាមរូបញ្ច ជាមរូបន្តិ**។

*កាលគួរនឹងពោលថា "**សមា ច សុសមា ច សមសុសមា**" ប្រែថា ធម៌ទាំងសូប់ និងធម៌ដែលសូប់ល្អប្រពៃ ឈ្មោះថា **សមសុសមា** ប្រែថា ធម៌ដែលសូប់ និងធម៌ដែលសូប់ល្អប្រពៃ ដូច្នេះ លោកពោលថា "**សុសមា**" ប្រែថា សូប់ប្រពៃ ប៉ុណ្ណោះ ព្រោះការធ្វើ**សរូបេកសេសសមាស** ដោយឯកទេស ដូចជាពាក្យថា "**ជាមញ្ច រូបញ្ច ជាមរូបញ្ច ជាមរូបំ**" ប្រែថា នាមផង រូបផង នាមនិងរូបផង ឈ្មោះថា **ជាមរូបំ** ប្រែថា នាមរូប ។*

"**ឥទំ សមំ, ឥទំ សុសម**"ន្តិ បន អនញ្ញាបេក្ខំ កត្វា ជបុំសកវចនំ កតំ។

*ចំណែកពាក្យថា "**ឥទំ សមំ, ឥទំ សុសម**" ប្រែថា (នេះឈ្មោះថា សេចក្តីសូប់, នេះឈ្មោះថា សេចក្តីសូប់ល្អប្រពៃ) លោកធ្វើឲ្យជាពាក្យនបុំសកលិង្គ មិនធ្វើឲ្យជាលិង្គដទៃទេ ។*

យស្មា បន ញាតម្បិ ឯដ្ឋន្តិ វុច្ចតិ, ឯដ្ឋញ្ច អារទ្ធញ្ច អត្តតោ ឯកំ។

ក៏ព្រោះ សូម្បីធម្មជាតិដែលភិក្ខុដឹងហើយលោកក៏ពោលថា ឃើញហើយ, ការឃើញ និងការប្រារព្ធដោយអត្ត ទើបសេចក្តីដូចគ្នា ។

វិឯតសច្ឆិកតឆស្សិតានិ បន ញាតវេវចនានិ, តស្មា ញាតន្តិ អារទ្ធត្តាយេវ វុត្តោ ហោតិ។

ចំណែកការដឹង ការធ្វើឲ្យជាក់ច្បាស់ និងការពាល់ត្រូវ ជាពាក្យវេវចនៈនៃការដឹងហើយ, ព្រោះដូច្នោះ ទើបជាការពោលនូវអត្ត ដែលបានប្រារព្ធហើយថា ដែលភិក្ខុនោះដឹងហើយដូច្នោះ នុ៎ះឯង ។

"**អារទ្ធំ ហោតិ វីរិយំ អសល្លីន**"ន្តិ អយំ បន អារទ្ធវចនស្ស ឧជុកត្តោយេវ។

*ក៏ពាក្យថា"**សេចក្តីព្យាយាម ដែលតឹកតុនោះប្រារព្ធហើយមិនថមថយ**" នេះជាអត្ថត្រង់នៃពាក្យថា ប្រារព្ធហើយ ។*

"**ឧបដ្ឋិតា សតី**"តិអាទីនិ បន សម្បយុត្តវីរិយស្ស ឧបការកធម្ម-ទស្សនត្ថំ វុត្តានិ, ន អារទ្ធវចនស្ស អត្ថទស្សនត្ថំ។

*ចំណែកពាក្យថា "**សតិ តម្ពល់មាំ**" ជាដើម លោកពោលទុកដើម្បី សម្តែងធម៌ដែលជាឧបការៈដល់ការប្រកបនូវសេចក្តីព្យាយាម, មិនមែនសម្តែង អត្ថនៃពាក្យថា ប្រារព្ធហើយ ទេ ។*

បុរិមេន អត្តេន សុដ្ឋុ សមារទ្ធាតិ សុសមារទ្ធា ច, ឥមិនា អត្តេន សុសមា អារទ្ធាតិ សុសមារទ្ធា ច ឯកសេសេ កតេ "សុសមារទ្ធា"តិ វុច្ចន្តិ។

*ប្រារព្ធព្រមហើយដោយល្អតាមអត្តមុន ព្រោះដូច្នោះ ទើបឈ្មោះថា **សុសមារទ្ធា**ផង, ប្រារព្ធសូប់ល្អប្រពៃ តាមអត្តនេះ ព្រោះដូច្នោះ ទើបឈ្មោះថា **សុសមារទ្ធា**ផង កាលធ្វើជាឯកសេសសមាស លោកពោលថា "**សុសមារទ្ធា**" ប្រែថា (ប្រារព្ធព្រមដោយល្អ និងប្រារព្ធសូប់ល្អប្រពៃ) ដូច្នេះ ។*

ឥមមត្ថំ បវិត្តហោត្វា "តេន វុច្ចតិ សុសមារទ្ធា"តិ វុត្តំ។

លោកកំណត់កាន់យកអត្តនេះ ទើបពោលថា "ដោយហេតុនោះ លោក ទើបពោលថា ប្រារព្ធហើយសូប់ល្អប្រពៃ" ។

"**អនុបុព្ព**"ន្តិ យថានុក្កមេនាតិ អត្ថោ, បុព្ពំ បុព្ពំ អនូតិ វុត្តំ ហោតិ។

*បទថា "**អនុបុព្ពំ**" មានអត្ថថា **យថានុក្កមេន** ប្រែថា "**តាមលំដាប់**" មានអធិប្បាយថា តាមខាងដើមៗ ។*

"ឌីយំ អស្សាសវសេនា"តិ ឌីយន្តិ វុត្តអស្សាសវសេន។

ពាក្យថា ***"ដោយអំណាចខ្យល់ដកដង្ហើមចូលវែង"*** *គឺដោយអំណាចខ្យល់ដកដង្ហើមចូល ដែលលោកពោលថាវែង ។*

"បុរិមា បុរិមា"តិ បុរិមា បុរិមា សតិ។

បទថា ***"បុរិមា បុរិមា"*** *បានដល់សតិខាងដើមៗ ។*

ឯតេន បុព្វន្តិបទស្ស អត្ថោ វុត្តោ ហោតិ។

ដោយពាក្យនេះ ដែលលោកពោលដល់អត្ថនៃបទថា **បុព្វំ** *។*

"បច្ឆិមា បច្ឆិមា"តិ សតិយេវ។

បទថា ***"បច្ឆិមា បច្ឆិមា"*** *បានដល់សតិនោះឯង ។*

ឯតេន អន្តិបទស្ស អត្ថោ វុត្តោ ហោតិ។

ដោយពាក្យនេះ ដែលលោកពោលដល់អត្ថនៃបទថា **អន្តំ** *។*

ឧភយេន បុព្វញ្ច អន្តំ ច បរិចិតាតិ អត្ថោ វុត្តោ ហោតិ។

ដោយពាក្យទាំង ២ ជាការដែលលោកពោលអត្ថថា អប់រំហើយ ទាំងខាងដើម និងទាំងខាងក្រោយ ។

ឧបរិ សោឡស វត្ថូនិ វិត្ថារេត្វា វចនតោ ឥធ សង្ខិបិត្វា "បដិនិស្សគ្គានុបស្សី"តិ **អន្តិមមេវ ឧស្សិតំ។**

*ព្រោះលោកពោលញុំាងវត្ថុទាំង ១៦ ឲ្យពិស្តារនៅខាងមុខ នៅក្នុងទីនេះ លោកទើបសម្តែងសង្ខេបបទដែលមានក្នុងទីបំផុតប៉ុណ្ណោះថា "**បដិនិស្សគ្គានុបស្សី**" ប្រែថា ពិចារណាឃើញថា សង្ខារគួរលះបង់ស្រឡះ ។*

យស្មា សិខាប្បត្តការណស្ស សព្ពាបិ អាធានស្សតិយោ បុនប្បុនំ យថារុចិបវត្តនតោ អនុបរិចិតាបិ ហោន្តិ។

ព្រោះហេតុដែលអានាបានស្សតិទាំងអស់ រមែងជាការដែលបុគ្គលអ្នកមានភាវនាដែលបានដល់កំពូល សូម្បីអប់រំហើយតាមលំដាប់ ព្រោះប្រព្រឹត្តិទៅតាមការពេញចិត្តរឿយ ។ ។

តេន វុត្តំ – "អញ្ញមញ្ញំ បរិចិតា ចេវ ហោន្តិ អនុបរិចិតា ចា"តិ។

ព្រោះហេតុនោះ លោកទើបពោលថា "អានាបានស្សតិមានវត្ថុ ១៦ យ៉ាង សូម្បីទាំងពួងក៏អាស្រ័យគ្នានិងគ្នាដែរ ភិក្ខុនោះអប់រំហើយ និងអប់រំទៅតាមលំដាប់ហើយ ។

ពាក្យថា តាម គឺតាមសតាទ ១០ យ៉ាង (អដ្ឋកថា ត)

"យថត្ថា"តិ យថាសភាវត្ថា។

*បទថា "**យថត្ថា** ប្រែថា **អត្ថតាមគួរដល់សភាវៈ**" ។*

"អត្តនមថត្ថោ"តិ អរហត្តមគ្គក្ខណោ អត្តនោ និព្ពិសេវនត្ថោ។

*ពាក្យថា "**អត្ថថា ហ្វឹកហាត់ខ្លួន**" បានដល់ ធ្វើខ្លួនឲ្យអស់នូវការប្រកាន់ក្នុងខណៈនៃអរហត្តមគ្គ (កើតឡើង) ។*

"(អត្ត)សមថត្ថោ"តិ សីតិភាវត្ថោ។

*អត្តថា "**សូប់រម្ងាប់នូវខ្លួន**" បានដល់អត្តថា ជាសភាវៈដែលត្រជាក់*

"បរិនិព្វាបនត្ថោ"តិ កិលេសបរិនិព្វានេន។

*ពាក្យថា "**អត្តថា ញ៉ាំងខ្លួនឲ្យបរិនិព្វាន**" គឺដោយកិលេសបរិនិព្វាន ។*

"អភិញ្ញត្ថោ"តិ សព្វធម្មវសេន។

*ពាក្យថា "**អត្តថា ដឹងយ៉ាងក្រៃលែង**" គឺដោយអំណាចនៃធម៌ទាំងពួង ។*

បរិញ្ញត្ថាទយោ មត្តញ្ញាណាភិច្ចវសេន។

អត្តថាកំណត់ដឹង ជាដើម ដោយអំណាចកិច្ចនៃមគ្គញាណ ។

សច្ចាភិសមយត្ថោ ចតុន្នំ សច្ចានំ ឯកបដិវេធទស្សនវសេន។

អត្តថា ត្រាស់ដឹងនូវសច្ច: ដោយអំណាចការសម្តែងសេចក្តីឯកបដិវេធនៃ *សច្ច:*ទាំង ៤ ។

និរោធេ បតិដ្ឋាបកត្ថោ អារម្មណាករណវសេន។

អត្តថា ញុាំងខ្លួនឲ្យប្រតិស្ឋាននៅក្នុងនិរោធ ដោយអំណាចការធ្វើឲ្យជាអារម្មណ៍ ។

ពុទ្ធោតិបទស្ស អភាវេបិ ពុទ្ធេជាតិបទេ យោ សោ ពុទ្ធោ, តំ និទ្ទិសិតុកាមេន **ពុទ្ធោតិ** វុត្តំ។

សូម្បីកាលមិនមានបទថា **ពុទ្ធោ** *លោកប្រាថ្នានឹងសម្តែងអធិប្បាយព្រះពុទ្ធជាម្ចាស់ក្នុងបទថា* **ពុទ្ធេន** *នោះ ទើបលោកពោលថា* **ពុទ្ធោ** ។

"**សយម្ភូ**"តិ ឧបនេសំ វិនា សយមេវ ភូតោ។

*បទថា "***សយម្ភូ** *ប្រែថា* ***ព្រះអង្គត្រាស់ដឹងដោយខ្លួនឯងនោះប៉ុណ្ណោះ"*** *ប្រាសចាកការណែនាំ ។*

"**អនាចរិយកោ**"តិ សយម្ភូបទស្ស អត្តវិវរណំ។

ពាក្យថា **មិនមានអាចារ្យ** *ជាពាក្យអធិប្បាយសេចក្តីរបស់បទថា សយម្ភូ។*

យោ ហិ អាចរិយំ វិនា សច្ចានិ បដិវិជ្ឈតិ, សោ សយម្ភូ នាម ហោតិ។

ពិតមែន បុគ្គលណាត្រាស់ចាកនូវអាចារ្យ រមែងចាក់ធ្លុះនូវសច្ច:ទាំងឡាយបាន,បុគ្គលនោះ ឈ្មោះថា ជាសយម្ភូ ។

"**បុព្វេ អននុស្សុតេសូ**"តិអាទិ អនាចរិយកភាវស្ស អត្តប្ប-

ការសនំ។

*ពាក្យថា "**ដែលមិនធ្លាប់បានស្តាប់មកក្នុងកាលមុន**" ជាដើម ជាពាក្យប្រកាសនូវសេចក្តីនៃការដែលព្រះអង្គជាអ្នកមិនមានអាចារ្យ ។*

"អននុស្សុតេសូ"តិ អាចរិយំ អននុស្សុតេសុ។

*ពាក្យថា "**ដែលមិនធ្លាប់បានស្តាប់មក**" គឺដែលមិនធ្លាប់បានស្តាប់ពីគ្រូអាចារ្យ ។*

"សាម"ន្តិ សយមេវ។

*បទថា "**សាមំ** ប្រែថា **ឯង**" ប៉ុណ្ណោះ ។*

"អភិសម្ពុជ្ឈី"តិ កុសំ សម្មា បដិវិជ្ឈិ។

*បទថា "**ត្រាស់ដឹង**" គឺចាក់ធ្លុះយ៉ាងប្រពៃ យ៉ាងក្រៃលែង ។*

"តត្ត ច សព្វញ្ញុតំ ចាបុណី"តិ តេសុ ច សច្ចេសុ សព្វញ្ញុការំ ចាបុណិ។

*ពាក្យថា "**នឹងទ្រង់បានដល់នូវសព្វញ្ញុតញ្ញាណក្នុងធម៌ទាំងឡាយនោះ**" មានសេចក្តីថា នឹងដល់ការៈជាព្រះសព្វញ្ញុក្នុងសច្ចៈទាំងឡាយនោះ ។*

យថា សច្ចានិ បដិវិជ្ឈន្តោ សព្វញ្ញុនោ ហោន្តិ, តថា សច្ចានំ បដិវិទ្ធត្តា ឯវំ វុត្តំ។

លោកជាអ្នកចាក់ធ្លុះនូវសច្ចៈទាំងឡាយ រមែងជាព្រះសព្វញ្ញូដោយប្រការណា, លោកពោលយ៉ាងនេះ ព្រោះព្រះអង្គទ្រង់ចាក់ធ្លុះនូវសច្ចៈទាំងឡាយដោយប្រការនោះ ។

សព្វញ្ញុតំ បត្តោតិបិ ចាហោ។

*បាឋៈ គឺព្រះបាឡីជា **សព្វញ្ញុតំ បត្តោ** បែបនេះក៏មាន (គឺមានសេចក្តី*

ដូចគ្នា)

"ពលេសុ ច វសីភាវ"ន្តិ ឧសសុ ច តថាគតពលេសុ ឥស្សរភាវំ ចាបុណិ។

ពាក្យថា ទ្រង់ដល់នូវ សេចក្តីស្ងាត់ជំនាញក្នុងកម្លាំងទាំងឡាយ មានសេចក្តីថា ទ្រង់ដល់នូវឥស្សរៈភាពក្នុងកម្លាំងរបស់ព្រះតថាគតទាំង ១០ ។

យោ សោ ឯវំ ភូតោ, សោ ពុទ្ធោតិ វុត្តំ ហោតិ។

មានសេចក្តីថា ព្រះដ៏មានព្រះភាគជាម្ចាស់ព្រះអង្គនោះណា ទ្រង់យ៉ាងនេះ, ព្រះដ៏មានព្រះភាគជាម្ចាស់អង្គនោះ ទ្រង់ជាព្រះពុទ្ធ ។

តត្ថ សព្ពេសុ ឩម្មេសុ អប្បដិហតញ្ញាណនិមិត្តានុត្តរវិមោក្ខាធិ-គមបរិភាវិតំ ខន្ធសន្តានំ ឧចាចាយ បណ្ណាត្តិភោ, សព្ពញ្ញុតបឩជ្ជានំ វា សច្ចាភិសម្ពោធិមុចាចាយ បណ្ណាត្តិភោ សត្តវិសេសោពុទ្ធោ។

សត្តវិសេសជាអ្នកមានព្រះបញ្ញា អាស្រ័យខន្ធសន្តានដែលបានអប់រំហើយ ដោយការបន្ទុះវិមោក្ខដែលជាកំពូលនៃធម៌ផង ជានិមិត្តនៃញាណជាបច្ច័យ ដែលអ្វីៗមកពាំងក្នុងធម៌ទាំងអស់នោះមិនបានផង, ឬជាអ្នកមានព្រះនាមបញ្ញត្តិអាស្រ័យការត្រាស់ដឹងព្រមដោយព្រះបញ្ញាដ៏ក្រៃលែងនូវសច្ចៈដែលមានភាពជាព្រះសព្វញ្ញុជាបទដ្ឋាន ឈ្មោះថា ពុទ្ធ ។

ឯត្តាវតា អត្តតោ ពុទ្ធវិភាវតា កតា ហោតិ។

*ដោយពាក្យត្រឹមតែប៉ុណ្ណោះ ជាការអធិប្បាយ **ពុទ្ធ** ដោយអត្ត ។*

ពាក្យថា ពុទ្ធោ ១៥ យ៉ាង (ចិដក ៧០[៩៤] (ត))

[១៦២] "**ពុទ្ធោ**"តិ កេនដ្ឋេន ពុទ្ធោ?

សំនួរត្រង់ពាក្យថា **ពុទ្ធោ** *តើព្រះពុទ្ធដោយអត្ថថា ដូចម្តេច?*

១. **ពុជ្ឈិតា សច្ចានីតិ – ពុទ្ធោ។**

ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុត្រាស់ដឹងនូវសច្ចៈទាំង៤ប្រាយ។

២. **ពោធេតា បជាយាតិ – ពុទ្ធោ។**

ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុព្រះអង្គញុំាងពពួកសត្វឲ្យត្រាស់ដឹងផង។

៣. **សព្វញ្ញុតាយ ពុទ្ធោ។**

ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គត្រាស់ដឹងនូវសព្វញ្ញុតញាណ។

៤. **សព្វទស្សាវិតាយ ពុទ្ធោ។**

ឈ្មោះថា ព្រះពុទ្ធ ព្រោះទ្រង់បានឃើញនូវសព្វគ្រប់។

៥. **អនញ្ញនេយ្យតាយ ពុទ្ធោ។**

ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គឥតមានបុគ្គលដទៃណែនាំ។

៦. **វិសវិតាយ**[៣០] **ពុទ្ធោ។**

ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គបើកបង្ហាញឲ្យដឹងនូវគុណធម៌គ្រប់ៗយ៉ាង។

៧. **ខីណាសវសង្ខាតេន ពុទ្ធោ។**

ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គមានអាសវៈអស់ហើយ។

៨. **និរុបលេបសង្ខាតេន**[៣១] **ពុទ្ធោ។**

---

៣០ ស្យា. វិកតិតាយ។

៣១ ស្យា. និរុបក្កិលេសសង្ខាតេន។

ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គមិនមានឧបក្កិលេស ។

๙. ฬ កន្តវីតរាគោតិ – ពុទ្ធោ។

ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុព្រះអង្គច្រាសចាករាគៈដោយដាច់ខាត ។

๑๐. ฬ កន្តវីតទោសោតិ – ពុទ្ធោ។

ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុព្រះអង្គច្រាសចាកទោសៈដោយដាច់ខាត។

๑๑. ฬ កន្តវីតមោហោតិ – ពុទ្ធោ។

ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុព្រះអង្គច្រាសចាកមោហៈដោយដាច់ខាត ។

๑๒. ฬ កន្តនិក្កិលេសោតិ – ពុទ្ធោ។

ឈ្មោះថា ព្រះពុទ្ធ ព្រោះព្រះអង្គមិនមានកិលេសដោយដាច់ខាត ។

๑๓. ฬ កាយនមក្កំ កតោតិ – ពុទ្ធោ។

ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុព្រះអង្គស្តេចយាងទៅកាន់ផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង។

๑๔. ฬ កោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ – ពុទ្ធោ។

ឈ្មោះថា ព្រះពុទ្ធ ព្រោះហេតុព្រះអង្គតែម្នាក់ឯងបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណដ៏ប្រសើរ ។

๑๕. អពុទ្ធិវិហតត្តា ពុទ្ធិបដិលាភា – ពុទ្ធោ។

ឈ្មោះថា ព្រះពុទ្ធ ព្រោះការបានចំពោះនូវបញ្ញាដោយហេតុព្រះអង្គកំចាត់ចោលនូវធម្មជាតិផ្ទុយនឹងប្រាជ្ញាចេញអស់ហើយ ។

"ពុទ្ធោ"តិ នេតំ នាមំ មាតរា កតំ,

ព្រះនាមថា ព្រះពុទ្ធនេះ មិនមែនជាព្រះនាមដែលព្រះមាតាថ្វាយទេ,

ន បិតរា កតំ, ន ភាតរា កតំ,

មិនមែនព្រះបិតាថ្វាយទេ, មិនមែនបងប្រុស ប្អូនប្រុសថ្វាយទេ,

ន ភគិនិយា កតំ,

មិនមែនបងស្រី ប្អូនស្រីថ្វាយទេ,

ន មិត្តាមច្ចេហិ កតំ,

មិនមែនពួកមិត្តអាមាត្យថ្វាយទេ,

ន ញាតិសាលោហិតេហិ កតំ,

មិនមែនពួកញាតិសាលោហិតថ្វាយទេ,

ន សមណាព្រាហ្មណេហិ កតំ,

មិនមែនពួកសមណៈព្រាហ្មណថ្វាយទេ,

ន ទេវតាហិ កតំ។

មិនមែនពួកទេវតាថ្វាយទេ,

វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ ពោធិយា មូលេ សហ សព្វញ្ញុ-តញ្ញាណស្ស បដិលាភា សច្ឆិកា បញ្ញត្តិ យទិទំ – ពុទ្ធោតិ។

ព្រះនាមថា ព្រះពុទ្ធនេះជាវិមោក្ខន្តិកនាម(ព្រះនាមដែលកើតមានក្នុងទីបំផុតនៃការរួចចាកកិលេស) របស់ព្រះពុទ្ធទាំងឡាយព្រះមានព្រះភាគជានាម **សច្ឆិកបញ្ញត្តិ** *ព្រោះការត្រាស់ដឹងមានដំណាលគ្នានឹងការបាននូវសព្វញ្ញុតញ្ញាណ នៅក្រោមម្លប់ពោធិព្រឹក្ស(អស្សត្ថព្រឹក្ស) ។*

"ឥសិតា"តិ អត្តឧមថត្តោ យថត្តោ យថា ពុទ្ធេន ឥសិតោ, អត្តសមថត្តោ យថត្តោ យថា ពុទ្ធេន ឥសិតោ, អត្តបរិនិព្ពាបនត្តោ យថត្តោ យថា ពុទ្ធេន ឥសិតោ។...បេ....។

*ពាក្យថា "**តាមដែលព្រះអង្គទ្រង់បានសម្តែងហើយ**" មានសេចក្តីថា តាម សការៈ* **យថា** *សព្ទ ប្រែថា តាម មានអត្ថថា ទូន្មាននូវខ្លួន ឈ្មោះអត្ថថា តាម គឺ តាមព្រះពុទ្ធទ្រង់បានសម្តែងហើយ, អត្ថថា សូប់រម្ងាប់នូវខ្លួន* **យថា** *សព្ទ ប្រែថា តាម ឈ្មោះអត្ថថាតាម គឺតាមព្រះពុទ្ធទ្រង់បានសម្តែងហើយ អត្ថថា រំលត់បង់ នូវកិលេស គឺចូលកាន់ព្រះនិព្វាន* **យថា** *សព្ទប្រែថា តាម ឈ្មោះអត្ថថា តាម គឺ តាមព្រះពុទ្ធទ្រង់បានសម្តែងហើយ ។ល។*

និភេឆេ បតិដ្ឋាបកត្តោ យថត្តោ យថា ពុទ្ធេន ឧទិសិតោ។

អត្ថថា ញុំាងខ្លួនឲ្យតម្កល់ស៊ប់ក្នុងនិភេធធម៌មាន **យថា** *សព្ទ ជាអត្ថ ដែលប្រែថា តាម ទោះបុគ្គលនោះជាគ្រហស្តក្តី ជាបព្វជិតក្តី ញុំាងខ្លួនឲ្យតម្កល់ ស៊ប់នៅក្នុងនិភេធធម៌ គឺតាមព្រះពុទ្ធទ្រង់បានសម្តែងហើយ ។*

"សោ"តិ កហដ្ឋោ វា ហោតិ បព្វជិតោ វា។

*ពាក្យថា "**យោគីភិក្ខុនោះ**"បានដល់ យោគីភិក្ខុ ជាគ្រហស្តក្តី ជាបព្វជិតក្តី។*

"លោកោ"តិ ខន្ធលោកោ ធាតុលោកោ អាយតនលោកោ វិបត្តិភវលោកោ វិបត្តិសម្ភវលោកោ សម្បត្តិភវលោកោ សម្បត្តិសម្ភ-វលោកោ។

*ពាក្យថា "**លោក**" បានដល់ ខន្ធលោក ធាតុលោក អាយតនលោក វិបត្តិ ភវលោកោ វិបត្តិសម្ភវលោកោ សម្បត្តិភវលោកោ និងសម្បត្តិសម្ភវលោកោ ។*

ឯកោ លោកោ – សព្ពេ សត្តា អាហារដ្ឋិតិកា។...បេ....។ អដ្ឋារស លោកា អដ្ឋារស ធាតុយោ។

លោក ๑ បានដល់ពួកសត្វទាំងឡាយទាំងពួងដែលតាំងនៅបាន ដោយសារអាហារ ។...ល...។ លោក ๑๘ , បានដល់ធាតុ ๑๘ ។

"បកាសេតី"តិ អត្តនមថត្តំ យថត្តំ អភិសម្ពុទ្ធត្តា សោ ឥមំ លោកំ

ឱភាសេតិ ភាសេតិ បភាសេតិ។

*ពាក្យថា "**រមែងឲ្យភ្លឺច្បាស់**" គឺបុគ្គលនោះ រមែងញុំាងលោកនេះឲ្យភ្លឺស្វាង ឲ្យភ្លឺច្បាស់ ព្រោះការត្រាស់ដឹងនូវអត្តថា ទូន្មាននូវខ្លួន ។*

អត្តសមថត្តំ យថត្តំ អភិសម្ពុទ្ធត្តា សោ ឥមំ លោកំ ឱភាសេតិ ភាសេតិ បភាសេតិ។

អត្តថា តាម បុគ្គលនោះរមែងញុំាងលោកនេះឲ្យភ្លឺស្វាង ឲ្យភ្លឺច្បាស់ ព្រោះការត្រាស់ដឹងនូវអត្តថា សូប់រម្ងាប់នូវខ្លួន ។

អត្តបរិនិព្វាបនត្តំ យថត្តំ អភិសម្ពុទ្ធត្តា សោ ឥមំ លោកំ ឱភាសេតិ ភាសេតិ បភាសេតិ។...បេ....។

អត្តថា តាម បុគ្គលនោះរមែងញុំាងលោកនេះ ឲ្យភ្លឺស្វាង ឲ្យភ្លឺច្បាស់ ព្រោះត្រាស់ដឹងនូវអត្តថា រំលត់ខន្ធចូលកាន់បរិនិព្វាន។...ល...។

និរោធេ បតិដ្ឋាបកត្តំ យថត្តំ អភិសម្ពុទ្ធត្តា សោ ឥមំ លោកំ ឱភាសេតិ ភាសេតិ បភាសេតិ។

អត្តថា តាម បុគ្គលនោះរមែងញុំាងលោកនេះ ឲ្យភ្លឺស្វាង ឲ្យភ្លឺច្បាស់ ព្រោះត្រាស់ដឹងនូវអត្តថា តម្កល់ខ្លួនស៊ប់នៅក្នុងនិរោធធម៌ ។

"អញ្ញា មុត្តោវ ចន្ទិមា"តិ យថា អញ្ញា, ឯវំ កិលេសា។

*ពាក្យថា "**ដូចជាព្រះចន្ទដែលផុតស្រឡះចាកពពក**" គឺពពកយ៉ាងណា, រីឯកិលេសវិញក៏យ៉ាងនោះ ដូចគ្នា ។*

យថា ចន្ទោ, ឯវំ អរិយញ្ញាណំ។

ព្រះចន្ទយ៉ាងណា, រីឯ អរិយញ្ញាណក៏យ៉ាងនោះ ។

យថា ចន្ទិមា ទេវបុត្តោ, ឯវំ ភិក្ខុ។

ចន្ទិមាទេវបុត្រយ៉ាងណា, រីឯ ភិក្ខុក៏យ៉ាងនោះ ។

យថា ចន្ទោ អញ្ភា មុត្តោ មហិកា មុត្តោ ធូមរជា មុត្តោ រាហុត-ហណា[๓๒]រិប្ឋមុត្តោ ភាសតេ ច តបតេ ច រិរោចតេ[๓๓] ច ។

ព្រះចន្ទដែលផុតស្រឡះហើយចាកពពក, ដែលផុតស្រឡះហើយចាកផ្សែង និងផុតស្រឡះហើយចាកធូលីនៅលើផែនដី, ផុតស្រឡះហើយចាកបាតដៃនៃរាហូ, រមែងភ្លឺច្បាស់ផង, រមែងរុងរឿងផង, រមែងថ្កើងថ្កានផង យ៉ាងណាមិញ ។

ឯវមេវំ ភិក្ខុ សព្វកិលេសេហិ រិប្ឋមុត្តោ, ភាសតេ ច តបតេ ច រិរោចតេ ច ។

ភិក្ខុដែលផុតស្រឡះហើយ ចាកកិលេសទាំងអស់, រមែងភ្លឺផង រុងរឿងផង ថ្កើងថ្កានផង ក៏យ៉ាងនោះដែរ ។

តេន វុចូតិ – "អញ្ភា មុត្តោវ ចន្ទិមា"តិ ។

ព្រោះហេតុនោះ លោកពោលថា "ដូចជាព្រះចន្ទដែលផុតស្រឡះចាកពពក"។

ឥមានិ តេរស វោជានេ ញាណានិ ។

ទាំងនេះ ឈ្មោះថា រោទានញ្ញាណទាំង ១៣ ដោយប្រការយ៉ាងនេះឯង។

វោជានញាណនិទ្ទេសោ ចតុត្តោ ។

រោទានញ្ញាណនិទ្ទេស ទី ៤ ។

ភាណវារោ ។

ភាណវារ ។

---

๓๒ ស្យា. រាហុបាណា ។
๓๓ ស្យា. រិរោចតិ ។

ចប់ ញាណលំដាប់ទី ៤

(រៅទានញ្ញាណទាំង ១៣ ប្រការនេះ គឺជាញាណដែលបានឲ្យដឹងឲ្យស្គាល់នូវអ្វីដែលគួរ ឬមិនគួរចម្រើនដែលនាំឲ្យសមាធិរីកចម្រើនដុះដាលទៅមុខបានល្អ ។ ចំណែកវិធីរាប់ចំនួន គឺនៅត្រង់ [៧៧] ដោយការយកនូវឋានទាំង ៦ គុណ ២ គឺស្មើនឹងញាណ ១២ ហើយបូកនឹងញាណចុងក្រោយ ១ ទៀតស្មើ ១៣ ញាណ)។

ពាក្យថា ពុទ្ធោ ១៥ យ៉ាង (អដ្ឋកថា)

[៧៦២] ឥជានិ ព្យញ្ជនតោ វិភាវេន្តោ "**ពុទ្ធោតិ កេនដ្ឋេន ពុទ្ធោ**"តិ អាធិមាហ។

ឥឡូវនេះ លោកនឹងអធិប្បាយដោយព្យញ្ជន:ទើបពោលពាក្យថា **ពុទ្ធោ** *មានសេចក្តីថា ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ព្រះនាមថា* ***ពុទ្ធោ ដោយអត្ថថា ដូចម្តេច ?*** *ជាដើម ។*

តត្ថ យថា លោកេ អវតន្តា អវតតោតិ វុចូតិ, ឯវំ "ពុជ្ឈិតា សច្ចានី"តិ ពុទ្ធោ។

ក្នុងពាក្យនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ព្រះនាមថា **ពុទ្ធ** *ដោយអត្ថថា "****ត្រាស់ដឹងនូវសច្ច:ទាំងឡាយ****" ដូចជាខាងផ្ទូវលោក បុគ្គលអ្នកញ្ចាំងចុះ ហើយ ហៅថា* **អវតតោ** *(អ្នកញ្ចាំងចុះ) ។*

យថា បណ្ណសោសា វាតា បណ្ណសុសាតិ វុចូន្តិ, ឯវំ ពោធេតា បជាយាតិ ពុទ្ធោ។

ដោយវិគ្រោះថា **ពោធេតា បជាយាតិ ពុទ្ធោ** *ប្រែថា* ***អ្នកញុំាងពពួកសត្វឲ្យត្រាស់ដឹង*** *ឈ្មោះថា* **ពុទ្ធោ**, *ដូចគ្នានឹង* **បណ្ណាសោសា វាតា** *ពោលថា* **បណ្ណាសា** *ប្រែថា ខ្យល់ដែលធ្វើស្វឹកឈើឲ្យស្ងួត ឈ្មោះថា* **បណ្ណាសុសា** ។

"សព្វញ្ញុតាយ ពុទ្ធោ"តិ សព្វញ្ញុតញ្ញាណសមត្ថាយ ពុទ្ធិយា ពុទ្ធោតិ វុត្តំ ហោតិ។

ពាក្យថា ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ព្រះនាមថា ***"ពុទ្ធ ដោយសភាវៈដែលព្រះអង្គជាព្រះសព្វញ្ញូ"*** *មានអធិប្បាយថា ព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះនាមថា ពុទ្ធ ដោយព្រះបញ្ញាដែលអាចត្រាស់ដឹងនូវធម៌ទាំងពួង ។*

"សព្វញ្ញុតាយ ពុទ្ធោ"តិ សព្វញ្ញុតំ ញាណចក្ខុនា ឥដ្ឋត្តា ពុទ្ធោតិ វុត្តំ ហោតិ។

ពាក្យថា ព្រះដ៏មានព្រះភាគជាម្ចាស់ព្រះនាមថា ***"ពុទ្ធ ដោយសភាវដែលព្រះអង្គបានឃើញធម៌ទាំងពួង"*** *អធិប្បាយថា ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះទ្រង់ឃើញធម៌ទាំងពួងដោយញាណចក្ខុ ។*

"អនញ្ញនេយ្យតាយ ពុទ្ធោ"តិ អញ្ញេន អពោធនីយតោ សយមេវ ពុទ្ធត្តា ពុទ្ធោតិ វុត្តំ ហោតិ។

ពាក្យថា ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ព្រះនាមថា ***"ពុទ្ធ ដោយសភាវដែលព្រះអង្គមិនចាំបាច់ឲ្យអ្នកដទៃណែនាំ"*** *មានអធិប្បាយថា ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះហេតុដែលព្រះអង្គទ្រង់បានត្រាស់ដឹងដោយព្រះអង្គឯងប៉ុណ្ណោះ ព្រោះមិនចាំបាច់ឲ្យអ្នកដទៃមកធ្វើឲ្យត្រាស់ដឹង ។*

"វិសវិតាយ ពុទ្ធោ"តិ ជាជាកុណវិសវនតោ បទុមមិវ វិកសនដ្ឋេន ពុទ្ធោតិ វុត្តំ ហោតិ ។

បទថា **"វិសវិតាយ ពុទ្ធោ"** *ប្រែថា* ***ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ព្រះនាមថា ពុទ្ធ"*** *ដោយសភាវៈដែលព្រះអង្គជាអ្នកបើកបង្ហាញ មានសេចក្តីថា ព្រះដ៏មានព្រះភាគជាម្ចាស់ព្រះនាមថា ពុទ្ធ ដោយអត្ថថា បើកបង្ហាញដូចជាផ្កាឈូក ព្រោះទ្រង់បើកបង្ហាញដោយព្រះគុណផ្សេងៗ ។*

"ខីណាសវសង្ខាតេន ពុទ្ធោ"តិអាទីហិ ឆហិ បរិយាយេហិ ចិត្តសង្កោចការឆម្មប្បហានេន និទ្ទុក្ខយវិពុទ្ធោ បុរិសោ វិយ សព្ពកិលេសនិទ្ទុក្ខយវិពុទ្ធត្តា ពុទ្ធោតិ វុត្តំ ហោតិ។

ដោយពាក្យដែលជាបរិយាយទាំង ៦យ៉ាង មានពាក្យថា ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ព្រះនាមថា ***"ពុទ្ធ ដោយចំណែកដែលព្រះអង្គទ្រង់មានអាសវៈអស់ហើយ"*** *ជាដើម មានអធិប្បាយថា ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះព្រះអង្គទ្រង់ភ្ញាក់ក្រោកពីផ្តំលក់ដោយវិសេសហើយ ដោយការអស់ទៅនៃការផ្តំលក់គឺកិលេសទាំងពួង ដូចបុរសភ្ញាក់ក្រោកពីដេកលក់ដោយវិសេសហើយ ដោយការអស់ទៅនៃការដេកលក់ ដូច្នោះ ដោយការលះធម៌ដែលធ្វើចិត្តឲ្យតក់ស្លុត។*

សង្ខា សង្ខាតន្តិ អត្តនោ ឯកត្តា "សង្ខាតេនា"តិ វចនស្ស កោដ្ឋាសេនាតិ អត្ថោ។

ព្រោះពាក្យថា **សង្ខា សង្ខាតំ** *គឺវាតែមួយ មានសេចក្តីដូចគ្នា ពាក្យថា* **សង្ខាតេន** *ទើបមានសេចក្តីស្មើនឹងពាក្យថា* **កោដ្ឋាសេន** *ប្រែថា ដោយចំណែក ។*

តណ្ហាលេបទិដ្ឋិលេចាភាវេន និរុបលេបសង្ខាតេន។

ដោយចំណែកដែលមិនមានការចូលទៅលាបទុក *ព្រោះមិនមានការលាបទុក គឺតណ្ហា និងការលាបទុកគឺទិដ្ឋិ ។*

សវាសនានំ សព្ពកិលេសានំ បហីនត្តា ឯកន្តវចនេន វិសេសេត្វា

ឯកន្តវីតរាគោតិអាទិ វុត្តំ។

*ព្រោះការដែលព្រះអង្គទ្រង់លះកិលេសទាំងពួងព្រមទាំងវាសនា លោកទើបពោលពាក្យថា **ព្រះអង្គទ្រង់មានរាគៈប្រាសទៅហើយ** ដោយចំណែកមួយ ឲ្យផ្សេងគ្នាដោយពាក្យថា ដោយចំណែកមួយ ។*

"ឯកន្តនិក្កិលេសោ"តិ រាគោសមោហាវសេសេហិ សព្វកិលេសេហិ និក្កិលេសោ ។

*ពាក្យថា "**ទ្រង់មិនមានកិលេសដោយចំណែកមួយ**" មានសេចក្តីថា ទ្រង់មិនមានកិលេសដោយកិលេសទាំងពួងដ៏សេសចាកពី រាគៈ ទោសៈ និងមោហៈ។*

"ឯកាយនមគ្គំ គតោតិ ពុទ្ធោ"តិ គមនត្ថាំ ធាតុំ ពុជ្ឈនត្ថតា ពុជ្ឈនត្ថាបិ ធាតុយោ គមនត្ថា ហោន្តិ, តស្មា ឯកាយនមគ្គំ គតត្តា ពុទ្ធោតិ វុត្តំ ហោតិ។

*ពាក្យថា ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ព្រះនាមថា **ពុទ្ធ ដោយអត្ថថា ស្តេចយាងទៅកាន់ឯកាយនមគ្គ** បានសេចក្តីថា ព្រោះហេតុដែលធាតុទាំងឡាយដែលមានអត្ថថា ទៅ ក៏មានសេចក្តីថា ត្រាស់ដឹង សូម្បីធាតុទាំងឡាយមានអត្ថថា ត្រាស់ដឹង ក៏មានសេចក្តីថា ទៅ ក៏បាន, ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទើបទ្រង់ព្រះនាមថា ពុទ្ធ ព្រោះហេតុដែលព្រះអង្គស្តេចយាងទៅកាន់ឯកាយនមគ្គ ។*

"ឯកាយនមគ្គោ"តិ ចេត្ថ –

ក្នុងពាក្យថា ឯកាយនមគ្គនេះ

"មគ្គោ បន្ថោ បថោ បជ្ជោ, អញ្ជសំ វដ្ដមាយនំ;
ជាវ ឧត្តរសេតុ ច, កុល្លោ ច កិសិ សង្កមោ"តិ[๓๔] ។

---

๓๔ (ចូឡនិ. បារាយនត្ថុតិគាថានិទ្ទេស ๑๐๑) ។

*"**មគ្គោ** ប្រែថា ផ្លូវ **បន្ថោ** ប្រែថា ផ្លូវ **បថោ** ប្រែថា ផ្លូវ **បឋ្ឋោ** ប្រែថា ផ្លូវ **អញ្ជសំ** ប្រែថា ផ្លូវ **វដុមំ** ប្រែថា ផ្លូវ **អយនំ** ប្រែថា ផ្លូវ ; **ជាវា** ប្រែថា ទូក **ឧត្តរសេតុ** ប្រែថា ស្ពានសំរាប់ឆ្លងទន្លេ , **កុល្លោ** ប្រែថា សណ្តោង **រឹថ្នក់ កិសិ** ប្រែថា អង្រឹងកូនក្មេង **សង្កមោ** ប្រែថា គ្រឿងឆ្លង" ។*

មគ្គស្ស ពហូសុ ជាមេសុ អយនជាមេន វុត្តោ។

*លោកពោលស្របគ្នានឹងឈ្មោះផ្លូវថា **អយន** ក្នុងបណ្តាឈ្មោះដោយច្រើននៃផ្លូវ ។*

តស្មា ឯកមគ្គភូតោ មគ្គោ, ន ទ្វេជាបថភូតោតិ អត្ថោ។

ព្រោះហេតុនោះ ផ្លូវទើបជាផ្លូវតែមួយ, អធិប្បាយថា មិនមែនជាផ្លូវបំបែកជាពីរទេ ។

អថ វា ឯកេន អយិតព្ពោ មគ្គោតិ ឯកាយនមគ្គោ។

*ន័យម្យ៉ាងទៀត ជាផ្លូវដែលបុគ្គលគប្បីទៅ ព្រោះដូច្នោះ ទើបឈ្មោះថា **ឯកាយនមគ្គ** ប្រែថា ផ្លូវដែលបុគ្គលម្នាក់ឯងនឹងគប្បីទៅបាន ។*

"ឯកេនា"តិ គណាសង្ខ្លណិកំ បហាយ បវិវេកេន ចិត្តេន។

*ពាក្យថា **"ម្នាក់ឯង"** បានដល់ ចិត្តដែលលះនូវភាពច្របូកច្របល់ដោយក្រុមពួក គណៈ ។*

"អយិតព្ពោ"តិ បដិបជ្ជិតព្ពោ។

*ពាក្យថា **"នឹងគប្បីទៅ"** គឺនឹងគប្បីធ្វើដំណើរទៅ ។*

អយន្តិ វា ឯតេនាតិ អយនោ, សំសារតោ និព្ពានំ គច្ឆន្តីតិ អត្ថោ។

*ន័យម្យ៉ាងទៀត ឈ្មោះថា **អយន** ដោយអត្ថថា ជាហេតុទៅ, បានសេចក្តីថា ទៅកាន់ព្រះនិព្វានចាកសង្សារ ។*

ឯកេសំ អយនោ ឯកាយនោ។

ផ្លូវរបស់លោកជាអ្នកឯកទាំងឡាយ ។

"ឯកេ"តិ សេដ្ឋា, សព្ពសត្តសេដ្ឋា ច សម្មាសម្ពុទ្ធា, តស្មា ឯកាយនមត្តោតិ សម្មាសម្ពុទ្ធានំ អយនភូតោ មត្តោតិ វុត្តំ ហោតិ។

*ពាក្យថា "**ជាអ្នកឯក**" គឺលោកជាអ្នកប្រសើរបំផុត, លោកជាអ្នកប្រសើរបំផុតជាងសត្វទាំងពួង បានដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំងឡាយ, ព្រោះដូច្នោះ ទើបមានអធិប្បាយថា ពាក្យថា **ឯកាយនមត្ត** ប្រែថា ផ្លូវជាទីដំណើរទៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំងឡាយ ។*

អយតីតិ វា អយនោ, កច្ឆតិ បវត្តតីតិ អត្ថោ។

*ន័យម្យ៉ាងទៀត ឈ្មោះថា **អយនោ** ដោយអត្ថថាទៅ, បានសេចក្តីថា ទៅគឺការប្រព្រឹត្តិទៅ ។*

ឯកស្មឹ អយនោ មត្តោតិ ឯកាយនមត្តោ, ឯកស្មឹយេវ ពុទ្ធសាសនេ បវត្តមានោ មត្តោ, ន អញ្ញត្ថាតិ វុត្តំ ហោតិ។

មានអធិប្បាយថា ផ្លូវដែលទៅក្នុងធម៌ដែលជាឯក ព្រោះដូច្នោះ ទើបឈ្មោះថា ឯកាយនមគ្គ, បានដល់ ផ្លូវដែលប្រព្រឹត្តទៅនៅក្នុងព្រះពុទ្ធសាសនាតែមួយប៉ុណ្ណោះ, មិនប្រព្រឹត្តទៅនៅក្នុងសាសនាដទៃឡើយ ។

អបិ ច ឯកំ អយតីតិ ឯកាយនោ, បុព្ពភាគេ ជាតាមុខភាវជាន-យប្បវត្តោបិ អបរភាគេ ឯកំ និព្ពានមេវ កច្ឆតីតិ វុត្តំ ហោតិ, តស្មា ឯកាយនមត្តោតិ ឯកនិព្ពានគមនមត្តោតិ អត្ថោ។

*ន័យម្យ៉ាងទៀត ឈ្មោះថា **ឯកាយន** ដោយអត្ថថា ទៅកាន់ធម្មជាតិតែម្យ៉ាង, មានអធិប្បាយថា ផ្លូវដែលប្រព្រឹត្តទៅតាមន័យនៃការនាដែលមានមុខផ្សេងៗគ្នាក្នុងចំណែកខាងដើម រមែងទៅកាន់ព្រះនិព្វានតែម្យ៉ាងប៉ុណ្ណោះ*

នៅក្នុងចំណែកខាងក្រោយ, ព្រោះដូច្នោះពាក្យថា ឯកាយនមគ្គ ទើបមានសេចក្តីស្មើនឹងពាក្យថា ជាផ្លូវទៅកាន់ព្រះនិព្វានតែម្យ៉ាង ។

"ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ពុទ្ធោ"តិ ន បរេហិ ពុទ្ធត្តា ពុទ្ធោ, កឹ បន សយមេវ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធត្តា ពុទ្ធោតិ វុត្តំ ហោតិ។

*ពាក្យថា ព្រះដ៏មានព្រះភាគជាម្ចាស់ព្រះនាមថា "**ពុទ្ធ ដោយអត្ថថា ត្រាស់ដឹងសម្មាសម្ពោធិញាណដ៏ប្រសើរក្រៃលែងតែមួយ**" បានសេចក្តីថា ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះមិនបានត្រាស់ដឹងជាមួយបុគ្គលដទៃ, តើដូចម្តេច ? ឈ្មោះថា ពុទ្ធ ព្រោះត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញាណដោយព្រះអង្គឯងតែប៉ុណ្ណោះ ។*

"អពុទ្ធិវិហតត្តា ពុទ្ធិបដិលាភា ពុទ្ធោ"តិ ពុទ្ធិ ពុទ្ធំ ពោធោតិ បរិយាយវចនមេតំ។

*ពាក្យថា ទ្រង់ព្រះនាមថា "**ពុទ្ធ ព្រោះទ្រង់កំចាត់ចោលនូវភាពមិនមានបញ្ញាត្រាស់ដឹង**" អធិប្បាយថា ពាក្យថា ពុទ្ធិ ពុទ្ធំ ពោធោ នេះជាពាក្យបរិយាយ។*

តត្ថ យថា នីលវត្ថុណាយោគា "នីលោ បដោ រត្តោ បដោ"តិ វុច្ចតិ, ឯវំ ពុទ្ធគុណាយោគា ពុទ្ធោតិ ញាបេតុំ វុត្តំ។

ក្នុងពាក្យនោះ លោកពោលទុកដើម្បីនឹងឲ្យចូលចិត្តថា ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ព្រះនាមថា ពុទ្ធ ព្រោះទ្រង់ប្រកបដោយគុណ គឺការត្រាស់ដឹង ដូចជា "សំពត់ដែលហៅថាសំពត់ពណ៌ខៀវ សំពត់ពណ៌ក្រហម" ព្រោះប្រកបដោយគុណ គឺខៀវ និង ក្រហម ។

តតោ បរំ "ពុទ្ធោតិ ឯតំ ជាម"ន្តិអាទិ "អត្តមនុកតា អយំ បញ្ញត្តី"តិ ញាបនត្ថំ វុត្តំ។

*ជាខាងដើមប៉ុណ្ណោះ ពាក្យថា "**ពុទ្ធោតិ នេតំ ជាមំ** ប្រែថា **ព្រះនាមថា ពុទ្ធ នេះ មិនមែននរណាដឹង**" ដូច្នេះជាដើម លោកពោលទុកដើម្បីនឹងឲ្យចូលចិត្តថា "ព្រះបញ្ញត្តិនេះប្រព្រឹត្តទៅតាមអត្ថ" ។*

តត្ថ មិត្តា សហាយា។ **អមច្ចា** កច្ចា។ **ញាតី** បិតុបក្ខិកា។ **សាលោហិតា** មាតុបក្ខិកា។ **សមណា** បព្ពជ្ជូបគតា។

*ក្នុងបណ្តាពាក្យទាំងនោះ **មិត្ត** បានដល់ មិត្តសម្លាញ់ ។ **អាមាត្យ** បានដល់ អ្នកដែលព្រះរាជាទ្រង់ជួយទំនុកបម្រុង ។ **ញាតិ** បានដល់ មនុស្សដែលនៅខាងផ្នែកបិតា ។ **សាលោហិត** បានដល់ មនុស្សដែលនៅខាងផ្នែក មាតា ។ **សមណ** បានដល់មនុស្សដែលចូលដល់ការបព្វជ្ជា ។*

ព្រហ្មណា កោវាទិនោ, សមិតចាបពាហិតចាចា វា។ **ទេវតា** សក្កាទយោ ព្រហ្មានោ ច។ "**វិមោក្ខន្តិក**"ន្តិ វិមោក្ខោ អរហត្តមគ្គោ, វិមោក្ខស្ស អន្តោ អរហត្តផលំ, តស្មឹ វិមោក្ខន្តេ ភវំ វិមោក្ខន្តិកំ នាម។

ព្រហ្មណ *បានដល់ ពួកព្រាហ្មណ៍ដែលឈ្មោះថាកោវាទី (គឺពោលថាចម្រើនៗ), ឬពួកព្រាហ្មណ៍អ្នកមានបាបដែលស្ងប់ហើយ មានបាបបណ្តែតហើយ ។ **ទេវតា** បានដល់ពួកទេវតា ដែលមានសក្កទេវរាជ ជាដើម និងពួកព្រាហ្មណ៍ទាំងឡាយផង ។ ពាក្យថា "**មានទីបំផុតនៃវិមោក្ខ**" អធិប្បាយថា វិមោក្ខ បានដល់អរហត្តមគ្គ, ទីបំផុតនៃវិមោក្ខ បានដល់ អរហត្តផល, ព្រះនាមនេះមាននៅក្នុងទីបំផុតនៃវិមោក្ខនោះ ទើបឈ្មោះថា មានក្នុងទីបំផុតនៃវិមោក្ខ ។*

សព្វញ្ញុភាវោ ហិ អរហត្តមគ្គេន សិជ្ឈតិ, អរហត្តផលេនយេ សិទ្ធោ ហោតិ, តស្មា សព្វញ្ញុភាវោ វិមោក្ខន្តេ ភវោ ហោតិ។

មែនពិត ធម្មតាភាវជាព្រះសព្វញ្ញុ រមែងសម្រេចបានដោយអរហត្តមគ្គ, កាលអរហត្តផលលេចឡើងរមែងជាការសម្រេចហើយ, ព្រោះដូច្នោះ សព្វញ្ញុភាវ ទើបជាការដែលមាននៅក្នុងទីបំផុតនៃវិមោក្ខ ។

តំ នេមិត្តិកម្បិ នាមំ វិមោក្ខន្តេ ភវំ នាម ហោតិ។

សូម្បីនេមិត្តិកនាមនោះ ក៏ឈ្មោះថាមានទីបំផុតនៃវិមោក្ខ ។

តេន វុត្តំ – "វិមោក្ខន្តិកមេតំ ពុទ្ធានំ ភតវន្តាន"ន្តិ។

ព្រោះហេតុនោះ លោកទើបពោលថា "ពាក្យថា ពុទ្ធោនេះជាព្រះនាមដែលមានក្នុងទីបំផុតនៃវិមោក្ខ របស់ព្រះដ៏មានព្រះភាគជាម្ចាស់ទាំងឡាយ" ។

"**ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា**"តិ មហាពោធិរុក្ខមូលេ យថាវុត្តក្ខណេ សព្វញ្ញុតញ្ញាណស្ស បដិលាភេន សហ។

*ពាក្យថា "**ព្រមដោយការបានចំពោះនូវព្រះសព្វញ្ញុតញ្ញាណក្រោមមណ្ឌលមហាពោធិព្រឹក្ស**" បានសេចក្តីថា ព្រមជាមួយការបានចំពោះព្រះសព្វញ្ញុតញ្ញាណ ក្នុងខណៈដែលបានពោលមកហើយ ក្រោមមណ្ឌលមហាពោធិព្រឹក្ស ។*

"**សច្ឆិកា បញ្ញត្តី**"តិ អរហត្តផលសច្ឆិកិរិយាយ, សព្វធម្មសច្ឆិកិ-រិយាយ វា ជាតាបញ្ញត្តិ។

*ពាក្យថា "**សច្ឆិកា បញ្ញត្តិ**" គឺជាព្រះបញ្ញត្តិដែលកើតឡើងដោយការធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល, ឬដោយការធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងពួង ។*

"**យជិជំ ពុទ្ធោ**"តិ យា អយំ ពុទ្ធោតិ បញ្ញត្តិ, អយំ ព្យញ្ជនតោ ពុទ្ធវិភាវនា។

*ពាក្យថា "**ព្រះនាមថា ពុទ្ធោ នេះ**" បានសេចក្តីថា ព្រះបញ្ញត្តិថាពុទ្ធោនេះណា, ព្រះបញ្ញត្តិនេះជាការញ្ជាំងពុទ្ធឲ្យជាក់ច្បាស់ដោយព្យញ្ជនៈ ។*

"យថា ពុទ្ធេន ទេសិតា"តិកាថាចាទស្ស បន ឥមិនា បទភាជនីយេ វុត្តត្តេន អយំ សំសន្ទនា អានាចានស្ស្សតិយោ ច យថា ពុទ្ធេន ទេសិតា,

យេន បការេន ទេសិតា។

បាទគាថា ថា "យថា ពុទ្ធេន ទេសិតា" មានពាក្យប្រៀបធៀបជាមួយអត្ថដែលពោលទុកក្នុងបទភាជនីដូចតទៅនេះ ៖

អានាបានស្សតិ ព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងហើយដោយប្រការណា គឺទ្រង់ទេសនាហើយដោយប្រការនោះ ។

យថា- សទ្ធេន សទ្ធហិតា ឧស យថត្តា ច យថា ពុទ្ធេន ទេសិតា, យេន បការេន ទេសិតាតិ បការត្តស្ស ច យថាសទ្ធស្ស, សភាវត្តស្ស ច យថាសទ្ធស្ស ស្សបេកសេសវសេន ឯកសេសំ កត្វា "យថា"តិ វុត្តន្តិ វេទិតព្វំ។

ក៏អត្ថតាមសភាវ: ១០ ប្រការដែលសង្ត្រោះតាម យថា-សព្ទ ព្រះពុទ្ធជាម្ចាស់ទ្រង់សម្តែងហើយដោយប្រការណា, គឺទេសនាហើយដោយប្រការនោះ គប្បីជ្រាបថា បទថា "យថា" លោកពោលថា ធ្វើឲ្យទៅជាឯកសេស ដោយអំណាចសរូបេកសេសនៃ យថា-សព្ទ ដែលមានអត្ថថា ប្រការ, និងនៃ យថា-សព្ទ ដែលមានអត្ថថា សភាវ:ដោយប្រការដូច្នេះឯង ។

បទភាជនីយេ បនស្ស យថត្តេសុ ឯកេកស្ស យោជនាវសេន "ទេសិតោ"តិ ឯកវចនំ កតំ។

ចំណែកក្នុងបទភាជនីនៃពាក្យនោះ លោកធ្វើជាឯកវចន:ថា "ទេសិតោ" ដោយអំណាចការប្រកបដែលលះបទ ក្នុងអត្ថតាមសភាវ:ទាំងឡាយ ។

"សោតិ ភហជ្ជោ វា ហោតិ បព្វជិតោ វា"តិ វុត្តត្តា អាធិបទេបិ យស្ស ភហជ្ជស្ស វា បព្វជិតស្ស វាតិ វុត្តមេវ ហោតិ។ លោកត្តោ វុត្តោ យេវ។

ព្រោះបានពោលទុកមកហើយថា "បទថា សោ បានសេចក្តីថា នឹងជា

គ្រហស្តក្តី ឬថាជាបព្វជិតក្តី” ដូច្នេះ ទើបជាការពោលថា នៃគ្រហស្ត ឬនៃបព្វជិត ណា សូម្បីក្នុងអាទិបទនោះឯង។ អត្ថថាលោក ខ្ញុំម្ចាស់បានពោលទុកហើយនៅ គ្រាមួយ។

“បកាសេតី”តិ អត្តនោ ញាណស្ស ចាកដំ កភោតីតិ អត្ថោ។

*ពាក្យថា “**រមែងភ្លឺច្បាស់**” បានសេចក្តីថា រមែងធ្វើឲ្យប្រាកដនៃញាណ របស់ខ្លួន។*

“អភិសម្ពុទ្ធត្តា”តិ សាវកចារមិញ្ញាណេនបិ បដិវិទ្ធភាវេន។

*ពាក្យថា “**ព្រោះជាអ្នកព្រមចំពោះ**” គឺការដឹងព្រមចំពោះភាពជាអ្នក ចាក់ធ្លុះ សូម្បីសាវកបារមីញាណ។*

“ឱភាសេតី”តិ កាមាវចរភូតំ លោកំ។ **“ភាសេតី”តិ** រូបាវចរភូតំ លោកំ។ **“បភាសេតី”តិ** អរូបាវចរភូតំ លោកំ។

*ពាក្យថា “**រមែងឲ្យភ្លឺស្វាង**” គឺញុំងលោកដែលជាជាន់កាមាវចរឲ្យភ្លឺស្វាង ។ ពាក្យថា “**រមែងឲ្យភ្លឺ**” គឺរមែងញុំងលោកដែលជាជាន់រូបាវចរឲ្យភ្លឺ។ ពាក្យថា **រមែងឲ្យភ្លឺច្បាស់** គឺរមែងញុំងលោកដែលជាជាន់អរូបាវចរឲ្យភ្លឺច្បាស់។*

“អរិយញ្ញាណ”ន្តិ អរហត្តមគ្គញ្ញាណំ។ **“មហិកា មុត្តោ”តិ** មហិកាយ មុត្តោ។ **“មហិកា”តិ** ជីហាភោ វុច្ចតិ។ មហិយា មុត្តោតិបិ ចាហោ។

*បទថា **អរិយញ្ញាណំ** បានដល់ អរហត្តមគ្គញ្ញាណ។ បទថា **មហិកា មុត្តោ** ប្រែថា **ផុតហើយចាកអព្ភ**។ ទឹកសន្សើម ហៅថា **អព្ភ**។ បាលីមានបែបជា **មហិយា មុត្តោ** បែបនេះក៏មានដែរ។*

“ជូមរជា មុត្តោ”តិ ជូមតោ ច រជតោ ច មុត្តោ។ **“ភហុតហណា វិប្បមុត្តោ”តិ** ភហុតោ ចជ្ជស្ស អាសន្នុបត្ថិលេសត្តា ទ្វីហិ ឧបសគ្គេហិ

វិសេសេត្វា វុត្តំ។

*ទាំង ๒ បទពោលថា "**ជូមរជា មុត្តោ** ប្រែថា **ផុតហើយចាកផ្សែង និង ចាកធូលីដី**" ។ ទាំង ๒ បទពោលថា "**រាហុកមាណា វិប្បមុត្តោ** ប្រែថា **ផុតហើយចាកពីការចាប់របស់រាហូ**" លោកពោលឲ្យពិសេសថែមទៀតដោយឧបសគ្គៈមាន ๒ តួព្រោះរាហូជាឧបក្កិលេសនៅជិតព្រះចន្ទ ។*

ភាសតេ ឥតិ សឱភាសដ្ឋេន។ តបតេ ឥតិ សតេជដ្ឋេន។ វិរោចតេ ឥតិ រុចិរដ្ឋេន។

*ពាក្យថា **រមែងញុំាងលោកឲ្យភ្លឺ** លោកពោលដោយអត្ថថា មានពន្លឺភ្លឺស្វាង ។ ពាក្យថា **រមែងញុំាងលោកឲ្យស្រស់ប្រិមប្រិយ** លោកពោលដោយអត្ថថា មានតេជៈ។ បទថា **រមែងញុំាងលោកឲ្យរុងរឿង** លោកពោលដោយអត្ថថា ល្អឥតខ្ចោះ ។*

ឯវមេវន្តិ ឯវំ ឯវំ។ យស្មា បន ចន្ទោបិ សយំ ភាសន្តោ តបន្តោ វិរោចន្តោ ឥមំ ឱភាសលោកំ ឱភាសេតិ, កិក្ខុ ច បញ្ញាយ ភាសន្តោ តបន្តោ វិរោចន្តោ ឥមំ ខន្ធាធិលោកំ បញ្ញាយ ឱភាសេតិ, តស្មា ឧភយត្រាបិ "ភាសេតី"តិ អវត្វា "ភាសតេ" ឥច្ចេវ វុត្តំ។

*បទថា **ឯវមេវំ** កាត់បទជា **ឯវំ ឯវំ** ។ ក៏សូម្បីដួងព្រះចន្ទភ្លឺថ្លាស្រស់ប្រិមប្រិយភ្លឺស្វាងចែងចាំង រមែងញុំាងឱភាសលោកនេះឲ្យភ្លឺថ្លា, និងកិក្ខុកាលភ្លឺថ្លាស្រស់ប្រិមប្រិយចែងចាំងដោយបញ្ញា រមែងញុំាងលោកដែលមានខន្ធលោកជាដើមនេះឲ្យភ្លឺថ្លាដោយបញ្ញា, ដូច្នេះ លោកទើបមិនបានពោលថា "**ភាសេតិ**" សូម្បីទាំងពីរកន្លែង ពោលថា "**ភាសតេ**" ប៉ុណ្ណោះ ។*

ឯវញ្ហិ វុត្តេ ហេតុអត្ថោបិ វុត្តោ ហោតិ។

ក៏កាលលោកពោលយ៉ាងនេះ រមែងជាការដែលពោលសូម្បីអត្ថនៃហេតុ។

អតិវិសទតរាកស្សរិយោបមំ អត្តហេតូ កស្មា ចន្ទោបមា កថិតាតិ ចេ? សព្ពកិលេសបរិឌ្ឌាហរូបសមេន សន្តស្ស ភិក្ខុនោ សន្តគុណាយុត្តចន្ទោបមា អនុច្ឆវិកាតិ កថិតាតិ វេទិតព្ពំ។

ប្រសិនបើមានអ្នកសង្ស័យបានសួរថា លោកមិនបានកាន់យកឧបមាដោយព្រះអាទិត្យទេ ដែលមានរស្មីខ្លាំងក្លាជាង ហើយកាន់យកការឧបមាដោយដួងចន្ទ្រព្រោះហេតុអ្វី? ឆ្លើយថា គប្បីជ្រាបថា លោកកាន់យកការឧបមាដោយដួងចន្ទ្រដែលប្រកបដោយគុណដែលសូប់ថា សមគួរដល់ភិក្ខុអ្នកសូប់ ដោយការចូលទៅសូប់នូវភាពត្រៀក្រហាយ ព្រោះតែកិលេសទាំងពួង។

ឯវំ អានាចានស្សតិភាវនាសិទ្ធិសាធកំ យោគាវចរំ ថុនិត្វា "ឥមានិ តេវេស ភោនានេ ញាណានី"តិ តានិ ញាណានិ និគមេត្វា ឧស្សាតីតិ។

*លោកកាលលើកសរសើរព្រះយោគាវចរ អ្នកញុំាងការសម្រេចនៃអានាបានស្សតិភាវនា ឲ្យសម្រេចយ៉ាងនេះហើយ ទើបសម្តែងនូវញាណម្តងទៀតថា "**ញាណក្នុងវោទាន ទាំង១៣ យ៉ាងនេះ**" ដូច្នេះឯង។*

ភោនានញ្ញាណនិទ្ទេសវណ្ណនា និដ្ឋិតា។

ការពណ៌នាវោទានញ្ញាណនិទ្ទេស ចប់។

๕. សតោការិញ្ញាណនិទ្ទេសោ

ញ្ញាណលំដាប់ទី ๕ សតោការិញ្ញាណនិទ្ទេស (ចិដក๗๐) [๙๕]

(ញ្ញាណក្នុងការតម្កល់សតិឲ្យបានល្អមាន ๓๒ ញាណ)

(មាន๔ ចតុក្ក:គុណនិង ๔ ញាណ ស្មើ ๑๖ ហើយ๑๖នេះឯង គុណជាមួយខ្យល់២ គឺចូល ចេញ ស្មើ ๓๒ ញាណ) ។

[๑๖๓] **កតមានិ ពាត្តឹស សតោការិស្ស ញាណានិ?**

តើសតោការិញ្ញាណ គឺការធ្វើនូវសតិឲ្យរឹងមាំមាន ๓๒ ដូចម្តេច?

ឥធ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា

ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ទៅកាន់គល់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី រួចហើយអង្គុយពែនភ្នែន

ឧជុំ កាយំ បណិធាយ

តាំងកាយឲ្យត្រង់

បរិមុខំ សតឹ ឧបដ្ឋបេត្វា។

តាំងសតិស្មារតី ឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ។

សោ សតោវ អស្សសតិ, សតោ បស្សសតិ។

ព្រះយោគីភិក្ខុនោះ មានសតិស្មារតី ដកដង្ហើមចូល , មានសតិស្មារតី ដកដង្ហើមចេញ ។

ចតុក្ក ទី ១ ពួកកាយ

๑. ទីឃំ វា អស្សសន្តោ "ទីឃំ អស្សសាមី"តិ បជានាតិ។

ភិក្ខុនោះ កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា "អាត្មាអញដកដង្ហើមចូលវែង" ។

๒. ទីឃំ វា បស្សសន្តោ "ទីឃំ បស្សសាមី"តិ បជានាតិ។

ភិក្ខុនោះកាលដកដង្ហើមចេញវែងក៏ដឹងច្បាស់ថា "អាត្មាអញដកដង្ហើមចេញវែង" ។

๓. រស្សំ វា អស្សសន្តោ "រស្សំ អស្សសាមី"តិ បជានាតិ។

ភិក្ខុនោះ កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា "អាត្មាអញដកដង្ហើមចូលខ្លី" ។

๔. រស្សំ វា បស្សសន្តោ "រស្សំ បស្សសាមី"តិ បជានាតិ។

ភិក្ខុនោះ កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា "អាត្មាអញដកដង្ហើមចេញខ្លី" ។

๕. "សព្ពកាយប្បដិសំវេទី អស្សសិស្សាមី"តិ សិក្ខតិ។

ភិក្ខុសិក្សាថា "អាត្មាអញ កំណត់ដឹងឲ្យច្បាស់ នូវកាយ គឺខ្យល់ដង្ហើមទាំងអស់ ជាចំណែកៗ ដោយល្អ ក្នុងខណៈដកដង្ហើមចូល" ។

๖. "សព្ពកាយប្បដិសំវេទី បស្សសិស្សាមី"តិ សិក្ខតិ។

ភិក្ខុសិក្សាថា "អាត្មាអញ កំណត់ដឹងឲ្យច្បាស់ នូវកាយ គឺខ្យល់ដង្ហើមទាំងអស់ ជាចំណែកៗ ដោយល្អ ក្នុងខណៈដកដង្ហើមចេញ" ។

๗. "បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមី"តិ សិក្ខតិ។

សិក្សាថា "អាត្មាអញ ធ្វើកាយសង្ខារ គឺខ្យល់ដង្ហើម (ដែលគ្រោតគ្រាត)

ឲ្យរលត់បាត់ ក្នុងខណៈដកដង្ហើមចូល" ។

๘. **"បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមី"តិ សិក្ខតិ។**

សិក្សាថា "អាត្មាអញ ធ្វើកាយសង្ខារ គឺខ្យល់ដង្ហើម(ដែលគ្រោតគ្រាត)ឲ្យ រលត់បាត់ ក្នុងខណៈដកដង្ហើមចេញ" ។

ចតុក្ក ទី ๒ ពួកវេទនា

๙. **បីតិប្បដិសំវេទី។...បេ....។**

សិក្សាថា អាត្មាអញដឹងច្បាស់នូវបីតិ ខណៈដកដង្ហើមចូល ។...ល...។

๑๑. **សុខប្បដិសំវេទី...**

សិក្សាថា អាត្មាអញដឹងច្បាស់នូវសុខ ខណៈដកដង្ហើមចូល...

๑๓. **ចិត្តសង្ខារប្បដិសំវេទី ...**

សិក្សាថា អាត្មាអញដឹងច្បាស់នូវចិត្តសង្ខារ (គឺវេទនាខន្ធ និងសញ្ញាខន្ធ) ខណៈដកដង្ហើមចូល...

๑๔. **បស្សម្ភយំ ចិត្តសង្ខារំ...។**

សិក្សាថា "អាត្មាអញរលត់សូប់នូវចិត្តសង្ខារ (ដែលគ្រោតគ្រាត) ខណៈ ដកដង្ហើមចូល...។

ចតុក្ក ទី ๓ ពួកចិត្ត

๑๗. **ចិត្តបដិសំវេទី...**

សិក្សាថា អាត្មាអញដឹងច្បាស់នូវចិត្ត ខណៈដកដង្ហើមចូល...

๑๙. **អភិប្បមោទយំ ចិត្តំ...**

រមែងសិក្សាថា អាត្មាអញធ្វើចិត្តឲ្យរីករាយ ខណៈដកដង្ហើមចូល...

២១. សមាទហំ ចិត្តំ...

រមែងសិក្សាថា អាត្មាអញតម្កល់ចិត្តឲ្យស្មើ (នៅក្នុងអារម្មណ៍) ខណៈដកដង្ហើមចូល...

២៣. វិមោចយំ ចិត្តំ...។

រមែងសិក្សាថា អាត្មាអញធ្វើចិត្តឲ្យរួចចាកពីនីវរណធម៌ ជាដើម ខណៈដកដង្ហើមចូល...។

ចតុក្ក ទី ៤ ពួកធម៌

២៥. អនិច្ចានុបស្សី...

រមែងសិក្សាថា អាត្មាអញឃើញរឿយៗ នូវបញ្ចក្ខន្ធថាមិនទៀង ខណៈដកដង្ហើមចូល...

២៧. វិរាគានុបស្សី...

សិក្សាថា អាត្មាអញឃើញរឿយៗ នូវធម៌ជាគ្រឿងធ្វើចិត្តឲ្យប្រាសចាកតម្រេក គឺវិបស្សនា និងមគ្គ ខណៈដកដង្ហើមចូល...

២៩. និរោធានុបស្សី...

សិក្សាថា អាត្មាអញឃើញរឿយៗ នូវសេចក្តីរលត់នៃកងទុក្ខ ខណៈដកដង្ហើមចូល

៣១. "បដិនិស្សគ្គានុបស្សី អស្សសិស្សាមី"តិ សិក្ខតិ។

សិក្សាថា អាត្មាអញឃើញរឿយៗ នូវធម៌ជាគ្រឿងរលាស់ចិត្តចេញចាកពីកិលេស (ព្រមទាំងខន្ធ និងអភិសង្ខារ បានដល់វិបស្សនា និងមគ្គ) ខណៈដកដង្ហើមចូល...

៣២. "បដិនិស្សគ្គានុបស្សី បស្សសិស្សាមី"តិ សិក្ខតិ។

សិក្សាថា អាត្មាអញឃើញរឿយៗ នូវធម៌ជាគ្រឿងរលាស់ចិត្តចេញចាកពីកិលេស (ព្រមទាំងខន្ធ និងអភិសង្ខារ បានដល់វិបស្សនា និងមគ្គ) ខណៈដកដង្ហើមចេញ...។

๕. សតោការិញ្ញាណនិទ្ទេសវណ្ណនា

ការពណ៌នាក្នុងសតោការីនិទ្ទេស (អដ្ឋកថា)

(ញាណក្នុងការតម្កល់សតិ)

[๑๖๓] **សតោការិញ្ញាណនិទ្ទេសេ មាតិកាយំ "๙๘ ភិក្ខូ"តិ ឥមស្មឹ សាសនេ ភិក្ខុ។**

គប្បីជ្រាបវិនិច្ឆ័យក្នុង **សតោការីញ្ញាណនិទ្ទេស** *(ញាណក្នុងការតម្កល់សតិ) ដូចតទៅនេះ ក្នុងមាតិកាត្រង់បទថា "***๙๘ ភិក្ខុ** *ដែលប្រែថា* ***ភិក្ខុក្នុងព្រះសាសនានេះ"*** *។*

អយញ្ហិ ឯត្ថ ๙๘-សទ្ទោ សព្ពប្បការអានាចានស្សតិសមាធិនិព្វត្តកស្ស បុគ្គលស្ស សន្ទិស្សយភូតសាសនបរិទីបនោ, អញ្ញសាសនស្ស តថាការបដិសេធនោ ច។

ពិតមែន ***๙๘-សទ្ទ*** *ក្នុងភាសាបាលី កំណត់សម្តែងព្រះសាសនាដែលជាទីអាស្រ័យរបស់បុគ្គលអ្នកញ៉ាំងអានាបានស្សតិសមាធិ ដែលមានប្រការទាំងអស់ឲ្យកើតឡើង, និងបដិសេធការៈយ៉ាងនោះ នៃសាសនាដទៃ ។*

វុត្តញ្ហេតំ – "ឥធេវ, ភិក្ខវេ, សមណោ។...បេ....។ សុញ្ញា បរប្បវាទា

សមណោតិ អញ្ញោហី"តិ[៣៥]។

ត្រង់សេចក្តីនេះ សមតាមព្រះបាលីដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់បានត្រាស់សម្តែងទុកយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ សមណៈ មានក្នុងសាសនានេះប៉ុណ្ណោះឯង។...ល...។ លទ្ធិដទៃសោះសូន្យចាកសមណៈទាំងឡាយនេះ និងទទេគ្មានអ្វីចាកសមណៈ(អ្នកតាំងនៅក្នុងមគ្គវិបស្សនា ដើម្បីបានមគ្គ)យ៉ាងដទៃ" ដូច្នេះ។

"អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា"តិ ឥមស្ស អានាចានស្សតិសមាធិ ភាវនានុរូបសេនាសនបរិគ្គហបរិទីបនំ។

*ពាក្យថា "**ទៅក្នុងព្រៃក្តី ទៅទៀបគល់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី**" នេះជាពាក្យសម្តែងការកំណត់កាន់យកសេនាសនៈដែលសមគួរដល់ការចម្រើននូវអានាបានស្សតិសមាធិ របស់ព្រះយោគីភិក្ខុនោះ។*

ឥមស្ស ហិ ភិក្ខុនោ ឋិយរត្តំ រូបាទីសុ អារម្មណេសុ អនុវិសដំ ចិត្តំ អានាចានស្សតិសមាធិអារម្មណំ អភិរុហិតុំ ន ឥច្ឆតិ, កូដគោណា-យុត្តរថោ វិយ ឧប្បថមេវ ធាវតិ។

ព្រោះថា ចិត្តរបស់ភិក្ខុនេះ ដែលខ្ចាត់ខ្ចាយទៅតាមអារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើម អស់កាលជាយូរមកហើយ មិនប្រាថ្នា ដើម្បីឡើងកាន់អារម្មណ៍ របស់អានាបានស្សតិសមាធិ រមែងគេចចេញទៅកាន់ផ្លូវខុសតែម្យ៉ាង, ប្រៀបដូចជារថដែលគេទឹមហើយដោយគោកៀច(គឺគោខូច)។

តស្មា សេយ្យថាបិ នាម គោចោ កូដជេតុយា សព្ពំ ទីរំ បរិត្វា វឌ្ឍិតំ កូដវច្ឆំ ឧមេតុកាមោ ជេតុនោ អបនេត្វា ឯកមន្តេ មហន្តំ ថម្ភំ និខណិត្វា តត្ត យោត្តេន ពន្ធេយ្យ, អថស្ស សោ វច្ឆោ ឥតោ ចិតោ ច វិប្ផន្ទិត្វា បលាយិតុំ អសក្កោន្តោ តមេវ ថម្ភំ ឧបនិសីទេយ្យ វា ឧបនិប-

---

៣៥ (ម. និ. ១.១៣៩; អ. និ. ៤.២៤១)។

ផ្ជេយ្យ វា,

ព្រោះហេតុនោះ មានការឧបមា ប្រៀបដូចនាយគោបាល កាលប្រាថ្នានឹងបង្វឹក (គឺការបង្ត្រៀប) កូនគោកៀច ដែលបានធំធាត់ឡើង ដោយសារបៅដោះមេគោហើយសមគួរក្នុងការបំបែកចេញអំពីមេគោ ដោយដាំនូវសសរបង្គោលដ៏ធំ ទុកក្នុងទីដ៏សមគួរមួយកន្ទែង ហើយយកខ្សែចងត្រង់សសរនោះ, កាលបើមានប្រការដូច្នោះ កូនគោ របស់នាយគោបាលនោះ ក៏មិនអាចដើម្បីនឹងរើបង្រះ ទៅខាងនេះផង ទៅខាងនោះផង ដើម្បីនឹងរត់គេចចេញបានឡើយ គប្បីឈរជ្រប់ ឬ ដេកជ្រប់នៅត្រង់សសរធំនោះឯង មានការឧបមាយ៉ាងណាមិញ,

ឯវមេវ ឥមិនាបិ ភិក្ខុនា ជីយរត្តំ រូចារម្មណាជិរសចានវឌ្ឍិតំ ជុដ្ឋចិត្តំ ជមេតុកាមេន រូចាជិអារម្មណតោ អបនេត្វា អរញ្ញំ វា រុក្ខមូលំ វា សុញ្ញាគារំ វា បវេសេត្វា តត្ត អស្សាសបស្សាសថម្ភេ សតិយោត្តេន ពន្ធិតព្វំ។

សូម្បីភិក្ខុនោះឯង ប្រាថ្នាដើម្បីនឹងទូន្មានចិត្តដ៏កាច ដែលចម្រើន ហើយដោយការផឹកនូវរសនៃអារម្មណ៍ មានរូបារម្មណ៍ជាដើម អស់កាលនៃរាត្រីដ៏វែង ក៏គប្បីនាំចេញអំពីអារម្មណ៍មានរូបារម្មណ៍ជាដើម ហើយចូលទៅក្នុងព្រៃក្តី ទៅទៀបគល់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី ហើយចងទុកដោយខ្សែ គឺសតិនៅត្រង់សសរ គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ក្នុងស្ថានទីនោះឯង ។

ឯវមស្ស តំ ចិត្តំ ឥតោ ចិតោ ច វិប្ជន្ទិត្វាបិ បុព្វេ អាចិណ្ណារម្មណំ អលភមានំ សតិយោត្តំ ឆិន្ទិត្វា បលាយិតុំ អសក្កោន្តំ តមេវារម្មណំ ឧបចារប្បនាវសេន ឧបនិសីជតិ ចេវ ឧបនិបជ្ជតិ ច។

កាលបើចងបានដូច្នោះ ចិត្តរបស់ភិក្ខុនោះ សូម្បីស្ទុះទៅខាងនេះផង ខាងនោះផង ក៏មិនបាននូវអារម្មណ៍ដែលខ្ជូនសន្សំមកហើយក្នុងកាលអតីត មិនអាច

ដើម្បីនឹងកាត់ផ្តាច់ខ្សែ គឺសតិ ហើយរត់គេចបានឡើយ ហើយក៏រមែងចូលទៅអែបនៅជាប់ និងនៅដោយជិតស្និទ្ធនឹងអារម្មណ៍កម្មដ្ឋាននោះឯងដោយអំណាចនៃឧបចារនិងអប្បនាក៏មានការឧបមេយ្យ យ៉ាងនេះឯង ។

តេនាហុ ចោរាណា –

ព្រោះហេតុនោះ ទើបលោកបោរាណាចារ្យទាំងឡាយ លោកពោលទុកថា ៖

"យថា ថម្ភេ និពន្ធេយ្យ, វច្ឆំ ឧមំ ឧភោ ឥធ;

ពន្ធេយ្យេវំ សកំ ចិត្តំ, សតិយារម្មណេ ឧជ្ជុ"ន្តិ[៣៦]។

"នរៈជន ក្នុងលោកនេះ កាលនឹងបង្ហាត់នូវកូនគោ គប្បីចង(កូនគោ)ទុកត្រង់សសរ យ៉ាងណាមិញ ព្រះយោគាវចរក្នុងព្រះសាសនានេះ គប្បីចងនូវចិត្តរបស់ខ្លួន ឲ្យបានមាំក្នុងអារម្មណ៍ ដោយសតិ ក៏យ៉ាងដូច្នោះដែរ" ។

ឯវមស្ស តំ សេនាសនំ ការណារុឡ្ហំ ហោតិ។

សេនាសនៈនោះ ជាទីសេនាសនៈដ៏សមគួរដល់ការភាវនា សម្រាប់ព្រះយោគីនោះ យ៉ាងនេះឯង ។

អរញ្ញគតោ វា ។បេ។ សុញ្ញាគារគតោ វា តាមន័យទី ២

អថ វា យស្មា ឥទំ កម្មដ្ឋានប្បភេទេ មុទ្ធភូតំ សព្ពពុទ្ធបច្ចេកពុទ្ធពុទ្ធសាវកានំ វិសេសាធិគមទិដ្ឋធម្មសុខវិហារបទដ្ឋានំ អាជាចានសប្បតិកម្មដ្ឋានំ ឥត្តិបុរិសហត្ថិអស្សាទិសទ្ធសមាកុលំ តាមត្តំ អបរិច្ចជិត្វា ន សុករំ ការេតុំ សទ្ធកណ្ដាកតា ឈានសប្ប។

នយមួយទៀត ព្រោះការដែលយោគាវចរ មិនលះបង់នូវសេនាសនៈ

---

៣៦ (វិសុទ្ធិ. ១.២១៧; បារា. អដ្ឋ. ២.១៦៥; ទី. និ. អដ្ឋ. ២.៣៧៤; ម. និ. អដ្ឋ. ១.១០៧) ។

ទីបំផុតនៃស្រុក ដែលរឹតវាវដោយសំឡេងរបស់ស្ត្រី បុរស ដំរី និងសេះ ជាដើម ហើយចម្រើននូវអានាបានស្សតិកម្មដ្ឋាននេះ ដែលជាកម្មដ្ឋានដ៏កំពូល ក្នុងប្រភេទនៃកម្មដ្ឋាន ជាបទដ្ឋាននៃការបន្ទុះនូវគុណវិសេស និងជាកិរិយានៅក្នុងទិដ្ឋធម្មសុខវិហារ(សុខក្នុងបច្ចុប្បន្ន) របស់ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធ និងសាវ័ករបស់ព្រះពុទ្ធគ្រប់ៗព្រះអង្គ មិនមែនជាកិច្ចដែលបុគ្គលធ្វើបានដោយងាយនោះទេ, ព្រោះភាពនៃឈាន មានសំឡេងជាបន្ទា ។

អតាមកេ បន អរញ្ញេ សុករំ យោគាវចរេន ឥទំ កម្មដ្ឋានំ បរិត្តហេតូ អាជាចានចតុក្កជ្ឈានំ និព្វត្តេត្វា តទេវ ចាឧកំ កត្វា សង្ខារេ សម្មសិត្វា អគ្គផលំ អរហត្តំ ចាបុណិតុំ។

តែថាក្នុងទីមិនមែនជាស្រុក គឺក្នុងព្រៃ ព្រះយោគាវចរ ធ្វើបានដោយងាយ ដើម្បីកាន់យកនូវកម្មដ្ឋាននេះ ហើយញុំាងអានាបាន ជាអារម្មណ៍ឲ្យកើតឡើង ហើយធ្វើឈានទាំង ៤ ដែលមានអានាបានជាអារម្មណ៍នោះឯង ឲ្យជាបាត ហើយពិចារណានូវសង្ខារទាំងឡាយ បានបន្ទុះនូវព្រះអរហត្ត ដែលជាផលដ៏កំពូល ។

តស្មា តស្ស អត្ថរូបំ សេជាសនំ ឧបនិសន្តោ ភគវា "អរញ្ញគតោ វា"តិអាទិមាហ, តថេវ ថេរោ។

*ព្រោះហេតុនោះ ព្រះមានព្រះភាគកាលទ្រង់ចង្អុលបង្ហាញនូវសេនាសនៈដ៏សមគួរ ដល់ព្រះយោគាវចរនោះ ទើបទ្រង់ត្រាស់ថា "**អរញ្ញគតោ វា** ប្រែថាទៅកាន់ព្រៃក្តី "ដូច្នេះជាដើម, ព្រះថេរៈក៏បានពោលយ៉ាងនោះដូចគ្នា ។*

អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា តាមន័យទី ៣

វត្តុវិជ្ជាចរិយោ វិយ ហិ ភគវា, សោ យថា វត្តុវិជ្ជាចរិយោ ឧតរភូមឹ បស្សិត្វា សុដ្ឋុ ឧបបរិក្ខិត្វា "ឯត្ថ ឧតរំ មាបេថា"តិ ឧបទិសតិ, សោត្តិជា ច ឧតរេ និដ្ឋិតេ រាជកុលតោ មហាសក្ការំ លភតិ, ឯវមេវំ យោគាវចរស្ស អនុរូបំ សេនាសនំ ឧបបរិក្ខិត្វា "ឯត្ថ កម្មដ្ឋានំ អនុយុញ្ជិតព្ព"ន្តិ ឧបទិសតិ, តតោ តត្ថ កម្មដ្ឋានមនុយុត្តេន យោគិនា ភគវតេ អរហតេ បតេ "សម្មាសម្ពុទ្ធោវត សោ ភគវា"តិ មហន្តំ សក្ការំ លភតិ ។

ពិតមែន ព្រះមានព្រះភាគ ប្រៀបដូចជាអាចារ្យ អ្នកចេះធ្លាតឈ្លាសក្នុងវិជ្ជាមើលនូវភូមិសាស្ត្រ, អាចារ្យអ្នកចេះនូវភូមិសាស្ត្រនោះ ឃើញនូវទីនៃនគរ ហើយពិចារណាដោយប្រពៃទើបចង្អុលប្រាប់ថា "ចូរអ្នកទាំងឡាយកសាងនូវនគរក្នុងទីនេះ" ដូច្នេះ, លុះដល់នគរបានសម្រេចដោយសួស្តីហើយ ក៏បាននូវសក្ការៈដ៏ច្រើន អំពីរាជត្រកូល ការឧបមា យ៉ាងណាមិញ, ព្រះមានព្រះភាគអង្គនោះ ទ្រង់ពិចារណានូវទីសេនាសនៈដ៏សមគួរ ដល់ព្រះយោគាវចរ ហើយទ្រង់ចង្អុលប្រាប់ថា "ព្រះយោគី គប្បីប្រកបកម្មដ្ឋានរឿយៗ ក្នុងទីសេនាសនៈនេះ" ដូច្នេះ, តអំពីនោះទៅ កាលព្រះអរហត្តផល ដែលព្រះយោគីអ្នកប្រកបកម្មដ្ឋានរឿយៗ ក្នុងទីនោះ បានសម្រេចហើយទៅតាមលំដាប់ រមែងទ្រង់បាននូវសក្ការៈដ៏ច្រើនថា "ព្រះមានព្រះភាគអង្គនោះ ជាព្រះសម្មាសម្ពុទ្ធ យ៉ាងពិតប្រាកដមែន" ការឧបមេយ្យ ក៏យ៉ាងដូច្នោះដែរ ។

អយំ បន ភិក្ខុ "ឥមិនាបិ សទិសោ"តិ វុច្ចតិ។

ចំណែក ភិក្ខុនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា "ប្រាកដស្មើដោយខ្លាដំបង"។

យថា ហិ មហាឥមិរាជា អរញ្ញេ តិណគហនំ វា វនគហនំ វា បព្ភតគហនំ វា និស្សាយ និលីយិត្វា វនមហិំសគោកណ្ណសូករាទយោ

មិកេ កណ្ហាតិ, ឯវមេវំ អយំ អរញ្ញាឌីសុ កម្មដ្ឋានមនុយុញ្ជន្តោ ភិក្ខុ យថាក្កមេន សោតាបត្តិសកទាគាមិអនាគាមិអរហត្តមត្តេ ចេវ អរិយផលានិ ច កណ្ហាតីតិ វេទិតព្ពោ ។

បណ្ឌិតគប្បីជ្រាបនូវសេចក្តីអធិប្បាយថា "ដូចជាស្តេចខ្វាដំបងដ៏ធំ ពួនសំងំ អែបនៅជិតស្បាតស្មៅក្តី ស្បាតព្រៃក្តី ស្បាតភ្នំក្តី ក្នុងព្រៃក្តី ហើយចាំចាប់ពួកសត្វម្រឹគទាំងឡាយ មានក្របីព្រៃ រមាំង និងជ្រូកព្រៃជាដើម យ៉ាងណាមិញ, ភិក្ខុ អ្នកប្រកបនូវកម្មដ្ឋានរឿយៗ ក្នុងទីសេនាសនៈដ៏សមគួរទាំងឡាយ ដែលមានព្រៃជាដើមនេះ រមែងចាប់យកនូវសោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ និង អរហត្តមគ្គផង និង នូវអរិយផលផង តាមសមគួរទៅតាមលំដាប់ យ៉ាងដូច្នេះដែរ ។

តេនាហុ ចោរាណា –

ព្រោះហេតុនោះ បោរាណាចារ្យទាំងឡាយ លោកបានពោលទុកថា

"យថាបិ ឌីបិកោ នាម, និលីយិត្វា កណ្ហាតេ មិកេ;
តថេវាយំ ពុទ្ធបុត្តោ, យុត្តយោគោ វិបស្សកោ;
អរញ្ញេ បវិសិត្វាន, កណ្ហាតិ ផលមុត្តម"ន្តិ[๓๗] ។

"ធម្មតាខ្វាដំបង ពួនសម្ងំហើយ រមែងចាំចាប់យកនូវម្រឹគទាំងឡាយ យ៉ាងណាមិញ, ភិក្ខុនេះ ជាបុត្ររបស់ព្រះពុទ្ធ ជាអ្នកមានសេចក្តីព្យាយាមប្រកបហើយ ជាអ្នកចម្រើនវិបស្សនា ចូលទៅកាន់ព្រៃហើយ តែងចាំចាប់យកនូវផលដ៏ឧត្តម ក៏យ៉ាងដូច្នោះដែរ" ដូច្នេះ ។

តេនស្ស បរក្កមជវយោគ្គភូមឹ អរញ្ញសេនាសនំ ឧស្សន្នោ "អរញ្ញកតោ វា"តិអាឌិមាហ។

---

๓๗ (មិ. ប. ๖.๑.๕) ។

ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងនូវទីសេនាសន:ក្នុងព្រៃ ដែលជាកន្លែងប្រកបសេចក្តីព្យាយាម នៃបុគ្គលអ្នកមានសេចក្តីព្យាយាម និងអ្នកមានសេចក្តីសុះស្ងា ដល់ព្រះយោគីភិក្ខុនោះ ទើបទ្រង់ត្រាស់សម្តែងថា "**អរញ្ញកតោ វា**" ដូច្នេះជាដើម ។

តត្ថ "អរញ្ញកតោ"តិ ឧបរិ វុត្តលក្ខណំ យំកិញ្ចិ បវិវេកសុខំ អរញ្ញកតោ។

ក្នុងបណ្តាបទទាំងនោះ បទថា "**អរញ្ញកតោ**" បានសេចក្តីថា ភិក្ខុ***ទៅកាន់ព្រៃ***ណាមួយ ដែលមានសេចក្តីសុខ កើតអំពីវិវេក បណ្តាព្រៃទាំងឡាយមានលក្ខណ:ដែលបានពោលមកហើយ ។

"រុក្ខមូលកតោ"តិ រុក្ខសមីបំ កតោ។

បទថា "**រុក្ខមូលកតោ**" ប្រែថា ភិក្ខុទៅកាន់ទីជិតនៃគល់ឈើ ។

"សុញ្ញាគារកតោ"តិ សុញ្ញំ វិវិត្តោកាសំ កតោ។

បទថា "**សុញ្ញាគារកតោ** ប្រែថា ***ទៅកាន់ផ្ទះស្ងាត់*** គឺទីកន្លែងដែលស្ងាត់ ។

ឯត្ថ ច បឋមេន អរញ្ញញ្ច រុក្ខមូលញ្ច អវសេសសត្តវិធសេនាសនំ កតោបិ "សុញ្ញាគារកតោ"តិ វត្តុំ វដ្ដតិ។

ក្នុងទីនេះ លើកទុកនូវព្រៃ និងគល់ឈើចេញ ភិក្ខុសូម្បីទៅកាន់ទីសេនាសន:ដ៏សេស មាន ៧ ប្រការ ក៏គួរពោលថាជា "**សុញ្ញាគារកតោ**" បានដូចគ្នា ។

ន វិវិត្តញ្ហិ សេនាសនំ។

ពិតមែន សេនាសន:មាន ៩ ប្រការ ។

យថាហ – "សោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ

កច្ឆវំ តិរិកុមាំ សុសានំ វនបត្តំ អព្ភោកាសំ បលាលបុញ្ជ”ន្តិ[๓๘] ។

ដូចដែលព្រះអង្គត្រាស់សម្តែងទុកថា “ភិក្ខុនោះ រមែងសេព នូវសេនាសនៈដែលស្ងាត់ គឺព្រៃ ជិតគល់ឈើ ភ្នំ ញកភ្នំ ល្អាងក្នុងភ្នំ ប៉ាឆា(កន្លែងដុតខ្មោច) ព្រៃក្រាស់ កណ្តាលវាល ពំនូកចំបើង” ដូច្នេះ ។

ឯវមស្ស ឧតុត្តយានុកូលំ ជាតុចរិយានុកូលញ្ច អានាចានសប្បតិការជានុរូបំ សេនាសនំ ឧបនិសិន្នា អលីនានុទ្ធច្ចបក្ខិកំ សន្តមិរិយាបថំ ឧបនិសន្តោ “ឯសីឧតី”តិ អាហ។

*ព្រះមានព្រះភាគ កាលទ្រង់ចង្អុលបង្ហាញប្រាប់នូវទីសេនាសនៈដ៏សមគួរដល់ការចម្រើននូវអានាបានស្សតិ ដែលសមគួរដល់រដូវទាំង ៣ ផង សមគួរដល់ធាតុផង និងចរិតរបស់ព្រះយោគីនោះផង យ៉ាងនេះហើយ ទ្រង់សម្តែងប្រាប់នូវឥរិយាបថ ដ៏សប់ ដែលប្រព្រឹត្តទៅក្នុងក្រុមពួក នៃការមិនរួញរា និងការមិនអណ្តែតអណ្តូង ដល់ព្រះយោគាវចរនោះ ទើបទ្រង់ត្រាស់ថា “**ឯសីឧតិ ការអង្គុយ**” ដូច្នេះ ។*

អថស្ស និសជ្ជាយ ឧជ្ជុការំ អស្សាសបស្សាសានំ បវត្តនសមត្តតំ អារម្មណាបរិគ្គហូចាយញ្ច ឧស្សេន្តោ “បល្លង្កំ អាភុជិត្វា”តិអាទិមាហ។

*ក្នុងលំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែង នូវភាពនៃការអង្គុយ នឹងធឹងតាំងមាំផង នូវភាពនៃការប្រព្រឹត្តទៅស្រួល របស់ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ និងនូវឧបាយជាគ្រឿងកំណត់ នូវអារម្មណ៍របស់ព្រះយោគាវចរផង ទើបទ្រង់ត្រាស់សម្តែងថា “**បល្លង្កំ អាភុជិត្វា** ប្រែថា **ពែនភ្នែន**” ដូច្នេះជាដើម ។*

តត្ថ “បល្លង្ក”ន្តិ សមន្តតោ ឱរុពន្ធាសនំ។

*បណ្តាបទទាំងនោះ បទថា “**បល្លង្កំ**” បានដល់ ការអង្គុយបត់នូវភ្លៅ*

---

๓๘ (វិភ. ๕๐๘) ។

ដោយជុំវិញ ។

"អាភុជិត្វា"តិ ពន្ធិត្វា។

*បទថា "**អាភុជិត្វា**" គឺបត់ហើយ ។*

"ឧជុំ កាយំ បណិធាយា"តិ ឧបរិមសរីរំ ឧជុកំ បវេត្វា អដ្ឋារស បិដ្ឋិកណ្ដកេ កោដិយា កោដិបដិបាទេត្វា។

*ច្រើនបទថា "**ឧជុំ កាយំ បណិធាយ** ប្រែថា ***ការតាំងកាយឲ្យត្រង់***" សេចក្តីថា ការតាំងសរីរៈផ្នែកខាងលើឲ្យត្រង់ ញាំងចុង ដោយចុង ឲ្យរៀបរយ ត្រង់ទ្រនុងនៃឆ្អឹងខ្នង ១៨ កង ។*

ឯវញ្ហិ និសិន្នស្ស ឧម្មមំសញ្ហារូនិ ន បណាមន្តិ។

ព្រោះថា កាលព្រះយោគី អង្គុយយ៉ាងនេះហើយ ចំណែកស្បែក សាច់ និងសរសៃទាំងឡាយ នឹងមិនព្រួយតបុះ ។

អថស្ស យា តេសំ បណាមនបច្ចយា ខណេ ខណេ វេទនា ឧប្បជ្ជេយ្យុំ, តា ន ឧប្បជ្ជន្តិ។

លំដាប់នោះ វេទនាទាំងឡាយណា គប្បីនឹងកើតឡើង រាល់ៗខណៈ ព្រោះតែការព្រួយតបុះ នៃស្បែក សាច់ និងសរសៃទាំងឡាយនោះជាបច្ច័យ, វេទនាទាំងឡាយនោះ រមែងមិនកើតឡើងដល់យោគីកិក្ខុនោះឡើយ ។

តាសុ អនុប្បជ្ជមានាសុ ចិត្តំ ឯកគ្គំ ហោតិ, កម្មដ្ឋានំ ន បរិហាយតិ, វុទ្ធិ ជាតិ ឧបកច្ឆតិ។

កាលបើវេទនាទាំងឡាយនោះ មិនកើតឡើង ចិត្ត រមែងជាធម្មជាតតែមួយ, កម្មដ្ឋាន ក៏មិនថ្កោះថ្កោយ ហើយចូលដល់សេចក្តីចម្រើនសេចក្តីលូតលាស់បានល្អ(ដល់កម្មដ្ឋាន) ។

"បរិមុខំ សតឹឧបដ្ឋបេត្វា"តិ កម្មដ្ឋានាភិមុខំ សតឹបបយិត្វា។

ច្រើនបទថា "**បរិមុខំ សតឹ ឧបដ្ឋបេត្វា** ប្រែថា ***តាំងសតិ ឲ្យមានមុខ ផ្តោះទៅរកកាន់កម្មដ្ឋាន***" (គឺសតិ តាំងនៅត្រង់ចុងច្រមុះ ឬផ្នែបបូរមាត់ខាងលើ ហើយដឹងនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ)។

"**សោ សតោវ អស្សសតិ សតោ បស្សសតី**"តិ សោ កិក្ខុ ឯវំ ឧិសីឧិត្វា ឯវញ្ច សតឹ ឧបដ្ឋបេត្វា តំ សតឹអវិជហាន្តោ សតោ ឯវ អស្សសតិ សតោ បស្សសតិ, សតោការី ហោតីតិ វុត្តំ ហោតិ។

ពាក្យថា "***យោគីកិក្ខុនោះ ជាអ្នកមានសតិ ខណៈដកដង្ហើមចូល កំណត់ដឹងថាចូល, ជាអ្នកមានសតិ ខណៈដកដង្ហើមចេញ កំណត់ដឹងថាចេញ***" បានសេចក្តីថា កិក្ខុនោះ អង្គុយយ៉ាងនេះហើយ និងបានតម្កល់សតិយ៉ាងនេះហើយ កាលដែលមិនលះបង់នូវសតិនោះ ឈ្មោះថា មានសតិស្មារតី ខណៈដកដង្ហើមចូល កំណត់ដឹងថាចូល និងមានសតិស្មារតីខណៈដកដង្ហើមចេញ កំណត់ដឹងថាចេញ ហ្នឹងឯង, អធិប្បាយថា កិក្ខុជាអ្នកចម្រើនូវសតិ ។

ឥជានិ យេហិ បការេហិ សតោការី ហោតិ, តេ បការេ ឧស្សេតុំ "**ឌីឃំ វា អស្សសន្តោ**"តិអាឌិមាហ។

ឥឡូវនេះ ព្រះយោគីកិក្ខុ ជាអ្នកធ្វើនូវសតិ ដោយអាការៈទាំងឡាយណា, ដើម្បីទ្រង់សម្តែងនូវអាការៈទាំងឡាយនោះ ទើបទ្រង់ត្រាស់ថា "**ឌីឃំ វា អស្សសន្តោ**" ដូច្នេះជាដើម ។

អធិប្បាយសព្ទ អស្សាស បស្សាស

តត្ថ "**ឌីឃំ វា អស្សសន្តោ**"តិ ឌីឃំ វា អស្សាសំ បវត្តយន្តោ។

បណ្តាបទទាំងនោះ បទថា "**ឌីឃំ វា អស្សសន្តោ**" សេចក្តីថា ញ៉ាំងខ្យល់ដកដង្ហើមចូលវែង ឲ្យប្រព្រឹត្តទៅ ក្តី ។

តថា **រស្សំ** ។

ខ្យល់ដកដង្ហើមចូលខ្លី ក៏ដូចគ្នា ។

យា បន ឧសំ ឌីឃរស្សតា, សា កាលវសេន វេឌិតព្វា។

ចំណែកឯភាពវែង និងខ្លី នៃខ្យល់ទាំង ២ នោះឯណា, ភាពវែង និងខ្លី នោះ បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃកាល (គឺរយៈពេល) ។

កថាចិ ហិ មនុស្សា ហត្ថិអហិអាទយោ វិយ កាលវសេន ឌីឃំ អស្សសន្តិ ច បស្សសន្តិ ច, កថាចិ សុទ្ធាវាសាទយោ វិយ រស្សំ។

មែនពិត ក្នុងគ្រាខ្លះ មនុស្សទាំងឡាយ រមែងដកដង្ហើមចូលវែង និង ដកដង្ហើមចេញវែង ដោយអំណាចនៃកាល ប្រៀបដូចជាសត្វទាំងឡាយ មាន ដំរី និងពស់ជាដើម, ក្នុងគ្រាខ្លះ មនុស្សទាំងឡាយ ដកដង្ហើមចូលខ្លី និង ដកដង្ហើមចេញខ្លី ប្រៀបដូចជាសត្វ តូចៗទាំងឡាយ ដែលមានឆ្កែ និងទន្សាយ ជាដើម ។

អញ្ញថា ហិ ចុណ្ណាវិចុណ្ណា អស្សាសបស្សាសា ឌីឃរស្សា ឧាម ន ហោន្តិ។

ក៏កាលកាន់យកនូវសេចក្តីតាមប្រការដទៃ ខ្យល់ដកដង្ហើមចូល និង ខ្យល់ដកដង្ហើមចេញ ដែលល្អិតសុខុមនោះ មិនឈ្មោះថា ខ្យល់ដកដង្ហើមចូល និងខ្យល់ដកដើមចេញ វែង និងខ្លី ទេ ។

តស្មា តេ ឌីឃំ កាលំ បវិសន្តា ច និក្ខមន្តា ច ឌីឃា, រស្សំ កាលំ បវិសន្តា ច និក្ខមន្តា ច រស្សាតិ វេឌិតព្វា។

ព្រោះហេតុនោះ ខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ នៃ មនុស្សទាំងឡាយនុ៎ះ កាលចូលក្តី កាលចេញក្តី អស់រយៈពេលយូរ ក៏គប្បីជ្រាប ថា វែង, កាលចូលក្តី កាលចេញក្តី អស់រយៈពេលបន្តិច ក៏គប្បីជ្រាបថា ខ្លី ដោយអំណាចនៃកាល (គឺ រយៈពេល) ។

តត្រាយំ ភិក្ខុ ឧបរិ រុត្តេហិ នវហាការេហិ ឧីយំ អស្សសន្តោ ច បស្សសន្តោ ច **"ឧីយំ អស្សសាមិ, បស្សសាមី"តិ បជានាតិ**, តថា **រស្សំ**។

ក្នុងកិរិយាដកដង្ហើមចូល និងដកដង្ហើចេញ រៃង និងខ្ងីនោះ ព្រះយោគាវចរនេះ កាលដកដង្ហើមចូលរៃង និងកាលដកដង្ហើមចេញរៃង ***ក៏ដឹងច្បាស់ថា "អាត្មាអញដកដង្ហើមចូលរៃង, ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញរៃង"***, *ដោយអាការៈទាំងឡាយ ៩ យ៉ាងដែលបានពោលមកហើយខាងមុខ, ចំណែក* ***ដកដង្ហើមចូលខ្ងី និងដកដង្ហើមចេញខ្ងី*** *ក៏មានសេចក្តីដូចគ្នា*។

ឯវំ បជានតោ ច –

ក៏កាលបើ ភិក្ខុដឹងច្បាស់យ៉ាងនេះ

"ឧីយោ រស្សោ ច អស្សាសោ, បស្សាសោបិ ច តាឧិសោ;

ចត្តារោ រណ្ណា រត្តន្តិ, នាសិកាក្តេវ ភិក្ខុនោ"តិ[๓๙]**។**

"ខ្យល់ ៤ យ៉ាងគឺ ខ្យល់ដកដង្ហើមចូលរៃង ១. ខ្យល់ដកដង្ហើមចូលខ្ងី ១. ខ្យល់ដកដង្ហើមចេញរៃង ១.ខ្យល់ដកដង្ហើមចេញខ្ងី ១. រមែងប្រព្រឹត្តទៅ នៅត្រង់កន្ទែងចុងច្រមុះ (ឬ លើផ្ទៃបបូរមាត់ខាងលើ) របស់ភិក្ខុនុ៉ះឯង" ។

នវន្នញ្ចស្ស អាការានំ ឯកេនាការេន កាយានុបស្សនាសតិប្ឋានភាវនា សម្បជ្ជតីតិ វេឧិតព្វា។

ការចម្រើនកាយានុបស្សនាសតិបដ្ឋាន របស់ភិក្ខុនោះ បណ្ឌិតគប្បីជ្រាបថា រមែងសម្រេចបានដោយអាការៈមួយ ក្នុងបណ្តាអាការៈទាំង ៩ យ៉ាង ។

---

๓๙ (រិសុទ្ធិ. ១.២១៩; បារា. អដ្ឋ. ២.១៦៥) ។

អធិប្បាយពាក្យ សព្វកាយប្បដិសំវេទី

"សព្វកាយបដិសំវេទី អស្សសិស្សាមី"តិ សិក្ខតិ។

ពាក្យថា កិក្ខុនោះ សិក្សាថា "អាត្មាអញកំណត់ដឹងឲ្យជាក់ច្បាស់ ដោយល្អ នូវខ្យល់ទាំងអស់ ជាចំណែកៗ ដកដង្ហើមចូល" ។

"សព្វកាយបដិសំវេទី បស្សសិស្សាមីតិ សិក្ខតី"តិ សកលស្ស អស្សាសកាយស្សាធិមជ្ឈបរិយោសានំ វិទិតំ ករោន្តោ ចាកដំ ករោន្តោ **អស្សសិស្សាមី"**តិ សិក្ខតិ។

*កិក្ខុសិក្សាថា **"អាត្មាអញកំណត់ដឹងឲ្យជាក់ច្បាស់ ដោយល្អ នូវខ្យល់ទាំងអស់ជាចំណែកៗ ដកដង្ហើមចេញ"** សេចក្តីថា កិក្ខុរមែងសិក្សាថា "អាត្មាអញកាលធ្វើនូវខាងដើមខ្យល់ ខាងកណ្តាលខ្យល់ និងខាងចុងខ្យល់ របស់កាយ គឺខ្យល់ដង្ហើមចូលទាំងអស់ ឲ្យជារបស់ដែលខ្លួនបានដឹង គឺធ្វើ(ខ្យល់ដង្ហើមនោះ) ឲ្យបានប្រាកដជាក់ច្បាស់ ខណៈដកដង្ហើមចូល" ។*

សកលស្ស បស្សាសកាយស្សាធិមជ្ឈបរិយោសានំ វិទិតំ ករោន្តោ ចាកដំ ករោន្តោ បស្សសិស្សាមីតិ សិក្ខតិ។

សិក្សាថា "អាត្មាអញកាលធ្វើនូវខាងដើមខ្យល់ ខាងកណ្តាលខ្យល់ និងខាងចុងខ្យល់ របស់កាយ គឺខ្យល់ដង្ហើមចេញទាំងអស់ ឲ្យជារបស់ដែលខ្លួនបានដឹង គឺធ្វើ(ខ្យល់ដង្ហើមនោះ) ឲ្យបានប្រាកដជាក់ច្បាស់ ខណៈដកដង្ហើមចេញ" (នេះជាការតាំងសតិទុកខាងដើម មុននឹងចម្រើនកម្មដ្ឋាន) ។

ឯវំ វិទិតំ ករោន្តោ ចាកដំ ករោន្តោ ញាណសម្បយុត្តចិត្តេន អស្សសតិ ចេវ បស្សសតិ ច។

កិក្ខុនោះកាលធ្វើ (នូវដង្ហើមនោះ) ឲ្យជារបស់ដែលខ្លួនបានដឹង គឺធ្វើ(ខ្យល់ដង្ហើមនោះ) ឲ្យបានប្រាកដជាក់ច្បាស់ យ៉ាងនេះហើយ ក៏ឈ្មោះថា

ដកដង្ហើមចូល និងដកដង្ហើមចេញ ដោយចិត្តដែលប្រកបព្រមដោយញាណ ។

តស្មា "អស្ឃសិស្ឃាមិ បស្ឃសិស្ឃាមីតិ សិក្ខតី"តិ វុច្ចតិ។

ព្រោះហេតុនោះ ទើបលោកពោលថា ភិក្ខុនោះ សិក្សាថា "អាត្មាអញ ដកដង្ហើមចូល និងដកដង្ហើមចេញ" ។

ឯកស្ឃ ហិ ភិក្ខុនោ ចុណ្ណាវិចុណ្ណាវិសេ(๖๐) អស្ឃាសកាយេ, បស្ឃាសកាយេ វា អាទិ ចាកនោ ហោតិ, ន មជ្ឈបរិយោសានំ។

មែនពិត ខាងដើមខ្យល់ របស់កាយ(របស់ខ្យល់) គឺដង្ហើមចូលក្តី, ឬ របស់កាយ គឺដង្ហើមចេញក្តី ដែលផ្សាយសុះទៅយ៉ាងល្អិតៗ រមែងប្រាកដ ដល់ភិក្ខុអង្គខ្លះ, ចំណែកត្រង់កណ្តាលខ្យល់ និងត្រង់ខាងចុង របស់ខ្យល់ រមែងមិនប្រាកដទេ ។

សោ អាទិមេវ បរិក្ខហេតុំ សក្កោតិ, មជ្ឈបរិយោសានេ កិលមតិ។

ភិក្ខុនោះ អាចកំណត់យកតែខ្យល់ខាងដើមប៉ុណ្ណោះ, រមែងលំបាក នៅត្រង់កណ្តាលខ្យល់ និងខាងចុងខ្យល់ ។

ឯកស្ឃ មជ្ឈំ ចាកដំ ហោតិ, ន អាទិបរិយោសានំ។

សំរាប់ភិក្ខុអង្គខ្លះ នៅត្រង់កណ្តាលខ្យល់ រមែងប្រាកដច្បាស់, ចំណែកនៅត្រង់ខាងដើមខ្យល់ និងខាងចុងខ្យល់ រមែងមិនប្រាកដទេ ។

សោ មជ្ឈមេវ បរិក្ខហេតុំ សក្កោតិ, អាទិបរិយោសានេ កិលមតិ។

ភិក្ខុនោះ អាចកំណត់យក នូវខ្យល់ខាងកណ្តាលតែប៉ុណ្ណោះ, រមែងលំបាក នៅត្រង់ខាងដើមខ្យល់ និងនៅខាងចុងខ្យល់ ។

ឯកស្ឃ បរិយោសានំ ចាកដំ ហោតិ, ន អាទិមជ្ឈំ។

---

๖๐ (*វិសុទ្ធិ. ๑.๒๑๙; ចារ. ๒.๑๖๕*) ។

សំរាប់កិក្ខុអង្គខ្លះ នៅត្រង់ខាងចុងខ្យល់ រមែងប្រាកដច្បាស់, ចំណែកនៅត្រង់ខាងដើមខ្យល់ និងខាងកណ្តាលខ្យល់ រមែងមិនប្រាកដទេ ។

សោ បរិយោសានំយេវ បរិគ្គហេតុំ សក្កោតិ, អាទិមជ្ឈេ កិលមតិ។

កិក្ខុនោះ អាចកំណត់យក នូវខ្យល់ខាងចុងតែប៉ុណ្ណោះ, រមែងលំបាកនៅត្រង់ខាងដើមខ្យល់ និងនៅត្រង់ខាងកណ្តាលខ្យល់ ។

ឯកស្ស សព្ពំ ចាកដំ ហោតិ, សោ សព្ពម្បិ បរិគ្គហេតុំ សក្កោតិ, ន កត្ថចិ កិលមតិ។

សម្រាប់កិក្ខុអង្គខ្លះ រមែងប្រាកដច្បាស់ គ្រប់ខ្យល់ទាំងអស់, កិក្ខុនោះអាចកំណត់យក នូវខ្យល់ទាំងអស់នោះបាន, រមែងមិនលំបាក ត្រង់ខ្យល់ណាមួយឡើយ ។

តាទិសេន ភវិតព្ពន្តិ ឧស្សន្នោ អាហ – "សព្ពកាយបដិសំវេទី"តិ អាទិ។

ព្រះថេរៈកាលសម្តែងថា កិក្ខុ គប្បីជាអ្នកប្រាកដដូច្នោះ ទើបពោលនូវធម្មថា "ជាអ្នកកំណត់ដឹងច្បាស់នូវកាយទាំងពួង" ដូច្នេះ ជាដើម ។

តត្ថ "*សិក្ខតី*"តិ ឯវំ យុជតិ ភាយមតិ។

*បណ្តាបទទាំងនោះ បទថា "**រមែងសិក្សា**" សេចក្តីថា គឺ ការប្រឹងប្រែង ការព្យាយាម យ៉ាងនេះ ។*

យោ ភ តថាភូតស្ស សំវរោ, អយមេត្ថ អធិសីលសិក្ខា។

ម្យ៉ាងទៀត សេចក្តីអធិប្បាយ ក្នុងបទនេះ បណ្ឌិតគប្បីជ្រាបថា សេចក្តីសង្រួមឯណា របស់កិក្ខុអ្នកប្រាកដដូច្នេះ, រីសេចក្តីសង្រួមនេះ ជាអធិសីលសិក្ខាក្នុងបទនេះ ។

យោ តថាភូតស្ស សមាធិ, អយំ អធិចិត្តសិក្ខា។

សមាធិឯណា របស់ភិក្ខុអ្នកជ្រាកដដូច្នេះ, រីសមាធិនេះ ជាអធិចិត្តសិក្ខា ក្នុងបទនេះ។

យា តថាភូតស្ស បញ្ញា, អយំ អធិបញ្ញាសិក្ខាតិ ឥមា តិស្សោ សិក្ខាយោ តស្មឹ អារម្មណេ តាយ សតិយា តេន មនសិការេន សិក្ខតិ អាសេវតិ ភាវេតិ ពហុលីករោតីតិ ឯវមេត្ថ អត្ថោ ឧដ្ឋហ្លោ។

បញ្ញាឯណា របស់ភិក្ខុអ្នកជ្រាកដដូច្នេះ, រីបញ្ញានេះ ជាអធិបញ្ញាសិក្ខា ក្នុងបទនេះ ភិក្ខុរមែងសិក្សា គឺចម្រើនធ្វើឲ្យច្រើន នូវសិក្ខាទាំង ៣ នោះ ដូចបានពោលមកហើយនេះ ដោយសតិនោះ ដោយការធ្វើទុកក្នុងចិត្តនោះ ក្នុងអារម្មណ៍នោះ។

តត្ត យស្មា បុរិមនយេន កេវលំ អស្សសិតព្ពំ បស្សសិតព្ពមេវ ច, ន អញ្ញំ កិញ្ចិ កាតព្ពំ, ឥតោ បដ្ឋាយ បន ញាណុប្បាទជាឌីសុ យោគោ ករណីយោ។

ក្នុងចតុក្កៈទី ១ នោះ ក្នុងន័យមុនគេ ព្រះយោគីគប្បីដកដង្ហើមចូល និងដកដង្ហើមចេញ តែម្យ៉ាងប៉ុណ្ណោះ, និង មិនគួរធ្វើកិច្ចអ្វីៗ ដទៃទេ, តែថា ការចាប់ផ្តើមអំពីនេះទៅ គប្បីធ្វើនូវសេចក្តីព្យាយាម ក្នុងអាការៈទាំងឡាយ មានការញុំាងញាណឲ្យកើតឡើងជាដើម។

តស្មា តត្ត "អស្សសាមីតិ បជានាតិ បស្សសាមីតិ បជានាតិ"ច្ចេវ វត្តមានកាលវសេន ចាបិ វុត្តា ឥតោ បដ្ឋាយ កត្តព្វស្ស ញាណុប្បាទជាឌិនោ អាការស្ស ឧស្សន្នត្តំ "សព្វកាយបដិសំវេទី អស្សសិស្សាមី"តិអាឌិនានយេន អនាគតកាលវសេន ចាបិ អាភោគិតាតិ វេឌិតព្វា។

*ព្រោះហេតុណា ព្រោះហេតុនោះ "បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងនូវព្រះបាលី ដោយអំណាចនៃបច្ចុប្បន្នកាល ថា "**អស្សសា-**

មីតិ បជានាតិ បស្សសាមីតិ បជានាតិ *ប្រែថា ភិក្ខុដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូល, ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញ" ដូច្នេះ នៅក្នុងន័យមុន នោះ ហើយទើបទ្រង់លើកយកព្រះបាលីមក ដោយអំណាចនៃពាក្យជាអនាគតកាល ដោយន័យជាដើម ថា "**សព្វកាយបដិសំវេទី អស្សសិស្សាមី** ប្រែថា អាត្មាអញ ជាអ្នកកំណត់ដឹងនូវកាយ គឺខ្យល់ដង្ហើមទាំងអស់ ខណៈដកដង្ហើមចូល" ដូច្នេះជាដើម ដើម្បីសម្តែងនូវអាការៈមានការញុំាងញាណ ឲ្យកើតឡើងជាដើម ដែលគប្បីធ្វើ ចាប់ផ្តើមអំពីន័យមុនដែលបានពោលមកហើយ" ដូច្នេះឯង ។*

អធិប្បាយពាក្យ បស្សម្ភយំ កាយសង្ខារំ

"បស្សម្ភយំ កាយសង្ខារំ។...បេ.... ។សិក្ខតី"តិ "ឱឡារិកំ អស្សាសបស្សាសសង្ខាតំ កាយសង្ខារំ បស្សម្ភេន្តោ បដិប្បស្សម្ភេន្តោ និរោធេន្តោ វូបសមេន្តោ អស្សសិស្សាមិ បស្សសិស្សាមី"តិ សិក្ខតិ។

*ពាក្យថា **"បស្សម្ភយំ កាយសង្ខារំ។...បេ.... ។ សិក្ខតិ** ប្រែថា **ភិក្ខុសិក្សាថា អាត្មាអញ កាលរម្ងាប់នូវកាយសង្ខារ ខណៈដកដង្ហើមចូល ។...ល...។ ខណៈដកដង្ហើមចេញ"** នោះ គឺភិក្ខុសិក្សាថា "អាត្មាអញ កាលរម្ងាប់ កាលពន្ធត់ កាលរំលត់ បង្ក្រាបនូវកាយសង្ខារ (ពួកខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលវែង និងខ្លី ដែលកំពុងប្រព្រឹត្តទៅក្នុងកាយ) ដែលមានសភាពគ្រោតគ្រាត ខណៈដកដង្ហើមចូល និងដកដង្ហើមចេញ" ដូច្នេះ ។*

តត្រែវំ ឱឡារិកសុខុមតា ច បស្សទ្ធិ ច វេទិតព្វា, ឥមស្ស ហិ កិក្ខុនោ បុព្វេ អបរិក្ខីណកាលេ កាយោ ច ចិត្តញ្ច សឌវថា ហោន្តិ ឱឡារិកា។

ក្នុងរឿងនេះ គឺខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ ជាខ្យល់គ្រោតគ្រាតក្តី និងខ្យល់ល្អិតៗក្តី និងសេចក្តីស្ងប់ក្តី បណ្ឌិតគប្បីជ្រាបនូវសេចក្តី

នោះដូចតទៅនេះ, ក៏កាយ និងចិត្ត របស់ភិក្ខុនោះក្នុងកាលមុន គឺពេលដែលមិនទាន់បានកំណត់ (នូវអានាបានស្សតិកម្មដ្ឋាននោះ) វាជាកាយ និងចិត្តដែលមានសភាពក្រវល់ក្រវាយ និងភាពគ្រោតគ្រាត។

កាយចិត្តានំ ឱឡារិកត្តេ អវូបសន្តេ អស្សាសបស្សាសាបិ ឱឡារិកា ហោន្តិ, ពលវតរា ហុត្វា បវត្តន្តិ, ជាសិកា ឧប្បជ្ជន្តិ, មុខេន អស្សសន្តោបិ បស្សសន្តោបិ តិដ្ឋតិ។

កាលបើភាពគ្រោតគ្រាត នៃកាយ និងចិត្ត មិនទាន់បានស្ងប់រម្ងាប់ទេ សូម្បីតែខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ ក៏គ្រោតគ្រាត, ព្រោះជាធម្មជាតដែលប្រព្រឹត្តទៅមានកម្លាំងខ្លាំងក្លា, ចំណែកច្រមុះ មិនគ្រប់គ្រាន់(ក្នុងការដកដង្ហើម), ភិក្ខុនោះ រមែងឈរដកដង្ហើមចូលខ្លះ ដកដង្ហើមចេញខ្លះ ទៅតាមមាត់ ។

យថា បនស្ស កាយោបិ ចិត្តម្បិ បរិក្ខហិតា ហោន្តិ, តថា តេ សន្តា ហោន្តិ វូបសន្តា។

ក៏ក្នុងពេលណា ទាំងកាយ ទាំងចិត្ត របស់ភិក្ខុនោះ គឺខ្លួនបានកំណត់ហើយ, គឺក្នុងពេលនោះ ទាំងកាយក្តី ទាំងចិត្តក្តី របស់ភិក្ខុនោះ រមែងស្ងប់ គឺចូលទៅស្ងប់រម្ងាប់ ។

តេសុ វូបសន្តេសុ អស្សាសបស្សាសា សុខុមា ហុត្វា បវត្តន្តិ, "អត្ថិ នុ ខោ, នត្ថី"តិ វិចេតព្វាការប្បត្តា ហោន្តិ។

កាលបើកាយ និងចិត្តទាំងនោះ ស្ងប់រម្ងាប់ហើយ ខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ ជាខ្យល់ធម្មជាតដ៏ល្អិតសុខុម រមែងប្រព្រឹត្តទៅ, ហើយជាខ្យល់ធម្មជាតដល់នូវអាការៈ ដែលគួរពិចារណាថា " មាន ឬ មិនមានទេហ្ន៎ ? " ។

សេយ្យថាបិ បុរិសស្ស ជាវិត្វា បព្វតា វា ឱរោហិត្វា, មហាការំ វា

សីសតោ ឱភេបេត្វា បិតស្ស ឱឌ្ឍារិកា អស្សាសបស្សាសា ហោន្តិ, ជាសិកា ន ហោតិ, មុខេន អស្សសន្តោបិ បស្សសន្តោបិ តិដ្ឋតិ។

ឧបមាប្រៀបដូចជា កាលបុរសដែលរត់ចុះមកអំពីភ្នំ ឬថា កាលបុរសទម្ងាក់នូវភារៈដ៏ធ្ងន់ចេញអំពីក្បាល ហើយក៏ឈរ ខ្យល់ដកដង្ហើមចូល និង ខ្យល់ដកដង្ហើមចេញ ដែលគ្រោតគ្រាត រមែងមាន, ច្រមុះ រមែងមិនគ្រប់គ្រាន់, ក៏ឈរដកដង្ហើមចូលខ្លះ និងដកដង្ហើមចេញខ្លះ តាមមាត់ ។

យថា បនេស តំ បរិស្សមំ វិនោទេត្វា ន្ហត្វា ច បិវិត្វា ច អល្ទសាដកំ ហទយេ កត្វា សីតាយ ឆាយាយ និបន្នោ ហោតិ, អថស្ស តេ អស្សាសបស្សាសា សុខុមា ហោន្តិ "អត្ថិ នុ ខោ, នត្ថី"តិ វិចេតព្វាការប្បត្តា, ឯវមេវំ ឥមស្ស ភិក្ខុនោ អបរិគ្គហិត កាលេតិ វិត្តារេតព្វំ។

ក៏ក្នុងពេលណា បុគ្គលនោះបន្ទោបង់ នូវសេចក្តីនឿយហត់នោះហើយ បានងូតទឹក និងផឹកទឹកហើយ ដាក់សំពត់ទទឹកលើបេះដូង ហើយដេកនៅក្រោមម្លប់ដ៏ត្រជាក់, ក្នុងពេលនោះ ខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញទាំងនោះរបស់បុគ្គលនោះ ជាខ្យល់ធម្មជាតដ៏ល្អិតសុខុម ដល់នូវអាការៈគួរពិចារណាថា "មាន ឬ មិនមានទេហ្ន៎ ?" ដូច្នេះ យ៉ាងណា, គប្បីញុំងនូវសេចក្តីនេះឲ្យពិស្តារថា សម្រាប់ភិក្ខុនេះក៏មានសេចក្តីដូចគ្នា គឺក្នុងពេលណាដែលមិនទាន់បានកំណត់ ។

តថា ហិស្ស បុព្ពេ អបរិគ្គហិតកាលេ "ឱឌ្ឍារិកោឱឌ្ឍារិកេ កាយសង្ខារេ បស្សម្ភេមី"តិ អាភោគសមន្នាហារមនសិការោ ន ត្តិ, បរិគ្គហិតកាលេ បន អត្តិ។

ពិតមែនហើយ ក្នុងកាលមុន គឺក្នុងពេលដែលមិនទាន់បានកំណត់(នូវកម្មដ្ឋាននោះ) ការរំពឹងគិត ការប្រមូលចិត្ត ការធ្វើទុកក្នុងចិត្ត ការពិចារណា ថា "អាត្មាអញ រម្ងាប់នូវកាយសង្ខារ ដែលគ្រោតគ្រាត" ដូច្នេះ រមែងមិនមានដល់

ភិក្ខុនោះ, តែក្នុងពេលដែលបានកំណត់ (នូវកម្មដ្ឋាននេះ)ហើយ ទើបមាន ។

តេនស្ស អបរិក្តហិតកាលតោ បរិក្តហិតកាលេ កាយសង្ខារោ សុខុមោ ហោតិ។

ព្រោះហេតុនោះ កាយសង្ខារ(ខ្យល់ដង្ហើម) របស់ភិក្ខុនោះ ក្នុងពេលដែលបានកំណត់(នូវកម្មដ្ឋាន)ហើយ រមែងល្អិតសុខុមជាងពេលដែលមិនទាន់បានកំណត់។

តេនាហុ ចោរាណា –

ព្រោះហេតុនោះ បានជាបោរាណាចារ្យទាំងឡាយ លោកពោលថា

"សារទ្ធេ កាយេ ចិត្តេ ច, អធិមត្តំ បវត្តតិ;

អសារទ្ធម្ហិ កាយម្ហិ, សុខុមំ សម្ឋវត្តតី"តិ[๖๑]**។**

ក៏កាលបើកាយ និងចិត្ត ក្រវល់ក្រវាយហើយ, កាយសង្ខារ(គឺខ្យល់ដង្ហើម) ក៏រមែងប្រព្រឹត្តទៅគ្រោតគ្រាតដែរ, កាលបើកាយ និងចិត្ត មិនក្រវល់ក្រវាយទេ, កាយសង្ខារ (គឺខ្យល់ដង្ហើម) រមែងប្រព្រឹត្តទៅ យ៉ាងល្អិតសុខុមផងដែរ ។

តាមន័យ សមថ

បរិក្តហេបិ ឱឡារិកោ, បឋមជ្ឈានូបចារេ សុខុមោ។

សូម្បីក្នុងពេលដែលបានកំណត់នូវ(កម្មដ្ឋាន) កាយសង្ខារ ក៏រាប់ថា នៅតែគ្រោតគ្រាតនៅឡើយ, នៅក្នុងឧបចារ: នៃបឋមជ្ឈាន ទើបឈ្មោះថាមានសភាពល្អិតសុខុមជាង ។

តស្មិម្ឋិ ឱឡារិកោ, បឋមជ្ឈានេ សុខុមោ។

សូម្បីតែក្នុងពេលឧបចារ: នៃបឋមជ្ឈាននោះសោត ក៏រាប់ថា នៅតែ

---

๖๑ (*វិសុទ្ធិ. ๑.๒๒๐; បារា. អដ្ឋ. ๒.๑๖๕*) ។

គ្រោតគ្រោតនៅឡើយ, នៅក្នុងបឋមជ្ឈាន ទើបឈ្មោះថាមានសភាពល្អិតសុខុមជាង ។

បឋមជ្ឈានេ ច ទុតិយជ្ឈានូបចារេ ច ឱឡារិកោ, ទុតិយជ្ឈានេ សុខុមោ។

នៅក្នុងបឋមជ្ឈានក្តី និងក្នុងឧបចារៈនៃទុតិយជ្ឈានក្តី ក៏រាប់ថានៅតែគ្រោតគ្រោតនៅឡើយ, នៅក្នុងទុតិយជ្ឈាន ទើបឈ្មោះថាល្អិតសុខុមជាង ។

ទុតិយជ្ឈានេ ច តតិយជ្ឈានូបចារេ ច ឱឡារិកោ, តតិយជ្ឈានេ សុខុមោ។

នៅក្នុងទុតិយជ្ឈានក្តី និងក្នុងឧបចារៈនៃតតិយជ្ឈានក្តី ក៏រាប់ថា នៅគ្រោតគ្រោតនៅឡើយ, នៅក្នុងតតិយជ្ឈាន ទើបឈ្មោះថាល្អិតសុខុមជាង ។

តតិយជ្ឈានេ ច ចតុត្ថជ្ឈានូបចារេ ច ឱឡារិកោ, ចតុត្ថជ្ឈានេ អតិសុខុមោ អប្បវត្តិមេវ ចាបុណាតិ។

ក្នុងតតិយជ្ឈានក្តី និងក្នុងឧបចារៈនៃចតុត្ថជ្ឈានក្តី ក៏រាប់ថា នៅតែគ្រោតគ្រោត, នៅក្នុងចតុត្ថជ្ឈាន ទើបឈ្មោះថាមានសភាពល្អិតសុខុមក្រៃលែងជាង រហូតដល់នូវមានការមិនបានប្រព្រឹត្តិទៅ ពិតមែន ។

ឥទំ តាវ ឌីឃភាណកសំយុត្តភាណកានំ មតំ។

*ពាក្យដែលបានពោលមកនេះ ជាមតិរបស់**ព្រះអាចារ្យទីឃភាណកៈ (ជាអ្នកពោលគម្ពីរទីឃនិកាយ) និងព្រះអាចារ្យសំយុត្តភាណកៈ (ជាអ្នកពោលគម្ពីរសំយុត្តនិកាយ)** ជាការពោលមុន ។*

មជ្ឈិមភាណកា បន "បឋមជ្ឈានេ ឱឡារិកោ, ទុតិយជ្ឈានូបចារេ សុខុមោ"តិ ឯវំ ហេដ្ឋិមហេដ្ឋិមជ្ឈានតោ ឧបរូបរិជ្ឈានូបចារេបិ សុខុមតរំ ឥច្ឆន្តិ។

ចំណែកឯ ***ព្រះអាចារ្យមជ្ឈិមភាណកៈ (អ្នកពោលគម្ពីរមជ្ឈិមនិកាយ) ទាំងឡាយ*** *តែងប្រាថ្នា សូម្បីក្នុងឧបចារៈ នៃឈានថ្នាក់ខ្ពស់ៗ ថា ក៏ល្អិតសុខុមក្រៃលែងជាងឈានថ្នាក់ខាងក្រោមៗ យ៉ាងនេះថា "ក្នុងបឋមជ្ឈាន កាយសង្ខារ រាប់ថា នៅគ្រោតគ្រាត, ក្នុងឧបចារៈរបស់ទុតិយជ្ឈាន ទើបល្អិត" ដូច្នេះ ។*

សព្ពេសំយេវ បន មតេន អបរិក្ខីតកាលេ បវត្តកាយសង្ខារោ បរិក្ខីតកាលេ បដិប្បស្សម្ភតិ, បរិក្ខីតកាលេ បវត្តកាយសង្ខារោ បឋមជ្ឈានូបចារេ ។...បេ... ។ ចតុត្ថជ្ឈានូបចារេ បវត្តកាយសង្ខារោ ចតុត្ថជ្ឈានេ បដិប្បស្សម្ភតិ។

ប៉ុន្តែបើតាមមតិ របស់លោកអាចារ្យទាំងឡាយទាំងពួងហ្នឹងឯង បានសេចក្តីថា កាយសង្ខារ ដែលប្រព្រឹត្តទៅ ក្នុងកាលដែលមិនបានកំណត់(នូវកម្មដ្ឋាន) រមែងស្ងប់រម្ងាប់ ក្នុងកាលដែលបានកំណត់(នូវកម្មដ្ឋាន), កាយសង្ខារ ដែលប្រព្រឹត្តទៅ ក្នុងកាលបានកំណត់ហើយ រមែងស្ងប់រម្ងាប់ក្នុងឧបចារៈ នៃបឋមជ្ឈាន ។...ល...។ កាយសង្ខារដែលប្រព្រឹត្តទៅ ក្នុងឧបចារៈនៃចតុត្ថជ្ឈាន រមែងស្ងប់រម្ងាប់ ក្នុងចតុត្ថជ្ឈាន"

អយំ តាវ សមថេ នយោ។

នេះជាន័យ ក្នុងសមថៈ ពោលមុនសិន ។

តាមនัយ វิបស្សនา

វិបស្សនាយំ បន អបរិក្ខីតកាលេ បវត្តកាយសង្ខារោ ឱឡារិកោ, មហាភូតបរិក្ខោ សុខុមោ។

ចំណែកក្នុងន័យវិបស្សនា កាយសង្ខារ ដែលប្រព្រឹត្តិទៅហើយ ក្នុងកាលមិនបានកំណត់ ក៏នៅគ្រោតគ្រាត, ក្នុងកាលដែលបានកំណត់នូវមហាភូតរូបនោះទើបមានសភាពល្អិតសុខុមជាង ។

សោបិ ឱឧ្បារិកោ, ឧចាជារូបបរិក្តហោ សុខុមោ។

សូម្បីកាយសង្ខារដែលប្រព្រឹត្តិទៅក្នុងកាលកំណត់នូវមហាភូតរូបនោះសោត ក៏រាប់ថា នៅគ្រោតគ្រាត, កាយសង្ខារ ក្នុងការកំណត់នូវឧបាទាយរូបនោះទើបមានសភាពល្អិតសុខុមជាង។

សោបិ ឱឧ្បារិកោ, សកាលរូបបរិក្តហោ សុខុមោ។

សូម្បីកាយសង្ខារ ក្នុងខណៈដែលកំណត់ឧបាទាយរូបនោះសោត ក៏រាប់ថា នៅគ្រោតគ្រាត, កាយសង្ខារ ក្នុងខណៈដែលកំណត់នូវរូបទាំងអស់ ទើបឈ្មោះថា ល្អិតសុខុមជាង ។

សោបិ ឱឧ្បារិកោ, អរូបបរិក្តហោ សុខុមោ។

សូម្បីកាយសង្ខារ ក្នុងខណៈដែលកំណត់នូវរូបទាំងអស់នោះសោត ក៏រាប់ថា នៅគ្រោតគ្រាត, កាយសង្ខារ ក្នុងខណៈដែលកំណត់នូវអរូប ទើបឈ្មោះថាល្អិតសុខុមជាង ។

សោបិ ឱឧ្បារិកោ, រូចារូបបរិក្តហោ សុខុមោ។

សូម្បីកាយសង្ខារ ក្នុងខណៈដែលកំណត់នូវអរូបនោះសោត ក៏រាប់ថា នៅគ្រោតគ្រាត, កាយសង្ខារ ក្នុងខណៈដែលកំណត់នូវរូប និង អរូប ទើបឈ្មោះថាល្អិតសុខុមជាង។

សោបិ ឱឧ្បារិកោ, បច្ចយបរិក្តហោ សុខុមោ។

សូម្បីកាយសង្ខារ ក្នុងខណៈដែលកំណត់នូវរូប និង អរូបនោះសោត ក៏រាប់ថា នៅគ្រោតគ្រាត, កាយសង្ខារ ក្នុងខណៈដែលកំណត់នូវបច្ច័យ ទើបឈ្មោះថាល្អិតសុខុមជាង។

សោបិ ឱឧ្បារិកោ, សប្បច្ចយនាមរូបជស្សនេ សុខុមោ។

សូម្បីកាយសង្ខារ ក្នុងខណៈដែលកំណត់នូវបច្ច័យនោះសោត ក៏រាប់ថា

នៅគ្រោតគ្រាត, កាយសង្ខារ ក្នុងកិរិយាឃើញនូវនាមរូប ព្រមទាំងបច្ច័យ ទើបឈ្មោះថាល្អិតសុខុមជាង ។

សោបិ ឱឞ្ឋរិកោ, លក្ខណារម្មណិកេ វិបស្សនាយ សុខុមោ។

សូម្បីកាយសង្ខារ ក្នុងកិរិយាឃើញនូវនាមរូប ព្រមទាំងបច្ច័យនោះសោត ក៏ពាប់ថា នៅគ្រោតគ្រាត, កាយសង្ខារ ក្នុងវិបស្សនាដែលមានត្រៃលក្ខណ៍ មកជាអារម្មណ៍ ទើបឈ្មោះថាល្អិតសុខុមជាង ។

សោបិ ឧឞ្ឋលវិបស្សនាយ ឱឞ្ឋរិកោ, ពលវវិបស្សនាយ សុខុមោ។

សូម្បីកាយសង្ខារ ក្នុងខណៈវិបស្សនាដែលមានកម្លាំងនៅខ្សោយ ក៏ពាប់ថា នៅគ្រោតគ្រាត, កាយសង្ខារ ក្នុងខណៈវិបស្សនា ដែលមានកម្លាំងខ្លាំង ទើបឈ្មោះថាល្អិតសុខុមជាង ។

តត្ថ បុព្ពេ វុត្តនយេនេវ បុរិមស្ស បុរិមស្ស បច្ឆិមេន បច្ឆិមេន បដិប្បស្សទ្ធិ វេទិតព្ពា។

ក្នុងវិបស្សនានោះ សេចក្តីរម្ងាប់ នៃកាយសង្ខារ ដែលមានក្នុងពេលមុនៗ ដោយកាយសង្ខារ ដែលមានខាងចុងៗ បណ្ឌិតគប្បីជ្រាបតាមន័យដែលលោកបានពោលហើយ ក្នុងកាលមុនហ្នឹងឯង ។

ឯវមេត្ថ ឱឞ្ឋរិកសុខុមតា បដិប្បស្សទ្ធិ ច វេទិតព្ពា។

សេចក្តីគ្រោតគ្រាតក្តី សេចក្តីល្អិតសុខុមក្តី និង សេចក្តីស្ងប់រម្ងាប់ក្តី បណ្ឌិតគប្បីជ្រាប នៅក្នុងសេចក្តីនេះ យ៉ាងនេះឯង ។

អយំ តាវេត្ថ កាយានុបស្សនាវសេន វុត្តស្ស បឋមចតុក្កស្ស អនុបុព្ពបទវណ្ណនា។

នេះជាការពណ៌នាបទ ទៅតាមលំដាប់នៃចតុក្កៈទី ๑ ដែលបានពោល

មកហើយ ដោយអំណាចនៃកាយានុបស្សនា នៅក្នុសេចក្តីនេះជាមុនសិន ។

យស្មា បនេត្ត ឥធមេវ ចតុក្ក៉ំ អាធិកម្មិកស្ស កម្មដ្ឋានវសេន វុត្តំ, ឥតរានិ បន តីណិ ចតុក្ក៉ានិ ឯត្ត បត្តជ្ឈានស្ស វេធនាចិត្តធម្មានុបស្ស-នាវសេន, តស្មា ឥមំ កម្មដ្ឋានំ ភាវេត្វា អានាចានចតុក្ក៉ជ្ឈានបធដ្ឋា-នាយ វិបស្សនាយ សហ បដិសម្ភិធាហិ អរហត្តំ ចាបុណិតុកាមេន អាធិកម្មិកេន កុលបុត្តេន វិសុទ្ធិមត្តេ វុត្តនយេន សីលបរិសោធនាធីនិ សព្វកិច្ចានិ កត្វា សត្តជ្ជ៉សមន្នាគតស្ស អាចរិយស្ស សន្តិកេ បញ្ចសន្ធិកំ កម្មដ្ឋានំ ឧក្តហោតព្វំ។

ព្រោះថាក្នុងចតុក្ក:ទាំង ៤ នោះ ចតុក្ក:នេះឯង គឺព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងដោយអំណាចជាកម្មដ្ឋាន នៃកុលបុត្រ អាទិកម្មិកយោគីភិក្ខុ គឺជាអ្នកចាប់ផ្តើមនូវសេចក្តីព្យាយាមដំបូង, ចំណែកចតុក្ក:ទាំងឡាយ ៣ ក្រៅអំពីនេះ ព្រះអង្គទ្រង់ត្រាស់ហើយ ដោយអំណាច នៃវេទនានុបស្សនា ចិត្តានុបស្សនា និងធម្មានុបស្សនានៃព្រះយោគី ដែលជាអ្នកបានបន្ទុះឈានរួចហើយ ក្នុងបឋមចតុក្ក:នេះ, ព្រោះហេតុនោះ កុលបុត្រជាអ្នកចាប់ផ្តើមនូវសេចក្តីព្យាយាម ជាអ្នកប្រាថ្នាដើម្បីចម្រើននូវកម្មដ្ឋាននេះ ហើយបន្ទុះព្រះអរហត្ត ព្រមជាមួយបដិសម្ភិទាទាំងឡាយ ដោយវិបស្សនា ដែលមានអានាបានស្សតិចតុត្ថជ្ឈាន ជាបទដ្ឋាន គប្បីធ្វើនូវកិច្ចទាំងពួងទាំងឡាយ មានការជម្រះនូវសីលឲ្យបរិសុទ្ធិជាដើម តាមន័យដែលលោកបានពោលមកហើយក្នុងវិសុទ្ធិមគ្គ ហើយគប្បីរៀនយកនូវកម្មដ្ឋានដែលមានសន្ធិ(គឺតំណ) ៥ យ៉ាង ក្នុងសំណាក់នៃព្រះអាចារ្យដែលជាអ្នកប្រកបដោយអង្គ ៧ ប្រការ ។

បញ្ចសន្ធិ តំណ ៥ យ៉ាង

តត្រិមេ បញ្ច សន្ធយោ ឧក្តហោ បរិបុច្ឆា ឧបដ្ឋានំ អប្បនា លក្ខណន្តិ។

នៅក្នុងសេចក្តីនេះ សន្ធិ ៥ យ៉ាង គឺ ១.ឧគ្គហៈ ការរៀនយក, ២. បរិបុច្ឆា ការសាកសួរ, ៣. ឧបដ្ឋាន ការកើតឡើងប្រាកដច្បាស់, ៤. អប្បនា ការបានសម្រេចតាំងមាំ, ៥. លក្ខណៈ ការចូលទៅទ្រទ្រង់ទុក ។

១. **តត្ថ ឧគ្គហោ** ជាម **កម្មដ្ឋានស្ស ឧគ្គណ្ហនំ**។

ក្នុងសន្ធិ ៥ យ៉ាងនោះ ការរៀនយកនូវកម្មដ្ឋាន ឈ្មោះថា **ឧគ្គហ** ។

២. **បរិបុច្ឆា** ជាម **កម្មដ្ឋានស្ស បរិបុច្ឆនំ**។

ការសាកសួរនូវកម្មដ្ឋាន ឈ្មោះថា **បរិបុច្ឆា** ។

៣. **ឧបដ្ឋានំ** ជាម **កម្មដ្ឋានស្ស ឧបដ្ឋានំ**។

ការកើតឡើងប្រាកដច្បាស់របស់កម្មដ្ឋាន ឈ្មោះថា **ឧបដ្ឋាន** ។

៤. **អប្បនា** ជាម **កម្មដ្ឋានស្ស អប្បនា**។

ការបានសម្រេចតាំងមាំ នៃកម្មដ្ឋាន ឈ្មោះថា **អប្បនា** ។

៥. **លក្ខណំ** ជាម **កម្មដ្ឋានស្ស លក្ខណំ, "ឯវំ លក្ខណមិទំ កម្មដ្ឋាន"ន្តិ កម្មដ្ឋានសភាវូបធារណន្តិ វុត្តំ ហោតិ**។

លក្ខណៈនៃកម្មដ្ឋាន ឈ្មោះថា **លក្ខណ** , *អធិប្បាយថា ការចូលទៅទ្រទ្រង់ទុកនូវសភាវៈ នៃកម្មដ្ឋាន ថា "កម្មដ្ឋាននេះ មានលក្ខណៈយ៉ាងនេះ" ដូច្នេះ ។*

ឯវំ បញ្ចសន្ធិកំ កម្មដ្ឋានំ ឧគ្គណ្ហន្តោ អត្តនាបិ ន កិលមតិ, អាចរិយម្បិ ន វិហេសេតិ។

យោគីកិក្ខុ កាលរៀនយកនូវកម្មដ្ឋាន ដែលមានសន្ធិ ៥ យ៉ាងនេះ រមែងមិនលំបាកដល់ខ្លួនឯងផង, ទាំងមិនបៀតបៀនដល់គ្រូបាអាចារ្យផង ។

តស្មា ថោកំ ឧទ្ធិសាបេត្វា ពហុំ កាលំ សជ្ឈាយិត្វា ឯវំ បញ្ច-

សន្ធិកំ កម្មដ្ឋានំ ឧគ្គហេត្វា អាចរិយស្ស សន្តិកេ វា អញ្ញត្ថ វា អដ្ឋារស ទោសយុត្តេ វិហារេ វជ្ជេត្វា បញ្ចង្គសមន្នាគតេ សេនាសនេ វសន្តេន ឧបច្ឆិន្នខុទ្ទកបលិពោធេន កតភត្ត-កិច្ចេន កត្តសម្មំ បដិវិនោទេត្វា សុខនិសិន្នេន រតនត្តយគុណានុស្សរណេន ចិត្តំ សម្បហំសេត្វា អាចរិយុគ្គហតោ ឯកបទម្បិ អបរិហាបេន្តេន ឥទំ អានាបានស្សតិ-កម្មដ្ឋានំ មនសិ កាតព្ពំ។

ព្រោះហេតុនោះ យោគីកិក្ខុ គប្បីញ៉ាំងគ្រូអាចារ្យឲ្យសម្តែងតៃបន្តិចបាន ហើយ ស្វាធ្យាយអស់កាលច្រើន រៀនយកនូវកម្មដ្ឋានដែលមានសន្ធិ ៥ យ៉ាងនេះ ហើយវៀរកន្លែងរស់នៅ ដែលប្រកបដោយទោស ១៨ យ៉ាង ក្នុងសំណាក់នៃគ្រូអាចារ្យ ឬ ក្នុងទីដទៃដោយរស់នៅក្នុងទីសេនាសនៈ ដែលប្រកបដោយអង្គ ៥ មានការកាត់បលិពោធតូចៗ មានកត្តកិច្ចដែលធ្វើហើយ បន្ទោបង់នូវសេចក្តីស្រវឹងក្នុងកត្ត អង្គុយឲ្យសប្បាយ ញ៉ាំងចិត្តឲ្យរីករាយ ដោយការរលឹកវឿយៗ នូវគុណព្រះរតនត្រៃ ហើយកុំឲ្យភ្លេចភ្ញាំងសូម្បីតែមួយបទ ចាកការរៀនអំពីគ្រូអាចារ្យ គប្បីធ្វើទុកក្នុងចិត្ត នូវអានាបានស្សតិកម្មដ្ឋាននេះ។

វិធី មនសិការយកកម្មដ្ឋាន មាន ៨ យ៉ាង

តត្រាយំ មនសិការវិធិ –

វិធីមនសិការ ក្នុងអានាបានស្សតិកម្មដ្ឋាននេះ មានដូចតទៅ៖

"តណាតា អនុពន្ធនា, ផុសនា បឋនា សល្លក្ខណា;

វិវដ្តនា ចារិសុទ្ធិ, តេសញ្ច បដិបស្សនា"តិ។

*"១ .**តណាតា** ការរាប់, ២. **អនុពន្ធនា** ការតាមចង់ក្រៀក, ៣. **ផុសនា** ការពាល់ត្រូវ, ៤. **ឋបនា** ការតម្កល់ចិត្តមាំ, ៥. **សល្លក្ខណា** ការកំណត់ជាក់ច្បាស់, ៦ .**វិវដ្តនា** ការមិនផ្ទាស់ប្តូរ, ៧. **ចារិសុទ្ធិ** សេចក្តីបរិសុទ្ធិ,*

๘. **តេសញ្ច បដិបស្សនា** *ប្រាជ្ញាពិចារណាឃើញនូវមគ្គ និងផលទាំងឡាយ នោះ ។*

๑. **តត្ថ "តណាជា"តិ តណាជាយេវ។**

ក្នុងវិធីមនសិការនោះ ពាក្យថា **"តណាជា** *ប្រែថា* ***ការរាប់*** *។*

๒. **"អនុពន្ធជា"តិ អនុគមជា។**

ពាក្យថា **"អនុពន្ធជា** *ប្រែថា* ***ការជាប់តាមចង់ក្រៀក*** *បានដល់ ការតាមជាប់ស្និត ។*

๓. **"ផុសនា"តិ ផុដ្ឋដ្ឋានំ។**

ពាក្យថា **"ផុសនា** *ប្រែថា* ***ការពាល់ត្រូវ*** *បានដល់ ទីកន្លែងដែលដឹងថា ខ្យល់ពាល់ត្រូវ។*

๔. **"បបជា"តិ អប្បជា។**

ពាក្យថា **"បបជា** *ប្រែថា* ***ការតម្កល់ចិត្តមាំ*** *បានដល់ ការតម្កល់ចិត្តមាំ នៅក្នុង បដិភាគនិមិត្ត ។*

๕. **"សល្លក្ខណា"តិ វិបស្សនា។**

ពាក្យថា **"សល្លក្ខណា** *ប្រែថា* ***ការកំណត់ជាក់ច្បាស់*** *បានដល់ ការឃើញច្បាស់ ។*

๖. **"វិវដ្ដនា"តិ មគ្គោ។**

ពាក្យថា **"វិវដ្ដនា** *ប្រែថា* ***ការមិនផ្ទាស់ប្តូរ*** *បានដល់ ការមិនផ្ទាស់ប្តូរ មកវិញ ។*

๗. **"ចារិសុទ្ធី"តិ ផលំ។**

ពាក្យថា **"ចារិសុទ្ធិ** *ប្រែថា* ***សេចក្តីបរិសុទ្ធិ*** *បានដល់ គឺ ផល នោះឯង ។*

៨. "**តេសញ្ច បដិបស្សនា**"តិ បច្ចវេក្ខណា។

*ពាក្យថា "**តេសញ្ច បដិបស្សនា** ប្រែថា **ប្រាជ្ញាពិចារណាឃើញនូវមគ្គ និងផលទាំងឡាយនោះ**" បានដល់ ការពិចារណាឃើញច្បាស់នូវមគ្គ និងផលទាំងឡាយនោះ ។*

ទិដ្ឋិ គណនា គឺការកំណត់រាប់

តត្ថ ឥមិនា អាទិកម្មិកេន កុលបុត្តេន បឋមំ គណនាយ ឥដំ កម្មដ្ឋានំ មនសិកាតព្ពំ។

ក្នុងវិធីមនសិការទាំងនោះ អាទិកម្មិកកុលបុត្រ(បុគ្គលទើបចាប់ផ្តើមបដិបត្តិ) គប្បីធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាននេះដោយការរាប់ជាមុនសិន ។

តណោន្តេន បន បញ្ចន្នំ ហេដ្ឋា ន បវេតព្ពំ, ឧសន្នំ ឧបរិ ន នេតព្ពំ, អន្តរា ខណ្ឌំ ន ទស្សេតព្ពំ។

កាលរាប់ មិនគប្បីបញ្ឈប់ខាងក្រោមចំនួន ៥, ហើយមិនគប្បីនាំទៅ(គឺការរាប់) ឲ្យលើសជាង៥ចំនួន ១០ ឡើយ, និងមិនគប្បីសម្តែងការរាប់ ដោយដាច់ជាចន្លោះៗ នោះទេ ។

បញ្ចន្នំ ហេដ្ឋា បវេន្តស្ស ហិ សម្ពាធេ ឱកាសេ ចិត្តុប្បាទោ វិយុជ្ជតិ សម្ពាធេ វជេ សន្និរុទ្ធគោគណោ វិយ។

ព្រោះថា កាលព្រះយោគីរាប់បញ្ឈប់ខាងក្រោម(គឺតិចជាង) ៥ ចិត្តុប្បាទរមែងញាប់ញ័រ ក្នុងឱកាសដ៏ចង្អៀត ដូចជាហ្វូងគោ ដែលនាយគោបាលឃាំងទុកហើយ ក្នុងក្រាលដ៏ចង្អៀតហើយក៏ញាប់ញ័រ ដូច្នោះ ។

ឧសន្នំ ឧបរិ នេន្តស្ស គណនានិស្សិតោវ ចិត្តុប្បាទោ ហោតិ។

កាលព្រះយោគីនាំទៅ ខាងលើ គឺការរាប់ឲ្យលើសជាង៥ចំនួន ១០ ចិត្តុប្បាទ

រមែងអាស្រ័យនៅតែនឹងការរាប់ហ្នឹងឯង ។

អន្តរា ឧណ្ហំ ឧស្សេន្តស្ស "សិទាប្បត្តំ នុ ខោ មេ កម្មដ្ឋានំ, នោ"តិ ចិត្តំ រិកម្បតិ, តស្មា ឯតេ ឧោសេ រជ្ជេត្វា កណេតព្វំ។

កាលបើព្រះយោគី សម្តែងការរាប់ដាច់ៗ ក្នុងចន្លោះ ចិត្ត រមែងកម្រើកញាប់ញ័រ ថា "កម្មដ្ឋាន របស់អាត្មាអញ ដល់ទីបំផុត ឬហ្នំ ? ឬក៏ មិនទាន់ដល់ទីបំផុតទេ", ព្រោះហេតុនោះ ព្រះយោគី គប្បីរៀរនូវទោសទាំងឡាយនេះ ហើយទើបប្រើការរាប់ចុះ ។

វិធី កំណត់រាប់យឺតៗ

កណេន្តេន ច បឋមំ ឧន្ធកណនាយ ឈញ្ញមាបកកណនាយ កណេតព្វំ។

*អាទិកម្មិកកុលបុត្រ កាលចាប់ផ្តើមរាប់ គប្បីរាប់ដោយវិធីយឺតៗ **គឺរាប់ដូចជាបុគ្គលអ្នកវាល់ស្រូវ** ជាដំបូងសិន ។*

ឈញ្ញមាបកោ ហិ នាឡឺ បូរេត្វា "ឯក"ន្តិ រត្វា ឱកិរតិ, បុន បូរេន្តោ កិញ្ចិ កចវរំ ឧិស្វា ឆឌ្ឌេន្តោ "ឯកំ ឯក"ន្តិ រឧតិ។

ពិតមែន បុគ្គលអ្នកវាល់ស្រូវ បានញ្ចាំងនាឡិ ឲ្យពេញរួចហើយ ពោលថា " មួយ " ហើយក៏ចាក់ធារចុះទៅ, កាលកើបពេញម្តងទៀត ឃើញនូវសំរាម ណាមួយ ក៏ចោលនូវសំរាមនោះ ហើយពោលថា " មួយ មួយ " ដូច្នេះ ។

ឯសេវ នយោ "ឧ្វេ ឧ្វេ"តិអាឧីសុ។

ក្នុងការរាប់ទាំងឡាយ មានការរាប់ថា "ពីរ ពីរ" ជាដើម ក៏មានន័យដូចគ្នានេះដែរ ។

ឯវមេវំ ឥមិនាបិ អស្សាសបស្សាសេសុ យោ ឧបដ្ឋាតិ, តំ កហេត្វា

"ឯកំ ឯក"ន្តិអាទឹ កត្វា យាវ "ទស ទសា"តិ បវត្តមានំ បវត្តមានំ ឧបលក្ខេត្វាវ គណេតព្ពំ។

យ៉ាងណាមិញ សូម្បីអាទិកម្មិកកុលបុត្រ(គឺកុលបុត្រដែលចាប់ផ្តើមបដិបត្តិដំបូង)រូបនេះ ក៏គប្បីកាន់យកនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញដែលប្រាកដ ហើយកំណត់កាន់យកនូវខ្យល់ ដែលប្រព្រឹត្តិទៅរឿយៗនោះឯង ហើយរាប់ចាប់ដើមតាំងពី "មួយ មួយ" រហូតទៅដល់ "ដប់ ដប់" ក៏យ៉ាងនោះដែរ។

តស្ស ឯវំ គណយតោ និក្ខមន្តា ច បវិសន្តា ច អស្សាស-បស្សាសា ចាកាសា ហោន្តិ។

កាលអាទិកម្មិកកុលបុត្រនោះ រាប់យ៉ាងនេះ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលកំពុងចូល និងកំពុងចេញ រមែងប្រាកដច្បាស់។

ទីធី កំណត់រាប់ឈឿន

អថានេន តំ ឧទ្ធគណនំ ឧញ្ញាមបកគណនំ បហាយ សីឃគណនាយ **គោចាលកគណនាយ** គណេតព្ពំ។

*លុះដាប់នោះ ព្រះយោគីនោះ គប្បីលះបង់នូវការរាប់យឺតៗ គឺ ការរាប់ដូចជាបុគ្គលវាល់ស្រូវនោះហើយគប្បីមករាប់ដោយការរាប់ឈឿនៗ**គឺរាប់តាមនាយគោបាលវិញ**។*

ឆេកោ ហិ គោចាលកោ សក្ខរាឧយោ ឧច្ចដ្ឋេន គហេត្វា រជ្ជុឧណ្ហាហត្ថោ ចាតោវ វជំ គន្ត្វា តាវេ បិដ្ឋិយំ បហរិត្វា បលិឃត្ថម្ភមត្ថកេ និសិន្នោ ទ្វារំ បត្តំ បត្តំយេវ តាវំ "ឯកោ ទ្វេ"តិ សក្ខរំ ទិបិត្វា ទិបិត្វា គណេតិ។

*ពិតមែន នាយគោបាលដែលឆ្លាត ដាក់នូវដុំក្រួសទាំងឡាយ នឹងថ្នក់

ហើយមានខ្សែ និងដំបង នៅក្នុងដៃ រួចដើរទៅកាន់ក្រោលគោ តាំងពីព្រលឹមស្រាងៗ គោះគោទាំងឡាយត្រង់ខ្នងឲ្យក្រោក រួចអង្គុយលើចុងនៃសសរគោលក្បែរក្រោលគោ ហើយរាប់នូវគោមួយក្បាលៗ ដែលមកដល់ច្រកទ្វារ ដោយបោះនូវដុំក្រួសមួយដុំៗ ថា " មួយ ពីរ " ដូច្នេះ។

តិយាមរត្តឹ សម្ពាធេ ឱកាសេ ខុក្កំ វុត្តកោកណោ ឯកូមត្តោ អញ្ញមញ្ញំ ឧបនិយ្យំសត្តោ វេគេន វេគេន បុញ្ជបុញ្ជោ ហុត្វា ឯកូមតិ។

ហ្វូងគោ ដែលនៅយ៉ាងលំបាក ក្នុងឱកាសដែលចង្អៀត អស់រាត្រីមានយាម ๓ កន្លងមកហើយ កាលចេញមក ក៏ប្រជ្រៀតគ្នានឹងគ្នា រមែងចេញមកជាហ្វូងៗ ចេញទៅដោយលឿនរហ័ស ។

សោ វេគេន វេគេន "តីណិ ចត្តារិ បញ្ច ឧសា"តិ កណោតិយេវ, ឯវមស្សាបិ បុរិមនយេន កណាយតោ អស្សាសបស្សាសា ចាកជា ហុត្វា សីឃំ សីឃំ បុនប្បុនំ សញ្ចរន្តិ។

នាយគោបាលនោះ ក៏រាប់ដោយលឿនៗ ថា " បី បួន ប្រាំ ... ដប់ " ដូច្នេះ, កាលព្រះយោគីសូម្បីកាលរាប់តាមន័យមុនយ៉ាងនេះ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ រមែងជាសភាវៈដែលប្រាកដច្បាស់ សញ្ចរទៅរឿយៗ យ៉ាងលឿនៗ ។

តតោ តេន "បុនប្បុនំ សញ្ចរន្តី"តិ ញត្វា អន្តោ ច ពហិ ច អគ្គហេត្វា ទ្វារប្បត្តំ ទ្វារប្បត្តំយេវ កហេត្វា "ឯកោ ទ្វេ តីណិ ចត្តារិ បញ្ច, ឯកោ ទ្វេ តីណិ ចត្តារិ បញ្ច ឆ, ឯកោ ទ្វេ តីណិ ចត្តារិ បញ្ច ឆ សត្ត។... បេ.... ។ អដ្ឋ ឯវ ឧសា"តិ សីឃំ សីឃំ កណេតព្វមេវ។

បន្ទាប់មកទៀត ព្រះយោគីនោះ គប្បីដឹង ថា "ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ តែងសញ្ចរទៅរឿយៗ " ដូច្នេះ ហើយកុំកាន់យក នូវខ្យល់ដង្ហើមខាងក្នុង និងខ្យល់ដង្ហើមខាងក្រៅ ត្រូវកាន់យកតែខ្យល់ដង្ហើម ដែលមកដល់ហើយៗ នូវទ្វារ(គឺ ត្រង់ចុងច្រមុះ ឬ ផ្ទៃបបូរមាត់ខាងលើ) នោះប៉ុណ្ណោះ ហើយ

ទើបរាប់យ៉ាងលឿនៗ ថា

"១ ២ ៣ ៤ ៥,

១ ២ ៣ ៤ ៥ ៦,

១ ២ ៣ ៤ ៥ ៦ ៧,

១ ២ ៣ ៤ ៥ ៦ ៧ ៨,

១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩,

១ ២ ៣ ៤ ៥ ៦ ៧ ៨ ៩ ១០" ដូច្នេះ ប៉ុណ្ណោះ ។

កណានាបដិពទ្ធេ ហិ កម្មដ្ឋានេ កណានពលេនេវ ចិត្តំ ឯកក្តំ ហោតិ អវិត្តុបត្តម្ភនវសេន ចណ្ឌាសោតេ នាវាបបនមិវ។

ព្រោះថា ក្នុងកម្មដ្ឋានដែលជាប់ទាក់ទងដោយការរាប់ ចិត្ត ជាធម្មជាត មានអារម្មណ៍តែមួយ ដោយកម្ចាំងនៃការរាប់ហ្នឹងឯង ដូចជាការចតនូវទូក ក្នុងក្រសែទឹកដ៏កំណាចគឺហូរខ្ចាំង ដោយអំណាចនៃការទប់ដោយថ្មោល យ៉ាងដូច្នោះឯង ។

តស្សេវំ សីឃំ សីឃំ កណយតោ កម្មដ្ឋានំ និរន្តរំ បវត្តំ វិយ ហុត្វា ឧបដ្ឋាតិ។

កាលព្រះយោគីនោះ រាប់លឿនៗ យ៉ាងនេះ កម្មដ្ឋាន រមែងប្រាកដច្បាស់ ដូចជាប្រព្រឹត្តិទៅហើយ មិនមានចន្ទោះ ។

អថ "និរន្តរំ បវត្តតី"តិ ញត្វា អន្តោ ច ពហិ ច វាតំ អបវិក្តហោត្វា បុរិមនយេនេវ វេកេន វេកេន កណេតព្វំ។

បន្ទាប់មក ព្រះយោគីនោះ គប្បីដឹងថា "កម្មដ្ឋាន រមែងប្រព្រឹត្តិទៅ មិនមានចន្ទោះ" ដូច្នេះហើយ កុំកាន់យកនូវខ្យល់ដង្ហើមខាងក្នុង និងខ្យល់ដង្ហើម

ខាងក្រៅ ហើយគប្បីរាប់ដោយរហ័សៗ តាមន័យមុនហ្នឹងឯង ។

អន្តោបវិសនវាតេន ហិ សជ្ជឺ ចិត្តំ បវេសយតោ អព្ភន្តរំ វាតញ្ភាហតំ មេឧបូរិតំ វិយ ហោតិ។

ព្រោះថា កាលព្រះយោគី បញ្ជូនចិត្ត ទៅជាមួយនឹងខ្យល់ ដែលចូលទៅ ខាងក្នុង ចិត្តប្រៀបដូចជា ត្រូវបានខ្យល់បក់បោកហើយ និងដូចជាពេញហើយ ដោយខ្ទាញ់ខាប់ ឲ្យដ៏ខាងក្នុង ។

ពហិនិក្ខមនវាតេន សជ្ជឺ ចិត្តំ នីហរតោ ពហិជ្ជា បុថុត្តារម្មណោ ចិត្តំ វិក្ខិបតិ។

កាលព្រះយោគី នាំចិត្តចេញមក ជាមួយនឹងខ្យល់ ដែលចេញមក ខាងក្រៅ ចិត្ត រមែងរាយមាយ ក្នុងអារម្មណ៍ដែលក្រាស់ ឲ្យដ៏ខាងក្រៅ ។

ផុដ្ឋផុដ្ឋោកាសេ បន សតឺបបេត្វា ភាវេន្តស្សេវ ភាវនា សម្បជ្ជតិ។

លុះដល់ព្រះយោគី តម្កល់នូវសតិចម្រើនក្នុងឱកាសដែលខ្យល់ពាល់ត្រូវ ហើយៗ (គឺ ត្រង់ចុងច្រមុះ ឬ ផ្ទៃបបូរមាត់ខាងលើ)ប៉ុណ្ណោះ ទើបការភាវនា រមែងបានសម្រេច ។

តេន វុត្តំ – "អន្តោ ច ពហិ ច វាតំ អបវិក្តហោត្វា បុរិមនយេនេវ វេកេន វេកេន កណេតព្ធ"ន្តិ។

ព្រោះហេតុនោះ ខ្ញុំម្ចាស់បានពោលមកហើយថា " ព្រះយោគី កុំកាន់យក នូវខ្យល់ដង្ហើមខាងក្នុង និងខ្យល់ដង្ហើមខាងក្រៅ ហើយគប្បីរាប់ដោយរហ័សៗ តាមន័យមុនហ្នឹងឯង" ។

កីវចិរំ បនេតំ កណេតព្ធន្តិ?, យាវ វិនា កណនាយ អស្សាសប-ស្សាសារម្មណសតិ សន្តិដ្ឋតិ។

ប្រសិនមានអ្នកសួរថា ក៏ការរាប់នេះ គួររាប់យូរប៉ុន្មានទៅ ? , ឆ្ងើយថា

ព្រះយោគី គប្បីរាប់ រហូតអាចរៀរចាកការរាប់បាន ហើយសតិ ក៏តាំងនៅព្រម ក្នុងអារម្មណ៍ គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ។

ពហិ រិសជវិតក្ការិច្ឆេជំ កត្វា អស្សាសបស្សាសារម្មណេ សតិ សណ្ឋាបនត្តំយេវហិ កណនាតិ។

ព្រោះថា ការរាប់ គឺដើម្បីធ្វើការកាត់ផ្តាច់ នូវវិតក្ក: ដែលរាលដាលទៅ ឲ្វដ៏ខាងក្រៅ ហើយតម្កល់នូវសតិ ក្នុងអារម្មណ៍ គឺ ខ្យល់ដង្ហើមចូល និងខ្យល់ ដង្ហើមចេញ ឲ្យបានហ្នឹងឯង ។

ឯវំ កណនាយ មនសិ កត្វា អនុពន្ធនាយ មនសិ កាតព្វំ។

*កាលព្រះយោគី បានធ្វើទុកក្នុងចិត្ត ដោយវិធីរាប់ យ៉ាងនេះហើយ គប្បីធ្វើទុកក្នុងចិត្ត **ដោយការជាប់តាមចងក្រៀក** (បន្តទៅទៀត) ។*

ចិធីប្រើអនុពន្ធនា គឺសតិនៅជាមួយខ្យល់

អនុពន្ធនា នាម កណនំ បដិសំហរិត្វា សតិយា និរន្តរំ អស្សាសប-ស្សាសានំ អនុកមនំ។

*កិរិយាបានផ្អាកទុកនូវការរាប់រួចហើយ តទៅត្រូវបញ្ជូនសតិ ទៅតាមដឹង ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ជាប់តៗគ្នាមិនឲ្យមានចន្ទោះ នេះ(គឺសតិ នៅ) ឈ្មោះថា **អនុពន្ធនា** ។*

តញ្ចា ទោ ន អាជិមជ្ឈបរិយោសានានុកមនវសេន។

ប៉ុន្តែថា ការបញ្ជូនសតិទៅនោះ មិនគប្បីធ្វើ ដោយអំណាចនៃការបញ្ជូន ទៅកាន់ខ្យល់ដង្ហើមខាងដើម ឬ ខ្យល់ដង្ហើមកណ្តាល និងខ្យល់ដង្ហើមខាងចុង នោះទេ ។

អាជិមជ្ឈបរិយោសានានិ តស្សានុកមនេ អាជីនវា ច ហោជ្ជា

វុត្តាយេវ។

រឿងខាងដើមខ្យល់ កណ្តាលខ្យល់ ខាងចុងខ្យល់ និងទោសក្នុងការទៅតាមខ្យល់នោះ ខ្ញុំម្ចាស់បានពោលទុកមកហើយ តាំងតែខាងដើមនោះឯង។

តស្មា អនុពន្ធនាយ មនសិករោន្តេន ន អាទិមជ្ឈបរិយោសាន-វសេន មនសិការតព្ពំ, អបិច ខោ ផុសនាវសេន ច បឋមនាវសេន ច មនសិ ការតព្ពំ។

*ព្រោះហេតុនោះ យោគីភិក្ខុ កាលធ្វើទុកក្នុងចិត្ត ដោយការជាប់តាមចងក្រៀក មិនគួរធ្វើទុកក្នុងចិត្ត ដោយអំណាចនៃខ្យល់ខាងដើម ខ្យល់កណ្តាល និងខ្យល់ខាងចុង នោះទេ, ប៉ុន្តែយោគីភិក្ខុនោះ គប្បីធ្វើទុកក្នុងចិត្ត **ដោយអំណាចនៃការពាល់ត្រូវខ្យល់** ផង **ដោយអំណាចនៃការតម្កល់ចិត្តមាំ** ផង។*

កណាជានុពន្ធនាវសេន វិយ ហិ ផុសនាបឋមនាវសេន វិសុំ មនសិការោ នត្ថិ, ផុដ្ឋផុដ្ឋដ្ឋានេយេវ បន តណោន្តោ កណាជាយ ច ផុសនាយ ច មនសិ ករោតិ, តស្មេវ កណានំ បដិសំហរិត្វា តេ សតិយា អនុពន្ធន្តោ, អប្បនាវសេន ច ចិត្តំ បវេទេន្តោ "អនុពន្ធនាយ ច ផុសនាយ ច បឋមនាយ ច មនសិ ករោតី"តិ វុច្ចតិ។

ពិតមែន ការធ្វើទុកក្នុងចិត្ត ដោយអំណាចនៃការពាល់ត្រូវ និងការតម្កល់ចិត្តមាំ មិនមានផ្សេងគ្នា ដូចជាការធ្វើទុកក្នុងចិត្ត ដោយអំណាចនៃការរាប់ និងការជាប់តាមចងក្រៀក នោះទេ, តែថា យោគីភិក្ខុ កាលធ្វើការរាប់ ក្នុងទីដែលខ្យល់ពាល់ត្រូវហើយៗ ហ្នឹងឯង ឈ្មោះថា រមែងធ្វើទុកក្នុងចិត្ត ដោយការរាប់ផង និងការពាល់ត្រូវផង, កាលណា ផ្អាកនូវការរាប់ ក្នុងទីដែលខ្យល់ពាល់ត្រូវហើយៗ នោះហើយ (បន្ទាប់មកទៀត) ត្រូវប្រើសតិស្មារតី ជាប់តាមចងក្រៀក(គឺសតិនៅត្រង់ចុងច្រមុះនោះដដែល ហើយដឹង)នូវខ្យល់ដង្ហើមចូល

*និងខ្យល់ដង្ហើមចេញទាំងនោះ(ដោយមិនឲ្យមានចន្ទោះ គឺមិនឲ្យមានការ រាយមាយចូលមករំខាន ហើយដឹងតែខ្យល់ចូល និងចេញតែម្យ៉ាងគត់), ហើយ តម្កល់នូវចិត្តឲ្យមាំ ដោយអំណាចនៃអប្បនា លោកហៅថា "ធ្វើទុកក្នុងចិត្ត ដោយអនុពន្ធនាផង ដោយផុសនាផង និយដោយ**ឋបនាផង**" ដូច្នេះ ។*

ស្វាយមត្ថោ អដ្ឋកថាសុ វុត្តបដ្ក្ុឧ្បដោវារិកោបមាហិ ឥធេវ ចាឧ្បិយំ វុត្តកកចូបមាយ ច វេទិតព្វោ។

*សេចក្តីនេះ បណ្ឌិតគប្បីជ្រាប តាមការឧបមា ដោយបុរសខ្ងិន និងអ្នក ឆ្មាំទ្វារ ដែលព្រះអដ្ឋកថា លោកបានពោលមកហើយ **នៅក្នុងអដ្ឋកថាទាំងឡាយ** និងតាមសេចក្តីឧបមានូវរណារអារឈើ ដែលព្រះសារីបុត្ថេរពោលទុកនៅក្នុង គម្ពីរបដិសម្ភិទាមគ្ត ក្នុងទីនោះ នុ៉ះឯង ។*

ការឧបមាទី ១ ដូចបុរសខ្ងិនដើង

តត្រាយំ បដ្ក្ុឧ្បោបមា –

*បណ្តាឧបមាទាំងនោះ នេះគឺជាសេចក្តីឧបមា **ដោយបុរសខ្ងិនដើង** ដូច្នេះ។*

សេយ្យថាបិ បដ្ក្ុឧ្បោ ដោលាយ កីឧ្បតំ មាតាបុត្តានំ ដោលំ ទិបិត្វា តត្ថេវ ដោលាថម្ភមូលេ និសិន្នោ កមេន អាកច្ចន្តស្ស ច កច្ចន្តស្ស ច ដោលាផលកស្ស ឧភោ កោដិយោ មជ្ឈញ្ច បស្សតិ,

ឧបមាថា មានបុរសខ្ងិនម្នាក់ បានយោលនូវទោង ដើម្បីមាតា និងបុត្រ (គឺ ជាភរិយា និងកូន) ដែលជាអ្នកលេងជិះទោង បានអង្គុយនៅជិតដើងសសរទោង ក្នុងទីនោះឯង រមែងឃើញនូវទីបំផុតទាំងពីរខាងផង នូវពាក់កណ្តាលផង នៃ ផែនក្តារទោង ដែលមកផង និងទៅផង តាមលំដាប់,

ន ច ឧភោកោដិមជ្ឈានំ ឧស្សនត្ថំ ញាវដោ ហោតិ,

តែថា ជាអ្នកមិនបានខ្ជល់ខ្ជាយ ដើម្បីនឹងមើលនូវទីបំផុតទាំងពីរខាង និង ត្រង់កណ្តាលទេ យ៉ាងណាមិញ,

ឯវមេវ ភិក្ខុ សតិវសេន ឧបនិពន្ធនត្ថម្ភមូលេ បត្វា អស្សាស-បស្សាសនោលំ ទិបិត្វា តត្ថេវ និមិត្តេ សតិយា និសីទន្តោ,, កាមេន អាគច្ឆន្តានញ្ច កច្ឆន្តានញ្ចេវ ផុដ្ឋដ្ឋានេ អស្សាសបស្សាសានំ អាទិមជ្ឈ-បរិយោសានំ សតិយា អនុគច្ឆន្តោ តត្ថេវ[៦២] ចិត្តំ បមេត្វា បស្សតិ,

ភិក្ខុ ក៏យ៉ាងនោះដូចគ្នា ឈរនៅទៀបសសរ ដែលជាទីចង (ចិត្ត គឺចុងច្រមុះ) ដោយអំណាចនៃសតិ ជិតទោង គឺខ្យល់អស្សាសៈ និងបស្សាសៈ អង្គុយចុះដោយសតិនោះក្នុងនិមិត្តនោះ, កាលជាប់តាមទៅដោយសតិ តម្កល់ចិត្តទុក(នោះ) ត្រង់កន្លែងដែលពាល់ត្រូវហើយៗ នោះ រមែងឃើញខាងដើមខ្យល់ ខាងកណ្តាលខ្យល់ និងខាងចុងខ្យល់ របស់ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ក្នុងទីដែលខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ បានមកផង និងទៅផង ទៅតាមលំដាប់,

ន ច តេសំ ឧស្សុកត្តំ ពា្យវដោ ហោតិ។

តែថា ភិក្ខុនេះ ជាអ្នកមិនបានខ្ជល់ខ្ជាយ ដើម្បីនឹងមើលនូវខ្យល់ខាងដើម (គឺត្រង់ចុងច្រមុះ), ខ្យល់កណ្តាល (គឺត្រង់បេះដូង), និងខ្យល់ខាងចុង (គឺត្រង់ផ្ចិត នូវរបៀបនេះ) នេះទេ ។

អយំ បដ្ឋេ្ឋបមា។

នេះជាការ ឧបមាដោយបុរសខ្វិន ។

ឧបមាទី ๒ ដូចជាអ្នកយាមទ្វារ

អយំ បន គោបរិក្ខោបមា –

---

๖๒ *វិសុទ្ធិ. ๑.๒๒๕ ។*

*ចំណែក **ការឧបមាដូចជាអ្នកយាមទ្វារ** មានដូចតទៅនេះ –*

សេយ្យថាបិ ទោវារិកោ ជនវស្ស អន្តោ ច ពហិ ច បុរិសេ "កោ តុំ, កុតោ វា អាគតោ, កុហឹ វា គច្ឆសិ, កឹ វា តេ ហាត្តេ"តិ ន វីមំសតិ។

គឺ អ្នកឆ្មាំទ្វារ មិន (ដើរទៅ) សាកសួរមនុស្ស (ដែលនៅ) ក្នុងព្រះនគរ និង ក្រៅព្រះនគរថា "អ្នកជានរណា?, ឬ អ្នកមកអំពីទីណា?, ឬ អ្នកនឹងទៅទីណា?, ឬថា អ្វីមាននៅក្នុងដៃរបស់អ្នក ?" ដូច្នេះ ទុំះទេ ។

ន ហិ តស្ស តេ ភារា, ទ្វារប្បត្តំ ទ្វារប្បត្តំយេវ បន វីមំសតិ, ឯវមេវ ឥមស្ស កិក្ខុនោ អន្តោបរិដ្ឋវតា ច ពហិនិក្ខន្តវតា ច ន ភារា ហោន្តិ, ទ្វារប្បត្តា ទ្វារប្បត្តាយេវ ភារាតិ ។

ព្រោះថា មនុស្សទាំងនោះ មិនមែនជាការៈរបស់អ្នកឆ្មាំទ្វារនោះទេ, តែថា អ្នកឆ្មាំទ្វារ អាចសាកសួរនូវមនុស្សណាដែលមកដល់ទ្វារហើយ? តែប៉ុណ្ណោះ, យ៉ាងណាមិញ ខ្យល់ដែលចូលទៅខាងក្នុងក្តី ខ្យល់ចេញមកខាងក្រៅក្តី មិនមែនជាការៈរបស់កិក្ខុនោះទេ, ខ្យល់ដែលមកដល់ទ្វារ(គឺចុងច្រមុះ)ហើយ មកដល់ទ្វារ(គឺចុងច្រមុះ)ហើយ ហ្នឹងឯង ទើបជាការៈ របស់កិក្ខុនេះ ក៏យ៉ាងនោះដូចគ្នា។

អយំ ទោវារិកោបមា។

នេះ ជាការឧបមាដោយអ្នកឆ្មាំទ្វារ ។

ឧបមាទី ៣ ដូចអ្នកអារឈើដោយរណារដៃ

កកចូបមា បន "និមិត្តំ អស្សាសបស្សាសា"តិអាទិកា[៤៣]នយេន ឥធ វុត្តាយេវ។

*ចំណែក **ការឧបមាដោយរណារដៃ** លោកបានពោលមកហើយ ក្នុងទីនេះប៉ុណ្ណោះ ដោយន័យមានអាទិថា " និមិត្ត(គឺចុងច្រមុះ ឬលើផ្ទៃបបូរមាត់*

---

៤៣ (បដិ. ម. ១.១៥៩) ។

ខាងលើ)๑, ខ្យល់ដង្ហើមចូល๑, និងខ្យល់ដង្ហើមចេញ๑ ” ដូច្នេះ ។

ឥទ បនស្ស អាកតាកតវសេន អមនសិការមត្តមេវ បយោជនន្តិ វេទិតព្ពំ។

ក៏ក្នុងទីនេះ គប្បីជ្រាបនូវប្រយោជន៍ ចំពោះត្រឹមតែ ការមិនបានធ្វើទុកក្នុងចិត្ត ដោយអំណាចខ្យល់ដែលមកហើយ និងទៅហើយ របស់កិក្ខុនោះប៉ុណ្ណោះ ។

ឥទំ កម្មដ្ឋានំ មនសិកពោតោ កស្សចិ ន ចិរេនេវ និមិត្តញ្ច ឧប្បជ្ជតិ, អវសេសឈានង្គបដិមណ្ឌិតា អប្បនាសង្ខាតា បឋមា ច សម្បជ្ជតិ។

ក៏កាលធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាននេះ សម្រាប់យោគីកិក្ខុរូបខ្លះ និមិត្តរមែងកើតឡើង ដោយការមិនយូរហ្នឹងឯង, ឋបនា ពោលគឺ អប្បនា ដែលប្រដាប់ដោយអង្គឈានដ៏សេសទៀត ក៏រមែងដល់ព្រមនឹងសម្រេច។

កស្សចិ បន កណាជាវសេនេវ មនសិការកាលតោ បភុតិ យថា សារទ្ធកាយស្ស មញ្ចោ វា បីឋេ វា និសីទតោ មញ្ចបីឋំ ឱនមតិ វិកូជតិ, បច្ចត្ថរណំវលឹ កណ្ហាតិ, អសារទ្ធកាយស្ស បន និសីទតោ នេវ មញ្ចបីឋំ ឱនមតិ ន វិកូជតិ, ន បច្ចត្ថរណំ វលឹ កណ្ហាតិ, តូលបិចុបុរិតំ វិយ មញ្ចបីឋំ ហោតិ។

ប៉ុន្តែ សម្រាប់ព្រះយោគីរូបខ្លះ ចាប់ផ្តើមអំពីកាលធ្វើទុកក្នុងចិត្តដោយអំណាចការរាប់នោះឯង មានកាយដែលមានសភាពក្រវល់ក្រវាយអង្គុយលើគ្រែក្តី ឬ លើតាំងក្តី គ្រែ និងតាំង ក៏រមែងទ្រុឌចុះ នឹងលាន់ឮសំលេង, គ្រឿងកម្រាលក៏រមែងចាប់ផ្តើមរួញ, តែថា កាលព្រះយោគី មិនមានកាយក្រវល់ក្រវាយអង្គុយលើគ្រែក្តី លើតាំងក្តី គ្រែ និងតាំង រមែងមិនទ្រុឌចុះ មិនឮសំឡេងទេ, គ្រឿងកម្រាលក៏មិនចាប់ផ្តើមរួញដែរ, គ្រែ និងតាំង ដូចជា ពួកដែលត្រូវបានគេ

ញាត់ពេញហើយដោយប៉ុយគរ ។

កស្មា? យស្មា អសារទ្ធោ កាយោ លហុកោ ហោតិ, ឯវមេវំ តណាជាវសេន មនសិការកាលតោ បភុតិ អនុក្កមតោ ឱឌ្ឌារិក-អស្សាសបស្សាសនិរោធវសេន កាយទរថេ វូបសន្តេ កាយោបិ ចិត្តម្បិ លហុកំ ហោតិ, សរីរំ អាកាសេ លង្ឃនាការប្បត្តំ វិយ ហោតិ។

ព្រោះហេតុអ្វី? ព្រោះថា កាយដែលមិនមានភាពក្រវល់ក្រវាយ រមែងជាធម្មជាតស្រាលៗ, ព្រោះហេតុណា ព្រោះហេតុនោះ កាលសេចក្តីក្រវល់ក្រវាយនៃកាយ បានសូប់រម្ងាប់ហើយ ដោយអំណាចនៃកិរិយារំលត់នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលមានសភាពគ្រោតគ្រោតៗ ទៅតាមលំដាប់ ចាប់ផ្តើមតាំងពីធ្វើទុកក្នុងចិត្ត ដោយអំណាចនៃការរាប់ ទាំងកាយក្តី និងចិត្តក្តី រមែងជាធម្មជាតស្រាលៗ, សរីរៈក៏រមែងជាធម្មជាត ប្រៀបដូចជា ដល់នូវអាការៈអណ្តែតឡើង ទៅឰដ៏អាកាស ក៏យ៉ាងនោះដែរ ។

តស្ស ឱឌ្ឌារិកេ អស្សាសបស្សាសេ និរុទ្ធេ សុខុមអស្សាស-បស្សាសនិមិត្តារម្មណំ ចិត្តំ បវត្តតិ។

កាលខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏គ្រោតគ្រោតរបស់ព្រះយោគីនោះ រលត់ទៅហើយ ចិត្តដែលមាននិមិត្ត គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏ល្អិតសុខុម មកជាអារម្មណ៍ ក៏រមែងប្រព្រឹត្តិទៅ ។

តស្មិម្បិ និរុទ្ធេ អបរាបរំ តតោ សុខុមតរំ សុខុមតរំ អស្សាស-បស្សាសនិមិត្តារម្មណំ បវត្តតិយេវ។

កាលអារម្មណ៍នោះ រលត់បាត់ទៅហើយ ចិត្តដទៃៗទៀត ដែលមាននិមិត្ត គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏ល្អិតសុខុមក្រៃលែងជាងនោះ មកជាអារម្មណ៍ ក៏រមែងប្រព្រឹត្តិទៅហ្នឹងឯង ។

ស្វាយមត្ថោ ឧបរិ វុត្តកំសថាលោបមាយ វេទិតព្ពោ។

សេចក្តីនេះ គប្បីជ្រាបតាមការឧបមា ដោយការបានគោះរគាំងសំរិទ្ធិ ដែលនឹងពោលនៅខាងមុខ ។

វិធីមនសិការអានាបានស្សតិ មានលក្ខណៈផ្សេងពីកម្មដ្ឋានដទៃ

យថា ហិ អញ្ញានិ កម្មដ្ឋានានិ ឧបរូបរិ វិភូតានិ ហោន្តិ, ន តថា ឥទំ។

ក៏អានាបានស្សតិកម្មដ្ឋាននេះ មិនដូចជាកម្មដ្ឋានទាំងឡាយដទៃៗ រមែងច្បាស់ប្រាកដឡើងៗ ទៅក្នុងលំដាប់ខាងលើៗ ។

ឥទំ បន ឧបរូបរិ ភាវេន្តស្ស សុខុមត្តំ កច្ឆតិ, ឧបដ្ឋានម្បិ ន ឧបកច្ឆតិ។

តែថា អានាបានស្សតិកម្មដ្ឋាននេះ កាលព្រះយោគីចម្រើនខ្ពស់ឡើងទៅៗ រមែងដល់នូវភាពជាកម្មដ្ឋានដ៏ល្អិតសុខុម, រមែងមិនចូលដល់ សូម្បីភាពប្រាកដឡើយ ។

ឯវំ អនុបដ្ឋហន្តេ បន តស្មឹ តេន ភិក្ខុនា "អាចរិយំ បុច្ឆិស្សាមី"តិ វា "ឧដ្ឋំ ឋានិ មេ កម្មដ្ឋាន"ន្តិ វា ឧដ្ឋាយាសនា ន តន្តព្ពំ។

តែថា កាលអានាបានស្សតិកម្មដ្ឋាននោះ មិនទាន់ប្រាកដ យ៉ាងនេះ ភិក្ខុនោះ មិនត្រូវក្រោកចាកអាសនៈ ទៅដោយគិតថា "អាត្មាអញ នឹងសួរនូវគ្រូអាចារ្យ" ដូច្នេះ ឬថា "ឥឡូវនេះ កម្មដ្ឋានរបស់អាត្មាអញ វិនាសហើយ" ដូច្នេះឡើយ ។

ឥរិយាបថំ វិកោបេត្វា កច្ឆតោ ហិ កម្មដ្ឋានំ ឧរុឧរុមេវ ហោតិ។

ព្រោះថា កាលព្រះយោគីញុំាងឥរិយាបថ ឲ្យកម្រើកទៅហើយកម្មដ្ឋានក៏រមែងជាកម្មដ្ឋានសារជាថ្មីម្តងទៀតភ្លាមៗ វិញហើយ។

តស្មា យថានិសិន្នេនេវ ឧសតោ អាហរិតព្វំ។

ព្រោះហេតុនោះ ព្រះយោគីនោះ គប្បីអង្គុយទៅតាមសភាពដើមដដែលនោះឯង ហើយគប្បីរក្សាសតិនៅទីកន្ទែងដែលប្រាកដ(គឺចុងច្រមុះ) ។

ឧបាយក្នុងការកំណត់ដឹងខ្យល់ឡើងវិញ

តត្រាយំ អាហរណ្ហចាយោ –

ឧបាយ ក្នុងការកំណត់ដឹងនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញឡើងវិញនោះ នឹងមានដូចតទៅនេះ ៖

តេន ភិក្ខុនា កម្មដ្ឋានស្ស អនុបដ្ឋានភាវំ ញត្វា ឥតិ បដិសញ្ចិក្ខិ-តព្វំ "ឥមេ អស្សាសបស្សាសា នាម កត្ត អត្ថិ, កត្ត នត្ថិ។

កាលដែលភិក្ខុនោះ ដឹងនូវសភាវៈថា កម្មដ្ឋានមិនប្រាកដ គប្បីពិចារណាយ៉ាងនេះថា "ឈ្មោះថា ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនេះ រមែងមានក្នុងទីណា, និងមិនមានក្នុងទីណា ។

កស្ស វា អត្ថិ, កស្ស វា នត្ថី"តិ។

ឬ មានដល់បុគ្គលណា, ឬថា នឹងមិនមានដល់បុគ្គលណាខ្លះ" ដូច្នេះ ។

អថេវំ បដិសញ្ចិក្ខតោ "ឥមេ អន្តោមាតុកុច្ឆិយំ នត្ថិ, ឧឧកេ និមុក្តានំ នត្ថិ, តថា អសញ្ញីភូតានំ មតានំ ចតុត្ថជ្ឈានសមាបន្នានំ រូចារូ-បភវសមជ្ជីនំ និរោធសមាបន្នាន"ន្តិ ញត្វា ឯវំ អត្តនាវ អត្តា បដិចោឧេ-តព្វោ "ឧនុ, ត្វំ បណ្ឌិត, នេវ មាតុកុច្ឆិកតោ, ន ឧឧកេ និមុក្តោ, ន អសញ្ញីភូតោ, ន មតោ, ន ចតុត្ថជ្ឈានសមា-បន្នោ, ន រូចារូបភវសមជ្ជី, ន និរោធសមាបន្នោ។

តមកទៀត កាលព្រះយោគី ពិចារណាយ៉ាងនេះ ក៏បានដឹងថា "ខ្យល់

ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនេះ មិនមានដល់សត្វទាំងឡាយ ១.ដែលនៅខាងក្នុងផ្ទៃនៃមាតា, ២.មិនមានដល់បុគ្គលដែលមុជចុះក្នុងទឹក, ៣.មិនមានដល់បុគ្គលដែលសន្ទប់ , ៤. មិនមានដល់បុគ្គលដែលស្លាប់ហើយ, ៥.មិនមានដល់បុគ្គលទាំងឡាយដែលលោកចូលចតុត្ថជ្ឈានសមាបត្តិ, ៦.មិនមានដល់បុគ្គលទាំងឡាយ ដែលលោកដល់ព្រមហើយដោយរូបកព និងអរូបកព, ៧.មិនមានដល់ព្រះអរិយបុគ្គលទាំងឡាយ ដែលលោកចូលនិរោធសមាបត្តិ" ដូច្នេះហើយគប្បីពិចារណាខ្លួន ដោយខ្លួនឯង យ៉ាងនេះថា " នែអ្នកបណ្ឌិត, ១. ក្រែងអ្នកមិនមែនបិតនៅក្នុងផ្ទៃមាតា, ២. មិនមែន ជាអ្នកមុជចុះក្នុងទឹក, ៣. មិនមែនជាអ្នកសន្ទប់, ៤. មិនមែន ជាអ្នកស្លាប់, ៥. មិនមែន ជាអ្នកចូលចតុត្ថជ្ឈានសមាបត្តិ, ៦. មិនមែន ជាអ្នកប្រកបព្រមដោយរូបកព និងអរូបកព, ៧. មិនមែន ជាអ្នកចូលនិរោធសមាបត្តិ,ពិតមែនឬទេ ? ។

អត្ថិយេវ តេ អស្សាសបស្សាសា, មន្ទបញ្ញតាយ បន បរិក្ខហេតុំ ន សក្កោសី"តិ។

ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនោះ របស់យោគីភិក្ខុ នៅតែមានដដែលហ្នឹងឯង, តែថា អ្នកមិនអាចដើម្បីនឹងកំណត់បាន ព្រោះភាពនៃខ្លួនជាអ្នកមានសតិបញ្ញាទន់ខ្សោយ" ។

អថានេន បកតិជវសេន ចិត្តំ បបេត្វា មនសិការោ បវត្តេតព្ពោ។

បន្ទាប់មក ព្រះយោគីនោះ គប្បីតាំងចិត្តទុក ដោយអំណាចនៃខ្យល់ដែលពាល់ត្រូវហើយៗតាមប្រក្រតី ហើយធ្វើទុកក្នុងចិត្ត ឲ្យប្រព្រឹត្តិទៅ ។

ឥមេ ហិ ឌីឃជាសិកស្ស ជាសាបុដំ ឃដ្ដេត្វា បវត្តន្តិ, រស្សជាសិកស្ស ឧត្តរោដ្ឋំ។

ក៏ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនេះ រមែងពាល់ត្រូវ នៅចុងច្រមុះ របស់បុគ្គលអ្នកមានក្តោងច្រមុះវែង ហើយប្រព្រឹត្តិទៅ, រមែងពាល់ត្រូវ

នៅផ្ទៃបបូរមាត់ខាងលើ របស់បុគ្គលអ្នកមានក្តោងច្រមុះខ្ងី ហើយប្រព្រឹត្តិទៅ ។

តស្មានេន "ឥមំ នាម ឋានំ ឃដ្តេន្តី"តិ និមិត្តំ ឋបេតព្វំ។

ព្រោះហេតុនោះ ព្រះយោគីនេះ គប្បីតម្កល់នូវនិមិត្តទុក ថា "ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ រមែងពាល់ត្រូវ នៅទីកន្ងែងនេះ" ។

ឥមមេវ ហិ អត្ថវសំ បដិច្ច វុត្តំ ភគវតា "នាហំ ភិក្ខវេ មុដ្ឋស្សតិស្ស អសម្បជានស្ស អានាចានស្សតិភាវនំ វជាមី"តិ(៤៤) ។

ពិតមែន ព្រះមានព្រះភាគ ទ្រង់អាស្រ័យនូវអំណាចនៃប្រយោជន៍នេះ ទើបទ្រង់ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ តថាគត មិនពោលនូវការចម្រើន អានាបានស្សតិ ដល់បុគ្គលអ្នកភ្ងេចភ្ងាំងសតិស្មារតី អ្នកមិនដឹងខ្លួននោះទេ" ដូច្នេះ ។

កិញ្ចាបិ ហិ យំកិញ្ចិ កម្មដ្ឋានំ សតស្ស សម្បជានស្សេវ សម្បជ្ជតិ, ឥតោ អញ្ញំ បន មនសិករោន្តស្ស ចាកដំ ហោតិ។

មែនពិត កម្មដ្ឋានឯណានីមួយរមែងសម្រេចដល់បុគ្គលអ្នកមានសតិស្មារតី ជាអ្នកដឹងខ្លួន ក៏ពិតមែនហើយ, ក៏ប៉ុន្តែថា កម្មដ្ឋានដទៃក្រៅអំពីកម្មដ្ឋាននេះ ក៏រមែងប្រាដកច្បាស់ ដល់បុគ្គលដែលបានធ្ងើទុកក្នុងចិត្តផងដែរ ។

ឥជំ បន អានាចានស្សតិកម្មដ្ឋានំ ករុកំ ករុកភាវនំ ពុទ្ធបច្ចេកពុទ្ធពុទ្ធបុត្តានំ មហាបុរិសានំយេវ មនសិការភូមិភូតំ, ន ចេវ ឥត្តរំ, ន ច ឥត្តរសត្តសមាសេវិតំ។

ចំណែកឯកម្មដ្ឋានអានាបានស្សតិកម្មដ្ឋាននេះ ជាកម្មដ្ឋានធ្ងន់ ជាភាវនាធ្ងន់ និងជាភូមិមនសិការរបស់មហាបុរសទាំងឡាយ គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងបុត្ត្ររបស់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ, មិនមែនជាកម្មដ្ឋានថោកថយទេ និងមិនមែនជាកម្មដ្ឋាន ដែលសត្ងថ្នាក់ល្មមៗប្រព្រឹត្តិបានទេ ។

---

៤៤ (ម. និ. ៣.១៤៩; សំ. និ. ៥.៩៩២) ។

យថា យថា មនសិ ករីយតិ, តថា តថា សន្តញ្ហេវ ហោតិ សុខុមញ្ច។

កម្មដ្ឋាននេះ ដែលព្រះយោគីធ្វើទុកក្នុងចិត្ត ដោយប្រការណាៗ, ជាកម្មដ្ឋាន ដែលស្ងប់រម្ងាប់ និងល្អិតសុខុម ដោយប្រការនោះៗ ។

តស្មា ឯត្ថ ពលវតី សតិ ច បញ្ញា ច ឥច្ឆិតព្វា។

ព្រោះហេតុនោះ ក្នុងអានាបានស្សតិកម្មដ្ឋាននេះ ព្រះយោគីគប្បី ចាំបាច់ប្រាថ្នានូវសតិ និងបញ្ញាដ៏មានកម្លាំង។

យថា ហិ មជ្ឈសាជកស្ស តុន្នការណាការេ សូចិបិ សុខុមា ឥច្ឆិតព្វា, សូចិថាសវេធនម្បិ តតោ សុខុមតរំ, ឯវមេវំ មជ្ឈសាជកសទិ-សស្ស ឥមស្ស កម្មដ្ឋានស្ស ភាវនាការេ សូចិបដិភាគា សតិបិ សូចិថាសវេធនបដិភាគា តំសម្បយុត្តា បញ្ញាបិ ពលវតី ឥច្ឆិតព្វា។

ឧបមា ប្រៀបដូចជា ក្នុងពេលដែលបុគ្គលធ្វើការដេរ នូវសំពត់សាដកសាច់ហ្មត់ ក៏បុគ្គលគប្បីប្រាថ្នា សូម្បីតែម្ជុលដែលតូចៗ , សូម្បីអំបោះចេសប្រើសម្រាប់ដោតចូល នូវប្រហោងនៃម្ជុលដែលតូចក្រៃលែងជាងនោះ ក៏បុគ្គលគប្បីប្រាថ្នាដែរ យ៉ាងណាមិញ, ក្នុងពេលចម្រើននូវកម្មដ្ឋាននេះ ដែលប្រាកដស្មើដោយសាដកសាច់ហ្មត់ ក៏គប្បីប្រាថ្នាទាំងសតិ ដែលប្រៀបធៀបដូចជាម្ជុលផង ទាំងបញ្ញាដែលសម្បយុត្តដោយសតិនោះផង ដែលប្រៀបដូចជាអំបោះចេសសំរាប់ដោតចូល នូវប្រហោងនៃម្ជុលផង ដែលមានកម្លាំងគឺព្រះយោគីគប្បីប្រាថ្នា ក៏យ៉ាងនោះដែរ ។

តាហិ ច បន សតិបញ្ញាហិ សមង្គាតតេន ភិក្ខុនា ន តេ អស្សាសបស្សាសា អញ្ញត្រ បកតិជុឝ្ឃោកាសា បរិយេសិតព្វា។

ភិក្ខុអ្នកប្រកបដោយសតិ និងបញ្ញាទាំងនោះ មិនគួរស្វែងរកនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនោះ ក្នុងទីដទៃក្រៅអំពីឱកាសដែលខ្យល់

ពាល់ត្រូវហើយៗ តាមប្រក្រតីនោះទេ ។

ឧបមា ដូចអ្នកដែលភ្ជួរស្រែ

យថា ហិ កស្សកោ ខេត្តំ កសិត្វា ពលីពទ្ទេ មុញ្ចិត្វា តោចរមុខេ កត្វា ឆាយាយ និសិន្នោ វិស្សមេយ្យ, អថស្ស តេ ពលីពទ្ទា វេគេន អដវិបវិសេយ្យុំ។

ប្រៀបដូចជា អ្នកស្រែបានភ្ជួរស្រែរួចហើយ គាត់បានលែងគោទឹមរបស់គាត់ដេញឲ្យមានមុខឆ្ពោះទៅកាន់ទីគោចរ(គឺទីដែលមានស្មៅ) ហើយក៏អង្គុយសម្រាកនៅក្រោមម្លប់, លំដាប់នោះ គោទឹមទាំងនោះ របស់អ្នកស្រែនោះ ក៏បានចូលទៅកាន់ដងព្រៃ ដោយលឿន ។

យោ ហោតិ ឆេកោ កស្សកោ, សោ បុន តេ គហេត្វា យោជេតុ-កាមោ ន តេសំ អនុបខំ កត្វា អដវិំ អាហិណ្ឌាតិ។

អ្នកស្រែ ដែលជាអ្នកឆ្នាត, កាលប្រាថ្នាចង់ចាប់នូវគោទាំងនោះ យកមកទឹមម្តងទៀត រមែងមិនចាំបាច់ ទៅកាន់ដងព្រៃតាមស្នាមជើងរបស់គោទាំងនោះទេ ។

អថ ខោ រស្មិញ្ច បតោទញ្ច គហេត្វា ឧជុកមេវ តេសំ និចាតនតិត្ថំ កត្វា និសីទតិ វា និបជ្ជតិ វា។

តាមការពិតអ្នកស្រែ គ្រាន់តែកាន់យកខ្សែ និងជន្លួញ ហើយដើរតម្រង់ត្រង់ ទៅកាន់កំពង់ទឹកដែលគោទាំងនោះ នៅផ្តុំជុំគ្នាតែម្តង ហើយអង្គុយ ឬក៏ដេកនៅរង់ចាំ។

អថ តេ គោណា ឯវសភាគំ ចរិត្វា និចាតនតិត្ថំ ឱតរិត្វា ន្ហត្វា ច បិវិត្វា ច បច្ចុត្តរិត្វា ឋិតេ ឯស្វា រស្មិយា ពន្ធិត្វា បតោទេន វិជ្ឈន្តោ អានេត្វា យោជេត្វា បុន កម្មំ ករោតិ ។

ក្រោយមក អ្នកស្រែនោះ ឃើញគោទាំងនោះត្រាច់ទៅ អស់ចំណែកនៃថ្ងៃហើយ ចុះកំពង់ទឹកជាទីប្រជុំគ្នា ត្រាំខ្លួនផង និងផឹកនូវទឹកផង ហើយឡើងមកឈរនៅ ក៏យកខ្សែចង ចាក់នឹងជន្លួញ នាំយកទៅទឹម ធ្វើការងារម្តងទៀតយ៉ាងណាមិញ ។

ឯវមេវំ តេន ភិក្ខុនា ន តេ អស្សាសបស្សាសា អញ្ញត្រ បកតិជុដ្ឋោកាសា បរិយេសិតព្វា។

ភិក្ខុនោះ មិនគប្បីស្វែងរកនូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនោះ ក្នុងទីដទៃក្រៅអំពីឱកាសដែលខ្យល់ពាល់ត្រូវហើយៗ តាមប្រក្រតី ក៏យ៉ាងនោះដូចគ្នា។

សតិរស្មឹ បន បញ្ញាបតោទញ្ច កហេត្វា បកតិជុដ្ឋោកាសេ ចិត្តំ បឋេត្វា មនសិការោ បវត្តេតព្ពោ។

គ្រាន់តែកាន់យកនូវខ្សែ គឺសតិ និងជន្លួញ គឺបញ្ញា ហើយតម្កល់នូវចិត្តទុកក្នុងឱកាសដែលខ្យល់ពាល់ត្រូវហើយៗ តាមប្រក្រតី ហើយញុាំងមនសិការ(គឺការធ្វើទុកក្នុងចិត្ត ត្រង់កន្លែងខ្យល់ពាល់ត្រូវនោះ) ឲ្យប្រព្រឹត្តិទៅ ។

ឯវំ ហិស្ស មនសិការោ ន ចិរស្សេវ តេ ឧបដ្ឋហន្តិ និចាតនតិត្តេ វិយ គោណា។

ដ្បិតថា កាលព្រះយោគាវចរនោះ ធ្វើទុកក្នុងចិត្តយ៉ាងនេះ មិនយូរប៉ុន្មានឡើយ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនោះ រមែងប្រាកដ ដូចជាគោទាំងឡាយដែលប្រាកដ ត្រង់កំពង់ទឹកដែលជាទីប្រជុំចុះ ដូច្នោះ ។

តតោ តេន សតិរស្មិយា ពន្ធិត្វា តស្មឹយេវ ឋានេ យោជេត្វា បញ្ញាបតោទេន វិជ្ឈន្តេន បុនប្បុនំ កម្មដ្ឋានំ អនុយុញ្ជិតព្ពំ។

តអំពីនោះមក ព្រះយោគីគប្បីយកខ្សែ គឺសតិ ចងទឹមក្នុងទីនោះ នុ៎ះឯង

ស្រេចហើយចាក់ដោយជន្ធញ គឺបញ្ញា ប្រកបនូវកម្មដ្ឋានរឿយៗ ក៏យ៉ាងនោះដែរ ។

តស្សេវមនុយុញ្ជតោ ន ចិរស្សេវ និមិត្តំ ឧបដ្ឋាតិ។

កាលព្រះយោគីនោះ ប្រកបយ៉ាងនេះ មិនយូរប៉ុន្មាន និមិត្ត រមែងប្រាកដឡើង ។

ឧគ្គហនិមិត្ត និងបដិភាគនិមិត្ត រមែងប្រាកដ ផ្សេងៗ គ្នា

"តំ បនេតំ ន សព្ពេសំ ឯកសទិសំ ហោតិ, អបិច ខោ កស្សចិ សុខសមុស្សាំ ឧប្បាទយមានោ តូលបិចុ វិយ កប្បាសបិចុ វិយ វាតជាវ វិយ ច ឧបដ្ឋាតី"តិ ឯកច្ចេ អាហុ។

ព្រះអាចារ្យទាំងឡាយ ពួកខ្លះ លោកបានពោលថា "និមិត្តនេះ មិនមែនជានិមិត្ត ដែលប្រាកដស្មើដូចគ្នាតែមួយ ដល់ព្រះយោគីទាំងពួងឡើយ, ប៉ុន្តែថា និមិត្តនោះ រមែងប្រាកដ ដល់ព្រះយោគីពួកខ្លះ ប្រៀបដូចជា ប៉ុយគក៏មាន ដូចជាប៉ុយកប្បាសក៏មាន ដូចជាខ្សែខ្យល់ដែលញាំងសុខសម្ផស្ស ឲ្យកើតឡើង បែបនេះក៏មាន" ។

អយំ បន អដ្ឋកថាសុ វិនិច្ឆយោ –

*ចំណែក **សេចក្តីវិនិច្ឆ័យ ក្នុងព្រះអដ្ឋកថាទាំងឡាយ** នឹងមានដូចតទៅនេះគឺ៖*

ឥធញ្ហិ កស្សចិ តារករូបំ វិយ មណិតុឌ្ឌិកា វិយ មុត្តាតុឌ្ឌិកា វិយ ច,

និមិត្តនេះ រមែងប្រាកដ ដល់ព្រះយោគីពួកខ្លះ ដូចជារូបផ្កាយក៏មាន ដូចជាដុំកែវមណីក៏មាន ដូចជាដុំកែវមុក្តាក៏មាន,

កស្បចិ ទរសម្ជស្បំ ហុត្វា កប្បាសដ្ឋិ រិយ ជារុសារស្ទចិ រិយ ច,

សម្រាប់ព្រះយោគីពួកខ្ទះ និមិត្ត មានសម្ជស្សគ្រោតគ្រាត(គឺរឹង) រមែងប្រាកដ ដូចជាគ្រាប់កប្បាសក៏មាន ដូចជារនុកឈើដែលមានខ្ទឹមក៏មាន,

កស្បចិ ជីយចាមជ្ជសុត្តំ រិយ កុសុមជាមំ រិយ ជូមសិទា រិយ ច,

សម្រាប់ព្រះយោគីពួកខ្ទះ រមែងប្រាកដ ដូចជាខ្សែសង្វារដ៏រៃងក៏មាន ដូចជាកម្រងផ្កាក៏មាន ដូចជាអណ្តាតផ្សែងក៏មាន,

កស្បចិ រិត្ទតំ មក្កដកសុត្តំ រិយ រលាហកបដលំ រិយ បជុមបុប្ជំ រិយ រថចក្ក្ពំ រិយ ចន្ទមណ្ឌលំ រិយ ស្ទរិយមណ្ឌលំ រិយ ច ឧបដ្ឋាតិ,

សម្រាប់ព្រះយោគីពួកខ្ទះ រមែងប្រាកដ ដូចជាសរសៃពីងពាងដែលលាតហើយក៏មាន ដូចជាផ្ទាំងពពកក៏មាន ដូចជាផ្កាឈូកក៏មាន ដូចជាកង់រថក៏មាន ដូចជាមណ្ឌលនៃព្រះចន្ទក៏មាន និងដូចជាមណ្ឌលនៃព្រះអាទិត្យក៏មាន,

តញ្ច បនេតំ យថា សម្ពហុលេសុ ភិក្ខូសុ សុត្តន្តំ សជ្ឈាយិត្វា និសិន្នេសុ ឯកេន ភិក្ខុនា "តុម្ហាកំ កីជិសំ ហុត្វា ឥជំ សុត្តំ ឧបដ្ឋាតី"តិ រុត្តេ ឯកោ "មយ្ហំ មហតី បព្ទតេយ្យា នជី រិយ ហុត្វា ឧបដ្ឋាតី"តិ អាហ។

ឯកម្មដ្ឋាននេះ តែមួយគត់ រមែងប្រាកដ ដោយសេចក្តីផ្សេងៗគ្នា ក៏ព្រោះភាពនៃព្រះយោគីមានសញ្ញាផ្សេងៗគ្នា ប្រៀបដូចជា កាលព្រះភិក្ខុទាំងឡាយច្រើនរូប អង្គុយស្វាធ្យាយនូវព្រះសូត្រ កាលភិក្ខុមួយរូប បានសួរថា "ព្រះសូត្រនេះ រមែងប្រាកដដល់លោកអ្នកទាំងឡាយ ដូចជាអ្វីខ្ទះ ? " ដូច្នេះ, ភិក្ខុមួយរូបក៏ឆ្ទើយតបថា "រមែងប្រាកដដល់ខ្ញុំ ដូចជាស្ទឹងដ៏ធំដែលហូរចុះអំពីភ្នំ" ដូច្នេះ។

អបរោ "មយ្ហំ ឯកា រនរាជិ រិយ"។

ភិក្ខុដទៃទៀត ឆ្ទើយតបថា "រមែងប្រាកដដល់ខ្ញុំ ដូចជាដងព្រៃមួយ" ។

អញ្ញោ "មយ្ហំ ឯកោ សីតច្ឆាយោ សាទាសម្បន្នោ ជលភារភរិតោ

រុក្ខោ វិយា"តិ។

ភិក្ខុមួយរូបទៀត ឆ្លើយតបថា "សម្រាប់រូបខ្ញុំ រមែងប្រាកដ ដូចជាដើមឈើមួយដើម ដែលពោរពេញទៅដោយផ្លែ និងផ្កា ដែលបរិបូរទៅដោយមែក និងមានម្លប់ដ៏ត្រជាក់" ដូច្នេះ ។

តេសញ្ហិ តំ ឯកមេវ សុត្តំ សញ្ញាជានតាយ ជានតោ ឧបដ្ឋាតិ។

ពិតមែន ព្រះសូត្រនេះតែមួយគត់ប៉ុណ្ណោះ រមែងប្រាកដ ដល់ភិក្ខុទាំងឡាយនោះ មានសេចក្តីផ្សេងៗគ្នា ព្រោះភិក្ខុទាំងនោះមានសញ្ញាផ្សេងៗគ្នាយ៉ាងណាមិញ។

ឯវំ ឯកមេវ កម្មដ្ឋានំ សញ្ញាជានតាយ ជានតោ ឧបដ្ឋាតិ។

កម្មដ្ឋាននេះតែមួយប៉ុណ្ណោះ រមែងប្រាកដ ដល់ភិក្ខុទាំងឡាយនោះ មានសេចក្តីផ្សេងៗគ្នា ព្រោះសេចក្តីផ្សេងគ្នានៃសញ្ញា ក៏យ៉ាងនោះដូចគ្នា ។

សញ្ញជញ្ហិ ឯតំ សញ្ញានិទានំ សញ្ញាបភវំ, តស្មា "សញ្ញាជានតាយ ជានតោ ឧបដ្ឋាតី"តិ វេទិតព្ពំ។

ពិតមែន កម្មដ្ឋាននេះ កើតឡើងអំពីសញ្ញា មានសញ្ញាជាហេតុ និងមានសញ្ញាជាដែនកើត, ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា "រមែងប្រាកដ ដោយសេចក្តីផ្សេងៗគ្នា ព្រោះភាវៈនៃព្រះយោគីទាំងនោះ មានសញ្ញាផ្សេងៗគ្នា" ។

ឯវំ ឧបដ្ឋិតេ បន និមិត្តេ តេន កិក្ខុនា អាចរិយស្ស សន្តិកំ គន្ត្វា អារោចេតព្ពំ "មយ្ហំ, ភន្តេ, ឯវរូបំ នាម ឧបដ្ឋាតី"តិ។

កាលនិមិត្ត ប្រាកដហើយយ៉ាងដូច្នេះ ភិក្ខុនោះ ក៏គប្បីទៅកាន់សំណាក់របស់គ្រូបាអាចារ្យ ហើយប្រាប់លោកថា "បពិត្រព្រះអាចារ្យដ៏ចម្រើន, និមិត្តមានរូបសភាពបែបនេះ រមែងប្រាកដដល់ខ្ញុំ" ។

អាចរិយេន បន "និមិត្តមិទំ, អាវុសោ, កម្មដ្ឋានំ បុនប្បុនំ មនសិ-

កភេហិ សប្បុរិសា"តិ វត្តព្ពោ។

ចំណែកគ្រូបាអាចារ្យ គប្បីប្រាប់ថា "ម្នាលអាវុសោ នេះគឺជានិមិត្ត, នែ៎លោកសប្បុរស អ្នកចូរធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាននេះរឿយៗ ចុះណា" ។

អថានេន និមិត្តេយេវ ចិត្តំ បឋេតព្ពំ។

លំដាប់នោះ ព្រះយោគីភិក្ខុរូបនេះ គប្បីតម្កល់ចិត្តទុកក្នុងនិមិត្តហ្នឹងឯង ចុះ។

ឯវមស្សាយំ ឥតោ បភុតិ បឋមាវសេន ភាវនា ហោតិ។

ភិក្ខុនេះ រមែងកើតភាវនា(គឺភាវនា រមែងសម្រេច) ដោយអំណាចនៃបឋមា(គឺការតម្កល់ចិត្តមាំ) ដែលចាប់ផ្តើមតាំងអំពីនេះទៅ យ៉ាងនេះឯង ។

វុត្តញ្ហេតំ ចោរាណេហិ –

សមដូចព្រះបុរាណាចារ្យទាំងឡាយ លោកបានពោលថា៖

"និមិត្តេ បឋមំ ចិត្តំ, ជាជាការំ វិភាវយំ;

ឱភេ អស្សាសបស្សាសេ, សកំ ចិត្តំ និពន្ធតី"តិ[๔๕]។

"អ្នកមានប្រាជ្ញា កាលតម្កល់នូវចិត្ត ទុកក្នុងនិមិត្ត ញ៉ាំងអាការៈផ្សេងៗ ឲ្យវិនាសទៅ រមែងចងក្រៀកទុកនូវចិត្តរបស់ខ្លួន ជាមួយខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ" ដូច្នេះ ។

តស្សេវំ និមិត្តបដ្ឋានតោ បភុតិ នីវរណានិ វិក្ខម្ភិតានេវ ហោន្តិ, កិលេសា សន្និសិន្នាវ, ចិត្តំ ឧបចារសមាធិនា សមាហិតមេវ។

ចាប់ផ្តើមអំពីការប្រាកដនៃនិមិត្តយ៉ាងនេះហើយ នីវរណធម៌ទាំងឡាយដែលជាធម្មជាត គឺភិក្ខុនោះបានគ្របសង្កត់ហើយយ៉ាងពិតប្រាកដ, កិលេសទាំងឡាយសូប់ស្ងៀមហើយ, ចិត្ត ក៏តម្កល់នៅមាំ ដោយឧបចារនៃសមាធិ ។

អថានេន តំ និមិត្តំ នេវ វណ្ណតោ មនសិ កាតព្ពំ, ន លក្ខណតោ បច្ចវេក្ខិតព្ពំ,

---

๔๕ (បារ. អដ្ឋ. ๒.๑๖๕; វិសុទ្ធិ. ๑.๒๓๒) ។

លំដាប់នោះ ព្រះយោគីនេះ មិនគប្បីធ្វើទុកក្នុងចិត្ត នូវនិមិត្តនោះដោយ ពណ៌, មិនគប្បីពិចារណា នូវនិមិត្តនោះដោយលក្ខណៈទេ,

អបិច ខោ ខត្តិយមហេសិយា ចក្ក្ការត្តិកញ្ញោ វិយ កស្សកេន សាលិយវកញ្ញោ វិយ ច អាវាសាជីនិ សត្ត អសប្បាយានិ វជ្ជេត្វា តានេវ សត្ត សប្បាយានិ សេវន្តេន សាធុកំ រក្ខិតព្វំ។

ក៏ប៉ុន្តែ ព្រះយោគីគប្បីវៀរ នូវអសប្បាយទាំង ៧ យ៉ាង ដែលមានទី អាវាសជាដើម ហើយសេពនូវសប្បាយទាំង ៧ យ៉ាងនោះ នុ៉ះឯង គប្បីរក្សាទុក(នូវនិមិត្ត)ឲ្យបានល្អ ប្រៀបដូចជា ព្រះខត្តិយមហេសីក្សត្រិយ៍ ដែលថែរក្សាព្រះរាជឱរសនៅក្នុងព្រះគភ៌ ដែលនឹងបានជាស្តេចចក្រពត្តិ និងប្រៀបដូចជា អ្នកស្រែដែលថែរក្សានូវស្រូវសាលីផើម និងស្រូវដំណើប ក៏ដូច្នោះដែរ ។

អថ នំ ឯវំ រក្ខិត្វា បុនប្បុនំ មនសិការវសេន វុទ្ធឹ វិរូឡ្ហឹ កមយិត្វា ឧសវិធំ អប្បនាកោសល្ជំ សម្បាទេតព្វំ, វីរិយសមតា យោជេតព្វា។

បន្ទាប់មក លុះព្រះយោគី បានរក្សានូវនិមិត្តនោះ យ៉ាងនេះហើយ ក៏គប្បីធ្វើឲ្យដល់ នូវសេចក្តីចម្រើនទូលំទូលាយ ដោយអំណាចនៃកិរិយាធ្វើទុកក្នុងចិត្ត ជារឿយៗ ហើយញ្ចាំងអប្បនាកោសល្ជទាំង ១០ ប្រការ ឲ្យដល់ព្រម, ហើយប្រកបនូវសេចក្តីព្យាយាមឲ្យបានល្អប្រពៃ (គឺធ្វើឲ្យស្មើៗគ្នានូវសេចក្តីព្យាយាម) ។

តស្សេវំ ឃដេន្តស្ស វិសុទ្ធិមក្ខេ វុត្តានុក្ក្រមេន តស្មឹ និមិត្តេ ចតុក្ក បញ្ចកជ្ឈានានិ និព្ធត្តន្តិ។

កាលព្រះយោគីភិក្ខុនោះ បានព្យាយាមយ៉ាងនេះ ឈានក្រុម ៤ និងឈានក្រុម ៥ រមែងកើតឡើង ក្នុងនិមិត្តនោះ ទៅតាមលំដាប់នៃពាក្យដែលបានពោលទុកមកហើយ ក្នុងគម្ពីរវិសុទ្ធិមគ្ត នៃបឋវីកសិណហ្នឹងឯង ។

ចប់ វិធីចម្រើនសមថ:

វិធីចម្រើនវិបស្សនា បន្តអំពីសមថ:

ការកំណត់ នាម និង រូប

ឯវំ និព្វត្តចតុក្ក្ជ្ឌបញ្ចកជ្ឌានោ បនេត្ត ភិក្ខុ សល្ខក្ខណាវិវដ្ត-នាវសេន កម្មដ្ឋានំ វឌ្ឍេត្វា ចារិសុទ្ធឹ បត្តុកាមោ តទេវ ឈានំ បញ្ចហា-កាវេហិ វសិប្បត្តំ បកុណំ កត្វា នាមរូបំ វវត្តបេត្វា វិបស្សនំ បដ្ឋបេតិ។

*នៅក្នុងទីនេះ ភិក្ខុអ្នកមាន ចតុត្តជ្ឌាន និងមានបញ្ចមជ្ឌាន បានកើតឡើងហើយ យ៉ាងនេះ ជាអ្នកប្រាថ្នានឹងញ៉ាំងកម្មដ្ឋានឲ្យចម្រើន ដោយអំណាចនៃ**សល្ខក្ខណា**(គឺវិបស្សនា) និង**វិវដ្ត**នា(គឺមគ្គ) ហើយដល់នូវសេចក្តីបរិសុទ្ធិ(គឺផល) រមែងធ្វើនូវឈាននោះ ឲ្យដល់នូវភាពស្ទាត់ជំនាញ ដោយអាការ:វសីទាំងឡាយ ៥ យ៉ាង ឱ្យបានស្ទាត់ជំនាញ ហើយក៏តាំងផ្តើមនូវវិបស្សនា កំណត់នូវនាម និងរូប តទៅ។*

កថំ?

សួរថា តើតាំងផ្តើម ដូចម្តេច?

សោ ហិ សមាបត្តិតោ វុដ្ឋាយ អស្សាសបស្សាសានំ សមុទយោ ការជកាយោ ច ចិត្តញ្ចាតិ បស្សតិ។

*ធ្វើយថា ព្រះយោគាវចរនោះ កាលចេញចាកសមាបត្តិហើយ រមែងឃើញថា **ការជកាយ** និងចិត្ត ជាដែនកើតឡើង នៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងឡាយ។*

យថា ហិ កម្មារកក្តរិយា ជមមានាយ ភស្តញ្ច បុរិសស្ស ច តជ្ជំ វាយាមំ បដិចូ វាតោ សញ្ចរតិ, ឯវមេវំ កាយញ្ច ចិត្តញ្ច បដិចូ អស្សាសប-ស្សាសាតិ។

ឧបមាដូចជា កាលស្នប់នៃជាងមាស គឺបុគ្គលសប់ ខ្យល់ដែលអាស្រ័យ ដោយស្នប់ផង ដោយសេចក្តីព្យាយាមផង ដ៏សមគួរដល់ស្នប់នោះ នៃបុរសផង រមែងសញ្ជរទៅមក យ៉ាងណាមិញ, ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ទាំងឡាយ រមែងសញ្ជរទៅមកបាន ក៏ព្រោះអាស្រ័យនូវកាយ និងចិត្ត ក៏យ៉ាងនោះដូចគ្នា ។

តតោ អស្សាសបស្សាសេ ច កាយញ្ច រូបន្តិ, ចិត្តញ្ច តំសម្បយុត្តេ ច ធម្មេ អរូបន្តិ វវត្ថបេតិ។

តអំពីនោះមក ព្រះយោគី រមែងកំណត់នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ និងកាយផង ថា ជារូប, កំណត់ចិត្ត និងធម៌ ដែលសម្បយុត្តជាមួយចិត្តនោះ ថា ជានាម ។

ឯវំ នាមរូបំ វវត្ថបេត្វា តស្ស បច្ចយំ បរិយេសតិ។

កាលព្រះយោគីបានកំណត់នូវនាម និងរូប យ៉ាងនេះហើយ ក៏រមែងស្វែងរកបច្ច័យនៃនាម និងរូបនោះ ។

បរិយេសន្តោ ច តំ ឯស្វា តីសុបិ អទ្ធាសុ នាមរូបស្ស បវត្តឹ អារព្ភ កង្ខំ វិតរតិ។

ព្រះយោគី កាលស្វែងរកឃើញនូវបច្ច័យនៃនាមនិងរូបនោះបានហើយ ក៏រមែងឆ្លងផុតនូវសេចក្តីសង្ស័យ ហើយប្រារព្ធនូវកិរិយាប្រព្រឹត្តិទៅ របស់នាម និងរូប ក្នុងកាលទាំងឡាយ ៣ មានអតីត អនាគត និងបច្ចុប្បន្ន ។

វិតិណ្ណកង្ខោ កលាបសម្មសនវសេន "អនិច្ចំ ខុក្ខមនត្តា"តិ តិលក្ខណំ អារោបេត្វា ឧឌយព្វយានុបស្សនាយ បុព្វភាគេ ឧប្បន្នេ ឱភាសាទយោ ឧស វិបស្សនុបក្កិលេសេ បហាយ ឧបក្កិលេសវិមុត្តំ ឧឌយព្វយានុបស្សនាញាណំ "មគ្គោ"តិ វវត្ថបេត្វា ឧឌយំ បហាយ ភង្គានុបស្សនំ បត្វា និរន្តរំ ភង្គានុបស្សនេន ភយតោ ឧបដ្ឋិតេសុ

សព្វសជ្ជាវេសុ និព្វិន្ទន្តោ វិរជ្ជន្តោ វិមុចូន្តោ យថាក្ការមេន ចត្តាវោ អរិយមត្តេ ចាបុណិត្វា អរហត្តផលេ បតិដ្ឋាយ ឯកូនវីសតិភេជស្ស បច្ចវេក្ខណាញាណស្ស បរិយន្តំ បត្តោ សដេវកស្ស លោកស្ស អក្តជក្ខិណេយ្យោ ហោតិ ។

*ភិក្ខុ ជាអ្នកមានសេចក្តីសង្ស័យដែលធ្ងងផុតហើយ លើកឡើង(នូវនាម និងរូប) កាន់ត្រៃលក្ខណ៍ ថា "**អនិចូំ ជុក្ខូំ អនត្តា**" ដោយអំណាចនៃ ការពិចារណានូវ **រូបកលាប** ហើយលះបង់ នូវ**វិបស្សនូបក្កិលេស**ទាំង ១០ ប្រការ ដែលមាន **ឱភាស** ជាដើម ដែលកើតឡើង ក្នុងបុព្វភាគ នៃ**ឧជយព្វ-យានុបស្សនាញាណ**(គឺ កិរិយាពិចារណាឃើញនូវការកើត និងការរលត់) កំណត់នូវ **ឧជយព្វយានុបស្សនាញាណ** ដែលផុតចាកឧបក្កិលេស ទាំងឡាយ ថា "ជា **មត្ត**" ហើយលះបង់ នូវការកើតឡើង ហើយដល់នូវ **ភជ្ជានុបស្សនា** (គឺ កិរិយាពិចារណាឃើញ នូវការបែកធ្ងាយ) ហើយក៏ នឿយណាយ ធុញទ្រាន់ ក្នុងសង្ខារទាំងពួង ដែលប្រាកដឡើងដោយភាពគួរឱ្យ ភ័យខ្លាច ដោយការពិចារណាឃើញនូវការរលត់ មិនមានចន្ទោះ បន្ទុះអរិយមគ្គ ទាំង ៤ តាមលំដាប់តាំងនៅស៊ីប់ក្នុងអរហត្តផលដល់នូវទីបំផុតនៃ **បច្ចវេក្ខណញ្ញាណ**ដែលមាន ១៩ ប្រភេទ រមែងជាអគ្គទក្ខិណេយ្យដ៏ប្រសើរ នៃលោក ព្រមទាំងទេវលោក ។*

ឯត្តាវតា ចស្ស កណនំ អាជឺ កត្វា បដិបស្សនាបរិយោសានា អានាចានស្សតិសមាធិភាវនា សមត្តា ហោតីតិ។

*ក៏ការចម្រើនអានាបានស្សតិសមាធិភាវនា របស់យោគីភិក្ខុនោះ ដែល ធ្វើការរាប់ ជាខាងដើម មាន**បដិបស្សនា**ជាទីបំផុត ជាធម្មជាតិចប់ស្រេចហើយ ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។*

អយំ សព្វាការតោ បឋមចតុក្ការណ្ណនា។

នេះជាការពណ៌នា នូវចតុក្កៈ ទី ១ ដោយអាការៈទាំងពួង ។

ចប់ ក្នុងចតុក្កៈ ទី ១

ក្នុងចតុក្ក ទី ២, ៣, ៤

ឥតរេសុ បន តីសុ ចតុក្កេសុ យស្មា វិសុំ កម្មដ្ឋានភាវនានយោ នាម នត្ថិ, តស្មា អនុបទវណ្ណនានយេនេវ តេសំ ឯវមត្ថោ វេទិតព្ពោ។

ចំណែកក្នុងចតុក្កៈទាំង ៣ ក្រៅអំពីនេះ ឈ្មោះថា នយនៃការចម្រើនកម្មដ្ឋានដែលផ្សេងគ្នាគឺមិនមានទេ(គឺដូចតែគ្នា) ព្រោះហេតុណា, ព្រោះហេតុនោះ គប្បីជ្រាបនូវសេចក្តីនៃចតុក្កៈទាំង ៣(គឺទី ២,៣,៤) នោះយ៉ាងនេះឯង តាមន័យនៃការពណ៌នាអនុបទ(គឺទៅតាមលំដាប់នៃបទ)ផងចុះ។

ចតុក្កទី ២ វេទនានុបស្សនា

"បីតិប្បដិសំវេទី"តិ បីតឺបដិសំវិទិតំ កភោន្តោ ចាកដំ កភោន្តោ អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតិ។

*បទថា **"បីតិប្បដិសំវេទី** ប្រែថា **ដឹងច្បាស់នូវបីតិ"** សេចក្តីថា ភិក្ខុសិក្សាថា "អាត្មាអញកាលធ្វើនូវបីតិ ឲ្យជាបីតិគឺខ្លួនដឹងច្បាស់ហើយ គឺធ្វើឲ្យជ្រាកដ ទើបដកដង្ហើមចូល ដកដង្ហើមចេញ ។*

តត្ថ ទ្វីហាការេហិ បីតិ បដិសំវិទិតា ហោតិ អារម្មណតោ ច អសម្មោហតោ ច។

*ត្រង់បទថា **"បីតិប្បដិសំវេទី"** នោះ មានសេចក្តីថា បីតិ ជាធម្មជាត គឺភិក្ខុដឹងច្បាស់ហើយដោយអាការៈទាំងឡាយ ២ យ៉ាង គឺដោយអារម្មណ៍ ១ និង

ដោយអសម្មោហ ១ ។

កថំ អារម្មណតោ បីតិ បដិសំវិទិតា ហោតិ ។

*សួរថាបីតិជាធម្មជាតគឺកិក្ខុដឹងច្បាស់ហើយ **ដោយអារម្មណ៍**តើដូចម្តេច?*

សប្បីតិកេ ទ្វេ ឈានេ សមាបជ្ជតិ, តស្ស សមាបត្តិក្ខណេ ឈានបដិលាភេន អារម្មណតោ បីតិ បដិសំវិទិតា ហោតិ អារម្មណស្ស បដិសំវិទិតត្តា។

ធ្វើយថា កិក្ខុរមែងចូលឈានទី ២ ដែលប្រកបដោយបីតិ, ព្រោះកិរិយាបាននូវឈានទី២ គឺសភាវៈបីតិ ជាធម្មជាដែលកិក្ខុនោះដឹងច្បាស់ហើយដោយអារម្មណ៍ ព្រោះតែនៃអារម្មណ៍ ជាធម្មជាត ដែលកិក្ខុនោះដឹងច្បាស់ហើយ ក្នុងខណៈដែលចូលសមាបត្តិរបស់កិក្ខុនោះ ។

កថំ អសម្មោហតោ ។

*សួរថា បីតិ ជាធម្មជាត គឺកិក្ខុនោះ ដឹងច្បាស់ហើយ **ដោយអសម្មោហ** តើដូចម្តេចទៅ?*

សប្បីតិកេ ទ្វេ ឈានេ សមាបជ្ជិត្វា វុដ្ឋាយ ឈានសម្បយុត្តំ បីតឹ ខយតោ វយតោ សម្មសតិ, តស្ស វិបស្សនាក្ខណេ លក្ខណបដិវេធេន អសម្មោហតោ បីតិ បដិសំវិទិតា ហោតិ។

ធ្វើយថា កិក្ខុចូលឈានទី ២ ប្រកបដោយបីតិ ចេញចាកហើយ រមែងពិចារណាបីតិ ដែលសម្បយុត្តដោយឈាន ដោយសេចក្តីអស់ទៅ ដោយសេចក្តីសូន្យទៅ, បីតិ ជាបីតិ គឺកិក្ខុនោះ ដឹងច្បាស់ហើយ ដោយអសម្មោហៈ ព្រោះកិរិយាចាក់ធ្លុះនូវលក្ខណៈ ក្នុងខណៈនៃវិបស្សនារបស់កិក្ខុនោះ ។

ឯតេនេវ នយេន អវសេសបទានិបិ អត្ថតោ វេទិតព្វានិ។

សូម្បីបទដ៏សេសទាំងឡាយ ក៏បណ្ឌិតគប្បីជ្រាប ដោយសេចក្តីតាមន័យ

នេះឯង ។

ឥទំ បនេត្ថ វិសេសមត្តំ –

ក្នុងទីនេះ គ្រាន់តែជាសេចក្តីប្លែកគ្នា ដូចតទៅគឺ៖

តិណ្ណំ ឈានានំ វសេន សុខបដិសំវិទិតា ហោតិ។

ភាពនៃព្រះយោគី ជាអ្នកដឹងច្បាស់នូវសុខ បណ្ឌិតគប្បីជ្រាប ដោយអំណាចនៃឈានទី ៣ ។

ចតុន្នម្បិ ឈានានំ វសេន ចិត្តសង្ខារបដិសំវិទិតា វេទិតព្វា។

ភាពនៃព្រះយោគី ជាអ្នកដឹងច្បាស់ នូវចិត្តសង្ខារ បណ្ឌិតគប្បីជ្រាប ដោយអំណាចឈានទី ៤ ។

"ចិត្តសង្ខារោ"តិ វេទនាសញ្ញាក្ខន្ធា។

*ពាក្យថា "**ចិត្តសង្ខារ**" បានដល់ វេទនាខន្ធ និងសញ្ញាខន្ធ ។*

"បស្សម្ភយំ ចិត្តសង្ខារ"ន្តិ ឱឝ្បវិកំ ឱឝ្បវិកំ ចិត្តសង្ខារំ បស្សម្ភេន្តោ, និរោធេន្តោតិ អត្ថោ។

*ក្នុងពាក្យថា "**បស្សម្ភយំ ចិត្តសង្ខារំ**" ប្រែថា **រម្ងាប់ចិត្តសង្ខារ** បានសេចក្តីថា ការរម្ងាប់, គឺ ការរំលត់នូវចិត្តសង្ខារ ដែលគ្រោតគ្រាតៗ ។*

សោ វិត្ថារតោ កាយសង្ខារេ វុត្តនយេន វេទិតព្វោ។

បណ្ឌិតគប្បីជ្រាប នូវសេចក្តីរលត់នូវចិត្តសង្ខារនោះ ដោយសេចក្តីពិស្តារ តាមន័យដែលលោកបានពោលហើយ ក្នុងកាយសង្ខារហ្នឹងឯង ។

អបិចេត្ថ បីតិបដេ បីតិសីសេន វេទនា វុត្តា, សុខបដេ សរូបេនេវ វេទនា។

*មួយទៀត បណ្តាបទទាំងនោះ **ក្នុងបទថា បីតិ** លោកពោលនូវវេទនា*

ធ្វើជាប្រធានរបស់បីតិ, លោកពោលនូវវេទនា ដោយសរុបទាំងខ្លួនឯងផង ***ក្នុងបទថា សុខៈ*** *នេះ ។*

ទ្វីសុ ចិត្តសង្ខារបទេសុ "សញ្ញា ច វេទនា ច ចេតសិកា, ឯតេ ធម្មា ចិត្តបដិពទ្ធា ចិត្តសង្ខារា"តិ(๘๖) វចនតោ សញ្ញាសម្បយុត្តា វេទនាតិ ។

ក្នុងបទថា ចិត្តសង្ខារទាំង ๒ លោកពោលនូវវេទនា ដែលប្រកបព្រមហើយ ដោយសញ្ញា ព្រោះបាលីពោលថា " សញ្ញា និង វេទនា ជាតួចេតសិក, ធម៌ទាំងនោះ ជាប់ចំពោះដោយចិត្ត ឈ្មោះថា ចិត្តសង្ខារ " ដូច្នេះ ។

ឯវំ វេទនានុបស្សនានយេន ឥធំ ចតុក្កំ ភាសិតន្តិ វេទិតព្វំ។

បណ្ឌិតគប្បីជ្រាបថា ចតុក្កៈនេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយតាមន័យនៃវេទនានុបស្សនា យ៉ាងនេះឯង ។

វេទនានុបស្សនា ចតុក្កៈទី ๒ ចប់

ចតុក្កទី ๓ ចិត្តានុបស្សនា

តតិយចតុក្កេបិ ចតុន្នំ ឈានានំ វសេន ចិត្តបដិសំវិទិតា វេទិតព្វា។

សូម្បីក្នុងចតុក្កៈ ទី ๓ បណ្ឌិតគប្បីជ្រាបនូវសភាព នៃព្រះយោគីជាអ្នកដឹងច្បាស់នូវចិត្ត ដោយអំណាចនៃឈានទាំង ๔ ប្លាយ ๔ ។

"អភិប្បមោទយំ ចិត្ត"ន្តិ ចិត្តំ មោទេន្តោ បមោទេន្តោ ហាសេន្តោ បហាសេន្តោ អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតិ។

---

๘๖ (បដិ. ម. ๑.๑๗๔; ម. និ. ๑.๔๖๓) ។

*២បទថា "**អភិប្បមោទយំ ចិត្តំ** ប្រែថា **ញុាំងចិត្តឲ្យរីករាយ**" សេចក្តីថា ភិក្ខុសិក្សាថា អាត្មាអញ កាលញុាំងចិត្តឲ្យរីករាយ គឺ ឲ្យរីករាយទូទៅ ឲ្យស្រស់ស្រាយ ឲ្យស្រស់ស្រាយទូទៅ ខណៈដកដង្ហើមចូល និងដកដង្ហើមចេញ។*

តត្ថ ទ្វីហាការេហិ អភិប្បមោទោ ហោតិ សមាធិវសេន ច វិបស្សនាវសេន ច។

*ត្រង់បទថា "**អភិប្បមោទយំ ចិត្តំ** ប្រែថា **ញុាំងចិត្តឲ្យរីករាយ**" នោះ សេចក្តីត្រេកអរដ៏ក្រៃលែង រមែងមាន ដោយអាការៈ ២ យ៉ាង គឺ ដោយអំណាចនៃសមាធិ ១ និងដោយអំណាចនៃវិបស្សនា ១។*

កថំ *សមាធិវសេន*? ។

*សួរថា សេចក្តីត្រេកអរដ៏ក្រៃលែង **ដោយអំណាចនៃសមាធិ** តើយ៉ាងដូចម្តេច?*

សប្បីតិកោ ទ្វេ ឈានេ សមាបជ្ជតិ, សោ សមាបត្តិក្ខណេ សម្បយុត្តាយ បីតិយា ចិត្តំ អាមោទេតិ បមោទេតិ។

ធ្វើយថា ភិក្ខុចូលឈានទី ២ ដែលប្រកបដោយបីតិ, ភិក្ខុនោះ ញុាំងចិត្តឲ្យរីករាយ ឲ្យរីករាយទូទៅ ដោយបីតិ ដែលសម្បយុត្តធម៌នឹងគ្នា ក្នុងខណៈដែលចូលសមាបត្តិ។

កថំ *វិបស្សនាវសេន* ។

*សួរថា សេចក្តីត្រេកអរដ៏ក្រៃលែង **ដោយអំណាចនៃវិបស្សនា** តើដូចម្តេច?*

សប្បីតិកោ ទ្វេ ឈានេ សមាបជ្ជិត្វា វុដ្ឋាយ ឈានសម្បយុត្តំ បីតឹ ខយតោ វយតោ សម្មសតិ។

ធ្វើយថា ភិក្ខុចូលឈានទី ២ ដែលប្រកបដោយបីតិ បានចេញចាកហើយ

ពិចារណានូវបីតិ ដែលសម្បយុត្តដោយឈាន ដោយសេចក្តីអស់ទៅ ដោយសេចក្តីសូន្យទៅ។

ឯវំ វិបស្សជាក្ខណោ ឈានសម្បយុត្តំ បីតឹអារម្មណំ កត្វា ចិត្តំ អាមោទេតិ បមោទេតិ។

ភិក្ខុនោះ ធ្វើបីតិ ដែលសម្បយុត្តហើយដោយឈានឲ្យមកជាអារម្មណ៍ ក្នុងខណៈនៃវិបស្សនាយ៉ាងនេះហើយ ញុំាងចិត្តឲ្យរីករាយ ឲ្យរីករាយទូទៅ។

ឯវំ បដិបន្នោ "អភិប្បមោទយំ ចិត្តំ អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតី"តិ វុច្ចតិ។

ព្រះយោគីអ្នកប្រតិបត្តិយ៉ាងនេះ លោកហៅថា "រមែងសិក្សាថា អាត្មាអញ នឹងញុំាងចិត្តឲ្យរីករាយក្រៃលែង ដកដង្ហើមចូល និងដកដង្ហើមចេញ"។

"សមាទហំ ចិត្ត"ន្តិ បឋមជ្ឈានាទិវសេន អារម្មណេ ចិត្តំ សមំ អាទហាន្តោ សមំ បវេន្តោ,

*២បទ ថា "**សមាទហំ ចិត្តំ** ប្រែថា **តម្កល់ចិត្តទុក**" បានសេចក្តីថា ព្រះយោគី កាលតម្កល់ នូវចិត្តឲ្យស្មើ គឺ តាំងចិត្តឲ្យស្មើ ក្នុងអារម្មណ៍ ដោយអំណាចនៃឈាន ដែលមានបឋមឈាន ជាដើម,*

តានិ វា បន ឈានានិ សមាបជ្ជិត្វា វុដ្ឋាយ ឈានសម្បយុត្តំ ចិត្តំ ខយ តោ វយតោ សម្មសតោ វិបស្សជាក្ខណោ លក្ខណាបដិវេធេន ឧប្បជ្ជតិ ខណិកចិត្តេកគ្គតា,

ឬពុំនោះសោត ចូលឈានទាំងនោះហើយ ក៏ចេញ ហើយពិចារណានូវចិត្តដែលសម្បយុត្តហើយដោយឈាន ដោយសេចក្តីអស់ទៅ ដោយសេចក្តីសូន្យទៅ ភាពនៃចិត្តប្រព្រឹត្តទៅ ក្នុងខណៈជាចិត្តមានអារម្មណ៍តែមួយ រមែង

កើតឡើង ដោយការចាក់ផ្ទុះនូវលក្ខណៈ ក្នុងខណៈនៃវិបស្សនា,

ឯវំ ឧប្បន្នាយ ខណិកចិត្តេកគ្គតាយ វសេនបិ អារម្មណេ ចិត្តំ សមំ អាឧហាត្តេ សមំ បវេត្តេ "សមាឧហំ ចិត្តំ អស្សសិស្សាមិ បស្សសិស្សាមីតិសិក្ខតី"តិ វុច្ចតិ។

កិក្ខុតម្កល់ចិត្តឲ្យស្មើ គឺ តាំងចិត្តឲ្យស្មើ ក្នុងអារម្មណ៍ ដោយអំណាចនៃឯកគ្គតារបស់ចិត្ត ដែលកើតឡើងមួយខណៈៗ គឺកើតហើយយ៉ាងនេះ លោកហៅថា "រមែងសិក្សាថា អាត្មាអញ នឹងតម្កល់ចិត្ត ឲ្យនឹងធឹង ដកដង្ហើមចូល និងដកដង្ហើមចេញ" ដូច្នេះ ។

"វិមោចយំ ចិត្ត"ន្តិ បឋមជ្ឈានេន នីវរណេហិ ចិត្តំ មោចេត្តេ វិមោចេត្តេ,

*២បទថា **"វិមោចយំ ចិត្តំ*** *ប្រែថា **ញុាំងចិត្តឲ្យរួច**" បានសេចក្តីថា ព្រះយោគី កាលញុាំងចិត្តឲ្យរួច ឲ្យរួចស្រឡះ ចាកពីនីវរណៈធម៌ទាំងឡាយ ដោយបឋមជ្ឈាន,*

ទុតិយេន វិតក្កវិចារេហិ,

កាលញុាំងចិត្តឲ្យរួច ឲ្យរួចស្រឡះចាកពីវិតក្កៈ និងវិចារៈទាំងឡាយ ដោយទុតិយជ្ឈាន,

តតិយេន បីតិយា,

កាលញុាំងចិត្តឲ្យរួច ឲ្យរួចស្រឡះ ចាកពីបីតិ ដោយតតិយជ្ឈាន,

ចតុត្ថេន សុខទុក្ខេហិ ចិត្តំ មោចេត្តេ វិមោចេត្តេ,

កាលញុាំងចិត្តឲ្យរួច ឲ្យរួចស្រឡះ ចាកពីសុខៈ និងទុក្ខទាំងឡាយ ដោយចតុត្ថជ្ឈាន,

តានិ វា បន ឈានានិ សមាបជ្ជិត្វា វុដ្ឋាយ ឈានសម្បយុត្តំ ចិត្តំ

ខយតោ វយតោ សម្មសតិ។

ម្យ៉ាងទៀត ព្រះយោគី ចូលឈានទាំង៤ឱ្យនោះ ចេញចាកហើយ ក៏ពិចារណានូវចិត្តដែលសម្បយុត្តហើយដោយឈាន ដោយសេចក្តីអស់ទៅ ដោយសេចក្តីសូន្យទៅ។

សោ វិបស្សនាក្ខណេ អនិច្ចានុបស្សនាយ និច្ចសញ្ញាតោ ចិត្តំ មោចេន្តោ វិមោចេន្តោ,

យោគីភិក្ខុនោះ ក្នុងខណៈនៃវិបស្សនា ដកចិត្តឱ្យរួច ឱ្យរួចស្រឡះ ចាកពី និច្ចសញ្ញា *ដោយ* អនិច្ចានុបស្សនា,

ទុក្ខានុបស្សនាយ សុខសញ្ញាតោ,

ចាកពីសុខៈសញ្ញា ដោយ ទុក្ខានុបស្សនា,

អនត្តានុបស្សនាយ អត្តសញ្ញាតោ,

ចាកពីអត្តសញ្ញា ដោយ អនត្តានុបស្សនា,

និព្វិទានុបស្សនាយ នន្ទិតោ,

ចាកពីសេចក្តីត្រេកត្រអាល ដោយ និព្វិទានុបស្សនា,

វិរាគានុបស្សនាយ រាគតោ,

ចាកពីរាគៈ ដោយ វិរាគានុបស្សនា,

និរោធានុបស្សនាយ សមុទយតោ,

ចាកពីសមុទយៈ ដោយ និរោធានុបស្សនា,

បដិនិស្សគ្គានុបស្សនាយ អាទានតោ ចិត្តំ មោចេន្តោ វិមោចេន្តោ អស្សសតិ ចេវ បស្សសតិ ច។

ចាកពីអាទានៈ (គឺ សេចក្តីប្រកាន់) ដោយបដិនិស្សគ្គានុបស្សនា

ដកដង្ហើមចូល និងដកដង្ហើមចេញ ។

តេន វុច្ចតិ – "វិមោចយំ ចិត្តំ អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតី"តិ។

ព្រោះហេតុនោះ ទើបលោកពោលថា "រមែងសិក្សាថា អាត្មាអញ នឹងដកចិត្តឲ្យរួច ដកដង្ហើមចូល និងដកដង្ហើមចេញ" ដូច្នេះ ។

ឯវំ ចិត្តានុបស្សនាវសេន ឥទំ ចតុក្កំ ភាសិតន្តិ វេទិតព្ពំ។

បណ្ឌិតគប្បីជ្រាប នូវចតុក្កៈនេះ ថា ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហើយ ដោយអំណាចនៃចិត្តានុបស្សនា យ៉ាងនេះ ដូច្នេះឯង ។

ចប់ ចតុក្កៈទី ៣

ចតុក្កទី ៤ ធម្មានុបស្សនា

ពាក្យថា អនិច្ចានុបស្សី

ចតុត្ថចតុក្កេ បន "អនិច្চានុបស្សី"តិ ឯត្ត តាវ អនិច្চំ វេទិតព្ពំ,

*ចំណែកក្នុងចតុក្កៈទី ៤ មានសេចក្តីវិនិច្ឆ័យថា ក្នុងបទថា "**អនិច្ចានុបស្សី** ប្រែថា **ការតាម ពិចារណាឃើញរឿយៗថា ជារបស់មិនទៀង**" នោះ ជាខាងដើម បណ្ឌិតគប្បីជ្រាប នូវពាក្យថា **អនិច្ចំ** ប្រែថា របស់មិនទៀង,*

អនិច្ចតា វេទិតព្វា,

*គប្បីជ្រាបនូវពាក្យថា **អនិច្ចតា** ប្រែថា ភាពជារបស់មិនទៀង,*

អនិច្চានុបស្សនា វេទិតព្វា,

គប្បីជ្រាបនូវពាក្យថា **អនិច្ចានុបស្សនា** *ប្រែថា ការតាមពិចារណាឃើញរឿយៗថាមិនទៀង,*

អនិច្ចានុបស្សី វេទិតព្ពោ។

គប្បីជ្រាបនូវពាក្យថា **អនិច្ចានុបស្សី** *ប្រែថា អ្នកដែលតាមពិចារណាឃើញថា ជារបស់មិនទៀង ជាមុនសិន ។*

តត្ថ "អនិច្ច"ន្តិ បញ្ចក្ខន្ធា។

ក្នុង ៤ បទ នោះ ត្រង់បទថា **"អនិច្ចំ** *ដែលប្រែថា* ***របស់មិនទៀង"*** *បានដល់គឺ ខន្ធ្រាំ ។*

កស្មា? ឧប្បាទវយញ្ញថត្តភាវា។

សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះសភាវៈនៃខន្ធ្រាំនោះ មានការកើតឡើង និងអស់សូន្យទៅ និងជារបស់ដទៃ ។

"អនិច្ចតា"តិ តេសំយេវ ឧប្បាទវយញ្ញថត្តំ,

បទថា **"អនិច្ចតា** *ប្រែថា* ***ភាពជារបស់មិនទៀង"*** *បានដល់ ភាពនៃបញ្ចក្ខន្ធទាំងនោះឯង មានការកើតឡើង អស់សូន្យទៅ និងជារបស់ដទៃ,*

ហុត្វា អភាវោ វា,

ឬថា ភាពនៃបញ្ចក្ខន្ធទាំងនោះ មានហើយ បែរទៅជាមិនមានទៅវិញ,

និព្ពត្តានំ តេនេវាការេន អដ្ឋត្វា ខណភង្គេន ភេទោតិ អត្ថោ។

អធិប្បាយថា **អនិច្ចតា** *ក៏គឺភាពនៃបញ្ចក្ខន្ធទាំងឡាយនោះ ដែលកើតឡើងហើយ មិនតាំងនៅ ដោយអាការៈនោះឯង ហើយបែកធ្លាយ ដោយការបែកធ្លាយគ្រប់ៗខណៈ ។*

"អនិច្ចានុបស្សនា"តិ តស្សា អនិច្ចតាយ វសេន រូបាទីសុ "អនិច្ច"ន្តិ

អនុបស្សនា។

*បទថា "**អនិច្ចានុបស្សនា** ប្រែថា **ការតាមពិចារណាឃើញរឿយៗថាមិនទៀង**" គឺ ការតាមពិចារណាឃើញថា មិនទៀង ក្នុងខន្ធទាំង៥ ដែលមានរូបជាដើម ដោយអំណាចនៃអនិច្ចតានោះ។*

"អនិច្ចានុបស្សី"តិ តាយ អនុបស្សនាយ សមង្គាគតោ។

*បទថា "**អនិច្ចានុបស្សី** ប្រែថា **ការតាមពិចារណាឃើញរឿយៗថា ជារបស់មិនទៀង**" បានដល់ព្រះយោគី ជាអ្នកប្រកបព្រម ដោយការតាមពិចារណានូវការឃើញនោះ។*

តស្មា ឯវំភូតោ អស្សសន្តោ ច បស្សសន្តោ ច ឥច "អនិច្ចានុបស្សី អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតី"តិ វេទិតព្ពោ។

ព្រោះហេតុនោះ ភិក្ខុជាអ្នកយ៉ាងដូច្នេះហើយ កាលដកដង្ហើមចូលផង និងដកដង្ហើមចេញផង បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា "រមែងសិក្សាថា អាត្មាអញ ជាអ្នកតាមពិចារណាឃើញថាមិនទៀង ខណៈដកដង្ហើមចូល និងដកដង្ហើមចេញ" ក្នុងទីនេះ។

ពាក្យថា ខិរគានុបស្សី

"វិគានុបស្សី"តិ ឯត្ថ បន ទ្វេ វិគា ខយវិគោ ច អច្ចន្តវិគោ ច។

*ចំណែកក្នុងបទថា "**វិគានុបស្សី**" នេះ វិគៈ (ការប្រាសចាកតម្រេក) មាន ២ យ៉ាង គឺ ខយវិគៈ ១ និងអច្ចន្តវិគៈ ១។*

តត្ថ "ខយវិគោ"តិ សង្ខារានំ ខណភង្គោ។

*បណ្តាវិគៈទាំង ២ យ៉ាង នោះ ការបែកធ្លាយគ្រប់ខណៈៗ នៃសង្ខារទាំងឡាយ ឈ្មោះថា **ខណវិគៈ**។*

"**អច្ចន្តវិរាគោ**"តិ និព្ពានំ។

ព្រះនិព្វាន ឈ្មោះថា ***អច្ចន្តវិរាគៈ*** *។*

"**វិរាគានុបស្សនា**"តិ តទុភយទស្សនវសេន បវត្តា វិបស្សនា ច មគ្គោ ច។

វិបស្សនា និងមគ្គ ដែលប្រព្រឹត្តទៅ ដោយអំណាចនៃវិរាគៈទាំង ២ នោះ ឈ្មោះថា **វិរាគានុបស្សនា** *។*

តាយ ទុវិធាយបិ អនុបស្សនាយ សមង្គីតតោ ហុត្វា អស្សសន្តោ ច បស្សសន្តោ ច "វិរាគានុបស្សី អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតី"តិ វេទិតព្ពោ។

ព្រះយោគីជាអ្នកប្រកបដល់ព្រម ដោយអនុបស្សនាទាំង ២ នោះឯង កាលដកដង្ហើមចូល និងដកដង្ហើមចេញ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា "សិក្សាថា អាត្មាអញ នឹងជាអ្នកពិចារណាឃើញការប្រាសចាកនូវតម្រេក ដកដង្ហើមចូល និងដកដង្ហើមចេញ" ដូច្នេះ ។

ពាក្យថា និរោធានុបស្សី

និរោធានុបស្សីបទេបិ ឯសេវ នយោ។

ន័យ សូម្បីក្នុងបទថា "**និរោធានុបស្សី**" *ក៏មានន័យដូចគ្នា នេះផងដែរ ។*

ពាក្យថា បដិនិស្សគ្គានុបស្សី

"**បដិនិស្សគ្គានុបស្សី**"តិ ឯត្ថាបិ ទ្វេ បដិនិស្សគ្គា បរិច្ចាគបដិនិ-ស្សគ្គោ ច បក្ខន្ទនបដិនិស្សគ្គោ ច។

សូម្បីក្នុងបទថា "**បដិនិស្សគ្គានុបស្សី**" *នេះបដិនិស្សគ្គៈ(ការរលាស់ចោល) មាន ២ យ៉ាង គឺ ការបរិច្ចាគប្បដិនិស្សគ្គៈ (បដិនិស្សគ្គៈ គឺ ការលះបង់) ១*

និងបក្ខន្ធនប្បដិនិស្សគ្គ: (បដិនិស្សគ្គ: គឺ ការស្ទុះទៅ) ១ ។

បដិនិស្សគ្គោយេវ អនុបស្សនា បដិនិស្សគ្គានុបស្សនា, វិបស្សនាមគ្គានមេតំ អធិវចនំ។

អនុបស្សនា *គឺ* **បដិនិស្សគ្គ** *ឈ្មោះថា* **បដិនិស្សគ្គានុបស្សនា**, *ពាក្យថា* **បដិនិស្សគ្គានុបស្សនា** *នេះ ជាឈ្មោះ នៃ***វិបស្សនា** *និងមគ្គទាំងឡាយ ។*

"វិបស្សនា"តិ តទង្គវសេន សទ្ធឹ ទន្ធាភិសង្ខ្ហារេហិ កិលេសេ បរិចូឥតិ,

ពិតមែន ***"វិបស្សនា"*** *រមែងលះបង់ នូវកិលេសទាំងឡាយ ព្រមទាំងខន្ធ និងអភិសង្ខារទាំងឡាយ ដោយអំណាចនៃតទង្គប្បហាន:,*

សង្ខ្ហតធោសទស្សនេន ច តព្ធិបរីតេ និព្ធានេ តន្និន្នតាយ បក្ខន្ទតីតិ **បរិចូាកបដិនិស្សគ្គោ** ចេវ **បក្ខន្ទនបដិនិស្សគ្គោ** ចាតិ វុចូតិ។

ថែមទាំង រមែងស្ទុះទៅ ក្នុងព្រះនិព្ធាន ដែលផ្ទុយគ្នានឹងកិលេសនោះ ព្រោះសភាវ:នៃវិបស្សនាឱនទៅ ក្នុងផ្ទូវនោះ ដោយកិរិយាឃើញនូវទោស ក្នុងសង្ខតធម៌ ព្រោះហេតុដូច្នោះ ទើបលោកហៅថា (បដិនិស្សគ្គ: មាន ២ គឺ) **បរិចូាកប្បដិនិស្សគ្គ ១** *និង***បក្ខន្ទនប្បដិនិស្សគ្គ ១** *។*

មគ្គោ សមុច្ឆេទវសេន សទ្ធឹ ទន្ធាភិសង្ខ្ហារេហិ កិលេសេ បរិចូឥតិ,

ចំណែក **មគ្គ** *រមែងលះបង់ នូវកិលេសទាំងឡាយ ព្រមទាំងខន្ធ និងអភិសង្ខារទាំងឡាយ ដោយអំណាចនៃសមុច្ឆេទប្បហាន:,*

អារម្មណការណេន ច និព្ធានេ បក្ខន្ទតីតិ **បរិចូាកបដិនិស្សគ្គោ** ចេវ **បក្ខន្ទនបដិនិស្សគ្គោ** ចាតិ វុចូតិ។

ថែមទាំង រមែងស្ទុះទៅ ក្នុងព្រះនិព្ធាន ដោយកិរិយាធ្វើ (នូវព្រះនិព្ធាន) ឲ្យជាអារម្មណ៍ ព្រោះហេតុដូច្នោះ ទើបលោកហៅថា (បដិនិស្សគ្គ: មាន២ គឺ)

បរិច្ចាគបដិនិស្សគ្គ ๑ និង **បក្ខន្ទនបដិនិស្សគ្គ ๑** ។

ឧភយម្បិ បន បុរិមបុរិមញាណានំ អនុអនុ បស្សនតោ អនុបស្សនាតិ វុច្ចតិ។

ក៏វិបស្សនាញាណ និងមគ្គញាណទាំង ๒ យ៉ាងនេះ លោកហៅថា អនុបស្សនា ព្រោះកិរិយាឃើញរឿយៗ នូវញាណ មានក្នុងខាងមុខៗទាំងឡាយ។

តាយ ឧភិន្នាយបិ បដិនិស្សគ្គានុបស្សនាយ សមង្គិតតោ ហុត្វា អស្សសន្តោ ច បស្សសន្តោ ច "បដិនិស្សគ្គានុបស្សី អស្សសិស្សាមិ បស្សសិស្សាមីតិ សិក្ខតី"តិ វេទិតព្ពោ។

*ព្រះយោគីកិក្ខុ ជាអ្នកប្រកបព្រម ដោយ **បដិនិស្សគ្គានុបស្សនា** ទាំង ๒ យ៉ាងនោះ កាលដកដង្ហើមចូល និងកាលដកដង្ហើមចេញ បណ្ឌិតគប្បីជ្រាបថា សិក្សាថា" អាត្មាអញ នឹងជាអ្នកពិចារណាឃើញរឿយៗ នូវកិរិយារលាស់ចោល ដកដង្ហើមចូល និងដកង្ហើមចេញ" ។*

ឯត្ថ ច "អនិច្ចានុបស្សី"តិ តរុណវិបស្សនាយ វសេន វុត្តំ,

ក៏ក្នុងសេចក្តីនេះពាក្យថា "អនិច្ចានុបស្សី ប្រែថា ការពិចារណាឃើញរឿយៗនូវបញ្ចក្ខន្ធនេះ ថាមិនទៀង" ដោយអំណាចវិបស្សនាយ៉ាងទន់ខ្សោយៗ,

"វិរាគានុបស្សី"តិ តតោ ពលវតរាយ សង្ខារេសុ វិរជ្ជនសមត្ថាយ វិបស្សនាយ វសេន,

*ពាក្យថា "**វិរាគានុបស្សី** ប្រែថា ពិចារណាឃើញរឿយៗ នូវធម៌ជាគ្រឿងធ្វើចិត្តឲ្យប្រាសចាកតម្រេក" លោកពោលដោយអំណាចវិបស្សនាដែលអាចនឹងប្រាសចាកតម្រេក ក្នុងសង្ខារទាំងឡាយ ដែលជាវិបស្សនាមានកម្លាំងខ្លាំងជាងនៃវិបស្សនាទន់ខ្សោយនោះ,*

"និពេជានុបស្សី"តិ តតោ ពលវតរាយ កិលេសនិពេជនសមត្ថាយ វិបស្សនាយ វសេន,

ពាក្យថា "និពេជានុបស្សី ប្រែថា ការពិចារណាឃើញរឿយៗ នូវសេចក្តីរំលត់នៃកងទុក្ខ" លោកពោលទុកដោយអំណាចវិបស្សនា ដែលអាចរលត់កិលេសបាន ដែលមានកម្លាំងខ្លាំង,

"បដិនិស្សគ្គានុបស្សី"តិ មគ្គស្ស អាសន្នភូតាយ អតិតិក្ខាយ វិបស្សនាយ វសេន វុត្តន្តិ វេទិតព្វំ។

ពាក្យថា "បដិនិស្សគ្គានុបស្សី ប្រែថា ការពិចារណាឃើញរឿយៗ នូវធម៌ជាគ្រឿងរលាស់ចិត្ត ចេញចាកកិលេស" គប្បីជ្រាបថា លោកពោលដោយអំណាចវិបស្សនាដែលមានកម្លាំងខ្លាំងយ៉ាងក្រៃលែង ដែលនៅកៀកកិតជិតនឹងមគ្គ ។

យត្ថ បន មគ្គោបិ លព្ភតិ, សោ អភិន្នោយេវ។

ចំណែកក្នុងព្រះបាលីប្រទេសណា រមែងបានសូម្បីជាមគ្គ, បាលីប្រទេសនោះ មិនផ្សេងគ្នាទេ គឺដូចគ្នា ។

ឯវមិធំ ចតុក្កំ សុទ្ធវិបស្សនាវសេន វុត្តំ, បុរិមានិ បន តីណិ សមថវិបស្សនាយវសេនាតិ។

ចតុក្ក:នេះ លោកពោលដោយអំណាចនៃវិបស្សនាសុទ្ធៗ យ៉ាងនេះ, ចំណែក ៣ ចតុក្ក:ខាងដើម លោកពោលដោយអំណាចនៃសមថៈ និងវិបស្សនាដូច្នេះឯង ។

អានាបានស្សតិមាតិកាវណ្ណនា និដ្ឋិតា។

ការពណ៌នាមាតិកានៃអានាបានស្សតិ ចប់ ។

ពាក្យថា ឥធ សព្ទ (ចិដក ៧០) [៩៦]

[១៦៤] "**ឥធា**"តិ ឥមិស្សា ទិដ្ឋិយា, ឥមិស្សា ខន្តិយា, ឥមិស្សា រុចិយា, ឥមស្មឹ អាទាយេ, ឥមស្មឹ ធម្មេ, ឥមស្មឹ វិនយេ, ឥមស្មឹ ធម្មវិនយេ, ឥមស្មឹ ចាវចនេ, ឥមស្មឹ ព្រហ្មចរិយេ, ឥមស្មឹ សត្ថុសាសនេ។

*ពាក្យថា "**ឥធ ក្នុងសាសនានេះ**" គឺក្នុងទិដ្ឋិនេះ, ក្នុងសេចក្តីពេញចិត្តនេះ, ក្នុងសេចក្តីគាប់ចិត្តនេះ, ក្នុងសេចក្តីប្រកាន់នេះ, ក្នុងធម្មនេះ, ក្នុងវិន័យនេះ, ក្នុងធម្មវិន័យនេះ, ក្នុងពាក្យជាប្រធាននេះ, ក្នុងព្រហ្មចរិយនេះ, ក្នុងព្រះសាសនានេះ។*

តេន វុច្ចតិ – "ឥធា"តិ។

ព្រោះហេតុនោះ លោកពោលថា ក្នុងសាសនានេះ។

"**ភិក្ខូ**"តិ បុថុជ្ជនកល្យាណកោ វា ហោតិ ភិក្ខុ សេក្ខោ វា អរហា វា អកុប្បធម្មោ។

ពាក្យថា "ភិក្ខុ" បានដល់ភិក្ខុជាកល្យាណបុថុជ្ជន ឬជាសេក្ខ ឬក៏ជាអរហន្ត ដែលមានធម៌មិនកម្រើក។

"**អរញ្ញេ**"តិ ឯកមិត្ថា ពហិ ឥន្ទខីលា សព្ពមេតំ អរញ្ញំ។

ពាក្យថា "ព្រៃ "បានដល់ ទីចេញទៅខាងក្រៅអំពីសសរគោល ទាំងអស់នេះ ឈ្មោះថា ព្រៃ។

"**រុក្ខមូលេ**"តិ យត្ត កិក្ខុនោ អាសនំ បញ្ញត្តំ ហោតិ,

*ពាក្យថា "**គល់ឈើ**" បានដល់ អាសនៈដែលគេក្រាលសម្រាប់ភិក្ខុទៀបគល់ឈើនោះ,*

មញ្ចោ វា បីឋំ វា កិសិ វា,

ត្រែក្តី តាំងក្តី ពូកក្តី,

តដ្ឋិកា វ ចម្មទណ្ឌោ វ តិណសន្ថរោ[៤៧] **វ,**

កន្ទេលក្តី ផ្ទាំងស្បែកក្តី កម្រាលស្មៅក្តី

បណ្ណសន្ថរោ វ បលាលសន្ថរោ[៤៨] **វ,**

កម្រាលស្ទឹកឈើក្តី កម្រាលចំបើងក្តី,

តត្ថ ភិក្ខុ ចង្ក្រមតិ វ តិដ្ឋតិ វ និសីទតិ វ សេយ្យំ វ កប្បេតិ។

ភិក្ខុចង្ក្រមក៏បាន ឈរក៏បាន អង្គុយក៏បាន សឹងក៏បាន លើអាសន:នោះ។

"សុញ្ញ"ន្តិ កេនចិ អនាកិណ្ណំ ហោតិ គហដ្ឋេហិ វ បព្វជិតេហិ វ។

*ពាក្យថា "**ស្ងាត់**"គឺមិនកុះករដោយពួកគ្រហស្ថ ឬពួកបព្វជិត ណាមួយ ។*

"អគារ"ន្តិ[៤៩] **វិហារោ អឌ្ឍយោគោ ចាសាទោ ហម្មិយំ គុហា។**

*ពាក្យថា "**ផ្ទះ**" បានដល់ វិហារ ផ្ទះមានដំបូលតែមួយ ផ្ទះមានប្រើនជាន់ ផ្ទះមានដំបូលរលីង និងល្អាងភ្នំ ។*

"និសីទតិ បល្ថង្ក៉ំ អាភុជិត្វា"តិ និសិន្នោ ហោតិ បល្ថង្ក៉ំ អាភុជិត្វា។

*ពាក្យថា "**អង្គុយពែនភ្នែន**" គឺជាអ្នកអង្គុយពែនភ្នែន ។*

"ឧជុំ កាយំ បណិធាយា"តិ ឧជុកោ ហោតិ កាយោ បិតោ[៥០] សុបណិហិតោ។

*ពាក្យថា "**តាំងកាយឲ្យត្រង់**" គឺមានកាយត្រង់ នឹងធឹង នឹងនួន។*

"បរិមុខំ សតឹ ឧបដ្ឋបេត្វា"តិ។

---

៤៧ ស្យា. តិណសណ្ឋារោ ។
៤៨ ស្យា. បលាសសន្ថរោ ។
៤៩ ស្យា. អាគារន្តិ ។
៥០ ស្យា. បនិធិតោ ។

តាំងសតិ ឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។

"បរី"តិ បរិក្ខហាដ្ឋោ។

*ពាក្យថា "**បរិ**" ក្នុងបទថា **បរិមុខំ សតឹ ឧបដ្ឋបេត្វា** មានអត្ថថា កំណត់កាន់យក។*

"មុខ"ន្តិ និយ្យានដ្ឋោ។

*ពាក្យថា "**មុខំ**" មានអត្ថថា ធម៌ជាគ្រឿងនាំចេញទៅ ។*

"សតី"តិ ឧបដ្ឋានដ្ឋោ។

*ពាក្យថា "**សតិ**" មានអត្ថថា ចូលទៅតាំងទុក ។*

តេន វុច្ចតិ – "បរិមុខំ សតឹ ឧបដ្ឋបេត្វា"តិ។

ព្រោះហេតុនោះ លោកពោលថា "តាំងសតិឲ្យមានមុខឆ្ពោះទៅរក(កម្មដ្ឋាន)" ។

ពាក្យថា ឥច សព្ព (អដ្ឋកថា)

[๑๖๔]

ឥទានិ យថានិក្ខិត្តំ មាតិកំ បដិចានិយា ភាវេត្វា ឧស្សេតុំ **"ឥទានិ ឥមិស្សា ចិដ្ឋិយា"**តិអាទិ អារទ្ធំ។

*ឥឡូវនេះ លោកប្រាថ្នានឹងសម្តែងចំណែកមាតិកាដែលបានលើកតាំងទុកហើយទៅតាមលំដាប់ ទើបចាប់ផ្តើមនូវបទថា "**ឥច**" អត្ថសេចក្តីថា **ក្នុងទិដ្ឋិនេះ** ដូច្នេះជាដើម ។*

តត្ថ "**ឥមិស្សា ទិដ្ឋិយា**"តិអាទីហិ ឧសហិ បទេហិ សិក្ខត្តយ-សង្ខាតំ សព្ពញ្ញុពុទ្ធសាសនមេវ កថិតំ។

*ក្នុងពាក្យនោះ ដោយបទទាំង ១០ មានពាក្យថា "**ក្នុងទិដ្ឋិនេះ**" ជាដើម លោកពោលដល់ពាក្យបង្រៀនរបស់ព្រះសព្វញ្ញុពុទ្ធជាម្ចាស់លោកបានពោល គឺ សិក្ខាទាំង ៣ នោះឯង ។*

តញ្ហិ ពុទ្ធេន ភគវតា ទិដ្ឋត្តា **ទិដ្ឋី**តិ វុច្ចតិ, តស្សេវ ខមនវសេន **ខន្តិ**, រុច្ចនវសេន **រុចិ**, តហាណវសេន **អាទាយោ**, សការដ្ឋេន **ធម្មោ**, សិក្ខិតព្ពដ្ឋេន **វិនយោ**, តទុភយេនបិ **ធម្មវិនយោ**, បវុត្តវសេន **ចាវចនំ**, សេដ្ឋចរិយដ្ឋេន **ព្រហ្មចរិយំ**, អនុសិដ្ឋិជានវសេន **សត្ថុសាសនន្តិ** វុច្ចតិ។

*ពិតមែន ពាក្យបង្រៀនរបស់ព្រះសព្វញ្ញុពុទ្ធជាម្ចាស់នោះ លោកហៅថា **ទិដ្ឋិ** ព្រោះដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ឃើញហើយ, លោកហៅថា **ខន្តិ** ដោយអំណាចភាពអត់ធន់ របស់ព្រះដ៏មានព្រះភាគជាម្ចាស់នោះឯង, លោកហៅថា **រុចិ** ដោយអំណាចការពេញចិត្ត, លោកហៅថា **អាទាយ** ដោយអំណាចការកាន់យក, លោកហៅថា **ធម្ម** ដោយអត្ថថា ជាសភាវៈ, លោកហៅថា **វិនយ** ដោយអត្ថថា ជាធម៌ដែលបុគ្គលគប្បីសិក្សា, លោកហៅថា **ធម្មវិនយ** សូម្បីដោយអត្ថទាំងពីរនោះ, លោកហៅថា **ចាវចន** ដោយអំណាចជាធម្មដែលត្រាស់ទុកជាប្រធាន, លោកហៅថា **ព្រហ្មចរិយ** ដោយអត្ថថា ជាការប្រព្រឹត្តិដ៏ប្រសើរ, លោកហៅថា **សត្ថុសាសន** ដោយអំណាចជាពាក្យការដាស់តឿន ។*

តស្មា "ឥមិស្សា ទិដ្ឋិយា"តិអាទីសុ ឥមិស្សា ពុទ្ធទិដ្ឋិយា, ឥមិស្សា ពុទ្ធខន្តិយា, ឥមិស្សា ពុទ្ធរុចិយា, ឥមស្មឹ ពុទ្ធអាទាយេ, ឥមស្មឹ ពុទ្ធធម្មេ, ឥមស្មឹ ពុទ្ធវិនយេ, ឥមស្មឹ ពុទ្ធធម្មវិនយេ, ឥមស្មឹ ពុទ្ធចាវចនេ, ឥមស្មឹ ពុទ្ធព្រហ្មចរិយេ, ឥមស្មឹ ពុទ្ធសត្ថុសាសនេតិ អត្ថោ វេទិតព្ពោ។

ព្រោះហេតុនោះ ក្នុងពាក្យថា "ក្នុងទិដ្ឋិនេះ" ជាដើម គប្បីជ្រាបនូវសេចក្តីថា ក្នុងពុទ្ធទិដ្ឋិនេះ, ក្នុងពុទ្ធខន្តិនេះ, ក្នុងពុទ្ធរុចិនេះ, ក្នុងពុទ្ធអាទាយៈនេះ, ក្នុងពុទ្ធធម្មនេះ, ក្នុងពុទ្ធវិនយនេះ, ក្នុងពុទ្ធធម្មវិនយនេះ, ក្នុងពុទ្ធបាវចនៈនេះ, ក្នុងពុទ្ធព្រហ្មចរិយនេះ, ក្នុងពុទ្ធសត្ថុសាសននេះ។

អបិចេតំ សិក្ខត្តយសង្ខាតំ សកលំ ចាវចនំ ភគវតា ឯដ្ឋត្តា សម្មាទិដ្ឋិបច្ចយត្តា សម្មាទិដ្ឋិបុព្វង្គមត្តា ច ទិដ្ឋិ។

ប្រការម្យ៉ាងទៀត បាវចនៈទាំងអស់ ពោលគឺ សិក្ខាទាំង ៣ នេះ ឈ្មោះថា ទិដ្ឋិ ព្រោះព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ឃើញហើយ ព្រោះមានសម្មាទិដ្ឋិជាបច្ច័យ និងព្រោះមានសម្មាទិដ្ឋិជាប្រធាន។

ភគវតោ ខមនវសេន ខន្តិ។ រុច្ចនវសេន រុចិ។ តហាណវសេន អាទាយោ។

ឈ្មោះថា **ខន្តិ** *ដោយអំណាចភាពអត់ធន់របស់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ ឈ្មោះថា* **រុចិ** *ដោយអំណាចភាពពេញចិត្ត ។ ឈ្មោះថា* **អាទាយ** *ដោយអំណាចការកាន់យក។*

អត្តនោ ការកំ អថាយេ អបតមានំ ជាវតីតិ ធម្មោ។

ឈ្មោះថា **ធម្ម** *ដោយអត្ថថា ទ្រទ្រង់ទុកនូវបុគ្គលអ្នកប្រព្រឹត្តខ្លួនមិនឲ្យធ្លាក់ទៅអបាយ។*

សោវ សំកិលេសបក្ខំ វិនេតីតិ វិនយោ។

ធម៌នោះឯង ឈ្មោះថា **វិនយ** *ដោយអត្ថថា នាំទៅឲ្យវិនាសនូវផ្នែកនៃសង្កិលេស។*

ធម្មោ ច សោ វិនយោ ចាតិ ធម្មវិនយោ, កុសលធម្មេហិ វា អកុសលធម្មានំ ឯស វិនយោតិ ធម្មវិនយោ។

ធម៌នោះផង ជាវិន័យផង ព្រោះហេតុនោះ ទើបឈ្មោះថា ធម្មវិន័យ, ន័យម្យ៉ាងទៀត ធម៌នេះនាំទៅឲ្យវិនាសនូវអកុសលធម៌ទាំងឡាយ ដោយកុសលធម៌ទាំងឡាយ ព្រោះហេតុនោះ ទើបឈ្មោះថា ធម្មវិន័យ ។

តេនេវ វុត្តំ – "យេ ច ខោ តុំ, គោតមិ, ធម្មេ ជានេយ្យាសិ ឥមេ ធម្មា វិរាគាយ សំវត្តន្តិ, នោ សរាគាយ។...បេ....។ ឯកំសេន, គោតមិ, ជានេយ្យាសិ ឯសោ ធម្មោ ឯសោ វិនយោ ឯតំ សត្ថុសាសន"ន្តិ[៥១] ។

ដោយហេតុនោះ នុ៎ះឯង ព្រះដ៏មានព្រះភាគជាម្ចាស់ ទើបត្រាស់ថា "ម្នាលគោតមី អ្នកគប្បីដឹងនូវធម៌ទាំងឡាយណា ធម៌ទាំងឡាយនេះ រមែងប្រព្រឹត្តទៅដើម្បីប្រាសចាកពាគៈ, មិនមែនប្រព្រឹត្តដើម្បីមានពាគៈទេ។...ល...។ ម្នាលគោតមី អ្នកគប្បីទ្រទ្រង់ទុកដោយចំណែកមួយថា នេះជាធម៌ នេះជាវិន័យ នេះជាសត្ថុសាសន" ។

ធម្មេន វា វិនយោ, ន ឧណ្ហាឌីហីតិ ធម្មវិនយោ។

ន័យម្យ៉ាងទៀត វិន័យដោយធម៌, មិនមែនដោយឈើដំបង ជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា ធម្មវិន័យ ។

វុត្តម្បិ ចេតំ –

សេចក្តីនេះសមតាមពាក្យព្រះបាលី ដែលលោកពោលទុកថា ៖

"ឧណ្ហោនេកេ ឧមយន្តិ, អង្គសេហិ កសាហិ ច;

អឧណ្ហេន អសត្តេន, ជាតោ ឧត្តោ មហេសិនា"តិ[៥២]។

"បុគ្គលពួកមួយ រមែងបង្វឹកដំរីដោយឈើដំបង ដោយកន្ទេរ និងខ្សែតឺ ដំរីដែលព្រះពុទ្ធជាម្ចាស់ អ្នកស្វែងរកនូវគុណដ៏ក្រៃលែងបង្វឹកហើយ មិនមែន

---

៥១ (អ. និ. ៨.៥៣; ចូឡវ. ៤០៦) ។

៥២ (ម. និ. ២.៣៥២; ចូឡវ. ៣៤២) ។

ដោយឈើដំបង មិនមែនដោយសាស្ត្រា" ដូច្នេះ ។

តថា

ដូចគ្នា ព្រះអង្គត្រាស់សម្តែងថា ៖

"ធម្មេន នយមានានំ, កា ឧសូយា វិជានត"ន្តិ[៥៣] **។**

"កាលព្រះតថាគត ទ្រង់ណែនាំដោយធម៌ ជាអ្នកដឹងច្បាស់ និងប្ចស្យា តើធ្វើទេ"។

ធម្មាយ វា វិនយោ ធម្មវិនយោ។

ន័យម្យ៉ាងទៀត វិន័យដើម្បីធម៌ ទើបឈ្មោះថា ធម្មវិន័យ ។

អនវជ្ជធម្មត្តំ ហោស វិនយោ, ន ភវភោតាមិសត្តំ។

ពិតមែន វិន័យនេះ ដើម្បីធម៌ដែលប្រាសចាកទោស, មិនមែនដើម្បីនុយគឺភព និងភោគៈទេ ។

តេនាហ ភតវា – "នយិធំ, ភិក្ខវេ, ព្រហ្មចរិយំ វុស្សតិ ជនកាហនត្ត"ន្តិ[៥៤] **វិត្តាវោ។**

ដោយហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទើបត្រាស់សម្តែងថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលនៅក្នុងព្រហ្មចរិយនេះ មិនដើម្បីនឹងកុហកនូវជនទាំងឡាយឡើយ" ដូច្នេះជាដើម គប្បីជ្រាបនូវសេចក្តីពិស្តារតទៅ ។

បុណ្ណត្តេរោបិ អាហ – "អនុចាជាបវិនិញ្ចានត្តំ ខោ, អាវុសោ, ភតវតិ ព្រហ្មចរិយំ វុស្សតី"តិ[៥៥]**។**

សូម្បីព្រះបុណ្ណត្តេរៈក៏បានពោលថា "ម្នាលអាវុសោ យើងជាអ្នកប្រព្រឹត្តិ

---

៥៣ (មហាវ. ៦៣) ។

៥៤ (ឥតិវុ. ៣៥; អ. និ. ៤.២៥) ។

៥៥ (ម. និ. ១.២៥៩) ។

ព្រហ្មចរិយក្នុងសំណាក់ព្រះដ៏មានព្រះភាគជាម្ចាស់ ដើម្បីអនុបាទាបរិនិព្វាន នោះឯង” ដូច្នេះ។

វិសុទ្ធំ វា ឧយតីតិ វិនយោ, ធម្មតោ វិនយោ ធម្មវិនយោ។

នីយម្យ៉ាងទៀត ឈ្មោះថាវិនីយ ដោយអត្ថថា នាំទៅកាន់ធម៌ដែលបរិសុទ្ធ, ការនាំទៅកាន់ធម៌ដែលបរិសុទ្ធដោយធម៌ ឈ្មោះថា ធម្មវិនីយ ។

សំសារធម្មតោ ហិ សោកាទិធម្មតោ វា ឯស វិសុទ្ធំ និព្វានំ ឧយតិ, ធម្មស្ស វា វិនយោ, ន តិត្ថករានន្តិ ធម្មវិនយោ។

ពិតមែន ធម៌នេះរមែងនាំទៅកាន់ធម៌ដែលបរិសុទ្ធ គឺនិព្វានចាកចេញធម៌គឺសង្សារ ឬ ចាកធម៌ដែលមានសោក: ជាដើម, នីយម្យ៉ាងទៀត ការនាំទៅកាន់ធម៌ដែលបរិសុទ្ធរបស់ព្រះធម្ម, មិនមែនរបស់ម្ចាស់លិទ្ធិទាំងឡាយ ព្រោះដូច្នោះទើបឈ្មោះថា ធម្មវិនីយ ។

ធម្មភូតោ ហិ ភគវា, តស្សេវ ឯស វិនយោ។

ពិតមែន ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ជា ព្រះធម្មវិនីយនេះជារបស់ព្រះដ៏មានព្រះភាគ ជាអ្នកព្រះធម៌នោះ នុ៎ះឯង ។

យស្មា វា ធម្មា ឯវ អភិញ្ញេយ្យា បរិញ្ញេយ្យា បហាតព្ពា ភាវេតព្ពា សច្ឆិកាតព្ពា ច, តស្មា ឯស ធម្មេសុ វិនយោ, ន សត្តេសុ ន ឋីវេសុ ចាតិ ធម្មវិនយោ។

នីយម្យ៉ាងទៀត ព្រោះធម្មទាំងឡាយ នុ៎ះឯង គួរដឹងយ៉ាងក្រៃលែង គួរកំណត់ដឹង គួរលះ គួរចម្រើននិងគួរធ្វើឲ្យជាក់ច្បាស់, ព្រោះហេតុនោះ នេះទើបជាវិនីយក្នុងធម្មទាំងឡាយ, មិនមែនក្នុងសត្វទាំងឡាយ និងមិនមែនក្នុងជីវៈទាំងឡាយ ព្រោះដូច្នោះ ទើបឈ្មោះថា ធម្មវិនីយ ។

សាត្ថសព្យញ្ជនតាទីហិ អញ្ញេសំ វចនតោ បជានំ វចនន្តិ បវចនំ,

បវចនមេវ ចាវចនំ។

ពាក្យដែលជាប្រធាន ព្រោះត្រាស់ដល់ជនដទៃ ដែលជាប្រធាន មានអត្ត និងមានព្យញ្ជន: ជាដើម ព្រោះដូច្នោះ ទើបឈ្មោះថា បវចនំ, បវចនំ នុ៉ះឯង ជាបាវចនំ ។

សព្ធចរិយាហិ រិសិដ្ឋចរិយភាវេន ព្រហ្មចរិយំ។

ឈ្មោះថា ព្រហ្មចរិយ ដោយសភាវ:ដែលគួរប្រព្រឹត្តដោយពិសេសជាង ការប្រព្រឹត្តិអ្វីៗទាំងពួង ។

ទេវមនុស្សានំ សត្ថុភូតស្ស ភតវតោ សាសនន្តិ សត្ថុសាសនំ, សត្ថុភូតំ វា សាសនន្តិបិ សត្ថុសាសនំ។

*ឈ្មោះថា **សត្ថុសាសន** ដោយអត្ថថា ជាពាក្យបង្រៀនប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះអង្គជាសាស្តាចារ្យរបស់ទេវតា និងមនុស្ស, ន័យម្យ៉ាងទៀត ឈ្មោះថា **សត្ថុសាសន** ដោយអត្ថថា ជាពាក្យបង្រៀន ប្រៀនប្រដៅរបស់អង្គសាស្តាចារ្យ ដូចនេះក៏មាន ។*

"យោ វោ, អានន្ទ, មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ, សោ វោ មមច្ចយេន សត្ថា"តិ[๕๖] ហិ ធម្មវិនយោវ សត្ថាតិ វុត្តោ។

ពិតមែន ព្រះធម៌ និងព្រះវិន័យនោះឯង ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ ត្រាស់ថា ជាសាស្តាចារ្យ ដោយព្រះបាលីថា "យោ វោ, អានន្ទ, មយា ធម្មោ ច វិនយោ ច ទេសិតោ បញ្ញត្តោ, សោ វោ មមច្ចយេន សត្ថា ប្រែថា ម្នាលអានន្ទ ធម៌ និងវិន័យឯណាដែលយើង សម្តែងហើយ បញ្ញាត្តិហើយ ដល់អ្នកទាំងឡាយ, ធម៌ និងវិន័យនោះ ចាត់ជាសាស្តាចារ្យរបស់អ្នកទាំងឡាយ ដោយការអស់ពីយើងទៅ" ដូច្នេះ ។

ឯវមេតេសំ បទានំ អត្ថោ វេទិតព្វោ។

---

๕๖ (ទី. និ. ២.២១៦) ។

គប្បីជ្រាបនូវអត្ថនៃបទទាំងឡាយនោះ ដោយប្រការដូច្នេះ ។

យស្មា បន ឥមស្មឹយេវ សាសនេ សព្ពាការអានាបានស្សតិ សមាធិនិព្ពត្តកោ កិក្ខុ វិជ្ជតិ, ន អញ្ញត្រ, តស្មា តត្ថ តត្ថ "ឥមិស្សា"តិ ច "ឥមស្មិ"ន្តិ ច អយំ និយមោ កតោតិ វេទិតព្ពោ។

*មួយទៀត ព្រោះព្រះកិក្ខុញុាំងអានាបានស្សតិសមាធិ ឲ្យកើតឡើងដោយប្រការទាំងពួង មាននៅក្នុងព្រះសាសនានេះ ប៉ុណ្ណោះ, ហើយមិនមាននៅក្នុងទីដទៃ, ព្រោះហេតុនោះ គប្បីជ្រាបពាក្យនិយមនេះថា លោកបានធ្វើទុកហើយថា "**ឥមិស្សា**" និងថា "**ឥមស្មឹ**" ក្នុងទីនេះប៉ុណ្ណោះៗ ។*

អយំ "ឥជា"តិមាតិកាយ និទ្ទេសស្ស អត្ថោ។

*នេះជាអត្ថ នៃនិទ្ទេសក្នុងមាតិកាថា " **ឥជ** " ។*

"បុថុជ្ជនកល្យាណកោ វា"តិអាទិនា ច កិក្ខុសទ្ទស្ស វចនត្ថំ អវត្វា ឥជាទិប្បភេទកិក្ខុយេវ ទស្សិតោ។

*ក៏អាស្រ័យពាក្យថា "**កិក្ខុជាកល្យាណបុថុជ្ជនក្តី**" ជាដើម លោកសម្តែងដល់កិក្ខុដែលជ្រាជ្ញាយកក្នុងទីនេះ មិនបានពោលនូវសេចក្តីរបស់សព្ទថាកិក្ខុសព្ទឡើយ ។*

តត្ថ បុថុជ្ជនោ ច សោ កិលេសានំ អសមុច្ឆិន្នត្តា, កល្យាណោ ច សីលាទិបដិបត្តិយុត្តត្តាតិ បុថុជ្ជនកល្យាណោ, បុថុជ្ជនកល្យាណោវ បុថុជ្ជនកល្យាណកោ។

*ក៏ក្នុងពាក្យនោះ មានសេចក្តីអធិប្បាយដូច្នេះ កិក្ខុនោះឈ្មោះ **បុថុជ្ជនកល្យាណោ** ដោយអត្ថថា ជាបុថុជ្ជន ព្រោះនៅមិនទាន់បានកាត់កិលេសជាសមុច្ឆេទ, និងជាមនុស្សល្អ ព្រោះជាអ្នកប្រកបដោយការបដិបត្តិ តាមគុណ មានសីលគុណ ជាដើម, **បុថុជ្ជនកល្យាណោ** នោះឯង ឈ្មោះថា **បុថុជ្ជន**

កល្យាណកោ *ប្រែថា កល្យាណបុថុជ្ជន ។*

អធិសីលាទីនិ សិក្ខតីតិ សេក្ខោ។

ឈ្មោះថា **សេក្ខ** *ដោយអត្ថថា ញុំាងសិក្ខាអធិសីល ជាដើម ។*

សោតាបន្នោ វា សកទាគាមី វា អនាគាមី វា។

បានដល់ព្រះសោតាបន្ន ឬ ព្រះសកទាគាមី ឬ ព្រះអនាគាមី ។

អកុប្បោ ចលយិតុមសក្កុណេយ្យោ អរហត្តផលធម្មោ អស្សាតិ អកុប្បធម្មោ។

ឈ្មោះថា មានធម៌ដែលមិនកម្រើក ដោយអត្ថថា មានធម៌ គឺ អរហត្តផល ដែលមិនកម្រើក គឺអ្វីៗ មិនអាចនឹងធ្វើឲ្យញាប់ញ័របាន ។

សោបិ ហិ ឥមំ សមាធឹ ភាវេតិ។

ក៏ភិក្ខុសូម្បីនេះ រមែងចម្រើននូវសមាធិ ។

អរញ្ញនិទ្ទេសេ វិនយបរិយាយេន តាវ "បវេត្វា តាមញ្ច តាមូបចារញ្ច អរសេសំ អរញ្ញ"ន្តិ[៥៧] អាគតំ។

*នឹងវិនិច្ឆ័យ ក្នុងអរញ្ញនិទ្ទេសដូចតទៅនេះ ដោយពាក្យថា "**បវេត្វា តាមញ្ច តាមូបចារញ្ច អរសេសំ អរញ្ញំ** ប្រែថា ស្ថានទីដែលរៀរចាកផ្ទះ និង ឧបចារៈរបស់ផ្ទះចេញ ដ៏សេស ឈ្មោះថា ជាព្រៃ" (បានអធិប្បាយ) មកហើយ ក្នុងរឿងអរញ្ញនិទ្ទេស ដោយបរិយាយទៅតាមព្រះវិន័យ ។*

សុត្តន្តបរិយាយេន អរញ្ញកំ ភិក្ខុំ សន្ធាយ "អរញ្ញកំ នាម សេនាសនំ បញ្ចធនុសតិកំ បច្ឆិម"ន្តិ[៥៨] អាគតំ។

ពោលដោយបរិយាយតាមព្រះសូត្រ លោកសំដៅដល់ភិក្ខុជាអ្នកនៅក្នុង

---

៥៧ (បារា. ៩២) ។

៥៨ (បាចិ. ៥៧៣) ។

ព្រៃស្រាប់មកហើយ ក្នុងប្រយោគថា "សេនាសន: ដែលឆ្ងាយចេញទៅចំនួន យ៉ាងតិច ៥០០ ជួរធ្នូ ឈ្មោះថា ព្រៃ"

វិនយសុត្តន្តា បន ឧភោបិ បរិយាយទេសនា នាម, អភិជម្មោ និប្បរិយាយទេសនាតិ អភិជម្មបរិយាយេន[៥៩] **អរញ្ញំ ទស្សេតុំ "និក្ខមិត្វា ពហិ ឥន្ទខីលា"**តិ វុត្តំ, ឥន្ទខីលតោ ពហិ និក្ខមិត្វាតិ អត្ថោ។

ក៏ព្រះវិន័យ និងព្រះសូត្រទាំង ២ យ៉ាងនេះ ឈ្មោះថា ជាការទេសនា ដោយបរិយាយ, ព្រះអភិធម្មជាការទេសនាដោយនិបរិយាយ ព្រោះហេតុនោះ លោកប្រាថ្នានឹងសម្តែងនូវព្រៃ ដោយបរិយាយនៃព្រះអភិធម្ម ទើបឈ្មោះថា **និក្ខមិត្វា ពហិ ឥន្ទខីលា**, *សេចក្តីថា ចេញទៅខាងក្រៅ សសរគោល ដូច្នេះ។*

និក្ខមិត្វា ពហិ ឥន្ទខីលន្តិបិ ចាហោ, ឥន្ទខីលំ អតិក្ក្មិត្វា ពហីតិ វុត្តំ ហោតិ។

ព្រះបាលី **និក្ខមិត្វា ពហិ ឥន្ទខីលំ** *បែបនេះក៏មាន, មានអធិប្បាយថា នៅខាងក្រៅសសរគោល (គឺសសរខឿន) ។*

"ឥន្ទខីលោ"តិ ចេត្ថ តាមស្ស វា នតរស្ស វា ឧម្មារោ។

*ក៏ធរណីទ្វារនៃផ្ទះ ឬក្រុង ឈ្មោះថា "**សសរគោល (គឺសសរខឿន)**" ក្នុងទីនេះ ។*

រុក្ខមូលនិទ្ទេសេ រុក្ខមូលស្ស ចាកាជត្តា តំ អវត្វាវ "យត្ថា"តិ-**អាទិមាហ។**

*នឹងវិនិច្ឆ័យក្នុងនិទ្ទេសនៃរុក្ខមូលតទៅ លោកមិនបានពោលនូវរុក្ខមូល នោះ ព្រោះរុក្ខមូលបានប្រាកដមកហើយ បានពោលបទថា "**យត្ថ**" ដូច្នេះ ជាដើម ។*

---

៥៩ (វិភ. ៥២៩) ។

តត្ថ "យត្ថា"តិ យស្មឹ រុក្ខមូលេ។

*ក្នុងបណ្តាបទទាំងឡាយនោះ បទថា "**យត្ថ** ប្រែថា **ទីគល់ឈើ**" ។*

អាសន្តិ និសីទន្តិ ឯត្ថាតិ អាសនំ។

*ឈ្មោះថា **អាសន** ព្រោះអត្ថថា **ជាទីអង្គុយ** គឺការអង្គុយចុះ ។*

"បញ្ញត្ត"ន្តិ បឋិតំ។

*ពាក្យថា "**ទីចាត់ចែងទុក**" គឺទីតាំងទុក ។*

"មញ្ចោ វា"តិអាទីនិ អាសនស្ស បភេទវចនានិ។

*ពាក្យថា "**គ្រែ**" ជាដើម ជាពាក្យពោលប្រភេទរបស់អាសន: ។*

មញ្ចោបិ ហិ និសជ្ជាយបិ ឱកាសត្តា ឥធ អាសនេសុ វុត្តោ។

ពិតមែន សូម្បីគ្រែ លោកក៏ពោលទុកក្នុងអាសន:ទាំងឡាយក្នុងទីនេះ ព្រោះជាឱកាសសូម្បីតែការអង្គុយ ។

សោ បន មសារកពុន្ទិកាពទ្ធកុឡីរចាទកអាហច្ចចាទកាទំ អញ្ញតរោ។

ក៏គ្រែនោះ បានដល់ ប្រភេទគ្រែណាមួយក្នុងបណ្តាគ្រែដែលឈ្មោះថា មសារក ប្រែថា គ្រែប្រភេទដែលមានមេបញ្ចូលទៅខាងក្នុងជើងគ្រែ ពុន្ទិកាពទ្ធ ប្រែថា គ្រែដែលមានមេបង្វាំជាប់ជាមួយជើងគ្រែ កុឡីរបាទក ប្រែថា គ្រែដែលមានជើងដូចជាជើងក្តាម អាហច្ចបាទក ប្រែថា គ្រែដែលមានជើងទល់នឹងមេគ្រែ។

បីឋំ តេសំ អញ្ញតរមេវ។

*ពាក្យថា **តាំង** បានដល់ តាំងប្រភេទណាមួយ បណ្តាតាំងដែលមានលក្ខណៈដូចជាគ្រែ ប៉ុណ្ណោះឯង ។*

"កិសី"តិ ឧណ្ណាកិសិចោឌ្ឌកិសិវាកកិសិតិណាកិសិបណ្ណាកិសីនំ អញ្ញតរា។

*ពាក្យថា "**ពូកដេក**" បានដល់ ពូកដេកដោយប្រភេទណាមួយ បណ្តាពូកដេកដែលញាត់ដោយពោមសត្វ ពូកដេកដែលញាត់ដោយក្រណាត់ ពូកដេកញាត់ដោយសំបកឆ្មែ ពូកដេកញាត់ដោយស្មៅ និងពូកដេកញាត់ដោយស្លឹកឈើ។*

"តដ្ដិកា"តិ តាលបណ្ណាទីហិ ចិនិត្វា កតា។

*ពាក្យថា "**កន្ទេល**" បានដល់ កន្ទេលដែលត្បាញធ្វើដោយស្លឹកត្នោត ជាដើម។*

"ចម្មខណ្ឌោ"តិ ជិរជ្ជារហោ យោ កោចិ ចម្មខណ្ឌោ។

*ពាក្យថា "**កម្រាលស្បែក**" បានដល់ កម្រាលស្បែកប្រភេទណាមួយដែលគួរដល់ការអង្គុយ។*

តិណាសន្ថរឧយោ តិណាទីនិ កុម្ពេត្វា កតា។

***គ្រឿងក្រាលធ្វើដោយស្មៅ** ជាដើម បានដល់ គ្រឿងក្រាលដែលស្មៅវារួមគ្នាជាដើម ហើយបានធ្វើទុក។*

"តត្ថា"តិ តស្មឹ រុក្ខមូលេ។

*បទថា "**តត្ថ**" ប្រែថា កន្លែងគល់ឈើនោះ។*

"ចង្កមតិ វា"តិអាទីហិ រុក្ខមូលស្ស ចតុឥរិយាបថបវត្តនយោគ្យតា កថិតា។

*ពាក្យថា "**ចង្ក្រម**" ជាដើម លោកពោលសំដៅដល់គល់ឈើដែលជាកន្លែងសមគួរដល់ការញុំាងនូវឥរិយាបទទាំង ៤ ឲ្យប្រព្រឹត្តិទៅ។*

"យត្ថា"តិអាឌីហិ សព្វបទេហិ រុក្ខមូលស្ស សទ្ធិច្ចាយតា ជនវិវិត្តតា ច វុត្តា ហោតិ។

*បទទាំងពួងថា "**យត្ថ**" ជាដើម លោកពោលដល់ទីកន្លែងគល់ឈើដែលមានម្លប់ឈើនៅជិតៗ និងនៅវាលដែលមិនមានមនុស្ស ។*

"**កេនចី**"តិ កេនចិ សមូហេន។

*ពាក្យថា "**ដោយអ្នកណាៗ**" គឺដោយប្រជុំជនណា ។*

តំ សមូហំ កិន្តិត្វា វិត្តាវេន្តោ "**តហាដ្ឋេហិ វា បព្វជិតេហិ វា**"តិ អាហ។

*លោកកាលនឹងចែកប្រជុំជន ជននោះៗ ធ្វើឲ្យពិស្តារ ទើបពោលថា "**ជាគ្រហស្តក្តី ជាបព្វជិតក្តី**" ។*

"**អនាកិណ្ណោ**"ន្តិ អសំកិណ្ណោ អសម្ពាធំ។

*ពាក្យថា "**មិនខ្ចាត់ខ្ចាយ**" គឺមិនច្របូកច្របល់ មិនចង្អៀតចង្អល់ ។*

យស្ស សេនាសនស្ស សមន្តា ការុតម្បិ អឌ្ឍយោជនម្បិ បព្វតមហនំ វនមហនំ ឧទកមហនំ ហោតិ, ន កោចិ អវេលាយ ឧបសង្កមិតុំ សក្កោតិ, ឥទំ សន្តិកេបិ អនាកិណ្ណំ នាម។

ទីសេនាសនៈណាមានព្រៃស្បាតភ្នំ ព្រៃក្រាស់ ព្រៃទន្លេ នៅដោយជុំវិញមួយគាវុតខ្លះ កន្លះយោជន៍ខ្លះ, អ្នកណាៗ មិនអាចចូលទៅជិតបានក្នុងឱកាសដែលមិនមែនជាវេលា, សេនាសនៈនោះសូម្បីនៅជិតក៏ឈ្មោះថា មិនខ្ចាត់ខ្ចាយ។

យំ បន អឌ្ឍយោជនិកំ វា យោជនិកំ វា ហោតិ, ឥទំ ទូរតាយ ឯវ អនាកិណ្ណំ នាម។

ចំណែកសេនាសនៈណា មានរយៈប្រវែងកន្លះយោជន៍ ឬមួយយោជន៍, សេនាសនៈនេះក៏ឈ្មោះថា មិនខ្ចាត់ខ្ចាយ ព្រោះការនៅឆ្ងាយនោះឯង ។

"**វិហារោ**"តិ អឌ្ឍយោតាឧិមុត្តកោ អវសេសាវាសោ។

*ពាក្យថា "**វិហារ**" បានដល់ ស្ថានទីដែលនៅសល់អំពីផ្ទះស្ថាបគ្រុឧ ជាដើម ។*

"**អឌ្ឍយោតោ**"តិ សុបណ្ណវណ្ណកេហំ។

*ពាក្យថា "**ផ្ទះស្ថាបគ្រុឧ**" បានដល់ ផ្ទះដែលកោងដូចគ្រុឧ ។*

"**ចាសាឧោ**"តិ ឧេ កណ្ណិកា តហោត្វា កតោ ឧីយចាសាឧោ។

*ពាក្យថា "**ប្រាសាទ**" បានដល់ ប្រាសាទវែងដែលគេធ្វើជាប់ហោជាងទាំង ២ ។*

"**ហម្មិយ**"ន្តិ ឧបរិអាកាសតលេ បតិដ្ឋិតកូដាការចាសាឧោយេវ។

*ពាក្យថា "**ប្រាសាទត្រង៉ោល**" បានដល់ ប្រាសាទដែលជាផ្ទះកំពូល តាំងនៅលើអាកាសខាងលើ ។*

"**កុហា**"តិ ឥដ្ឋកាកុហា សិលាកុហា ឧារុកុហា បំសុកុហាតិ ឯវញ្ហិ ខន្ធកដ្ឋកថាយំ[60] វុត្តំ។

*ពាក្យថា "**ល្អាង**" បានដល់ ល្អាងឥដ្ឋ ល្អាងសិលា ល្អាងឈើ ល្អាងដី លោកបានពោលទុកហើយក្នុងអដ្ឋកថាខន្ធក: យ៉ាងនេះឯង ។*

វិភដ្ជដ្ឋកថាយំ បន "**វិហារោ**"តិ សមន្តា បរិហារបថំ អន្តោយេវ រត្តិដ្ឋានឧិវាដ្ឋានានិ ច ឧស្សេត្វា កតសេនាសនំ។

*ចំណែកអដ្ឋកថាវិភង្គ លោកពោលឲ្យវិសេស ២ យ៉ាង ដូច្នេះថា ពាក្យថា "**វិហារ**" បានដល់ សេនាសន:ដែលធ្វើមានផ្ទូវដើរជុំវិញបាន និងមានទីសម្រាក ពេលយប់ពេលថ្ងៃនៅខាងក្នុង ។*

"**កុហា**"តិ ភូមិកុហា, យត្ថ រត្តិន្ទិវំ ឧីបំ លទ្ធុំ វដ្ដតិ។

---

៦០ (ចូឡវ. អដ្ឋ. ២៩២) ។

*ពាក្យថា "**ល្អាង**" បានដល់ ល្អាងផែនដី, ដែលគួរនឹងបាននូវប្រទីបទាំងពេលថ្ងៃ និងពេលយប់ ។*

"បព្វតកុហា វា ភូមិកុហា វា"តិ ឥទំ ទ្វយំ វិសេសេត្វា វុត្តំ។

*បានដល់ "**ល្អាងក្នុងភ្នំ ឬ ល្អាងក្នុងផែនដី**" ដូច្នេះ ។*

មាតិកាយ សព្វកាលសាធារណេ លក្ខណេ សេន "និសីទតី"តិ វត្តមានវចនំ កតំ, ឥធ បន និសិន្នស្ស ភាវជាវម្ភសព្ភាវតោ និសជ្ជាវម្ភ-បរិយោសានទស្សនត្ថំ "និសិន្នោ"តិ និដ្ឋានវចនំ កតំ។

*ក្នុងមាតិកា លោកធ្វើពាក្យឲ្យជាបច្ចុប្បន្នកាលថា "**និសីទតិ** ប្រែថា **អង្គុយ**" ដោយអំណាចលក្ខណៈទូទៅដល់កាលទាំងអស់, តែនៅក្នុងទីនេះលោកធ្វើឲ្យជាពាក្យអតីតកាលថា "**និសិន្នោ** ប្រែថា **អង្គុយហើយ**" ដើម្បីនឹងសម្តែងទីបំផុតនៃការចាប់ផ្តើមនៃការអង្គុយ ព្រោះកិក្ខុអង្គុយហើយ ទើបមានការចាប់ផ្តើមចម្រើនភាវនា ។*

យស្មា បន ឧជុំ កាយំ បណិធាយ និសិន្នស្ស កាយោ ឧជុកោ ហោតិ, តស្មា ព្យញ្ជនេ អាទរំ អកត្វា អធិប្បេតមេវ ទស្សេន្តោ "ឧជុកោ"តិអាទិមាហ។

*ក៏ព្រោះ កាលកិក្ខុអង្គុយតាំងកាយឲ្យត្រង់ កាយរមែងត្រង់, ព្រោះដូច្នោះ លោកទើបមិនធ្វើការខ្វល់ខ្វាយក្នុងព្យញ្ជនៈ សម្តែងចំពោះរឿងដែលត្រូវការប្រាថ្នាប៉ុណ្ណោះ ដោយពោលពាក្យថា "**ឧជុកោ** ប្រែថា **ត្រង់**" ដូចនេះ ជាដើម ។*

តត្ថ "បិតោ សុបណិហិតោ"តិ ឧជុកំ បណិហិតត្តា ឧជុកោ ហុត្វា បិតោ, ន សយមេវាតិ អត្ថោ។

*ក្នុងពាក្យនោះ ពាក្យថា "**តាំងទុកហើយ តាំងទុកល្អហើយ**" មានសេចក្តីថា ព្រោះកិក្ខុតាំងកាយទុកឲ្យត្រង់ កាយទើបជាកាយត្រង់តាំងនៅបាន, គឺមិន*

មានការត្រង់ ដោយឯងៗទេ ។

"បរិក្ខហាដ្ឋោ"តិ បរិក្ខហិតដ្ឋោ។

*បទថា "**បរិក្ខហាដ្ឋោ** ប្រែថា មានអត្ថថា **កំណត់កាន់យក**" ។*

កឹ បរិក្ខហិតំ? និយ្យានំ។

តើកំណត់កាន់យកនូវអ្វី? គឺកំណត់កាន់យកនូវនិយាម គឺការនាំចេញទៅ ។

កឹ និយ្យានំ? អានាចានស្សតិសមាធិយេវ យាវ អរហត្តមគ្គា និយ្យានំ។

តើនិយាម បានដល់អ្វី ? បានដល់ អានាបានស្សតិសមាធិ នោះឯង រហូតដល់អរហត្តមគ្គ ទើបឈ្មោះថា និយាម ។

តេនាហនិយ្យានដ្ឋោតិ ។

*ព្រោះហេតុនោះ លោកទើបពោលថា "**និយ្យានដ្ឋោ** ប្រែថា មានអត្ថថា **នាំចេញទៅ**" ។*

មុខ-សទ្ទស្ស ជេដ្ឋកត្តវសេន សំសារតោ និយ្យានដ្ឋោ វុត្តោ។

*លោកពោលអត្ថ នៃ **មុខ**-សព្ទថា នាំចេញទៅចាកសង្សារ ដោយអំណាច មានអត្ថថា ចម្រើនទីបំផុត ។*

"ឧបដ្ឋានដ្ឋោ"តិ សភាវដ្ឋោយេវ។

*បទថា "**ឧបដ្ឋានដ្ឋោ** មានអត្ថថា **ប្រាកដ**" បានសេចក្តីថា មានអត្ថថា ជាសភាវៈនោះឯង ។*

សព្ពេហិ បនេតេហិ បទេហិ បរិក្ខហិតនិយ្យានំ សតឹ កត្វាតិ អត្ថោ វុត្តោ ហោតិ។

ក៏ព្រោះបទនេះទាំងអស់ ដែលលោកពោលថា ធ្វើសតិដែលមានការ

នាំចេញទៅ បានកំណត់កាន់យកហើយ ។

កេចិ បន "បរិគ្គហាដ្ឋោតិ សតិយា បរិគ្គហាដ្ឋោ, និយ្យានដ្ឋោតិ អស្សាសបស្សាសានំ បវិសននិក្ខមនទ្វារដ្ឋោ"តិ វណ្ណយន្តិ។

*ចំណែក កេចិអាចារ្យ បានពណ៌នាថា បទថា "**បរិគ្គហាដ្ឋោ** បានដល់ មានអត្ថថា កំណត់កាន់យកដោយសតិ, បទថា **និយ្យានដ្ឋោ** បានដល់ មានអត្ថថា ជាទ្វារចូល និងចេញនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ" ។*

បរិគ្គហិតអស្សាសបស្សាសនិយ្យានំ សតិ ឧបដ្ឋបេត្វាតិ វុត្តំ ហោតិ។

មានការអធិប្បាយថា ចូលទៅតាំងសតិដែលមានខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលបានកំណត់កាន់យកហើយ ជាផ្លូវនាំចេញទៅ ដូចនេះ។

ច្រាប់ទិធីនៃការរាប់ញាណសតោការី ๓๒ ញាណ (**បិដក ๗0**) [**๔๗**]

[๑๖๔] **"សតោវ អស្សសតិ, សតោ បស្សសតី"តិ** ពាត្តឹសាយ អាការេហិ **សតោការី** ហោតិ។

*ពាក្យថា "**យោគីភិក្ខុនោះ ជាអ្នកមានសតិ ខណៈដកដង្ហើមចូល កំណត់ដឹងថាចូល, ជាអ្នកមានសតិ ខណៈដកដង្ហើមចេញ កំណត់ដឹងថាចេញ**" អធិប្បាយថា ភិក្ខុអប់រំនូវសតិ ដោយអាការៈ ๓๒ យ៉ាង ។*

๑. **ឌីឃំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ, សតិ ឧបដ្ឋិតា ហោតិ។**

កាលភិក្ខុដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ

ដោយអំណាចនៃខ្យល់ដកដង្ហើមចូលវែង, សតិ ក៏តម្កល់នៅមាំ ។

តាយ សតិយា តេន ញាណេន សតោការី ហោតិ។

ភិក្ខុឈ្មោះថា ជាអ្នកអប់រំសតិ ដោយសតិស្មារតីនោះ ដោយញាណនោះ។

២. ទីឃំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ, សតិ ឧបដ្ឋិតា ហោតិ។

កាលភិក្ខុដឹងច្បាស់ នូវសភាពនៃចិត្តមានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចេញវែង, សតិ ក៏តម្កល់នៅមាំ ។

តាយ សតិយា តេន ញាណេន សតោការី ហោតិ។

ភិក្ខុឈ្មោះថា ជាអ្នកអប់រំសតិ ដោយសតិស្មារតីនោះ ដោយញាណនោះ ។

៣. រស្សំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ, សតិ ឧបដ្ឋិតា ហោតិ។

កាលភិក្ខុដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូលខ្លី, សតិ ក៏តម្កល់នៅមាំ ។

តាយ សតិយា តេន ញាណេន សតោការី ហោតិ។

ភិក្ខុឈ្មោះថា ជាអ្នកអប់រំសតិ ដោយសតិស្មារតីនោះ ដោយញាណនោះ។

៤. រស្សំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ, សតិ ឧបដ្ឋិតា ហោតិ។

កាលភិក្ខុដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចេញខ្លី, សតិ ក៏តម្កល់នៅមាំ ។

តាយ សតិយា តេន ញាណេន សតោការី ហោតិ។...ហេ....។

ភិក្ខុឈ្មោះថា ជាអ្នកអប់រំសតិ ដោយសតិស្មារតីនោះ ដោយញាណនោះ ។ល។

៣១. បដិនិស្សត្តានុបស្សី អស្សាសវសេន។

កាលភិក្ខុដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូល...ឈ្មោះថា ជាអ្នកអប់រំសតិ ដោយ សតិនោះ ដោយញាណនោះ ។

៣២. បដិនិស្សត្តានុបស្សី បស្សាសវសេន ចិត្តស្ស ឯកត្តតំ អវិក្ខេបំ បជានតោ, សតិ ឧបដ្ឋិតា ហោតិ។

កាលភិក្ខុដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចេញ សម្រាប់អ្នកពិចារណាឃើញនូវធម៌ ជាគ្រឿងរលាស់ចេញចាកកិលេស ដោយអំណាចនៃខ្យល់ដង្ហើមចេញ, សតិ ក៏តម្កល់នៅមាំ ។

តាយ សតិយា តេន ញាណេន សតោការី ហោតិ។

ភិក្ខុឈ្មោះថា ជាអ្នកអប់រំសតិ ដោយសតិស្មារតីនោះ ដោយញាណនោះ។

ចប់ការអប់រំសតិ ដោយអាការ ៣២ យ៉ាង

ទិធីរាប់ញាណសតោការី ៣២ ញាណ (អដ្ឋកថា)

[១៦៤] "**ពាត្តឹសាយ អាការេហី**"តិ តាសុ តាសុ អវត្ថាសុ យថាក្កមេន លព្ភមានានំ អនវសេសបរិយាជានវសេន វុត្តំ។

*ពាក្យថា "**ដោយអាការៈ ៣២ យ៉ាង**" លោកពោលដោយអំណាចការកំណត់កាន់យកមិនមានចំណែកសេសសល់ នូវអាការៈដែលមានទៅតាមលំដាប់ក្នុងបណ្ដាកិរិយាដែលតាំងទុកនោះ ។*

"ឌីយំ អស្សាសវសេនា"តិ មាតិកាយ "ឌីយ"ន្តិវុត្តអស្សាសវសេន។

*ពាក្យថា "**ដោយអំណាចខ្យល់ដកដង្ហើមចូលវែង**" លោកពោលទុកដោយអំណាចនៃខ្យល់ដកដង្ហើមចូល ដែលលោកពោលថា "វែង" នៅក្នុងមាតិកា ។*

ឯវំ សេសេសុ។ "ឯកក្ខត"ន្តិ ឯកក្ខការំ។ "អវិក្ខេប"ន្តិ អវិក្ខិបនំ។

*ក្នុងបទដ៏សេស ក៏យ៉ាងនេះ ។ បទថា "**ឯកក្ខតំ**" ប្រែថា ការៈដែលចិត្តមានអារម្មណ៍តែមួយ ។ បទថា "**អវិក្ខេបំ**" ប្រែថា សការៈមិនរាយមាយ ។*

ឯកក្ខតា ឯវ ហិ ជាជារម្មណេសុ ចិត្តស្ស អវិក្ខិបនតោ អវិក្ខេបោតិ វុច្ចតិ។

ការៈដែលចិត្តមានអារម្មណ៍តែមួយនោះឯង លោកហៅថា សការៈមិនរាយមាយ ព្រោះចិត្តមិនរាយមាយទៅក្នុងអារម្មណ៍ផ្សេងៗ ។

"បជានតោ"តិ អសម្មោហវសេន បជានន្តស្ស, វិជ្ជន្តស្សាតិ វា អត្ថោ។

*បទថា **បជានតោ** សេចក្ដីថា កំពុងដឹងឬ សេចក្ដីថា បានដឹងដោយអំណាចអសម្មោហៈ ។*

"អវិក្ខេបោ មេ បដិលទ្ធោ"តិ អារម្មណាការណវសេន បជានន្តស្ស វា។ "តាយ សតិយា"តិ តាយ ឧបដ្ឋិតាយ សតិយា។

ឬកំពុងដឹងដោយអំណាចធ្វើឲ្យជាអារម្មណ៍ថា "សេចក្ដីមិនរាយមាយ

*យើងបានហើយ" ដូចនេះ។ ពាក្យថា "**ដោយសតិនោះ**" គឺដោយសតិដែលចូលទៅតាំងទុកនោះ។*

"តេន ញាណេនា"តិ តេន អវិក្ខេបជាននញាណេន។

*ពាក្យថា "**ដោយញាណនោះ**" គឺដោយញាណដែលដឹងនូវភាពមិនរាយមាយនោះ។*

"សតោការី ហោតី"តិ ឯត្ថ យស្មា ញាណសម្បយុត្តា ឯវ សតិ សតីតិ អធិប្បេតា, យថាហ – "សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ"តិ(๖๑)។

*ក្នុងបទថា "**សតោការី ហោតិ** ប្រែថា **ជាអ្នកធ្វើសតិ**" នេះ ព្រោះហេតុថា សតិដែលសម្បយុត្តដោយញាណប៉ុណ្ណោះ លោកទើបប្រាថ្នាយកថាជាសតិ, ដូចដែលព្រះអង្គបានត្រាស់ទុកថា "ជាអ្នកមានសតិ ប្រកបដោយសតិគ្រប់គ្រងខ្លួនឯងយ៉ាងក្រៃលែង"ដូចនេះ។*

តស្មា "សតោ"តិ វចនេនេវ ញាណម្បិ តហិតមេវ ហោតិ។

*ព្រោះហេតុនោះ ដោយអំណាចពាក្យថា "**សតោ** ដែលប្រែថា មានសតិនោះឯង ជាការកាន់យកសូម្បីតែញាណក៏ដូចគ្នាដែរ។*

---

๖๑ (វិភ. ๘๖๗)។

បឋមចតុក្កនិទ្ទេសោ (ចិដក ៧០) [៩៨]

និទ្ទេសនៃចតុក្កទី ១

សម្តែងនូវវិធីបដិបត្តិ ៩ យ៉ាង

[១៦៦] **កថំ ទីឃំ អស្សសន្តោ "ទីឃំ អស្សសាមី"តិ បជានាតិ។ ទីឃំ បស្សសន្តោ "ទីឃំ បស្សសាមី"តិ បជានាតិ។**

សួរថា កាលភិក្ខុដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា "អាត្មាអញដកដង្ហើមចូលវែង"។ កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា "អាត្មាអញដកដង្ហើមចេញវែង" តើដូចម្តេច ?

ការកំណត់ដឹងនូវខ្យល់ដង្ហើមវែង ៩ យ៉ាង

១. ទីឃំ អស្សាសំ អទ្ធានសង្ខាតេ អស្សសតិ។

ធ្វើយថា យោគីភិក្ខុនោះ រមែងដកចូល នូវខ្យល់ដង្ហើមចូល ក្នុងចំណែកនៃកាលពេលវេលាកំណត់ថាវែង (គឺយូរ),

២. ទីឃំ បស្សាសំ អទ្ធានសង្ខាតេ បស្សសតិ។

យោគីភិក្ខុនោះ រមែងដកចេញ នូវខ្យល់ដង្ហើមចេញ ក្នុងចំណែកនៃកាលពេលវេលាកំណត់ថាវែង (គឺយូរ),

៣. ទីឃំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសតិបិ បស្សសតិបិ។

យោគីភិក្ខុនោះ រមែងដកចូលក្តី ដកចេញក្តី នូវខ្យល់ដង្ហើមចូល ឬខ្យល់ដង្ហើមចេញ ក្នុងចំណែកនៃកាលពេលវេលាកំណត់ថាវែង (គឺយូរ) (នេះហៅថា ដកដង្ហើមចូល វែង និងដកដង្ហើមចេញវែង) ។

ទីឃំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសតោបិ

បស្សសតោបិ ឆន្ទោ ឧប្បជ្ជតិ។

កាលភិក្ខុ រមែងដកចូលក្តី ដកចេញក្តី នូវខ្យល់ដង្ហើមចូលខ្លះ នូវខ្យល់ដង្ហើមចេញខ្លះ ក្នុងចំណែកនៃកាលពេលវេលាកំណត់ថាវែង (គឺយូរច្រើនៗដង), រីឯន្ទៈ (គឺចំណង់ក្នុងអ្វីមួយ) រមែងកើតឡើង ដល់ភិក្ខុនោះ។

๔. ឆន្ទវសេន តតោ សុខុមតរំ ទីឃំ អស្សាសំ អគ្គាណសង្ខាតេ អស្សសតិ។

កាលយោគីភិក្ខុ រមែងដកចូល នូវខ្យល់ដង្ហើមចូលវែង ដែលល្អិតសុខុមជាងនោះ ក្នុងចំណែក នៃកាលពេលវេលាកំណត់ថាវែង (គឺយូរ) ដោយអំណាចនៃឆន្ទៈ។

๕. ឆន្ទវសេន តតោ សុខុមតរំ ទីឃំ បស្សាសំ អគ្គាណសង្ខាតេ បស្សសតិ។

កាលយោគីភិក្ខុ រមែងដកចេញ នូវខ្យល់ដង្ហើមចេញវែង ដែលល្អិតសុខុមជាងនោះ ក្នុងចំណែក នៃកាលពេលវេលាកំណត់ថាវែង (គឺយូរ) ដោយអំណាចនៃឆន្ទៈ។

๖. ឆន្ទវសេន តតោសុខុមតរំ ទីឃំ អស្សាសបស្សាសំ អគ្គាណសង្ខាតេ អស្សសតិបិ បស្សសតិបិ។

យោគីភិក្ខុនោះ រមែងដកចូលក្តី ដកចេញក្តី នូវខ្យល់ដង្ហើមចូលវែង ឬខ្យល់ដង្ហើមចេញវែង ដែលល្អិតសុខុមជាងនោះ ក្នុងចំណែកនៃកាលពេលវេលាកំណត់ថាវែង (គឺយូរ) ដោយអំណាចនៃឆន្ទៈ។

ឆន្ទវសេន តតោ សុខុមតរំ ទីឃំ អស្សាសបស្សាសំ អគ្គាណ-សង្ខាតេ អស្សសតោបិ បស្សសតោបិ, ចាមោជ្ជំ ឧប្បជ្ជតិ។

កាលភិក្ខុដកចូលក្តី ដកចេញក្តី នូវខ្យល់ដង្ហើមចូលវែង ឬខ្យល់

ដង្ហើមចេញវែង ដែលល្អិតសុខុមជាងនោះ ក្នុងកាលពេលវេលាកំណត់ថាវែង(គឺយូរ) ដោយអំណាចនៃឆន្ទៈ(ច្រើនៗដង), វីរិយៈ(សេចក្តីព្យាយាម) រមែងកើតឡើង ដល់ភិក្ខុនោះ។

៧. ចាមោជ្ជវសេន តតោ សុខុមតរំ ទីឃំ អស្សាសំ អទ្ធានសង្ខាតេ អស្សសតិ។

យោគីភិក្ខុ រមែងដកចូល នូវខ្យល់ដង្ហើមចូលវែង ដែលល្អិតសុខុមជាងនោះ ក្នុងចំណែក នៃកាលពេលវេលាកំណត់ថាវែង (គឺយូរ) ដោយអំណាចនៃបាមោជ្ជៈ។

៨. ចាមោជ្ជវសេន តតោ សុខុមតរំ ទីឃំ បស្សាសំ អទ្ធានសង្ខាតេ បស្សសតិ ។

យោគីភិក្ខុ រមែងដកចេញ នូវខ្យល់ដង្ហើមចេញវែង ដែលល្អិតសុខុមជាងនោះ ក្នុងចំណែក នៃកាលពេលវេលាកំណត់ថាវែង (គឺយូរ) ដោយអំណាចនៃបាមោជ្ជៈ។

៩. ចាមោជ្ជវសេន តតោ សុខុមតរំ ទីឃំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសតិបិ បស្សសតិបិ។

យោគីភិក្ខុនោះ រមែងដកចូលក្តី ដកចេញក្តី នូវខ្យល់ដង្ហើមចូលវែង ឬខ្យល់ដង្ហើមចេញវែង ដែលល្អិតសុខុមជាងនោះ ក្នុងចំណែកនៃកាលពេលវេលាកំណត់ថាវែង(គឺយូរ) ដោយអំណាចនៃបាមោជ្ជៈ ។

ចាមោជ្ជវសេន តតោ សុខុមតរំ ទីឃំ អស្សាសបស្សាសំ អទ្ធានសង្ខាតេ អស្សសន្តោបិ បស្សសន្តោបិ ទីឃំ អស្សាសបស្សាសាបិ ចិត្តំ វិវត្តតិ, ឧបេក្ខា សណ្ឋាតិ។

កាលភិក្ខុ រមែងដកចូលក្តី ដកចេញក្តី នូវខ្យល់ដង្ហើមចូលវែង ឬខ្យល់

ដង្ហើមចេញវែង ដែលល្អិតសុខុមជាងនោះ ក្នុងចំណែកនៃកាលពេលវេលា កំណត់ថាវែង(គឺយូរ) ដោយអំណាចនៃបាមោជ្ជ: សេចក្តីរីករាយ (ច្រើនៗដង) ចិត្ត រមែងយ្ងាតចេញ អំពីខ្យល់ដង្ហើមចូលវែង ខ្យល់ដង្ហើមចេញវែង, រីសភាវ: ឧបេក្ខា រមែងតាំងនៅស៊ីប់ ។

ឥមេហិ នវហាការេហិ ឌីឃំ អស្សាសបស្សាសា កាយោ។

ខ្យល់ដកដង្ហើមចូលវែង និងខ្យល់ដកដង្ហើមចេញវែង ដោយអាការ:៩ យ៉ាងនេះ ឈ្មោះថា **កាយ** *។*

ឧបដ្ឋានំ សតិ, អនុបស្សនា ញាណំ។

សភាវ:ដែលចូលទៅតម្កល់ទុក ឈ្មោះថា សតិ, ការពិចារណាឃើញរឿយៗ ឈ្មោះថា ញាណ ។

កាយោ ឧបដ្ឋានំ, នោ សតិ ។ សតិ ឧបដ្ឋានញ្ចេវ សតិ ច។

កាយជាទីចូលទៅតម្កល់ទុក, មិនមែនជាសតិទេ ។ សតិជាសភាវ:ចូលទៅតម្កល់ទុកផង និងជាសតិផង ។

តាយ សតិយា តេន ញាណេន តំ កាយំ អនុបស្សតិ។

ភិក្ខុ រមែងពិចារណាឃើញរឿយៗនូវកាយនោះ ដោយសតិនោះ ដោយញាណនោះ។

តេន វុចូតិ – "កាយេ កាយានុបស្សនាសតិប្បដ្ឋានភាវនា"តិ។

ព្រោះហេតុនោះ លោកទើបពោលថា "សតិប្បដ្ឋានភាវនា គឺការពិចារណាឃើញនូវកាយក្នុងកាយ" ។

បឋមចតុក្កនិទ្ទេសោ

កំណត់ដឹងខ្យល់ដង្ហើមវែង ៩ យ៉ាង (អដ្ឋកថា)

[១៦៦] "**អទ្ធានសង្ខាតេ**"តិ ឌីឃសង្ខាតេ កាលេ។

*បទថា "**អទ្ធានសង្ខាតេ** ប្រែថា **ក្នុងកាលដែលពោលថាវែង**" ។*

ឌីឃោ ហិ មត្តោ អទ្ធានោតិ វុច្ចតិ។

ពិតមែន ផ្លូវឆ្ងាយ លោកហៅថា អទ្ធាន ។

អយម្បិ កាលោ ឌីឃត្តា អទ្ធានោ វិយ អទ្ធានោតិ វុត្តោ។

សូម្បីកាល ជាពេលវេលានេះ ក៏ដូចគ្នាជាមួយផ្លូវឆ្ងាយ ព្រោះជាវេលាវែងឆ្ងាយ លោកទើបហៅថា អទ្ធាន ។

"អស្សសតី"តិ ច "បស្សសតី"តិ ច អស្សាសញ្ច បស្សាសញ្ច វិសុំ វិសុំ វត្វាបិ ភាវនាយ និរន្តរប្បវត្តិឧស្សន្នត្តំ "អស្សសតិបិ បស្សសតិបី"តិ បុន សមាសេត្វា វុត្តំ។

*លោកសូម្បីពោលនូវ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ជាចំណែកៗ ថា "**អស្សសតិ**" និងពោលថា "**បស្សសតិ**" បែបនេះហើយ លោកបានពោលរួមសេចក្តីម្តងទៀតថា "**អស្សសតិបិ បស្សសតិបិ**" ដើម្បីនឹងសម្តែងនូវសេចក្តីប្រព្រឹត្តទៅជាប់តគ្នានៃការភាវនា ។*

"ឆន្ទោ ឧប្បជ្ជតី"តិ ភាវនាកិរិយ្ហិយា កិយ្យាការាយ ឆន្ទោ ជាយតិ។

*ពាក្យថា "**ឆន្ទៈរមែងកើតឡើង**" សេចក្តីថា ឆន្ទៈរមែងកើតដើម្បីសេចក្តីចម្រើនឡើងៗ ដើម្បីជាកិយ្យាការៈនៃការភាវនា ។*

"សុខុមតរ"ន្តិ បស្សម្ភនសព្ភាវតោ វុត្តំ។

*ពាក្យថា "**ល្អិតសុខុម**" លោកពោល ព្រោះមានសេចក្តីរម្ងាប់ ។*

"**ចាមោជ្ជំ ឧប្បជ្ជតី**"តិ ភាវនាចារិបូរិយា បីតិ ជាយតិ។

*ពាក្យថា **ចាមោជ្ជ:រមែងកើតឡើង** សេចក្តីថា បីតិរមែងកើតឡើង ដើម្បីភាពបរិបូរណ៌នៃភាវនា ។*

"**អស្សាសបស្សាសាបិ ចិត្តំ រិវត្តតី**"តិ អស្សាសបស្សាសេ និស្សាយ បដិភាគនិមិត្តេ ឧប្បជ្ជន្តេ បកតិអស្សាសបស្សាសតោ ចិត្តំ និវត្តតិ។

*ពាក្យថា "**ចិត្ត រមែងឃ្វាតចេញ សូម្បីពីខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ**" សេចក្តីថា កាលកើតឡើងនៃពន្ធឹបដិភាគនិមិត្ត អាស្រ័យខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ចិត្តរមែងងាកចេញពីខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ជាប្រក្រតី ។*

"**ឧបេក្ខា សណ្ឋាតី**"តិ តស្មឹ បដិភាគនិមិត្តេ ឧបចារប្បនាសមាធិ-បត្តិយា បុន សមាធានេ ព្យាចារាភាវតោ តត្រមជ្ឈត្តុបេក្ខា សណ្ឋាតិ នាម។

*ពាក្យថា "**ឧបេក្ខា រមែងតាំងនៅស៊ប់**" សេចក្តីថា ព្រោះបានបន្ទុះឧបចារ: សមាធិ និងអប្បនាសមាធិ ក្នុងពន្ធឹបដិភាគនិមិត្តនោះ ឈ្មោះថា តត្រមជ្ឈត្តុ-បេក្ខា រមែងតាំងនៅស៊ប់ ព្រោះមិនមានភាពខូល់ខ្ទាយក្នុងសមាធិទៀត ។*

"**នវហាការេហី**"តិ ឯត្ត ភាវនារម្ភតោ បកុតិ បុរេ ឆន្ទុប្បាទា "អស្សសតិបិ បស្សសតិបី"តិ វុត្តា តយោ អាការា, ឆន្ទុប្បាទតោ បកុតិ បុរេ ចាមោជ្ជុប្បាទា តយោ, ចាមោជ្ជុប្បាទតោ បកុតិ តយោតិ នវ អាការា។

*ក្នុងពាក្យថា **ដោយអាការ: ៩ យ៉ាងនេះ** គប្បីជ្រាបវិនិច្ឆ័យថា អាការ: ៩ យ៉ាង គឺ អាការ: ៣ យ៉ាង ដែលលោកពោលទុកថា "**អស្សសតិបិ** ប្រែថា ដកដង្ហើមចូល **បស្សសតិបិ** ប្រែថា ដកដង្ហើមចេញ" ចាប់ផ្តើមតាំងតែភាវនា មុនដែលឆន្ទ:នឹងកើត, អាការ: ៣ យ៉ាង ចាប់តាំងតែឆន្ទ:កើត ហើយមុនពេល*

ដែលបាមោជ្ជៈកើត, អាការៈ ៣ យ៉ាង ចាប់តាំងតែបាមោជ្ជៈកើតឡើងទៅ ។

"កាយោ"តិ ចុណ្ណាវិចុណ្ណាបិ អស្សាសបស្សាសា សមូហដ្ឋេន កាយោ។

*ពាក្យថា "**កាយ**" បានសេចក្តីថា ខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ សូម្បីល្អិតសុខុមដ៏ក្រៃលែង ក៏ឈ្មោះថា កាយ ដោយអត្ថថា ប្រជុំ ។*

បកតិអស្សាសបកតិបស្សាសេ និស្សាយ ឧប្បន្ននិមិត្តម្បិ អស្សាសបស្សាសាតិ ជាមំ លភតិ។

សូម្បីនិមិត្តដែលកើតឡើង ក៏អាស្រ័យខ្យល់ដង្ហើមចូលជាប្រក្រតី និងខ្យល់ដង្ហើមចេញជាប្រក្រតី ក៏បានឈ្មោះថា អស្សាសៈបស្សាសៈ ។

"ឧបដ្ឋានំ សតី"តិ តំ អារម្មណំ ឧបេច្ច តិដ្ឋតីតិ សតិ ឧបដ្ឋានំ ជាម។

*ពាក្យថា **សភាវៈដែលចូលទៅតម្កល់ទុក** ឈ្មោះថា **សតិ** មានសេចក្តីថា សតិ ឈ្មោះថា ឧបដ្ឋានៈ ប្រែថា គឺសភាវៈដែលចូលទៅតម្កល់ទុក ដោយអត្ថថា ចូលទៅអាស្រ័យអារម្មណ៍នោះហើយក៏តាំងនៅ ។*

"អនុបស្សនា ញាណា"ន្តិ សមថវសេន និមិត្តកាយានុបស្សនា, វិបស្សនាវសេន ជាមកាយរូបកាយានុបស្សនា ញាណន្តិ អត្ថោ។

*ពាក្យថា "**អនុបស្សនា**" ឈ្មោះថា **ញាណ** មានសេចក្តីថា ការពិចារណាឃើញកាយ គឺនិមិត្តដោយអំណាចសមថៈ, ការពិចារណាឃើញកាយ គឺនាមកាយ និងរូបកាយ ដោយអំណាចវិបស្សនា ឈ្មោះថា ញាណ ។*

"កាយោ ឧបដ្ឋាន"ន្តិ សោ កាយោ ឧបេច្ច តិដ្ឋតិ ឯត្ថ សតីតិ ឧបដ្ឋានំ ជាម។

*ពាក្យថា "**កាយ ឈ្មោះថា ឧបដ្ឋាន**" មានសេចក្តីថា កាយនោះឈ្មោះថា **ឧបដ្ឋាន** ដោយអត្ថថា ជាទីចូលទៅអាស្រ័យតាំងនៅនៃសតិ ។*

"នោ សតី"តិ សោ កាយោ សតិ នាម ន ហោតីតិ អត្ថោ។

*ពាក្យថា "**មិនមែនជាសតិទេ**" មានសេចក្តីថា កាយនោះមិនឈ្មោះថា ជាសតិទេ។*

"តាយ សតិយា"តិ ឥជានិ វុត្តាយ សតិយា។

*ពាក្យថា "**ដោយសតិនោះ**" គឺដោយសតិដែលពោលនៅពេលនេះ ។*

"តេន ញាណេនា"តិ ឥជានេវ វុត្តេន ញាណេន។

*ពាក្យថា "**ដោយញាណនោះ**" មានសេចក្តីថា ដោយញាណដែលពោលនៅពេលនេះ ដូចគ្នា ។*

"តំ កាយំ អនុបស្សតី"តិ សមថវិបស្សនាវសេន យថាវុត្តំ កាយំ អនុតន្ត្វា ឈានសម្បយុត្តញាណេន វា វិបស្សនាញាណេន វា បស្សតិ។

*ពាក្យថា "**រមែងពិចារណាឃើញរឿយៗនូវកាយនោះ**" មានសេចក្តីថា ទៅតាមកាយ តាមដែលបានពោលហើយ ដោយអំណាចសមថ: និងវិបស្សនា ហើយឃើញដោយញាណដែលសម្បយុត្តដោយឈាន ឬដោយវិបស្សនា-ញាណ ។*

មាតិកាយ កាយាជីនំ បជានំ អភាវេបិ ឥមស្ស ចតុក្កស្ស កាយានុបស្សនាវសេន វុត្តត្តា ឥជានិ វត្តព្ទំ "កាយេ កាយានុបស្សនា សតិប្បដ្ឋានភាវនា"តិ វចនំ សន្ធាយ កាយបជនិជ្ជេសោ កតោ។

សូម្បីកាលមិនមានបទទាំងឡាយ ដែលមានបទថា កាយ ជាដើម ក្នុងមាតិកា លោកក៏ធ្វើនូវនិទ្ទេស បទថា កាយ សំដៅដល់ពាក្យថា "ចម្រើនសតិប្បដ្ឋាន គឺការពិចារណាឃើញនូវកាយក្នុងកាយ" ដែលនឹងគប្បីពោលក្នុងពេលនេះ ព្រោះចតុក្ក:នេះ លោកពោលដោយអំណាចកាយានុបស្សនា ។

"កាយេ កាយានុបស្សនា"តិ ពហុវិធេ កាយេ តស្ស តស្ស

កាយស្ស អនុបស្សនា។

*ពាក្យថា "**ពិចារណាឃើញកាយក្នុងកាយ**" បានសេចក្តីថា ពិចារណាឃើញរឿយៗនូវកាយនោះៗ ក្នុងកាយច្រើនយ៉ាង ។*

អថ វា កាយេ កាយានុបស្សនា, ន អញ្ញធម្មានុបស្សនាតិ វុត្តំ ហោតិ។

ម្យ៉ាងទៀតមានពាក្យអធិប្បាយថា ពិចារណាឃើញរឿយៗនូវកាយក្នុងកាយ, មិនមែនពិចារណាឃើញធម្មយ៉ាងដទៃទេ ។

អនិច្ចទុក្ខានត្តាសុភតូតេ កាយេ ន និច្ចសុខត្តសុភានុបស្សនា, អថ ខោ អនិច្ចទុក្ខានត្តាសុភតោ កាយស្សេវ អនុបស្សនា។

មិនមែនពិចារណាឃើញថា ទៀង ថាជាសុខ ថាជាអត្តា ថាស្អាត ក្នុងកាយ ដែលជារបស់មិនទៀង ជាទុក្ខ ជាអនត្តា មិនស្អាត, ជាការពិតពិចារណាឃើញកាយនោះឯង ជារបស់មិទៀង ជាទុក្ខ ជាអនត្តា និងមិនស្អាត ។

អថ វា កាយេ អហន្តិ វា មមន្តិ វា ឥត្ថីតិ វា បុរិសោតិ វា តហោ-តព្វស្ស កស្សចិ អនុបស្សនតោ តស្សេវ កាយមត្តស្ស អនុបស្សនាតិ វុត្តំ ហោតិ។

ន័យម្យ៉ាងទៀត មានអធិប្បាយថា ពិចារណាឃើញថាគ្រាន់តែជាកាយនោះឯង ព្រោះមិនពិចារណាឃើញអ្វីៗ ដែលនឹងកាន់យកថា ជាយើងខ្ញុំ ថាជារបស់យើងខ្ញុំ ថាជាមនុស្សស្រីខ្ញុំ ថាជាមនុស្សប្រុសខ្ញុំ ក្នុងកាយឡើយ ។

ឧបរិ "វេទនាសុ វេទនានុបស្សនា"តិអាទីសុ តីសុបិ ឯសេវ នយោ។

*ក្នុងបទទាំង ៣ មានអាទិថា "**ពិចារណាឃើញវេទនាក្នុងវេទនា**" ដូចនេះក៏មានន័យដូចគ្នា ។*

សតិយេវ ឧបដ្ឋានំ សតិបដ្ឋានំ, កាយានុបស្សនាយ សម្បយុត្តំ

សតិបដ្ឋានំ កាយានុបស្សនាសតិបដ្ឋានំ, តស្ស ភាវនា កាយានុបស្សនាសតិប្បដ្ឋានភាវនា។

សភាវៈចូលទៅតម្កល់ទុក គឺសតិ ឈ្មោះថា សតិប្បដ្ឋាន, សតិប្បដ្ឋាន ដែលសម្បយុត្តដោយកាយានុបស្សនា ឈ្មោះថា កាយានុបស្សនាសតិប្បដ្ឋាន, ការចម្រើនកាយានុបស្សនាសតិប្បដ្ឋាននោះ ឈ្មោះថា ***កាយានុបស្សនាសតិ-ប្បដ្ឋានភាវនា*** *។*

តិក្ខពិចារណាឃើញរឿយៗ ๗ យ៉ាង (បិដក ๗๐) [๙๙]

[๑๖๗] "***អនុបស្សតី***"តិ កថំ តំ កាយំ អនុបស្សតិ?

*សំនួរត្រង់ពាក្យថា "**តិក្ខពិចារណាឃើញរឿយៗ**" តើតិក្ខពិចារណាឃើញនូវកាយនោះ ដូចម្តេច?*

๑. **អនិច្ចតោ អនុបស្សតិ, នោ និច្ចតោ។**

តិក្ខពិចារណាឃើញថា មិនទៀង, មិនមែនថាទៀងទេ។

๒. **ទុក្ខតោ អនុបស្សតិ, នោ សុខតោ។**

ពិចារណាឃើញថា ជាទុក្ខ, មិនមែនថាជាសុខទេ។

๓. **អនត្តតោ អនុបស្សតិ, នោ អត្តតោ។**

ពិចារណាឃើញថា មិនមែនខ្លួន, មិនមែនថាជាខ្លួនឯងទេ។

๔. **និព្វិន្ទតិ, នោ នន្ទតិ។**

តែងនឿយណាយ, មិនមែនរីករាយទេ។

៤. **វិរជ្ជតិ, ន្តោ រជ្ជតិ។**

តែងជិនឆ្ពន់, មិនមែនត្រេកអរត្រអាលនោះទេ ។

៦. **និរោធេតិ, ន្តោ សមុទេតិ។**

តែងរំលត់បង់, មិនមែនឲ្យកើតទេ ។

៧. **បដិនិស្សជ្ជតិ, ន្តោ អាទិយតិ។**

តែងរលាស់ចោល, មិនមែនចាប់ប្រកាន់ទេ ។

ចានអានិសង្ស ៧ យ៉ាង

១. **អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហតិ។**

កិក្ខុកាលពិចារណាឃើញថា មិនទៀង រមែងលះបង់នូវនិច្ចសញ្ញា ។

២. **ទុក្ខតោ អនុបស្សន្តោ សុខសញ្ញំ បជហតិ។**

កិក្ខុកាលពិចារណាឃើញថា ជាទុក្ខរឿយៗ រមែងលះបង់នូវសុខសញ្ញា។

៣. **អនត្តតោ អនុបស្សន្តោ អត្តសញ្ញំ បជហតិ។**

កិក្ខុកាលពិចារណាឃើញថា មិនមែនខ្លួន រមែងលះបង់នូវអត្តសញ្ញា ។

៤. **និព្ពិន្ទន្តោ នន្ទឹ បជហតិ។**

កិក្ខុកាលនឿយណាយ រមែងលះបង់នូវសេចក្តីរីករាយ ។

៥. **វិរជ្ជន្តោ រាគំ បជហតិ។**

កិក្ខុកាលជិនឆ្ពន់ រមែងលះបង់នូវរាគៈ ។

៦. **និរោធេន្តោ សមុទយំ បជហតិ។**

កិក្ខុកាលរំលត់ រមែងលះបង់នូវហេតុជាគ្រឿងឲ្យកើត

៧. បដិនិស្សជ្ជន្តោ អាជានំ បជហតិ។

ភិក្ខុកាលរលាស់ចោល រមែងលះបង់នូវសេចក្តីប្រកាន់ ។

ឯវំ តំ កាយំ អនុបស្សតិ។

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយនោះ យ៉ាងនេះឯង ។

អត្ថនៃពាក្យថា ភាវនា មាន ៤ យ៉ាង

"**ភាវនា**"តិ ចតស្សោ ភាវនា –

*ពាក្យថា "**ភាវនា**" បានដល់ភាវនា ៤ យ៉ាងគឺះ*

១. តត្ត ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា,

"ភាវនា" ដោយអត្ថថា មិនប្រព្រឹត្តកន្ធង់នូវពួកធម៌ (គឺសង្ខារខន្ធ) ដែលកើតក្នុង់មគ្គនោះ ឬ (កើតក្នុង់ទីនោះ មិនឲ្យកន្ធង់គ្នា និង់គ្នាបាន) ១ ,

២. ឥន្ទ្រិយានំ ឯករសដ្ឋេន ភាវនា,

"ភាវនា" ដោយអត្ថថា ឥន្ទ្រិយទាំង់ឡាយមានរសតែមួយ ១,

៣. តជុបតវីរិយវាហនដ្ឋេន ភាវនា,

"ភាវនា" ដោយអត្ថថា នាំមកនូវសេចក្តីព្យាយាម ដែលសមគួរដល់ឥន្ទ្រិយនោះ ១,

៤. អាសេវនដ្ឋេន ភាវនា។

"ភាវនា" ដោយអត្ថថា ប្រព្រឹត្ត គឺប្រើប្រាស់ឲ្យជាប្រចាំ ឲ្យជំនាញ ១,

ចិត្តដែលមានឧបចារ

ជីឃំ អស្សាសបស្សាសវសេន ចិត្តស្ស ឯកត្តតំ អវិក្ខេបំ បជានតោ,

កាលភិក្ខុដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ (គឺចិត្តដែលមានឧបចារៈដ៏មានកម្លាំង) ដោយអំណាចនៃខ្យល់ដង្ហើមចូលវែង និងខ្យល់ដង្ហើមចេញវែង,

១. វិទិតា វេទនា ឧប្បជ្ជន្តិ,

វេទនាដ៏ប្រាកដ រមែងកើតឡើង,

២. វិទិតា ឧបដ្ឋហន្តិ,

វេទនាដ៏ប្រាកដ រមែងតាំងឡើង,

៣. វិទិតា អព្ភត្ថំ គច្ឆន្តិ។

វេទនាដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស ។

១. វិទិតា សញ្ញា ឧប្បជ្ជន្តិ,

សញ្ញាដ៏ប្រាកដ រមែងកើតឡើង,

២. វិទិតា ឧបដ្ឋហន្តិ,

សញ្ញាដ៏ប្រាកដ រមែងតាំងឡើង,

.៣ វិទិតា អព្ភត្ថំ គច្ឆន្តិ។

សញ្ញាដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស ។

១. វិទិតា វិតក្កា ឧប្បជ្ជន្តិ,

វិតក្កៈដ៏ប្រាកដ រមែងកើតឡើង,

២. វិទិតា ឧបដ្ឋហន្តិ,

វិតក្កៈដ៏ប្រាកដ រមែងតាំងឡើង,

៣. វិទិតា អព្ភត្ថំ គច្ឆន្តិ។

វិតក្កៈដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស ។

អធិប្បាយអំពី វេទនា

កថំ វិទិតា វេទនា ឧប្បជ្ជន្តិ, វិទិតា ឧបដ្ឋហន្តិ, វិទិតា អព្ភត្ថំ កច្ឆន្តិ?

វេទនាដ៏ប្រាកដ រមែងកើតឡើង, វេទនាដ៏ប្រាកដ រមែងតាំងឡើង, វេទនាដ៏ប្រាកដ រមែងដល់នូវសេក្តីវិនាស តើដូចម្តេច ?,

កថំ វេទនាយ ឧប្បាទោ វិទិតោ ហោតិ?

ការកើតឡើងនៃវេទនា រមែងប្រាកដ តើដូចម្តេច ?

๑. **"អវិជ្ជាសមុទយា វេទនាសមុទយោ"តិ– បច្ចយសមុទយដ្ឋេន វេទនាយ ឧប្បាទោ វិទិតោ ហោតិ។**

ការកើតឡើងនៃវេទនាដ៏ប្រាកដ ដោយអត្ថថា កើតឡើងព្រោះបច្ច័យ ព្រោះយល់ថា "ការកើតឡើងនៃវេទនា ព្រោះកើតឡើងនៃអវិជ្ជា" ។

๒. **"តណ្ហាសមុទយា វេទនាសមុទយោ"តិ។...បេ...។**

ព្រោះយល់ថា "ការកើតឡើងនៃវេទនា ព្រោះការកើតឡើង នៃតណ្ហា" ។...ល..។

๓. **"កម្មសមុទយា វេទនាសមុទយោ"តិ។...បេ...។**

ព្រោះយល់ថា "ការកើតឡើងនៃវេទនា ព្រោះការកើតឡើងនៃកម្ម"។..ល...។

๔. **"ផស្សសមុទយា វេទនាសមុទយោ"តិ បច្ចយសមុទយដ្ឋេន វេទនាយ ឧប្បាទោ វិទិតោ ហោតិ។**

ការកើតឡើងនៃវេទនាដ៏ប្រាដក ដោយអត្ថថា កើតឡើងព្រោះបច្ច័យ ព្រោះយល់ថា "ការកើតឡើងនៃវេទនា ព្រោះការកើតឡើងនៃផស្សៈ" ។

ឯវត្តិលក្ខណា បស្សតោបិ វេទនាយ ឧប្បាទោ វិទិតោ ហោតិ។

កាលកិក្ខុពិចារណាឃើញនូវលក្ខណៈនៃកំណើត ការកើតឡើងនៃវេទនា ក៏ប្រាកដឡើង ។

ឯវំ វេទនាយ ឧប្បាដោ វិទិតោ ហោតិ។

ការកើតឡើងនៃវេទនា រមែងប្រាកដ យ៉ាងនេះឯង ។

ការតាំងឡើងរបស់វេទនា

កថំ វេទនាយ ឋបដ្ឋានំ វិទិតំ ហោតិ?

ការតាំងឡើងនៃវេទនា រមែងប្រាកដ តើដូចម្តេច?

១. អនិច្ចតោ មនសិករោតោ ខយតុបដ្ឋានំ វិទិតំ ហោតិ។

កាលកិក្ខុធ្វើទុកក្នុងចិត្តថា មិនទៀង ការតាំងឡើងថា អស់ទៅ រមែងប្រាកដ ។

២. ទុក្ខតោ មនសិករោតោ ភយតុបដ្ឋានំ វិទិតំ ហោតិ។

កាលកិក្ខុធ្វើទុកក្នុងចិត្តថា ជាទុក្ខ ការតាំងឡើងថា គួរខ្លាច រមែងប្រាកដ។

៣. អនត្តតោ មនសិករោតោ សុញ្ញតុបដ្ឋានំ វិទិតំ ហោតិ។

កាលកិក្ខុធ្វើទុកក្នុងចិត្តថា មិនមែនជាខ្លួន ការតាំងឡើងថា សូន្យ រមែងប្រាកដ ។

ឯវំ វេទនាយ ឧបដ្ឋានំ វិទិតំ ហោតិ។

ការតាំងឡើងនៃវេទនា រមែងប្រាកដ យ៉ាងនេះឯង ។

ការរលត់ទៅរបស់វេទនា

កថំ វេទនាយ អត្ថង្គមោ វិទិតោ ហោតិ?

ការដល់នូវសេចក្តីវិនាសនៃវេទនា រមែងប្រាកដ តើដូចម្តេច?

๑. **អវិជ្ជានិរោធា វេទនានិរោធោតិ – បច្ចយនិរោធេន វេទនាយ អត្ថង្គមោ វិទិតោ ហោតិ។**

ការដល់នូវសេចក្តីវិនាសនៃវេទនា រមែងប្រាកដ ដោយអត្ថថា រលត់នៃបច្ច័យ ព្រោះយល់ថា ការរលត់វេទនា ព្រោះការរលត់នៃអវិជ្ជា ។

๒. **"តណ្ហានិរោធា វេទនានិរោធោ"តិ ។...បេ...។**

ព្រោះយល់ថា "ការរលត់វេទនា ព្រោះការរលត់នៃតណ្ហា" ។...ល...។

๓. **"កម្មនិរោធា វេទនានិរោធោ"តិ។...បេ...។**

ព្រោះយល់ថា "ការរលត់វេទនា ព្រោះការរលត់នៃកម្ម" ។...ល...។

๔. **ផស្សនិរោធា វេទនានិរោធោតិ បច្ចយនិរោធេន វេទនាយ អត្ថង្គមោ វិទិតោ ហោតិ។**

ការដល់នូវសេចក្តីវិនាសនៃវេទនា រមែងប្រាកដ ដោយអត្ថថា រលត់នៃបច្ច័យ ព្រោះយល់ថា ការរលត់នៃវេទនា ព្រោះការរលត់ទៅនៃផស្សៈ ។

๕. **វិបរិណាមលក្ខណំ បស្សតោបិ វេទនាយ អត្ថង្គមោ វិទិតោ ហោតិ។**

កាលកិក្ខពិចារណាឃើញនូវលក្ខណៈ នៃការប្រែប្រួល ការដល់នូវសេចក្តីវិនាសនៃវេទនា រមែងប្រាកដ ។

ឯវំ វេទនាយ អត្ថង្គមោ វិទិតោ ហោតិ។

សេក្តីវិនាសនៃវេទនា រមែងប្រាកដ យ៉ាងនេះ ។

ឯវំ វិទិតា វេទនា ឧប្បជ្ជន្តិ, វិទិតា ឧបដ្ឋហន្តិ, វិទិតា អព្ភត្ថំ គច្ឆន្តិ។

វេទនាដ៏ប្រាកដ រមែងកើតឡើង, វេទនាដ៏ប្រាកដ រមែងតាំងឡើង, វេទនាដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស យ៉ាងនេះ ។

អធិប្បាយអំពី សញ្ញា

កថំ វិទិតា សញ្ញា ឧប្បជ្ជន្តិ, វិទិតា ឧបដ្ឋហន្តិ, វិទិតា អព្ភត្ថំ កច្ឆន្តិ?

សញ្ញាដ៏ប្រាកដ រមែងកើតឡើង, សញ្ញាដ៏ប្រាកដ រមែងតាំងឡើង, សញ្ញាដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស តើដូចម្តេច?

កថំ សញ្ញាយ ឧប្បាដោ វិទិតោ ហោតិ?

ការកើតឡើងនៃសញ្ញា រមែងប្រាកដ តើដូចម្តេច?

១. អវិជ្ជាសមុទយា សញ្ញាសមុទយោតិ – បច្ចយសមុទយដ្ឋេន សញ្ញាយ ឧប្បាដោ វិទិតោ ហោតិ។

ការកើតឡើងនៃសញ្ញា រមែងប្រាកដ ដោយអត្ថថា កើតឡើងព្រោះបច្ច័យ ព្រោះយល់ថា ការកើតឡើងនៃសញ្ញា ព្រោះការកើតឡើងនៃអវិជ្ជា។

២. "តណ្ហាសមុទយា សញ្ញាសមុទយោ"តិ។...បេ...។

ព្រោះយល់ថា "ការកើតឡើងនៃសញ្ញា ព្រោះការកើតឡើងនៃតណ្ហា"។...ល...។

៣. "កម្មសមុទយា សញ្ញាសមុទយោ"តិ។...បេ...។

ព្រោះយល់ថា "ការកើតឡើងនៃសញ្ញា ព្រោះការកើតឡើងនៃកម្ម"។...ល...។

៤. ផស្សសមុទយា សញ្ញាសមុទយោតិ – បច្ចយសមុទយដ្ឋេន សញ្ញាយ ឧប្បាដោ វិទិតោ ហោតិ។

ការកើតឡើងនៃសញ្ញា រមែងប្រាកដ ដោយអត្ថថា កើតឡើងព្រោះបច្ច័យ ព្រោះយល់ថា ការកើតឡើងនៃសញ្ញា ព្រោះការកើតឡើងនៃផស្សៈ។

៥. ឥព្ភត្តិលក្ខណំ បស្សតោបិ សញ្ញាយ ឧប្បាដោ វិទិតោ ហោតិ។

កាលកិក្ខុពិចារណាឃើញនូវលក្ខណៈនៃកំណើត ការកើតឡើងនៃសញ្ញា រមែងប្រាកដ។

ឯវំ សញ្ញាយ ឧប្បាដោ វិដិតោ ហោតិ។

ការកើតឡើងនៃសញ្ញា រមែងប្រាកដ យ៉ាងនេះឯង ។

ការតាំងឡើងរបស់សញ្ញា

កថំ សញ្ញាយ ឧបដ្ឋានំ វិដិតំ ហោតិ?

ការតាំងឡើងនៃសញ្ញា រមែងប្រាកដ តើដូចម្តេច?

๑. អនិច្ចតោ មនសិកពោតោ ខយតុបដ្ឋានំ វិដិតំ ហោតិ។

កាលកិក្ខុធ្វើទុកក្នុងចិត្តថា មិនទៀង ការតាំងឡើងថា អស់ទៅ រមែងប្រាកដ ។

๒. ទុក្ខតោ មនសិកពោតោ ភយតុបដ្ឋានំ វិដិតំ ហោតិ។

កាលកិក្ខុធ្វើទុកក្នុងចិត្តថា ជាទុក្ខ ការតាំងឡើងថា គួរខ្លាច រមែងប្រាកដ។

๓. អនត្តតោ មនសិកពោតោ សុញ្ញតុបដ្ឋានំ វិដិតំ ហោតិ។

កាលកិក្ខុធ្វើទុកក្នុងចិត្តថា មិនមែនខ្លួន ការតាំងឡើងថា សូន្យ រមែងប្រាកដ។

ឯវំ សញ្ញាយ ឧបដ្ឋានំ វិដិតំ ហោតិ។

ការតាំងឡើងនៃសញ្ញា រមែងប្រាកដ យ៉ាងនេះឯង ។

ការរលត់ទៅរបស់សញ្ញា

កថំ សញ្ញាយ អត្ថង្គមោ វិដិតោ ហោតិ?

ការដល់នូវសេចក្តីវិនាសនៃសញ្ញា រមែងប្រាកដ តើដូចម្តេច?

๑. អវិជ្ជានិរោធា សញ្ញានិរោធោតិ – បច្ចយនិរោធេន សញ្ញាយ អត្ថង្គមោ វិដិតោ ហោតិ។

ការដល់នូវសេចក្តីវិនាសនៃសញ្ញា រមែងប្រាកដ ដោយអត្ថថា រលត់បច្ច័យ ព្រោះយល់ថា ការរលត់នៃសញ្ញា ព្រោះការរលត់នៃអវិជ្ជា ។

២. "តណ្ហានិរោធា សញ្ញានិរោធោ"តិ។...បេ...។

ព្រោះយល់ថា "ការរលត់នៃសញ្ញា ព្រោះការរលត់នៃតណ្ហា"។...ល...។

៣. "កម្មនិរោធា សញ្ញានិរោធោ"តិ។...បេ...។

ព្រោះយល់ថា "ការរលត់នៃសញ្ញា ព្រោះការរលត់នៃកម្ម"។...ល...។

៤. ផស្សនិរោធា សញ្ញានិរោធោតិ – បច្ចយនិរោធដ្ឋេន សញ្ញាយ អត្ថង្គមោ វិនិតោ ហោតិ។

ការដល់នូវសេចក្តីវិនាសនៃសញ្ញា រមែងប្រាកដ ដោយអត្ថថា រលត់បច្ច័យ ព្រោះយល់ថា ការរលត់នៃសញ្ញា ព្រោះការរលត់ទៅនៃផស្សៈ ។

៥. វិបរិណាមលក្ខណំ បស្សតោបិ សញ្ញាយ អត្ថង្គមោ វិនិតោ ហោតិ។

កាលភិក្ខុពិចារណាឃើញនូវលក្ខណៈ នៃការប្រែប្រួល ការដល់នូវសេចក្តីវិនាសនៃសញ្ញា រមែងប្រាកដ ។

ឯវំ សញ្ញាយ អត្ថង្គមោ វិនិតោ ហោតិ។

ការដល់នូវសេចក្តីវិនាសនៃសញ្ញា រមែងប្រាកដ យ៉ាងនេះឯង ។

ឯវំ វិនិតា សញ្ញា ឧប្បជ្ជន្តិ, វិនិតា ឧបដ្ឋហន្តិ, វិនិតា អព្ភត្ថំ កច្ឆន្តិ។

សញ្ញាដ៏ប្រាកដ រមែងកើតឡើង , សញ្ញាដ៏ប្រាកដ រមែងតាំងឡើង, សញ្ញាដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស យ៉ាងនេះឯង ។

អធិប្បាយអំពីវិតក្ក

កថំ វិនិតា វិតក្កា ឧប្បជ្ជន្តិ, វិនិតា ឧបដ្ឋហន្តិ, វិនិតា អព្ភត្ថំ កច្ឆន្តិ?

វិតក្កៈជ័ប្រាកដ រមែងកើតឡើង, វិតក្កៈជ័ប្រាកដ រមែងតាំងឡើង, វិតក្កៈជ័ប្រាកដ រមែងដល់នូវសេចក្តីវិនាស តើដូចម្តេច ?

កថំ វិតក្កានំ ឧប្បាដោ ឋិតោ ហោតិ?

ការកើតឡើងនៃវិតក្កៈ រមែងប្រាកដ តើដូចម្តេច ?

๑. **អវិជ្ជាសមុទយា វិតក្កសមុទយោតិ – បច្ចយសមុទយដ្ឋេន វិតក្កានំ ឧប្បាដោ ឋិតោ ហោតិ។**

ការកើតឡើងនៃវិតក្កៈទាំងឡាយ រមែងប្រាកដ ដោយអត្ថថា កើតឡើងព្រោះបច្ច័យ ព្រោះយល់ថា ការកើតឡើងនៃវិតក្កៈ ព្រោះការកើតឡើងនៃអវិជ្ជា។

๒. **"តណ្ហាសមុទយា វិតក្កសមុទយោ"តិ។...បេ...។**

ព្រោះយល់ថា "ការកើតឡើងនៃវិតក្កៈ ព្រោះការកើតឡើងនៃតណ្ហា"។...ល...។

๓. **"កម្មសមុទយា វិតក្កសមុទយោ"តិ។...បេ...។**

ព្រោះយល់ថា "ការកើតឡើងនៃវិតក្កៈ ព្រោះការកើតឡើងនៃកម្ម"។...ល...។

๔. **"សញ្ញាសមុទយា វិតក្កសមុទយោ"តិ – បច្ចយសមុទយដ្ឋេន វិតក្កានំ ឧប្បាដោ ឋិតោ ហោតិ។**

ព្រោះយល់ថា "ការកើតឡើងនៃវិតក្កៈ ព្រោះការកើតឡើងនៃសញ្ញា"។...ល...។

๕. **ឯវម្បិ វិតក្កានំ ឧប្បាដោ ឋិតោ ហោតិ។**

កាលភិក្ខុពិចារណាឃើញនូវលក្ខណៈនៃកំណើត ការកើតឡើងនៃវិតក្កៈ រមែងប្រាកដ ។

ឯវំ វិតក្កានំ ឧប្បាដោ ឋិតោ ហោតិ។

ការកើតឡើងនៃវិតក្កៈ រមែងប្រាកដ យ៉ាងនេះ ។

ការតាំងឡើងនៃវិតក្ក

កថំ វិតក្កានំ ឧបដ្ឋានំ វិឌិតំ ហោតិ?

ការតាំងឡើងនៃវិតក្ក: រមែងប្រាកដ តើដូចម្តេច?

១. អនិច្ចតោ មនសិករោតោ ខយតុបដ្ឋានំ វិឌិតំ ហោតិ។

កាលភិក្ខុធ្វើទុកក្នុងចិត្តថា មិនទៀង ការតាំងឡើងថា អស់ទៅ រមែងប្រាកដ។

២. ទុក្ខតោ មនសិករោតោ ភយតុបដ្ឋានំ វិឌិតំ ហោតិ។

កាលភិក្ខុធ្វើទុកក្នុងចិត្តថា ជាទុក្ខ ការតាំងឡើងថា គួរខ្លាច រមែងប្រាកដ។

៣. អនត្តតោ មនសិករោតោ សុញ្ញតុបដ្ឋានំ វិឌិតំ ហោតិ។

កាលភិក្ខុធ្វើទុកក្នុងចិត្តថា មិនមែនខ្លួន ការតាំងឡើងថា សូន្យ រមែងប្រាកដ។

ឯវំ វិតក្កានំ ឧបដ្ឋានំ វិឌិតំ ហោតិ។

ការតាំងឡើងនៃវិតក្ក: រមែងប្រាកដ យ៉ាងនេះឯង។

ការវិនាសទៅនៃវិតក្ក

កថំ វិតក្កានំ អត្ថង្គមោ វិឌិតោ ហោតិ?

ការដល់នូវសេចក្តីវិនាសនៃវិតក្ក: រមែងប្រាកដ តើដូចម្តេច?

១. អវិជ្ជានិរោធា វិតក្កនិរោធោតិ – បច្ចយនិរោធេន វិតក្កានំ អត្ថង្គមោ វិឌិតោ ហោតិ។

ការដល់នូវសេចក្តីវិនាសនៃវិតក្ក: រមែងប្រាកដ ដោយអត្ថថា រលត់បច្ច័យ ព្រោះយល់ថា ការរលត់នៃវិតក្ក: ព្រោះការរលត់នៃអវិជ្ជា។

២. "តណ្ហានិរោជា វិតក្កានិរោជោ"តិ។...បេ...។

ព្រោះយល់ថា "ការរលត់នៃវិតក្ក: ព្រោះការរលត់នៃតណ្ហា"។...ល...។

៣. "កម្មនិរោជា វិតក្កានិរោជោ"តិ។...បេ...។

ព្រោះយល់ថា "ការរលត់នៃវិតក្ក: ព្រោះការរលត់នៃកម្ម"។...ល...។

៤. "សញ្ញានិរោជា វិតក្កានិរោជោ"តិ – បច្ចយនិរោជដ្ឋេន វិតក្កានំ អត្តដ្ឋមោ វិជិតោ ហោតិ។

ការប្រាកដនូវសេចក្តីវិនាសនៃវិតក្ក: រមែងប្រាកដ ដោយអត្តថា រលត់បច្ច័យ ព្រោះយល់ថា "ការរលត់នៃវិតក្ក: ព្រោះការរលត់ទៅនៃសញ្ញា" ។

៥. វិបរិណាមលក្ខណំ បស្សតោបិ វិតក្កានំ អត្តដ្ឋមោ វិជិតោ ហោតិ។

កាលភិក្ខុពិចារណាឃើញនូវលក្ខណៈនៃការប្រែប្រួល ការដល់នូវសេចក្តីវិនាសនៃវិតក្ក: រមែងប្រាកដ ។

ឯវំ វិតក្កានំ អត្តដ្ឋមោ វិជិតោ ហោតិ។

ការដល់នូវសេចក្តីវិនាសនៃវិតក្ក: រមែងប្រាកដ យ៉ាងនេះ ។

ឯវំ វិជិតា វិតក្កា ឧប្បជ្ជន្តិ, វិជិតា ឧបដ្ឋហន្តិ, វិជិតា អព្ភត្ថំ គច្ឆន្តិ។

វិតក្ក:ដ៏ប្រាកដ រមែងកើតឡើង, វិតក្ក:ដ៏ប្រាកដ រមែងតាំងឡើង, វិតក្ក:ដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស យ៉ាងនេះ ។

ការកំណត់ដឹង ៧ យ៉ាង (អដ្ឋកថា)

[៧៦៧] "**តំ កាយ**"ន្តិ អនិទ្ធិដ្ឋេបិ នាមរូបកាយេ កាយសទ្ទេន តស្សាបិ សង្ខហិតត្តា និទ្ធិដ្ឋំ វិយ កត្វា វុត្តំ។

*ពាក្យថា "**កាយ**" **នោះ** លោកពោលធ្វើឲ្យដូចបានសម្តែងអធិប្បាយទុក ព្រោះក្នុងនាមកាយ និងរូបកាយ សូម្បីមិនបានសម្តែងអធិប្បាយទុក ក៏សង្ត្រោះ នាមកាយ និងរូបកាយនោះ ដោយកាយសព្ទ ។*

អនិច្ចានុបស្សនាឧយោ ហិ នាមរូបកាយេ ឯវ លព្ភន្តិ, ន និមិត្តកាយេ។

អនិច្ចានុបស្សនា ជាដើម រមែងបានតែចំពោះក្នុងនាមកាយ និងរូបកាយ ប៉ុណ្ណោះ, រមែងមិនបានក្នុងនិមិត្តកាយ ។

អនុបស្សនា ច ភាវនា ច វុត្តត្តា ឯវ ។

អនុបស្សនា និងភាវនា មានអត្ត គឺខ្ញុំម្ចាស់បានពោលទុកមកហើយ ។

"**ឧីយំ អស្សាសបស្សាសវសេនា**"តិអាឧិ អានាចានស្សតិភាវនាយ អានិសំសំ ឧស្សេតុំ វុត្តំ ។

*ពាក្យថា "**ដោយអំណាចខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ**" ជាដើម លោកពោលទុកដើម្បីសម្តែងនូវអានាបានស្សតិភាវនា ។*

តស្សា ហិ សតិវេបុល្ជតាញាណវេបុល្ជតា ច អានិសំសោ។

ការចម្រើនដោយសតិ និងដោយញាណ ជាអានិសង្សនៃអានាបានស្សតិ ភាវនានោះ។

តត្ត "ចិត្តស្ស ឯកក្ខតំ អវិក្ខេបំ បជានតោ"តិ បដិលទ្ធជ្ឈានស្ស វិបស្សនាកាលេ ចិត្តេកក្ខតំ សន្ធាយ វុត្តំ។

*ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា "**កាលដឹងនូវភាពមានអារម្មណ៍តែមួយនៃចិត្ត ភាពមិនមានរាយមាយ**" លោកពោលសំដៅដល់ឯកគ្គតានៃចិត្ត ក្នុងកាលនៃវិបស្សនារបស់ព្រះយោគី អ្នកបានញាណហើយ ។*

"វិទិតា វេទនា"តិ សាមញ្ញតោ ឧភយវសេន វិទិតា វេទនា។

*ពាក្យថា "**វេទនាប្រាកដ**" មានសេចក្តីថា វេទនាប្រាកដដោយការឃើញនូវការកើតឡើងដោយស្មើគ្នា ។*

"វិទិតា ឧបដ្ឋហន្តី"តិ ខយតោ វយតោ សុញ្ញតោ វិទិតា ឧបដ្ឋហន្តិ។

*ពាក្យថា "**ប្រាកដហើយចូលទៅតាំងនៅ**" សេចក្តីថា ប្រាកដហើយដោយការអស់ទៅ សូន្យទៅ ដោយភាពទទេចូលទៅតាំងនៅ ។*

"វិទិតា អព្ភត្ថំ គច្ឆន្តី"តិ សាមញ្ញតោ វយវសេន វិទិតា វិនាសំ គច្ឆន្តិ, ភិជ្ជន្តីតិ អត្ថោ។

*ពាក្យថា **ប្រាកដហើយដល់ការរលត់ទៅ** សេចក្តីថា ប្រាកដហើយ ដោយការឃើញនូវការអស់ទៅដោយភាពស្មើគ្នាដល់ភាពវិនាសទៅ, អធិប្បាយថា បែកធ្លាយទៅ ។*

សញ្ញាវិតក្កេសុបិ ឯសេវ នយោ។

***សូម្បីក្នុងសញ្ញា និងវិតក្ក:** ក៏មានន័យនេះ ដូចគ្នា ។*

ឥមេសុ បន តីសុ វុត្តេសុ សេសា រូបធម្មាបិ វុត្តា ហោន្តិ។

កាលពោលដល់នាមធម៌ទាំង ៣ យ៉ាងនេះហើយ រមែងជាការពោលដល់សូម្បីរូបធម៌ដ៏សេសទៀត ។

កស្មា បន ឥមេ តយោ ឯវ វុត្តាតិ ចេ? ឧប្បវិត្តហត្តា។

ប្រសិនបើមានអ្នកសង្ស័យសួរថា ព្រោះហេតុអ្វី លោកទើបពោលដល់

នាមធម៌ទាំង ៣ យ៉ាងនេះប៉ុណ្ណោះ ? ឆ្វើយថា ព្រោះកំណត់កាន់យកបានដោយលំបាក។

វេទនាសុ តាវ សុខគ្គា ចាកជា, ឧបេក្ខា បន សុខុមា ទុប្បរិគ្គហា, ន សុដ្ឋុ ចាកជា។

ក្នុងបណ្តាវេទនាទាំងឡាយ ខាងដើមសុខ និងទុក្ខច្រាកដបានល្អ, ចំណែកឧបេក្ខាល្អិតកំណត់កាន់យកបានលំបាក, មិនច្រាកដបានល្អទេ ។

សាបិ ចស្ស ចាកជា ហោតិ, សញ្ញា អាការមត្តគ្គាហកត្តា ន យថាសភាវគ្គាហិនី។

សូម្បីឧបេក្ខានោះ ក៏រមែងច្រាកដហើយដល់ព្រះយោគីនោះ, សញ្ញាមិនមែនកាន់យកសភាវៈតាមសេចក្តីពិត ព្រោះកាន់យកត្រឹមតែអាការៈប៉ុណ្ណោះ។

សា ច សភាវសាមញ្ញលក្ខណគ្គាហកេន វិបស្សនាញាណេន សម្បយុត្តា អតិវិយ អចាកជា។

សញ្ញានោះសម្បយុត្តដោយវិបស្សនាញាណ ដែលឲ្យកាន់យកសភាវៈលក្ខណៈ និងសាមញ្ញលក្ខណៈ ទើបមិនច្រាកដ ដែលលើសហួសចំនួននឹងប្រៀនបាន ។

សាបិ ចស្ស ចាកជា ហោតិ, វិតក្កោ ញាណបតិរូបកត្តា ញាណតោ វិសុំ កត្វា ទុប្បរិគ្គហោ។

សូម្បីសញ្ញានោះ ក៏ច្រាកដហើយដល់ព្រះយោគីនោះ, វិតក្កៈក៏កំណត់កាន់យកបានលំបាក ព្រោះធ្វើទុកមួយផ្នែកដោយញាណ ព្រោះមានរូបប្រៀបដោយញាណ ។

ញាណបតិរូបកោ ហិ វិតក្កោ។

ពិតមែន វិតក្កៈមានរូប ប្រៀបដោយញាណ ។

យថาหา – "ยา จาวุโสวิสาข, สมฺมาทิฏฺฐิ โย จ สมฺมาสงฺกปฺโป, ឥเม ธมฺมา បญฺญากฺขนฺเธ สงฺคหิตา"ติ[๖๒] ។

ដូចដែលព្រះអង្គសម្តែងទុកថា "ម្នាលនាងវិសាខា សម្មាទិដ្ឋិណា, និង សម្មាសង្កប្បៈណា, ធម៌ទាំងនោះ សង្គ្រោះចូលក្នុងបញ្ញាខន្ធ" ដូចនេះ ។

สោปิ จสฺส วิตกฺโก จาคโต ហោតីតិ ฯเปฯ ตุปฺปวิตฺตหេสุ วุตฺเตสุ เสสานุสฺสาว ហោន្តីតិ។

សូម្បីវិតក្កៈនោះ ក៏ប្រាកដហើយដល់ព្រះយោគីនោះ កាលពោលដល់ នាមធម៌ដែលកំណត់កាន់យកបានលំបាក ដូចពោលមកនេះហើយ រមែងជាការ ពោលដល់រូបធម៌នោះ ដែលនៅសល់ដូចគ្នានោះឯង ។

ឥเมสំ បน បទានំ นิทฺเทเส "กถं วิตกฺกิตา วเจนา อุปฺปชฺชนฺตี"ติ បុច្ឆិត្វา **តំ អวิสฺสชฺเชตฺวา วเจนุปฺปาทสฺส วิตกฺกิตตฺเตยเว วิสฺสชฺชิเต วเจนาย วิตกฺกิตตฺตំ วิสฺสชฺชิตំ ហោតីតិ "กถं วเจนาย อุปฺปาโท วิตกฺโก ហោតี"តิ** អាចិមាហา។ **เสเสสุปิ ឯเสว นโย**។

*ក្នុងនិទ្ទេសនៃបទទាំងឡាយនេះ លោកសួរថា **វេទនាប្រាកដហើយរមែងកើតឡើង យ៉ាងដូចម្តេច ?** ដូចនេះហើយ មិនបានវិសជ្ជនានូវពាក្យនោះ តែម្យ៉ាង កាលវិសជ្ជនាសេចក្តីប្រាកដនៃភាពកើតឡើង នៃវេទនានោះឯង រមែងជាការដែលលោកវិសជ្ជនា សេចក្តីប្រាកដនៃវេទនា ព្រោះដូច្នោះ លោកទើបពោលថា **ការកើតឡើងនៃវេទនា ដែលប្រាកដហើយ យ៉ាងដូចម្តេច ?** ។ សូម្បីក្នុងពាក្យដ៏សេស ក៏មានន័យបែបនេះដូចគ្នា ។*

"อวิชฺชาสมุทยา อวิชฺชานิโรธา"តិอาทโย ហេដ្ឋา วุตฺตត្តา ឯវ។

*ពាក្យថា "**ព្រោះអវិជ្ជាកើតឡើង ព្រោះអវិជ្ជារលត់ទៅ**" ជាដើម មានអត្ថ*

๖๒ ม. นิ. ๑

សេចក្តីដូចខ្ញុំម្ចាស់បានពោលមកហើយ ក្នុងន័យខាងដើមនោះឯង ។

ឥមិនាវ នយេន សញ្ញាវិតក្កាបិ វេទិតព្វា។

គប្បីជ្រាបសូម្បីក្នុងសញ្ញា និងវិតក្ក:ដោយន័យសេចក្តីបែបនេះឯង ។

វិតក្កាវេ បន "ផស្សសមុទយា ផស្សនិរោធា"តិ អវត្វា ផស្សដ្ឋានេ "សញ្ញាសមុទយា សញ្ញានិរោធា"តិ វុត្តំ។

*ប៉ុន្តែក្នុងវារៈនៃវិតក្ក:លោកមិនបានពោលថា "ព្រោះផស្ស:កើតឡើង ព្រោះផស្ស:រលត់ទៅ" គឺពោលថា "**ព្រោះសញ្ញាកើតឡើង ព្រោះសញ្ញារលត់ទៅ**" ក្នុងឋាន:នៃ ផស្ស: ។*

តំ កស្មា ឥតិ ចេ? សញ្ញាមូលកត្តា វិតក្កស្ស។

ប្រសិនបើមានអ្នកសង្ស័យសួរថា ព្រោះហេតុអ្វី ទើបលោកពោលបែបនោះ? ឆ្លើយថា ព្រោះវិតក្ក:មានសញ្ញាជាមូល ។

"សញ្ញានានត្តំ បដិច្ច ឧប្បជ្ជតិ សង្កប្បនានត្ត"ន្តិ[៦៣] ហិ វុត្តំ។

សមដូចពាក្យដែលលោកបានពោលទុកមកថា "សេចក្តីផ្សេងគ្នានៃសង្កប្ប:កើតឡើង ព្រោះអាស្រ័យ នូវសេចក្តីផ្សេងគ្នានៃសញ្ញា" ។

"អនិច្ចតោ មនសិករោតោ"តិអាទីសុ ច "វេទនំ អនិច្ចតោ មនសិ-ករោតោ"តិអាទិនា នយេន តស្មឹ តស្មឹ ភវេ សោ សោយេវ ធម្មោ យោជេតព្វោ។

*ក្នុងពាក្យថា "**កាលមនសិការ:ដោយភាពមិនទៀង**" ជាដើម គប្បីប្រកបធម៌ទាំងនោះៗឯង ក្នុងវារៈនោះៗ ដោយន័យមានអាទិថា "កាលមនសិការ:វេទនាដោយភាពមិនទៀង" ដូចនេះ ។*

យស្មា បន វិបស្សនាសម្បយុត្តា វេទនា វិបស្សនាកិច្ចការណោ

---

៦៣ (ទី. និ. ៣.៣៥៩) ។

អសមត្តត្តា វិបស្សនាយ អនុបការិកា, តស្មាយេវ ច ពោធិបក្ខិយ-ធម្មេសុ ជាតតា។

ព្រោះវេទនាដែលសម្បយុត្តដោយវិបស្សនា មិនជាឧបការៈដល់វិបស្សនា ព្រោះមិនអាចធ្វើកិច្ចនៃវិបស្សនា, ព្រោះហេតុនោះឯង ទើបមិនមានក្នុង ពោធិបក្ខិយធម៌ទាំងឡាយ ។

វិបស្សនាសម្បយុត្តាយ បន សញ្ញាយ កិច្ចមេវ អបរិព្យត្តំ, តស្មា សា វិបស្សនាយ ឯកន្តមនុបការិកា ឯវ។

ម្យ៉ាងទៀត កិច្ចនៃសញ្ញា ដែលសម្បយុត្តដោយវិបស្សនានោះឯង ក៏មិនក្វីចាំង, ព្រោះហេតុនោះ សញ្ញានោះ ទើបមិនជាឧបការៈដោយចំណែកតែម្យ៉ាង ដល់វិបស្សនា នោះឯង ។

វិតក្កំ បន វិនា វិបស្សនាកិច្ចមេវ នត្ថិ។

តែវៀរវិតក្កៈចេញហើយ កិច្ចនៃវិបស្សនានោះឯង ក៏រមែងមិនមាន ។

វិតក្កសហាយា ហិ វិបស្សនា សកកិច្ចំ ករោតិ។

ព្រោះថាវិបស្សនាមាន វិតក្កៈជាសម្ភាញ់ ទើបធ្វើកិច្ចរបស់ខ្លួនបាន ។

យថាហ –

ដូចដែលព្រះពុទ្ធឃោសាចារ្យបានពោលទុកមកថា

"បញ្ញា អត្តនោ ធម្មតាយ អនិច្ចំ ទុក្ខមនត្តាតិ អារម្មណំ និច្ឆេតុំ ន សក្កោតិ, វិតក្កេ បន អាកោដេត្វា អាកោដេត្វា ឋបេន្តេ សក្កោតិ។

*"បញ្ញាមិនអាចនឹងវិនិច្ឆ័យនូវអារម្មណ៍ថា **អនិច្ចំ ទុក្ខំ អនត្តា** ដោយ ធម្មតាៗរបស់ខ្លួនបានឡើយ, ប៉ុន្តែកាលមានវិតក្កៈ កំពុងគោះឲ្យហើយៗ បែបនេះទើបអាច។*

កថំ? យថា ហិ ហេរញ្ញិកោ កហាបណំ ហត្ថេ ឋបេត្វា សព្ទភាតេសុ ឱលោកេតុកាមោ សមានោបិ ន ចក្ខុតលេនេវ បរិវត្តេតុំ សក្កោតិ, អជ្ជុលិបព្ទេហិ បន បរិវត្តេត្វា បរិវត្តេត្វា ឥតោ ចិតោ ច ឱលោកេតុំ សក្កោតិ, ឯវមេវ ន បញ្ញា អត្តនោ ធម្មតាយ អនិច្ចាទិវសេន អារម្មណំ និច្ឆេតុំ សក្កោតិ, អភិនិរោបនលក្ខណេន បន អាហានន-បរិយាហានន្យសេន វិតក្កេន អាកោដេន្តេន វិយ បរិវត្តេន្តេន វិយ ច អាទាយាទាយ ទិន្នមេវ និច្ឆេតុំ សក្កោតី"តិ[៦៤] ។

សេចក្តីនេះ តើដូចម្តេច ? ឧបមាប្រៀបដូចជា អ្នកហេរញ្ញិកវត្ថុ ជា អ្នកពិនិត្យទឹកប្រាក់ បានទុកប្រាក់កហាបណៈនៅក្នុងដៃ ប្រាថ្នាដើម្បីនឹងត្រួតពិនិត្យគ្រប់ៗ ចំណែក មិនអាចនឹងប្រើផ្ទៃនៃភ្នែកតែម្យ៉ាងត្រឡប់ទៅមកបាន, តែ ប្រើក្រញរដៃត្រឡប់ទៅមកបាន ទើបអាចនឹងត្រួតពិនិត្យមើលខាងនោះ ខាងនេះបាន សេចក្តីនេះយ៉ាងណា, បញ្ញាក៏យ៉ាងនោះដូចគ្នា មិនអាចនឹង វិនិច្ឆ័យអារម្មណ៍ដោយអំណាចជារបស់មិនទៀង ជាដើម តាមធម្មតារបស់ខ្លួន បាន, តែក៏រមែងអាចនឹងវិនិច្ឆ័យអារម្មណ៍ដែលវិតក្ក:មានលក្ខណៈលើកឡើង មានកិច្ច គឺការត្រឡប់ទាំងអស់ ឬការត្រឡប់ជុំវិញកាន់យកហើយ ហាក់បីដូចជា គោះ និងដូចជាឲ្យត្រឡប់ទៅមកហើយ នោះឯង ។

តស្មា វេទនាសញ្ញានំ វិបស្សនាយ អនុបការត្តា លក្ខណម-ត្តវសេនេវ ទស្សេតុំ "វេទនាយ សញ្ញាយា"តិ តត្ថ តត្ថ ឯកវចនេន និទ្ទេសោ កតោ។

ព្រោះហេតុនោះ ដើម្បីនឹងសម្តែងដោយអំណាចត្រឹមតែជាលក្ខណៈ ប៉ុណ្ណោះ ព្រោះវេទនា និងសញ្ញាមិនបានជាឧបការៈដល់វិបស្សនា ទើបលោក ធ្វើនិទ្ទេសដោយឯកវចនៈក្នុងទីនោះៗ ថា "វេទនាយ សញ្ញាយ" ដូចនេះ ។

យត្តកោ បន វិបស្សនាយ ភេទោ, តត្តកោ ឯវ វិតក្កស្សាតិ

---

៦៤ (*វិសុទ្ធិ. ២.៥៦៨*)។

ឧស្សេតុំ "វិតក្កាន"ន្តិ តត្ត តត្ត ពហុវចនេន និទ្ទេសោ កតោតិ វត្តុំ យុជ្ជតិ។

ដើម្បីនឹងសម្តែងថា ប្រភេទនៃវិបស្សនាមានប៉ុន្មាន, នៃវិតក្កៈក៏មានប្រមាណប៉ុណ្ណោះ ទើបគួរដើម្បីនឹងពោលថា លោកធ្វើនិទ្ទេសទុកដោយពហុវចនៈក្នុងទីនោះៗ ថា "វិតក្កានំ"។

ខ្យល់ដង្ហើមចូល - ចេញ រមែងប្រមូលមកនូវធម៌ទាំងឡាយ

ចតុក្កទី ๑ លំដាប់ទី ๑ (បិដក ๗๐) [๑๐๔]

[๑๖๘] ឥឃំ អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានន្តោ ឥន្ទ្រិយានិ សមោជានេតិ,

បុគ្គលកាលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញវែង រមែងប្រមូលមកនូវឥន្ទ្រិយទាំងឡាយ,

គោចរញ្ច បជានាតិ, សមត្តញ្ច បដិវិជ្ឈតិ។...បេ...។

រមែងដឹងច្បាស់នូវគោចរផង, និងរមែងចាក់ធ្លុះនូវសភាវៈនៃការស្ងប់ផង។...ល...។

មគ្គំ សមោជានេតិ, ផលេ សមោជានេតិ, គោចរញ្ច បជានាតិ, សមត្តញ្ច បដិវិជ្ឈតិ។

រមែងឲ្យមគ្គប្រជុំចុះ, រមែងប្រមូលនូវផលទាំងឡាយឲ្យប្រជុំចុះ, រមែងដឹង

ច្បាស់នូវគោចរផង, និងវមែងចាក់ផ្ទុះនូវសភាវៈនៃការស្ងប់ផង ។

"ឥន្ទ្រិយានិ សមោធានេតី"តិ កថំ ឥន្ទ្រិយានិ សមោធានេតិ?

*សំណួរត្រង់ពាក្យថា "**ប្រមូលនូវឥន្ទ្រិយទាំងឡាយ**" តើប្រមូលឥន្ទ្រិយទាំងឡាយ ដូចម្តេច?*

អធិមោក្ខដ្ឋេន សទ្ធិន្ទ្រិយំ សមោធានេតិ, បគ្គហដ្ឋេន វីរិយិន្ទ្រិយំ សមោធានេតិ, ឧបដ្ឋានដ្ឋេន សតិន្ទ្រិយំ សមោធានេតិ, អវិក្ខេបដ្ឋេន សមាធិន្ទ្រិយំ សមោធានេតិ, ទស្សនដ្ឋេន បញ្ញិន្ទ្រិយំ សមោធានេតិ។

បុគ្គលប្រមូលនូវសទ្ធិន្ទ្រិយ ដោយអត្ថថា ជឿស៊ប់, ប្រមូលនូវវីរិយិន្ទ្រិយ ដោយអត្ថថា ផ្គងឡើង, ប្រមូលនូវសតិន្ទ្រិយ ដោយអត្ថថា ប្រុងប្រយ័ត្ន (ឬឲ្យច្រាកដ), ប្រមូលនូវសមាធិន្ទ្រិយ ដោយអត្ថថា មិនរាយមាយ, ប្រមូលនូវបញ្ញិន្ទ្រិយ ដោយអត្ថថា ឃើញ ។

អយំ បុគ្គលោ ឥមានិ ឥន្ទ្រិយានិ ឥមស្មឹ អារម្មណេ សមោធានេតិ។

បុគ្គលនេះ ឈ្មោះថា ប្រមូលនូវឥន្ទ្រិយទាំងឡាយ ៥ យ៉ាងនេះ ទុកក្នុងអារម្មណ៍នេះ។

តេន វុច្ចតិ – "ឥន្ទ្រិយានិ សមោធានេតី"តិ។

ព្រោះហេតុនោះ លោកពោលថា "ប្រមូលនូវឥន្ទ្រិយទាំងឡាយ" ដោយប្រការដូច្នេះ ។

"គោចរញ្ច បជានាតី"តិ យំ តស្ស អារម្មណំ, តំ តស្ស គោចរំ។

*ពាក្យថា "**ដឹងច្បាស់នូវគោចរ**" មានសេចក្តីថា បុគ្គលដឹងច្បាស់ថា ធម្មជាតណា ជាអារម្មណ៍នៃចិត្តនោះ, ធម្មជាតនោះ ជាគោចររបស់ចិត្តនោះ ។*

យំ តស្ស គោចរំ, តំ តស្ស អារម្មណំ។

ធម្មជាតណា ជាគោចរនៃចិត្តនោះ, ធម្មជាតនោះ ជាអារម្មណ៍របស់ចិត្តនោះ។

"បជានាតី"តិ បុគ្គលោ បជានតិ បញ្ញា។

*ពាក្យថា "**ការដឹងច្បាស់**" បានដល់ បុគ្គល ដឹងច្បាស់ ឈ្មោះថា បញ្ញា ។*

"សម"ន្តិ អារម្មណស្ស ឧបដ្ឋានំ សមំ, ចិត្តស្ស អវិក្ខេបោ សមំ, ចិត្តស្ស អធិដ្ឋានំ សមំ, ចិត្តស្ស ភោជានំ សមំ។

*ពាក្យថា "**ការស្ងប់**" គឺការតម្កល់អារម្មណ៍ ឈ្មោះថា ការស្ងប់, ការមិនរាយមាយរបស់ចិត្ត ឈ្មោះថា ការស្ងប់, ការអធិដ្ឋានរបស់ចិត្ត ឈ្មោះថា ការស្ងប់, សេចក្តីផ្សះផ្សង់របស់ចិត្ត ឈ្មោះថា ការស្ងប់ ។*

"អត្ថោ"តិ អនវជ្ជដ្ឋោ និក្កិលេសដ្ឋោ ភោជនដ្ឋោ បរមដ្ឋោ។

ឈ្មោះថាអត្ថ គឺអត្ថនៃការមិនមានទោស អត្ថនៃការមិនសៅហ្មង (គឺអស់កិលេស) អត្ថនៃការផ្សះផ្សង់ អត្ថនៃគុណក្រៃលែង ។

"បដិវិជ្ឈតី"តិ អារម្មណស្ស ឧបដ្ឋានដ្ឋំ បដិវិជ្ឈតិ, ចិត្តស្ស អវិក្ខេបដ្ឋំ បដិវិជ្ឈតិ, ចិត្តស្ស អធិដ្ឋានដ្ឋំ បដិវិជ្ឈតិ, ចិត្តស្ស ភោជនដ្ឋំ បដិវិជ្ឈតិ។

*ពាក្យថា **ចាក់ធ្លុះ** គឺចាក់ធ្លុះនូវអត្ថ នៃការតម្កល់មាំនូវអារម្មណ៍, ចាក់ធ្លុះនូវអត្ថនៃការមិនរាយមាយរបស់ចិត្ត, ចាក់ធ្លុះនូវអត្ថ នៃការអធិដ្ឋានរបស់ចិត្ត, ចាក់ធ្លុះនូវអត្ថនៃការផ្សះផ្សង់របស់ចិត្ត ។*

តេន វុច្ចតិ – "សមត្តញ្ច បដិវិជ្ឈតី"តិ។

ព្រោះហេតុនោះ លោកពោលថា "កិរិយាមៃង់ចាក់ធ្លុះនូវអត្ថ នៃការស្ងប់" ។

១. ប្រមូលមកនូវពលៈទាំង៦ឲ្យដោយអត្ថ ៥ យ៉ាង

"ពលានិ សមោធានេតី"តិ កថំ ពលានិ សមោធានេតិ?

សំនួរត្រង់ពាក្យថា ***ប្រមូលមកនូវពលៈទាំង៦ឲ្យ*** *តើប្រមូលនូវពលៈដូចម្តេច?*

១. អស្សទ្ធិយេ អកម្បិយដ្ឋេន សទ្ធាពលំ សមោធានេតិ,

ប្រមូលមកនូវសទ្ធាពលៈ ដោយអត្ថថាមិនកម្រើកទៅក្នុងសេចក្តីមិនមានសទ្ធា,

២. កោសជ្ជេ អកម្បិយដ្ឋេន វីរិយពលំ សមោធានេតិ,

ប្រមូលមកនូវវីរិយៈពលៈ ដោយអត្ថថាមិនកម្រើកទៅក្នុងសេចក្តីខ្ជិលច្រអូស,

៣. បមាទេ អកម្បិយដ្ឋេន សតិពលំ សមោធានេតិ,

ប្រមូលមកនូវសតិពលៈ ដោយអត្ថថា មិនកម្រើកទៅក្នុងសេចក្តីប្រមាទ,

៤. ឧទ្ធច្ចេ អកម្បិយដ្ឋេន សមាធិពលំ សមោធានេតិ,

ប្រមូលមកនូវសមាធិពលៈ ដោយអត្ថថា មិនកម្រើកទៅក្នុងឧទ្ធច្ចៈ,

៥. អវិជ្ជាយ អកម្បិយដ្ឋេន បញ្ញាពលំ សមោធានេតិ។

ប្រមូលមកនូវបញ្ញាពលៈ ដោយអត្ថថា មិនកម្រើកទៅក្នុងអវិជ្ជា។

អយំ បុគ្គលោ ឥមានិ ពលានិ ឥមស្មឹ អារម្មណេ សមោធានេតិ។

បុគ្គលនេះ ឈ្មោះថា ប្រមូលមកនូវកម្លាំងទាំង៦ឲ្យ ទុកក្នុងអារម្មណ៍នេះ។

តេន វុច្ចតិ – ពលានិ សមោធានេតីតិ។

ព្រោះហេតុនោះ លោកពោលថា – ប្រមូលមកនូវកម្ចាត់ទាំងឡាយ ដោយប្រការដូច្នេះ។

គោចរញ្ច បជានាតីតិ។...បេ...។ តេន វុច្ចតិ – "សមត្តញ្ច បដិវិជ្ឈតី"តិ។

ពាក្យថា រមែងដឹងច្បាស់នូវគោចរ(អារម្មណ៍)។...ល...។ ព្រោះហេតុនោះ លោកពោលថា រមែងចាក់ធ្លុះនូវអត្តនៃការស្ងប់។

២. ប្រមូលមកនូវពោជ្ឈង្គទាំងឡាយដោយអត្ថ ៧ យ៉ាង

"ពោជ្ឈង្គេ សមោធានេតី"តិ កថំ ពោជ្ឈង្គេ សមោធានេតិ?

*សំណួរត្រង់ពាក្យថា "**ប្រមូលមកនូវពោជ្ឈង្គទាំងឡាយ**" តើប្រមូលមកនូវពោជ្ឈង្គ ដូចម្តេច?*

๑. **ឧបដ្ឋានដ្ឋេន សតិសម្ពោជ្ឈង្គំ សមោធានេតិ,**

ប្រមូលមកនូវសតិសម្ពោជ្ឈង្គ ដោយអត្ថថា ប្រុងប្រយ័ត្ន,

๒. **បវិចយដ្ឋេន ធម្មវិចយសម្ពោជ្ឈង្គំ សមោធានេតិ,**

ប្រមូលមកនូវធម្មវិចយៈសម្ពោជ្ឈង្គ ដោយអត្ថថា ឈ្វេចឈ្វើរក,

๓. **បគ្គហដ្ឋេន វីរិយសម្ពោជ្ឈង្គំ សមោធានេតិ,**

ប្រមូលមកនូវវីរិយៈសម្ពោជ្ឈង្គ ដោយអត្ថថា ផ្គងឡើង,

๔. **ផរណដ្ឋេន បីតិសម្ពោជ្ឈង្គំ សមោធានេតិ,**

ប្រមូលមកនូវបីតិសម្ពោជ្ឈង្គ ដោយអត្ថថា ផ្សាយទៅ,

๕. **ឧបសមដ្ឋេន បស្សទ្ធិសម្ពោជ្ឈង្គំ សមោធានេតិ,**

ប្រមូលមកនូវបស្សទ្ធិសម្ពោជ្ឈង្គ ដោយអត្ថថា ស្ងប់រម្ងាប់,

៦. **អវិក្ខេបដ្ឋេន សមាធិសម្ពោជ្ឈង្គំ សមោធានេតិ,**

ប្រមូលមកនូវសមាធិសម្ពោជ្ឈង្គ ដោយអត្ថថា មិនរាយមាយ,

៧. **បដិសង្ខានដ្ឋេន ឧបេក្ខាសម្ពោជ្ឈង្គំ សមោធានេតិ។**

ប្រមូលមកនូវឧបេក្ខាសម្ពោជ្ឈង្គ ដោយអត្ថថា ពិចារណាឃើញច្បាស់។

អយំ បុគ្គលោ ឥមេ ពោជ្ឈង្គេ ឥមស្មឹ អារម្មណេ សមោធានេតិ។

បុគ្គលនេះ ឈ្មោះថា ប្រមូលមកនូវពោជ្ឈង្គទាំងឡាយនេះ ទុកក្នុងអារម្មណ៍នេះ។

តេន វុច្ចតិ – "ពោជ្ឈង្គេ សមោធានេតី"តិ។

ព្រោះហេតុនោះ លោកពោលថា "ប្រមូលមកនូវពោជ្ឈង្គទាំងឡាយ" ដោយប្រការដូចនេះ។

គោចរញ្ច បជានាតីតិ។...បេ...។ តេន វុច្ចតិ – "សមត្តញ្ច បដិវិជ្ឈតី"តិ។

ពាក្យថា រមែងដឹងច្បាស់នូវគោចរ(អារម្មណ៍)។...ល...។ ព្រោះហេតុនោះ លោកពោលថា រមែងចាក់ធ្លុះនូវអត្ថនៃការស្ងប់។

៣. ប្រមូលមកនូវមគ្គដោយអត្ថ ៨ យ៉ាង

"មគ្គំ សមោធានេតី"តិ កថំ មគ្គំ សមោធានេតិ?

*"សំនួរត្រង់ពាក្យថា **ប្រមូលមកនូវមគ្គ** តើប្រមូលមកនូវមគ្គ ដូចម្តេច?*

១. **ទស្សនដ្ឋេន សម្មាទិដ្ឋិំ សមោធានេតិ,**

ប្រមូលមកនូវសម្មាទិដ្ឋិ ដោយអត្ថថា ឃើញ,

២. **អភិនិរោបនដ្ឋេន សម្មាសង្កប្បំ សមោធានេតិ,**

ប្រមូលមកនូវសម្មាសង្កប្បៈ ដោយអត្ថថា លើកចិត្តឡើង,

๓. **បរិក្ខហាដ្ឋេន សម្មាវាចំ សមោធានេតិ,**

ប្រមូលមកនូវសម្មាវាចា ដោយអត្ថថា រក្សាទុក,

๔. **សមុដ្ឋានដ្ឋេន សម្មាកម្មន្តំ សមោធានេតិ,**

ប្រមូលមកនូវសម្មាកម្មន្តៈ ដោយអត្ថថា តាំងឡើងដោយប្រពៃ,

๕. **ភោធានដ្ឋេន សម្មាអាជីវំ សមោធានេតិ,**

ប្រមូលមកនូវសម្មាអាជីវៈ ដោយអត្ថថា ផូរផង់,

๖. **បគ្គហាដ្ឋេន សម្មាវាយាមំ សមោធានេតិ,**

ប្រមូលមកនូវសម្មាវាយាមៈ ដោយអត្ថថា ផ្គងឡើង,

๗. **ឧបដ្ឋានដ្ឋេន សម្មាសតឺសមោធានេតិ,**

ប្រមូលមកនូវសម្មាសតិ ដោយអត្ថថា ប្រុងប្រយ័ត្ន,

๘. **អវិក្ខេបដ្ឋេន សម្មាសមាធឺ សមោធានេតិ។**

ប្រមូលមកនូវសម្មាសមាធិ ដោយអត្ថថា មិនវាយមាយ ។

អយំ បុគ្គលោ ឥមំ មគ្គំ ឥមស្មឹ អារម្មណេ សមោធានេតិ។

បុគ្គលនេះ ឈ្មោះថា ប្រមូលមកនូវមគ្គនេះ ទុកក្នុងអារម្មណ៍នេះ ។

តេន វុច្ចតិ – "មគ្គំ សមោធានេតី"តិ។

ព្រោះហេតុនោះ លោកពោលថា ប្រមូលមកនូវមគ្គ ដោយប្រការដូចនេះ។

កោចរញ្ចេ បជានាតីតិ។...បេ...។ តេន វុច្ចតិ – "សមត្តញ្ចេ បដិវិជ្ឈតី"តិ។

ពាក្យថា រមែងដឹងច្បាស់នូវគោចរ(អារម្មណ៍)។...ល...។ ព្រោះហេតុនោះ លោកពោលថា "រមែងចាក់ធ្លុះនូវអត្តនៃការស្លាប់" ដូចនេះ ។

៤. ប្រមូលមកនូវធម៌ទាំងឡាយទុកក្នុងអារម្មណ៍ដោយអត្ថ ២៩ យ៉ាង

"ឆម្មេ សមោធានេតី"តិ កថំ ឆម្មេ សមោធានេតិ?

*សំនួរត្រង់ពាក្យថា "**ប្រមូលមកនូវធម៌ទាំងឡាយ**" តើប្រមូលមកនូវធម៌ទាំងឡាយ ដូចម្តេច?*

១. **អាធិបតេយ្យដ្ឋេន ឥន្ទ្រិយានិ សមោធានេតិ,**

ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ដោយអត្ថថា ជាធំ,

២. **អកម្បិយដ្ឋេន ពលានិ សមោធានេតិ,**

ប្រមូលមកនូវពល:ទាំងឡាយ ដោយអត្ថថា មិនកម្រើក,

៣. **និយ្យានដ្ឋេន ពោជ្ឈង្គេ សមោធានេតិ,**

ប្រមូលមកនូវពោជ្ឈង្គ:ទាំងឡាយ ដោយអត្ថថា ចេញទៅ(ចាកធម៌ដែលជាសឹកសត្រូវ),

៤. **ហេតុដ្ឋេន មគ្គំ សមោធានេតិ,**

ប្រមូលមកនូវមគ្គ: ដោយអត្ថថា ជាហេតុ,

៥. **ឧបដ្ឋានដ្ឋេន សតិបដ្ឋានំ សមោធានេតិ,**

ប្រមូលមកនូវសតិប្បដ្ឋាន ដោយអត្ថថា ប្រុងប្រយ័ត្ន,

៦. **បឌហានដ្ឋេន សម្មប្បធានំ សមោធានេតិ,**

ប្រមូលមកនូវសម្មប្បធាន ដោយអត្ថថា តម្កល់មាំ(គឺឲ្យប្រាកដ),

៧. ឥដ្ឋជនដ្ឋេន ឥទ្ធិចាតំ សមោធានេតិ,

ប្រមូលមកនូវឥទ្ធិបាទ ដោយអត្ថថា សម្រេច,

៨. តថដ្ឋេន សច្ចំ សមោធានេតិ,

ប្រមូលមកនូវសច្ចៈ ដោយអត្ថថា ពិត,

៩. អវិក្ខេបដ្ឋេន សមថំ សមោធានេតិ,

ប្រមូលមកនូវសមថៈ ដោយអត្ថថា មិនរាយមាយ,

១០. អនុបស្សនដ្ឋេន វិបស្សនំ សមោធានេតិ,

ប្រមូលមកនូវវិបស្សនា ដោយអត្ថថា ពិចារណាឃើញរឿយៗ,

១១. ឯករសដ្ឋេន សមថវិបស្សនំ សមោធានេតិ,

ប្រមូលមកនូវសមថៈ និងវិបស្សនា ដោយអត្ថថា មានរសតែមួយ(គឺក្នុងការលះកិលេស),

១២. អនតិវត្តនដ្ឋេន យុគនទ្ធំ សមោធានេតិ,

ប្រមូលមកនូវធម៌ដែលជាប់គ្នាជាគូ ដោយអត្ថថា មិនកន្ទុងគ្នា,

១៣. សំវរដ្ឋេន សីលវិសុទ្ធិ សមោធានេតិ,

ប្រមូលមកនូវសីលវិសុទ្ធិ ដោយអត្ថថា សង្រួម,

១៤. អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ សមោធានេតិ,

ប្រមូលមកនូវចិត្តវិសុទ្ធិ ដោយអត្ថថា មិនរាយមាយ,

១៥. ឧស្សនដ្ឋេន ទិដ្ឋិវិសុទ្ធិ សមោធានេតិ,

ប្រមូលមកនូវទិដ្ឋិវិសុទ្ធិ ដោយអត្ថថា ឃើញ,

១៦. វិមុត្តដ្ឋេន វិមោក្ខំ សមោធានេតិ,

ប្រមូលមកនូវវិមោក្ខ ដោយអត្ថថា រួច,

១៧. បដិវេធដ្ឋេន វិជ្ជំ សមោធានេតិ,

ប្រមូលមកនូវវិជ្ជា ដោយអត្ថថា ចាក់ធ្លុះ,

១៨. បរិច្ចាគដ្ឋេន វិមុត្តឹ សមោធានេតិ,

ប្រមូលមកនូវវិមុត្ត ដោយអត្ថថា លះស្រឡះ,

១៩. សមុច្ឆេទដ្ឋេន ខយេ ញាណំ សមោធានេតិ,

ប្រមូលមកនូវខយញ្ញាណ ដោយអត្ថថា ផ្តាច់បង់,

២០. បដិប្បស្សទ្ធដ្ឋេន អនុប្បាទេ ញាណំ សមោធានេតិ,

ប្រមូលមកនូវអនុប្បាទញ្ញាណ ដោយអត្ថថា ស្ងប់,

២១. ឆន្ទំ មូលដ្ឋេន សមោធានេតិ,

ប្រមូលមកនូវឆន្ទៈ ដោយអត្ថថា ជាឫសគល់,

២២, មនសិការំ សមុដ្ឋានដ្ឋេន សមោធានេតិ,

ប្រមូលមកនូវមនសិការៈ ដោយអត្ថថា តាំងឡើងព្រម,

២៣. ផស្សំ សមោធានដ្ឋេន សមោធានេតិ,

ប្រមូលមកនូវផស្សៈ ដោយអត្ថថា ប្រមូលមក(នូវអារម្មណ៍),

២៤. វេទនំ សមោសរណដ្ឋេន សមោធានេតិ,

ប្រមូលមកនូវវេទនា ដោយអត្ថថា ប្រជុំចុះ,

២៥. សមាធឹ បមុខដ្ឋេន សមោធានេតិ,

ប្រមូលមកនូវសមាធិ ដោយអត្ថថា ជាប្រធាន,

២៦. សតឹ អាធិបតេយ្យដ្ឋេន សមោធានេតិ,

ប្រមូលមកនូវសតិ ដោយអត្ថថា ជាធំ,

๒๗. សតិសម្បជញ្ញំ តតុត្តរដ្ឋេន សមោជានេតិ,

ប្រមូលមកនូវសតិសម្បជញ្ញៈ ដោយអត្ថថា ជាធម៌ដែលប្រសើរជាងនោះ,

๒๘. វិមុត្តឹ សារដ្ឋេន សមោជានេតិ,

ប្រមូលមកនូវវិមុត្តិ ដោយអត្ថថា ជាខ្លឹម,

๒๙. អមតោគធំ និព្វានំ បរិយោសានដ្ឋេន សមោជានេតិ។

ប្រមូលមកនូវនិព្វាន ឈ្មោះអមតៈ(ជាទីពឹងរបស់សត្វ) ដោយអត្ថថា ទីបំផុត(នៃកិច្ចក្នុងព្រះសាសនានេះ),

អយំ បុគ្គលោ ឥមេ ធម្មេ ឥមស្មឹ អារម្មណេ សមោជានេតិ។

បុគ្គលនេះ ឈ្មោះថា ប្រមូលមកនូវធម៌ទាំងឡាយនេះ ទុកក្នុងអារម្មណ៍នេះ។

តេន វុច្ចតិ – "ធម្មេ សមោជានេតី"តិ។

ព្រោះហេតុនោះ លោកពោលថា "ប្រមូលមកនូវធម៌ទាំងឡាយ" ដោយប្រការដូច្នេះ ។

"គោចរញ្ច បជានាតី"តិ យំ តស្ស អារម្មណំ, តំ តស្ស គោចរំ។

*ពាក្យថា "**រមែងដឹងច្បាស់នូវគោចរ**" មានសេចក្តីថា បុគ្គលតែងដឹងច្បាស់ថា ធម្មជាតណា ជាអារម្មណ៍នៃចិត្តនោះ, ធម្មជាតនោះ ជាគោចរនៃចិត្តនោះ ។*

យំ តស្ស គោចរំ, តំ តស្ស អារម្មណំ "បជានាតី"តិ បុគ្គលោ បជានាតិ បញ្ញា។

ធម្មជាតណា ជាគោចរនៃចិត្តនោះ, ធម្មជាតនោះ ជាអារម្មណ៍នៃចិត្ត

*នោះ ព្រោះហេតុនោះ ពាក្យថា រមែងដឹងច្បាស់ បានដល់បុគ្គល "**ដឹងច្បាស់**" គឺ បញ្ញា ។*

"សមៈ"ន្តិ អារម្មណស្ស ឧបដ្ឋានំ សមំ, ចិត្តស្ស អវិក្ខេបោ សមំ, ចិត្តស្ស អធិដ្ឋានំ សមំ, ចិត្តស្ស ភោជានំ សមំ ។

*ពាក្យថា "**ការស្ងប់**" គឺការតម្កល់ទុកនូវអារម្មណ៍ ឈ្មោះថា ការស្ងប់, ការមិនរាយមាយនៃចិត្ត ឈ្មោះថា ការស្ងប់, ការអធិដ្ឋានចិត្ត ឈ្មោះថា ការស្ងប់, សេចក្តីផ្សះផង់នៃចិត្ត ឈ្មោះថា ការស្ងប់ ។*

"អត្ថោ"តិ អនវជ្ជដ្ឋោ និក្កិលេសដ្ឋោ ភោជនដ្ឋោ បរមដ្ឋោ។

*អត្ថនៃការមិនមានទោស អត្ថនៃការមិនមានកិលេស អត្ថនៃការផ្សះផង់ អត្ថនៃគុណដ៏ក្រៃលែង ឈ្មោះថា "**អត្ថ**" ។*

"បដិវិជ្ឈតី"តិ អារម្មណស្ស ឧបដ្ឋានដ្ឋំ បដិវិជ្ឈតិ, ចិត្តស្ស អវិក្ខេបដ្ឋំ បដិវិជ្ឈតិ, ចិត្តស្ស អធិដ្ឋានដ្ឋំ បដិវិជ្ឈតិ, ចិត្តស្ស ភោជនដ្ឋំ បដិវិជ្ឈតិ។

*ពាក្យថា "**ចាក់ធ្លុះ**" គឺចាក់ធ្លុះនូវអត្ថនៃការតម្កល់មាំនូវអារម្មណ៍, ចាក់ធ្លុះនូវអត្ថនៃការមិនរាយមាយនៃចិត្ត, ចាក់ធ្លុះនូវអត្ថនៃការអធិដ្ឋាន, ចាក់ធ្លុះនូវអត្ថនៃការផ្សះផង់ចិត្ត ។*

តេន វុច្ចតិ – "សមត្តញ្ច បដិវិជ្ឈតី"តិ។

ព្រោះហេតុនោះ លោកពោលថា "ចាក់ធ្លុះនូវអត្ថនៃការស្ងប់" ។

ខ្យល់ដង្ហើមចូល ចេញវែង រមែងប្រមូលមកនូវធម៌ទាំងឡាយ

ចតុក្កទី ១ លំដាប់ទី ១ (អដ្ឋកថា)

[១៦៨] បុន "**ឧីយំ អស្សាសបស្សាសវសេនា**"តិអាឧិ អានាចានស្សតិ-ការនាយ សម្ឆត្តឹ ការនាផលញ្ច ឧស្សេតុំ វុត្តំ។

*ពាក្យថា "**ដោយអំណាចខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញវែង**" ជាដើម លោកពោលទុកដើម្បីនឹងសម្តែងសម្បត្តិនិងផលនៃភាវនានៃការចម្រើនអានាបានស្សតិ ។*

តត្ត "**សមោឧានេតី**"តិ អារម្មណំ ឋបេតិ, អារម្មណំ បតិដ្ឋាបេតីតិ វា អត្តោ។

*ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា "**រមែងប្រមូលមកនូវឥន្ទ្រិយទាំងឡាយ**" សេចក្តីថា រមែងតាំងអារម្មណ៍ទុក, ឬសេចក្តីថារមែងញុាំងអារម្មណ៍ឲ្យតាំងនៅចំពោះ ។*

សមោឧហានញ្ចាចារាកាវេបិ ការនាចារិបូរិយា ឯវ សមោឧហតិ នាម។

សូម្បីកាលមិនមានភាពតាំងចុះ និងភាពខ្ចល់ខ្ចាយ ក៏ឈ្មោះថា រមែងតាំងចុះ ដោយភាពបរិបូរណ៍នៃភាវនានោះឯង ។

"**គោចរ**"ន្តិ វិបស្សនាក្ខណេ សង្ខារារម្មណំ, មត្តក្ខណេ ផលក្ខណេ ច និព្ខានារម្មណំ។

*ពាក្យថា "**គោចរ**" បានដល់អារម្មណ៍គឺសង្ខារ ក្នុងខណៈវិបស្សនា, និងអារម្មណ៍គឺនិព្ខានក្នុងខណៈមគ្គ និងក្នុងខណៈផល ។*

"**សមត្ត**"ន្តិ សមមេវ អត្តោ, សមស្ស វា អត្តោតិ សមត្តោ។

បទថា ***សមត្តំ*** *ប្រែថា* ***សេចក្តីស្ងប់នោះឯងជាប្រយោជន៍***, *ឬប្រយោជន៍ដើម្បីភាពស្ងប់ ព្រោះហេតុនោះ ទើបឈ្មោះថា សមត្តោ ប្រែថា មានភាពស្ងប់ជាប្រយោជន៍ ។*

តំ សមត្តំ។ សេសេសុបិ ឯសេវ នយោ។

ធម៌ដែលមានភាពស្ងប់ជាប្រយោជន៍នោះ ។ សូម្បីក្នុងបទដទៃទៀតក៏មានន័យបែបនេះដូចគ្នា ។

"មត្តំ សមោធានេតី"តិ មត្តផលក្ខណោយេវ គោចរំ និព្ពានមេវ ។

ពាក្យថា ***"រមែងញុំាងមគ្គឲ្យប្រជុំចុះ"*** *សេចក្តីថា រមែងញុំាងនិព្វាននោះឯង ដែលជាអារម្មណ៍ឲ្យប្រជុំចុះក្នុងខណៈនៃមគ្គ និងផលនោះឯង ។*

"អយំ បុគ្គលោ"តិ អានាចានស្សតិការំ អនុយុត្តោ យោគាវចរោ ។

ពាក្យថា ***"បុគ្គលនេះ"*** *បានដល់ ព្រះយោគាវចរអ្នកប្រព្រឹត្តនូវអានាបានស្សតិភាវនានោះឯង ។*

"ឥមស្មឹ អារម្មណេ"តិ ឯត្ត បន "កាយេ"តិបទេន សង្ខហិតេ ជាមរូបកាយសង្ខាតេ សង្ខតារម្មណេ តេនេវ កមេន មគ្គេ និព្ពានារម្មណេ ច ។

ចំណែកក្នុងពាក្យថា ***"ក្នុងអារម្មណ៍នេះ"*** *សេចក្តីថា ក្នុងអារម្មណ៍សង្ខតៈពោលគឺនាមកាយ និងរូបកាយដែលសង្គ្រោះដោយបទថា "* ***កាយេ*** *" ក្នុងអារម្មណ៍ គឺនិព្វាន ក្នុងមគ្គតាមលំដាប់នោះ នុ៎ះឯង ។*

"យំ តស្ស"តិអាទីហិ អារម្មណាគោចរសទ្ធាទំ ឯកត្តតា វុត្តា។

បទថា "យំ តស្ស" ជាដើម លោកពោលតាមសព្ទថា អារម្មណៈ ជាមួយគោចរ មានអត្ថសេចក្តី ដូចគ្នា ។

"**តស្សា**"តិ តស្ស បុគ្គលស្ស។ "**បជានាតីតិ បុគ្គលោ បជានាតិ បញ្ញា**"តិ បុគ្គលោ បញ្ញាយ បជានាតីតិ វុត្តំ ហោតិ។

*បទថា "**តស្ស** ប្រែថា **នៃបុគ្គលនោះ**" ។ បទថា "**បជានាតិ បញ្ញា** មានសេចក្តីថា **បុគ្គលរមែងដឹងច្បាស់ដោយបញ្ញា**" ។*

"**អារម្មណស្ស ឧបដ្ឋាន**"ន្តិ វិបស្សនាក្ខណោ សង្ខារារម្មណស្ស, មគ្គផលក្ខណោ និព្វានារម្មណស្ស ឧបដ្ឋានំ សតិ។

*បទថា "**អារម្មណស្ស ឧបដ្ឋានំ** ប្រែថា **ភាពចូលទៅតម្កល់ទុកនូវអារម្មណ៍** បានសេចក្តីថា ភាពចូលទៅតាំងនូវអារម្មណ៍ គឺសង្ខារក្នុងខណៈវិបស្សនា, និងអារម្មណ៍ គឺនិព្វាន ក្នុងខណៈនៃមគ្គ និងផលជាតួសតិ ។*

ឯត្ថ ច កម្មត្ថេ សាមិវចនំ យថា រញ្ញោ ឧបដ្ឋានន្តិ។ "អវិក្ខេបោ"តិ សមាធិ។

*ក៏ក្នុងបទថា អារម្មណស្ស ឧបដ្ឋានំ នេះ ជាឆដ្ឋីវិភត្តិដែលចុះក្នុងអត្ថនៃកម្ម ដូចជាក្នុងបទថា រញ្ញោ ឧបដ្ឋានំ ប្រែថា ការទំនុកបម្រុងនូវព្រះរាជា ។ បទថា "**អវិក្ខេបោ** ប្រែថា **ការមិនរាយមាយ**" បានដល់ សមាធិ ។*

"**អធិដ្ឋាន**"ន្តិ យថាវុត្តសង្ខារារម្មណំ និព្វានារម្មណញ្ច។

*បទថា "**អធិដ្ឋានំ** ប្រែថា **ភាពតាំងមាំ**" បានដល់ អារម្មណ៍ គឺ សង្ខារតាមដែលបានពោលមកហើយ និងអារម្មណ៍ គឺនិព្វាន ។*

តញ្ហិ អធិដ្ឋាតិ ឯត្ថ ចិត្តន្តិ អធិដ្ឋានំ។ "ភោជាន"ន្តិ ញាណំ។ តញ្ហិ ភោជាយតិ វិសុជ្ឈតិ តេន ចិត្តន្តិ ភោជានំ។

*ក៏អារម្មណ៍ទាំង ២ យ៉ាងនោះ ឈ្មោះថា **អធិដ្ឋាន** (ការតាំងមាំ) ដោយអត្ថថា ជាទីតាំងមាំនៃចិត្ត ។ បទថា "**ភោជានំ** ប្រែថា **ផូរផង់**" បានដល់គឺញាណ ។ ពិតមែន ញាណនោះ ឈ្មោះថា **ភោជាន** ដោយអត្ថថា ជាហេតុធ្វើឲ្យចិត្តផូរផង់*

និងឲ្យបរិសុទ្ធិ ។

លីនបក្ខិកោ សមាធិ អលីនការប្បត្តិយា សមភូតត្តា *សមំ*, ឧទ្ធច្ចបក្ខិកំ ញាណំ អនុទ្ធតការប្បត្តិយា សមភូតត្តា សមំ។

*សមាធិដែលប្រព្រឹត្តិទៅក្នុងចំណែកនៃសេចក្តីរួញរា ក៏ឈ្មោះថា **ស្ងប់** ព្រោះភាពស្ងប់ ដោយការបន្ទុះដល់ភាវៈដែលមិនរួញរា, ញាណដែលប្រព្រឹត្តទៅក្នុងចំណែកនៃឧទ្ធច្ចៈ ក៏ឈ្មោះថា ជាការស្ងប់ ព្រោះជាការស្ងប់ ដោយការបន្ទុះភាវៈដែលមិនរាយមាយ ។*

តេន វិបស្សនាមគ្គផលក្ខណេសុ សមថវិបស្សនាំ យុគនទ្ធតាវុត្តា ហោតិ។

ដោយពាក្យនោះ ដែលលោកពោលនូវសេចក្តីនៃសមថៈ និងវិបស្សនាស្របគ្នាដូចបន្ទាត់ជាគូគ្នាក្នុងខណៈវិបស្សនាមគ្គ និងផល ។

សតិ បន សព្ពត្ថិកត្តា តទុភយសមតាយ ឧបការិកាតិ សមំ, អារម្មណំ សមតាធិដ្ឋានត្តា សមំ។

ចំណែកសតិ ជាឧបការៈដល់ការស្ងប់ទាំងពីរនោះ ព្រោះមានប្រយោជន៍គ្រប់ស្ថានការណ៍ ព្រោះដូច្នោះ ទើបជាការស្ងប់, អារម្មណ៍ឈ្មោះថា ជាការស្ងប់ ព្រោះជាទីតាំងនៃសមថៈ ។

"អនវជ្ជដ្ឋោ"តិ វិបស្សនាយ អនវជ្ជសភាវោ។ "និក្កិលេសដ្ឋោ"តិ មគ្គស្ស និក្កិលេសសភាវោ។

*ពាក្យថា **"អត្ថថាមិនមានទោស"** បានដល់ សភាវៈដែលមិនមានទោសនៃវិបស្សនា ។ បទថា **"និក្កិលេសដ្ឋោ** ប្រែថា **មិនមានកិលេស** បានដល់ សភាវៈដែលមិនមានកិលេសនៃមគ្គ។*

និក្ខេសដ្ឋោតិ វា ចាហោ។ "ភោគានដ្ឋោ"តិ ផលស្ស បរិសុទ្ធ-

សភាវោ។

*នីយម្យ៉ាងទៀត ព្រះបាលីពោលថា និក្ខេសដ្ឋោ ប្រែថា អត្តថា មិនមានកិលេស បែបនេះក៏មាន ។ ពាក្យថា "**អត្តថា ផ្ទរផង់** បានដល់ សភាវៈដែលបរិសុទ្ធិនៃផល ។*

"បរមដ្ឋោ"តិ និព្វានស្ស សព្វជម្មុត្តមសភាវោ។

*ពាក្យថា "**អត្តថាក្រៃលែង**" បានដល់ សភាវៈដែលខ្ពស់បំផុតនៃធម៌ទាំងពួងនៃព្រះនិព្វាន ។*

"បដិវិជ្ឈតី"តិ តំ តំ សភាវំ អសម្មោហតោ បដិវិជ្ឈតិ។

*ពាក្យថា "**រមែងចាក់ធ្ទុះ**" គឺរមែងចាក់ធ្ទុះនូវសភាវៈនោះៗ ដោយភាពមិនវង្វេង ។*

ឯត្ត ច "អារម្មណស្ស ឧបដ្ឋាន"ន្តិអាទីហិ សម្មា បដិវេធោ វុត្តោ។

ក៏ក្នុងទីនេះ លោកពោលដល់ការចាក់ធ្ទុះដោយប្រពៃ ដោយពាក្យថា "ការចូលទៅតាំងទុកនូវអារម្មណ៍" ដូចនេះ ។

ឯត្តេវ ច ភេទានដ្ឋបដិវេធស្ស វុត្តត្តា តេន ឯកលក្ខណា អនវជ្ជ-ដ្ឋនិក្ពិលេសដ្ឋបរមដ្ឋា លក្ខណហារវសេន វុត្តាយេវ ហោន្តិ។

ព្រោះក្នុងអធិការនេះ នុ៉ះឯង លោកពោលដល់ភាពចាក់ធ្ទុះ ដែលមានភាពផ្ទរផង់ជាអត្ត ដូចនោះ អត្តថាមិនមានទោស អត្តថាអស់កិលេស និងអត្តថាក្រៃលែង ដែលមានលក្ខណៈដូចគ្នាជាមួយនិងសេចក្តីនោះ ជាការដែលលោកពោលហើយដោយអំណាចលក្ខណៈជាវោហារសព្ទ ។

យថាហ –

ដូចជាលោកបានពោលថា ៖

"វុត្តម្ហិ ឯកធម្មេ, យេ ធម្មា ឯកលក្ខណា កេចិ;
វុត្តា ភវន្តិ សព្ពេ, សោ ហាហោ លក្ខណោ ជាមា"តិ[៦៥]។

"កាលធម៌ឯណាមួយ លោកពោលហើយ ធម៌ទាំងឡាយនោះ ដែលមានលក្ខណៈដូចគ្នា ក៏រមែងដូចជាការពោលហើយទាំងអស់ ហោហាសព្ទដែលលោកពោលហើយយ៉ាងនេះ ឈ្មោះថា លក្ខណៈហោហា"។

អនវជ្ជដ្ឋោ និក្កិលេសដ្ឋោ ចេត្ថ អវិក្ខេបសង្ខាតស្ស សមស្ស អត្តោ បយោជនន្តិ សមត្តោ, ភោជានដ្ឋោ វិមុត្តរសមត្តភោជានំ សង្ខាយ សមមេវ អត្តោតិ សមត្តោ, ផលភោជានំ សង្ខាយ មត្តភោជានសង្ខាតស្ស សមស្ស អត្តោតិ សមត្តោ, បរមដ្ឋោ បន សមមេវ អត្តោតិ វា និព្ពានបយោជនត្តា សព្ពស្ស សមស្ស អត្តោតិ វា សមត្តោ, តំ វុត្តប្បការំ សមញ្ច សមត្តញ្ច ឯកទេសសរូ-បេកសេសំ កត្វា "សមត្តញ្ច បដិវិជ្ឈតី"តិ វុត្តំ។

*ក៏អត្តថាមិនមានទោស អត្តថាមិនមានកិលេស ក្នុងអធិការនេះជាអត្ត គឺជាប្រយោជន៍នៃការសូប់ ពោលគឺ ភាពមិនរាយមាយ ព្រោះដូច្នោះ ទើបឈ្មោះថា អត្តថាសូប់, អត្តថាផូរផង់ ជាអត្តគឺភាពសូប់ បានដល់ភាពផូរផង់ ព្រោះដូច្នោះ ទើបឈ្មោះថា អត្តថាសូប់, អត្តនៃភាពសូប់ ពោលគឺ ភាពផូរផង់ គឺមគ្គ បានដល់ភាពផូរផង់គឺផល ព្រោះដូច្នោះ ទើបឈ្មោះថា អត្តថាសូប់, ចំណែកអត្តថា ក្រៃលែងជាអត្ត គឺភាពសូប់ ឬជាអត្តនៃភាពសូប់ទាំងអស់ ព្រោះមាននិព្វានជាប្រយោជន៍ ព្រោះដូច្នោះ ទើបឈ្មោះថា អត្តថាសូប់, លោកពោលថា "**និងចាក់ធុះអត្តថាសូប់**" ដូចនេះ ព្រោះធ្វើភាពសូប់ និងអត្តថាសូប់ ដែលមានប្រការដូចបានពោលមកហើយនោះ ឲ្យជាសរូបេកសេស ដោយឯកទេស។*

ឥន្ទ្រិយពលពោជ្ឈង្គធម្មា វិមុត្តរសមត្តផលក្ខណោបិ លព្ភន្តិ,

---

៦៥ (នេត្តិ. ៤.៥ និទ្ទេសវារ)។

មគ្គោ ច តិស្សោ ច វិសុទ្ធិយោ មគ្គផលក្ខណោយេវ, វិមោក្ខោ ច វិជ្ជា ច ខយេ ញាណញ្ច មគ្គក្ខណោយេវ, វិមុត្តិ ច អនុប្បាទេ ញាណញ្ច ផលក្ខណោយេវ, សេសា វិបស្សនាក្ខណោបីតិ។

ធម៌គឺឥន្ទ្រិយ ពល: និងពោជ្ឈង្គ រមែងបានសូម្បីក្នុងខណៈវិបស្សនា មគ្គផល, មគ្គ និងវិសុទ្ធិទាំង ៣ ក៏រមែងបានក្នុងខណៈនៃមគ្គ និងផល នុ៎ះឯង, ចំណែកវិមោក្ខៈផង វិជ្ជាផង និងខយញាណ រមែងបាន ក្នុងខណៈនៃមគ្គតែម្យ៉ាង, ចំណែកវិមុត្ត និងអនុប្បាទញាណ រមែងបាន ក្នុងខណៈនៃផលតែម្យ៉ាង, ដ៏សេសក្រៅពីនោះ រមែងបាន សូម្បីក្នុង ខណៈនៃវិបស្សនាដូចនេះឯង ។

ឧម្មាវេ "ឥមេ ធម្មេ ឥមស្មឹ អារម្មណេ សមោធានេតី"តិ ឯត្ថាំ បមេត្វា សេសា យថាយោគំ វេទិតព្វា។

*ក្នុងវារៈនៃធម៌មានវិនិច្ឆ័យដូចនេះ ពាក្យថា "**រមែងញុំាងធម៌ទាំងនេះឲ្យប្រជុំចុះក្នុងអារម្មណ៍**" មានសេចក្តីថា ធម៌ដ៏សេសរៀរលែងនិព្វាន គប្បីជ្រាបតាមសេចក្តីគួរ ។*

ឥទំ បន យេកុយ្យវសេន វុត្តំ។ អវុត្តត្តា បនេត្ថ ហេដ្ឋា វុត្តា ឯវ។

ក៏ពាក្យនេះ លោកពោលដោយអំណាចនៃយេកុយ្យន័យ ។ ចំណែកអត្ថដែលលោកមិនបានពោលទុកក្នុងទីនេះ លោកបានពោលទុកហើយក្នុងក្រមខាងក្រោយនោះឯង។

ឯកេកចតុក្កវសេនេត្ថ និយ្យានេ ឧស្សិតេបិ ចតុក្កន្តោគធស្ស ឯកេកស្សាបិ ភាគស្ស និយ្យានស្ស ឧបនិស្សយត្តា ឯកេកភាគវសេន និយ្យានំ ឧស្សិតំ។

សូម្បីកាលលោកសម្តែងនូវនិយាមទុកក្នុងទីនេះ ដោយអំណាចចតុក្កៈតែមួយចតុក្កៈ លោកក៏បានសម្តែងនូវនិយាមដោយអំណាចតែមួយចំណែក។

ព្រោះចំណែកសូម្បីតែមួយចំណែកៗ ដែលញ៉ាំងចុះក្នុងចតុក្ក: ក៏ជាឧបនិស្សយ នៃនិយ្យាន ។

ន ហិ ឯកេកំ វិនា និយ្យានំ ហោតីតិ។

ព្រោះវៀរចំណែក តែមួយចំណែកៗ ក៏រមែងមិនមាននិយ្យាន ដូច្នេះឯង (និយ្យាន សតិដែលនាំខ្យល់អស្សាស:បស្សាស: ចេញទៅ ឬសមាធិ គឺអានាបានស្សតិ នុ៎ះឯង ។

ឥមំ អស្សាសបស្សាសនិទ្ទេសវណ្ណនា និដ្ឋិតា។

ការពណ៌នានូវនិទ្ទេសនៃខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញ វែង ចប់ ។

ខ្យល់ដកដង្ហើមចូល ចេញខ្លី

ចតុក្កទី ១ ឈំជាប់ទី ២ (បិដក ៧០) [១០៩]

[១៦៩] **កថំ រស្សំ អស្សសន្តោ "រស្សំ អស្សសាមី"តិ បជានាតិ, រស្សំ បស្សសន្តោ**

"រស្សំ បស្សសាមី"តិ បជានាតិ?

កិក្ខុកាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា "អាត្មាអញ ដកដង្ហើមចូលខ្លី", កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា "អាត្មាអញ ដកដង្ហើមចេញខ្លី" តើដូចម្តេច?។

១. ខ្យល់ដង្ហើមចូល ចេញខ្លី

១. រស្សំ អស្សាសំ ឥត្តរសង្ខាតេ អស្សសតិ,

ព្រះយោគីភិក្ខុ ដកចូល នូវដង្ហើមចូលខ្លី ក្នុងចំណែកកាលដែលខ្លី,

២. រស្សំ បស្សាសំ ឥត្តរសង្ខាតេ បស្សសតិ,

យោគីភិក្ខុ ដកចេញ នូវដង្ហើមចេញខ្លី ក្នុងចំណែកកាលដែលខ្លី,

៣. រស្សំ អស្សាសបស្សាសំ ឥត្តរសង្ខាតេ អស្សសតិបិ បស្សសតិបិ។

ភិក្ខុ ដកចូលក្តី ដកចេញក្តី នូវដង្ហើមចូល ឬដង្ហើមចេញខ្លី ក្នុងចំណែកកាលដែលខ្លី។

២. ឆន្ទៈ រមែងកើតឡើង

រស្សំ អស្សាសបស្សាសំ ឥត្តរសង្ខាតេ អស្សសតោបិ បស្សសតោបិ ឆន្ទោ ឧប្បជ្ជតិ។

ភិក្ខុកាលដកចូលក្តី ដកចេញក្តី នូវដង្ហើមចូល ឬដង្ហើមចេញខ្លី ក្នុងចំណែកកាលដែលខ្លី (ច្រើនៗ ដង) វីរិយៈ(គឺចំណង់ក្នុងអ្វីមួយ) រមែងកើតឡើង។

១. ឆន្ទវសេន តតោ សុខុមតរំ រស្សំ អស្សាសំ ឥត្តរសង្ខាតេ អស្សសតិ។

ភិក្ខុកាលដកចូល នូវដង្ហើមចូលខ្លី ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលដែលខ្លី ដោយអំណាចឆន្ទៈ។

២. ឆន្ទវសេន តតោ សុខុមតរំ រស្សំ បស្សាសំ ឥត្តរសង្ខាតេ បស្សសតិ។

ភិក្ខុកាលដកចេញ នូវដង្ហើមចេញខ្លី ល្អិតក្រៃលែងជាងនោះ ក្នុងចំណែកកាលដែលខ្លី ដោយអំណាចឆន្ទៈ។

៣. ឆន្ទវសេន តតោ សុខុមតរំ រស្សំ អស្សាសបស្សាសំ ឥត្តរសេ-ជ្ជាតេ អស្សសតិបិ បស្សសតិបិ។

កិក្ខុកាលដកចូលក្តី ដកចេញក្តី នូវដង្ហើមចូល ឬដង្ហើមចេញខ្លី ល្អិត ក្រៃលែងជាងនោះ ក្នុងចំណែកកាលដែលខ្លី ដោយអំណាចឆន្ទៈ។

៣. បាមោជ្ជ រមែងកើតឡើង

ឆន្ទវសេន តតោ សុខុមតរំ រស្សំ អស្សាសបស្សាសំ ឥត្តរសេជ្ជាតេ អស្សសតោបិ បស្សសតោបិ ចាមោជ្ជំ ឧប្បជ្ជតិ។

កិក្ខុកាលដកចូលក្តី ដកចេញក្តី នូវដង្ហើមចូល ឬដង្ហើមចេញខ្លី ល្អិត សុខុមក្រៃលែងជាងនោះ ក្នុងចំណែកកាលខ្លី ដោយអំណាចឆន្ទៈ(ច្រើនៗ ដង) រីបាមោជ្ជៈ រមែងកើតឡើង។

១. ចាមោជ្ជវសេន តតោ សុខុមតរំ រស្សំ អស្សាសំ ឥត្តរសេជ្ជាតេ អស្សសតិ។

កិក្ខុកាលដកចូល នូវដង្ហើមចូលខ្លី ល្អិតសុខុមក្រៃលែងជាងនោះ ក្នុងចំណែកកាលខ្លី ដោយអំណាចបាមោជ្ជ។

២. ចាមោជ្ជវសេន តតោ សុខុមតរំ រស្សំ បស្សាសំ ឥត្តរសេជ្ជាតេ បស្សសតិ។

កិក្ខុកាលដកចេញ នូវដង្ហើមចេញខ្លី ល្អិតសុខុមក្រៃលែងជាងនោះក្នុងចំណែកកាលខ្លី ដោយអំណាចបាមោជ្ជ។

៣. ចាមោជ្ជវសេន តតោ សុខុមតរំ រស្សំ អស្សាសបស្សាសំ ឥត្តរសេជ្ជាតេ អស្សសតិបិ បស្សសតិបិ។

កិក្ខុកាលដកចូលក្តី ដកចេញក្តី នូវដង្ហើមចូល ឬដង្ហើមចេញខ្លី ដែលល្អិត

សុខុមក្រៃលែងជាងនោះ ក្នុងចំណែកកាលខ្ចី ដោយអំណាចបាមោជ្ជ: ។

៤. ឧបេក្ខា រមែងកើតឡើង

ចាមោជ្ជវសេន តតោ សុខុមតរំ រស្សំ អស្សាសបស្សាសំ ឥត្តរសជ្ជាតេ អស្សសតោបិ បស្សសតោបិ,

ភិក្ខុកាលដកចូលក្តី ដកចេញក្តី នូវដង្ហើមចូល ឬដង្ហើមចេញខ្ចី ដែលល្អិត សុខុមក្រៃលែងជាងនោះ ក្នុងចំណែកកាលខ្ចី ដោយអំណាចបាមោជ្ជ ,

រស្សំ អស្សាសបស្សាសា ចិត្តំ រិវជ្ជតិ, ឧបេក្ខា សណ្ឋាតិ។

ចិត្ត(ជានាមធម៌) ក៏ឃ្ងាតចេញ អំពីដង្ហើមចូល ឬដង្ហើមចេញខ្ចី(ខ្យល់ជារូបធម៌), រីឧបេក្ខា ក៏តាំងនៅស៊ប់ ។

ឥមេហិ នវហាការេហិ រស្សា អស្សាសបស្សាសា កាយោ,

កាយ គឺដង្ហើមចូល និងដង្ហើមចេញខ្ចី ដោយអាការ: ៩ យ៉ាងនេះ,

ឧបដ្ឋានំ សតិ, អនុបស្សនា ញាណំ។

សភាវធម៌ដែលចូលទៅកាន់អារម្មណ៍ ហើយតាំងនៅ ឈ្មោះថា សតិ (សតិជានាមធម៌) ឬ (ភាពប្រាកដ ឈ្មោះថា សតិ), សភាវ:តាមពិចារណា ឃើញរឿយៗ ឈ្មោះថា ញាណ ។

កាយោ ឧបដ្ឋានំ, នោ សតិ; សតិ ឧបដ្ឋានញ្ចេវ សតិ ច។

កាយ ឈ្មោះថា ឧបដ្ឋាន (ដែលចូលទៅ ហើយតាំងនៅនៃសតិ បានដល់ខ្យល់ចូលចេញ), មិនមែន ឈ្មោះថា ជាសតិទេ, ចំណែកខាងសតិ ឈ្មោះថា ជាឧបដ្ឋានផង និងជាតួសតិផង ។

តាយ សតិយា តេន ញាណេន តំ កាយំ អនុបស្សតិ។

ភិក្ខុរមែងពិចារណាឃើញរឿយៗ នូវកាយនោះ ដោយសតិនោះ ដោយ

ញាណនោះ។

តេន វុច្ចតិ – "កាយេ កាយានុបស្សនាសតិប្បដ្ឋានភាវនា"តិ។

ព្រោះហេតុនោះ លោកពោលថា **"កាយេ កាយានុបស្សនាសតិ-ប្បដ្ឋានភាវនា"** *គឺការចម្រើនសតិប្បដ្ឋាន ដោយការពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ដោយប្រការៈ ដូច្នេះឯង។*

"អនុបស្សតី"តិ កថំ តំ កាយំ អនុបស្សតិ។...បេ...។ ឯវំ តំ កាយំ អនុបស្សតិ។

ពាក្យថា ***"ពិចារណាឃើញរឿយៗ"*** *តើពិចារណាឃើញនូវកាយនោះដូចម្តេច? ។...ល...។ កិក្ខុពិចារណាឃើញរឿយៗ នូវកាយនោះ យ៉ាងនេះឯង។*

"ភាវនា"តិ ចតស្សោ ភាវនា។...បេ...។ អាសេវនដ្ឋេន ភាវនា។

ពាក្យថា "ភាវនា" បានដល់ ភាវនា ៤ យ៉ាង។...ល...។ ភាវនា ដោយអត្ថថា សេព ប្រព្រឹត្ត។

រស្សំ អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ វិទិតា វេទនា ឧប្បជ្ជន្តិ។...បេ...។

កាលកិក្ខុដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូល ឬខ្យល់ដង្ហើមចេញខ្លី វេទនាទាំងឡាយ ដែលប្រាកដ រមែងកើតឡើង។...ល...។

រស្សំ អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ឥន្ទ្រិយានិ សមោធានេតិ។...បេ...។

កាលកិក្ខុដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូល ឬខ្យល់ដង្ហើមចេញខ្លី ឈ្មោះថាប្រមូលមកនូវឥន្ទ្រិយទាំងឡាយ។...ល...។

តេន វុច្ចតិ – "សមត្ថញ្ច បដិវិជ្ឈតី"តិ។

ព្រោះហេតុនោះ លោកពោលថា "ចាក់ធ្ទុះនូវអត្ថនៃការសូប់" ។

ចប់ ចតុក្ក:ទី ១ លំដាប់ទី ២

ខ្យល់ជកជឡើមចូល ចេញខ្លី

ចតុក្កទី ១ លំដាប់ទី ២ (អដ្ឋកថា)

[៣៦៩] រស្សនិទ្ទេសេ "**ឥត្តរសជ្ជាតេ**"តិ បរិត្តសជ្ជាតេ កាលេ។

*នឹងវិនិច្ច័យក្នុងរស្ស:និទ្ទេសដូចតទៅនេះ ពាក្យថា "**ក្នុងចំណែកកាលខ្លី**" គឺក្នុងកាលដែលពោលថា បន្តិចបន្ទួច ។*

សេសមេត្ត វុត្តនយេន វេទិតព្ធំ។

ពាក្យដទៃក្នុងទីនេះ គប្បីជ្រាបទៅតាមន័យដែលបានពោលទុកមកហើយ ។

សព្វកាយប្បដិសំវេទី

ចតុក្កៈ ទី ១ លំដាប់ទី ៣ (បិដក ៧០) [១១១]

[១៧០] កថំ "សព្វកាយប្បដិសំវេទី អស្សសិស្សាមី"តិ សិក្ខតិ, "សព្វកាយប្បដិសំវេទី បស្សសិស្សាមី"តិ សិក្ខតិ?

កិត្តុសិក្សាថា "អាត្មាអញ កំណត់ដឹងឲ្យច្បាស់ នូវកាយ គឺខ្យល់ដង្ហើមទាំងអស់ ជាចំណែកៗ ដោយល្អ ក្នុងខណៈដកដង្ហើមចូល",

សិក្សាថា "អាត្មាអញ កំណត់ដឹងឲ្យច្បាស់ នូវកាយ គឺខ្យល់ដង្ហើមទាំងអស់ ជាចំណែកៗ ដោយល្អ ក្នុងខណៈដកដង្ហើមចេញ", តើដូចម្តេច?

"កាយោ"តិ ទ្វេ កាយា – នាមកាយោ ច រូបកាយោ ច។

*ពាក្យថា "**កាយ**" បានដល់ កាយ ២ យ៉ាង គឺនាមកាយ ១ និងរូបកាយ ១។*

កតមោ នាមកាយោ?

តើនាមកាយ ដូចម្តេច?

វេទនា, សញ្ញា, ចេតនា, ផស្សោ, មនសិការោ, នាមញ្ច នាមកាយោ ច, យេ ច វុច្ចន្តិ ចិត្តសង្ខារា – អយំ នាមកាយោ។

វេទនា, សញ្ញា, ចេតនា, ផស្សៈ, មនសិការៈ, ឈ្មោះថា ជានាមផង ឈ្មោះថា ជាកាយផង, មួយទៀត ពួកធម៌ណា ដែលលោកពោលថា ចិត្តសង្ខារ នេះ ឈ្មោះថា ជានាមកាយ។

កតមោ រូបកាយោ?

រូបកាយ តើដូចម្តេច?

ចត្តារោ ច មហាភូតា, ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ,

មហាភូតរូប ៤ ផង និងឧបាទាយរូប របស់មហាភូតរូប ៤ ផង,

អស្សាសោ ច បស្សាសោ ច, និមិត្តញ្ច ឧបនិពន្ធនា, យេ ច វុច្ចន្តិ កាយសង្ខារា – អយំ រូបកាយោ ។

ខ្យល់ដង្ហើមចូលផង ខ្យល់ដង្ហើមចេញផង និងនិមិត្តដែលចូលទៅតម្កល់ទុកផង (គឺត្រង់ចុងច្រមុះ ឬលើផ្ទៃបបូរមាត់ខាងលើ) ឈ្មោះថា រូបកាយ, មួយទៀត ពួកធម៌ណា ដែលលោកពោលថា កាយសង្ខារ នេះ ឈ្មោះថា ជារូបកាយ ។

កថំ តេ កាយា បដិវិទិតា ហោន្តិ?

កាយទាំងឡាយនោះ ដែលភិក្ខុដឹងច្បាស់ហើយ តើដូចម្តេច?

ឌីឃំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ។

កាលភិក្ខុដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយដែលមិនរាយមាយដោយអំណាចនៃខ្យល់ដង្ហើមចូលវែង សតិរមែងតាំងឡើង ។

តាយ សតិយា តេន ញាណេន តេ កាយា បដិវិទិតា ហោន្តិ។

*កាយទាំងឡាយនោះ ឈ្មោះថា ភិក្ខុដឹងច្បាស់ច្បាស់ច្បាស់

កាយទាំងឡាយនោះ ឈ្មោះថា ភិក្ខុដឹងច្បាស់ប្រាកដហើយ ដោយសតិនោះ ដោយញាណនោះ ។

រស្សំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ។

កាលភិក្ខុដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូលខ្លី សតិរមែងតាំងឡើង ។

តាយ សតិយា តេន ញាណេន តេ កាយា បដិវិទិតា ហោន្តិ។

កាយទាំងឡាយនោះ ឈ្មោះថា ភិក្ខុដឹងច្បាស់ប្រាកដហើយ ដោយសតិនោះ ដោយញាណនោះ ។

រស្សំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ។

កាលភិក្ខុដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍មូលតែមួយ ដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចេញខ្លី សតិរមែងតាំងឡើង ។

តាយ សតិយា តេន ញាណេន តេ កាយា បដិវិទិតា ហោន្តិ។

កាយទាំងឡាយនោះ ឈ្មោះថា ភិក្ខុដឹងច្បាស់ប្រាកដហើយ ដោយសតិនោះ ដោយញាណនោះ

ការដឹងប្រាកដមាន ១៥ យ៉ាង

១. **អាវជ្ជតោ តេ កាយា បដិវិទិតា ហោន្តិ,**

កាលភិក្ខុ គិតរំពឹងដល់កាយទាំងឡាយនោះ ឈ្មោះថា គេដឹងប្រាកដហើយ,

២. **បជានតោ តេ កាយា បដិវិទិតា ហោន្តិ,**

កាលកិក្ខុ ដឹងនូវកាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្រាកដហើយ,

៣. **បស្សម្ភតោ តេ កាយា បដិវិទិតា ហោន្តិ,**

កាលកិក្ខុ ឃើញនូវកាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្រាកដហើយ,

៤. **បច្ចវេក្ខតោ តេ កាយា បដិវិទិតា ហោន្តិ,**

កាលកិក្ខុ ពិចារណានូវកាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្រាកដហើយ,

៥. **ចិត្តំ អធិដ្ឋហតោ តេ កាយា បដិវិទិតា ហោន្តិ,**

កាលកិក្ខុ តាំងចិត្តឲ្យតាំងនៅ នៃកាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្រាកដហើយ,

៦. **សទ្ធាយ អធិមុច្ចតោ តេ កាយា បដិវិទិតា ហោន្តិ,**

កាលកិក្ខុ ជឿស៊ប់ដោយសទ្ធា កាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្រាកដហើយ,

៧. **វីរិយំ បគ្គណ្ហាតោ តេ កាយា បដិវិទិតា ហោន្តិ,**

កាលកិក្ខុ ផ្គងព្យាយាម កាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្រាកដហើយ,

៨. **សតិឧបដ្ឋាបយតោ តេ កាយា បដិវិទិតា ហោន្តិ,**

កាលកិក្ខុ តម្កល់នូវសតិ កាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្រាកដហើយ,

៩. **ចិត្តំ សមាទហតោ តេ កាយា បដិវិទិតា ហោន្តិ,**

កាលកិក្ខុ តម្កល់នូវចិត្ត កាយទាំងឡាយនោះ ឈ្មោះថា គេដឹងច្រាកដហើយ,

១០. បញ្ញាយ បជានតោ តេ កាយា បដិវិទិតា ហោន្តិ,

កាលភិក្ខុ ដឹងច្បាស់ដោយប្រាជ្ញា កាយទាំងឡាយនោះ ឈ្មោះថា គេដឹងប្រាកដហើយ,

១១. អភិញ្ញេយ្យំ អភិជានតោ តេ កាយា បដិវិទិតា ហោន្តិ,

កាលភិក្ខុ ត្រាស់ដឹងនូវធម៌ដែលគួរត្រាស់ដឹង កាយទាំងឡាយនោះ ឈ្មោះថា គេដឹងប្រាកដហើយ,

១២. បរិញ្ញេយ្យំ បរិជានតោ តេ កាយា បដិវិទិតា ហោន្តិ,

កាលភិក្ខុ កំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង កាយទាំងឡាយនោះ ឈ្មោះថា គេដឹងប្រាកដហើយ,

១៣. បហាតព្ពំ បជហតោ តេ កាយា បដិវិទិតា ហោន្តិ,

កាលភិក្ខុ លះបង់នូវធម៌ដែលគួរលះបង់ កាយទាំងឡាយនោះ ឈ្មោះថា គេដឹងប្រាកដហើយ,

១៤. ភាវេតព្ពំ ភាវយតោ តេ កាយា បដិវិទិតា ហោន្តិ,

កាលភិក្ខុ ចម្រើននូវធម៌ដែលគួរចម្រើនកាយទាំងឡាយនោះ ឈ្មោះថា គេដឹងប្រាកដហើយ,

១៥. សច្ឆិកាតព្ពំ សច្ឆិករោតោ តេ កាយា បដិវិទិតា ហោន្តិ។

កាលភិក្ខុ ធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យជាក់ច្បាស់ កាយទាំងឡាយនោះ ឈ្មោះថា គេដឹងប្រាកដហើយ ។

ឯវំ តេ កាយា បដិវិទិតា ហោន្តិ។

កាយទាំងឡាយនោះ ដែលមានប្រាកដ យ៉ាងនេះឯង ។

សព្ពកាយប្បដិសំវេទី អស្សាសបស្សាសា កាយោ,

កាយ គឺខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ សម្រាប់អ្នកកំណត់ដឹងនូវ សព្វកាយប្បដិសំវេទី,

ឧបដ្ឋានំ សតិ, អនុបស្សនា ញាណំ។

សភាវៈធម៌ ដែលចូលទៅកាន់អារម្មណ៍ ហើយតាំងនៅ ឈ្មោះថា សតិ (សតិជានាមធម៌) ឬ (ដឹងភាពប្រាកដ ឈ្មោះថា សតិ), សភាវៈតាមពិចារណា ឃើញរឿយៗ ឈ្មោះថា ញាណ ។

កាយោ ឧបដ្ឋានំ, នោ សតិ; សតិ ឧបដ្ឋានញ្ចេវ សតិ ច។

កាយ ឈ្មោះថា ឧបដ្ឋាន (ដែលចូលទៅ ហើយតាំងនៅនៃសតិ បានដល់ ខ្យល់ចូលចេញ), មិនមែន ឈ្មោះថា ជាសតិទេ, ចំណែកខាងសតិ ឈ្មោះថា ជា ឧបដ្ឋានផង និងជាតួសតិផង ។

តាយ សតិយា តេន ញាណេន តំ កាយំ អនុបស្សតិ។

ភិក្ខុរមែងពិចារណាឃើញរឿយៗ នូវកាយនោះ ដោយសតិនោះ ដោយ ញាណនោះ។

តេន វុច្ចតិ – "កាយេ កាយានុបស្សនាសតិប្បដ្ឋានភាវនា"តិ។

ព្រោះហេតុនោះ លោកពោលថា "កាយេ កាយានុបស្សនាសតិប្បដ្ឋាន ភាវនា" គឺការចម្រើនសតិប្បដ្ឋាន ដោយការពិចារណាឃើញរឿយៗ នូវកាយក្នុង កាយ ដោយប្រការៈ ដូច្នេះឯង ។

"អនុបស្សតី"តិ កថំ តំ កាយំ អនុបស្សតិ។...បេ...។ ឯវំ តំ កាយំ អនុបស្សតិ។

*ពាក្យថា "**ពិចារណាឃើញរឿយៗ**" តើពិចារណាឃើញនូវកាយនោះ ដូចម្តេច ? ។ល។ ភិក្ខុពិចារណាឃើញរឿយៗ នូវកាយនោះ យ៉ាងនេះឯង ។*

"ភាវនា"តិ ចតស្សោ ភាវនា។...បេ...។ អាសេវនដ្ឋេន ភាវនា។

*ពាក្យថា "**ភាវនា**" បានដល់ ភាវនា ៤ យ៉ាង ។...ល...។ ភាវនា ដោយអត្ថ ថា ប្រព្រឹត្ត ។*

វិសុទ្ធិ និងសិក្ខាទាំង ៣

១. សព្វកាយបដិសំវេទី អស្សាសបស្សាសំ[៦៦] សំវរដ្ឋេន សីលវិសុទ្ធិ,

*ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ របស់យោគាវចរអ្នកកំណត់ដឹង នូវកាយទាំងពួង ឈ្មោះថា **សីលវិសុទ្ធិ** ដោយអត្ថថា សង្រួម ។*

២. អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ,

*ឈ្មោះថា **ចិត្តវិសុទ្ធិ** ដោយអត្ថថា មិនរាយមាយ,*

៣. ឧស្សជ្ជដ្ឋេន ទិដ្ឋិវិសុទ្ធិ។

*ឈ្មោះថា **ទិដ្ឋិវិសុទ្ធិ** ដោយអត្ថថា ឃើញ ។*

១. យោ តត្ថ សំវរដ្ឋោ, អយំ អធិសីលសិក្ខា។

*បណ្តាធម៌ទាំងនោះ ធម៌ណា មានអត្ថថា សង្រួម, ធម៌នេះ ឈ្មោះថា **អធិសីលសិក្ខា**។*

២. យោ តត្ថ អវិក្ខេបដ្ឋោ, អយំ អធិចិត្តសិក្ខា។

*បណ្តាធម៌ទាំងនោះ ធម៌ណា មានអត្ថថា មិនរាយមាយ, ធម៌នេះ ឈ្មោះថា **អធិចិត្តសិក្ខា** ។*

៣. យោ តត្ថ ឧស្សជ្ជដ្ឋោ, អយំ អធិបញ្ញាសិក្ខា។

*បណ្តាធម៌ទាំងនោះ ធម៌ណាមានអត្ថថា ឃើញ, ធម៌នេះ ឈ្មោះថា **អធិបញ្ញាសិក្ខា**។*

---

៦៦ ស្យា. អស្សាសបស្សាសា ។

ពាក្យថា សិក្ខាមាន ១៥ យ៉ាង

១. **ឥមា តិស្សោ សិក្ខាយោ អាវជ្ជន្តោ សិក្ខតិ,**

ភិក្ខុកាល រំពឹងគិតដល់ នូវសិក្ខាទាំង ៣ ឈ្មោះថា រមែងសិក្សា,

២. **ជានន្តោ សិក្ខតិ,**

កាលដឹង ឈ្មោះថា រមែងសិក្សា,

៣. **បស្សន្តោ សិក្ខតិ,**

កាលឃើញ ឈ្មោះថា រមែងសិក្សា,

៤. **បច្ចវេក្ខន្តោ សិក្ខតិ,**

កាលពិចារណា ឈ្មោះថា រមែងសិក្សា,

៥. **ចិត្តំ អធិដ្ឋហន្តោ សិក្ខតិ,**

កាលអធិដ្ឋានចិត្ត ឈ្មោះថា រមែងសិក្សា,

៦. **សទ្ធាយ អធិមុច្ចន្តោ សិក្ខតិ,**

កាលជឿស៊ប់ដោយសទ្ធា ឈ្មោះថា រមែងសិក្សា,

៧. **វីរិយំ បគ្គណ្ហន្តោ សិក្ខតិ,**

កាលផ្គងនូវវីរិយៈ ឈ្មោះថា រមែងសិក្សា,

៨. **សតឹ ឧបដ្ឋបេន្តោ សិក្ខតិ,**

កាលប្រុងនូវសតិ ឈ្មោះថា រមែងសិក្សា,

៩. **ចិត្តំ សមាទហន្តោ សិក្ខតិ,**

កាលតម្កល់នូវចិត្ត ឈ្មោះថា រមែងសិក្សា,

១០. **បញ្ញាយ បជានន្តោ សិក្ខតិ,**

កាលដឹងច្បាស់ដោយប្រាជ្ញា ឈ្មោះថា វមែង់សិក្សា,

១១. **អភិញ្ញេយ្យំ អភិជានន្តោ សិក្ខតិ,**

កាលត្រាស់ដឹងនូវធម៌ ដែលគួរត្រាស់ដឹង ឈ្មោះថា វមែង់សិក្សា,

១២. **បរិញ្ញេយ្យំ បរិជានន្តោ សិក្ខតិ,**

កាលកំណត់ដឹងនូវធម៌ ដែលគួរកំណត់ដឹង ឈ្មោះថា វមែង់សិក្សា,

១៣. **បហាតព្ពំ បជហន្តោ សិក្ខតិ,**

កាលលះនូវធម៌ ដែលគួរលះ ឈ្មោះថា វមែង់សិក្សា,

១៤. **ភាវេតព្ពំ ភាវេន្តោ សិក្ខតិ,**

កាលចម្រើននូវធម៌ ដែលគួរចម្រើនឈ្មោះថា វមែង់សិក្សា,

១៥. **សច្ឆិកាតព្ពំ សច្ឆិករោន្តោ សិក្ខតិ។**

កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា វមែង់សិក្សា ។

សព្ពកាយបដិសំវេទី អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ, វិទិតា វេទនា ឧប្បជ្ជន្តិ។...បេ...។

កាលភិក្ខុដឹងច្បាស់នូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ សម្រាប់អ្នកកំណត់ដឹងនូវកាយទាំងពួង, វេទនាទាំងឡាយ ដែលប្រាកដ វមែងកើតឡើង ។...ល...។

សព្ពកាយបដិសំវេទី អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានន្តោ, ឥន្ទ្រិយានិ សមោជានេតិ។...បេ...។

ភិក្ខុកាលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិន

ភយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ សម្រាប់អ្នក កំណត់ដឹងនូបកាយទាំងពួង, រមែងប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ។...ល...។

តេន វុច្ចតិ – "សមត្តញ្ច បដិវិជ្ឈតី"តិ។

ព្រោះហេតុនោះ លោកពោលថា "រមែងចាក់ធ្លុះនូវអត្ថនៃការសូប" ។

ចតុក្ក:ទី ๑ លំដាប់ ទី ๓

សព្វកាយប្បដិសំវេទី

ចតុក្កទី ๑ លំដាប់ទី ๓ (អដ្ឋកថា)

[๑๗๐] សព្វកាយបដិសំវេទិនិទ្ទេសេ អរូបធម្មេសុ វេទនាយ ឱក្កាវិកត្តា សុខក្ខណាតំ បឋមំ ឥជ្ឈានិជ្ឈារម្មណសំវេទិកា វេទនា វុត្តា, តតោ យំ វេទេតិ, តំ សញ្ញាជានីតិ ឯវំ វេទនាវិសយស្ស អាការក្តា ហិកា សញ្ញា, តតោ សញ្ញាវសេន អភិសង្ខារិកា ចេតនា, តតោ "ផុដ្ឋោ វេទេតិ, ផុដ្ឋោ សញ្ញានាតិ, ផុដ្ឋោចេតេតី"តិ[๖๗] វចនតោ ផស្សោ, តតោ សព្វេសំ សាធារណលក្ខណោ មនសិការោ, ចេតនាធីហិ សង្ខារក្ខន្ធោ វុត្តោ។

នឹងវិនិច្ឆ័យក្នុងនិទ្ទេសនេះថា ភិក្ខុរមែងសិក្សាថា "អាត្មាអញនឹងកំណត់ដឹងនូវកាយទាំងអស់" ដូចតទៅ ព្រោះក្នុងបណ្តាអរូបធម៌ទាំងឡាយ វេទនាជាធម្មជាតិដែលគ្រោតគ្រាតទើបលោកពោលនូវវេទនាដែលជាតួសោយអារម្មណ៍ជាទីគួរជ្រាប្តា និងមិនគួរជ្រាប្តាមុន ដើម្បីកាន់យកបានដោយងាយ, តអំពីនោះ

---

๖๗ (*សំ. និ. ๔.๙๓*) ។

លោកទើបពោល នូវសញ្ញាដែលធ្វើឲ្យកាន់យកអាការៈនៃអារម្មណ៍របស់វេទនា យ៉ាងនេះថា រមែងសោយអារម្មណ៍បាន, ក៏រមែងចាំបាននូវអារម្មណ៍នោះ, តអំពីនោះ លោកទើបពោលនូវចេតនាដែលតាក់តែងដោយអំណាចសញ្ញា, តអំពីនោះ លោកទើបពោល ផស្សៈ ព្រោះមានព្រះបាលីសម្តែងថា "អ្នកមានសមួស្សហើយ រមែងសោយនូវអារម្មណ៍, អ្នកដែលមានសមួស្សសោយហើយ រមែងចាំបាន, អ្នកមានសមួស្សហើយ រមែងជាប់" ដូចនេះ, តអំពីនោះ លោកទើបពោលមនសិការៈ ដែលមានលក្ខណៈទាំងពួង បានដល់ធម៌ទាំងពួង លោកពោលសង្ខារខន្ធដោយពាក្យថា ចេតនា ជាដើម ។

ឯវំ តីសុ ខន្ធេសុ វុត្តេសុ តំនិស្សយោ វិញ្ញាណក្ខន្ធោ វុត្តោ ហោតិ។

កាលលោកពោលខន្ធទាំង ៣ យ៉ាងនេះហើយ ជាការដែលលោកពោលវិញ្ញាណខន្ធ ដែលជាទីអាស្រ័យរបស់ធម៌ទាំងនោះ តែម្យ៉ាង ។

"ជាមញ្ចា"តិ វុត្តប្បការំ ជាមញ្ចា។ "ជាមកាយោ ចា"តិ ឥទំ បន ជាមេន និព្វានស្សបិ សច្ឆិកតត្តា លោកុត្តរានញ្ច អវិបស្សនុបកតត្តា តំ អបនេតុំ វុត្តំ។

*ពាក្យថា "**ជាម**" បានដល់ នាមមានប្រការៈដូចបានពោលមកហើយ ។ ចំណែកពាក្យថា "**នាមកាយ**" លោកពោលដើម្បីនឹងនាំចេញទៅកាន់នាមនោះ ព្រោះសូម្បីព្រះនិព្វានលោកក៏សង្គ្រោះដោយនាម និងព្រោះលោកុត្តរទាំងឡាយមិនគួរដល់ការចម្រើនវិបស្សនា ។*

"កាយោ"តិ ហិ វចនេន និព្វានំ អបនីតំ ហោតិ និព្វានស្ស រាសិវិនិមុត្តត្តា។

*ក៏ដោយពាក្យថា "**កាយ**" រមែងជាការនាំនិព្វានចេញទៅ ព្រោះនិព្វានជា រាសីវិមុត្តិ។*

"**យេ ច វុច្ចន្តិ ចិត្តសង្ខារា**"តិ "សញ្ញា ច វេទនា ច ចេតសិកា ឯតេ ធម្មា ចិត្តបដិពទ្ធា ចិត្តសង្ខារា"តិ[๖๘] ឯវំ វុច្ចមានាបិ ចិត្តសង្ខារ ឥធ ជាមកាយេវេ សង្គហិតាតិ វុត្តំ ហោតិ។

បទថា "**យេ ច វុច្ចន្តិ ចិត្តសង្ខារា** *ប្រែថា* ***ដែលហៅថាចិត្តសង្ខារ*** *មានសេចក្តីថា* ***ចិត្តសង្ខារសូម្បីដែលលោកពោលហើយយ៉ាងនេះថា*** " "*សញ្ញា និងវេទនាដែលមានក្នុងចិត្ត, ធម៌ទាំងនេះ ជាប់ដោយចិត្តជាចិត្តសង្ខារ* " *លោកសង្គ្រោះដោយនាមកាយ នុ៎ះឯងក្នុងទីនេះ។*

"**មហាភូតា**"តិ មហន្តចាតុការតោ មហាភូតសាមញ្ញតោ មហាបរិហារតោ មហាវិការតោ មហន្តភូតត្តា ចាតិ មហាភូតា។

ពាក្យថា "**មហាភូត**" *មានន័យថា ឈ្មោះថា មហាភូត ដោយអត្ថថា ព្រោះជាការប្រាកដធំ ព្រោះមានភាពស្មើគ្នាដោយភូតយ៉ាងធំ ព្រោះមានការមើលថែរក្សាយ៉ាងធំ ព្រោះមានវិការៈយ៉ាងធំ និងព្រោះមានភាពជាធំ (ដែលមានប្រាកដ)។*

តេ បន – បឋវី អាចោ តេជោ វាយោតិ ចត្តារោ។

មហាភូតទាំងនោះមាន ๔ យ៉ាង គឺបឋវី១ អាបោ១ តេជោ១ វាយោ១។

"**ចតុន្នញ្ច មហាភូតានំ ឧបាទាយរូប**"ន្តិ ឧបយោគត្ថេ សាមិវចនំ, ចត្តារោ មហាភូតេ ឧបាទាយ និស្សាយ អមុញ្ចិត្វា បវត្តរូបន្តិ អត្ថោ។

បទថា "**ចតុន្នញ្ច មហាភូតានំ ឧបាទាយរូប** *ប្រែថា* ***រូបអាស្រ័យមហាភូតទាំង ๔*** " *ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ, សេចក្តីថា រូបដែលប្រព្រឹត្តទៅអាស្រ័យ គឺនៅជិតស្និតមិនចោលនូវមហាភូតទាំង ๔។*

តំ បន – ចក្ខុ សោតំ ឃានំ ជិវ្ហា កាយោ រូបំ សទ្ទោ គន្ធោ រសោ

---

๖๘ (បដិ. ម. ๑.๑๗๔; ម. និ. ๑.๔๖๓)។

ឥត្ថិន្ទ្រិយំ បុរិសិន្ទ្រិយំ ជីវិតិន្ទ្រិយំ ហាទយវត្ថុ ឱជា កាយវិញ្ញត្តិ វចីវិញ្ញត្តិ អាកាសធាតុ រូបស្ស លហុតា មុទុតា កម្មញ្ញតា ឧបចយោ សន្តតិ ជរតា អនិច្ចតាតិ ចតុវីសតិវិធំ។

ក៏ឧបាទាយរូបនោះមាន ២៤ យ៉ាង គឺ ចក្ខុ១ សោត១ ឃាន១ ជិវ្ហា១ កាយ១ រូប១ សំឡេង១ ក្លិន១ រស១ ឥត្ថិន្ទ្រិយ១ បុរិសិន្ទ្រិយ១ ជីវិតិន្ទ្រិយ១ ហទយវត្ថុ១ ឱជា១ កាយវិញ្ញត្តិ១ វចីវិញ្ញត្តិ១ អាកាសធាតុ១ លហុតារូប១ មុទុតារូប១ កម្មញ្ញតារូប១ ឧបចយរូប១ សន្តតិរូប១ ជរតារូប១ អនិច្ចតា រូប១ ។

"អស្សាសោ ច បស្សាសោ ចា"តិ ចាកតិកោយេវ។

*បទថា "**អស្សាសោ ច បស្សាសោ ច** ប្រែថា **ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ** បានដល់ ខ្យល់ជាប្រក្រតីនោះឯង ។*

អស្សាសបស្សាសេ និស្សាយ ឧប្បន្នំ បដិភាគនិមិត្តម្បិ តទេវ ចាមំ លភតិ បថវីកសិណាទីនិ វិយ។

សូម្បី ពន្ធឹបដិភាគនិមិត្ត ដែលអាស្រ័យខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ទើបកើតឡើង ក៏រមែងបានឈ្មោះថា ដូច្នោះដូចគ្នា ដូចកសិណ មានបឋវីកសិណជាដើម ។

រូបសរិក្ខកត្តា រូបន្តិ ច ចាមំ លភតិ "ពហិទ្ធា រូបានិ បស្សតី"តិ-អាទីសុ[៦៩] វិយ។

ក៏រមែងបានឈ្មោះថា រូប ព្រោះមានចំណែកដែលបុគ្គលគប្បីឃើញ ដោយរូប ដូចជាក្នុងពាក្យថា " រមែងឃើញរូបខាងក្រៅ" ដូច្នេះ ជាដើម ។

"និមិត្តញ្ច ឧបនិពន្ធា"តិ សតិឧបនិពន្ធាយ និមិត្តភូតំ អស្សាសបស្សាសានំ ផុសនដ្ឋានំ។

---

៦៩ (ធ. ស. ២០៤; ទី. និ. ៣.៣៣៨) ។

*ពាក្យថា "**និមិត្តចូលទៅតាមចង់ត្រៀក**" សេចក្តីថា ហានៈនៃការពាល់ត្រូវនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលជានិមិត្តនៃការចូលទៅចង់ដោយសតិ ។*

"**យេ ច វុចូន្តិ កាយសង្ខ្ហារា**"តិ "អស្សាសបស្សាសា កាយិកា ឯតេ ធម្មា កាយបដិពទ្ធា កាយសង្ខ្ហារា"តិ[៧០] ឯវំ វុចូមានាបិ កាយសង្ខ្ហារា ឥធ រូបកាយេនេវ សង្ហរិតាតិ វុត្តំ ហោតិ។

*ពាក្យថា "**លោកពោលថា កាយសង្ខ្ហារ**" មានអធិប្បាយថា កាយសង្ខ្ហារ សូម្បីដែលលោកនៅយ៉ាងនេះថា "ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ មានក្នុងកាយ ធម៌ទាំងនេះជាប់ដោយកាយ ឈ្មោះថា កាយសង្ខ្ហារ" លោកសង្ត្រោះចូលដោយរូបកាយនុ៉ះឯង ក្នុងទីនេះ។*

"**តេ កាយា បដិវិទិតា ហោន្តី**"តិ ឈានក្ខណេ អស្សាសបស្សាស-និមិត្តកាយា វិបស្សនាក្ខណេ អវសេសរូចារូបកាយា អារម្មណតោ បដិវិទិតា ហោន្តិ, មក្តក្ខណេ អសម្មោហតោ បដិវិទិតា ហោន្តិ ។

*ពាក្យថា "**កាយទាំងនោះរមែងប្រាកដ**" សេចក្តីថា កាយគឺនិមិត្តនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ រមែងប្រាកដក្នុងខណៈនៃឈានរូបកាយ និងអរូបកាយដ៏សេស រមែងប្រាកដក្នុងខណៈនៃវិបស្សនាដោយអារម្មណ៍, រមែងប្រាកដក្នុងខណៈនៃមគ្គដោយអសម្មោហៈ ។*

អស្សាសបស្សាសវសេន បដិលទ្ធជ្ឈានស្ស យោគិស្ស ឧប្បន្ន វិបស្សនាមត្តេបិ សន្ធាយ "**ទីឃំ អស្សាសបស្សាសវសេនា**"តិអាទិ វុត្តំ។

*ពាក្យថា "**ដោយអំណាចនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញវែង**" ជាដើម លោកពោលសំដៅដល់ សូម្បីវិបស្សនា និងមគ្គដែលកើតឡើងដល់ព្រះយោគី អ្នកដែលបានឈានហើយ ដោយអំណាចខ្យល់ដង្ហើមចូល និងខ្យល់*

---

៧០ (បដិ. ម. ១.១៧១; ម. និ. ១.៤៦៣) ។

ដង្ហើមចេញ ។

"អាវជ្ជតោ បជានតោ"តិអាទីនិ សីលកថាយំ វុត្តត្តា និ។

ពាក្យថា " **កាលនឹកវាំពីង** " ជាដើម មានអត្ថ ដែលលោកបានពោលទុកមកហើយ ក្នុងសីលកថា ។

តេ វុត្តប្បការេ កាយេ អន្តោករិត្វា "សព្ពកាយបដិសំវេទី"តិ វុត្តំ។

ពាក្យថា "ដឹងច្បាស់នូវចំណែកខ្យល់ទាំងពួង" លោកពោលការធ្វើកាយដែលមានប្រការៈបានពោលទុកមកហើយនោះ ទុកខាងក្នុង ។

"សព្ពកាយបដិសំវេទី អស្សាសបស្សាសានំ សំវរដ្ឋេនា"តិអាទីសុ **"សព្ពកាយប្បដិសំវេទី"**តិវុត្តអស្សាសបស្សាសតោ ឧប្បន្នឆ្សាន-វិបស្សនាមគ្គេសុ **សំវរោយេវ សីលវិសុទ្ធិ**។

ក្នុងពាក្យថា **"ដោយអត្ថថា ជាអ្នកដឹងច្បាស់នូវកាយទាំងពួង ប្រុងប្រយ័ត្ន នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ"** ជាដើម សេចក្តីថា ការប្រុងប្រយ័ត្ន ក្នុងឈាន វិបស្សនា និងមគ្គ ដែលកើតឡើងដោយខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលលោកបានពោលទុកថា "ជាអ្នកដឹងច្បាស់នូវកាយទាំងពួង" ដូច្នេះ នេះឯង ឈ្មោះថា **សីលវិសុទ្ធិ ដោយអត្ថថា ប្រុងប្រយ័ត្ន** ។

អវិក្ខេបោយេវ អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ។

ភាពមិនរាយមាយ នុ៎ះឯង ឈ្មោះថា **ចិត្តវិសុទ្ធិ ដោយអត្ថថា មិនរាយមាយ** ។

បញ្ញាយេវ ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធិ។

បញ្ញានុ៎ះឯង ឈ្មោះថា **ទិដ្ឋិវិសុទ្ធិ ដោយអត្ថថា ឃើញ** ។

ឈានវិបស្សនាសុ វិរតិអភាវេបិ ចាចាភាវមត្តមេវ **សំវរោ** នាមាតិ វេទិតព្ពំ។

*សូម្បីកាលក្នុងឈាន និងវិបស្សនានឹងមិនមានវិរតិ តែត្រឹមតែមិនមានបាបប៉ុណ្ណោះ ក៏គប្បីជ្រាបថា ឈ្មោះថា **សំវរ** ។*

បស្សម្ភយំ កាយសង្ខារំ

ចតុក្កធី ១ លំដាប់ធី ៤ (បិកដ ៧០) [១១៤]

[១៧១] កថំ "បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមី"តិ សិក្ខតិ, "បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមី"តិ សិក្ខតិ?

ភិក្ខុរមែងសិក្សាថា " អាត្មាអញនឹងធ្វើឲ្យរលត់បាត់នូវកាយសង្ខារ ខណៈដកដង្ហើមចូល", ភិក្ខុរមែងសិក្សាថា "អាត្មាអញនឹងធ្វើឲ្យរលត់បាត់នូវកាយសង្ខារ ខណៈដកដង្ហើមចេញ" តើដូចម្តេច?

កតមោ កាយសង្ខារោ?

ពាក្យថា កាយសង្ខារ តើដូចម្តេច?

១. ឧីឃំ អស្សាសា កាយិកា។ ឯតេ ធម្មា កាយបដិពទ្ធា កាយសង្ខារា។

ខ្យល់ដង្ហើមចូលវែង ដែលប្រព្រឹត្តទៅក្នុងកាយ ។ ធម៌ទាំងនេះជាប់ដោយកាយ ឈ្មោះថា កាយសង្ខារ ។

តេ កាយសង្ខារេ បស្សម្ភេន្តោ និរោធេន្តោ វូបសមេន្តោ សិក្ខតិ។

យោគីភិក្ខុរម្ចាប់ គឺរលត់សូប់ រលត់បាត់ នូវកាយសង្ខារទាំងនោះ ឈ្មោះថា រមែងសិក្សា។

២. **ឥឃំ បស្សាសោ កាយិកោ។ ឯតេ ធម្មា កាយបដិពទ្ធា កាយសង្ខារា។**

ខ្យល់ដង្ហើមចេញវែង ដែលប្រព្រឹត្តិទៅក្នុងកាយ ។ ធម៌ទាំងនេះជាប់ដោយកាយ ឈ្មោះថា កាយសង្ខារ ។

តេ កាយសង្ខារេ បស្សម្ភេន្តោ និរោធេន្តោ វូបសមេន្តោ សិក្ខតិ។

ព្រះយោគីកិក្ខុរម្ងាប់ គឺរលត់សូប្ប រលត់បាត់ នូវកាយសង្ខារទាំងនោះ ឈ្មោះថា រមែងសិក្សា ។

៣. **រស្សំ អស្សាសោ,**

ខ្យល់ដង្ហើមចូលខ្លី,

៤. **រស្សំ បស្សាសោ។**

ខ្យល់ដង្ហើមចេញខ្លី ។

៥. **សព្ពកាយបដិសំវេទី អស្សាសោ សព្ពកាយបដិសំវេទេ បស្សាសោ-កាយិកោ ។ ឯតេ ធម្មា កាយបដិពទ្ធា កាយសង្ខារា ។**

ខ្យល់ដង្ហើមចូល សម្រាប់បុគ្គលអ្នកកំណត់ដឹងនូវកាយសង្ខារទាំងពួង ខ្យល់ដង្ហើមចេញ សម្រាប់បុគ្គលអ្នកកំណត់ដឹងនូវកាយសង្ខារទាំងពួង ដែលប្រព្រឹត្តទៅក្នុងកាយ ។ ធម៌ទាំងនេះជាប់ដោយកាយ ឈ្មោះថា កាយសង្ខារ ។

តេ កាយសង្ខារេ បស្សម្ភេន្តោ និរោធេន្តោ វូបសមេន្តោ សិក្ខតិ។

យោគីកិក្ខុរម្ងាប់ គឺរលត់សូប្ប រលត់បាត់ នូវកាយសង្ខារទាំងនោះ ឈ្មោះថា រមែងសិក្សា។

១. **យថារូបេហិ កាយសង្ខារេហិ យា កាយស្ស អានមនា វិនមនា**

សន្ថមនា បណាមនា ឥញ្ជនា ផន្ទនា ចលនា បកម្បនា –

ការទម្រេតកាយ ការងាកកាយ ការទ្រេតកាយ ការឱនកាយ ការរញ្ជួយកាយ ការអន្ទះសាកាយ ការកម្រើកកាយ ការញាប់ញ័រកាយ នៃកាយណា ព្រោះកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា

បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ,

កិក្ខុសិក្សាថា អាត្មាអញ កាលរលត់បាត់នូវកាយសង្ខារ ខណៈដកដង្ហើមចូល,

បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ។

កិក្ខុសិក្សាថា អាត្មាអញ កាលរលត់បាត់នូវកាយសង្ខារ ខណៈដកដង្ហើមចេញ ។

๒. **យថារូបេហិ កាយសង្ខារេហិ យា កាយស្ស ន អានមនា ន វិនមនា ន សន្ថមនា ន បណាមនា អនិញ្ជនា អផន្ទនា អចលនា អកម្បនា,**

ការមិនទម្រេតកាយ ការមិនងាកកាយ ការមិនទ្រេតកាយ ការមិនឱនកាយ ការមិនរញ្ជួយកាយ ការមិនអន្ទះសាកាយ ការមិនកម្រើកកាយ ការមិនញាប់ញ័រកាយ នៃកាយណា ព្រោះកាយសង្ខារទាំងឡាយ មានសភាពយ៉ាងណា,

សន្តំ សុខុមំ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ, បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ។

កិក្ខុសិក្សាថា អាត្មាអញនឹងធ្វើកាយសង្ខារដែលស្ងប់ល្អិតសុខុម មានសភាពយ៉ាងនោះ ឲ្យរលត់បាត់ ខណៈដកដង្ហើមចូល, កិក្ខុសិក្សាថា អាត្មាអញនឹងធ្វើកាយសង្ខារដែលស្ងប់ល្អិតសុខុម មានសភាពយ៉ាងនោះ ឲ្យរលត់បាត់ ខណៈដកដង្ហើមចេញ ។

ឥតិ កិរ "បស្សម្ភយំ កាយសង្ខ្ហារំ អស្សសិស្សាមី"តិ សិក្ខតិ, "បស្សម្ភយំ កាយសង្ខ្ហារំ បស្សសិស្សាមី"តិ សិក្ខតិ។

បានព្ទថា បុគ្គលសិក្សាថា "អាត្មាអញកាលរលត់បាត់នូវកាយសង្ខារ ខណៈដកដង្ហើមចូល", "អាត្មាអញកាលរលត់បាត់នូវកាយសង្ខារ ខណៈដកដង្ហើមចេញ" ដោយប្រការៈដូច្នេះ ។

ឯវំ សន្តេ វាតូបលទ្ធិយា ច បភាវនា ន ហោតិ។

កាលបើយ៉ាងនេះ ការប្រាកដនៃការបាននូវខ្យល់ មិនទាន់មាន ។

១. អស្សាសបស្សាសានញ្ច បភាវនា ន ហោតិ,

ការប្រាកដ នៃដង្ហើមចូល និងដង្ហើមចេញ ក៏មិនទាន់មាន,

២. អានាចានស្សតិយា ច បភាវនា ន ហោតិ,

ការប្រាកដ នៃអានាបានស្សតិ ក៏មិនទាន់មាន,

៣. អានាចានស្សតិសមាធិស្ស ច បភាវនា ន ហោតិ;

ទាំងការប្រាកដ នៃអានាបានស្សតិសមាធិ ក៏មិនទាន់មាន,

៤. ន ច នំ តំ សមាបត្តឹ បណ្ឌិតា សមាបជ្ជន្តិបិ វុដ្ឋហន្តិបិ ។

បណ្ឌិតទាំងឡាយ រមែងមិនចូលកាន់សមាបត្តិនោះផង និងមិនចេញ ចាកសមាបត្តិនោះផង ។

ការដឹងខ្យល់ឡើងចិញ

ឥតិ កិរ "បស្សម្ភយំ កាយសង្ខ្ហារំ អស្សសិស្សាមី"តិ សិក្ខតិ, "បស្សម្ភយំ កាយសង្ខ្ហារំ បស្សសិស្សាមី"តិ សិក្ខតិ។

បានព្ទថា បុគ្គលសិក្សាថា "អាត្មាអញកាលរលត់បាត់នូវកាយសង្ខារ ខណៈដកដង្ហើមចូល ", "អាត្មាអញកាលរលត់បាត់នូវកាយសង្ខារ ខណៈ

ដកដង្ហើមចេញ" ដោយប្រការៈដូច្នេះ ។

ឯវំ សន្តេ ឯតូបលទ្ធិយា ច បការោ ហោតិ។

កាលបើយ៉ាងនេះ ការប្រាកដនៃការបាននូវខ្យល់ ក៏មាន ។

๑. **អស្សាសបស្សាសានញ្ច បការោ ហោតិ,**

ការប្រាកដ នៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ក៏មាន,

๒. **អានាបានស្សតិយា ច បការោ ហោតិ,**

ការប្រាកដ នៃអានាបានស្សតិ ក៏មាន,

๓. **អានាបានស្សតិសមាធិស្ស ច បការោ ហោតិ;**

ការប្រាកដ នៃអានាបានស្សតិសមាធិ ក៏មាន,

๔. **តញ្ច ំ សមាបត្តឹ បណ្ឌិតា សមាបជ្ជន្តិបិ វុដ្ឋហន្តិបិ។**

ទើបបណ្ឌិតទាំងឡាយ ចូលកាន់សមាបត្តិនោះផង និងចេញចាក សមាបត្តិនោះផង ។

ការឧបមា

យថា កថំ វិយ?

ឧបមាដំណើរនោះប្រៀបដូចម្តេច?

๑. **សេយ្យថាបិ កំសេ អាកោដិតេ បឋមំ ឱឌ្ឌារិកា សទ្ទា បវត្តន្តិ។**

ប្រៀបដូចជា ជួងសំរឹទ្ធិដែលគេគោះ សំឡេងគ្រោតគ្រាត រមែងប្រព្រឹត្ត ទៅជាលើកដំបូង ។

๒. **ឱឌ្ឌារិកានំ សទ្ទានំ និមិត្តំ សុត្តហិតត្តា សុមនសិកតត្តា សុបធារិតត្តា ។**

ព្រោះបុគ្គលកាន់យកបានល្អ ព្រោះធ្វើទុកក្នុងចិត្តបានល្អ ព្រោះចាំទុកបានល្អ នូវនិមិត្តនៃសំឡេងដ៏គ្រោតគ្រាត(គឺសំឡេងឮខ្លាំងនោះ) ។

៣. និរុទ្ធេបិ ឱឡារិកេ សទ្ទេ។

កាលបើសំឡេងគ្រោតគ្រាតរលត់បាត់ទៅហើយ(ចិត្តក៏រមែងប្រព្រឹត្តិទៅបាន ព្រោះសភាវៈដែលមាននិមិត្តនៃសំឡេងគ្រោតគ្រាតនោះមកជាអារម្មណ៍)។

៤. អថ បច្ឆា សុខុមកា សទ្ធា បវត្តន្តិ។

បន្ទាប់មក សំឡេងដ៏ល្អិតសុខុម រមែងប្រព្រឹត្តិទៅជាខាងក្រោយ ។

៥. សុខុមកានំ សទ្ធានំ និមិត្តំ សុគ្គហិតត្តា សុមនសិកតត្តា សុបធារិតត្តា

ព្រោះបុគ្គលកាន់យកបានល្អ ព្រោះធ្វើទុកក្នុងចិត្តបានល្អ ព្រោះចាំទុកបានល្អនូវនិមិត្តនៃសំឡេងដ៏ល្អិតសុខុម

៦. និរុទ្ធេបិ សុខុមកេ សទ្ធេ,

កាលសំឡេងដ៏ល្អិតសុខុមរលត់បាត់ទៅហើយ

៧. អថ បច្ឆា សុខុមសទ្ធនិមិត្តារម្មណតាបិ ចិត្តំ បវត្តតិ។

បន្ទាប់មកទៀត ចិត្តក៏រមែងប្រព្រឹត្តិទៅជាខាងក្រោយ ព្រោះចិត្តមានសំឡេងនិមិត្តដ៏ល្អិតសុខុមនោះ មកជាអារម្មណ៍ (ការឧបមាយ៉ាងណាមិញ រឯការឧបមេយ្យក៏ដូចគ្នា) ។

ការឧបមេយ្យ

១. ឯវមេវំ បឋមំ ឱឡារិកា អស្សាសបស្សាសា បវត្តន្តិ,

មានការឧបមេយ្យ ដូចជាខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏

គ្រោតគ្រាត រមែងប្រព្រឹត្តទៅជាលើកដំបូង,

២. ឱឧ្បារិកានំ អស្សាសបស្សាសានំ និមិត្តំ សុក្តហិតត្តា សុមនសិ-កតត្តា សូបឥារិតត្តា ។

ព្រោះព្រះយោគីបានកាន់យកបានល្អ នូវនិមិត្តនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏គ្រោតគ្រាត ព្រោះធ្វើទុកក្នុងចិត្តបានល្អ ព្រោះចាំទុកបានល្អ ។

៣. និរុទ្ធេបិ ឱឧ្បារិកេ អស្សាសបស្សាសេ,

កាលបើខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏គ្រោតគ្រាតបានរលត់បាត់ទៅហើយ (ចិត្តក៏មិនរាយមាយ ព្រោះសភាវៈដែលមាននិមិត្តនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ មកធ្វើជាអារម្មណ៍),

៤. អថ បច្ឆា សុខុមកា អស្សាសបស្សាសា បវត្តន្តិ។

បន្ទាប់មក ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏ល្អិតសុខុម រមែងប្រព្រឹត្តិទៅជាខាងក្រោយ ។

៥. សុខុមកានំ អស្សាសបស្សាសានំ និមិត្តំ សុក្តហិតត្តា សុមនសិ-កតត្តា សូបឥារិតត្តា

ព្រោះបុគ្គលបានកាន់យកល្អ ព្រោះធ្វើទុកក្នុងចិត្តបានល្អ ព្រោះចាំទុកបានល្អ នូវនិមិត្តនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញដ៏ល្អិតសុខុម

៦. និរុទ្ធេបិ សុខុមកេ អស្សាសបស្សាសេ,

កាលបើខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏ល្អិតសុខុមនោះ បានរលត់បាត់ទៅហើយ,

៧. អថ បច្ឆា សុខុមកអស្សាសបស្សាសានំ និមិត្តារម្មណតាបិ ចិត្តំ ន រិក្ខេបំ កច្ឆតិ។

បន្ទាប់មកទៀត ចិត្តក៏មិនដល់នូវសេចក្តីរាយមាយ(គឺសតិតាំងមាំ) ក្នុងកាលជាខាងក្រោយមក ព្រោះចិត្តបានកាន់យកនូវនិមិត្តនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដ៏ល្អិតសុខុមនោះមកធ្វើជាអារម្មណ៍ ។

ខ្យល់បានប្រាកដមកវិញ

ឯវំ សន្តេ វាតូបលទ្ធិយា ច បភាវនា ហោតិ,

ក៏យ៉ាងនោះដែរ កាលបើយ៉ាងនេះ ការប្រាកដនៃការបាននូវខ្យល់ ក៏កើតមានឡើង,

អស្សាសបស្សាសានញ្ច បភាវនា ហោតិ,

ការប្រាកដ នៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ក៏មាន,

អានាចានស្សតិយា ច បភាវនា ហោតិ,

ការប្រាកដ នៃខ្យល់អានាបានស្សតិ ក៏មាន,

អានាចានស្សតិសមាធិស្ស ច បភាវនា ហោតិ;

ការប្រាកដ នៃអានាបានស្សតិសមាធិ ក៏មាន,

តញ្ច នំ សមាបត្តឹ បណ្ឌិតា សមាបជ្ជន្តិបិ វុដ្ឋហន្តិបិ ។

បណ្ឌិតទាំងឡាយ រមែងចូលកាន់សមាបត្តិនោះផង រមែងចេញចាកសមាបត្តិនោះផង ។

បស្សម្ភយំ កាយសង្ខារំ អស្សាសបស្សាសា កាយោ,

ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ របស់យោគីភិក្ខុកាលរលត់បាត់នូវកាយសង្ខារ ឈ្មោះថា ជាកាយ,

ឧបដ្ឋានំ សតិ, អនុបស្សនា ញាណំ។

ភាពជ្រាកដ ឈ្មោះថា សតិ ឬសភាវៈដែលចូលទៅកាន់អារម្មណ៍ ហើយតាំងនៅបាន ឈ្មោះថា សតិ, ការតាមពិចារណាឃើញរឿយៗ ឈ្មោះថា ញាណ ។

កាយោ ឧបដ្ឋានំ, នោ សតិ; សតិ ឧបដ្ឋានញ្ចេវ សតិ ច។

កាយ ជាតួជ្រាកដនៃអារម្មណ៍, មិនឈ្មោះថា ជាសតិទេ, ចំណែកខាងសតិ ជាតួជ្រាកដនៃអារម្មណ៍ផង និងជាតួសតិផង ។

តាយ សតិយា តេន ញាណេន តំ កាយំ អនុបស្សតិ។

បុគ្គលរមែងពិចារណាឃើញរឿយៗនូវកាយនោះ ដោយសតិនោះ ដោយញាណនោះ ។

តេន វុច្ចតិ – "កាយេ កាយានុបស្សនាសតិប្បដ្ឋានភាវនា"តិ។

*ព្រោះហេតុនោះ លោកពោលថា "**កាយេ កាយានុបស្សនា សតិប្ប-ដ្ឋានភាវនា** ប្រែថា ការចម្រើនសតិប្បដ្ឋានភាវនា គឺការពិចារណាឃើញរឿយៗនូវកាយក្នុងកាយ" ដោយប្រការៈដូច្នេះ ។*

"អនុបស្សតី"តិ កថំ តំ កាយំ អនុបស្សតិ។...បេ...។ ឯវំ តំ កាយំ អនុបស្សតិ ។

*សំនួរត្រង់ពាក្យថា "**ពិចារណាឃើញរឿយៗ**" តើយោគីកិក្ខុពិចារណាឃើញរឿយៗនូវកាយនោះ ដូចម្តេច ? ។ ល។ យោគីកិក្ខុពិចារណាឃើញរឿយៗនូវកាយនេះ យ៉ាងនេះឯង។*

"ភាវនា"តិ ចតស្សោ ភាវនា។...បេ...។ អាសេវនដ្ឋេន ភាវនា។

ពាក្យថា "ភាវនា" បានដល់ភាវនា ៤ យ៉ាង ។...ល...។ ឈ្មោះថា ភាវនា ដោយអត្ថថា ប្រព្រឹត្ត ។

បស្សម្ភយំ កាយសង្ខារំ, អស្សាសបស្សាសានំ សំវរដ្ឋេន សីលវិសុទ្ធិ,

ការដកដង្ហើមចូល និងដកដង្ហើមចេញរបស់បុគ្គល កាលរលត់បាត់នូវកាយសង្ខារ ឈ្មោះថា **សីលវិសុទ្ធិ** *ដោយអត្ថថាសង្រួម ,*

អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ, ឧស្សដ្ឋេន ទិដ្ឋិវិសុទ្ធិ។

ឈ្មោះថា **ចិត្តវិសុទ្ធិ** *ដោយអត្ថថា មិនរាយមាយ, ឈ្មោះថា* **ទិដ្ឋិវិសុទ្ធិ** *ដោយអត្ថថា ឃើញ ។*

យោ តត្ត សំវរដ្ឋោ, អយំ អធិសីលសិក្ខា;

បណ្តាធម៌ទាំងនោះ ធម៌ណា មានអត្ថថា សង្រួម, ធម៌នេះ ឈ្មោះថា អធិសីលសិក្ខា,

យោ តត្ត អវិក្ខេបដ្ឋោ, អយំ អធិចិត្តសិក្ខា;

បណ្តាធម៌ទាំងនោះ ធម៌ណា មានអត្ថថា មិនរាយមាយ, ធម៌នេះ ឈ្មោះថា អធិចិត្តសិក្ខា,

យោ តត្ត ឧស្សដ្ឋោ អយំ អធិបញ្ញាសិក្ខា។

បណ្តាធម៌ទាំងនោះ ធម៌ណា មានអត្ថថា ឃើញ, ធម៌នេះ ឈ្មោះថា អធិប្បញ្ញាសិក្ខា,

ឥមា តិស្សោ សិក្ខាយោ អាវជ្ជន្តោ សិក្ខតិ។...បេ...។

យោគីកិក្ខុកាលរំពឹង ឃើញនូវសិក្ខាទាំង ៣ យ៉ាងនេះ ឈ្មោះថា រមែងសិក្សា ។ល។

សច្ចិកាតព្ពំ សច្ចិករោន្តោ សិក្ខតិ,

កិក្ខុកាលធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា សិក្សា,

បស្សម្ភយំ កាយសង្ខារំ អស្សាសបស្សាសវសេន ចិត្តស្ស

ឯកគ្គតំ អវិក្ខេបំ បជានតោ វិនិតា វេទនា ឧប្បជ្ជន្តិ។...បេ...។

កាលភិក្ខុដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញរបស់អ្នក កាលរលត់បាត់នូវកាយសង្ខារ វេទនាទាំងឡាយ ដែលប្រាកដរមែងកើតឡើង។...ល...។

បស្សម្ភយំ កាយសង្ខារំ អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ឥន្ទ្រិយានិ សមោធានេតិ។...បេ...។

កាលភិក្ខុដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញរបស់អ្នក កាលរលត់បាត់នូវកាយសង្ខារ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ។...ល...។

តេន វុច្ចតិ – "សមត្តញ្ច បដិវិជ្ឈតី"តិ។

ព្រោះហេតុនោះ លោកពោលថា "ចាក់ធ្លុះនូវអត្ថនៃការស្ងប់"

អដ្ឋ អនុបស្សនាញាណានិ, អដ្ឋ ច ឧបដ្ឋានានុស្សតិយោ, ចត្តារិ សុត្តន្តិកវត្ថូនិ កាយេ កាយានុបស្សនាយ។

អនុបស្សនាញាណ (ញាណ តាមពិចារណាឃើញរឿយៗមាន ៨ យ៉ាង), **ឧបដ្ឋានានុស្សតិ** (អនុស្សតិដែលប្រើក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ឲ្យប្រាកដមាន ៨ ប្រភេទ, **សុត្តន្តិកវត្ថុ** (វត្ថុ គឺជារឿងដែលមានក្នុងព្រះសូត្រ) ៤ ក្នុងការពិចារណាក្នុងកាយ ។

ភាណវារោ។

វារៈនៃការសូត្រ ក្នុងចតុក្កៈទី ១ចប់

បស្សម្ភយំ កាយសង្ខារំ

ចតុក្កទី១ ឈំជាប់ទី ៤ (អដ្ឋកថា)

[១៧១] "**បស្សម្ភយ**"ន្តិអាទីនំ និទ្ទេសេ "**កាយិកា**"តិ រូបកាយេ កវា។

*នឹងវិនិច្ឆ័យក្នុងនិទ្ទេសនៃពាក្យថា "**រលត់បាត់**" ជាដើមតទៅ ពាក្យថា "**ប្រព្រឹត្តិទៅតាមផ្លូវកាយ**" គឺមាននៅក្នុងរូបកាយ ។*

"**កាយបដិពទ្ធា**"តិ កាយំ បដិពទ្ធា កាយំ និស្សិតា, កាយេ សតិ ហោន្តិ, អសតិ ន ហោន្តិ, តស្មាយេវ តេ កាយេន សង្ខរីយន្តីតិ **កាយសង្ខារា**។

*ពាក្យថា "**ជាប់ដោយកាយ**" គឺជាប់ចំពោះកាយអាស្រ័យកាយ, កាលកាយមាន ធម៌ គឺខ្យល់ដង្ហើមទាំងនេះទើបមាន, កាលកាយមិនមាន ក៏មិនមានដូចគ្នា, ព្រោះហេតុនោះឯង ធម៌គឺខ្យល់ដង្ហើមទាំងនោះ ទើបឈ្មោះថា **កាយសង្ខារ** ដោយអត្ថថា ដែលកាយតាក់តែង ។*

"**បស្សម្ភេន្តោ**"តិ និព្ពាបេន្តោ សន្និសីទាបេន្តោ។ បស្សម្ភនវចនេនេវ ឱឌ្ឍារិកានំ បស្សម្ភនំ សិទ្ធំ ។

*ពាក្យថា "**រលត់បាត់**" សេចក្តីថា បុគ្គលកាលធ្វើឲ្យរលត់ កាលធ្វើឲ្យស្ងប់ ។ កាលរម្ងាប់ខ្យល់ដង្ហើមគ្រោតគ្រាត សម្រេចហើយ ដោយពាក្យថា រលត់បាត់នោះឯង ។*

"**និរោធេន្តោ**"តិ ឱឌ្ឍារិកានំ អនុប្បាទនេន និរោធេន្តោ។

*ពាក្យថា "**រលត់**" គឺរលត់ដោយការធ្វើខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញដែលគ្រោតគ្រាតមិនឲ្យកើតឡើងបាន ។*

"វូបសមេន្តោ"តិ ឱឍ្បារិកេយេវ ឯកសន្តតិបរិណាមនយេន សន្តការំ ឧយន្តោ។

*ពាក្យថា "**ចូលទៅស្ងប់រម្ងាប់**" គឺនាំទៅកាន់ភាពស្ងប់ដោយការញ៉ាំងខ្យល់ដង្ហើមគ្រោតគ្រាតនុ៎ះឯង ឲ្យបង្ហើនទៅកាន់សន្តតិជាមួយគ្នា។*

"សិក្ខតី"តិ អធិការវសេន អស្សសិស្សាមីតិ សិក្ខតីតិ សម្ពន្ធោ, តិស្សោ សិក្ខា សិក្ខតីតិ វា អត្ថោ។

*ពាក្យថា "**រមែងសិក្សា**" ភ្ជាប់សេចក្តីថា រមែងសិក្សាថា អាត្មាអញ និងដកដង្ហើមចូល ដោយអំណាចនៃអធិការ (គឺការធ្វើឲ្យក្រៃលែង), ន័យម្យ៉ាងទៀត បានសេចក្តីថា រមែងសិក្សានូវសិក្ខាទាំង ៣ ដូចនេះ។*

ឥទានិ ឱឍ្បារិកបស្សម្ភនំ ឧស្សេតុំ "យថារូបេហី"តិអាទិមាហ។

*ឥឡូវនេះ លោកប្រាថ្នានឹងសម្តែង នូវការរលត់បាត់ខ្យល់ដង្ហើមដែលគ្រោតគ្រាត ទើបពោលពាក្យថា "**ព្រោះកាយសង្ខារ យ៉ាងណា**" ដូចនេះ ជាដើម។*

តត្ថ "យថារូបេហី"តិ យាទិសេហិ។

*ក្នុងពាក្យនោះ ពាក្យថា "**ព្រោះកាយសង្ខារ យ៉ាងណា**" បានដល់ ព្រោះកាយសង្ខារ បែបណា។*

"អានមតា"តិ បច្ឆតោ ឧមតា។

*បទថា "**អានមតា** ប្រែថា **ការទម្រេតកាយ**" បានដល់ ការបង្ហើនកាយទៅខាងក្រោយ។*

"វិនមតា"តិ ឧភយបស្សតោ ឧមតា។

*បទថា "**វិនមតា** ប្រែថា **ការងាក**" បានដល់ ការបង្ហើនទៅទាំងសងខាង។*

"សន្នមតា"តិ សព្វតោបិ ឧមន្តស្ស សុដ្ឋុ ឧមតា។

*បទថា "**សន្ថម្ភនា** ប្រែថា **ទ្រេតកាយ**" បានដល់ ការបង្ហោនទៅដោយល្អ នៃភិក្ខុជាអ្នកបង្ហោនទៅសូម្បីគ្រប់ៗទិស ។*

"បណាមនា"តិ បុរតោ នមនា។

*បទថា "**ការឱនកាយ**" បានដល់ ការបង្ហោនកាយទៅខាងមុខ ។*

"ឥញ្ជនា"តិ កម្បនា។

*បទថា "**ការរញ្ជយកាយ**" បានដល់ ការញាប់ញ័រ ។*

"ផន្ទនា"តិ ឆ្វាសកំ ចលនា។

*បទថា "**ការអន្ទុះសា**" បានដល់ ការកម្រើកបន្តិចបន្តួច ។*

"បកម្បនា"តិ កុសំ កម្បនា។

*បទថា "**ការញាប់ញ័រ**" បានដល់ ការញាប់ញ័រយ៉ាងក្រៃលែង ។*

យថារូបេហិ កាយសង្ខារេហិ កាយស្ស អានមនា។...បេ...។ បកម្បនា,

គប្បីធ្វើការភ្ជាប់សេចក្តីថា ការបង្ហោនទៅ។...ល...។ ការគ្រលែងនៃកាយ ព្រោះកាយសង្ខារ យ៉ាងណា,

តថារូបំ កាយសង្ខារំ បស្សម្ភយន្តិ ច, យា កាយស្ស អានមនា។...បេ...។ បកម្បនា, តញ្ច បស្សម្ភយន្តិ ច សម្ពន្ធោ កាតព្ពោ។

ការរលត់បាត់នូវកាយសង្ខារ យ៉ាងនោះ, និងថា ការបង្ហោនទៅ។...ល...។ ការគ្រលែងនៃកាយ យ៉ាងណា, ការរលត់បាត់នូវការបង្ហោនទៅ នូវការគ្រលែងទៅ យ៉ាងនោះ ដូចនេះ ។

កាយសង្ខារេសុ ហិ បស្សម្ភិតេសុ កាយស្ស អានមនាទយោ ច បស្សម្ភិតាយេវ ហោន្តីតិ។

ពិតមែន កាលរលត់បាត់កាយសង្ខារបានហើយ ការបង្អោនទៅជាដើមនៃកាយ រមែងជាការដែលរលត់បាត់ហើយតែម្តង ។

យថារូបេហិ កាយសង្ខារេហិ កាយស្ស ន អានមនាឝិកា ហោតិ, តថារូបំ សន្តំ សុខុមម្បិ កាយសង្ខារំ បស្សម្ភយន្តិ ច, យា កាយស្ស ន អានមនាឝិកា, តញ្ច សន្តំ សុខុមំ បស្សម្ភយន្តិ ច សម្ពន្ធតោ វេឝិតព្ពំ។

គប្បីជ្រាបដោយការភ្ជាប់សេចក្តីថា អាការៈដែលមានការផ្សៀងទៅជាដើមនៃកាយ រមែងមិនជ្រាកដ ដោយកាយសង្ខារ យ៉ាងណា, ការរលត់បាត់នូវកាយសង្ខារសូម្បីដែលស្ងប់សុខុម ក៏យ៉ាងនោះ, និងថា អាការៈដែលមានផ្សៀងទៅជាដើម នៃកាយ យ៉ាងណារមែងមិនជ្រាកដ, ការរលត់បាត់នូវអាការៈដែលស្ងប់សុខុម ក៏យ៉ាងនោះ ។

"សន្តំ សុខុម"ន្តិ ច ការនបុំសកវចនមេតំ។

*ពាក្យថា "**សន្តំ** ប្រែថា ស្ងប់ **សុខុមំ** ប្រែថា សុខុម នេះជាពាក្យការនបុំសកលិង្គ ។*

"ឥតិ កិរា"តិ ឯត្ថ ឥតិ ឯវមត្ថេ, កិរ យឝិអត្ថេ។

*ទាំង ២ បទថា **ឥតិ** និង **កិរ** នេះ **ឥតិ** ចុះក្នុងអត្ថថា **ឯវំ** ដែលប្រែថា យ៉ាងនេះ, **កិរ** ចុះក្នុងអត្ថថា **យឝិ** ដែលប្រែថា ប្រសិនបើថា ។*

យឝិ ឯវំ សុខុមកេបិ អស្សាសបស្សាសេ បស្សម្ភយំ អស្សសិ-ស្សាមិ បស្សសិស្សាមីតិ សិក្ខតីតិ ចោឝកេន ចោឝនា អារទ្ធា ហោតិ។

អាចារ្យជាអ្នកសួរ ផ្តើមសួរថា ប្រសិនបើកាលយ៉ាងនេះ យោគីភិក្ខុ រមែងសិក្សាថា អាត្មាអញនឹងរលត់បាត់នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ សូម្បីដែលល្អិតសុខុមដកដង្ហើមចូល និងដកដង្ហើមចេញ ។

អថ វា "**កិរ**"តិ ចោទកវចនត្តា អសទ្ធហានត្តេ អសហានត្តេ បវេក្ខត្តេ ច យុជ្ជតិយេវ, ឯវំ សុខុមានម្បិ បស្សម្ភនំ សិក្ខតីតិ ន សទ្ធហាមិ ន សហាមិ អបច្ចក្ខំ មេតិ វុត្តំ ហោតិ។

*នយម្យ៉ាងទៀត សព្ទថា "**កិរ**" លោកប្រកបក្នុងអត្ថថា មិនជឿ និងក្នុងអត្ថថា ផុតវិស័យ ព្រោះជាពាក្យរបស់លោកអាចារ្យជាអ្នកសួរនោះឯង, អធិប្បាយថា ខ្ញុំម្ចាស់មិនជឿថា យោគីកិក្ខុ នឹងសិក្សានូវការរលត់បាត់ សូម្បីខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលល្អិតសុខុមយ៉ាងនេះ ព្រោះនៅមិនទាន់បានប្រចក្សច្បាស់មកដល់រូបខ្ញុំម្ចាស់។*

"**ឯវំ សន្តេ**"តិ ឯវំ សុខុមានំ បស្សម្ភនេ សន្តេ។

*បទថា "**ឯវំ សន្តេ** សេចក្តីថា ក្នុងកាលភាពរលត់បាត់នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលល្អិតសុខុមយ៉ាងនេះ ។*

"**ភវូបលទ្ធិយា ច បភាវនា ន ហោតី**"តិ អស្សាសបស្សាសភាវស្ស ឧបលទ្ធិយា ។

*ច្រើនបទថា "**ភវូបលទ្ធិយា ច បភាវនា ន ហោតិ** សេចក្តីថា **ការចូលទៅបាននូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ** " ។*

"**ឧបលទ្ធី**"តិ វិញ្ញាណំ។ អស្សាសបស្សាសភាវំ ឧបលព្ភមានស្ស តជារម្មណស្ស ភាវនាវិញ្ញាណស្ស បភាវនា ឧប្បាទនា ន ហោតិ, តស្ស អារម្មណស្ស ភាវនា ន ហោតីតិ អត្ថោ។

*ពាក្យថា "**ឧបលទ្ធិ** " បានដល់ វិញ្ញាណ ។ សេចក្តីថា ការធ្វើឲ្យមានមុន គឺធ្វើឲ្យកើតឡើងនូវវិញ្ញាណ គឺការចម្រើននូវអារម្មណ៍នោះ ដែលចូលទៅបាននូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញមិនមាន ។*

"**អស្សាសបស្សាសានញ្ច បភាវនា ន ហោតី**"តិ ភាវនាយ

សុខុមកាយម្បិ អស្សាសបស្សាសំ និកេតនតោ តេសញ្ច ឧប្បាទនា បវត្តនា ន ហោតីតិ អត្ថោ ។

*ច្រើនបទថា "**អស្សាសបស្សាសានញ្ច បការនា ន ហោតិ**" សេចក្តីថា ការញុំាងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងនោះឲ្យកើតឡើង គឺឲ្យប្រព្រឹត្តទៅ រមែងមាន ព្រោះខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលល្អិតសុខុមរលត់បាត់ទៅហើយដោយការភាវនា ។*

"**អានាចានស្សតិយា ច បការនា ន ហោតី**"តិ អស្សាសបស្សាសា ភាវតោយេវ តជារម្មណាយ ភាវនាវិញ្ញាណសម្បយុត្តាយ សតិយា ច បវត្តនា ន ហោតិ។

*ច្រើនបទថា "**អានាចានស្សតិយា ច បការនា ន ហោតិ**" សេចក្តីថា ក៏សតិដែលសម្បយុត្តជាមួយវិញ្ញាណ គឺភាវនាដែលមានខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនោះជាអារម្មណ៍ រមែងមិនប្រព្រឹត្តិទៅ ព្រោះមិនមានខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ នុ៎ះឯង ។*

តស្មាយេវ តំសម្បយុត្តស្ស អានាចានស្សតិសមាធិស្ស ច ភាវនា ន ហោតិ។

ព្រោះហេតុនោះឯង ទើបមិនឈ្មោះថា ជាការចម្រើនអានាបានស្សតិសមាធិ ដែលសម្បយុត្តដោយវិញ្ញាណ គឺការភាវនានោះ ។

"**ន ច នំ ត**"ន្តិ ឯត្ថ "**ច ន**"ន្តិ និបាតមត្តំ "**កិក្ខុ ច ន**"ន្តិអាទីសុ[๗๑] វិយ។

*ពាក្យថា "**ច នំ**" ក្នុងពាក្យថា "**ន ច នំ តំ**" នេះត្រឹមជានិបាត ដូចជាក្នុងពាក្យថា "**កិក្ខុ ច នំ**" ជាដើម ។*

តំ វុត្តវិធឹ សមាបត្តឹ បណ្ឌិតា ន សមាបជ្ជន្តិបិ តតោ ន វុដ្ឋហន្តិបីតិ

๗๑ (បារា. ๒๗๓) ។

សម្ពន្ធោ។

ភ្ជាប់សេចក្តីថា បណ្ឌិតទាំងឡាយ ទាំងនៅមិនទាន់ចូលសមាធិ តាមវិធីដែលបានពោលមកហើយនោះ ទាំងមិនចេញចាកសមាបត្តិនោះ។

ចោទនាបក្ខស្ស បរិហារវចនេ "**ឥតិ កិរា**"តិ ឯវមេវ។ ឯត្ថ ឯវការត្ថេ កិរសទ្ទោ ទដ្ឋព្ពោ។ "**ឯវំ សន្តេ**"តិ ឯវំ បស្សម្ភនេ សន្តេ ឯវ។

*នឹងវិនិច្ឆ័យ ក្នុងពាក្យធ្វើយផ្នែកខាងសំនួរតទៅ ពាក្យថា **ឥតិ កិរ** ស្មើនឹងពាក្យថា **ឯវមេវ**។ ក្នុងពាក្យថា **ឥតិ កិរ** នេះ គប្បីឃើញ **កិរ** សព្ទចុះក្នុងអត្ថស្មើនឹងពាក្យថា **ឯវ** សព្ទ។ បទថា "**ឯវំ សន្តេ**" សេចក្តីថា ក្នុងកាលរលត់បាត់យ៉ាងនេះ ប៉ុណ្ណោះ។*

"**យថា កថំ វិយា**"តិ យថា តំ វុត្តវិធានំ ហោតិ, តថា តំ កថំ វិយាតិ ឧបមំ បុច្ឆតិ។ ឥទានិ "**សេយ្យថាបី**"តិ តំ ឧបមំ ទស្សេតិ។

*ដោយបទថា "**យថា កថំ វិយ** លោកសួរជាពាក្យឧបមាថា តាមវិធីដែលលោកពោលមកហើយនោះ តើប្រៀបដូចជាអ្វី? ឥឡូវនេះលោកសម្តែងនូវការឧបមានោះដោយពាក្យថា **សេយ្យថាបិ** ប្រែថា **ស្អុមប្រីយ៉ាងនោះ**។*

"**កំសេ**"តិ កំសមយភាជនេ។ "**និមិត្ត**"ន្តិ តេសំ សទ្ទានំ អាការំ។

*បទថា "**កំសេ**" ប្រែថា ភាជន:សំរឹទ្ធ។ បទថា "**និមិត្តំ**" បានដល់អាការៈនៃសំឡេងប៉ុណ្ណោះ។*

និមិត្តន្តិ ច សាមិអត្ថេ ឧបយោគវចនំ, និមិត្តស្សាតិ អត្ថោ។ សទ្ទនិមិត្តញ្ច សទ្ទតោ អនញ្ញំ។

*ម្យ៉ាងទៀត បទថា "**និមិត្តំ**" ជាទុតិយាវិភត្តិចុះក្នុងឆដ្ឋីវិភត្តិ, មានអត្ថស្មើនឹង **និមិត្តស្ស**។ ម្យ៉ាងទៀត **និមិត្ត** គឺសំឡេង មិនមែនអ្វីដទៃឡើយក្រៅអំពីសំឡេង។*

"**សុក្តហិតត្តា**"តិ សុដ្ឋុ ឧក្តហិតត្តា។ សុកហិតត្តាតិបិ ចាហោ, សុដ្ឋុ កហិតត្តាតិ អត្ថោ។

*បទថា "**សុក្តហិតត្តា**" ប្រែថា ព្រោះរៀនកាន់យកដោយល្អហើយ។ ព្រះបាលី ជា សុកហិតត្តា បែបនេះក៏មាន។ សេចក្តីថា ព្រោះការកាន់កយដោយល្អហើយ។*

"**សុមនសិកតត្តា**"តិ សុដ្ឋុ អាវជ្ជិតត្តា។ "**សុបជាវិតត្តា**"តិ សុដ្ឋុ ចិត្តេ បវិតត្តា ។

*បទថា "សុមនសិកតត្តា" សេចក្តីថា ព្រោះនឹកហើយដោយល្អ។ បទថា "**សុបជាវិតត្តា**" សេចក្តីថា ព្រោះការតាំងទុកក្នុងចិត្តដោយល្អ។*

"**សុខុមសទ្ធនិមិត្តារម្មណតាបី**"តិ តថា សុខុមានម្បិ សទ្ធាន៎ ជិវុទ្ធត្តា អនុក្តហិតសទ្ធនិមិត្តស្ស អជារម្មណម្បិ សុខុមតរំ សទ្ធនិមិត្តំ អារម្មណំ កត្វា សុខុមតរំ សទ្ធនិមិត្តារម្មណម្បិ ចិត្តំ បវត្តតិ, សុខុមតរ-សទ្ធនិមិត្តារម្មណភាវតោបីតិ វា អត្ថោ ។

*ពាក្យថា "**សូម្បីព្រោះនិមិត្តនៃសំឡេងល្អិតសុខុមជាអារម្មណ៍**" សេចក្តីថា ព្រោះរលត់សំឡេង សូម្បីដែលល្អិតសុខុមបានក្នុងខណៈនោះ ចិត្តសូម្បីមាននិមិត្ត គឺសំឡេងជាអារម្មណ៍ដែលល្អិតសុខុមជាង ធ្វើជានិមិត្ត គឺសំឡេងដែលល្អិតជាង សូម្បីដែលជាអារម្មណ៍មិនបានរបស់សទ្ធសំឡេងនិមិត្តដែលកាន់យកមិនបាន មកធ្វើជាអារម្មណ៍ឲ្យប្រព្រឹត្តទៅ, ន័យម្យ៉ាងទៀត សេចក្តីថា សូម្បីព្រោះមាននិមិត្ត គឺសំឡេងដែលល្អិតសុខុមជាង មកជាអារម្មណ៍។*

ឥមិនាវ នយេន អប្បនាយម្បិ អត្ថោ វេទិតព្ពោ។

គប្បីជ្រាប នូវសេចក្តីសូម្បីក្នុងអប្បនាដោយន័យនេះឯង។

"**បស្សម្ភយ**"ន្តិអាទីសុ "បស្សម្ភយំ កាយសង្ខារ"ន្តិ វុត្តា អស្សាស-

បស្សាសា កាយោតិ ឯ "បស្សម្ភយំ កាយសង្ខារ"ន្តិ ឯត្ថ អស្សាស-បស្សាសា កាយោតិ ឯ យោគិនា វេទិតព្ពា ។

*ក្នុងបទថា **"បស្សម្ភយំ"** ជាដើម គប្បីជ្រាបនូវពាក្យប្រកបថា ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលលោកពោលទុកថា "រលត់បាត់កាយសង្ខារ" ឈ្មោះថា កាយ ឬថា ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញក្នុងបទថា "បស្សម្ភយំ កាយសង្ខារំ ប្រែថា រលត់បាត់កាយសង្ខារ" ឈ្មោះថា កាយ ។*

ភាវនាវិសុទ្ធិយា កាយសង្ខារេ បស្សម្ភមានេបិ ឱឞ្ឋារិកំ កាយសង្ខារំ បស្សម្ភេមីតិ យោគិនោ អាភោគេ សតិ តេនាឧវេន អតិវិយ បស្សម្ភតិ ។

កាលព្រះយោគីនឹកថា អាត្មាអញនឹងរលត់បាត់កាយសង្ខារដែលគ្រោតគ្រាត សូម្បីក្នុងកាលកាយសង្ខារកំពុងរលត់បាត់ ដោយភាពបរិសុទ្ធិនៃការភាវនា កាយសង្ខារក៏រមែងរលត់បាត់យ៉ាងក្រៃលែង ដោយការយកចិត្តទុកដាក់នោះ ។

អនុបដ្ឋហន្តម្បិ សុខុមំ សុអានយំ ហោតិ។

ការដែលរលត់បាត់ រមែងជាធម្មជាតិនាំមកដោយល្អ នូវនិមិត្តដែលល្អិតសុខុម សូម្បីដែលមិនប្រាកដ ។

"អដ្ឋ អនុបស្សនាញាណានី"តិ "ឥឞំ វស្សំ សព្ពកាយបដិសំវេទី បស្សម្ភយំ កាយសង្ខារ"ន្តិ វុត្តេសុ ចតូសុ វត្ថូសុ អស្សាសវសេន ចតស្សោ, បស្សាសវសេន ចតស្សោតិ អដ្ឋ អនុបស្សនាញាណានិ។

*ពាក្យថា "អនុបស្សនាញាណ ៨" សេចក្តីថា អនុបស្សនាញាណ ៨ គឺ អនុបស្សនាញាណ ៤ ដោយអំណាចខ្យល់ដង្ហើមចូល ក្នុងវត្ថុទាំង ៤ ដែលលោកពោលទុកថា "**ឥឞំ...វស្សំ...សព្ពកាយប្បដិសំវេទី បស្សម្ភយំ កាយសង្ខារំ**" ប្រែថា **ឥឞំ...** អាត្មាអញខណៈដកដង្ហើមចូលវែង ក៏ដឹងច្បាស់*

ថា អាត្មាអញដកដង្ហើមចូលវែង **រស្សំ...** *អាត្មាអញ ខណៈដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី* **សព្វកាយប្បដិសំវេទី** *អាត្មាអញនឹងដឹងនូវចំណែកខ្យល់ទាំងពួងដកដង្ហើមចូល* **បស្សម្ភយំ កាយសង្ខារំ** *អាត្មាអញនឹងរលត់បាត់កាយសង្ខារដកដង្ហើមចូល, អនុបស្សនាញាណដទៃទៀត ៤ ដោយអំណាចខ្យល់ដង្ហើមចេញ (តាមន័យខាងដើមនោះឯង) ដូចនេះ ។*

"អដ្ឋ ច ឧបដ្ឋានានុស្សតិយោ"តិ "ទីឃំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតី"តិអាទិនា[๗๒] **នយេន វុត្តេសុ ចតូសុ វត្ថូសុ អស្សាសវសេន ចតស្សោ, បស្សាសវសេន ចតស្សោតិ អដ្ឋ ច ឧបដ្ឋានានុស្សតិយោ ។**

បទថា **"អដ្ឋ ច ឧបដ្ឋានានុស្សតិយោ"** *សេចក្តីថា ឧបដ្ឋានានុស្សតិ ៨ គឺឧបដ្ឋានានុស្សតិ ៤ ដោយអំណាចខ្យល់ដង្ហើមចូល ក្នុងវត្ថុ ៤ ដែលត្រាស់សម្តែងទុកដោយន័យថា "ទីឃំ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ" ប្រែថា កាលដឹងច្បាស់នូវភាពដែលចិត្តមានអារម្មណ៍តែមួយ គឺមិនរាយមាយដោយអំណាចនៃខ្យល់ដង្ហើមចូលវែង សតិក៏រមែងតាំងមាំ, ឧបដ្ឋានានុស្សតិ ដទៃទៀត ៤ ដោយអំណាចខ្យល់ដង្ហើមចេញ (តាមន័យដូចគ្នា) បែបនេះជាដើម ។*

អដ្ឋ ចុបដ្ឋានានុស្សតិយោតិបិ ចាហោ។

ព្រះបាលីជា **អដ្ឋ ចុបដ្ឋានានុស្សតិយោ** *ដូចនេះក៏មាន ។*

"ចត្តារិ សុត្តន្តិកវត្ថូនី"តិ *ភគវតា* **អាជាចានសុត្តន្តេ**[๗๓] **វុត្តត្តា បឋមចតុក្កវសេន ចត្តារិ សុត្តន្តិកវត្ថូនីតិ។**

---

๗๒ (បដិ. ម. ๑.๑๗๐) ។

๗๓ (ម. និ. ๓.๑๔๔ អាទយោ) ។

ពាក្យថា "សុត្តន្តិកវត្ថុ ៤" សេចក្តីថា សុត្តន្តិកវត្ថុ ៤ ដោយអំណាចចតុក្កៈទី ១ ព្រោះព្រះដ៏មានព្រះភាគជាម្ចាស់បានត្រាស់សម្តែងទុកហើយក្នុងអានាបានស្សតិសូត្រ យ៉ាងនេះឯង ។

បឋមចតុក្កនិទ្ទេសវណ្ណនា និដ្ឋិតា។

ការពណ៌នានិទ្ទេសនៃចតុក្កៈទី ១ ចប់ ។

ទុតិយចតុក្កនិទ្ទេសោ

ពណ៌នានិទ្ទេសនៃចតុក្កទី ២

បីតិប្បដិសំវេទី

ចតុក្កទី ២ ឈំជាប់ទី ១ (បិដក ៧០) [១១៦]

[១៧២] កថំ "បីតិប្បដិសំវេទី អស្សសិស្សាមី"តិ សិក្ខតិ "បីតិប្បដិសំវេទី បស្សសិស្សាមី"តិ សិក្ខតិ?

យោគីភិក្ខុ រមែងសិក្សាថា "អាត្មាអញជាអ្នកកំណត់ដឹងច្បាស់ នូវបីតិ ខណៈដកដង្ហើមចូល", រមែងសិក្សាថា "អាត្មាអញជាអ្នកកំណត់ដឹងច្បាស់ នូវបីតិ ខណៈដកដង្ហើមចេញ" តើដូចម្តេច? ។

កតមា បីតិ?

តើបីតិ ដូចម្តេច?

ឥធ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ

ឧប្បជ្ជតិ បីតិ ចាមោជ្ជំ ។

កាលកិក្ខុដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូលវែង បីតិ គឺសេចក្តីបាមោជ្ជៈ រមែងកើតឡើង ។

យា បីតិ ចាមោជ្ជំ អាមោទនា បមោទនា ហាសោ បហាសោ វិត្តិ ឱទក្យំ អត្តមនតា ចិត្តស្ស ។

បីតិ គឺបាមោជ្ជៈ ជាគ្រឿងរីករាយ រីករាយខ្លាំង ការត្រេកអរ ការត្រេកអរខ្លាំង ការសប្បាយចិត្ត ការអរសប្បាយខ្លាំង ភាពមានចិត្តជារបស់ខ្លួន ។

ឥឃំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ឧប្បជ្ជតិ បីតិ ចាមោជ្ជំ។...បេ...។

កាលកិក្ខុដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចខ្យល់ដង្ហើមចូលវែង បីតិ គឺបាមោជ្ជៈ រមែងកើតឡើង ។...ល...។

រស្សំ អស្សាសវសេន..., រស្សំ បស្សាសវសេន..., សព្វកាយបដិសំវេទី អស្សាសវសេន..., សព្វកាយបដិសំវេទី បស្សាសវសេន..., បស្សម្ភយំ កាយសង្ខារំ អស្សាសវសេន..., បស្សម្ភយំ កាយសង្ខារំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ឧប្បជ្ជតិ បីតិ ចាមោជ្ជំ។

កាលកិក្ខុដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចខ្យល់ដង្ហើមចូលខ្លី...,ដោយអំណាចខ្យល់ដង្ហើមចេញខ្លី...,ដោយអំណាចជាអ្នកកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួងជាចំណែកៗដង្ហើមចូល...,ដោយអំណាចជាអ្នកកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួងជាចំណែកៗដង្ហើមចេញ...,ដោយអំណាចជាអ្នករលត់បាត់កាយសង្ខារដកដង្ហើម

ចូល, កាលដឹងច្បាស់នៃចិត្តដែលមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចជាអ្នករលត់បាត់កាយសង្ខារដកដង្ហើមចេញ បីតិ គឺបាមោជ្ជៈ រមែងកើតឡើង ។

យា បីតិ ចាមោជ្ជំ អាមោទនា បមោទនា ហាសោ បហាសោ វិត្តិ ឱទគ្យំ អត្តមនតា ចិត្តស្ស – អយំ បីតិ។

បីតិ គឺបាមោជ្ជៈ ជាគ្រឿងរីករាយ រីករាយខ្លាំង ការត្រេកអរ ការត្រេកអរខ្លាំង ការសប្បាយចិត្ត ការអរសប្បាយខ្លាំង ការមានចិត្តជារបស់ខ្លួន, សភាវៈនេះ គឺជាបីតិ ។

កថំ សា បីតិ បដិវិនិតា ហោតិ?

តើបីតិនោះ រមែងប្រាកដដូចម្តេច?

ឥធ យំ អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ។

កាលយោគីកិក្ខុដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយដែលមិនរាយមាយដោយអំណាចនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ សតិក៏រមែងតម្កល់មាំ ។

តាយ សតិយា តេន ញាណេន សា បីតិ បដិវិនិតា ហោតិ។

បីតិនោះ រមែងប្រាកដ ដោយសតិនោះ ដោយញាណនោះ ។

ឥធ យំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ។

កាលយោគីកិក្ខុ ដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយដោយអំណាចនៃខ្យល់ដង្ហើមចេញវែង សតិក៏រមែងតម្កល់មាំ ។

តាយ សតិយា តេន ញាណេន សា បីតិ បដិវិនិតា ហោតិ។

បីតិនោះ រមែងប្រាកដ ដោយសតិនោះ ដោយញាណនោះ ។

រស្សំ អស្សាសវសេន។...បេ...។ រស្សំ បស្សាសវសេន... សព្វកាយ-បដិសំវេទី អស្សាសវសេន... សព្វកាយបដិសំវេទី បស្សាសវសេន... បស្សម្ភយំ កាយសង្ខារំ អស្សាសវសេន... បស្សម្ភយំ កាយសង្ខារំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ សតិ ឧបដ្ឋិតា ហោតិ។

ដោយអំណាចខ្យល់ដង្ហើមចូលខ្លី។...ល...។ ដោយអំណាចខ្យល់ដង្ហើមចេញខ្លី...ដោយអំណាចជាអ្នកកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួងជាចំណែកៗដង្ហើមចូល...,ដោយអំណាចជាអ្នកកំណត់ដឹងច្បាស់នូវកងខ្យល់ទាំងពួងជាចំណែកៗដង្ហើមចេញ...,ដោយអំណាចជាអ្នករលត់បាត់កាយសង្ខារដកដង្ហើមចូល, កាលដឹងច្បាស់នៃចិត្តដែលមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចជាអ្នករលត់បាត់កាយសង្ខារដកដង្ហើមចេញ សតិ ក៏រមែងតម្កល់មាំ ។

តាយ សតិយា តេន ញាណេន សា បីតិ បដិវិទិតា ហោតិ។

បីតិនោះ រមែងប្រាកដ ដោយសតិនោះ ដោយញាណនោះ ។

អាវជ្ជតោ សា បីតិ បដិវិទិតា ហោតិ, ជានតោ។...បេ...។ បស្សតោ... បច្ចវេក្ខតោ... ចិត្តំ អធិដ្ឋហតោ... សទ្ធាយ អធិមុច្ចតោ... វីរិយំ បគ្គណ្ហតោ... សតឹ ឧបដ្ឋាបយតោ... ចិត្តំ សមាទហតោ... បញ្ញាយ បជានតោ... អភិញ្ញេយ្យំ អភិជានតោ... បរិញ្ញេយ្យំ បរិជានតោ... បហាតព្ពំ បជហតោ... ភាវេតព្ពំ ភាវយតោ... សច្ឆិកាតព្ពំ សច្ឆិករោតោ សា បីតិ បដិវិទិតា ហោតិ ។

កាលព្រះយោគីរំពឹងគិតដល់ បីតិនោះ រមែងប្រាកដ, កាលដឹង។...ល...។ កាលឃើញ... កាលពិចារណា... កាលអធិដ្ឋានចិត្ត... កាលជឿស៊ប់ដោយសទ្ធា...

កាលផ្គងសេចក្តីព្យាយាម... កាលប្រុងទុកនូវសតិ... កាលតម្កល់មាំនូវចិត្ត... កាលដឹងច្បាស់ដោយបញ្ញា...កាលត្រាស់ដឹងនូវធម៌ដែលគួរត្រាស់ដឹង... កាលកំណត់ដឹងនូវធម៌ដែលគួរកំណត់ដឹង... កាលលះនូវធម៌ដែលគួរលះ... កាលចម្រើននូវធម៌ដែលគួរចម្រើន... កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ បីតិនោះ ក៏រមែងប្រាកដ ។

ឯវំ សា បីតិ បដិវិទិតា ហោតិ។

បីតិនោះ រមែងប្រាកដយ៉ាងនេះ ។

បីតិបដិសំវេទី អស្សាសបស្សាសវសេន វេទនា, ឧបដ្ឋានំ សតិ, អនុបស្សនា ញាណំ។

ឈ្មោះថា វេទនា ដោយអំណាចជាអ្នកដឹងច្បាស់នូវបីតិ ដកដង្ហើមចូលនិងដកដង្ហើមចេញ, ការចូលទៅតម្កល់ទុក ឈ្មោះថា សតិ, ការពិចារណារឿយៗ ឈ្មោះថា ញាណ ។

វេទនា ឧបដ្ឋានំ, នោ សតិ; សតិ ឧបដ្ឋានញ្ចេវ សតិ ច។

វេទនាជាទីចូលទៅតម្កល់ទុក, មិនមែនជាសតិទេ, សតិជាទីចូលទៅតម្កល់ទុកផង ជាតួសតិផង ។

តាយ សតិយា តេន ញាណេន តំ វេទនំ អនុបស្សតិ។

យោគីភិក្ខុនោះ រមែងពិចារណាឃើញរឿយៗនូវវេទនានោះ ដោយសតិនោះ ដោយញាណនោះ ។

តេន វុច្ចតិ – "វេទនាសុ វេទនានុបស្សនាសតិប្បដ្ឋានភាវនា"តិ។

ព្រោះហេតុនោះ លោកពោលថា "សតិប្បដ្ឋានភាវនា គឺការពិចារណាឃើញរឿយៗនូវវេទនាក្នុងវេទនាទាំងឡាយ" ។

"អនុបស្សតី"តិ កថំ តំ វេទនំ អនុបស្សតិ? អនិច្ចតោ

អនុបស្សតិ។...បេ...។ ឯវំ តំ វេទនំ អនុបស្សតិ ។

*ពាក្យថា "**វមែងពិចារណាឃើញរឿយៗ**" សួរថា ពិចារណាឃើញរឿយៗ នូវវេទនានោះ យ៉ាងដូចម្តេច ? ។...ល...។ ពិចារណាឃើញរឿយៗនូវវេទនានោះ យ៉ាងនេះ ។*

"ភាវនា"តិ ចតស្សោ ភាវនា។...បេ...។ អាសេវនដ្ឋេន ភាវនា។

*ពាក្យថា "**ភាវនា**" បានដល់ ភាវនា ៤ យ៉ាង ។ ល ។ ឈ្មោះថា ភាវនា ដោយអត្ថថា ប្រព្រឹត្ត ។*

បីតិបដិសំវេទី អស្សាសបស្សាសានំ សំវរដ្ឋេន សីលវិសុទ្ធិ។...បេ...។

*ជាអ្នកដឹងច្បាស់នូវបីតិ ឈ្មោះថា **សីលវិសុទ្ធិ** ដោយអត្ថថា សង្រួមដកដង្ហើមចូល និងដកដង្ហើមចេញ។...ល...។*

បីតិបដិសំវេទី អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ ។...បេ...។

កាលដឹងច្បាស់នូវការៈដែលចិត្ត មានអារម្មណ៍តែមួយ មិនរាយមាយ ដោយអំណាចជាអ្នកដឹងច្បាស់នូវបីតិដកដង្ហើមចូល និងដកដង្ហើមចេញ។...ល...។

បជានតោ ឥន្ទ្រិយានិ សមោធានេតិ។

ព្រះយោគីកិក្ខុ កាលដឹងច្បាស់ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ។

តេន វុច្ចតិ – "សមត្តញ្ច បដិវិជ្ឈតី"តិ។

ព្រោះហេតុនោះ លោកពោលថា "ព្រះយោគីកិក្ខុ ឈ្មោះថា រមែងចាក់ធ្លុះ នូវអត្ថ នៃសេចក្តីស្ងប់" ។

ចតុត្ថនិទ្ទេសោ

និទ្ទេសទី ២

បីតិប្បដិសំវេទី

ចតុក្កទី ២ លំដាប់ទី ១ (អដ្ឋកថា)

[១៧២] ចតុត្ថស្ស បីតិប្បដិសំវេទិនិទ្ទេសេ **"ឧប្បជ្ជតិ បីតិ ចាមោជ្ជ"**ន្តិ ឯត្ថ **"បីតី"**តិ មូលបទំ។

*នឹងវិនិច្ឆ័យក្នុងនិទ្ទេសថា ដោយកិរិយាដឹងច្បាស់នូវបីតិនៃចតុក្កៈទី ២ តទៅ ក្នុងពាក្យថា **"បីតិ គឺបាមោជ្ជៈ រមែងកើតឡើង"** នេះ បទថា **"បីតិ"** ជាមូលបទ ។*

"ចាមោជ្ជ"ន្តិ តស្ស អត្ថបទំ, បមុទិតភាវោតិ អត្ថោ។

*ពាក្យថា **"ចាមោជ្ជ"** ជាបទអធិប្បាយនូវសេចក្តីរបស់មូលបទនោះ, បានសេចក្តីថា ភាវៈដែលចិត្តរីករាយ ។*

"យា បីតិ ចាមោជ្ជ"ន្តិអាទីសុ យា "បីតី"តិ ច "ចាមោជ្ជ"ន្តិ ច ឯវមាទីនិ ជាមានិ លក្ខតិ, សា បីតីតិ វុត្តំ ហោតិ។

*ក្នុងពាក្យថា **"បីតិ គឺ ចាមោជ្ជណា"** ជាដើម មានវិនិច្ឆ័យដូចតទៅនេះ មានសេចក្តីអធិប្បាយថា ធម្មជាតិណា រមែងបានឈ្មោះ មានអាទិយ៉ាងនេះថា **"បីតិ"** និងថា **"ចាមោជ្ជ"**, ធម្មជាតិនោះ ឈ្មោះថា **បីតិ** ។*

តត្ថ "បីតី"តិ សភាវបទំ។ បមុទិតស្ស ភាវោ **ចាមោជ្ជំ**។

*ក្នុងបណ្តាបទទាំងនោះ បទថា **"បីតិ"** ជាបទដែលសម្តែងនូវសភាវៈ ។ ភាវៈដែលរីករាយចិត្ត ឈ្មោះថា **ចាមោជ្ជ** ។*

អាមោទនាភាវោ អាមោទនា។ បមោទនាភាវោ **បមោទនា**។

អាការៈ គឺភាពរីកពយចិត្ត ឈ្មោះថា ***អាមោឌនា ភាពរីកពយចិត្ត*** *។ អាការៈ គឺភាពរីកពយទូទៅ ឈ្មោះថា* ***បមោឌនា ភាពរីកពយទូទៅ*** *។*

យថា ឯ កេសញ្ជាំ ឯ តេលាំ ឯ ឧណ្ហោឌកសីតោឌកានំ ឯ ឯកតោការណំ មោឌនាតិ វុច្ចតិ, ឯវមយម្បិ ឩម្មាំ ឯកតោការណេន ***មោឌនា*****, ឧបសគ្គវសេន បន បទំ មណ្ឌេត្វា "*****អាមោឌនា បមោឌនា*****"តិ វុត្តំ។**

ការធ្វើកេសជ្ជៈ ឬប្រេង ឬទឹកក្តៅ និងទឹកត្រជាក់រួមគ្នាហៅថា មោទនា ធាន់បាន, សូម្បីបីតិនេះក៏ឈ្មោះថា មោទនា ដោយការធ្វើធម៌ទាំងឡាយរួមគ្នា ក៏ដូចនោះដែរ, (ម្យ៉ាងទៀត) លោកតែងបទ ដោយអំណាចឧបសគ្គពោលថា ***អាមោទនា បមោទនា*** *។*

ហាសេតីតិ ***ហាសោ*****, បហាសេតីតិ** ***បហាសោ*****, ហដ្ឋបហដ្ឋាការ-ភាវមេតំ អធិវចនំ ។**

ឈ្មោះថា ***ហាសោ*** *ដោយអត្ថថា* ***សើចរីកពយ****, ឈ្មោះថា* ***បហាសោ*** *ដោយអត្ថថា* ***សើចរីកពយទូទៅ****, ពាក្យទាំងពីរនេះជាឈ្មោះនៃអាការៈសើចរីកពយ និងសើចរីកពយទូទៅ។*

"***វិត្តី*****"តិ វិត្តំ, ឩនស្សេតំ ជាមំ។ អយំ បន សោមនស្សបច្ចយត្តា វិត្តិសរិក្ខតាយ វិត្តិ។**

បទថា **"*****វិត្តិ*** *ប្រែថា រីកពយសប្បាយខ្លាំង" , បទនេះជាឈ្មោះនៃទ្រព្យ ។ ក៏បីតិនេះឈ្មោះថា វិត្តិ ព្រោះគប្បីឃើញស្មើដោយទ្រព្យគ្រឿងរីកពយចិត្ត ព្រោះជាបច្ច័យដល់សោមនស្ស ។*

យថា ហិ ឩនិលោ ឩនំ បដិច្ច សោមនស្សំ ឧប្បជ្ជតិ, ឯវំ បីតិមតោបិ បីតឹ បដិច្ច សោមនស្សំ ឧប្បជ្ជតិ។

ដូចជា មនុស្សមានទ្រព្យរមែងកើតសោមនស្ស ព្រោះអាស្រ័យទ្រព្យ យ៉ាងណា, សូម្បីមនុស្សមានបីតិ ក៏រមែងកើតសោមនស្ស ព្រោះអាស្រ័យបីតិ ក៏យ៉ាងនោះដែរ ។

តស្មា "វិត្តី"តិ វុត្តា។ តុដ្ឋិសភាវសណ្ឋិតាយ ហិ បីតិយា ឯតំ នាមំ។

*ព្រោះហេតុនោះ លោកទើបហៅថា "**វិត្តិ** " ។ ពាក្យថា **វិត្តិ** នេះជាឈ្មោះនៃបីតិដែលតាំងនៅដោយសភាពនៃការត្រេកអរ ។*

បីតិមា បន បុគ្គលោ កាយចិត្តានំ ឧក្គតត្តា អព្ភុក្គតត្តា "ឧឧក្កោ"តិ វុចូតិ, ឧឧក្គស្ស ភាកោ ឧិឧក្យំ។ អត្តនោ មនតា អត្តមនតា។

*ម្យ៉ាងទៀត បុគ្គលអ្នកមានបីតិលោកហៅថា "**ឧឧក្កោ** ប្រែថា សេចក្តីត្រេកអរ" ព្រោះថា កាយ និងចិត្តត្រេកអរឡើង គឺអណ្តែតឡើង, ភាវៈនៃបុគ្គលអ្នកមានចិត្តត្រេកអរឡើង ឈ្មោះថា **ឧិឧក្យំ** ប្រែថា **សេចក្តីត្រេកអរ** ។ សភាពដែលមានចិត្តជារបស់ខ្ជួន ឈ្មោះថា **អត្តមនតា** ប្រែថា ភាពមានចិត្តជារបស់ខ្ជួន ។*

អនភិរទ្ធស្ស ហិ មនោ ឧក្ខបឧដ្ឋានត្តា ន អត្តនោ មនោ នាម ហោតិ, អភិរទ្ធស្ស សុខបឧដ្ឋានត្តា អត្តនោ មនោ នាម ហោតិ, ឥតិ អត្តនោ មនតា អត្តមនតា, សកមនតា សកមនស្ស ភាវោតិ អត្តោ។

*ក៏ចិត្តរបស់បុគ្គលអ្នកមិនត្រេកអរ ឈ្មោះថាជាចិត្តរបស់ខ្ជួនឬអត់ ព្រោះមានទុក្ខជា **បឧដ្ឋាន**, ចិត្តរបស់បុគ្គលអ្នកត្រេកអរហើយ ឈ្មោះថាជាចិត្តរបស់ខ្ជួន ព្រោះមានសុខជា **បឧដ្ឋាន**, ភាវៈដែលចិត្តជារបស់ខ្ជួនដូចបានពោលមកនេះ ឈ្មោះថា **អត្តមនតា**, សេចក្តីថា ភាវៈដែលមានចិត្តជារបស់ខ្ជួន គឺភាវៈនៃចិត្តរបស់ខ្ជួន ។*

សា បន យស្មា ន អញ្ញស្ស កស្សចិ អត្តនោ មនតា, ចិត្តស្សេវ បនេសោ ភាវោ ចេតសិកោ ឌម្មោ, តស្មា អត្តមនតា ចិត្តស្សាតិ វុត្តា។

ក៏ភាវៈដែលចិត្តជារបស់ខ្លួននោះ ព្រោះហេតុថា ជាចិត្តរបស់ខ្លួនមិនមាននៃអ្នកដទៃ, ប៉ុន្តែភាវៈនេះជារបស់ចិត្តនុ៎ះឯង គឺជាចេតសិកធម្ម, ព្រោះដូច្នោះទើបលោកពោលថា ភាពមានចិត្តជារបស់ខ្លួននៃចិត្ត ។

សេសមេត្ត ច ឧបរិ ច ហេដ្ឋា វុត្តនយេន យោជេត្វា វេទិតព្ពំ។

ពាក្យដ៏សេសទៀតក្នុងអធិការនេះ និងខាងមុខ គប្បីប្រកបជ្រាបនូវតាមន័យដែលបានពោលមកហើយតាមន័យខាងដើម ។

សុខប្បដិសំវេទី

ចតុក្កទី ๒ ឈំដាប់ទី ๒ (ចិដក ๗๐) [๑๑๗]

[๑๗๓] កថំ "សុខប្បដិសំវេទី អស្សសិស្សាមី"តិ សិក្ខតិ,

កិក្ខុសិក្សាថា "អាត្មាអញជាអ្នកកំណត់ដឹងនូវសេចក្តីសុខ ខណៈដកដង្ហើមចូល,

"សុខប្បដិសំវេទី បស្សសិស្សាមី"តិ សិក្ខតិ ? ។

"អាត្មាអញជាអ្នកកំណត់ដឹងនូវសេចក្តីសុខ ខណៈដកដង្ហើមចេញ តើដូចម្តេច ? ។

"សុខ"ន្តិ ទ្វេ សុខានិ – កាយិកញ្ច សុខំ, ចេតសិកញ្ច សុខំ។

*ពាក្យថា "**សុខ**" បានដល់ សុខ ๒ យ៉ាងគឺ កាយិកសុខ ๑, ចេតសិកសុខ ๑ ។*

កតមំ កាយិកំ សុខំ ?

កាយិកសុខ (សុខតាមផ្លូវកាយ) តើដូចម្តេច ?

យំ កាយិកំ សាតំ កាយិកំ សុខំ, កាយសម្ផស្សជំ សាតំ សុខំ វេទយិតំ, កាយសម្ផស្សជា សាតា សុខា វេទនា – ឥទំ កាយិកំ សុខំ។

សេចក្តីត្រេកអរ ដែលប្រព្រឹត្តិទៅក្នុងកាយ សេចក្តីសុខ ដែលប្រព្រឹត្តិទៅតាមផ្លូវកាយ , សេចក្តីសោយអារម្មណ៍ដែលជាសុខ គឺសេចក្តីត្រេកអរ កើតពីកាយសម្ផស្ស, សុខវេទនា ដែលជាសេចក្តីត្រេកអរកើតពីកាយសម្ផស្ស ឯណា, នេះឈ្មោះថា កាយិកសុខ (សុខតាមផ្លូវកាយ) ។

កតមំ ចេតសិកំ សុខំ?

ចេតសិកសុខ *តើដូចម្តេ?*

យំ ចេតសិកំ សាតំ ចេតសិកំ សុខំ, ចេតោសម្ផស្សជំ សាតំ សុខំ វេទយិតំ, ចេតោសម្ផស្សជា សាតា សុខា វេទនា – ឥទំ ចេតសិកំ សុខំ។

សេចក្តីត្រេកអរ ដែលប្រព្រឹត្តិទៅក្នុងចិត្ត សេចក្តីសុខ ដែលប្រព្រឹត្តិទៅតាមផ្លូវចិត្ត, សេចក្តីសោយអារម្មណ៍ដែលជាសុខ គឺសេចក្តីត្រេកអរ កើតពីចិត្តសម្ផស្ស, សុខវេទនា ដែលជាសេចក្តីត្រេកអរកើតពីចិត្តសម្ផស្ស ឯណា, នេះឈ្មោះថា ចេតសិកសុខ (សុខតាមផ្លូវចិត្ត) ។

កថំ តេ សុខា បដិវិទិតា ហោន្តិ?

សេចក្តីសុខទាំងនោះ កិក្ខុរមែងដឹងច្បាស់ តើដូចម្តេច?

ឥធ អស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ, សតិ ឧបដ្ឋិតា ហោតិ។

កាលកិក្ខុដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនពុយមាយ ដោយអំណាចនៃដង្ហើមចូលវែង, សតិ រមែងតម្កល់មាំ ។

តាយ សតិយា តេន ញាណេន តេ សុខា បដិវិទិតា ហោន្តិ។

សេចក្តីសុខទាំងនោះ ឈ្មោះថា បុគ្គលដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ ។

ឥឃំ បស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ, សតិ ឧបដ្ឋិតា ហោតិ។

កាលភិក្ខុដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃដង្ហើមចេញវែង, សតិ រមែងតម្កល់មាំ ។

តាយ សតិយា តេន ញាណេន តេ សុខា បជិវិឥតា ហោន្តិ។...បេ..។ សច្ឆិកាតព្ពំ សច្ឆិកភោតោ តេ សុខា បជិវិឥតា ហោន្តិ។

សេចក្តីសុខទាំងនោះ ឈ្មោះថា បុគ្គលរមែងដឹងច្បាស់ហើយ ដោយសតិនោះ ដោយញាណនោះ ។...ល...។ កាលភិក្ខុធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់ សេចក្តីសុខទាំងនោះ ឈ្មោះថា ភិក្ខុដឹងច្បាស់ហើយ ។

ឯវំ តេ សុខា បជិវិឥតា ហោន្តិ។

សេចក្តីសុខទាំងនោះ ភិក្ខុជាអ្នកដឹងច្បាស់ហើយ យ៉ាងនេះឯង ។

សុខប្បដិសំវេឥី អស្សាសបស្សាសវសេន វេឥនា, ឧបដ្ឋានំ សតិ, អនុបស្សនា ញាណំ។

ដោយអំណាចនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ របស់បុគ្គលអ្នកកំណត់ដឹងនូវសុខវេទនា ឈ្មោះថា ជាវេទនា, ភាពប្រាកដ ឈ្មោះថា សតិ, សភាវៈធម៌តាមពិចារណាឃើញរឿយៗ ឈ្មោះថា ញាណ ។

វេឥនា ឧបដ្ឋានំ, នោ សតិ; សតិ ឧបដ្ឋានញ្ចេវ សតិ ច។

វេទនា ជាតួប្រាកដឡើង, មិនឈ្មោះថា ជាតួសតិទេ, ចំណែកខាងសតិទើបឈ្មោះថា ជាតួប្រាកដផង និងជាតួសតិផង ។

តាយ សតិយា តេន ញាណេន តំ វេឥនំ អនុបស្សតិ។

បុគ្គលតាមពិចារណាឃើញរឿយៗ នូវវេទនានោះ ដោយសតិនោះ ដោយញាណនោះ ។

តេន វុច្ចតិ – "វេទនាសុ វេទនានុបស្សនាសតិប្បដ្ឋានភាវនា"តិ។

ព្រោះហេតុនោះ លោកពោលថា – "វេទនាសុ វេទនានុបស្សនាសតិប្បដ្ឋានភាវនា គឺសតិប្បដ្ឋានភាវនា ជាការពិចារណាឃើញរឿយៗនូវវេទនាក្នុងវេទនាទាំងឡាយ" ។

"អនុបស្សតី"តិ កថំ តំ វេទនំ អនុបស្សតិ។ អនិច្ចតោ អនុបស្សតិ។...បេ...។ ឯវំ តំ វេទនំ អនុបស្សតិ។

*សំនួរត្រង់ពាក្យថា "**ពិចារណាឃើញរឿយៗ**" តើពិចារណាឃើញរឿយៗនូវវេទនានោះ ដូចម្តេច ? ។ បុគ្គលពិចារណាឃើញរឿយៗថា មិនទៀង។...ល...។ កិក្ខុពិចារណាឃើញរឿយៗ នូវវេទនានោះ យ៉ាងនេះឯង ។*

"ភាវនា"តិ ចតស្សោ ភាវនា។...បេ...។ អាសេវនដ្ឋេន ភាវនា។

*ពាក្យថា "**ភាវនា**" បានដល់ភាវនា ៤ យ៉ាង ។...ល...។ ឈ្មោះថា ភាវនា ដោយអត្ថថា ប្រព្រឹត្ត ។*

សុខប្បដិសំវេទី អស្សាសបស្សាសានំ សំវរដ្ឋេន សីលវិសុទ្ធិ។...បេ...។

*ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ របស់បុគ្គលអ្នកកំណត់ដឹងនូវសុខវេទនា ឈ្មោះថា **សីលវិសុទ្ធិ** ដោយអត្ថថា សង្រួម ។*

សុខប្បដិសំវេទី អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ។...បេ...។ បជានន្តោ ឥន្ទ្រិយានិ សមោធានេតិ។

កាលកិក្ខុដឹងនូវភាពនៃចិត្ត មានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ របស់អ្នកកំណត់ដឹងនូវសុខ។...ល...។ កិក្ខុកាលដឹងច្បាស់ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ។

តេន វុច្ចតិ – "សមត្តញ្ច បដិវិជ្ឈតី"តិ។

ព្រោះហេតុនោះ លោកពោលថា "បុគ្គល រមែងចាក់ធ្លុះនូវអត្តនៃការស្ងប់"។

ចតុក្ក:ទី ២ លំដាប់ទី ២

សុខប្បដិសំវេទី

ចតុក្កទី ២ លំដាប់ទី ២ (**អដ្ឋកថា**)

[๑๗๓] **សុខប្បដិសំវេទិនិទ្ទេសេ "ទ្វេ សុខានី"តិ សមថវិបស្សនាភូមិទស្សនត្ថំ វុត្តំ។**

*នឹងវិនិច្ឆ័យក្នុងនិទ្ទេសថា ភិក្ខុជាអ្នកដឹងច្បាស់នូវសុខតទៅ ពាក្យថា "**សុខ ២ យ៉ាង**" លោកពោលទុក ដើម្បីសម្តែងភូមិនៃសមថៈ និងវិបស្សនា ។*

កាយិកញ្ហិ សុខំ វិបស្សនាយ ភូមិ, ចេតសិកំ សុខំ សមថស្ស ច វិបស្សនាយ ច ភូមិ។

*ពិតមែន **កាយិកសុខ** (សុខតាមផ្លូវកាយ) ជាភូមិនៃវិបស្សនា, **ចេតសិកសុខ** (សុខតាមផ្លូវចិត្ត) ជាភូមិនៃសមថៈ និងវិបស្សនា ។*

"កាយិក"ន្តិ បសាទកាយំ វិនា អនុប្បត្តិតោ កាយេ និយុត្តន្តិ កាយិកំ។

*បទថា "**កាយិកំ**" មានអត្ថថា ឈ្មោះថា **កាយិក** ដោយអត្ថថា ប្រកបក្នុងកាយ ព្រោះរឿកាយប្រសាទមិនអាចកើតឡើងបានទេ ។*

"**ចេតសិក**"ន្តិ អវិប្បយោគវសេន ចេតសិ និយុត្តន្តិ ចេតសិកំ។

ពាក្យថា "**ចេតសិកំ**" *មានអត្ថថា ឈ្មោះថា ចេតសិក ដោយអត្ថថា ប្រកបក្នុងចិត្តដោយអំណាចមិនប្រាសចាកគ្នា ។*

តត្ថ កាយិកបឌេន ចេតសិកំ សុខំ បដិក្ខិបតិ, សុខបឌេន កាយិកំ ទុក្ខំ។

ក្នុងសុខ ២ យ៉ាងនោះ លោកបដិសេធសុខតាមផ្លូវចិត្ត ដោយបទថា កាយិក, លោកបដិសេធទុក្ខតាមផ្លូវកាយ ដោយបទថា សុខ: ។

តថា ចេតសិកបឌេន កាយិកំ សុខំ បដិក្ខិបតិ, សុខបឌេន ចេតសិកំ ទុក្ខំ។

ម្យ៉ាងទៀត លោកបដិសេធសុខតាមផ្លូវកាយ ដោយបទថា **ចេតសិក**, *លោកបដិសេធទុក្ខតាមផ្លូវចិត្ត ដោយបទថា សុខ: ។*

"**សាត**"ន្តិ មធុរំ សុមធុរំ។ "**សុខ**"ន្តិ សុខមេវ, ន ទុក្ខំ។ "**កាយសម្ផស្សជ**"ន្តិ កាយសម្ផស្សេ ជាតំ។

បុគ្គលអ្នកមានប្រក្រតីពិចារណាឃើញការនឿយណាយទាំង ២ យ៉ាងនោះ ដោយអារម្មណ៍ និងដោយអធ្យាស្រ័យ លោកហៅថា "អ្នកពិចារណាឃើញការនឿយណាយក្នុងរូប"។ ក្នុងវេទនា ជាដើមនោះ ក៏មានន័យដូចគ្នា។

និពេធានុបស្សីបទនិទ្ទេសេបិ ឯសេវ នយោ។

សូម្បីក្នុងនិទ្ទេសនៃបទថា អ្នកពិចារណាឃើញការរលត់ ក៏មានន័យបែបនេះដូចគ្នា។

បដិច្ចសមុប្បាទ (ចិដក ๗๐) [๑๒๗]

[๑๘๑] **កតិហាការេហិ អវិជ្ជាយ អាទីនវោ ហោតិ?**

ទោសក្នុងអវិជ្ជា ដោយអាការប៉ុន្មានយ៉ាង?

កតិហាការេហិ អវិជ្ជា និវុជ្ឈតិ?

អវិជ្ជារលត់ទៅ ដោយអាការប៉ុន្មានយ៉ាង?

បញ្ចហាការេហិ អវិជ្ជាយ អាទីនវោ ហោតិ។

ទោសក្នុងអវិជ្ជាមានអាការ ៥ យ៉ាង។

អដ្ឋហាការេហិ អវិជ្ជា និវុជ្ឈតិ។

អវិជ្ជារលត់ទៅដោយអាការ ៨ យ៉ាង។

កតមេហិ បញ្ចហាការេហិ អវិជ្ជាយ អាទីនវោ ហោតិ?

ទោសក្នុងអវិជ្ជា ដោយអាការ ៥ យ៉ាង តើមានអ្វីខ្លះ?

๑. **អនិច្ចដ្ឋេន អវិជ្ជាយ អាទីនវោ ហោតិ,**

ទោសក្នុងអវិជ្ជា ដោយអត្ថថា មិនទៀង ๑,

๒. **ទុក្ខដ្ឋេន អវិជ្ជាយ អាទីនវោ ហោតិ,**

ទោសក្នុងអវិជ្ជា ដោយអត្ថថា ជាទុក្ខ ๑,

๓. **អនត្តដ្ឋេន អវិជ្ជាយ អាទីនវោ ហោតិ,**

ទោសក្នុងអវិជ្ជា ដោយអត្ថថា ជាអនត្តា ๑,

๔. **សន្តាបដ្ឋេន អវិជ្ជាយ អាទីនវោ ហោតិ,**

ទោសក្នុងអវិជ្ជា ដោយអត្ថថា ក្តៅសព្វ ๑,

๕. **វិបរិណាមដ្ឋេន អវិជ្ជាយ អាទីនវោ ហោតិ,**

ទោសក្នុងអវិជ្ជា ដោយអត្ថ ប្រៃប្រួល ១,

ឥមេហិ បញ្ចហាការេហិ អវិជ្ជាយ អាទីនវោ ហោតិ។

នេះជាទោសក្នុងអវិជ្ជា ដោយអាការ ៥ យ៉ាង ។

កតមេហិ អដ្ឋហាការេហិ អវិជ្ជា និវុឌ្ឍតិ?

អវិជ្ជារលត់ ដោយអាការ ៨ យ៉ាង តើមានអ្វីខ្លះ?

១. **និដាននិរោធេន អវិជ្ជា និវុឌ្ឍតិ,**

អវិជ្ជារលត់ ដោយការរលត់នៃធម៌ជាគ្រឿងប្រគល់ឲ្យនូវផល ១ ,

២. **សមុទយនិរោធេន អវិជ្ជា និវុឌ្ឍតិ,**

អវិជ្ជារលត់ ដោយការរលត់នៃហេតុជាទីប្រជុំកើតឡើង ១ ,

៣. **ជាតិនិរោធេន អវិជ្ជា និវុឌ្ឍតិ,**

អវិជ្ជារលត់ ដោយការរលត់នៃជាតិ ១ ,

៤. **បភវនិរោធេន[៨៣] អវិជ្ជា និវុឌ្ឍតិ,**

អវិជ្ជារលត់ ដោយការរលត់នៃអាហារ (គឺបច្ច័យដែលមកប្រជុំគ្នា) ១ ,

៥. **ហេតុនិរោធេន អវិជ្ជា និវុឌ្ឍតិ,**

អវិជ្ជារលត់ ដោយការរលត់នៃហេតុ ១,

៦. **បច្ចយនិរោធេន អវិជ្ជា និវុឌ្ឍតិ,**

អវិជ្ជារលត់ ដោយការរលត់នៃបច្ច័យ ១,

៧. **ញាណុប្បាទេន អវិជ្ជា និវុឌ្ឍតិ,**

អវិជ្ជារលត់ ដោយការកើតឡើងនៃញាណ ១,

---

៨៣ ស្យា. អាហារនិរោធេន ។

๘. និរោធុបដ្ឋានេន អវិជ្ជា និវុជ្ឈតិ,

អវិជ្ជារលត់ ព្រោះការប្រាកដនៃនិរោធធម៌ ๑,

ឥមេហិ អដ្ឋហាការេហិ អវិជ្ជា និវុជ្ឈតិ។

នេះជាអវិជ្ជារលត់ ដោយអាការ ๘ យ៉ាង ។

ឥមេហិ បញ្ចហាការេហិ អវិជ្ជាយ អាទីនវំ ទិស្វា, ឥមេហិ អដ្ឋហាការេហិ អវិជ្ជានិរោធេ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ, ចិត្តញ្ចស្ស សណ្ឋាតិដ្ឋិតំ។

បុគ្គលឃើញទោសក្នុងអវិជ្ជា ដោយអាការ ๕ យ៉ាងនេះ, ហើយជាអ្នកមានឆន្ទៈក្នុងការរលត់នៃអវិជ្ជា ដោយអាការ ๘ យ៉ាងនេះ មានចិត្តចុះស៊ប់ក្នុងសទ្ធា, ចិត្តរបស់បុគ្គលនោះ ក៏តម្កល់នៅស៊ប់សួន ។

"អវិជ្ជាយ និរោធាទុបស្សឺ អស្សសិស្សាមី"តិ សិក្ខតិ, "អវិជ្ជាយ និរោធាទុបស្សឺ បស្សសិស្សាមី"តិ សិក្ខតិ។

យោគីភិក្ខុនោះ សិក្សាថា "អាត្មាអញជាអ្នកពិចារណាឃើញរឿយៗនូវការរលត់នៃអវិជ្ជា ដកដង្ហើមចូល", សិក្សាថា "អាត្មាអញជាអ្នកពិចារណាឃើញរឿយៗនូវការរលត់នៃអវិជ្ជា ដកដង្ហើមចេញ" ។

កតិហាការេហិ សង្ខារេសុ អាទីនវោ ហោតិ, កតិហាការេហិ សង្ខារា និវុជ្ឈន្តិ។...បេ...។

ទោសក្នុងសង្ខារ ដោយអាការៈប៉ុន្មានយ៉ាង ? , សង្ខាររមែងរលត់ទៅដោយអាការៈប៉ុន្មានយ៉ាង ? ។...ល...។

កតិហាការេហិ វិញ្ញាណេ អាទីនវោ ហោតិ,

ទោសក្នុងវិញ្ញាណ រមែងមានដោយអាការៈប៉ុន្មានយ៉ាង ?,

កតិហាការេហិ វិញ្ញាណំ និរុជ្ឈតិ...

វិញ្ញាណ រមែងរលត់ទៅ ដោយអាការៈប៉ុន្មានយ៉ាង ?...

កតិហាការេហិ នាមរូបេ អាទីនវោ ហោតិ, កតិហាការេហិ នាមរូបំ និរុជ្ឈតិ...

ទោសក្នុងនាមរូប ដោយអាការៈប៉ុន្មានយ៉ាង ?, នាមរូប រមែងរលត់ទៅ ដោយ អាការៈប៉ុន្មានយ៉ាង ?...

កតិហាការេហិ សឡាយតនេ អាទីនវោ ហោតិ, កតិហាការេហិ សឡាយតនំ និរុជ្ឈតិ...

ទោសក្នុងសឡាយតនៈ ដោយអាការៈប៉ុន្មានយ៉ាង ?, សឡាយតនៈ រមែងរលត់ទៅ ដោយអាការៈប៉ុន្មានយ៉ាង ?...

កតិហាការេហិ ផស្សេ អាទីនវោ ហោតិ, កតិហាការេហិ ផស្សោ និរុជ្ឈតិ...

ទោសក្នុងផស្សៈ ដោយអាការៈប៉ុន្មានយ៉ាង ?, ផស្សៈរលត់ទៅ ដោយ អាការៈប៉ុន្មានយ៉ាង ?...

កតិហាការេហិ វេទនាយ អាទីនវោ ហោតិ, កតិហាការេហិ វេទនា និរុជ្ឈតិ...

ទោសក្នុងវេទនា ដោយអាការៈប៉ុន្មានយ៉ាង ?, វេទនារលត់ទៅ ដោយ អាការៈប៉ុន្មានយ៉ាង ?...

កតិហាការេហិ តណ្ហាយ អាទីនវោ ហោតិ, កតិហាការេហិ តណ្ហា និរុជ្ឈតិ...

ទោសក្នុងតណ្ហា ដោយអាការៈប៉ុន្មានយ៉ាង ?, តណ្ហារលត់ទៅ ដោយ អាការៈប៉ុន្មានយ៉ាង ?...

កតិហាការេហិ ឧចាជានេ អាឌីនវេ ហោតិ, កតិហាការេហិ ឧចាជានំ និរុជ្ឈតិ...

ទោសក្នុងឧបាទាន ដោយអាការៈប៉ុន្មានយ៉ាង ?, ឧបាទានរលត់ទៅ ដោយអាការៈប៉ុន្មានយ៉ាង ?...

កតិហាការេហិ ភវេ អាឌីនវេ ហោតិ, កតិហាការេហិ ភវេ និរុជ្ឈតិ...

ទោសក្នុងភព ដោយអាការៈប៉ុន្មានយ៉ាង ?, ភពរលត់ទៅ ដោយអាការៈប៉ុន្មានយ៉ាង ?...

កតិហាការេហិ ជាតិយា អាឌីនវេ ហោតិ, កតិហាការេហិ ជាតិ និរុជ្ឈតិ...

ទោសក្នុងជាតិ ដោយអាការៈប៉ុន្មានយ៉ាង ?, ជាតិរលត់ទៅ ដោយអាការៈប៉ុន្មានយ៉ាង ?...

កតិហាការេហិ ជរាមរណេ អាឌីនវេ ហោតិ, កតិហាការេហិ ជរាមរណំ និរុជ្ឈតិ ?

ទោសក្នុងជរាមរណៈ ដោយអាការៈប៉ុន្មានយ៉ាង ?, ជរាមរណៈរលត់ទៅ ដោយអាការៈប៉ុន្មានយ៉ាង ?...

បញ្ចហាការេហិ ជរាមរណេ អាឌីនវេ ហោតិ, អដ្ឋហាការេហិ ជរាមរណំ និរុជ្ឈតិ។

ទោសក្នុងជរាមរណៈ ដោយអាការៈ ៥ យ៉ាង , ជរាមរណៈរលត់ទៅ ដោយអាការៈ៨ យ៉ាង ។

កតមេហិ បញ្ចហាការេហិ ជរាមរណេ អាឌីនវេ ហោតិ ?

ទោសក្នុងជរា និងមរណៈ ដោយអាការៈ ៥ យ៉ាង តើមានអ្វីខ្លះ ?

១. អនិច្ចដ្ឋេន ជរាមរណោ អាជីនភោ ហោតិ,

ទោសក្នុងជរា និងមរណៈ ដោយអត្ថថា មិនទៀង ១,

២. ទុក្ខដ្ឋេន។...បេ...។

ដោយអត្ថថា ជាទុក្ខ ១ ។...ល...។

៣. អនត្តដ្ឋេន។...បេ...។

ដោយអត្ថថា ជាអនត្តា ១ ។...ល...។

៤. សន្តាបដ្ឋេន។...បេ...។

ដោយអត្ថថា ក្តៅសព្ទ ១ ។...ល...។

៥. វិបរិណាមដ្ឋេន ជរាមរណោ អាជីនភោ ហោតិ,

ទោសក្នុងជរា និងមរណៈ ដោយអត្ថថា ប្រែប្រួល ១

ឥមេហិ បញ្ចហាការេហិ ជរាមរណោ អាជីនភោ ហោតិ។

នេះជាទោសក្នុងជរា និងមរណៈ ដោយអាការ: ៥ យ៉ាង ។

កតមេហិ អដ្ឋហាការេហិ ជរាមរណំ និរុជ្ឈតិ?

ជរា និងមរណៈ រលត់ដោយអាការ:ប៉ុន្មានយ៉ាង ?

១. និជាននិភោជេន ជរាមរណំ និរុជ្ឈតិ,

ជរា និងមរណៈ:រលត់ទៅ ដោយការរលត់នៃហេតុជាគ្រឿងប្រគល់ឲ្យនូវ ផល ១,

២. សមុទយនិភោជេន។...បេ...។

ដោយការរលត់នៃហេតុជាទីប្រជុំការកើត ១។...ល...។

៣. ជាតិនិភោជេន។...បេ...។

ដោយការរលត់នៃជាតិ ១។...ល...។

៤. **បភវនិរោធេន**[๘๒]...

ដោយការរលត់នៃភព ១។...ល...។

៥. **ហេតុនិរោធេន**...

ដោយការរលត់នៃហេតុ ១។...ល...។

៦. **បច្ចយនិរោធេន**...

ដោយការរលត់នៃបច្ចុ័យ ១។...ល...។

៧. **ញាណុប្បាទេន**។...បេ...។

ដោយការកើតឡើងនៃញាណ ១។...ល...។

៨. **និរោធុបដ្ឋានេន ជរាមរណំ និរុជ្ឈតិ** ,

ជរា និងមរណ:រមែងរលត់ ដោយការប្រាកដនៃនិរោធធម៌(គឺព្រះនិញាន) ១,

ឥមេហិ អដ្ឋហាការេហិ ជរាមរណំ និរុជ្ឈតិ។

នេះជរា និងមរណ: រមែងរលត់ដោយអាការ: ៨ យ៉ាងនេះ ។

ឥមេហិ បញ្ចហាការេហិ ជរាមរណេ អាទីនវំ ទិស្វា ឥមេហិ អដ្ឋហាការេហិ ជរាមរណនិរោធេ ឆន្ទជាតោ ហោតិ សទ្ធាធិមុត្តោ, ចិត្តញ្ចស្ស ស្វាធិដ្ឋិតំ។

បុគ្គលឃើញទោស ក្នុងជរា និងមរណ:ដោយអាការ: ៥ យ៉ាងនេះហើយ ជាអ្នកមានឆន្ទ:កើតឡើងហើយ ក្នុងការរលត់នៃជរា និងមរណ: ដោយអាការ: ៨ យ៉ាងនេះ ជាអ្នកមានចិត្តចុះស៊ិប់ក្នុងព្រះនិញាន ដោយសទ្ធា, ចិត្តរបស់បុគ្គលនោះ ក៏តម្កល់នៅស៊ិប់សួនបានល្អ ។

---

៨៤ [ភវនិរោធេន (ស្យា.)]

"ជរាមរណេ និរោជានុបស្សី អស្សសិស្សាមី"តិ សិក្ខតិ, "ជរាមរណេ និរោជានុបស្សី បស្សសិស្សាមី"តិ សិក្ខតិ។

យោគីភិក្ខុនោះ រមែងសិក្សាថា "អាត្មាអញជាអ្នកពិចារណាឃើញរឿយៗ នូវការរលត់ជរា និងមរណ: ដកដង្ហើមចូល", សិក្សាថា "អាត្មាអញជាអ្នកពិចារណាឃើញរឿយៗ នូវការរលត់ជរា និងមរណ: ដកដង្ហើមចេញ" ។

និរោជានុបស្សី អស្សាសបស្សាសវសេន ជម្មា, ឧបដ្ឋានំ សតិ, អនុបស្សនា ញាណំ។

ការឃើញរឿយៗ នូវការរលត់ ដោយអំណាចនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ឈ្មោះថា ជាធម៌, ភាពប្រាកដ ឈ្មោះថា ជាសតិ, ការឃើញរឿយៗ ឈ្មោះថា ជាញាណ ។

ជម្មា ឧបដ្ឋានំ, នោ សតិ; សតិ ឧបដ្ឋានញ្ចេវ សតិ ច។

ធម៌ទាំងឡាយជាតួប្រាកដ, មិនមែនជាសតិទេ, ចំណែកខាងសតិ ទើបឈ្មោះថា ជាតួប្រាកដផង និងឈ្មោះថា ជាសតិផង ។

តាយ សតិយា តេន ញាណេន តេ ជម្មេ អនុបស្សតិ។

បុគ្គលរមែងឃើញរឿយៗនូវធម៌ទាំងឡាយនោះ ដោយសតិនោះ ដោយញាណនោះ។

តេន វុចូតិ – "ជម្មេសុ ជម្មានុបស្សនាសតិប្បដ្ឋានភាវនា"តិ។

*ព្រោះហេតុនោះ លោកពោលថា "**សតិប្បដ្ឋានភាវនា** គឺការពិចារណាឃើញ រឿយៗនូវធម៌ទាំងឡាយក្នុងធម៌" ។*

"អនុបស្សតី"តិ ភាចំ តេ ជម្មេ អនុបស្សតិ។...បេ...។ ឯវំ តេ ជម្មេ អនុបស្សតិ ។

*សំនួរត្រង់ពាក្យថា "**ពិចារណាឃើញរឿយៗ**" តើពិចារណាឃើញ នូវធម៌*

ទាំងនោះ ដូចម្តេច ? ฯ...ល...ฯ បុគ្គលពិចារណាឃើញនូវធម៌ទាំងនោះ យ៉ាងនេះឯង ฯ

"ភាវនា"តិ ចតស្សោ ភាវនា។...បេ...។ អាសេវនដ្ឋេន ភាវនា។

*ពាក្យថា "**ភាវនា**" បានដល់ ភាវនា ๔ យ៉ាង ฯ..ល...ฯ ឈ្មោះថា **ភាវនា** ដោយអត្ថថា សេព ฯ*

និកោជនុបស្សី អស្សាសបស្សាសានំ សំវរដ្ឋេន សីលវិសុទ្ធិ។...បេ...។

*ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ របស់បុគ្គលអ្នកពិចារណាឃើញរឿយៗ នូវការរលត់ ឈ្មោះថា **សីលវិសុទ្ធិ** ដោយអត្ថថា សង្រួម ฯ..ល...ฯ*

និកោជនុបស្សី អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ។...បេ...។

កាលបុគ្គលដឹងច្បាស់នូវភាពនៃចិត្តមានអារម្មណ៍តែមួយដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ របស់បុគ្គលអ្នកពិចារណាឃើញរឿយៗនូវការរលត់ฯ...ល...ฯ

បជានតោ ឥន្ទ្រិយានិ សមោជានេតិ។

បុគ្គលកាលដឹងច្បាស់ ឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ฯ

តេន វុច្ចតិ – "សមត្តញ្ច បដិវិជ្ឈតី"តិ។

ព្រោះហេតុនោះ លោកពោលថា "បុគ្គល រមែងចាក់ធ្លុះនូវអត្ថនៃការស្ងប់" ฯ

ចតុក្កទី ๔ លំដាប់ទី ๓ ចប់ ฯ

បដិច្ចសមុប្បាទ (អដ្ឋកថា)

[១៨១] "**កតិហាការេហី**"តិអាទិ បនេត្ថ វិសេសោ –

*ចំណែកសេចក្តីផ្សេងគ្នាក្នុងទីនេះដែលចាប់ផ្តើមថា **ដោយអាការៈប៉ុន្មាន** ដូច្នេះ*

តត្ថ អវិជ្ជាទីនំ បដិច្ចសមុប្បាទង្គានំ អាទីនវនិព្ភេទទស្សនេនេវ - រូចាទីនម្បិ អាទីនវនិព្ភេទា ទស្សិតា ហោន្តិ តេសម្បិ បដិច្ចសមុប្បាទង្គា-នតិវត្តនតោ។

ក្នុងសេចក្តីនោះ ជាការសម្តែងទោស និងការរលត់នៃអង្គបដិច្ចសមុប្បាទ ដែលមានអវិជ្ជា ជាដើម នុ៎ះឯង ជាការដែលលោកសម្តែងដល់ទោស និងការ រលត់សូម្បីនៃរូបជាដើម ព្រោះសូម្បីរូបជាដើមទាំងនោះក៏មិនប្រព្រឹត្តិកន្លងនៃ បដិច្ចសមុប្បាទ។

ឥមិនា ឃវ ច វិសេសវចនេន វិភាគានុបស្សនតោ និព្ភេទានុ-បស្សនាយ វិសិដ្ឋភាវេ វុត្តោ ហោតិ។

ក៏ដោយការពោលនូវសេចក្តីផ្សេងគ្នានេះឯង ជាការដែលលោកពោល ដល់សេចក្តីដែល និព្ភេទានុបស្សនា ប្រសើរជាងការពិចារណាឃើញការ នឿយណាយ។

តត្ថ "អនិច្ចដ្ឋេនា"តិ ខយដ្ឋេន, ហុត្វា អភាវដ្ឋេន វា។ "ទុក្ខដ្ឋេនា"តិ ភយដ្ឋេន, បដិបីឡនដ្ឋេន វា។ "អនត្តដ្ឋេនា"តិ អសារកដ្ឋេន, អវស-វត្តនដ្ឋេន វា។

*ក្នុងបណ្តាពាក្យទាំងនោះ ពាក្យថា "**ដោយអត្ថថាមិនទៀង**" គឺដោយអត្ថ ថា អស់សូន្យទៅ, ឬ ដោយអត្ថថា មានហើយ បែរជាមិនមានទៅវិញ។ ពាក្យថា "**ដោយអត្ថថា ជាទុក្ខ**" គឺដោយអត្ថថា ជាភ័យ, ឬ ដោយអត្ថថា ច្របាច់ខ្ទ។*

*ពាក្យថា "**ដោយអត្តថា ជាអនត្តា**" គឺដោយអត្តថា មិនមានសារៈ ឬដោយអត្តថាមិនប្រព្រឹត្តិទៅដោយអំណាច ។*

"**សន្តាបដ្ឋេនា**"តិ កិលេសសន្តាបនដ្ឋេន។ "**វិបរិណាមដ្ឋេនា**"តិ ជរាភង្គវសេន ទ្វិធា បរិណាមនដ្ឋេន។ "**និទានាទិភាវេនា**"តិ មូលបច្ចយាការេន។

*ពាក្យថា "**ដោយអត្តថាជាហេតុឲ្យកើតសព្វ**" គឺដោយអត្តថា ជាហេតុឲ្យកើតសព្វ គឺកិលេស ។ ពាក្យថា "**ដោយអត្តថាប្រែប្រួល**" គឺដោយអត្តថាប្រែប្រួល ២ ប្រការ គឺជរា និងការរលត់ ។ ពាក្យថា "**ដោយការរលត់នៃហេតុជាគ្រឿងប្រគល់ឲ្យនូវផល**" គឺមិនមានបច្ច័យដែលជាមូល ។*

"**ជិរុជ្ឈតី**"តិ ន ភវតិ។ "**សមុទយនិភាវេនា**"តិ អាសន្នបច្ចយាការេន។

*ពាក្យថា "**រមែងរលត់**" បានដល់ រមែងមិនមាន ។ ពាក្យថា "**ដោយការរលត់នៃហេតុជាទីប្រជុំការកើត**" គឺដោយការមិនមានបច្ច័យនៅជិត ។*

មូលបច្ចយោ ហិ ព្យាធិស្ស អសប្បាយភោជនំ វិយ និទានន្តិ វុត្តោ, អាសន្នបច្ចយោ ព្យាធិស្ស ភតបិត្តសេម្ហា វិយ សមុទយោតិ វុត្តោ។

*ពិតមែន បច្ច័យដែលជាមូល លោកពោលថា **និទាន** ប្រែថា ដើមហេតុ ដូចជាការបរិភោគអាហារ ដែលមិនសប្បាយ ជាដើមហេតុរបស់ព្យាធិ, បច្ច័យដែលនៅជិត លោកពោលថា **សមុទយ** ដូចជាខ្យល់ ប្រមាត់ និងស្លេស្ម ជាសមុទយៈរបស់ព្យាធិ ។*

និទានញ្ហិ និច្ឆយេន ឧប្បាតិ ផលមិតិ និទានំ, សមុទយោ បន សុដ្ឋុ ឧទេតិ ឯតស្មា ផលមិតិ សមុទយោ។ "**ជាតិនិភាវេនា**"តិ មូលបច្ចយស្ស ឧប្បត្តិអភាវេន។

ពិតមែន ដើមហេតុឈ្មោះថា **ជនក** *ដោយអត្ថថាឲ្យនូវផលយ៉ាងពិតប្រាកដ, ចំណែកបច្ច័យដែលនៅជិត ឈ្មោះថា សមុទយៈ ដោយអត្ថថា ជាដែនកើតនៃផលដោយល្អ ។ ពាក្យថា* **"ដោយការរលត់នៃជាតិ"** *គឺដោយការមិនមាននៃការកើតឡើងនៃបច្ច័យដែលជាមូល ។*

"បភវនិភោគេនា"តិ អាសន្នបច្ចយស្ស ឧប្បត្តិអភាវេន។ ជាតិយេវ ហិ បភវតិ ឯតស្មា ទុក្ខន្តិ បភវោតិ វត្តុំ យុជ្ជតិ។ "ហេតុនិភោគេនា"តិ ជនកបច្ចយាភាវេន។

ពាក្យថា **"ដោយការរលត់នៃភព"** *គឺដោយមិនមានការកើតឡើងនៃបច្ច័យដែលនៅជិត ។ ពិតមែន ជាតិនោះឯងគួរនឹងហៅថា* **បភវោ** *ប្រែថា ដែនកើតដោយអត្ថថា ជាដែនកើតមុននៃទុក្ខ ។ ពាក្យថា* **"ដោយការរលត់នៃហេតុ"** *គឺដោយមិនមាន**ជនកបច្ចយ** ។*

"បច្ចយនិភោគេនា"តិ ឧបត្ថម្ភកបច្ចយាភាវេន។ មូលបច្ចយោបិ ហិ អាសន្នបច្ចយោ ច ជនកបច្ចយោ ឧបត្ថម្ភកបច្ចយោ ច ហោតិយេវ។

*ពាក្យថា "ដោយការរលត់បច្ច័យ" គឺដោយមិនមាន**ឧបត្ថម្ភកបច្ចយ** ។ ពិតមែន សូម្បីបច្ច័យដែលជាមូល ក៏រមែងជា**អាសន្នបច្ចយ** គឺបច្ច័យដែលនៅជិត **ជនកបច្ចយ** គឺបច្ច័យដែលជាតួឲ្យកើត និង**ឧបត្ថម្ភកបច្ចយ** គឺបច្ច័យដែលជាឧបត្ថម្ភកតែម្យ៉ាង ។*

ឯតេហិ តិក្ខវិបស្សនាក្ខណោ តទង្គនិភោគោ, មគ្គក្ខណោ សមុច្ឆេទនិភោគោ វុត្តោ ហោតិ។

ដោយពាក្យទាំងនេះ ជាការដែលលោកពោលដល់ការរលត់ ជាតទង្គក្នុងខណៈនៃវិបស្សនាដែលចាស់ក្លា, ដែលលោកពោលការរលត់ជាសមុច្ឆេទ ក្នុងខណៈនៃមគ្គ ។

"ញាណុប្បាគេនា"តិ តិក្ខវិបស្សនាញាណស្ស ឯ មគ្គញាណស្ស

ภ ឧប្បាដេន។

ពាក្យថា **"ដោយការកើតឡើងនៃញាណ"** *គឺដោយការកើតឡើងនៃវិបស្សនាញាណ ដែលចាស់ក្លា ឬនៃមគ្គញាណ ។*

"និរោធុបដ្ឋានេនា"តិ វិបស្សនាក្ខណោ បច្ចក្ខតោ ខយនិរោធស្ស អនុស្សវវសេន និរោធសង្ខាតស្ស និព្ពានស្ស ឧបដ្ឋានេន, មគ្គក្ខណោ បច្ចក្ខតោ ច និព្ពានស្ស ឧបដ្ឋានេន។

ពាក្យថា **"ដោយការប្រាកដនៃនិរោធធម៌"** *គឺដោយការប្រាកដនៃព្រះនិព្វាន ពោលគឺនិរោធ ដោយអំណាចការជាប់តៗគ្នាមក នៃខយនិរោធ (គឺការរលត់ដោយការអស់សូន្យទៅ) ដោយប្រចក្សច្បាស់ក្នុងខណៈវិបស្សនា, និង ដោយការប្រាកដនៃព្រះនិព្វាន ដោយប្រចក្សក្នុងខណៈនៃមគ្គ ។*

ឯតេហិ វិសយវិសយិនិយមោវ កតោ ហោតិ, តទង្គសមុច្ឆេទនិ-រោធោ ច វុត្តោ ហោតិ។

ដោយពាក្យទាំងនេះ ដែលលោកបានធ្វើការកំណត់អារម្មណ៍ និងធម៌ ដែលមានអារម្មណ៍, និងជាការដែលលោកពោលដល់ **តទង្គនិរោធ** *និង* **សមុច្ឆេទនិរោធ** *។*

បដិនិស្សគ្គានុបស្សី

ចតុក្ក ទី ៤ ឈំដាប់ទី ៤ (ចិដក ៧០) [១២៩]

[១៨២] កថំ "បដិនិស្សគ្គានុបស្សី អស្សសិស្សាមី"តិ សិក្ខតិ, "បដិនិស្សគ្គានុបស្សី បស្សសិស្សាមី"តិ សិក្ខតិ?

យោគីកិក្ខុ រមែងសិក្សាថា "អាត្មាអញជាអ្នកពិចារណាឃើញរឿយៗ នូវការរលាស់ចោល ដកដង្ហើមចូល", រមែងសិក្សាថា "អាត្មាអញជាអ្នកពិចារណាឃើញរឿយៗ នូវការរលាស់ចោល ដកដង្ហើមចេញ" តើដូចម្តេច?

"បដិនិស្សគ្គា"តិ ទ្វេ បដិនិស្សគ្គា: បរិច្ចាគបដិនិស្សគ្គោ ច បក្ខន្ទនបដិនិស្សគ្គោ ច។

បទថា **"បដិនិស្សគ្គា"** *បានដល់ ការរលាស់ចោល មាន ២ យ៉ាងគឺ*

*១. ការរលាស់ចោល គឺការលះបង់ (*បរិច្ចាគបដិនិស្សគ្គ*)*

*២. ការរលាស់ចោល គឺដោយការស្ទុះទៅ (*បក្ខន្ទនបដិនិស្សគ្គ*)។*

"រូបំ បរិច្ចជតី"តិ – បរិច្ចាគបដិនិស្សគ្គោ។

បុគ្គលលះស្រឡះនូវរូប យ៉ាងនេះហៅថា **បរិច្ចាគបដិនិស្សគ្គោ** *។*

រូបនិរោធេ និព្ពានេ ចិត្តំ បក្ខន្ទតីតិ – បក្ខន្ទនបដិនិស្សគ្គោ។

ចិត្តរមែងស្ទុះទៅ ក្នុងទីរលត់នៃរូប គឺព្រះនិព្វាន ដូច្នេះហៅថា **បក្ខន្ទនបដិនិស្សគ្គោ***។*

"រូបេ បដិនិស្សគ្គានុបស្សី អស្សសិស្សាមី"តិ សិក្ខតិ, "រូបេ បដិនិស្សគ្គានុបស្សី បស្សសិស្សាមី"តិ សិក្ខតិ។

យោគីកិក្ខុរមែងសិក្សាថា "អាត្មាអញជាអ្នកពិចារណាឃើញរឿយៗនូវការរលាស់ចោលនូវរូប ដកដង្ហើមចូល", រមែងសិក្សាថា "អាត្មាអញជាអ្នក

ពិចារណាឃើញរឿយៗនូវការរលាស់ចោលនូវរូប ដកដង្ហើមចេញ” ។

វេទនំ។...បេ...។ សញ្ញំ... សង្ខារេ... វិញ្ញាណំ... ចក្ខុំ។...បេ...។ ជរាមរណំ បរិច្ចជតីតិ បរិច្ចាគបដិនិស្សគ្គោ។

*បុគ្គលលះស្រឡះនូវវេទនា។...ល...។ នូវសញ្ញា...នូវសង្ខារ...នូវវិញ្ញាណ...នូវចក្ខុ។...ល...។ បុគ្គលលះស្រឡះនូវជរា និងមរណៈ យ៉ាងនេះ ហៅថា **បរិច្ចាគបដិនិស្សគ្គោ** ។*

ជរាមរណនិរោធេ និព្ពានេ ចិត្តំ បក្ខន្ទតីតិ បក្ខន្ទនបដិនិស្សគ្គោ។

*ចិត្តរមែងស្ទុះទៅ ក្នុងព្រះនិព្វានជាទីរលត់នៃជរា និងមរណៈ ដូច្នេះ ហៅថា **បរិច្ចាគបដិនិស្សគ្គោ** ។*

“ជរាមរណោ បដិនិស្សគ្គានុបស្សី អស្សសិស្សាមី”តិ សិក្ខតិ, “ជរាមរណោ បដិនិស្សគ្គានុបស្សី បស្សសិស្សាមី”តិ សិក្ខតិ។

យោគីភិក្ខុ រមែងសិក្សាថា “អាត្មាអញជាអ្នកពិចារណាឃើញរឿយៗ នូវការរលាស់ជរា និងមរណៈ ខណៈដកដង្ហើមចូល”, រមែងសិក្សាថា “អាត្មាអញជាអ្នកពិចារណាឃើញរឿយៗ នូវការរលាស់ជរា និងមរណៈ ខណៈដកដង្ហើមចេញ” ។

បដិនិស្សគ្គានុបស្សី អស្សាសបស្សាសវសេន ធម្មា, ឧបដ្ឋានំ សតិ, អនុបស្សនា ញាណំ ។

ការពិចារណាឃើញរឿយៗ នូវការរលាស់ចោលដោយអំណាចនៃដកដង្ហើមចូល និងដកដង្ហើមចេញ ឈ្មោះថា ជាធម្ម, ការប្រាកដ ឈ្មោះថា សតិ, ការតាមពិចារណាឃើញរឿយៗ ឈ្មោះថា ជាញាណ ។

ធម្មា ឧបដ្ឋានំ, នោ សតិ; សតិ ឧបដ្ឋានញ្ចេវ សតិ ច។

ធម្មទាំងឡាយ ជាតួប្រាកដ, មិនមែន ឈ្មោះថា ជាសតិទេ, ចំណែកខាង

សតិ ឈ្មោះថា ជាតួប្រាកដផង និងជាសតិផង ។

តាយ សតិយា តេន ញាណេន តេ ធម្មេ អនុបស្សតិ។

យោគីភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ទាំងឡាយនោះ ដោយសតិនោះ ដោយញាណនោះ ។

តេន វុច្ចតិ – "ធម្មេសុ ធម្មានុបស្សនាសតិប្បដ្ឋានភាវនា"តិ។

ព្រោះហេតុនោះ លោកពោលថា "សតិប្បដ្ឋានភាវនា គឺការពិចារណាឃើញរឿយៗនូវធម៌ទាំងឡាយក្នុងធម៌" ។

"អនុបស្សតី"តិ កថំ តេ ធម្មេ អនុបស្សតិ?

*សំនួរត្រង់ពាក្យថា "**ពិចារណាឃើញរឿយៗ**" តើពិចារណាឃើញនូវធម៌ទាំងឡាយនោះ ដូចម្តេច?*

អនិច្ចតោ អនុបស្សតិ, នោ និច្ចតោ។...បេ...។ បដិនិស្សជ្ជតិ, នោ អាទិយតិ។

យោគីភិក្ខុពិចារណាឃើញថា មិនទៀង, មិនមែនថាទៀងទេ។..ល...។ រលាស់ចេញ, មិនមែនកាន់យកទេ ។

អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហតិ។...បេ...។ បដិនិស្សជ្ជន្តោ អាទានំ បជហតិ។ ឯវំ តេ ធម្មេ អនុបស្សតិ។

យោគីភិក្ខុ កាលពិចារណាឃើញថា មិនទៀង រមែងលះបង់នូវនិច្ចសញ្ញា(ការសំគាល់ថា ទៀង)។...ល...។ យោគីភិក្ខុកាលរលាស់ចោលឈ្មោះថាលះបង់ នូវសេចក្តីប្រកាន់ ។ យោគីភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ទាំងឡាយនោះ យ៉ាងនេះឯង ។

"ភាវនា"តិ ចតស្សោ ភាវនា។ តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន ភាវនា។...បេ...។ អាសេវនដ្ឋេន ភាវនា។

*ពាក្យថា "**ភាវនា**" បានដល់ ភាវនា ៤ យ៉ាង ។ ឈ្មោះថា **ភាវនា** ដោយអត្ថថា មិនកន្ធង់នូវធម៌ទាំងឡាយ ដែលកើតឡើងក្នុងសមាធិនោះ ។...ល...។ ឈ្មោះថា **ភាវនា** ដោយអត្ថថា សេព ។*

បដិនិស្សគ្គានុបស្សី អស្សាសបស្សាសានំ សំវរដ្ឋេន សីលវិសុទ្ធិ, អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ, ឧស្សជនដ្ឋេន ទិដ្ឋិវិសុទ្ធិ។

ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ របស់បុគ្គលអ្នកពិចារណាឃើញរឿយៗ នូវការរលាស់ចោលឈ្មោះថា សីលវិសុទ្ធិ ដោយអត្ថថា សង្រួម, ឈ្មោះថា ចិត្តវិសុទ្ធិ ដោយអត្ថថា មិនរាយមាយ, ឈ្មោះថា ទិដ្ឋិវិសុទ្ធិ ដោយអត្ថថា ឃើញ ។

យោ តត្ថ សំវរដ្ឋោ, អយំ អធិសីលសិក្ខា; យោ តត្ថ អវិក្ខេបដ្ឋោ, អយំ អធិចិត្តសិក្ខា; យោ តត្ថ ឧស្សជនដ្ឋោ, អយំ អធិបញ្ញាសិក្ខា។

*អត្ថថា សង្រួមក្នុងធម៌នោះ ឯណា, នេះឈ្មោះថា **អធិសីលសិក្ខា**, អត្ថថា មិនរាយមាយ ក្នុងធម៌នោះ ឯណា, នេះឈ្មោះថា **អធិចិត្តសិក្ខា**, អត្ថថា ឃើញ ក្នុងធម៌នោះ ឯណា, នេះឈ្មោះថា **អធិបញ្ញាសិក្ខា** ។*

ឥមា តិស្សោ សិក្ខាយោ អាវជ្ជន្តោ សិក្ខតិ, ជានន្តោ សិក្ខតិ។...បេ...។ សច្ឆិកាតព្ពំ សច្ឆិករោន្តោ សិក្ខតិ។

យោគីកិក្ខុកាលរំពឹងឃើញនូវសិក្ខាទាំង ៣ នេះ ឈ្មោះថា សិក្សា, កាលដឹង ឈ្មោះថា សិក្សា។...ល...។កាលធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា សិក្សា។

បដិនិស្សគ្គានុបស្សី អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានតោ, វិនិតា វេទនា ឧប្បជ្ជន្តិ, វិនិតា ឧបដ្ឋហន្តិ, វិនិតា អព្ភត្ថំ គច្ឆន្តិ។ ...បេ...។

កាលយោគីកិក្ខុដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ របស់បុគ្គល អ្នកពិចារណាឃើញរឿយៗ នូវការរលាស់ចេញ, វេទនាដ៏ប្រាកដ រមែងកើតឡើង, វេទនាដ៏ប្រាកដ រមែងតាំងឡើង, វេទនាដ៏ប្រាកដ រមែងដល់នូវសេចក្តីវិនាស។ ...ល...។

បជិនិស្សគ្គានុបស្សី អស្សាសបស្សាសវសេន ចិត្តស្ស ឯកគ្គតំ អវិក្ខេបំ បជានន្តោ ឥន្ទ្រិយានិ សមោជានេតិ, គោចរញ្ច បជានាតិ, សមត្តញ្ច បដិវិជ្ឈតិ; ពលានិ សមោជានេតិ... ពោជ្ឈង្គេ សមោជានេតិ... មគ្គំ សមោជានេតិ... ធម្មេ សមោជានេតិ គោចរញ្ច បជានាតិ សមត្តញ្ច បដិវិជ្ឈតិ។

កាលបុគ្គលដឹងច្បាស់ នូវភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយ ដោយអំណាចនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ របស់បុគ្គល អ្នកពិចារណាឃើញរឿយៗនូវការរលាស់ចោលឈ្មោះថា ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ, ឈ្មោះថា ដឹងច្បាស់នូវគោចរផង, ចាក់ធ្លុះនូវអត្ថនៃការស្ងប់ផង, បុគ្គលប្រមូលមកនូវពលៈ...ប្រមូលមកនូវពោជ្ឈង្គ...ប្រមូលមកនូវមគ្គ...ប្រមូលមកនូវធម៌ទាំងឡាយ ឈ្មោះថា ដឹងច្បាស់នូវគោចរផង និងចាក់ធ្លុះនូវអត្ថផងនៃការស្ងប់ផង ។

"ឥន្ទ្រិយានិ សមោជានេតី"តិ កថំ ឥន្ទ្រិយានិ សមោជានេតិ? អធិមោក្ខដ្ឋេន សទ្ធិន្ទ្រិយំ សមោជានេតិ។...បេ...។

សំនួរត្រង់ពាក្យថា "ប្រមូលមកនូវឥន្ទ្រិយទាំងឡាយ" តើប្រមូលមកនូវឥន្ទ្រិយទាំងឡាយ ដូចម្តេច? យោគីកិក្ខុប្រមូលមកនូវសទ្ធិន្ទ្រិយ ដោយអត្ថថាជឿស៊ប់។...ល...។

តេន វុច្ចតិ – "សមត្តញ្ច បដិវិជ្ឈតី"តិ។

ព្រោះហេតុនោះ លោកពោលថា "ចាក់ធ្លុះនូវអត្តនៃការសូប" ។

អដ្ឋ អនុបស្សនេ ញាណានិ អដ្ឋ ច ឧបដ្ឋានានុស្សតិយោ ចត្តារិ សុត្តន្តិកវត្ថូនិ ឯម្ហេសុ ឯម្ហានុបស្សនាយ។

អនុបស្សនាញាណ ៨ ឧបដ្ឋានានុស្សតិ ៨ និងសុត្តន្តិកវត្ថុ ៤ (រមែងមាន) ក្នុង ឯម្ហេសុ ឯម្ហានុបស្សនា ។

ឥមានិ ពាត្តឹស សតោការិស្ស ញាណានិ។

ទាំងនេះឈ្មោះថា សតោការីញាណ ៣២ ប្រការ ។

សតោការិញាណនិទ្ទេសោ បញ្ចមោ។

សតោការីញាណនិទ្ទេសទី ៥ ចប់

បដិនិស្សគ្គានុបស្សី (អដ្ឋកថា)

[១៨២] បដិនិស្សគ្គានុបស្សីបទនិទ្ទេសេ **"រូបំ បរិច្ចជតី"**តិ អាទីនវទស្សនេន និរបេក្ខតាយ រូបក្ខន្ធំ បរិច្ចជតិ។

*នឹងវិនិច្ឆ័យក្នុងនិទ្ទេសនៃបទថា ដោយការពិចារណាឃើញការរលាស់ចោលតទៅ ពាក្យថា **"លះស្រឡះនូវរូប"** គឺរលាស់នូវរូបខន្ធ ព្រោះជាអ្នកមិនមានសម្ងឹងដោយការឃើញទោស។*

"បរិច្ចាគបដិនិស្សគ្គោ"តិ បរិច្ចាគដ្ឋេន បដិនិស្សគ្គោតិ វុត្តំ ហោតិ។

*បទថា **"បរិច្ចាគបដិនិស្សគ្គោ"** ប្រែថា **ការលះបង់ដោយការបរិច្ចាគ** លោកពោលអធិប្បាយថាលះបង់ ដោយការបរិច្ចាគ។*

ឯតេន បដិនិស្សគ្គបទស្ស បរិច្ចាគដ្ឋោ វុត្តោ, តស្មា កិលេសានំ បជហនន្តិ អត្ថោ។

ដោយពាក្យនេះ លោកពោលនូវអត្ថថាបរិច្ចាគ នៃបទថា លះបង់, ព្រោះដូច្នោះ មានសេចក្តីថា ការលះស្រឡះនូវកិលេសទាំងអស់។

ឯត្ថ ច វុដ្ឋានគាមិនី វិបស្សនា កិលេសេ តទង្គវសេន បរិច្ចជតិ, មគ្គោ សមុច្ឆេទវសេន។

*ក្នុងទីនេះ វុដ្ឋានគាមិនីវិបស្សនា រមែងលះបង់កិលេស ដោយអំណាចតទង្គប្បហាន, មគ្គ រមែងលះបង់កិលេស ដោយអំណាច **សមុច្ឆេទ**។*

"រូបនិរោធេ និព្ពានេ ចិត្តំ បក្ខន្ទតី"តិ វុដ្ឋានគាមិនី តំនិន្នតាយ បក្ខន្ទតិ, មគ្គោ អារម្មណករណេន។

*ពាក្យថា **"ចិត្ត រមែងស្ទុះទៅ ក្នុងទីរលត់នៃរូប គឺព្រះនិព្វាន"** សេចក្តីថា វុដ្ឋានគាមិនីវិបស្សនា រមែងស្ទុះទៅ ព្រោះជាធម្មជាតិបង្អោនទៅក្នុងព្រះនិព្វាននោះ, មគ្គរមែងស្ទុះទៅ ដោយការធ្វើឲ្យជាអារម្មណ៍។*

"**បក្ខន្ទនបដិនិស្សគ្គោ**"តិ បក្ខន្ទនដ្ឋេន បដិនិស្សគ្គោតិ វុត្តំ ហោតិ។

*បទថា "**បក្ខន្ទនបដិនិស្សគ្គោ**" ប្រែថា "**ការរលាស់ចោល គឺដោយការស្ទុះទៅ**" លោកពោលអធិប្បាយថា ឈ្មោះថា ការរលាស់ចោល ព្រោះអត្ថថា ដោយការស្ទុះទៅ។*

ឯតេន បដិនិស្សគ្គបទស្ស បក្ខន្ទនដ្ឋោ វុត្តោ, តស្មា ចិត្តស្ស និព្ពានេ វិស្សជ្ជនត្តិ អត្ថោ។

ដោយពាក្យនេះ លោកពោល អត្ថថាដោយការស្ទុះទៅ នៃបទថា បដិនិស្សគ្គ, ព្រោះដូច្នោះ ត្រង់សេចក្តីថា ការលះបង់ចិត្តទៅក្នុងព្រះនិព្វាន ។

ចត្តារិ សុត្តន្តិកវត្ថូនិ ចតុត្ថចតុក្កវសេន វេទិតព្វានិ។

សុត្តន្តិកវត្ថុ ๔ គប្បីជ្រាបដោយអំណាចនៃចតុក្កៈទី ๔ ។

ឥមស្មឹ ចតុក្កេ ជាតមរណោ វត្តព្វំ ហោតិ វុត្តនយេនេវ វេទិតព្វំ។

ពាក្យដែលគួរពោលនៃជាត និងមរណៈក្នុងចតុក្កៈនេះ គប្បីជ្រាបដោយនัยដែលបានពោលមកហើយ ក្នុងនัยខាងដើមនោះឯង ។

សតិបដ្ឋានេសុ ច "កាយេ កាយានុបស្សនា, ចិត្តេ ចិត្តានុបស្សនា"តិ កាយចិត្តានំ ឯកត្តវោហារវសេន ឯកវចននិទ្ទេសោ កតោ។

*ក្នុងសតិប្បដ្ឋាននេះ លោកធ្វើនិទ្ទេសជាឯកវចនៈ ដោយអំណាចឯកត្តវោហានៃកាយ និងចិត្តទាំងឡាយថា "**កាយេ កាយានុបស្សនា, ចិត្តេ ចិត្តានុបស្សនា**" ដូច្នេះ។*

"វេទនាសុ វេទនានុបស្សនា, ធម្មេសុ ធម្មានុបស្សនា"តិ វេទនាធម្មានំ នានត្តវោហារវសេន ពហុវចននិទ្ទេសោ កតោតិ វេទិតព្វោតិ។

*គប្បីជ្រាបថា "លោកធ្វើនិទ្ទេសជាពហុវចនៈ ដោយអំណាចនានត្តវោហារនៃវេទនា និងធម៌ទាំងឡាយថា "**វេទនាសុ វេទនានុបស្សនា, ចិត្តេសុ ចិត្តានុបស្សនា**" ដូច្នេះឯង។*

ចតុត្ថចតុក្កនិទ្ទេសវណ្ណនា និដ្ឋិតា។

ការពណ៌នានិទ្ទេសនៃចតុក្កៈទី ៤ ចប់ ។

និដ្ឋិតា ច សតោការិញ្ញាណនិទ្ទេសវណ្ណនា។

ការពណ៌នា សតោការីញ្ញាណនិទ្ទេស ចប់ ។

๖. ញាណរាសិឆក្កនិទ្ទេសោ

ញាណរាសីនិទ្ទេសលំដាប់ទី ๖

ចតុវីសតិ សមាធិភាវនេន ញាណានិ

ញាណសមាធិមាន ๒๔ ញាណ លំដាប់ទី ๖ (បិដក ๗๐)

[๑๓๐]

[๑๘๓] កតមានិ ចតុវីសតិ សមាធិភាវនេន ញាណានិ?

ញាណទាំង២ប្រាយ ๒๔ ញាណ ដោយអំណាចនៃសមាធិ តើដូចម្តេច?

๑. **ឌីឃំ អស្សាសវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ,**

ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយដោយអំណាចនៃខ្យល់ដង្ហើមចូលវែង ឈ្មោះថា សមាធិ,

๒. **ឌីឃំ បស្សាសវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ។...បេ...។**

ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយដោយអំណាចនៃខ្យល់ដង្ហើមចេញវែង ឈ្មោះថា សមាធិ,

๒๓. **រិមោចយំ ចិត្តំ អស្សាសវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ,**

ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនរាយមាយដោយអំណាចនៃខ្យល់ដង្ហើមចូល របស់បុគ្គលកាលញុំាងចិត្តឲ្យរួច (ចាកកិលេស) ឈ្មោះថា សមាធិ,

๒๔. **រិមោចយំ ចិត្តំ បស្សាសវសេន ចិត្តស្ស ឯកគ្គតា អវិក្ខេបោ សមាធិ។**

ភាពនៃចិត្តមានអារម្មណ៍តែមួយ ដែលមិនវាយមាយដោយអំណាចនៃខ្យល់ដង្ហើមចេញ របស់បុគ្គលកាលញុំាងចិត្តឲ្យរួច(ចាកកិលេស) ឈ្មោះថា សមាធិ ។

ឥមានិ ចតុវីសតិ សមាធិវសេន ញាណានិ។

នេះជាញាណ ២៤ ដោយអំណាចនៃសមាធិ ។

វិធីរាប់ញាណសមាធិទាំង ២៤

(ក្នុងចតុក្កៈទី ១ ជាកាយសតិប្បដ្ឋានមាន ៤ ញាណ ,គុណខ្យល់ចូលនិងចេញស្មើ ៨ ញាណ ។

ក្នុងចតុក្កៈទី ២ ជាវេទនាសតិប្បដ្ឋានមាន ៤ ញាណ ,គុណខ្យល់ចូល និងចេញស្មើ ៨ ញាណ ។

ក្នុងចតុក្កៈទី ៣ ជាចិត្តសតិប្បដ្ឋានមាន ៤ ញាណ ,គុណខ្យល់ចូល និងចេញស្មើ ៨ ញាណ ។ សរុបបាន ២៤ ញាណ ជាញាណសមាធិ) ។

លំដាប់ទី ៧

๗.ទ្វេសត្តតិ វិបស្សនាវសេន ញាណានិ

វិបស្សនាញាណ ៧២ ញាណ លំដាប់ទី ៧

កតមានិ ទ្វេសត្តតិ វិបស្សនាវសេន ញាណានិ?

ញាណទាំងឡាយ ៧២ ប្រការ ដោយអំណាចនៃវិបស្សនា តើដូចម្តេចខ្លះ?

๑. **ឥឃំ អស្បាសំ អនិច្ចតោ អនុបស្សនដ្ឋេន វិបស្សនា,**

ឈ្មោះថា វិបស្សនា ដោយលក្ខណៈឃើញរឿយៗ នូវខ្សល់ដង្ហើមចូលវែង ថាមិនទៀង,

๒. **ទុក្ខតោ អនុបស្សនដ្ឋេន វិបស្សនា,**

ឈ្មោះថា វិបស្សនា ដោយលក្ខណៈឃើញរឿយៗ នូវខ្សល់ដង្ហើមចូលវែង ថាជាទុក្ខ,

๓. **អនត្តតោ អនុបស្សនដ្ឋេន វិបស្សនា,**

ឈ្មោះថា វិបស្សនា ដោយលក្ខណៈឃើញរឿយៗ នូវខ្សល់ដង្ហើមចូលវែង ថាជាអនត្តា,

๔. **ឥឃំ បស្បាសំ អនិច្ចតោ អនុបស្សនដ្ឋេន វិបស្សនា,**

ឈ្មោះថា វិបស្សនា ដោយលក្ខណៈឃើញរឿយៗនូវខ្សល់ដង្ហើមចេញវែង ថាមិនទៀង,

๔. **ទុក្ខតោ អនុបស្សនដ្ឋេន វិបស្សនា,**

ឈ្មោះថា វិបស្សនា ដោយលក្ខណៈឃើញរឿយៗ នូវខ្សល់ដង្ហើមចេញ

វែង ថាជាទុក្ខ,

៦. អនត្តតោ អនុបស្សនដ្ឋេន វិបស្សនា។...បេ...។

ឈ្មោះថា វិបស្សនា ដោយលក្ខណៈឃើញរឿយៗ នូវខ្យល់ដង្ហើមចេញ វែង ថាជាអនត្តា។...ល...។

៦៧. វិមោចយំ ចិត្តំ អស្សាសំ,

ឈ្មោះថា វិបស្សនា ដោយលក្ខណៈឃើញរឿយៗ របស់បុគ្គលកាលញុំងចិត្តឲ្យរួច ដកដង្ហើមចូល ថាមិនទៀង,

៦៨. វិមោចយំ ចិត្តំ បស្សាសំ អនិច្ចតោ អនុបស្សនដ្ឋេន វិបស្សនា,

ឈ្មោះថា វិបស្សនា ដោយលក្ខណៈឃើញរឿយៗ របស់បុគ្គលកាលញុំងចិត្តឲ្យរួច ដកដង្ហើមចេញ ថាមិនទៀង,

៦៩. ៧០. ទុក្ខតោ អនុបស្សនដ្ឋេន វិបស្សនា,

ឈ្មោះថា វិបស្សនា ដោយលក្ខណៈឃើញរឿយៗ របស់បុគ្គលកាលញុំងចិត្តឲ្យរួច ដកដង្ហើមចូល ថាជាទុក្ខ,
ឈ្មោះថា វិបស្សនា ដោយលក្ខណៈឃើញរឿយៗ របស់បុគ្គលកាលញុំងចិត្តឲ្យរួច ដកដង្ហើមចេញ ថាជាទុក្ខ,

៧១. ៧២. អនត្តតោ អនុបស្សនដ្ឋេន វិបស្សនា។

ឈ្មោះថា វិបស្សនា ដោយលក្ខណៈឃើញរឿយៗ របស់បុគ្គលកាលញុំងចិត្តឲ្យរួច ដកដង្ហើមចូល ថាជាអនត្តា ។

ឈ្មោះថា វិបស្សនា ដោយលក្ខណៈឃើញរឿយៗ របស់បុគ្គលកាលញុំងចិត្តឲ្យរួច ដកដង្ហើមចេញ ថាជាអនត្តា ។

ឥមានិ ទ្វេសត្តតិ វិបស្សនាវសេន ញាណានិ។

នេះជាញាណ ៧២ ប្រការ ដោយអំណាចនៃវិបស្សនា ។

វិធីរាប់វិបស្សនាញាណ ៧២

(ក្នុងចតុក្ក:ទី ១ ជាកាយានុបស្សនាសតិប្បដ្ឋានមាន ៤ ញាណ ,គុណនិងខ្យល់ចូល និងខ្យល់ចេញ,និងគុណអនិច្ចតោ.ទុក្ខតោ.អនត្តតោ ស្មើ ២៤ ញាណ ។

ក្នុងចតុក្ក:ទី ២ ជាវេទនានុបស្សនាសតិប្បដ្ឋានមាន ៤ ញាណ ,គុណខ្យល់ចូល និងខ្យល់ចេញ,និងគុណអនិច្ចតោ.ទុក្ខតោ.អនត្តតោ ស្មើ ២៤ ញាណ ។

ក្នុងចតុក្ក:ទី ៣ ជាចិត្តានុបស្សនាសតិប្បដ្ឋានមាន ៤ ញាណ ,គុណខ្យល់ចូល និងខ្យល់ចេញ,និងគុណអនិច្ចតោ.ទុក្ខតោ.អនត្តតោ ស្មើ ២៤ ញាណ) ។
សរុបបាន ២៤ ញាណ គុណ ៣ ស្មើ ៧២ វិបស្សនាញាណ ។

លំដាប់ទី ៨

៨.អដ្ឋ និព្វិទាញ្ញាណានិ

ញាណដែលនឿយណាយក្នុងសង្ខារធម៌មាន ៨ ញាណ

កតមានិ អដ្ឋ និព្វិទាញ្ញាណានិ?

ញាណដែលនឿយណាយក្នុងសង្ខារធម៌ទាំងឡាយមាន ៨ ញាណ តើដូចម្តេច?

១. អនិច្ចានុបស្សី អស្សាសំ យថាភូតំ ជាតាតិ បស្សតីតិ និព្វិទាញ្ញំ,

ឈ្មោះថា និព្វិទាញាណ ព្រោះហេតុដឹង ហេតុឃើញ តាមការពិត នូវខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញរឿយៗថា មិនទៀង,

២. អនិច្ចានុបស្សី បស្សាសំ យថាភូតំ ជាតាតិ បស្សតីតិ និព្វិទាញ្ញំ។...បេ...។

*ឈ្មោះថា **និព្វិទាញ្ញា** ព្រោះហេតុដឹង ហេតុឃើញ តាមការពិត នូវខ្យល់ដង្ហើមចេញ របស់បុគ្គលអ្នកពិចារណាឃើញរឿយៗថា មិនទៀង ។...ល...។*

៧. បដិនិស្សគ្គានុបស្សី អស្សាសំ យថាភូតំ ជាតាតិ បស្សតីតិ និព្វិទាញ្ញំ,

*ឈ្មោះថា **និព្វិទាញ្ញា** ព្រោះហេតុដឹង ហេតុឃើញ តាមការពិត នូវខ្យល់ដង្ហើមចូល របស់បុគ្គលអ្នកពិចារណាឃើញរឿយៗ នូវការលាស់ចោល,*

៨. បដិនិស្សគ្គានុបស្សី បស្សាសំ យថាភូតំ ជានាតិ បស្សតីតិ និព្វិទាញាណំ។

ឈ្មោះថា **និព្វិទាញាណ** *ព្រោះហេតុដឹង ហេតុឃើញ តាមការពិត នូវខ្យល់ដង្ហើមចេញ របស់បុគ្គលអ្នកពិចារណាឃើញរឿយៗ នូវការរលាស់ចោល ។*

ឥមានិ អដ្ឋ និព្វិទាញាណានិ។

នេះ គឺជា **និព្វិទាញាណ** *ទាំង៨ប្រាយ ៨ យ៉ាង ។*

វិធីរាប់និព្វិទាញាណ ៨ យ៉ាង

(នេះធម្មាសតិប្បដ្ឋានក្នុងចតុក្កៈទី ៤. មាន ៤ ញាណ គុណនិងខ្យល់ចូលខ្យល់ចេញ ស្មើ ៨ ញាណ ហៅថា និព្វិទាញាណ ៨ យ៉ាង) ។

លំដាប់ទី ៩

៩.អដ្ឋ និព្វិទានុលោមេ ញាណានិ

ញាណពិចារណាឃើញសង្ខារស្របតាមនិព្វិទាញាណមាន ៨ ញាណ

កតមានិ អដ្ឋ និព្វិទានុលោមេ ញាណានិ?

និព្វិទានុលោមញាណ *៨ យ៉ាង តើដូចម្តេច?*

១. អនិច្ចានុបស្សី អស្សាសំ កយតុបដ្ឋានេ បញ្ញា និព្វិទានុលោមេ ញាណំ,

បញ្ញាក្នុងការច្រាកដ ដោយភាពជារបស់គួរភ័យ របស់យោគីកិក្ខុអ្នក

ពិចារណាឃើញរឿយៗថា មិនទៀង ដកដង្ហើមចូល ឈ្មោះថា និព្វិទានុលោមញាណ ,

២. អនិច្ចានុបស្សី បស្សាសំ កយតុបដ្ឋានេ បញ្ញា និព្វិទានុលោមេ ញាណំ។...បេ...។

បញ្ញាក្នុងការច្រាកដ ដោយភាពជារបស់គួរភ័យ របស់យោគីកិក្ខុអ្នក ពិចារណាឃើញរឿយៗថា មិនទៀង ដកដង្ហើមចេញ ឈ្មោះថា និព្វិទានុលោមញាណ *។...ល...។*

៧. បដិនិស្សគ្គានុបស្សី អស្សាសំ កយតុបដ្ឋានេ បញ្ញា និព្វិទានុលោមេ ញាណំ,

បញ្ញាក្នុងការច្រាកដ ដោយភាពជារបស់គួរភ័យ របស់យោគីកិក្ខុអ្នក ពិចារណាឃើញរឿយៗ នូវការរលាស់ចោល ដកដង្ហើមចូល ឈ្មោះថា

និព្វិទានុលោមញាណ ,

៨. បដិនិស្សគ្គានុបស្សី បស្សាសំ ភយតុបដ្ឋានេ បញ្ញា និព្វិទានុលោ-
មេ ញាណំ,

*បញ្ញាក្នុងការជ្រាកដ ដោយភាពជារបស់គួរភ័យ របស់យោគីកិក្ខុអ្នក
ពិចារណាឃើញរឿយៗ នូវការរលាស់ចោល ដកដង្ហើមចេញ ឈ្មោះថា*
និព្វិទានុលោមញាណ ,

ឥមានិ អដ្ឋ និព្វិទានុលោមេ ញាណានិ។

នេះ គឺជា **និព្វិទានុលោមញាណ** *ទាំង៨ប្រាយ ៨ យ៉ាង ។*

*(ក្នុងធម្មាសតិប្បដ្ឋាននេះ ជាចតុក្ក:ទី ៤ និងមាន ៤ ចំណុច ហើយគុណ
និង ខ្យល់ចូល ខ្យល់ចេញ ស្មើ ៨ និព្វិទានុលោមញាណ) ។*

ឈំដាប់ទី ១០

១០.អដ្ឋ និព្វិទាបដិប្បស្សទ្ធិញ្ញាណ

ញ្ញាណដឹងក្នុងការនឿយណាយមាន ៨ ញ្ញាណ ឈំដាប់ទី ១០

កតមានិ អដ្ឋ និព្វិទាបដិប្បស្សទ្ធិញ្ញាណានិ?

និព្វិទាបដិប្បស្សទ្ធិញ្ញាណ *(ញ្ញាណដឹងក្នុងការនឿយណាយ និងការស្ងប់រម្ងាប់)* ៨ យ៉ាង តើដូចម្តេច?

១. **អនិច្ចានុបស្សី អស្សាសំ បដិសង្ខា សន្តិដ្ឋតា បញ្ញា និព្វិទាបដិប្បស្សទ្ធញ្ញាណំ,**

បញ្ញា គឺការពិចារណារកផ្លូវស្ងប់ របស់យោគីកិក្ខុអ្នកពិចារណាឃើញរឿយៗ ថា ជារបស់មិនទៀង ដកដង្ហើមចូល ឈ្មោះថា **និព្វិទាបដិប្បស្សទ្ធិញ្ញាណ,**

២. **អនិច្ចានុបស្សី បស្សាសំ បដិសង្ខា សន្តិដ្ឋតា បញ្ញា និព្វិទាបដិប្បស្សទ្ធិញ្ញាណំ។...បេ...។**

បញ្ញា គឺការពិចារណារកផ្លូវស្ងប់ របស់យោគីកិក្ខុអ្នកពិចារណាឃើញរឿយៗ ថា ជារបស់មិនទៀង ដកដង្ហើមចេញ ឈ្មោះថា **និព្វិទាបដិប្បស្សទ្ធិញ្ញាណ។.ល.។**

៧. **បដិនិស្សគ្គានុបស្សី អស្សាសំ បដិសង្ខា សន្តិដ្ឋតា បញ្ញា និព្វិទាបដិប្បស្សទ្ធិញ្ញាណំ,**

បញ្ញា គឺការពិចារណារកផ្លូវស្ងប់ របស់យោគីកិក្ខុអ្នកពិចារណាឃើញរឿយៗ នូវការរលាស់ចោល ដកង្ហើមចូល ឈ្មោះថា **និព្វិទាបដិប្បស្សទ្ធិញ្ញាណ,**

๘. បដិនិស្សគ្គានុបស្សី បស្សាសំ បដិសង្ខា សន្តិដ្ឋតា បញ្ញា និព្វិទា-បដិប្បស្សទ្ធិញាណំ។

បញ្ញា គឺការពិចារណារកផ្លូវសូប់ របស់យោគីភិក្ខុអ្នកពិចារណាឃើញរឿយៗ នូវការរលាស់ចោល ដកដើមចេញ ឈ្មោះថា **និព្វិទាបដិប្បស្សទ្ធិញាណ**។

ឥមានិ អដ្ឋ និព្វិទាបដិប្បស្សទ្ធិញាណានិ។

នេះ ជា **និព្វិទាបដិប្បស្សទ្ធិញាណ** *៨ យ៉ាង*។

លំដាប់ទី ១១

១១.ឯកាទសតិ វិមុត្តិសុខេ ញាណានិ

វិមុត្តិសុខញ្ញាណ ២១ យ៉ាង លំដាប់ទី ១១

កតមានិ ឯកាទសតិ វិមុត្តិសុខេ ញាណានិ?

វិមុត្តិសុខញ្ញាណទាំងឡាយមាន ២១ យ៉ាង តើដូចម្តេច?

សោតាបត្តិមគ្គ លះបាន ៥ យ៉ាង

១. សោតាបត្តិមគ្គេន សក្កាយទិដ្ឋិយា បហីនត្តា សមុច្ឆិន្នត្តា ឧប្បជ្ជតិ វិមុត្តិសុខេ ញាណំ,

ព្រោះព្រះសោតាបត្តិមគ្គ លោកលះបង់សក្កាយទិដ្ឋិ បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ។

២. វិចិកិច្ឆាយ បហីនត្តា សមុច្ឆិន្នត្តា ឧប្បជ្ជតិ វិមុត្តិសុខេ ញាណំ,

ព្រោះព្រះសោតាបត្តិមគ្គ លោកលះបង់នូវវិចិកិច្ឆា បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ។

៣. សីលព្វតបរាមាសស្ស។...បេ...។

ព្រោះព្រះសោតាបត្តិមគ្គ លោកលះបង់នូវសីលព្វតបរាមាសៈ បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ។

៤. ទិដ្ឋានុសយស្ស,

ព្រោះព្រះសោតាបត្តិមគ្គ លោកលះបង់នូវទិដ្ឋានុសយៈ បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ។

๔. វិចិកិច្ឆានុសយស្ស បហីនត្តា សមុច្ឆិន្នត្តា ឧប្បជ្ជតិ វិមុត្តិសុខេ ញាណំ,

ព្រោះព្រះសោតាបត្តិមគ្គ លោកលះបង់នូវវិចិកិច្ឆានុសយៈ បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

សកទាគាមិមគ្គ លះបាន ๔ យ៉ាង

๖. សកទាគាមិមគ្គេន ឱឌ្ឍារិកស្ស, កាមរាគសញ្ញោជនស្ស។...បេ...។

ព្រោះព្រះសកទាគាមិមគ្គ លោកលះបង់នូវកាមរាគសញ្ញោជនៈ ចំណែកដែលគ្រោតគ្រាត បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

๗. បដិឃសញ្ញោជនស្ស,

ព្រោះព្រះសកទាគាមិមគ្គ លោកលះបង់នូវបដិឃសញ្ញោជនៈ ចំណែកដែលគ្រោតគ្រាត បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

๘. ឱឌ្ឍារិកស្ស កាមរាគានុសយស្ស,

ព្រោះព្រះសកទាគាមិមគ្គ លោកលះបង់នូវកាមរាគានុសយៈ ចំណែកដែលគ្រោតគ្រាត បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

๙. បដិឃានុសយស្ស បហីនត្តា សមុច្ឆិន្នត្តា ឧប្បជ្ជតិ វិមុត្តិសុខេ ញាណំ,

ព្រោះព្រះសកទាគាមិមគ្គ លោកលះបង់នូវបដិឃានុសយៈ ចំណែកដែលគ្រោតគ្រាត បានផ្តាច់ផ្តិលជាសមុច្ឆេទហើយ រមែងកើតនូវញាណ

ក្នុងវិមុត្តិសុខ ។

អនាគាមិមគ្គ លះបាន ៤ យ៉ាង

១០. **អនាគាមិមគ្គេន អនុសហគតស្ស កាមរាគសញ្ញោជនស្ស។...បេ...។**

ព្រោះព្រះអនាគាមិមគ្គ លោកលះបង់នូវកាមរាគសញ្ញោជន: ចំណែកដែលល្អិតហ្មត់ហ្មង បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

១១. **បដិឃសញ្ញោជនស្ស,**

ព្រោះព្រះអនាគាមិមគ្គ លោកលះបង់នូវបដិឃសញ្ញោជន: ចំណែកដែលល្អិតហ្មត់ហ្មង បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

១២. **អនុសហគតស្ស កាមរាគានុសយស្ស,**

ព្រោះព្រះអនាគាមិមគ្គ លោកលះបង់នូវកាមរាគានុសយ: ចំណែកដែលល្អិតហ្មត់ហ្មង បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

១៣. **បដិឃានុសយស្ស បហីនត្តា សមុច្ឆិន្នត្តា ឧប្បជ្ជតិ វិមុត្តិសុខេ ញាណំ,**

ព្រោះព្រះអនាគាមិមគ្គ លោកលះបង់នូវបដិឃានុសយ: ចំណែកដែលល្អិតហ្មត់ហ្មង បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

អរហត្តមគ្គ លះបាន ៨ យ៉ាង

១៤. **អរហត្តមគ្គេន, រូបរាគស្ស។...បេ...។**

ព្រោះព្រះអរហត្តមគ្គ លោកលះបង់នូវរូបរាគៈ បានផ្តាច់ផ្តិលដាច់ខាត ហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

๑๔. **អរូបរាគស្ស,**

ព្រះអរហត្តមគ្គ លោកលះបង់នូវអរូបរាគៈ បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

๑๖. **មានស្ស,**

ព្រះអរហត្តមគ្គ លោកលះបង់នូវមានៈ បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

๑๗. **ឧទ្ធច្ចស្ស,**

ព្រះអរហត្តមគ្គ លោកលះបង់នូវឧទ្ធច្ចៈ បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

๑๘. **អវិជ្ជាយ,**

ព្រះអរហត្តមគ្គ លោកលះបង់នូវអវិជ្ជា បានផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

๑๙. **មានានុសយស្ស,**

ព្រះអរហត្តមគ្គ លោកលះបង់នូវមានានុសយៈ បានផ្តាច់ផ្តិលដាច់ខាត ហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

๒๐. **ភវរាគានុសយស្ស,**

ព្រះអរហត្តមគ្គ លោកលះបង់នូវភវរាគានុសយៈ បានផ្តាច់ផ្តិលដាច់ខាត ហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

๒๑. **អវិជ្ជានុសយស្ស បហីនត្តា សមុច្ឆិន្នត្តា ឧប្បជ្ជតិ វិមុត្តិសុខេ**

ញាណំ។

ព្រះអរហត្តមគ្គ លោកលះបង់នូវអវិជ្ជានុសយ: បានកាត់ផ្តាច់ផ្តិលដាច់ខាតហើយ រមែងកើតនូវញាណក្នុងវិមុត្តិសុខ ។

ឥមានិ ឯកវីសតិ វិមុត្តិសុខេ ញាណានិ។

នេះជាញាណទាំងឡាយក្នុងវិមុត្តិសុខមាន ២១ យ៉ាង ។

សោឧ្យសវត្ថុកំ អានាចានស្សតិសមាធឺ ភាវយតោ សមធិកានិ ឥមានិ ឧ្ទេ ញាណសតានិ ឧប្បជ្ជន្តិ។

យោគីភិក្ខុកាល ចម្រើននូវអានាបានស្សតិសមាធិ ដែលមានវត្ថុ(គឺរឿង) ១៦ រមែងកើតនូវញាណ ២២០ នេះ ។

ញាណរាសិធក្កនិឧ្ទេសោ ធជ្ជោ។

ញាណរាសីធក្កនិទ្ទេសទី ៦ ចប់ ។

បដិសម្ភិជាមត្តេ អានាចានស្សតិកថា វណ្ណនា[៨៥]និដ្ឋិតា។

ការពណ៌នាអានាបានស្សតិកថាក្នុងបដិសម្ភិទាមគ្គ ចប់ ។

---

៨៥ ស្យា. ក. អានាបានកថា ។

๖. ញាណរាសិឆក្កនិទ្ទេសវណ្ណនា (អដ្ឋកថា)

ការពណ៌នារាសីឆក្កនិទ្ទេស

[๑๘๓] ឥទានិ ឆហិ រាសីហិ ឧទ្ធិដ្ឋញ្ញាណេសុ ចតុវីសតិសមាធិញ្ញាណនិទ្ទេសេ តាវ កាយានុបស្សនាឌីនំ តិណ្ណំ ចតុក្កានំ វសេន ទ្វាទសន្នំ វត្ថូនំ ឯកេកស្មឹ អស្សាសវសេន ឯកោ, បស្សាសវសេន ឯកោតិ ទ្វេ ទ្វេ សមាធីតិ ទ្វាទសសុ វត្ថូសុ ចតុវីសតិ សមាធយោ ហោន្តិ។

ក្នុងកាលឥឡូវនេះ នឹងវិនិច្ឆ័យក្នុងនិទ្ទេសនៃញាណដោយអំណាចនៃសមាធិ ๒๔ ក្នុងបណ្តាញាណដែលលើកមកសម្តែងហើយ ដោយជាក្រុមៗ ๖ ដោយអំណាចជាចតុក្ក: ๓ មានកាយានុបស្សនាជាដើមមុនសិន បណ្តាវត្ថុ ๑๒ តែម្យ៉ាងៗ មានសមាធិមួយយ៉ាង ដោយអំណាចខ្យល់ដង្ហើមចូល, មានសមាធិមួយយ៉ាង ដោយអំណាចខ្យល់ដង្ហើមចេញ រួមគ្នាទៅជាសមាធិ ๒ យ៉ាង ទើបទៅជាសមាធិ ๒๔ ក្នុងវត្ថុ ๑๒ យ៉ាង ។

ឈានក្ខណេ តេហិ សម្បយុត្តានិ ចតុវីសតិសមាធិវសេន ញាណានិ។

ញាណទាំងឡាយដោយអំណាចសមាធិ ๒๔ ដែលសម្បយុត្តដោយសមាធិទាំងនោះ ក្នុងខណៈនៃញាណ ។

ទ្វាសត្តតិវិបស្សនាញាណនិទ្ទេសេ"**ឌីឃំ អស្សាសា**"តិ "ឌីឃ"ន្តិ វុត្តអស្សាសតោ។

*នឹងវិនិច្ឆ័យក្នុងនិទ្ទេសដែលថា ដោយវិបស្សនាញាណ ๗๒ ពាក្យថា "**ខ្យល់ដង្ហើមចូលវែង**" បានដល់ ខ្យល់ដង្ហើមចូលដែលលោកពោលថា "វែង" ។*

កឹ វុត្តំ ហោតិ?

តើមានពាក្យអធិប្បាយ ដូចម្តេច ?

ឥតិ អស្សាសហេតុ ឈានំ បដិលភិត្វា សមាហិតេន ចិត្តេន វិបស្សនាក្ខណេ អនិច្ចតោ អនុបស្សន្តេន វិបស្សនាតិ វុត្តំ ហោតិ។

មានពាក្យអធិប្បាយថា បានដល់ ការដែលបាននូវឈានហើយ ព្រោះហេតុនៃខ្យល់ដង្ហើមចូលវែង មានចិត្តជាសមាធិ ឃើញច្បាស់ ដោយអត្តថាពិចារណាឃើញ ដោយសេចក្តីជារបស់មិនទៀង ក្នុងខណៈនៃវិបស្សនា ។

ឯស នយោ ឧត្តរត្រាបិ។

សូម្បីក្នុងបទទៅខាងមុខក៏មានន័យបែបនេះ ។

តេសំយេវ ទ្វាទសន្នំ វត្ថូនំ ឯកេកស្មឹ អស្សាសវសេន តិស្សោ, បស្សាសវសេន តិស្សោតិ ឆ ឆ អនុបស្សនាតិ ទ្វាទសសុ វត្ថូសុ ទ្វាសត្ততិ អនុបស្សនា ហោន្តិ។

ការពិចារណាឃើញមាន ៧២ យ៉ាង ក្នុងវត្ថុ ១២ គឺ អនុបស្សនា មួយយ៉ាងៗមាន ៦ៗ គឺដោយអំណាចខ្យល់ដង្ហើមចូលមាន ៣ និងដោយអំណាចខ្យល់ដង្ហើមចេញមាន ៣ ក្នុងវត្ថុមួយយ៉ាងៗ បណ្តាវត្ថុ ១២ ទាំងនោះនុ៎ះឯង ។

តា ឯវ ទ្វាសត្ততិ អនុបស្សនា ទ្វាសត្ততិវិបស្សនាវសេន ញាណានិ។

អនុបស្សនា *៧២ ទាំងនោះ ឈ្មោះថា* **ញាណ** *ដោយអំណាចវិបស្សនា ៧២ ។*

និទ្ទិដ្ឋាញាណនិទ្ទេសេ "*អនិច្ចានុបស្សី អស្សាសន្តិ*" អនិច្ចានុបស្សី ហុត្វា អស្សសន្តោ, អនិច្ចានុបស្សី ហុត្វា វត្តេន្តោតិ អត្ថោ។

នឹងវិនិច្ឆ័យក្នុងនិទ្ទេសថា **និទ្ទិដ្ឋាញាណ** *ដូចតទៅ ពាក្យថា "* ***ពិចារណាឃើញរឿយៗថា មិនទៀង ខណៈដកដង្ហើមចូល***" *មានសេចក្តីថា ជាអ្នក*

ពិចារណាឃើញរឿយៗ ជារបស់មិនទៀង ខណ:ដកដង្ហើមចូល, សេចក្តីថា ជាអ្នកពិចារណាឃើញរឿយៗ ប្រព្រឹត្តិទៅជារបស់មិនទៀង ។

"**អស្សាស**"ន្តិ ច ឥទំ វចនំ ហេតុអត្ថេ ឧដ្ឋញ្ចំ។

*ពាក្យថា "**អស្សាសំ**" ប្រែថា "ដកដង្ហើមចូល" នេះ បណ្ឌិតគប្បីឃើញក្នុងអត្ថនៃហេតុ។*

"**យថាភូតំ ជានាតិ បស្សតីតិ និព្វិទាញាណ**"ន្តិ ភាលាបសម្ទស-នតោ បដ្ឋាយ យាវ ភង្គានុបស្សនា បវត្តវិបស្សនាញាណេន សង្ខារានំ យថាសភាវំ ជានាតិ, ចក្ខុនា ឧដ្ឋមិវ ច តេនេវ ញាណចក្ខុនា បស្សតិ។

ពាក្យថា "ឈ្មោះថា **និព្វិទាញាណ** ***ព្រោះហេតុដឹង ហេតុឃើញ តាមការពិត"*** *សេចក្តីថា ដឹងនូវសភាវ:តាមការពិតនៃសង្ខារទាំងឡាយ ដោយវិបស្សនាញាណ ដែលប្រព្រឹត្តទៅតាំងតែពិចារណានូវរូបកលាប: រហូតដល់* **ភង្គានុបស្សនា**, *និងការឃើញដោយបញ្ញាចក្ខុនោះ ដូចជាឃើញដោយចក្ខុ ។*

តស្មា និព្វិទាញាណំ នាមាតិ អត្ថោ, សង្ខារេសុ និព្វិទាញាណំ នាមាតិ វុត្តំ ហោតិ។

ព្រោះហេតុនោះ ទើបឈ្មោះថា **និព្វិទាញាណ**, *មានពាក្យអធិប្បាយថា ឈ្មោះថា* **និព្វិទាញាណ** *គឺជាញាណនឿយណាយក្នុងសង្ខារទាំងឡាយ ។*

ឧបរិ ភយតូបដ្ឋានាទីនំ មុញ្ចិតុកម្យតាទីនញ្ច ញាណានំ វិសុំ អាភតត្តា ឥធ យថាវុត្តានេវ វិបស្សនាញាណានិ និព្វិទាញាណានីតិ វេទិតព្វានិ។

វិបស្សនាញាណតាមដែលបានពោលមកហើយ ក្នុងទីនេះ នុ៉ះឯង គប្បីជ្រាបថា ឈ្មោះថា **និព្វិទាញាណ** *ព្រោះជាញាណមានភយតូបដ្ឋាន ជាដើម*

និងមាន **មុញ្ចិតុកម្យតាញាណា** *ជាដើម មកហើយមួយផ្នែកតទៅ។*
និព្វិទាឧលោមញាណនិទ្ទេសេ "អនិច្ចានុបស្សី អស្សស"ន្តិ អនិច្ចានុបស្សិនោ អស្សសន្តស្ស។

នឹងវិនិច្ឆ័យក្នុងនិទ្ទេសថា **និព្វិទាឧលោមញាណា** *បទថា* ***"អនិច្ចានុបស្សី អស្សសំ"*** *ប្រែថា* ***"ពិចារណាឃើញរឿយៗដោយភាពជារបស់មិនទៀង ដកដង្ហើមចូល"*** *បានសេក្តីថា ជាអ្នកបានពិចារណាឃើញរឿយៗ ដោយភាពជារបស់មិនទៀង ដកដង្ហើមចូល។*

សាមិអត្ថេ បច្ចត្តវចនំ។

បទថា ***អស្សសំ*** *នេះ ជាបឋមាវិភត្តិ ដែលចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ។*

"ភយតុបដ្ឋានេ បញ្ញា"តិវចនេនេវ ភយតុបដ្ឋានអាទីនវានុបស្សនា និព្វិទានុបស្សនាញាណានិ វុត្តានិ ហោន្តិ តិល្លំ្ហ ឯកលក្ខណត្តា។

ពាក្យថា "បញ្ញាក្នុងការជ្រាកដ ដោយភាពជារបស់គួរភ័យ" នោះឯង ជាការដែលលោកពោលដល់ **ភយតុបដ្ឋានញាណា អាទីនវានុបស្សនាញាណា** *និងនិព្វិទានុបស្សនាញាណា ព្រោះញាណទាំង ៣ យ៉ាងនេះ មានលក្ខណៈដូចតែគ្នា។*

ឥមានិ តីណិ ញាណានិ អនន្តរា វុត្តានំ និព្វិទាញាណានំ អនុកូលភាវេន អនុលោមតោ និព្វិទានុលោមញាណានីតិ វុត្តានិ។

ញាណទាំងឡាយ ៣ នេះ លោកពោលថា ឈ្មោះថា **និព្វិទានុលោមញាណា** *ព្រោះអនុលោមដោយភាវៈជាអនុកូលដល់និព្វិទាញាណ ដែលលោកបានពោលទុកដោយមិនមានចន្លោះៗ។*

និព្វិទាបដិប្បស្សទ្ធិញាណនិទ្ទេសេ "អនិច្ចានុបស្សី អស្សស"ន្តិ អនន្តរសទិសមេវ។

នឹងវិនិច្ឆ័យក្នុងនិទ្ទេស និព្វិទាបដិប្បស្សទ្ធិញាណ *តទៅ ពាក្យថា "ពិចារណាឃើញរឿយៗ នូវភាពជារបស់មិនទៀង ដកដង្ហើមចូល" ដូចគ្នាក្នុងលំដាប់នោះឯង ។*

"បដិសង្ខា សន្តិដ្ឋនា បញ្ញា" តិវចនេនេវ មុញ្ចិតុកម្យតាបដិ-សង្ខានុបស្សនាសង្ខារុបេក្ខាញាណានិ វុត្តានិ ហោន្តិ តិណ្ណំ ឯកលក្ខណត្តា។

*ពាក្យថា "**បញ្ញា គឺការពិចារណារកផ្ទូវសូប់**" ជាការដែលលោកពោលដល់* មុញ្ចិតុកម្យតាញាណ បដិសង្ខានុបស្សនាញាណ *និង* សង្ខារុបេក្ខា-ញាណ *ព្រោះញាណទាំង ៣ នេះ មានលក្ខណៈដូចតែគ្នា ។*

"បដិសង្ខា សន្តិដ្ឋនា" តិវចនេនេវ អនុលោមញាណមក្តញាណា-និបិ តហិតានិ ហោន្តិ ។

ពាក្យថា "ការពិចារណារកផ្ទូវសូប់" នោះឯង ជាការដែលលោកពោលយកនូវ សូម្បី អនុលោមញាណ *និង* មក្តញាណ *។*

សង្ខារុបេក្ខាញាណអនុលោមញាណានិបិ ហិ និព្វិទាយ សិទ្ធាប្បត្តត្តា និព្វិទាជនន ព្យាធារប្បហានេន និព្វិទាបដិប្បស្សទ្ធិ-ញាណានិ នាម ហោន្តិ។

សូម្បី សង្ខារុបេក្ខាញាណ *និង* អនុលោមញាណ *រមែងមានឈ្មោះ ថាជា*និព្វិទាបដិប្បស្សទ្ធិញាណ *ដោយការញុាំង* និព្វិទាញាណ *ឲ្យ កើតឡើង និងការលះភាពខ្ទល់ខ្ទាយ ព្រោះនិព្វិទាញាណបានដល់កំពូលហើយ។*

មក្តញាណំ បន និព្វិទាបដិប្បស្សទ្ធន្តេ ឧប្បជ្ជនតោ និព្វិទាបដិប្ប-ស្សទ្ធិញាណំ នាម ហោតីតិ អតិវិយ យុជ្ជតីតិ។

ចំណែក **មគ្គញាណ** *រមែងមានឈ្មោះថាជា* **និព្វិទាបដិប្បស្សទ្ធិ-ញាណ** *ព្រោះកើតឡើងក្នុងទីបំផុតនៃការរម្ងាប់ដោយនិព្វិទា (***និព្វិទាបដិប្ប-ស្សទ្ធិញាណ***) ព្រោះដូច្នោះ រមែងសមគួរដ៏ក្រៃលែងដោយប្រការយ៉ាងនេះឯង ។*

និព្វិទានុលោមញ្ញាណេសុ វិយ អាធិភូតំ មុញ្ចិតុកម្យតាញ្ញាណំ អត្តហោតិ ''បដិសង្ខា សន្តិដ្ឋនា''តិ អន្តេ ញាណទ្វយត្តហាណំ មគ្គញ្ញាណសង្គហាណត្តំ។

លោកមិនបានកាន់យក **មុញ្ចិតុកម្យតាញ្ញាណ** *ដែលជាខាងដើម ដូចជាក្នុង* **និព្វិទានុលោមញ្ញាណ** *ហើយកាន់យកញ្ញាណទាំង ២ ក្នុងទីបំផុត ថា "ការពិចារណារកផ្លូវសូប៌" ដូច្នេះ ដើម្បីជាការសង្គ្រោះនូវ* **មគ្គញ្ញាណ** *។*

មុញ្ចិតុកម្យតាតិ ហិ វុត្តេ អនុលោមញ្ញាណំ សង្គយ្ហតិ, ន មគ្គញ្ញាណំ។

កាលពោលថា **មុញ្ចិតុកម្យតាញ្ញាណ** *លោករមែងសង្គ្រោះនូវ* **អនុលោមញ្ញាណ**, *មិនមែនសង្គ្រោះ* **មគ្គញ្ញាណ** *។*

មគ្គញ្ញាណញ្ហិ មុញ្ចិតុកម្យតា ជាម ន ហោតិ, កិច្ចសិទ្ធិយំ សន្តិដ្ឋនតោ បន សន្តិដ្ឋនា ជាម ហោតិ។

ព្រោះមគ្គញ្ញាណ មិនឈ្មោះថា ជាមុញ្ចិតុកម្យតា, ប៉ុន្តែ ព្រោះភាពស្ងប់ក្នុងការសម្រេចកិច្ច ទើបឈ្មោះថា ជាសន្តិដ្ឋនា ប្រែថា ភាពស្ងប់ ។

អដ្ឋកថាយម្បិ ច "ផុសនាតិ អប្បនា"តិ វុត្តំ។

សូម្បីក្នុងអដ្ឋកថាលោកក៏ពោលថា "ពាក្យថា ការពាល់ត្រូវ បានដល់ ការអែបនែប ឬអែបស៊ប់ (អប្បនា)" ។

ឥធញ្ច មគ្គញ្ញាណំ និព្វានេ អប្បនាតិ កត្វា សន្តិដ្ឋនា ជាម

ហោតីតិ "**សន្តិដ្ឋនា**"តិវចនេន មគ្គញាណម្បិ សង្គយ្ហតិ។

*មគ្គញាណនេះ ឈ្មោះថា ជា**សន្តិដ្ឋនា** (ភាពស្ងប់) ព្រោះថា ជា**អប្បនា** ក្នុងព្រះនិព្វាន ព្រោះហេតុនោះ លោកទើបសង្គ្រោះសូម្បី **មគ្គញាណ** ដោយពាក្យថា "**សន្តិដ្ឋនា**" ប្រែថា ភាពស្ងប់ ។*

និព្វិទានុលោមញាណានិបិ អត្តនោ និព្វិទាញាណានេវ ហោន្តីតិ តានិបិ និព្វិទាញាណេហិ សង្គហេត្វា និព្វិទាបដិប្បស្សទ្ធិញាណានីតិ និព្វិទាតហាណាមេវ កតំ, ន និព្វិទានុលោមគ្គហណំ។

*សូម្បី**និព្វិទានុលោមញាណ** ដោយអត្ថថា ជា**និព្វិទាញាណ**ដូចគ្នា ព្រោះដូច្នោះ លោកទើបសង្គ្រោះ សូម្បី **និព្វិទានុលោមញាណ**ទាំងនោះ ដោយ**និព្វិទាញាណ** ហើយធ្វើសព្ទថា **និព្វិទា**នោះឯងថា **និព្វិទាបដិប្បស្សទ្ធិញាណ**, មិនបានធ្វើសព្ទថា **និព្វិទានុលោម** ។*

តីសុបិ ចេតេសុ ញាណដ្ឋកនិទ្ទេសេសុ ចតុត្ថស្ស ធម្មានុបស្សនាចតុក្កស្ស វសេន វុត្តានំ ចតុន្នំ វត្ថូនំ ឯកេកស្មឹ អសុភសវសេន ឯកំ, បសុភសវសេន ឯកន្តិ ទ្វេ ទ្វេ ញាណានីតិ ចតូសុ វត្ថូសុ អដ្ឋ ញាណានិ ហោន្តិ។

ញាណទាំងឡាយមាន ៨ ក្នុងវត្ថុ ៤ គឺញាណមួយយ៉ាងៗមាន ២ គឺ ញាណមួយយ៉ាងដោយអំណាចខ្សល់ដង្ហើមចូល, ជាមួយញាណមួយយ៉ាងទៀត ដោយអំណាចខ្សល់ដង្ហើមចេញ ក្នុងវត្ថុតែមួយយ៉ាងៗ បណ្តាវត្ថុទាំង ៤ ដែលលោកពោលទុក ដោយអំណាចក្រុម ៤ នៃធម្មានុបស្សនា ត្រង់ចំណុចទី ៤ ក្នុងនិទ្ទេសពួក ៨ នៃញាណទាំង ៣ នេះ ។

វិមុត្តិសុខញាណនិទ្ទេសេ "**បហីនត្តា**"តិ បហានំ ឧស្សេត្វា តស្ស បហានស្ស សមុច្ឆេទប្បហានត្តំ ឧស្សេត្តោ "**សមុច្ឆិន្នត្តា**"តិ អាហ។

*នឹងវិនិច្ឆ័យក្នុងនិទ្ទេសវិមុត្តិសុខញាណ ដូចតទៅ ពាក្យថា "**ព្រោះលះ**"*

*លោកសម្តែងនូវការលះហើយ សម្តែងការៈនៃការលះនោះជាសមុច្ឆេទប្បហាន ពោលថា "**ព្រោះបានកាត់ផ្តាច់**" ។*

"វិមុត្តិសុខេ ញាណ"ន្តិ ផលវិមុត្តិសុខសម្បយុត្តញាណញ្ច ផលវិមុត្តិសុខារម្មណបច្ចវេក្ខណាញាណញ្ច។

*ពាក្យថា "**ញាណក្នុងវិមុត្តិសុខ**" បានដល់ ញាណដែលសម្បយុត្តដោយសុខក្នុងផលវិមុត្តិ និងបច្ចវេក្ខណាញាណ ដែលមានសុខក្នុងផលវិមុត្តិជាអារម្មណ៍ ។*

អនុសយវត្ថុស្ស កិលេសស្ស បហានេន បរិយុដ្ឋានទុច្ចរិតវត្ថុប្បហានំ ហោតីតិ ឧស្សន្នត្តំ បុន អនុសយានំ បហានំ វុត្តំ។

លោកពោលការលះអនុស័យទៀត ដើម្បីនឹងសម្តែងថា ការលះវត្ថុនៃបរិយុដ្ឋានទុច្ចរិត រមែងមាន ដោយការលះកិលេស ដែលមានអនុស័យជាទីតាំង ។

ឯការីសតិផលញាណំ សន្ធាយ បហីនកិលេសគណនាយបិ ញាណគណនា កតា ហោតិ, បច្ចវេក្ខណាញាណញ្ច សន្ធាយ បហីនកិលេសបច្ចវេក្ខណគណនាយ ផលបច្ចវេក្ខណាញាណគណនា កតា ហោតីតិ។

*លោកសំដៅយកផលញាណទាំង ២១ យ៉ាង ទើបបានធ្វើការរាប់នូវញាណទាំងឡាយ សូម្បីដោយការរាប់កិលេសដែលបានលះហើយ, និងសំដៅយក **បច្ចវេក្ខណាញាណ** ទើបបានធ្វើការរាប់ញាណ ដែលពិចារណាផល ដោយការរាប់ពិចារណាកិលេសដែលលះបានហើយ យ៉ាងនេះឯង ។*

ញាណភាសិតត្ថនិទ្ទេសវណ្ណនា និដ្ឋិតា។

ការពណ៌នាភាសីតត្ថនិទ្ទេស ចប់

សទ្ធម្មប្បកាសិនិយា បដិសម្ភិទាមគ្គដ្ឋកថាយ

អានាបានស្សតិកថាវណ្ណនា និដ្ឋិតា។

ការពណ៌នានូវអានាបានស្សតិកថា ក្នុងសទ្ធម្មប្បកាសិនី

អដ្ឋកថា បដិសម្ភិទាមគ្គ ចប់ ។

ឥមម្បិ ពុទ្ធេ រតនំ បណីតំ

ឥមម្បិ ធម្មេ រតនំ បណីតំ

ឥមម្បិ សង្ឃេ រតនំ បណីតំ

កែវគឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ

ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់យើងខ្ញុំ និងសព្វសត្វទាំងឡាយ ។

ថ្ងៃសៅរ៍ ៨កោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៤

ភិក្ខុ ឋានវរោ សួស ប៊ុនថន

ឯកសារយោង

១. បាលីឆដ្ឋសង្គាយនា លើកទី ៦ ។

២. ព្រះត្រៃបិដកបាលី និងប្រែជាភាសាខ្មែរ ភាគទី ១៧,២៦, ៧០ ។

៣. អដ្ឋកថា សទ្ធម្មបកាសិនី បាលី ប្រែ ។

៤. គម្ពីរវិសុទ្ធិមគ្គ បាលី ប្រែ ។

៥. គម្ពីរបរមត្ថមញ្ជុសា វិសុទ្ធិមគ្គមហាដីកា បាលី ប្រែ ។

៦. បទានុក្រមបាលី ប្រែភាសាខ្មែរ ។

៧. វចនានុក្រមខ្មែរ សម្តេច ជោតញ្ញាណោ ជួន ណាត ។

អានាបានស្សតិ យស្ស, បរិបុណ្ណា សុភាវិតា;
អនុបុព្ពំ បរិចិតា, យថា ពុទ្ធេន ទេសិតា;
សោ ឥមំ លោកំ បភាសេតិ, អព្ភា មុត្តោវ ចន្ទិមាតិ ។

ព្រះយោគីភិក្ខុណា ចម្រើនអានាបានស្សតិបានល្អប្រពៃហើយ អប់រំសន្សំហើយ ទៅតាមលំដាប់ ឲ្យបរិបូរណ៍តាមដែលព្រះពុទ្ធអង្គទ្រង់បានសម្តែងទុកមកហើយ បុគ្គលនោះរមែងញ្ចុំងលោកនេះឲ្យភ្លឺច្បាស់ ដូចជាព្រះចន្ទរះដែលផុតស្រឡះចាក ពីពពក ។

"យថា ថម្តេ និពន្ធេយ្យ, វច្ឆំ ទមំ នរោ ឥធ;
ពន្ធេយ្យេវំ សកំ ចិត្តំ, សតិយារម្មណេ ទឡ្ហ"ន្តិ ។

"នរៈជន ក្នុងលោកនេះ កាលនឹងបង្ហាត់នូវកូនគោ គប្បីចង(កូនគោ)ទុកត្រង់ សសរ យ៉ាងណាមិញ ព្រះយោគាវចរក្នុងព្រះសាសនានេះ គប្បីចងនូវចិត្តរបស់ ខ្លួន ឲ្យបានមាំក្នុងអារម្មណ៍ ដោយសតិ ក៏យ៉ាងដូច្នោះដែរ" ។

"យថាបិ ទីបិកោ នាម, និលីយិត្វា គណ្ហាតេ មិគេ;
តថេវាយំ ពុទ្ធបុត្តោ, យុត្តយោគោ វិបស្សកោ;
អរញ្ញំ បវិសិត្វាន, គណ្ហាតិ ផលមុត្តម"ន្តិ ។

"ធម្មតាខ្លាដំបង ពួនសម្ងំហើយ រមែងចាំចាប់យកនូវម្រឹគទាំងឡាយ យ៉ាងណាមិញ, ភិក្ខុនេះ ជាបុត្ត្ររបស់ព្រះពុទ្ធ ជាអ្នកមានសេចក្តីព្យាយាមប្រកបហើយ ជាអ្នក ចម្រើនវិបស្សនា ចូលទៅកាន់ព្រៃហើយ តែងចាំចាប់យកនូវផលដ៏ឧត្តម ក៏យ៉ាង ដូច្នោះដែរ" ។

"និមិត្តេ ឋបយំ ចិត្តំ, នានាការំ វិភាវយំ;
ធីរោ អស្សាសបស្សាសេ, សកំ ចិត្តំ និពន្ធតី"តិ ។

"អ្នកមានប្រាជ្ញា កាលតម្កល់នូវចិត្ត ទុកក្នុងនិមិត្ត ញ្ចុំងអាការៈផ្សេងៗ ឲ្យវិនាសទៅ រមែងចងក្រៀកទុកនូវចិត្តរបស់ខ្លួន ជាមួយខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ" ។